

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ  ទសកនិបាត
# ឯកាទសមភាគ
# ៥០



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

# AṄGUTTARANIKĀYA

# DASAKANIPĀTA

# EKĀDASAMABHĀGA

# 50

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្ខឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ទសកនិបាត

## ឯកាទសមកភាគ

៤០

ព. ស. ២៤៩៩

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ទសកនិបាតោ

# ឯកាទសមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកោ

## បឋមោ អានិសំសវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កិមត្ថិយានិ ភន្តេ កុសលានិ សីលានិ កិមានិសំសានីតិ ។ អវិប្បដិសារត្ថានិ ខោ អានន្ទ កុសលានិ សីលានិ អវិប្បដិសារានិសំសានីតិ ។ អវិប្បដិសារោ បន ភន្តេ កិមត្ថិយោ

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ទសកនិបាត

# ឯកាទសមភាគ

---

*សូមនមស្ការចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## បឋមបណ្ណាសក

## អានិសំសវគ្គទី ១

[១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកសីល ជាកុសល មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ ពួកសីល ជាកុសល មានអវិប្បដិសារៈ (សេចក្តីមិនក្តៅក្រហាយ) ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះអវិប្បដិសារៈ មានអ្វី ជាប្រយោជន៍*

កិមានិសំសោតិ ។ អវិប្បដិសារោ ខោ អានន្ទ ចាមុជ្ជត្ថោ ចាមុជ្ជានិសំសោតិ ។ ចាមុជ្ជំ បន ភន្តេ កិមត្ថិយំ កិមានិសំសន្តិ ។ ចាមុជ្ជំ ខោ អានន្ទ បីតត្ថំ បីតានិសំសន្តិ ។ បីតិ បន ភន្តេ កិមត្ថិយា កិមានិសំសាតិ ។ បីតិ ខោ អានន្ទ បស្សទ្ធត្ថា បស្សទ្ធានិសំសាតិ ។ បស្សទ្ធិ បន ភន្តេ កិមត្ថិយា កិមានិសំសាតិ ។ បស្សទ្ធិ ខោ អានន្ទ សុខត្ថា សុខានិសំសាតិ ។ សុខំ បន ភន្តេ កិមត្ថិយំ កិមានិសំសន្តិ ។ សុខំ ខោ អានន្ទ សមាធត្ថំ សមាធានិសំសន្តិ ។ សមាធិ បន ភន្តេ កិមត្ថិយោ កិមានិសំសោតិ ។ សមាធិ ខោ អានន្ទ យថាភូតញ្ញាណទស្សនត្ថោ យថាភូតញ្ញាណទស្សនានិសំសោតិ ។ យថាភូតញ្ញា-ណទស្សនំ បន ភន្តេ កិមត្ថិយំ កិមានិសំសន្តិ ។

មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ អវិប្បដិសារៈ មានបាមុជ្ជៈ (សេចក្តីរីករាយ) ជាប្រយោជន៍ មានបាមុជ្ជៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបាមុជ្ជៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បាមុជ្ជៈមានបីតិ (សេចក្តីឆ្អែតចិត្ត) ជាប្រយោជន៍ មានបីតិជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបីតិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បីតិ មានបស្សទ្ធិ (សេចក្តីស្ងប់) ជាប្រយោជន៍ មានបស្សទ្ធិ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបស្សទ្ធិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ បស្សទ្ធិ មានសុខៈជាប្រយោជន៍ មានសុខៈជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសុខៈ មានអ្វី ជាប្រយោជន៍ មានអ្វី ជាអានិសង្ស ។ ម្នាលអានន្ទ សុខៈ មានសមាធិ ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសមាធិ មានអ្វី ជាប្រយោជន៍ មានអ្វី ជាអានិសង្ស ។ ម្នាលអានន្ទ សមាធិ មានយថាភូតញ្ញាណទស្សនៈ (វិបស្សនាញាណទន់ខ្ចី) ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះយថាភូតញ្ញាណទស្សនៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស ។

៣

បឋមបណ្ណាសកេ អានិសំសវគ្គោ

យថាភូតញ្ញាណទស្សនំ ខោ អានន្ទ និព្ពិទា-
វិរាគត្ថំ និព្ពិទាវិរាគានិសំសន្តិ ។ និព្ពិទាវិរាគោ
បន ភន្តេ កិមត្ថិយោ កិមានិសំសោតិ ។ និព្ពិ-
ទាវិរាគោ ខោ អានន្ទ វិមុត្តិញ្ញាណទស្សនត្ថោ
វិមុត្តិញ្ញាណទស្សនានិសំសោតិ ។ ឥតិ ខោ អានន្ទ
កុសលានិ សីលានិ អវិប្បដិសារត្ថានិ អវិប្បដិសារា-
និសំសានិ អវិប្បដិសារោ បាមុជ្ជត្ថោ បាមុជ្ជានិសំ-
សោ បាមុជ្ជំ បីតត្ថំ បីតានិសំសំ បីតិ បស្សទ្ធត្ថា
បស្សទ្ធានិសំសា បស្សទ្ធិ សុខត្ថា សុខានិសំសា
សុខំ សមាធត្ថំ សមាធានិសំសំ សមាធិ យថា-
ភូតញ្ញាណទស្សនត្ថោ យថាភូតញ្ញាណទស្សនានិ-
សំសោ យថាភូតញ្ញាណទស្សនំ និព្ពិទាវិរាគត្ថំ
និព្ពិទាវិរាគានិសំសំ និព្ពិទាវិរាគោ វិមុត្តិញ្ញា-
ណទស្សនត្ថោ វិមុត្តិញ្ញាណទស្សនានិសំសោ ។

ម្នាលអានន្ទ យថាភូតញ្ញាណទស្សនៈ មាននិព្វិទានិងវិរាគៈ (វិបស្ស-នាញាណដ៏មានកម្លាំងនិងមគ្គ) ជាប្រយោជន៍ មាននិព្វិទានិងវិរាគៈ ជាអានិសង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះនិព្វិទានិងវិរាគៈ មានអ្វីជា ប្រយោជន៍ មានអ្វីជាអានិសង្ស ។ ម្នាលអានន្ទ និព្វិទានិងវិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ (អរហត្តផលនិងបច្ចវេក្ខណញ្ញាណ) ជា ប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស ។ ម្នាលអានន្ទ ពួកសីល ជាកុសល មានអវិប្បដិសារៈ ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជៈ ជាប្រយោជន៍ មានបាមុជ្ជៈ ជាអានិសង្ស បាមុជ្ជៈ មានបីតិ ជាប្រយោជន៍ មានបីតិ ជាអានិសង្ស បីតិ មានបស្សទ្ធិ ជាប្រយោជន៍ មានបស្សទ្ធិ ជាអានិសង្ស បស្សទ្ធិ មានសុខៈ ជាប្រយោជន៍ មានសុខៈ ជាអានិសង្ស សុខៈមានសមាធិ ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស សមាធិ មានយថាភូតញ្ញាណ-ទស្សនៈជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈជាអានិសង្ស យថាភូ-តញ្ញាណទស្សនៈ មាននិព្វិទានិងវិរាគៈ ជាប្រយោជន៍ មាននិព្វិទា និងវិរាគៈ ជាអានិសង្ស និព្វិទានិងវិរាគៈមានវិមុត្តិញ្ញាណទស្សនៈ ជាប្រ-យោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស ដោយប្រការដូច្នេះឯង ។

ឥតិ ខោ អានន្ទ កុសលានិ សីលានិ អនុបុព្វេន អរហត្តាយ ប្ញូរេន្តីតិ[១] ។

[២] សីលវតោ ភិក្ខវេ សីលសម្បន្នស្ស ន ចេតនាយ ករណីយំ អវិប្បដិសារោ មេ ឧប្បជ្ជតូ-តិ ។ ធម្មតា ឯសា ភិក្ខវេ យំ សីលវតោ សីលសម្បន្នស្ស អវិប្បដិសារោ ឧប្បជ្ជតិ អវិប្បដិសា-រិស្ស ភិក្ខវេ ន ចេតនាយ ករណីយំ បាមុជ្ជំ មេ ឧប្បជ្ជតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ អវិប្បដិ-សារិស្ស បាមុជ្ជំ ឧប្បជ្ជតិ បមុទិតស្ស ភិក្ខវេ ន ចេតនាយ ករណីយំ បីតិ មេ ឧប្បជ្ជតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ បមុទិតស្ស បីតិ ឧប្បជ្ជតិ បីតិមនស្ស ភិក្ខវេ ន ចេតនាយ ករណីយំ កាយោ មេ បស្សម្ភតូតិ ។

១ ឱ. ម. អគ្គាយ បូរេន្តីតិ ។

ម្នាលអានន្ទ ពួកសីល ជាកុសល រមែងញុំាងធម៌ទាំងនោះឲ្យពេញ តាមលំដាប់ ដើម្បីព្រះអរហត្តដោយប្រការដូច្នេះ ។

[២] ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសីល បរិបូណ៌ ដោយសីលហើយ មិនបាច់ធ្វើដោយចេតនាថា អវិប្បដិសារៈ ចូរ កើតឡើងដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ កើតឡើងដល់បុគ្គលមានសីល អ្នកបរិបូណ៌ដោយសីល ដោយហេតុ ណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើ បុគ្គលមិនមានវិប្បដិសារៈហើយ មិនបាច់ធ្វើដោយចេតនាថា បាមុជ្ជៈ ចូរកើតឡើងដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ បាមុជ្ជៈ កើតឡើងដល់បុគ្គលមិនមានវិប្បដិសារៈ ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានបាមុជ្ជៈ ហើយ មិនបាច់ធ្វើដោយចេតនាថា បីតិ ចូរកើតឡើងដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ បីតិ កើតឡើង ដល់បុគ្គលអ្នកមានបាមុជ្ជៈ ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាល ភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តប្រកបដោយបីតិហើយ មិន បាច់ធ្វើដោយចេតនាថា កាយរបស់អាត្មាអញ ចូរស្ងប់រម្ងាប់ ។

ធម្មតា ឯសា ភិក្ខវេ យំ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយស្ស ភិក្ខវេ ន ចេតនាយ ករណីយំ សុខំ វេទិយាមីតិ[១] ។ ធម្មតា ឯសា ភិក្ខវេ យំ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ភិក្ខវេ ន ចេតនាយ ករណីយំ ចិត្តំ មេ សមាធិយតូតិ ។ ធម្មតា ឯសា ភិក្ខវេ យំ សុខិនោ ចិត្តំ សមាធិយតិ សមាហិតស្ស ភិក្ខវេ ន ចេតនាយ ករណីយំ យថាភូតំ ជានាមិ បស្សាមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ សមា-ហិតោ យថាភូតំ ជានាតិ បស្សតិ យថាភូតំ ភិក្ខវេ ជានតោ បស្សតោ ន ចេតនាយ ករណីយំ និព្វិន្ទាមិ វិរជ្ជាមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ យថាភូតំ ជានំ បស្សំ និព្វិន្ទតិ វិរជ្ជតិ និព្វិន្នស្ស

១ ម. វេទិស្សាមីតិ ។

ម្នាលភិក្ខុទាំងឡាយ កាយស្ងប់រម្ងាប់ដល់បុគ្គលមានចិត្តប្រកបដោយបីតិ ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានកាយស្ងប់រម្ងាប់ហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញនឹងសោយសុខៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានកាយស្ងប់រម្ងាប់សោយសុខៈ ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសុខៈហើយ មិនបាច់ធ្វើដោយចេតនាថា ចិត្តរបស់អាត្មាអញ ចូរនឹងធឹង ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់បុគ្គលមានសុខៈ នឹងធឹងដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តនឹងធឹងហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញនឹងដឹង នឹងឃើញតាមពិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តនឹងធឹង ដឹង ឃើញ តាមពិត ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ម្នាលភិក្ខុទាំងឡាយ កាលបើ បុគ្គលដឹង ឃើញ តាមពិតហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញ នឹងធុញទ្រាន់ នឿយណាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញតាមពិត ធុញទ្រាន់ នឿយណាយ ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា

ភិក្ខវេ វិរត្តស្ស ន ចេតនាយ ករណីយំ វិមុត្តិញ្ញាណទស្សនំ សច្ឆិករោមីតិ ។ ធម្មតា ឯសា ភិក្ខវេ យំ និព្វិន្នោ វិរត្តោ វិមុត្តិញ្ញាណទស្សនំ សច្ឆិករោតិ ។ ឥតិ ខោ ភិក្ខវេ និព្វិទាវិរាគោ វិមុត្តិញ្ញាណទស្សនត្ថោ វិមុត្តិញ្ញាណទស្សនានិសំសោ យថាភូតញ្ញាណទស្សនំ និព្វិទាវិរាគត្ថំ និព្វិទាវិរាគានិសំសំ សមាធិ យថាភូតញ្ញាណទស្សនត្ថោ យថាភូតញ្ញាណទស្សនានិសំសោ សុខំ សមាធត្ថំ សមាធានិសំសំ បស្សទ្ធិ សុខត្ថា សុខានិសំសា បីតិ បស្សទ្ធត្ថា បស្សទ្ធានិសំសា បាមុជ្ជំ បីតត្ថំ បីតានិសំសំ អវិប្បដិសារោ បាមុជ្ជត្ថោ បាមុជ្ជានិសំសោ កុសលានិ សីលានិ អវិប្បដិសារត្ថានិ អវិប្បដិសារានិសំសានិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើ បុគ្គលធុញទ្រាន់ នឿយណាយហើយ មិនបាច់ធ្វើដោយចេតនាថា អាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលធុញទ្រាន់ នឿយណាយ ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិញ្ញាណទស្សនៈ ដោយហេតុណា ហេតុនុ៎ះ រមែងមានជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ និព្វិទានិងវិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ ជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស យថាភូតញ្ញាណទស្សនៈ មាននិព្វិទានិងវិរាគៈ ជាប្រយោជន៍ មាននិព្វិទានិងវិរាគៈ ជាអានិសង្ស សមាធិមានយថាភូតញ្ញាណទស្សនៈ ជាប្រយោជន៍ មានយថាភូតញ្ញាណទស្សនៈ ជាអានិសង្ស សុខៈ មានសមាធិ ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស បស្សទ្ធិ មានសុខៈ ជាប្រយោជន៍ មានសុខៈ ជាអានិសង្ស បីតិ មានបស្សទ្ធិ ជាប្រយោជន៍ មានបស្សទ្ធិ ជាអានិសង្ស បាមុជ្ជៈ មានបីតិ ជាប្រយោជន៍ មានបីតិ ជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជៈ ជាប្រយោជន៍ មានបាមុជ្ជៈ ជាអានិសង្ស ពួកសីល ជាកុសល មានអវិប្បដិសារៈ ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស ដោយប្រការដូច្នេះ ។

ឥតិ ខោ ភិក្ខវេ ធម្មា ធម្មេ អភិ-សន្ទេន្តិ ធម្មា ធម្មេ បរិបូរេន្តិ អបារា បារំ គមនាយាតិ ។

[៣] ទុស្សីលស្ស ភិក្ខវេ សីលវិបន្នស្ស ហតូ-បនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ បាមុជ្ជេ អសតិ បាមុជ្ជវិបន្នស្ស ហតូបនិសា ហោតិ បីតិ បីតិយា អសតិ បីតិវិបន្នស្ស ហតូបនិសា ហោតិ បស្សទ្ធិ បស្សទ្ធិយា អសតិ បស្សទ្ធិវិបន្នស្ស ហតូបនិសំ ហោតិ សុខំ សុខេ អសតិ សុខវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ តែងហូរទៅកាន់ធម៌ទាំងឡាយ ធម៌ទាំងឡាយ តែងញ៉ាំងធម៌ទាំងឡាយឲ្យពេញ ដើម្បីចេញចាកទីមិនមែនជាត្រើយ គឺវដ្ដៈប្រកបដោយភូមិ ៣ ហើយទៅកាន់ត្រើយ គឺព្រះនិព្វាន ដោយប្រការដូច្នេះឯង ។

[៣] ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជៈរបស់បុគ្គលវិបត្តិ ចាកអវិប្បដិសារៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើបាមុជ្ជៈ មិនមានហើយ បីតិរបស់បុគ្គលវិបត្តិចាកបាមុជ្ជៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើបីតិមិនមានហើយ បស្សទ្ធិរបស់បុគ្គលវិបត្តិចាកបីតិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើបស្សទ្ធិមិនមានហើយ សុខៈរបស់បុគ្គលវិបត្តិចាកបស្សទ្ធិ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើសុខៈមិនមានហើយ សម្មាសមាធិ របស់បុគ្គលវិបត្តិចាកសុខៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើសម្មាសមាធិ មិនមានហើយ

អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគ-វិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បប្បដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ទុស្សី-លស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិ-សារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ ។ បេ ។ វិមុត្តិញាណ-ទស្សនំ ។ សីលវតោ ភិក្ខវេ សីលសម្បន្នស្ស ឧបនិស-សម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ

យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកសម្មាសមាធិ រមែង សាបសូន្យ ចាកឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈ មិន មានហើយ និព្វិទានិងវិរាគៈ របស់បុគ្គល វិបត្តិចាកយថាភូតញ្ញាណ-ទស្សនៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើនិព្វិទានិង វិរាគៈមិនមានហើយ វិមុត្តិញ្ញាណទស្សនៈរបស់បុគ្គល វិបត្តិចាកនិព្វិទា និងវិរាគៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រៀបដូចដើមឈើ ដែលមិនមានមែកនិងស្លឹកហើយ ក្រមរ របស់ឈើនោះក្តី ក៏មិនសូវបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិន សូវបរិបូណ៌ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យ ចាកឧបនិ-ស្ស័យ កាលបើអវិប្បដិសារៈ មិនមានហើយ បាមុជ្ជៈរបស់បុគ្គលវិបត្តិ ចាកអវិប្បដិសារៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ ដោយសីល រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើមានអវិប្បដិសារៈហើយ

៩

## បឋមបណ្ណាសកេ អានិសំសវគ្គោ

អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ បាមុជ្ជំ បាមុជ្ជេ សតិ បាមុជ្ជសម្បន្នស្ស ឧបនិសស-ម្បន្នា ហោតិ បីតិ បីតិយា សតិ បីតិសម្បន្នស្ស ឧប-និសសម្បន្នា ហោតិ បស្សទ្ធិ បស្សទ្ធិយា សតិ បស្សទ្ធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ សុខំ សុខេ សតិ សុខសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មា-សមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ សតិ យថាភូតញាណ-ទស្សនសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ និព្វិទា-វិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បប្បដិកាបិ បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ

បាមុជ្ជៈរបស់បុគ្គលបរិបូណ៌ ដោយអវិប្បដិសារៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើបាមុជ្ជៈ មានហើយ បីតិរបស់បុគ្គល បរិបូណ៌ ដោយបាមុជ្ជៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើ បីតិ មានហើយ បស្សទ្ធិរបស់បុគ្គលបរិបូណ៌ ដោយបីតិ រមែង បរិបូណ៌ ដោយឧបនិស្ស័យ កាលបើបស្សទ្ធិ មានហើយ សុខៈរបស់ បុគ្គលបរិបូណ៌ ដោយបស្សទ្ធិ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាល បើសុខៈ មានហើយ សម្មាសមាធិរបស់បុគ្គលបរិបូណ៌ ដោយសុខៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើសម្មាសមាធិ មានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ ដោយសម្មាសមាធិ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈ មានហើយ និព្វិទានិងវិរាគៈរបស់បុគ្គលបរិបូណ៌ ដោយយថាភូត-ញ្ញាណទស្សនៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើនិព្វិទានិង វិរាគៈមានហើយ វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ ដោយ និព្វិទានិងវិរាគៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ ។ ម្នាលភិក្ខុ ទាំងឡាយ ប្រៀបដូចដើមឈើដែលបរិបូណ៌ ដោយមែកនិងស្លឹក ហើយ ក្រមររបស់ឈើនោះក្តី ក៏រមែងបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏រមែងបរិបូណ៌ យ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ សីលវតោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ បាមុជ្ជំ ។ បេ ។ វិមុត្តិញ្ញាណទស្សនន្តិ ។

[៤] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ទុស្សីលស្ស អាវុសោ សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ បាមុជ្ជេ អសតិ បាមុជ្ជវិបន្នស្ស ហតូបនិសា ហោតិ បីតិ បីតិយា អសតិ បីតិវិបន្នស្ស ហតូបនិសា ហោតិ បស្សទ្ធិ បស្សទ្ធិយា អសតិ បស្សទ្ធិវិបន្នស្ស ហតូបនិសំ ហោតិ សុខំ សុខេ អសតិ

ម្នាលភិក្ខុទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ ដោយសីល រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈ មានហើយ បាមុជ្ជៈរបស់បុគ្គលបរិបូណ៌ ដោយអវិប្បដិសារៈ រមែង បរិបូណ៌ ដោយឧបនិស្ស័យ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ ក៏ យ៉ាងនោះដែរ ។

[៤] ក្នុងទីនោះឯង ព្រះសារីបុត្រដ៏មានអាយុ មានថេរវាចា នឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គល ទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យ ចាកឧបនិស្ស័យ កាល បើអវិប្បដិសារៈមិនមានហើយ បាមុជ្ជៈរបស់បុគ្គលវិបត្តិ ចាកអវិប្បដិ-សារៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើបាមុជ្ជៈ មិន មានហើយ បីតិ របស់បុគ្គលវិបត្តិ ចាកបាមុជ្ជៈ រមែង សាបសូន្យ ចាកឧបនិស្ស័យ កាលបើបីតិ មិនមានហើយ បស្សទ្ធិរបស់បុគ្គលវិបត្តិ ចាកបីតិ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើបស្សទ្ធិ មិនមានហើយ សុខៈរបស់បុគ្គលវិបត្តិ ចាកបស្សទ្ធិ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើសុខៈ មិនមានហើយ

១១



សុខវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូប-និសំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណ-ទស្សនេ អសតិ យថាភូតញ្ញាណទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញ្ញាណទ-ស្សនំ ។ សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាស-វិបន្នោ តស្ស បប្បដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ ទុស្សីលស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ ។ បេ ។ វិមុត្តិញ្ញាណទស្សនំ ។

សម្មាសមាធិរបស់បុគ្គលវិបត្តិ ចាកសុខៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើសម្មាសមាធិ មិនមានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិ ចាកសម្មាសមាធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ និព្វិទានិងវិរាគៈរបស់បុគ្គលវិបត្តិ ចាកយថាភូតញ្ញាណទស្សនៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើនិព្វិទានិងវិរាគៈ មិនមានហើយ វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិ ចាកនិព្វិទានិងវិរាគៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើដែលវិបត្តិ ចាកមែកនិងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនសូវបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈមិនមានហើយ បាមុជ្ជៈរបស់បុគ្គលវិបត្តិ ចាកអវិប្បដិសារៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

សីលវតោ អាវុសោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ បាមុជ្ជំ បាមុជ្ជេ សតិ បាមុជ្ជសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បីតិ បីតិយា សតិ បីតិសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បស្សទ្ធិ បស្សទ្ធិយា សតិ បស្សទ្ធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ សុខំ សុខេ សតិ សុខសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនេ សតិ យថាភូតញ្ញាណ-ទស្សនសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ និព្វិ-ទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។

ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលមានសីល បរិបូណ៌ ដោយសីលហើយ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើអវិប្បដិ-សារៈ មានហើយ បាមុជ្ជៈរបស់បុគ្គលបរិបូណ៌ ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបាមុជ្ជៈមានហើយ បីតិរបស់បុគ្គលបរិបូណ៌ដោយបាមុជ្ជៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបីតិមានហើយ បស្សទ្ធិរបស់បុគ្គលបរិបូណ៌ ដោយបីតិ រមែងបរិបូណ៌ដោយឧប-និស្ស័យ កាលបើបស្សទ្ធិមានហើយ សុខៈរបស់បុគ្គលបរិបូណ៌ដោយបស្សទ្ធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសុខៈមានហើយ សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសុខៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិ មានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមានហើយ និព្វិទានិងវិរាគៈរបស់បុគ្គលបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើនិព្វិទានិងវិរាគៈមានហើយ វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ដោយនិព្វិទានិងវិរាគៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ ។

សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បប្បដិកាបិ ចារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ចារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ សីលវតោ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ សតិ អវិប្បដិសារសម្ប-ន្នស្ស ឧបនិសសម្បន្នំ ហោតិ បាមុជ្ជំ ។ បេ ។ វិមុត្តិញ្ញាណទស្សនន្តិ ។

[៤] តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ អាមន្តេសិ ទុស្សីលស្ស អាវុសោ សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិសារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ បាមុជ្ជេ អសតិ បាមុជ្ជវិបន្នស្ស ហតូបនិសា ហោតិ បីតិ បីតិយា អសតិ បីតិវិបន្នស្ស ហតូបនិសា ហោតិ បស្សទ្ធិ បស្សទ្ធិយា អសតិ

ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយមែក និងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏បរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏បរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្ប-ដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈមានហើយ បាមុជ្ជៈរបស់បុគ្គល បរិបូណ៌ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

[៥] ក្នុងទីនោះឯង ព្រះអានន្ទដ៏មានអាយុ មានថេរវាចានឹង ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គល ទ្រុស្តសីល វិបត្តិចាកសីល រមែងសាបសូន្យចាកឧបនិស្ស័យ កាល បើអវិប្បដិសារៈមិនមានហើយ បាមុជ្ជៈរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើបាមុជ្ជៈ មិនមានហើយ បីតិរបស់បុគ្គលវិបត្តិ ចាកបាមុជ្ជៈ រមែងសាបសូន្យ ចាកឧប-និស្ស័យ កាលបើបីតិ មិនមានហើយ បស្សទ្ធិរបស់បុគ្គលវិបត្តិ ចាកបីតិ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើបស្សទ្ធិ មិនមានហើយ

បស្សទ្ធិវិបន្នស្ស ហតូបនិសំ ហោតិ សុខំ សុខេ អសតិ សុខវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនេ អសតិ យថាភូតញ្ញាណ-ទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្ពិទាវិរាគោ និព្ពិទាវិរាគេ អសតិ និព្ពិទាវិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។ សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលាសវិបន្នោ តស្ស បប្បដិកាបិ ន ចារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន ចារិបូរឹ គច្ឆតិ ឯវមេវ ខោ អាវុសោ ទុស្សីលស្ស សីលវិបន្នស្ស ហតូបនិសោ ហោតិ អវិប្បដិសារោ អវិប្បដិសារេ អសតិ អវិប្បដិ-សារវិបន្នស្ស ហតូបនិសំ ហោតិ បាមុជ្ជំ ។ បេ ។

សុខៈរបស់បុគ្គលវិបត្តិចាកបស្សទ្ធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើសុខៈមិនមានហើយ សម្មាសមាធិ របស់បុគ្គលវិបត្តិចាកសុខៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ កាលបើសម្មាសមាធិ មិនមានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកសម្មាសមាធិ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈ មិនមានហើយ និព្វិទានិង្វិរាគៈរបស់បុគ្គលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើនិព្វិទានិង្វិរាគៈមិនមានហើយ វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិ ចាកនិព្វិទានិង្វិរាគៈ រមែងសាបសូន្យចាកឧបនិស្ស័យ ។ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចដើមឈើ ដែលវិបត្តិ ចាកមែកនិងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏មិនសូវបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ អវិប្បដិសារៈរបស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ រមែងសាបសូន្យចាកឧបនិស្ស័យ កាលបើអវិប្បដិសារៈ មិនមានហើយ បាមុជ្ជៈរបស់បុគ្គលវិបត្តិចាកអវិប្បដិសារៈ រមែងសាបសូន្យ ចាកឧបនិស្ស័យ ។ បេ ។

វិមុត្តិញ្ញាណទស្សនំ ។ សីលវតោ អាវុសោ សីល-
សម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ
អវិប្បដិសារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិស-
សម្បន្នំ ហោតិ បាមុជ្ជំ បាមុជ្ជេ សតិ បាមុជ្ជសម្ប-
ន្នស្ស ឧបនិសសម្បន្នា ហោតិ បីតិ បីតិយា សតិ
បីតិសម្បន្នស្ស ឧបនិសសម្បន្នា ហោតិ បស្សទ្ធិ
បស្សទ្ធិយា សតិ បស្សទ្ធិសម្បន្នស្ស ឧបនិសសម្បន្នំ
ហោតិ សុខំ សុខេ សតិ សុខសម្បន្នស្ស ឧបនិស-
សម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ
សតិ សម្មាសមាធិសម្បន្នស្ស ឧបនិសសម្បន្នំ
ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណ-
ទស្សនេ សតិ យថាភូតញ្ញាណទស្សនសម្បន្នស្ស
ឧបនិសសម្បន្នោ ហោតិ និព្វិទាវិរាគោ
និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស
ឧបនិសសម្បន្នំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។

វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ ទាំងឡាយ អវិប្បដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈមានហើយ បាមុជ្ជៈ របស់បុគ្គលបរិបូណ៌ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបាមុជ្ជៈមានហើយ បីតិរបស់បុគ្គលបរិបូណ៌ដោយបាមុជ្ជៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើ បីតិ មានហើយ បស្សទ្ធិរបស់បុគ្គលបរិបូណ៌ដោយបីតិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើបស្សទ្ធិមានហើយ សុខៈរបស់បុគ្គលបរិបូណ៌ដោយបស្សទ្ធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសុខៈ មានហើយ សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសុខៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើសម្មាសមាធិមានហើយ យថាភូតញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ ដោយសម្មាសមាធិ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើយថាភូតញ្ញាណទស្សនៈមានហើយ និព្វិទានិងវិរាគៈ របស់បុគ្គលបរិបូណ៌ ដោយយថាភូតញ្ញាណទស្សនៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ កាលបើនិព្វិទានិងវិរាគៈ មានហើយ វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ដោយនិព្វិទានិងវិរាគៈ រមែងបរិបូណ៌ ដោយឧបនិស្ស័យ ។

សេយ្យថាបិ អាវុសោ រុក្ខោ សាខាបលា-
សសម្បន្នោ តស្ស បប្បដិកាបិ ចារិបូរឹ គច្ឆតិ
តចោបិ ផេគ្គុបិ សារោបិ ចារិបូរឹ គច្ឆតិ
ឯវមេវ ខោ អាវុសោ សីលវតោ សីលសម្បន្នស្ស
ឧបនិសសម្បន្នោ ហោតិ អវិប្បដិសារោ អវិប្បដិ-
សារេ សតិ អវិប្បដិសារសម្បន្នស្ស ឧបនិសសម្បន្នំ
ហោតិ ចាមុជ្ជំ ។ បេ ។ វិមុត្តិញាណទស្សនន្តិ ។

[៦] អថខោ អាយស្មា អានន្ទោ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា
ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា
អានន្ទោ ភគវន្តំ ឯតទវោច សិយា នុ ខោ ភន្តេ
ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ
បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ
អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី
អស្ស ន វាយស្មឹ វាយោសញ្ញី

ម្នាលអានន្ទ ដូចដើមឈើដែលបរិបូណ៌ដោយមែកនិងស្លឹកហើយ ក្រមររបស់ឈើនោះក្តី ក៏រមែងបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏រមែងបរិបូណ៌ យ៉ាងណាមិញ ម្នាលអានន្ទ អវិប្បដិសារៈ របស់បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ រមែងបរិបូណ៌ដោយឧបនិស្ស័យ កាលបើអវិប្បដិសារៈ មានហើយ បាមុជ្ជៈរបស់បុគ្គលបរិបូណ៌ ដោយអវិប្បដិសារៈ រមែងបរិបូណ៌ដោយឧបនិស្ស័យ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

[៦] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរឬ ដូចយ៉ាងភិក្ខុ មិនសម្គាល់ថា ដីក្នុងដី មិនសម្គាល់ថាទឹកក្នុងទឹក មិនសម្គាល់ថា ភ្លើងក្នុងភ្លើង មិនសម្គាល់ថាខ្យល់ក្នុងខ្យល់

អស្ស ន អាកាសានញ្ចាយតនេ អាកាសា-
នញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ
វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ច-
ញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន
នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតន-
សញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី
អស្ស ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី
ច បន អស្សាតិ ។ សិយា អានន្ទ ភិក្ខុនោ
តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ
បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន
តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី
អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចា-
យតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញា-
ណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ
អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានា-
សញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស

មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវ-សញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះ ក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា (សេចក្ដីសម្គាល់ជាធម្មតា) ប៉ុណ្ណោះ ។ ម្នាលអានន្ទ ការបាននូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរ ដូចយ៉ាងភិក្ខុមិនសម្គាល់ថា ដី ក្នុងដី មិនសម្គាល់ថា ទឹក ក្នុងទឹក មិនសម្គាល់ថា ភ្លើង ក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ

១៨



ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ យថាកថំ បន ភន្តេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឥធានន្ទ ភិក្ខុ ឯវំ សញ្ញី ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។

មិនសម្គាល់ថា លោកនេះក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខក្នុងលោកខាងមុខទេ គ្រាន់តែមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការបាននូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុ តើដូចម្តេច ដូចយ៉ាងភិក្ខុ មិនសម្គាល់ថា ដី ក្នុងដី មិនសម្គាល់ថា ទឹក ក្នុងទឹក មិនសម្គាល់ថា ភ្លើង ក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញា-យតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះ ក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ម្នាលអានន្ទ ក្នុងធម្មវិន័យនេះ ភិក្ខុជាអ្នកមានសេចក្តីសម្គាល់ យ៉ាងនេះថា នុ៎ះ ជាធម្មជាតស្ងប់ នុ៎ះ ជាធម្មជាតឧត្តម គឺធម៌ ជាគ្រឿងរម្ងាប់ នូវសង្ខារទាំងពួង ជាគ្រឿងរលាស់ចោល នូវកិលេសទាំងពួង ជាគ្រឿងអស់ទៅនៃតណ្ហា ជាគ្រឿងនឿយណាយ ជាទីរលត់ គឺព្រះនិព្វាន ។

បឋមបណ្ណាសកេ   អានិសំសវគ្គោ

ឯវំ ខោ អានន្ទ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

[៧] អថខោ អាយស្មា អានន្ទោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ម្នាលអានន្ទ ការបានន្ទូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុយ៉ាងនេះឯង ដូចយ៉ាងភិក្ខុ មិនសម្គាល់ថា ដី ក្នុងដី មិនសម្គាល់ថាទឹក ក្នុងទឹក មិនសម្គាល់ថា ភ្លើង ក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះ ក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។

[៧] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យ ដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។

ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ ឯតទវោច សិយា នុ ខោ អាវុសោ សារីបុត្ត ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ន អាបស្មឹ អាបោសញ្ញី អស្ស ន តេជស្មឹ តេជោសញ្ញី អស្ស ន វាយស្មឹ វាយោសញ្ញី អស្ស ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អស្ស ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អស្ស ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អស្ស ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អស្ស ន ឥធលោកេ ឥធលោកសញ្ញី អស្ស ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ សិយា អាវុសោ អានន្ទ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។

លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក៏មានថេរវាចា នឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោទាំងឡាយ ការបាន នូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរឬហ្ន៎ ដូចយ៉ាង ភិក្ខុមិនសម្គាល់ថា ដី ក្នុងដី មិនសម្គាល់ថា ទឹក ក្នុងទឹក មិនសម្គាល់ ថា ភ្លើង ក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ច-ញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញា-យតនៈ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនសម្គាល់ថា លោកនេះ ក្នុងលោកនេះ មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ ការបាននូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុដែរ ដូចយ៉ាងភិក្ខុ មិនសម្គាល់ថា ដី ក្នុងដី ។ បេ ។ មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។

យថាកថំ បនាវុសោ សារីបុត្ត សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា នេវ បឋវិយំ បឋវីសញ្ញី អស្ស ។ បេ ។ ន បរលោកេ បរលោកសញ្ញី អស្ស សញ្ញី ច បន អស្សាតិ ។ ឯកមិទាហំ អាវុសោ អានន្ទ សមយំ ឥធេវ សាវត្ថិយំ វិហរាមិ អន្ធវនស្មឹ តត្ថាហំ[១] តថារូបំ សមាធឹ សមាបជ្ជឹ[២] យថា នេវ បឋវិយំ បឋវីសញ្ញី អហោសឹ ន អាបស្មឹ អាបោសញ្ញី អហោសឹ ន តេជស្មឹ តេជោសញ្ញី អហោសឹ ន វាយស្មឹ វាយោសញ្ញី អហោសឹ ន អាកាសានញ្ចាយតនេ អាកាសានញ្ចាយតនសញ្ញី អហោសឹ ន វិញ្ញាណញ្ចាយតនេ វិញ្ញាណញ្ចាយតនសញ្ញី អហោសឹ ន អាកិញ្ចញ្ញាយតនេ អាកិញ្ចញ្ញាយតនសញ្ញី អហោសឹ ន នេវសញ្ញានាសញ្ញាយតនេ នេវសញ្ញានាសញ្ញាយតនសញ្ញី អហោសឹ ន ឥធលោកេ ឥធលោកសញ្ញី អហោសឹ

---

១ ឱ. ម. អថាហំ ។ ២ ម. បដិលភាមិ ។

ម្នាលអាវុសោសារីបុត្ត ចុះការបាននូវសមាធិ មានសភាពដូច្នោះ គប្បីមានដល់ភិក្ខុ តើដូចម្ដេច ដូចយ៉ាងភិក្ខុ មិនសម្គាល់ថា ដី ក្នុងដី ។ បេ ។ មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ម្នាលអាវុសោអានន្ទ សម័យមួយ ខ្ញុំនៅក្នុងអន្ធវ័ន ទៀបក្រុងសាវត្ថីនេះឯង ខ្ញុំបានចូលសមាធិ មានសភាពដូច្នោះ ក្នុងទីនោះគឺខ្ញុំមិនសម្គាល់ថា ដី ក្នុងដី មិនសម្គាល់ថា ទឹក ក្នុងទឹក មិនសម្គាល់ថា ភ្លើង ក្នុងភ្លើង មិនសម្គាល់ថា ខ្យល់ក្នុងខ្យល់ មិនសម្គាល់ថា អាកាសានញ្ចាយតនៈ ក្នុងអាកាសានញ្ចាយតនៈ មិនសម្គាល់ថា វិញ្ញាណញ្ចាយតនៈ ក្នុងវិញ្ញាណញ្ចាយតនៈ មិនសម្គាល់ថា អាកិញ្ចញ្ញាយតនៈ ក្នុងអាកិញ្ចញ្ញាយតនៈ មិនសម្គាល់ថា នេវសញ្ញានាសញ្ញាយតនៈ ក្នុងនេវសញ្ញានាសញ្ញាតនៈ មិនសម្គាល់ថា លោកនេះក្នុងលោកនេះ

ន បរលោកោ បរលោកសញ្ញី អហោសឹ សញ្ញី ច បន(១) អហោសិន្តិ ។ កឹសញ្ញី បនា-យស្មា សារីបុត្តោ តស្មឹ សមយេ អហោសីតិ ។ ភវនិរោធោ និព្វានំ ភវនិរោធោ និព្វានន្តិ ខោ មេ អាវុសោ អញ្ញាវ សញ្ញា ឧប្បជ្ជតិ អញ្ញាវ សញ្ញា និរុជ្ឈតិ ។ សេយ្យថាបិ អាវុសោ សកលិកគ្គិស្ស ឈាយមានស្ស អញ្ញាវ អច្ចិ ឧប្បជ្ជតិ អញ្ញាវ អច្ចិ និរុជ្ឈតិ ឯវមេវ ខោ មេ អាវុសោ ភវនិរោធោ និព្វានំ ភវនិរោធោ និព្វានន្តិ អញ្ញាវ សញ្ញា ឧប្បជ្ជតិ អញ្ញាវ សញ្ញា និរុជ្ឈតិ ភវនិរោធោ និព្វានន្តិ សញ្ញី ច បនាហំ អាវុសោ តស្មឹ សមយេ អហោសិន្តិ ។

[៨] សទ្ធោ ភិក្ខវេ ភិក្ខុ ហោតិ នោ ច សីលវា ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ អស្សំ សីលវា ចាតិ ។

១ ម. ឯត្តន្តរេ មេតិ បាហោ ទិស្សតិ ។

មិនសម្គាល់ថា លោកខាងមុខ ក្នុងលោកខាងមុខទេ គ្រាន់តែជាអ្នកមានសញ្ញា ជាធម្មតាប៉ុណ្ណោះ ។ ចុះព្រះសារីបុត្តដ៏មានអាយុ មានសញ្ញាដូចម្តេចក្នុងសម័យនោះ ។ ម្នាលអាវុសោ សញ្ញាកើតឡើងដល់ខ្ញុំដោយឡែកថាការរលត់ទៅនៃភពគឺនិព្វាន ការរលត់ទៅនៃភពគឺនិព្វានដូច្នេះ សញ្ញារលត់ទៅវិញដោយឡែក ។ ម្នាលអាវុសោ ប្រៀបដូចបំណែកភ្លើងកំពុងឆេះ អណ្តាតកើតឡើងដោយឡែក អណ្តាតរលត់ទៅវិញដោយឡែកយ៉ាងណាមិញ ម្នាលអាវុសោ សញ្ញាកើតឡើងដល់ខ្ញុំដោយឡែកថា ការរលត់ទៅនៃភពគឺនិព្វាន ការរលត់ទៅនៃភពគឺនិព្វាន ដូច្នេះសញ្ញារលត់ទៅវិញ ដោយឡែក ម្នាលអាវុសោ ក្នុងសម័យនោះខ្ញុំនៅតែមានសញ្ញាថា ការរលត់ទៅនៃភពគឺនិព្វាន (ប៉ុណ្ណោះ) ។

[៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាហើយ តែមិនមានសីល ភិក្ខុនោះឈ្មោះថា មិនពេញលេញ ដោយអង្គនោះ យ៉ាងនេះ ភិក្ខុនោះ គប្បីបំពេញអង្គនោះ ឲ្យពេញលេញឡើង ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ មានសទ្ធាផង មានសីលផង ។

២៣



យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ឯវំ សោ តេនង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ សីលវា ច នោ ច ពហុស្សុតោ ។ បេ ។ ពហុស្សុតោ ច នោ ច ធម្មកថិកោ ធម្មកថិកោ ច នោ ច បរិសាវចរោ បរិសាវចរោ ច នោ ច វិសារទោ បរិសាយ ធម្មំ ទេសេតិ វិសារទោ ច បរិសាយ ធម្មំ ទេសេតិ នោ ច វិនយធរោ វិនយធរោ ច នោ ច អារញ្ញកោ បន្តសេនាសនោ អារញ្ញកោ ច បន្តសេនាសនោ នោ ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ចតុន្នញ្ច ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី នោ ច អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុមានសទ្ធាផង មានសីលផង ទើបភិក្ខុនោះឈ្មោះថា ពេញលេញ ដោយអង្គនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធា ទាំងមានសីលហើយ តែថា មិនបានចេះដឹងច្រើន ។ បេ ។ ចេះដឹងច្រើនហើយ តែមិនចេះសម្ដែងធម៌ ចេះសម្ដែងធម៌ហើយ តែចូលកាន់បរិសទ្យមិនកើត ចូលកាន់បរិសទ្យកើតហើយ តែមិនក្លៀវក្លាសម្ដែងធម៌ដល់បរិសទ្យ ក្លៀវក្លាសម្ដែងធម៌ដល់បរិសទ្យហើយ តែមិនទ្រទ្រង់វិន័យ ទ្រទ្រង់វិន័យហើយ តែមិនប្រព្រឹត្តនៅក្នុងព្រៃ ដែលមានសេនាសនៈស្ងាត់ នៅក្នុងព្រៃ មានសេនាសនៈស្ងាត់ហើយ តែមិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ នូវចតុត្ថជ្ឈានដែលអាស្រ័យនូវចិត្តដ៏ប្រសើរជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នហើយ តែមិនធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។

២៤



ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេយ្យំ វិនយធរោ ច អារញ្ញកោ ច បន្តសេនាសនោ ចតុន្នញ្ច ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ ។ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេតិ វិនយធរោ ច អារញ្ញកោ ច បន្តសេនាសនោ ចតុន្នញ្ច ឈានានំ អាភិ-ចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាម-លាភី ហោតិ អកិច្ឆលាភី អកសិរលាភី

ភិក្ខុនោះ ឈ្មោះថា នៅមិនទាន់ពេញលេញ ដោយអង្គនោះ យ៉ាងនេះ ភិក្ខុនោះ ត្រូវបំពេញអង្គនោះ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិសទ្យកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិសទ្យផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃមានសេនាសនៈស្ងាត់ផង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិសទ្យកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិសទ្យផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃមានសេនាសនៈស្ងាត់ផង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវចតុត្ថជ្ឈាន ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង

អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ សោ តេនង្គេន បរិបូរោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមន្តបាសាទិកោ ច ហោតិ សព្វាការបរិបូរោ ចាតិ ។

[៩] សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ នោ ច សីលវា សីលវា ច នោ ច ពហុស្សុតោ ពហុស្សុតោ ច នោ ច ធម្មកថិកោ ធម្មកថិកោ ច នោ ច បរិសាវចរោ បរិសាវចរោ ច នោ ច វិសារទោ បរិសាយ ធម្មំ ទេសេតិ វិសារទោ ច បរិសាយ ធម្មំ ទេសេតិ នោ ច វិនយធរោ វិនយធរោ ច នោ ច អារញ្ញកោ បន្តសេនាសនោ អារញ្ញកោ ច បន្តសេនាសនោ នោ ច យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ កាយេន ផុសិត្វា វិហរតិ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ច កាយេន ផុសិត្វា វិហរតិ

ធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង ។ ភិក្ខុនោះទើបពេញលេញដោយអង្គនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ នេះហើយ ឈ្មោះថា នាំឲ្យកើតសេចក្តីជ្រះថ្លា ដោយជុំវិញផង បរិបូណ៌ដោយអាការគ្រប់យ៉ាងផង ។

[៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាហើយ តែគ្មានសីល មានសីលហើយ តែមិនចេះដឹងច្រើន ចេះដឹងច្រើនហើយ តែមិនចេះសម្តែងធម៌ ចេះសម្តែងធម៌ហើយ តែចូលកាន់បរិសទ្យមិនកើត ចូលកាន់បរិសទ្យកើតហើយ តែមិនក្លៀវក្លា សម្តែងធម៌ដល់បរិសទ្យ ក្លៀវក្លាសម្តែងធម៌ ដល់បរិសទ្យហើយ តែមិនទ្រទ្រង់វិន័យ ទ្រទ្រង់វិន័យហើយ តែមិនប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ ប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ហើយ តែមិនបានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈានហើយ បានអារុប្បជ្ឈានដោយកាយ បានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈាន បានអារុប្បជ្ឈាន ដោយកាយហើយ

ណោ ច អាសវានំ ខយា អនាសវំ ចេតោ-
វិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា
សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ សោ តេន-
ង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ
កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ
ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច
បរិសាយ ធម្មំ ទេសេយ្យំ វិនយធរោ ច អារញ្ញកោ
ច បន្តសេនាសនោ យេ តេ សន្តា វិមោក្ខា អតិ-
ក្កម្ម រូបេ អារុប្បា តេ ច កាយេន ផុសិត្វា វិហរេយ្យំ
អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ
ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ
វិហរេយ្យន្តិ ។ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ
ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ
ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ
ទេសេតិ វិនយធរោ ច អារញ្ញកោ ច បន្តសេនាសនោ

តែមិនបានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះ ឈ្មោះថា នៅមិនទាន់ពេញលេញ ដោយអង្គនោះ យ៉ាងនេះ ភិក្ខុនោះ ត្រូវបំពេញអង្គនោះ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ មានសទ្ធាផង មានសីលផង ចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិសទ្យកើតផង ក្លៀវក្លាសម្តែងធម៌ ដល់បរិសទ្យផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ផង បានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈានហើយ បានអារុប្បជ្ឈានដោយកាយផង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្នផង ។ ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុមានសទ្ធាផង មានសីលផង ចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិសទ្យកើតផង ក្លៀវក្លាសម្តែងធម៌ ដល់បរិសទ្យផង ទ្រទ្រង់វិន័យផង ប្រព្រឹត្តនៅក្នុងព្រៃ មានសេនាសនៈស្ងាត់ផង

យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ច កាយេន ផុសិត្វា វិហរតិ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេនង្គេន បរិបូរោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមន្តប្បាសាទិកោ ច ហោតិ សព្វាការបរិបូរោ ចាតិ ។

[១០] សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ នោ ច សីលវា ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ចាតិ ។ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ឯវំ សោ តេនង្គេន បរិបូរោ ហោតិ ។

បានវិមោក្ខធម៌ដ៏ល្អិត ដែលកន្លងរូបជ្ឈានហើយ បានអារុប្បជ្ឈាន ដោយកាយផង ធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង ភិក្ខុនោះ ទើបឈ្មោះថា ពេញលេញដោយអង្គនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ នេះហើយ ឈ្មោះថា នាំឲ្យកើតសេចក្ដីជ្រះថ្លា ដោយជុំវិញផង បរិបូណ៌ដោយអាការគ្រប់យ៉ាងផង ។

[១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាហើយ តែមិនមានសីល ភិក្ខុនោះឈ្មោះថា នៅមិនទាន់ពេញលេញ ដោយអង្គនោះ យ៉ាងនេះឡើយ ភិក្ខុនោះ ត្រូវបំពេញអង្គនោះ ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ មានសទ្ធាផង មានសីលផង ។ ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុមានសទ្ធាផង មានសីលផងហើយ ភិក្ខុនោះ ទើបឈ្មោះថា ពេញលេញដោយអង្គនោះ យ៉ាងនេះ ។

សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ សីលវា ច នោ ច ពហុស្សុតោ ពហុស្សុតោ ច នោ ច ធម្មកថិកោ ធម្មកថិកោ ច នោ ច បរិសាវចរោ បរិសាវចរោ ច នោ ច វិសារទោ បរិសាយ ធម្មំ ទេសេតិ វិសារទោ ច បរិសាយ ធម្មំ ទេសេតិ នោ ច វិនយធរោ វិនយធរោ ច នោ ច អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ អនេកវិហិតញ្ច បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ នោ ច ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ទិព្វេន ច ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសទ្ធាផង មានសីលផងហើយ តែមិនជាអ្នកចេះដឹងច្រើន ចេះដឹងច្រើនហើយ តែមិនចេះសម្តែងធម៌ ចេះសម្តែងធម៌ហើយ តែចូលកាន់បរិសទ្យមិនកើត ចូលកាន់បរិសទ្យកើតហើយ តែមិនក្លៀវក្លាសម្តែងធម៌ដល់បរិសទ្យ ក្លៀវក្លាសម្តែងធម៌ដល់បរិសទ្យហើយ តែមិនទ្រទ្រង់វិន័យ ទ្រទ្រង់វិន័យហើយ តែមិនបានរលឹកនូវបុព្វេនិវាសច្រើនប្រការ គឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាស ច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ រលឹកឃើញនូវបុព្វេនិវាស ច្រើនប្រការគឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះហើយ តែទាស់មិនមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។ បេ ។

២៩



យថាកម្មូបគេ សត្តេ បជានាតិ នោ ច អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ សោ តេនង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេយ្យំ វិនយធរោ ច អនេកវិហិតញ្ច បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យ ទិព្វេន ច ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានេយ្យំ អាសវានញ្ច ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ ។

ដឹងច្បាស់នូវពួកសត្វដែលអន្ទោល ទៅតាមកម្មហើយ តែមិនធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយហើយ ។ ភិក្ខុនោះឈ្មោះថា នៅមិនទាន់ពេញលេញ ដោយអង្គនោះ យ៉ាងនេះឡើយ ភិក្ខុនោះ ត្រូវបំពេញអង្គនោះដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្តែងធម៌ផង ចូលកាន់បរិសទ្យកើតផង ក្លៀវក្លាសម្តែងធម៌ដល់បរិសទ្យផង ទ្រទ្រង់វិន័យផង រលឹកឃើញនូវបុព្វេនិវាសច្រើនប្រការគឺ រលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះផង មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មផង ធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ។

យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេតិ វិនយធរោ ច អនេកវិហិតញ្ច បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេក-វិហិតំ បុព្វេនិវាសំ អនុស្សរតិ ទិព្វេន ច ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូ-បគេ សត្តេ បជានាតិ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេនង្គេន បរិបូរោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមន្តបាសា-ទិកោ ច ហោតិ សព្វាការបរិបូរោ ចាតិ ។

អានិសំសវគ្គោ បឋមោ ។

ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុមានសទ្ធាផង មានសីលផង ជាអ្នកចេះដឹងច្រើនផង ចេះសម្ដែងធម៌ផង ចូលកាន់បរិសទ្យកើតផង ក្លៀវក្លាសម្ដែងធម៌ ដល់បរិសទ្យផង ទ្រទ្រង់វិន័យផង រលឹកឃើញនូវបុព្វេនិវាស ច្រើនប្រការ គឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាស ច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះផង មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មផង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង ភិក្ខុនោះ ទើបឈ្មោះថាពេញលេញដោយអង្គនោះយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ទាំង ១០ យ៉ាងនេះហើយ ឈ្មោះថា នាំឲ្យកើតសេចក្ដីជ្រះថ្លាដោយជុំវិញផង បរិបូណ៌ដោយអាការគ្រប់យ៉ាងផង ។

ចប់ អានិសំសវគ្គទី ១ ។

៣១



# តស្សុទ្ទានំ[១]

ភិមត្តិយំ ចេតនា សីលំ

ឧបនិសា អានន្ទ បញ្ចមំ

សមាធិ សារីបុត្តោ ច

សទ្ធោ សន្តេន[២] វិជ្ជយាតិ ។

---

១ ម. តត្រុទ្ទានំ ។ ២ ម. បន្តេន ។

បឋមបណ្ណាសក    អានិសំសវគ្គ

# ឧទ្ទាននៃអានិសំសវគ្គនោះគឺ

និយាយអំពីសីល មានប្រយោជន៍ដូចម្តេច ១ អំពីចេតនា ១ អំពីសីល ១ អំពីការសោបសូន្យចាកឧបនិស្ស័យ ១ អំពីព្រះអានន្ទជាគម្រប់ ៤ អំពីសមាធិ ១ អំពីព្រះសារីបុត្រ ១ អំពីភិក្ខុមានសទ្ធា ១ អំពីសន្តវិមោក្ខ ១ អំពីភិក្ខុមានសទ្ធាជាដើម ១ ។

# ទុតិយោ នាថករណវគ្គោ

[១១] បញ្ចង្គសមន្នាគតោ ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតំ សេនាសនំ សេវមានោ ភជមានោ ន ចិរស្សេវ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ ។ កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ

# នាថករណវគ្គទី ២

[១១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ កាលសេពគប់នូវសេនាសនៈ ដែលប្រកបដោយអង្គ ៥ មិនយូរប៉ុន្មាន គប្បីធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសទ្ធា ជឿសេចក្តីត្រាស់ដឹង របស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធ មានបុញ្ញសិរី ១ ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុ បក់កម្តៅស្មើគឺមិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល អត់ធន់នូវសេចក្តីព្យាយាមបាន ១ មិនជាអ្នកអួតអាង មិនមានមាយាគឺប្រព្រឹត្តខ្លួន ឲ្យពិតប្រាកដ ក្នុងព្រះសាស្តា ឬ ក្នុងពួកសព្រហ្មចារី ជាអ្នកចេះដឹង ១

អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតោ ហោតិ ។ កតមញ្ច ភិក្ខវេ សេនាសនំ បញ្ចង្គសមន្នាគតំ ហោតិ ។ ឥធ ភិក្ខវេ សេនាសនំ នាតិទូរំ ហោតិ នាច្ចាសន្នំ គមនាគមនសម្បន្នំ ទិវា អប្បកិណ្ណំ រត្តឹ អប្បសទ្ទំ អប្បនិគ្ឃោសំ អប្បឌំសមកសវាតាតបសិរឹសបសម្ផស្សំ តស្មឹ ខោ បន សេនាសនេ វិហរន្តស្ស អប្បកសិរេនេវ ឧប្បជ្ជន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា តស្មឹ ខោ បន សេនាសនេ ថេរា ភិក្ខូ វិហរន្តិ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា

ជាអ្នកមានព្យាយាមប្រារព្ធ ដើម្បីលះបង់ពួកអកុសលធម៌ ចូលដល់នូវកុសលធម៌ ១ ជាអ្នកមានកម្លាំង ប្រឹងប្រែងមាំមួន មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយ ១ មានប្រាជ្ញា ប្រកបដោយបញ្ញាយល់ច្បាស់នូវសេចក្តីចម្រើននិងសេចក្តីវិនាស ជាប្រាជ្ញាប្រសើរមោះមុត ប្រព្រឹត្តទៅ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះសេនាសនៈប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវមានសំឡេង មិនសូវគឹកកង ក្នុងរាត្រី មិនសូវមានសម្ផស្ស ដោយរបោមមូសខ្យល់ កម្តៅថ្ងៃនិងពស់តូចពស់ធំ ១ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ កើតឡើង ដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះ ដោយមិនលំបាក ១ ពួកភិក្ខុជាថេរៈដែលនៅ ក្នុងសេនាសនៈនោះ ជាពហុស្សូតចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ១

តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេក-វិហិតេសុ ច កង្ខដ្ឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ ។ ឯវំ ខោ ភិក្ខវេ សេខាសនំ បញ្ចង្គសមន្នាគតំ ហោតិ ។ បញ្ចង្គសមន្នាគតោ ខោ ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតំ សេខាសនំ សេវមានោ ភជមានោ ន ចិរស្សេវ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។

[១២] បញ្ចង្គវិប្បហីនោ ភិក្ខវេ ភិក្ខុ បញ្ចង្គ-សមន្នាគតោ ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ កាមច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ ថីនមិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ វិចិកិច្ឆា បហីនា ហោតិ ។

ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្តង ៗ ហើយសួរ ប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះតើដូចម្តេច សេចក្តីអធិប្បាយនៃរឿងនេះ តើដូចម្តេច ១ លោកដ៏មានអាយុទាំងនោះ រមែងពន្យល់រឿងដែលមិនទាន់ច្បាស់លាស់ផង ធ្វើឲ្យងាយនូវរឿងដែលជ្រៅផង បន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើនប្រការផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ កាលបើសេពគប់នូវសេនាសនៈ ប្រកបដោយអង្គ ៥ ហើយ មិនយូរប៉ុន្មាននឹងបានធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ។

[១២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ ប្រការដោយអង្គ ៥ ហៅថាជាឧត្តមបុរស មានគុណគ្រប់គ្រាន់ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះកាមច្ឆន្ទៈ ១ លះព្យាបាទ ១ លះថីនមិទ្ធៈ ១ លះឧទ្ធច្ចកុក្កុច្ចៈ ១ លះវិចិកិច្ឆា ១ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន បញ្ញាខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិញ្ញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតោ ហោតិ ។ បញ្ចង្គវិប្បហីនោ ខោ ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតោ ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតីតិ ។

កាមច្ឆន្ទោ ច ព្យាបាទោ ថីនមិទ្ធញ្ច ភិក្ខុនោ
ឧទ្ធច្ចំ វិចិកិច្ឆា ច សព្វសោ វ ន វិជ្ជតិ
អសេក្ខេន ច សីលេន អសេក្ខេន សមាធិនា
វិមុត្តិយា ច សម្បន្នោ ញាណេន ច តថាវិធោ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះភិក្ខុប្រកបដោយអង្គ ៥ តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងសាសនានេះ ភិក្ខុប្រកបដោយសីលក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធ ជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ហៅថាជាឧត្តមបុរស មានគុណគ្រប់គ្រាន់ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ។

*កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចៈ ១ វិចិកិច្ឆា ១*
*មិនមានដល់ភិក្ខុ ដោយប្រការទាំងពួង ភិក្ខុបែបនោះ ប្រកប*
*ដោយអសេក្ខសីលផង ដោយអសេក្ខសមាធិផង (ដោយ*
*អសេក្ខបញ្ញាផង) ដោយវិមុត្តិផង ដោយវិមុត្តិញ្ញាណផង*

សវេ បញ្ចង្គសម្បន្នោ បញ្ចង្គានិ[១] វិវជ្ជយំ
សវេ ឥមស្មិំ ធម្មវិនយេ កេវលី ឥតិ វុច្ចតីតិ ។

[១៣] ទសយិមានិ ភិក្ខវេ សំយោជនានិ ។ កតមានិ ទស ។ បញ្ចោរម្ភាគិយានិ សំយោជនានិ បញ្ចុទ្ធម្ភាគិយានិ សំយោជនានិ ។ កតមានិ បញ្ចោរម្ភាគិយានិ សំយោជនានិ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ កាមច្ឆន្ទោ ព្យាបាទោ ។ ឥមានិ បញ្ចោរម្ភាគិយានិ សំយោជនានិ ។ កតមានិ បញ្ចុទ្ធម្ភាគិយានិ សំយោជនានិ ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ បញ្ចុទ្ធម្ភាគិយានិ សំយោជនានិ ។ ឥមានិ ខោ ភិក្ខវេ ទស សំយោជនានីតិ ។

---

១ ឱ. ម. បញ្ច អង្គេ ។

ភិក្ខុនោះឯង ឈ្មោះថា ប្រកបដោយអង្គ ៥ លះអង្គ ៥ ភិក្ខុនោះឯង ហៅថា ប្រកបដោយគុណទាំងអស់ ក្នុងធម្មវិន័យនេះ ។

[១៣] ម្នាលភិក្ខុទាំងឡាយ សំយោជនៈនេះមាន ១០ យ៉ាង ។ សំយោជនៈ ១០ យ៉ាងតើដូចម្តេច ។ គឺសំយោជនៈ ជាចំណែកខាងក្រោម ៥ សំយោជនៈជាចំណែកខាងលើ ៥ ។ សំយោជនៈជាចំណែកខាងក្រោម ៥ តើដូចម្តេច ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ។ នេះជាសំយោជនៈ ជាចំណែកខាងក្រោម ៥ ។ សំយោជនៈជាចំណែកខាងលើ ៥ តើដូចម្តេច ។ គឺ រូបរាគៈ ១ អរូបរាគៈ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ នេះជាសំយោជនៈ ជាចំណែកខាងលើ ៥ ។ ម្នាលភិក្ខុទាំងឡាយ សំយោជនៈមាន ១០ យ៉ាងនេះឯង ។

[១៤] យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា បញ្ច ចេតោខិលា អប្បហីនា បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ កតមស្ស បញ្ច ចេតោខិលា អប្បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។

[១៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬ ភិក្ខុនីណាមួយ មិនបានលះសេចក្ដីរឹងត្អឹងនៃចិត្ត ៥ មិនបានផ្ដាច់ផ្ដិលចំណងរបស់ចិត្ត ៥ ទេ យប់ ឬ ថ្ងៃមកដល់ភិក្ខុ ឬ ភិក្ខុនីនោះ សេចក្ដីសាបសូន្យក្នុងកុសលធម៌ទាំង-ឡាយ រមែងប្រាកដឡើង មិនមានសេចក្ដីចម្រើនឡើយ ។ សេចក្ដីរឹងត្អឹងនៃចិត្ត ៥ ដែលភិក្ខុមិនបានលះបង់តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្ដា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសង្ស័យងឿងឆ្ងល់មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្ដា ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។

យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បឋមោ ចេតោ-ខីលោ អប្បហីនោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេ កង្ខតិ ។ បេ ។ សង្ឃេ កង្ខតិ សិក្ខាយ កង្ខតិ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ ។ យោ សោ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុ-យោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បញ្ចមោ ចេតោខីលោ អប្បហីនោ ហោតិ ។

ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ភិក្ខុនោះឈ្មោះថា មិនបានលះបង់សេចក្តីរឹងត្អឹងនៃចិត្តទី ១ នេះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុសង្ស័យក្នុងធម៌ ។ បេ ។ សង្ស័យក្នុងសង្ឃ សង្ស័យក្នុងសិក្ខា ក្រោធខឹង មិនពេញចិត្ត មានចិត្តត្រូវទោសៈ ខ្នាំងខ្នប់ មានសេចក្តីរឹងរូសក្នុងសព្រហ្មចារីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកក្រោធខឹង មិនពេញចិត្ត មានចិត្តត្រូវទោសៈខ្នាំងខ្នប់ មានសេចក្តីរឹងរូសក្នុងសព្រហ្មចារីទាំងឡាយហើយ ចិត្តរបស់ភិក្ខុនោះ រមែងមិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកនូវព្យាយាម ។ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះឈ្មោះថា មិនបានលះបង់សេចក្តីរឹងត្អឹងនៃចិត្តទាំង ៥ នេះ យ៉ាងនេះឯង ។

៣៩



ឥមស្ស បញ្ច ចេតោខីលា អប្បហីនា ហោន្តិ ។ កាតមស្ស បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតប្បេមោ អវិគតបិចាសោ អវិគតបរិឡាហោ អវិគតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ កាមេសុ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតប្បេមោ អវិគតបិចាសោ អវិគតបរិឡាហោ អវិគតតណ្ហោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។

នេះជាសេចក្ដីរឹងត្អឹងនៃចិត្តទាំង ៥ ដែលភិក្ខុមិនបានលះបង់ហើយ ។ ចុះចំណងរបស់ចិត្ត ៥ ដែលភិក្ខុមិនបានផ្ដាច់ផ្ដិល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្ដីប្រាថ្នា មិនទាន់ប្រាសចាកសេចក្ដីគាប់ចិត្ត មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្ដៅក្រហាយ មិនទាន់ប្រាសចាកបំណងក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្ដីប្រាថ្នា មិនទាន់ប្រាសចាកសេចក្ដីគាប់ចិត្ត មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្ដៅក្រហាយ មិនទាន់ប្រាសចាកបំណងក្នុងកាមទាំងឡាយហើយ ចិត្តរបស់ភិក្ខុនោះ រមែងមិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។

យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បឋមោ ចេតសោ វិនិពន្ធោ អសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កាយេ អវីតរាគោ ហោតិ ។ បេ ។ រូបេ អវីតរាគោ ហោតិ យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរតិ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ។ យោ សោ ភិក្ខវេ ភិក្ខុ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។

ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាមទេ ភិក្ខុនោះឈ្មោះថា មិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទី ១ នេះយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ។ បេ ។ មិនទាន់ប្រាសចាកតម្រេកក្នុងរូប បរិភោគអាហារពេញពោះដរាបដល់ឆ្អែត រៀបចំតែទីដេកឲ្យស្រួល ទីផ្អែកឲ្យស្រួល ទីលក់ឲ្យស្រួល ប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នា ឲ្យបានជាពួកទេវតាណាមួយថា ខ្ញុំសូមឲ្យបានជាទេវតាធំ ឬ ទេវតាតូចណាមួយ ដោយសីល ឬវ័ត ឬតបៈឬក៏ព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នាឲ្យបានជាពួកទេវតាណាមួយថា ខ្ញុំសូមឲ្យបានជាទេវតាធំ ឬ ទេវតាតូចណាមួយ ដោយសីល ឬវ័ត ឬ តបៈឬក៏ព្រហ្មចរិយៈនេះ ចិត្តរបស់ភិក្ខុនោះ រមែងមិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។

៤១



យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បញ្ចមោ ចេតសោ វិនិពន្ធោ អសមុច្ឆិន្នោ ហោតិ ។ ឥមស្ស បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា ហោន្តិ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ឥមេ បញ្ច ចេតោខិលា អប្បហីនា ឥមេ បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ ភិក្ខវេ កាឡបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហាយតេវ វណ្ណេន ហាយតិ មណ្ឌលេន ហាយតិ អាភាយ ហាយតិ អារោហបរិណាហេន ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ឥមេ បញ្ច ចេតោខិលា អប្បហីនា ឥមេ បញ្ច ចេតសោ វិនិពន្ធា អសមុច្ឆិន្នា តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ

ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាមមិនដាច់ទេ ភិក្ខុនោះឈ្មោះថា មិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទី ៥ នេះ យ៉ាងនេះឯង ។ នេះជាចំណង របស់ចិត្តទាំង ៥ ដែលភិក្ខុមិនបានផ្តាច់ផ្តិល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ មិនបានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ មិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទាំង ៥ នេះហើយ យប់និងថ្ងៃ មកដល់ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ មិនមានសេចក្តីចម្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាយប់និងថ្ងៃ រមែងមកដល់ព្រះចន្ទ្រក្នុងកាលបក្ខ តែងសាបសូន្យចាកវណ្ណៈ សាបសូន្យចាកមណ្ឌល សាបសូន្យចាករស្មី សាបសូន្យចាកទំហំនិងកម្ពស់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ មិនបានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ មិនបានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទាំង ៥ នេះហើយ យប់និងថ្ងៃមកដល់ភិក្ខុឬភិក្ខុនីនោះ

ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា បញ្ច ចេតោខីលា បហីនា បញ្ច ចេតសោ វិនិពន្ធា សមុច្ឆិន្នា តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ កតមស្ស បញ្ច ចេតោខីលា បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថរិ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ ន កង្ខតិ ន វិចិកិច្ឆតិ អធិមុច្ចតិ សម្បសីទតិ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បឋមោ ចេតោខីលោ បហីនោ ហោតិ ។

សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ មិនមានសេចក្តីចម្រើនឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឬភិក្ខុនីណាមួយ បានលះបង់សេចក្តីរឹងត្អឹងរបស់ចិត្ត ៥ បានផ្តាច់ផ្តិលនូវចំណងរបស់ចិត្ត ៥ ហើយ យប់និងថ្ងៃមកដល់ភិក្ខុឬភិក្ខុនីនោះ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ មិនបានសាបសូន្យឡើយ ។ សេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ ដែលភិក្ខុឬភិក្ខុនីបានលះបង់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនងឿងឆ្ងល់ មិនសង្ស័យ ចុះចិត្តស៊ប់ ជ្រះថ្លា ក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនងឿងឆ្ងល់ មិនសង្ស័យ ចុះចិត្តស៊ប់ ជ្រះថ្លាក្នុងព្រះសាស្តាហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណា បង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះឈ្មោះថា បានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទី ១ នេះ យ៉ាងនេះឯង ។

បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេ ន កង្ខតិ ។ បេ ។ សង្ឃេ ន កង្ខតិ... សិក្ខាយ ន កង្ខតិ សព្រហ្មចារីសុ ន កុបិតោ ហោតិ អត្តមនោ ន អាហតចិត្តោ ន ខីលជាតោ ។ យោ សោ ភិក្ខវេ ភិក្ខុ សព្រហ្មចារីសុ ន កុបិតោ ហោតិ អត្តមនោ ន អាហតចិត្តោ ន ខីលជាតោ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បញ្ចមោ ចេតោខីលោ បហីនោ ហោតិ ។ ឥមស្ស បញ្ច ចេតោខីលា បហីនា ហោន្តិ ។ កតមស្ស បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា ហោន្តិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនងឿងឆ្ងល់ ក្នុងធម៌ ។ បេ ។ មិនងឿងឆ្ងល់ ក្នុងសង្ឃ... មិនងឿងឆ្ងល់ ក្នុងសិក្ខា មិនក្រោធខឹង មិនអន់ចិត្ត មិនមានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មិនមានសេចក្តីរឹងរូស ក្នុងពួកសព្រហ្មចារី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនក្រោធខឹង មិនអន់ចិត្ត មិនមានចិត្តត្រូវទោសៈ ខ្ទាំងខ្ទប់ មិនមានសេចក្តីរឹងរូស ក្នុងពួកសព្រហ្មចារីហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ចិត្តរបស់ភិក្ខុណា បង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះឈ្មោះថា លះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទី ៥ នេះយ៉ាងនេះឯង ។ នេះជាសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ ដែលភិក្ខុបានលះបង់ហើយ ។ ចំណងរបស់ចិត្ត ៥ ដែលភិក្ខុ បានផ្តាច់ផ្តិលហើយ តើដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុ កាមេសុ វីតរាគោ ហោតិ វិគតច្ឆន្ទោ វិគតបេមោ វិគតបិបាសោ វិគតបរិឡាហោ វិគតតណ្ហោ ។ យោ សោ ភិក្ខវេ ភិក្ខុ កាមេសុ វីតរាគោ ហោតិ វិគតច្ឆន្ទោ វិគតបេមោ វិគតបិបា-សោ វិគតបរិឡាហោ វិគតតណ្ហោ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បឋមោ ចេតសោ វិនិពន្ធោ សុសមុច្ឆិន្នោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កាយេ វីតរាគោ ហោតិ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីប្រាថ្នា ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសម្រេក ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីប្រាថ្នា ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសម្រេក ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ ក្នុងកាមទាំងឡាយហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណា បង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះឈ្មោះថា បានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទី ១ នេះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាសចាកតម្រេក ក្នុងកាយ ។ បេ ។

រូបេ វីតរាគោ ហោតិ ន យាវទត្ថំ ឧទរាវទេហកំ កុញ្ចិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរតិ ន អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ។ យោ សោ ភិក្ខវេ ភិក្ខុ ន អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ តស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ។ យស្ស ចិត្តំ នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ ឯវមស្សាយំ បញ្ចមោ ចេតសោ វិនិពន្ធោ សុសមុច្ឆិន្នោ ហោតិ ។

ប្រាសចាកតម្រេកក្នុងរូប មិនបរិភោគពេញពោះដរាបដល់ឆ្អែត ហើយរៀបចំតែទីដេកឲ្យស្រួល ទីផ្អែកឲ្យស្រួល ទីលក់ឲ្យស្រួល មិនប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នា ឲ្យបានជាពួកទេវតាណាមួយថាអាត្មាអញសូមឲ្យបានជាទេវតាធំ ឬទេវតាតូចណាមួយដោយសីល ឬវ័ត ឬក៏តបៈ ឬក៏ ព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនប្រព្រឹត្តព្រហ្មចរិយៈ ព្រោះតម្កល់ទុកនូវសេចក្តីប្រាថ្នា ឲ្យបានជាពួកទេវតាណាមួយថា អាត្មាអញសូមឲ្យបានជាទេវតាធំ ឬទេវតាតូចណាមួយ ដោយសីល ឬវ័ត ឬក៏តបៈ ឬក៏ព្រហ្មចរិយៈនេះហើយ ចិត្តរបស់ភិក្ខុនោះ រមែងបង្អោនទៅ ដើម្បីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ។ ចិត្តរបស់ភិក្ខុណា បង្អោនទៅ ដើម្បីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដើម្បីប្រកបរឿយ ៗ ដើម្បីព្យាយាមមិនដាច់ ដើម្បីតាំងទុកព្យាយាម ភិក្ខុនោះឈ្មោះថាផ្តាច់ផ្តិលនូវចំណង របស់ចិត្តទី ៥ នេះ យ៉ាងនេះឯង ។

៤៦



ឥមស្ស បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា ហោន្តិ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ឥមេ បញ្ច ចេតោខិលា បហីនា ឥមេ បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ ភិក្ខវេ ជុណ្ហបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ អារោហបរិណាហេន ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ឥមេ បញ្ច ចេតោខិលា បហីនា ឥមេ បញ្ច ចេតសោ វិនិពន្ធា សុសមុច្ឆិន្នា តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។

នេះជាចំណងរបស់ចិត្តទាំង ៥ ដែលភិក្ខុបានផ្តាច់ផ្តិល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬភិក្ខុនីណាមួយ បានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ បានផ្តាច់ផ្តិលនូវចំណងរបស់ចិត្តទាំង ៥ នេះហើយ យប់និងថ្ងៃមកដល់ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយប់និងថ្ងៃ រមែងមកដល់ព្រះចន្ទ្រខាងខ្នើត តែងចម្រើនដោយវណ្ណៈ ចម្រើនដោយមណ្ឌល ចម្រើនដោយរស្មី ចម្រើនដោយកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឬភិក្ខុនីណាមួយ បានលះបង់នូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះ បានផ្តាច់ផ្តិលនូវសេចក្តីរឹងត្អឹងរបស់ចិត្តទាំង ៥ នេះហើយ យប់និងថ្ងៃ មកដល់ភិក្ខុ ឬភិក្ខុនីនោះ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ ក៏យ៉ាងនោះដែរ ។

៤៧

បឋមបណ្ណាសកេ នាថករណវគ្គោ

[១៩] យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញីនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ[១] អគ្គមក្ខាយតិ ។ សេយ្យថាបិ ភិក្ខវេ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ អគ្គមក្ខាយតិ ។

---

១ ឱ. ម. ឯត្ថន្តរេ ធម្មានន្តិ បាឋោ ទិស្សតិ ។

[១៥] ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងអម្បាលមាណ ទោះបី មិនមានជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនក្តី ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរ ជាងពួកសត្វទាំងអម្បាលនោះ (យ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ កងធម៌ជាកុសលឯណានីមួយ កងធម៌ជាកុសលទាំងអស់នោះ មានអប្បមាទជាឫស ប្រជុំចុះក្នុងអប្បមាទ អប្បមាទ ប្រាកដជាប្រសើរជាងកងធម៌ជាកុសលទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាស្នាមជើងទាំងឡាយណាមួយ របស់ពួកសត្វ ដែលដើរលើផ្ទៃផែនដី ស្នាមជើងទាំងអស់នោះ រមែងដល់នូវការប្រជុំចុះ ក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរី ប្រាកដជាប្រសើរជាងស្នាមជើងនៃសត្វទាំងនោះ ព្រោះជាស្នាមជើងធំ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កងធម៌ជាកុសលឯណានីមួយ កងធម៌ ជាកុសលទាំងអស់នោះ មានអប្បមាទជាឫស ប្រជុំចុះ ក្នុងអប្បមាទ អប្បមាទ ប្រាកដជាប្រសើរជាងកងធម៌ ជាកុសលទាំងអស់នោះ ក៏យ៉ាងនោះដែរ ។

សេយ្យថាបិ ភិក្ខវេ កូដាគារស្ស យា កាចិ គោបានសិយោ សព្វា តា កូដង្គមា កូដនិន្នា កូដសមោសរណា កូដំ តាសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោ-សរណា អប្បមាទោ តេសំ អគ្គមក្ខាយតិ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ មូលគន្ធា កាឡានុសារិយំ តេសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ។ បេ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ សារគន្ធា លោហិតចន្ទនំ តេសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាបង្គង់ទាំងឡាយ ឯណានីមួយ របស់កូដាគារ (ផ្ទះដែលគេសង្រ្គោះដោយកំពូល) បង្គង់ទាំងអស់នោះ ឈមទៅរកកំ-ពូល ទេរទៅរកកំពូល ប្រជុំទៅត្រង់កំពូល កំពូលប្រាកដជាប្រសើរជាង បង្គង់ទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កងធម៌ជាកុសល ឯណានីមួយ កងធម៌ជាកុសលទាំងអស់នោះ មានអប្បមាទ ជាឫស ប្រជុំចុះក្នុងអប្បមាទ អប្បមាទ ប្រាកដជាប្រសើរជាងកងធម៌ជាកុសល ទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជា ក្លិនឫសឈើទាំងឡាយ ឯណានីមួយ ក្លិនឫសក្លាំពាក់ ប្រាកដជា ប្រសើរជាងក្លិនឫសឈើទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាក្លិនខ្លឹម ទាំងឡាយណានីមួយ ក្លិនខ្លឹមចន្ទន៍ក្រហមប្រាកដជាប្រសើរជាងក្លិនខ្លឹម ទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ យ៉ាងនោះដែរ ។

សេយ្យថាបិ ភិក្ខវេ យេ កេចិ បុប្ផគន្ធា វស្សិកំ តេសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ។ បេ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ កុឌ្ឌរាជា សព្វេ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា វត្តន្តិ[១] រាជា តេសំ ចក្កវត្តិ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ។ បេ ។ សេយ្យថាបិ ភិក្ខវេ យា កាចិ តារករូបានំ បភា សព្វា តា ចន្ទប្បភាយ កលំ នាគ្ឃន្តិ សោឡសឹ ចន្ទប្បភា តាសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ ។ បេ ។

១ ឱ. ម. ភវន្តិ ។

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាក្លិនផ្កាឈើទាំងឡាយ ឯណានីមួយ ក្លិនផ្កាម្លិះ ប្រាកដជាប្រសើរ ជាងក្លិនផ្កាឈើទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាពួកស្តេចតូច ៗ ឯណានីមួយ ពួកស្តេចតូច ៗ ទាំងអស់នោះ រមែងជាចំណុះរបស់ស្តេចចក្រពត្តិ ស្តេចចក្រពត្តិ ប្រាកដជាប្រសើរជាងពួកស្តេចតូច ៗ ទាំងនោះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រៀបដូចជាពន្លឺ របស់រូបផ្កាយទាំងឡាយឯណានីមួយ ពន្លឺទាំងអស់នោះ មិនបានដល់នូវចំណិត ជាគម្រប់ ១៦ ៗ ដង នៃពន្លឺព្រះចន្ទ្រ ពន្លឺព្រះចន្ទ្រ ប្រាកដជាប្រសើរ ជាងពន្លឺនៃរូបផ្កាយទាំងនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ក៏យ៉ាងនោះដែរ ។

សេយ្យថាបិ ភិក្ខវេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អាទិច្ចោ នភំ អព្ភុស្សក្កមានោ[១] សព្វំ អាកាសគតំ តមគតំ អភិវិហច្ច ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវ ខោ ភិក្ខវេ ។ បេ ។ សេយ្យថាបិ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី សព្វា តា សមុទ្ទង្គមា សមុទ្ទនិន្នា សមុទ្ទបោណា សមុទ្ទបព្ភារា មហាសមុទ្ទោ តាសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ អគ្គមក្ខាយតីតិ ។

---

១ ឱ. អព្ភុស្សុក្កមានោ ។ ម. អភូសក្កមានោ ។

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាព្រះអាទិត្យ កាលបើភ្លៀងស្វាង ប្រាស ចាកពពកក្នុងសរទសម័យ ខ្ពស់ផុតពពក កម្ចាត់បង់នូវងងឹតទាំងអស់ ដែលនៅលើអាកាសហើយភ្លឺស្វាងរុងរឿង យ៉ាងណាមិញ ម្នាលភិក្ខុ ទាំងឡាយ ។ បេ ។ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាទន្លេធំទាំងឡាយ ឯណានីមួយ គឺទន្លេគង្គា យមុនា អចិ-រវតី សរភូ មហី ទន្លេទាំងអស់នោះ ក៏ឈមទៅរកសមុទ្រ ឱន ទៅរកសមុទ្រ ទេរទៅរកសមុទ្រ ញោចទៅរកសមុទ្រ មហាស-មុទ្រ ប្រាកដជាប្រសើរជាងទន្លេធំទាំងនោះ យ៉ាងណាមិញ ម្នាល ភិក្ខុទាំងឡាយ កងធម៌ ជាកុសលឯណានីមួយ កងធម៌ ជាកុសល ទាំងអស់នោះ មានអប្បមាទជាឫស ប្រជុំចុះក្នុងអប្បមាទ អប្បមាទ ប្រាកដជាប្រសើរជាងកងធម៌ជាកុសលទាំងនោះ ក៏យ៉ាងនោះដែរ ។

[១៦] ទសយិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ ទស ។ តថាគតោ អរហំ សម្មាសម្ពុទ្ធោ បច្ចេកសម្ពុទ្ធោ ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី គោត្រភូ ។ ឥមេ ខោ ភិក្ខវេ ទស បុគ្គលា អាហុនេយ្យា ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១៧] សនាថា ភិក្ខវេ វិហរថ មា អនាថា ទុក្ខំ ភិក្ខវេ អនាថោ វិហរតិ ។

[១៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ១០ ពួកនេះជាអ្នកគួរទទួលនូវវត្ថុ ដែលគេនាំមកដើម្បីបូជា គួរទទួលវត្ថុដែលគេតាក់តែងដើម្បីទទួលភ្ញៀវ គួរទទួលទានដែលគេជឿកម្មនិងផលរបស់កម្មហើយបូជា គួរឲ្យបុគ្គលដែលត្រូវការដោយកុសល ប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ បុគ្គលទាំង ១០ ពួក តើដូចម្តេច ។ គឺព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ១ ព្រះបច្ចេកសម្ពុទ្ធ ១ ឧភតោ-ភាគវិមុត្តបុគ្គល ១ បញ្ញាវិមុត្តបុគ្គល ១ កាយសក្ខិបុគ្គល ១ ទិដ្ឋិ-ប្បត្តបុគ្គល ១ សទ្ធាវិមុត្តបុគ្គល ១ ធម្មានុសារីបុគ្គល ១ សទ្ធានុសារី-បុគ្គល ១ គោត្រភូបុគ្គល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ១០ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុ ដែលគេនាំមកដើម្បីបូជា ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើរ របស់សត្វលោក ។

[១៧] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គល មានទីពឹង កុំជាបុគ្គល មិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គល មិនមានទីពឹង រមែងនៅជាទុក្ខ ។

ទសយិមេ ភិក្ខវេ នាថករណា ធម្មា ។ កតមេ ទស ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ យម្បិ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។

ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ (ធម៌សម្រាប់ធ្វើឲ្យមានទីពឹង) នេះមាន ១០ យ៉ាង ។ នាថករណធម៌ ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ព្រោះធម៌ណា នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈ ដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌មានសភាព ដូច្នោះ ភិក្ខុនោះក៏ចេះចាំច្រើន បានចាំទុក ចាំជាប់ក្នុងចិត្ត បានចាក់ដុះល្អ ដោយទិដ្ឋិ ។

៤៣



យម្បិ ភិក្ខវេ ភិក្ខុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ យម្បិ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនឹ ។ យម្បិ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនឹ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាពហុស្សូត ។ បេ ។ បានចាក់ធ្លុះល្អ ដោយទិដ្ឋិ ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ ជាអ្នកពត់ខ្លួនតាមមិត្តសំឡាញ់ល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ ជាអ្នកផ្អាកចិត្តទៅតាមមិត្តសំឡាញ់ល្អ ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយផ្ចិតផ្ចង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដែលគេប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយផ្ចិតផ្ចង់ ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើណា ដ៏ខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងអំពើនោះថា គួរធ្វើគួរចាត់ចែងបាន ។

យម្បិ ភិក្ខវេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ ។ បេ ។ អលំ កាតុំ អលំ សំវិធាតុំ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ ។ យម្បិ ភិក្ខវេ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ យម្បិ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា

ម្នាលភិក្ខុទាំងឡាយ អំពើណា ដ៏ខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គលត្រូវសួរគ្នីគ្នា ហើយទើបធ្វើ ភិក្ខុ ។ បេ ។ ថា គួរធ្វើ គួរចាត់ចែង ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាធម៌ ពេញចិត្តនឹងការនិយាយធម៌ មានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម៌និងអភិវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នាធម៌ ពេញចិត្តនឹងការនិយាយធម៌ មានសេចក្តីរីករាយលើសលុប ក្នុងអភិធម៌និងអភិវិន័យ ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ និងញុំាងពួកកុសលធម៌ ឲ្យសម្រេច ជាអ្នកមានកម្លាំង សង្វាតមាំមួន មិនដាក់ចុះនូវធុរៈ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ និងញុំាងកុសលធម៌ ឲ្យសម្រេច ជាអ្នកមានកម្លាំង

ឧប្បន្នបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារេន ។ យម្បិ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារេន អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។ យម្បិ ភិក្ខវេ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិ-តម្បិ សរិតា អនុស្សរិតា អយម្បិ ធម្មោ នាថករណោ ។

សង្ឃាតមាំមួន មិនដាក់ចុះនូវធុរៈ ក្នុងកុសលធម៌ទាំងឡាយ ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ព្រោះហេតុណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតីនិងបញ្ញាដ៏ឧត្តម ជាអ្នករលឹកឃើញ រលឹកតាមនូវអំពើ ដែលធ្វើយូរហើយផង នូវពាក្យ ដែលនិយាយយូរហើយផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នក មានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករលឹកឃើញ រលឹកតាមនូវអំពើ ដែលធ្វើយូរហើយផង នូវពាក្យ ដែលនិយាយយូរហើយផង ព្រោះហេតុណា នេះឯង ជានាថករណធម៌ ១ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ យម្បិ ភិក្ខវេ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា អយម្បិ ធម្មោ នាថករណោ ។ សនាថា ភិក្ខវេ វិហរថ មា អនាថា ទុក្ខំ ភិក្ខវេ អនាថោ វិហរតិ ។ ឥមេ ខោ ភិក្ខវេ ទស នាថករណា ធម្មាតិ ។

[១៨] សនាថា ភិក្ខវេ វិហរថ មា អនាថា ទុក្ខំ ភិក្ខវេ អនាថោ វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើតនិងការរលត់នៃ (ខន្ធ) ដ៏ប្រសើរ ជាប្រាជ្ញាសម្រាប់ទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើតនិងការរលត់នៃ (ខន្ធ) ដ៏ប្រសើរ ជាប្រាជ្ញាសម្រាប់ទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ព្រោះធម៌ណា នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ (ធម៌ជាគ្រឿងធ្វើឲ្យមានទីពឹង) ១០ យ៉ាងនេះឯង ។

[១៨] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានទីពឹង កុំជាបុគ្គល មិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គល មិនមានទីពឹង រមែងនៅជាទុក្ខ ។

ទសយិមេ ភិក្ខវេ នាថករណា ធម្មា ។ កតមេ ទស ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ សីលវា វតាយំ ភិក្ខុ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសូតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។

ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ (ធម៌ជាគ្រឿងធ្វើឲ្យមានទីពឹង) នេះមាន ១០ យ៉ាង ។ នាថករណធម៌ ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយដែរ ។ កាលភិក្ខុនោះដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។

៤៨



បុន ចបរំ ភិក្ខវេ ភិក្ខុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ពហុស្សុតោ វតាយំ ភិក្ខុ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសាន-កល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មន-សានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធាតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុ-កម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ។ បេ ។ បាន ចាក់ធ្លុះល្អដោយទិដ្ឋិ ពួកភិក្ខុជាថេរៈ តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌មានសភាពដូច្នោះ ភិក្ខុនោះក៏បានចេះចាំច្រើន បានចាំទុក ចាំរត់មាត់ ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អ ដោយទិដ្ឋិដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈ អនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយ តែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។

៤៩



បុន ចបរំ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ កល្យាណមិត្តោ វតាយំ ភិក្ខុ កល្យាណសហាយោ កល្យាណសម្បវង្កោតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ ចាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានមិត្តល្អ មានសំឡាញ់ល្អ មានការងាកចិត្ត ទៅតាមមិត្តសំឡាញ់ល្អ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី . . . ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកមានមិត្តល្អ មានសំឡាញ់ល្អ មានការងាកចិត្ត ទៅតាមសំឡាញ់ល្អដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រដៅងាយ ប្រកបដោយធម៌ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយផ្ចិតផ្ចង់

៦០



អនុសាសនី សុវចោ វតាយំ ភិក្ខុ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនិន្តិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។

ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី . . . ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកប្រដៅងាយ ប្រកបដោយធម៌ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយផ្ចិតផ្ចង់ដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយមួយទៀត អំពើណា ដ៏ខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គលត្រូវសួរគ្នីគ្នា ហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបដោយប្រាជ្ញា ជាគ្រឿងពិចារណាដោយឧបាយ ក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបាន ។

បឋមបណ្ណាសកេ   នាថករណវគ្គោ

យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ វតាយំ ភិក្ខុ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធា-តុន្តិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិ-តព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុ-កម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថ-ករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ

ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី . . . ពួកភិក្ខុថ្មីក្តី តែងសម្គាល់ភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ អំពើណា ដ៏ខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នា ហើយទើបធ្វើ ភិក្ខុនេះ ជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបដោយប្រាជ្ញា ជាគ្រឿងពិចារណាដោយឧបាយ ក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបានដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើន កើតប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯងជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាធម៌ មានសេចក្តីពេញចិត្ត ចំពោះការពោលធម៌ មានសេចក្តីរីករាយ ដ៏លើសលុប ក្នុងអភិធម៌ ក្នុងអភិវិន័យ

ធម្មកាមោ វតាយំ ភិក្ខុ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុក-ម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។ បុនចបរំ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អារទ្ធវីរិយោ វតាយំ ភិក្ខុ វិហរតិ អកុ-សលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសូតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។

ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី . . . ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកប្រាថ្នាធម៌ មានសេចក្តីពេញចិត្តចំពោះការពោលធម៌ មានសេចក្តីរីករាយដ៏លើសលុបក្នុងអភិធម៌ក្នុងអភិវិន័យដែរ ។ កាលភិក្ខុនោះដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើន កើតប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ ញ៉ាំងពួកកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំងសង្វាតមាំ មិនដាក់ចុះនូវធុរៈ ក្នុងកុសលធម៌ទាំងឡាយ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ ទាំងញ៉ាំងពួកកុសលធម៌ឲ្យសម្រេច ជាអ្នកមានកម្លាំងសង្វាតមាំ មិនដាក់ចុះនូវធុរៈក្នុងកុសលធម៌ទាំងឡាយដែរ ។

៦៣



តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុ-កម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន សន្តុដ្ឋោ វតាយំ ភិក្ខវេ ឥតរីតរចីវរបិណ្ឌបាតសេនា-សនគិលានប្បច្ចយភេសជ្ជបរិក្ខារេនាតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិ-តព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។

កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយនេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជ-បរិក្ខារតាមមាន តាមបាន ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារដែរ ។ កាលភិក្ខុនោះដែលភិក្ខុជាថេរៈអនុ-គ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។

៦៤



បុន ចបរំ ភិក្ខវេ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា សតិមា វតាយំ ភិក្ខុ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតាតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករលឹកឃើញ រលឹកតាម នូវអំពើដែលធ្លាប់ធ្វើមក យូរហើយផង នូវពាក្យដែលធ្លាប់និយាយមក យូរហើយផង ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់ នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់ នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករលឹកឃើញ រលឹកតាមនូវអំពើដែលធ្លាប់ធ្វើមក យូរហើយផង នូវពាក្យដែលធ្លាប់និយាយមក យូរហើយផង បានដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើនប្រាកដ ក្នុងកុសលធម៌ទាំងឡាយតែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា បញ្ញវា វតាយំ ភិក្ខុ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយាតិ ថេរាបិ នំ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ មជ្ឈិមាបិ ភិក្ខូ ... នវាបិ ភិក្ខូ វត្តព្វំ អនុសាសិតព្វំ មញ្ញន្តិ ។ តស្ស ថេរានុកម្បិតស្ស មជ្ឈិមានុកម្បិតស្ស នវានុកម្បិតស្ស វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ អយម្បិ ធម្មោ នាថករណោ ។ សនាថា ភិក្ខវេ វិហរថ មា អនាថា ទុក្ខំ ភិក្ខវេ អនាថោ វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងដឹងការកើតនិងការរលត់ (ខន្ធ) ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ ជាគ្រឿងអស់ទុក្ខដោយប្រពៃ ពួកភិក្ខុជាថេរៈក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ពួកភិក្ខុជាកណ្តាលក្តី ... ពួកភិក្ខុថ្មីក្តី តែងសម្គាល់នូវភិក្ខុនោះ ថាជាបុគ្គលគួរស្តី គួរប្រៀនប្រដៅ ដោយគិតថា ឱហ្ន៎ ភិក្ខុនេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងដឹងការកើតនិងការរលត់ ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លុះទម្លាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ ជាគ្រឿងអស់ទុក្ខដោយប្រពៃដែរ ។ កាលភិក្ខុនោះ ដែលភិក្ខុជាថេរៈអនុគ្រោះហើយ ដែលភិក្ខុជាកណ្តាលអនុគ្រោះហើយ ដែលភិក្ខុថ្មីអនុគ្រោះហើយ រមែងមានសេចក្តីចម្រើន កើតប្រាកដក្នុងកុសលធម៌ទាំងឡាយ តែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ នេះឯង ជានាថករណធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។

ឥមេ ខោ ភិក្ខវេ ទស នាថករណា ធម្មាតិ ។[១]

[១៩] ទសយិមេ ភិក្ខវេ អរិយាវាសា យេ អរិយា អាវសឹសុ វា អាវសន្តិ វា អាវសិស្សន្តិ វា ។ កតមេ ទស ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេនោ បនុណ្ណប្ប-ច្ចេកសច្ចោ សមវយសដ្ឋេសនោ អនាវិល-សង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តប្បញ្ញោ ។ ឥមេ ខោ ភិក្ខវេ ទស អរិយាវាសា យេ អរិយា អាវសឹសុ វា អាវសន្តិ វា អាវសិស្សន្តិ វាតិ ។

[២០] ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម កុរូនំ និគមោ ។

---

១ ម. ឥតោ បរំ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តីតិ បាឋោ ទិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ (ធម៌ជាគ្រឿងធ្វើឲ្យមានទីពឹង) មាន ១០ យ៉ាងនេះឯង ។

[១៩] ម្នាលភិក្ខុទាំងឡាយ អរិយវាសៈ (ធម៌ជាគ្រឿងអប់រំដ៏ប្រសើរ) នេះ មាន ១០ យ៉ាង ដែលពួកព្រះអរិយៈបានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។ អរិយវាសៈទាំង ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអង្គ ៥ ប្រកបដោយអង្គ ៦ មានគ្រឿងរក្សាចិត្តតែមួយ មានធម៌ជាបង្អែក ៤ បានបន្ទោបង់នូវបច្ចេកសច្ចៈ (សច្ចៈដែលតិរ្ថិយប្រកាន់ប្លែក ៗ គ្នា) បានលះបង់នូវការស្វែងរក ជ្រះស្រឡះហើយ មានការត្រិះរិះ មិនកករល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយ មានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ ។ ម្នាលភិក្ខុទាំងឡាយ អរិយវាសៈ ១០ យ៉ាងនេះឯង ដែលពួកព្រះអរិយៈ បានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។

[២០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគមឈ្មោះកម្មាសធម្មៈ របស់ពួកជនអ្នកដែនកុរុ ជិតដែនកុរុ ។

## ៦៧

### បឋមបណ្ណាសកេ នាថករណវគ្គោ

តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ។ បេ ។ ភគវា ឯតទវោច ទសយិមេ ភិក្ខវេ អរិយវាសា យេ អរិយា អាវសឹសុ វា អាវសន្តិ វា អាវសិស្សន្តិ វា ។ កតមេ ទស ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេនោ បនុណ្ណប្បច្ចេកសច្ចោ សមវយសដ្ឋេសនោ អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តប្បញ្ញោ ។ កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ កាមច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ ថីនមិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ វិចិកិច្ឆា បហីនា ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។

ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមក ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អរិយវាសៈនេះមាន ១០ យ៉ាង ដែលពួកព្រះអរិយៈ បានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។ អរិយវាសៈ ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់នូវអង្គ ៥ ប្រកបដោយអង្គ ៦ មានគ្រឿងរក្សាចិត្តតែមួយ មានធម៌ជាបង្អែក ៤ បានបន្ទោបង់នូវបច្ចេក-សច្ចៈ បានលះបង់នូវការស្វែងរក ជ្រះស្រឡះហើយ មានការត្រិះរិះមិនកករល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយ មានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានលះបង់អង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះកាមច្ឆន្ទៈ បានលះ ព្យាបាទ បានលះ ថីនមិទ្ធៈ បានលះឧទ្ធច្ចកុក្កុច្ចៈ បានលះ វិចិកិច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានលះ អង្គ ៥ យ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឯការក្ខោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុំ សតារក្ខេន ចេតសា សមន្នាគតោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឯការក្ខោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ចតុរាបស្សេនោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៦ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលមានចិត្តព្រងើយ មានស្មារតីដឹងខ្លួនគ្រប់ឥរិយាបថទាំង ៤ បានឮសំឡេងដោយត្រចៀក ។ បេ ។ បានធុំក្លិនដោយច្រមុះ បានជញ្ជក់រសដោយអណ្តាត បានប៉ះផ្សព្វដោយកាយ បានដឹងធម្មារម្មណ៍ដោយចិត្តហើយ មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលមានចិត្តព្រងើយ មានស្មារតី ដឹងខ្លួនគ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៦ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានគ្រឿងរក្សាចិត្តតែមួយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត ដែលមានស្មារតីថែរក្សា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានគ្រឿងរក្សាចិត្តតែមួយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានធម៌ជាបង្អែក ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយ ទើបសេពនូវរបស់ដែលគួរសេព ពិចារណាហើយទើបអត់សង្កត់នូវហេតុដែលគួរអត់សង្កត់ ពិចារណាហើយ ទើបវៀរនូវហេតុដែលគួរវៀរ ពិចារណាហើយ ទើបបន្ទោបង់នូវហេតុដែលគួរបន្ទោបង់ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ ចតុរាបស្សេនោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ យានិ តានិ បុថុសមណព្រាហ្មណានំ បុថុប្បច្ចេកសច្ចានិ សេយ្យថីទំ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា សព្វានិ តានិ នុណ្ណានិ ហោន្តិ បនុណ្ណានិ ចត្តានិ វន្តានិ មុត្តានិ បហីនានិ បដិនិស្សដ្ឋានិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សមវយសដ្ឋេសនោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានធម៌ជាបង្អែក ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានបន្ទោបង់នូវបច្ចេកសច្ចៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បច្ចេកសច្ចៈ ជាច្រើនណា របស់សមណៈនិងព្រាហ្មណ៍ជាច្រើន គឺការប្រកាន់ថា លោកទៀងដូច្នេះខ្លះ លោកមិនទៀងដូច្នេះខ្លះ លោកមានទីបំផុតដូច្នេះខ្លះ លោកមិនមានទីបំផុតដូច្នេះខ្លះ ជីវិតនោះ គឺសរីរៈនោះ ដូច្នេះខ្លះ ជីវិតដទៃ សរីរៈដទៃដូច្នេះខ្លះ សត្វស្លាប់ទៅកើតទៀតដូច្នេះខ្លះ សត្វស្លាប់ទៅមិនកើតទៀតដូច្នេះខ្លះ សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះខ្លះ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះខ្លះ ភិក្ខុក្នុងសាសនានេះ បានបន្ទោបង់ បោះបង់ លះបង់ ខ្ជាក់ចោល លែងចោល លះលែង លះស្រឡះ នូវបច្ចេកសច្ចៈជាច្រើនទាំងអស់នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានបន្ទោបង់នូវបច្ចេកសច្ចៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបានលះបង់ នូវការស្វែងរកជ្រះស្រឡះហើយ តើដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុនោ កាមេសនា បហីនា ហោតិ ភវេ-
សនា បហីនា ហោតិ ព្រហ្មចរិយេសនា បដិប្បស្សទ្ធា ។
ឯវំ ខោ ភិក្ខវេ ភិក្ខុ សមវយសដ្ឋេសនោ ហោតិ ។
កថញ្ច ភិក្ខវេ ភិក្ខុ អនាវិលសង្កប្បោ ហោតិ ។
ឥធ ភិក្ខវេ ភិក្ខុនោ កាមសង្កប្បោ បហីនោ ហោតិ
ព្យាបាទសង្កប្បោ បហីនោ ហោតិ វិហឹសាសង្កប្បោ
បហីនោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អនា-
វិលសង្កប្បោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ
បស្សទ្ធកាយសង្ខារោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ
សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ
សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេ-
ក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។
ឯវំ ខោ ភិក្ខវេ ភិក្ខុ បស្សទ្ធកាយសង្ខារោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់ការស្វែងរកកាម លះបង់ការស្វែងរកភព មានការស្វែងរកនូវព្រហ្មចរិយៈស្ងប់រម្ងាប់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានលះបង់ការស្វែងរក ជ្រះស្រឡះហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានសេចក្តីត្រិះរិះ មិនកករល្អក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានលះបង់សេចក្តីត្រិះរិះ ក្នុងកាម បានលះបង់សេចក្តីត្រិះរិះ ក្នុងការព្យាបាទ បានលះបង់សេចក្តីត្រិះរិះ ក្នុងការបៀតបៀន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះ មិនកករល្អក់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកាយសង្ខារ ស្ងប់រម្ងាប់ហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះអស់ទៅ នៃសោមនស្សនិងទោមនស្ស ក្នុងកាលមុន ក៏បានសម្រេចនូវចតុត្ថជ្ឈាន មិនមែនជាទុក្ខ មិនមែនជាសុខ មានតែសតិ ដ៏បរិសុទ្ធ កើតអំពីឧបេក្ខា ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមានកាយសង្ខារ ស្ងប់រម្ងាប់ យ៉ាងនេះឯង ។

៧១



កថញ្ច ភិក្ខវេ ភិក្ខុ សុវិមុត្តចិត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ ហោតិ ទោសា ចិត្តំ វិមុត្តំ ហោតិ មោហា ចិត្តំ វិមុត្តំ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សុវិមុត្តចិត្តោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សុវិមុត្តប្បញ្ញោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ រាគោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ ទោសោ មេ បហីនោ ។ បេ ។ មោហោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សុវិមុត្តប្បញ្ញោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តផុតស្រឡះហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តផុតស្រឡះចាករាគៈ មានចិត្តផុតស្រឡះ ចាកទោសៈ មានចិត្តផុតស្រឡះ ចាកមោហៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តផុតស្រឡះហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះដឹងច្បាស់ថា អាត្មាអញបានលះបង់រាគៈហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតចុង ធ្វើមិនឲ្យមានបែបភាព ជាសភាពមិនមានការកើតឡើង តទៅទៀតជាធម្មតា ដឹងច្បាស់ថា អាត្មាអញបានលះបង់ ទោសៈហើយ ។ បេ ។ អាត្មាអញ បានលះបង់មោហៈហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតចុង បានធ្វើមិនឲ្យមានបែបភាព ជាសភាពមិនមានការកើតឡើង តទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រាជ្ញាដឹងថា ចិត្តផុតស្រឡះហើយ យ៉ាងនេះឯង ។

យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ អរិយា អរិយាវាសេ អាវសឹសុ សព្វេ តេ ឥមេ វ ទស អរិយាវាសេ អាវសឹសុ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ អរិយា អរិយាវាសេ អាវសិស្សន្តិ សព្វេ តេ ឥមេ វ ទស អរិយាវាសេ អាវសិស្សន្តិ យេ ហិ កេចិ ភិក្ខវេ ឯតរហិ អរិយា អរិយាវាសេ អាវសន្តិ សព្វេ តេ ឥមេ វ ទស អរិយាវាសេ អាវសន្តិ ។ ឥមេ ខោ ភិក្ខវេ ទស អរិយាវាសា យេ អរិយា អាវសឹសុ វា អាវសន្តិ វា អាវសិស្សន្តិ វាតិ ។

នាថករណវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

សេនាសនា ច អង្គា ច[១] សំយោជនខីលេន ច
អប្បមាទោ អាហុនេយ្យោ ទ្វេ នាថា ទ្វេវសេន ចាតិ[២] ។

១ ឱ. ម. អង្គានិ ។ ២ ឱ. ម. អរិយាវាសេន ចាតិ ។ ម. អរិយាវាសា ចាតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកអរិយៈណាមួយ បានអាស្រ័យនៅក្នុងអរិយវាសៈ ក្នុងកាលដែលកន្លងហើយ ពួកអរិយៈទាំងអស់នោះ បានអាស្រ័យនៅ ក្នុងអរិយវាសៈទាំង ១០ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកអរិយៈ ណាមួយ នឹងអាស្រ័យនៅ ក្នុងអរិយវាសៈ ក្នុងកាលដែលមិនទាន់មក ដល់ ពួកអរិយៈទាំងអស់នោះ នឹងអាស្រ័យនៅ ក្នុងអរិយវាសៈទាំង ១០ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកអរិយៈណាមួយ កំពុង អាស្រ័យនៅ ក្នុងអរិយវាសៈ ក្នុងកាលឥឡូវនេះ ពួកអរិយៈទាំងអស់ នោះអាស្រ័យនៅ ក្នុងអរិយវាសៈទាំង ១០ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អរិយវាសៈទាំង ១០ នេះឯង ដែលពួកអរិយៈ បានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ។

ចប់ នាថករណវគ្គទី ២ ។

# ឧទ្ទាននៃនាថករណវគ្គនោះគឺ

និយាយអំពីសេនាសនៈ ១ អំពីអង្គ ១ អំពីសំយោជនៈ ១ អំពីចេតោខីលៈ ១ អំពីអប្បមាទ ១ អំពីអាហុនេយ្យ ១ អំពីនាថករណធម៌មានពីរលើក អំពីអរិយវាសៈមានពីរលើក ។

# តតិយោ មហាវគ្គោ

[២១] សីហោ ភិក្ខវេ មិគរាជា សាយណ្ហសមយំ អាសយា និក្ខមតិ អាសយា និក្ខមិត្វា វិជម្ភតិ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេតិ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទតិ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កមតិ ។ តំ កិស្ស ហេតុ ។ មាហំ ខុទ្ទកេ បាណេ វិសមគតេ សង្ឃាតំ អាបាទេសិន្តិ[១] ។ សីហោតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ យំ ខោ ភិក្ខវេ តថាគតោ បរិសាយ ធម្មំ ទេសេតិ ឥទមស្ស ហោតិ សីហនាទស្មឹ ។ ទសយិមានិ ភិក្ខវេ តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ ទស ។

---

១ ម. អាបាតេសិន្តិ ។

# មហាវគ្គ ទី ៣

[២១] ម្នាលភិក្ខុទាំងឡាយ ក្នុងសាយណ្ហសម័យ សត្វសីហៈជាស្តេចម្រឹគ ចេញពីលំនៅ លុះចេញពីលំនៅហើយ ក៏មិតពត់ខ្លួន លុះមិតពត់ខ្លួនរួចហើយ ក៏ក្រឡេកមៀងមើលទិសទាំង ៤ ជុំវិញ លុះក្រឡេកមៀងមើលទិស ទាំង ៤ ជុំវិញហើយ ក៏បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ទើបចេញទៅរកចំណី ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា សត្វសីហៈគិតថា អាត្មាអញកុំធ្វើពួកសត្វតូច ៗ ដែលដើរទៅរកស៊ីក្នុងទីក្រហេងក្រហូងឲ្យស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា សីហៈនេះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតសម្តែងធម៌ដល់បរិស័ទ ដោយហេតុណា នេះជាសីហនាទ របស់ព្រះតថាគតនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពល របស់ព្រះតថាគតនេះមាន ១០ ប្រការគឺព្រះតថាគត ប្រកបដោយពលៈទាំងឡាយហើយ ទើបប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រ (ចក្រដ៏ប្រសើរ) ឲ្យប្រព្រឹត្តទៅ ។ តថាគតពល ១០ ប្រការ តើដូចម្តេចខ្លះ ។

ឥទ  ភិក្ខវេ  តថាគតោ  ឋានញ្ច  ឋានតោ  អដ្ឋានញ្ច  អដ្ឋានតោ  យថាភូតំ  បជានាតិ  ។  យម្បិ  ភិក្ខវេ  តថាគតោ  ឋានញ្ច  ឋានតោ  អដ្ឋានញ្ច  អដ្ឋានតោ  យថាភូតំ  បជានាតិ  ឥទម្បិ  ភិក្ខវេ  តថាគតស្ស  តថាគតពលំ  ហោតិ  យំ  ពលំ  អាគម្ម  តថាគតោ  អាសភណ្ឌានំ  បដិជានាតិ  បរិសាសុ  សីហនាទំ  នទតិ  ព្រហ្មចក្កំ  បវត្តេតិ  ។  បុន  ចបរំ  ភិក្ខវេ  តថាគតោ  អតីតានាគតប្បច្ចុប្បន្នានំ  កម្មសមាទានានំ  ឋានសោ  ហេតុសោ  វិបាកំ  យថាភូតំ  បជានាតិ  ។  យម្បិ  ភិក្ខវេ  តថាគតោ  អតីតានាគតប្បច្ចុប្បន្នានំ  កម្មសមាទានានំ  ឋានសោ  ហេតុសោ  វិបាកំ  យថាភូតំ  បជានាតិ  ឥទម្បិ  ភិក្ខវេ  តថាគតស្ស  តថាគតពលំ  ហោតិ

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតក្នុងលោកនេះ រមែងជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវហេតុ តាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមឋាន តាមហេតុ ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវវិបាកនៃកុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមឋាន តាមហេតុ ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល របស់ព្រះតថាគត

## ៧៤



យំ ពលំ អាគម្ម តថាគតោ អាសភណ្ឌានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ ភិក្ខវេ តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ ។ យម្បិ ភិក្ខវេ តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឌានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្ម-ចក្កំ បវត្តេតិ ។ បុន ចបរំ ភិក្ខវេ តថាគតោ អនេកធាតុំ នានាធាតុំ[១] លោកំ យថាភូតំ បជានាតិ ។ យម្បិ ភិក្ខវេ តថាគតោ អនេក-ធាតុំ នានាធាតុំ លោកំ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឌានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

---

១ ឱ. ម. អនេកធាតុ នានាធាតុ ។

ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវផ្លូវ ដែលទៅកាន់ទីទាំងពួង ដោយសេចក្ដីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់នូវផ្លូវ ដែលទៅកាន់ទីទាំងពួង ដោយសេចក្ដីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្ដេជ្ញានូវហេតុ ដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវលោក ដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេង ៗ គ្នា ដោយសេចក្ដីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវលោកដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេង ៗ គ្នា ដោយសេចក្ដីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

៧៦



បុន ចបរំ ភិក្ខវេ តថាគតោ សត្តានំ នានា-ធិមុត្តិកតំ យថាភូតំ បជានាតិ ។ យម្បិ ភិក្ខវេ តថាគតោ សត្តានំ នានាធិមុត្តិកតំ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្ម-ចក្កំ បវត្តេតិ ។ បុន ចបរំ ភិក្ខវេ តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ ។ យម្បិ ភិក្ខវេ តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវអធ្យាស្រ័យ ផ្សេង ៗ គ្នា របស់ពួកសត្វ ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំង-ឡាយ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់នូវអធ្យាស្រ័យផ្សេង ៗ គ្នា របស់ពួកសត្វ ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគត-ពលរបស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់របស់ពួកសត្វដទៃ ពួកបុគ្គលដទៃ ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវឥន្ទ្រិយក្លៀវក្លា និងទន់របស់ពួកសត្វដទៃ ពួកបុគ្គលដទៃ ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្តេជ្ញានូវហេតុ ដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

៧៧

បឋមបណ្ណាសកេ មហាវគ្គោ

បុន ចបរំ ភិក្ខវេ តថាគតោ ឈានវិមោក្ខសមាធិ-សមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ ។ យម្បិ ភិក្ខវេ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ ភិក្ខវេ តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវសេចក្តីសៅហ្មងផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ ដោយសេចក្តីជាក់លាក់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវសេចក្តីសៅហ្មង ផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ ដោយសេចក្តីជាក់លាក់ ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល របស់ព្រះតថាគត ព្រោះព្រះតថា-គតអាស្រ័យនឹងពលៈ ហើយប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត រលឹកឃើញជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១.០០០ ជាតិខ្លះ ១០០.០០០ ជាតិខ្លះ រលឹកឃើញបាន ច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ

៧៨



អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិ-សំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ យម្បិ ភិក្ខវេ តថាគតោ អនេកវិ-ហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ

ច្រើនសំវដ្តវិវដ្តកប្បខ្លះថា ក្នុងភពឯណោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ អាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើត ក្នុងភពឯណោះ ដែលទៅកើត ក្នុងភពនោះទៀត អាត្មាអញ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ ទើបមកកើត ក្នុងភពនេះ ។ ព្រះតថាគតរលឹកឃើញជាតិ ដែលបាននៅអាស្រ័យ ក្នុងកាលមុនជាអនេកជាតិព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត រលឹកឃើញជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគត អាស្រ័យនឹងពលៈ ហើយប្ដេជ្ញានូវហេតុ ដ៏ប្រសើរ បន្លឺសីហនាទ

ព្រហ្មចក្កំ បវត្តេតិ ។ បុន ចបរំ ភិក្ខវេ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នា-គតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវា-ទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយ-សុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។

ក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតមានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវពួកសត្វដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ជ្រាបច្បាស់នូវពួកសត្វ ដែលអន្ទោលទៅ តាមកម្មថា អើហ្ន៎ សត្វអម្បាលនេះ ដែលជាអ្នកប្រកប ដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលពួកអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់កម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកខាងសត្វទាំងនេះ ដែលជាអ្នកប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលពួកអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់កម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើត ក្នុងសុគតិ សួគ៌ទេវលោក ។

ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមា-
នុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ
ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ
យថាកម្មូបគេ សត្តេ បជានាតិ ។ យម្បិ ភិក្ខវេ
តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-
មានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ
បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ
ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ
បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ
បវត្តេតិ ។ បុន ចបរំ ភិក្ខវេ តថាគតោ
អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ
ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

ព្រះតថាគតមានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្សធម្មតា ឃើញនូវពួកសត្វ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ជ្រាបច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្សធម្មតា ។ បេ ។ ជ្រាបច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល របស់ព្រះតថាគត ព្រោះ ព្រះតថាគតអាស្រ័យនឹងពលៈហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រះតថាគត បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញា ដ៏ប្រសើរ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។

យម្បិ ភិក្ខវេ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ ឥមានិ ខោ ភិក្ខវេ ទស តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតីតិ ។

[២២] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលព្រះតថាគត បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ប្រសើរ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈ ហើយប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជា តថាគតពល ១០ ប្រការ របស់ព្រះតថាគត ព្រោះព្រះតថាគត ប្រកបដោយពលៈទាំងឡាយ ហើយប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

[២២] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

ឯកាមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច យេ តេ អានន្ទ ធម្មា តេសំ តេសំ អភិមុត្តិបទានំ អភិញ្ញា សច្ឆិកិរិយាយ សំវត្តន្តិ វិសារទោ អហំ អានន្ទ តត្ថ បដិជានាមិ តេសំ តេសំ តថា តថា ធម្មំ ទេសេតុំ យថា យថា បដិបន្នោ សន្តំ វា អត្ថីតិ ញស្សតិ អសន្តំ វា នត្ថីតិ ញស្សតិ ហីនំ វា ហីនន្តិ ញស្សតិ បណីតំ វា បណីតន្តិ ញស្សតិ សឧត្តរំ វា សឧត្តរន្តិ ញស្សតិ អនុត្តរំ វា អនុត្តរន្តិ ញស្សតិ យថា យថា វា បន តំ ញាតយ្យំ វា ទដ្ឋយ្យំ(១) វា សច្ឆិកាតយ្យំ(២) វា តថា តថា ញស្សតិ វា ទក្ខតិ វា សច្ឆិការិស្សតិ វាតិ ឋានមេតំ វិជ្ជតិ ។

---

១ ឱ. ម. ញាតេយ្យំ វា ទិដ្ឋេយ្យំ វា ។ ២ ម. សច្ឆិករេយ្យំ វា ។

លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ធម៌ទាំងឡាយណា ប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអធិមុត្តិបទ[១] ទាំងឡាយនោះ ៗ ដោយប្រាជ្ញា ដ៏ឧត្តម ម្នាលអានន្ទ តថាគតជាអ្នកក្លៀវក្លា ដឹងច្បាស់ ក្នុងអធិមុត្តិ-បទនោះ ៗ អាចសម្ដែងធម៌ដល់ពួកសត្វនោះ ៗ តាមដែលអ្នកប្រតិបត្តិ ហើយនឹងដឹងរបស់ដែលមានថា មាន ក្ដី ដឹងរបស់ដែលមិនមាន ថាមិន មាន ក្ដី ដឹងរបស់ថោកទាបថា ថោកទាប ក្ដី ដឹងរបស់ឧត្តម ថា ឧត្តម ក្ដី ដឹងរបស់ដែលមានរបស់ដទៃប្រសើរជាងថា មានរបស់ ដទៃប្រសើរជាងក្ដី ដឹងរបស់ដែលមិនមានរបស់ដទៃប្រសើរជាងថា មិន មានរបស់ដទៃប្រសើរជាងក្ដី ម្យ៉ាងទៀត របស់នោះ ដែលបុគ្គលត្រូវ ដឹង ឬ ត្រូវឃើញ ឬ ក៏ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយហេតុណា ៗ នឹង ដឹង ឬ នឹងឃើញ ឬ ក៏នឹងធ្វើឲ្យជាក់ច្បាស់ ដោយហេតុនោះ ៗ ហេតុនេះ រមែងមានជាធម្មតា ។ ម្នាលអានន្ទ បណ្ដាសេចក្ដីដឹង ទាំងឡាយ សេចក្ដីដឹងតាមពិត ក្នុងធម៌នោះ ៗ ណាមួយ សេចក្ដីដឹង តាមពិតនុ៎ះ ឈ្មោះថា មិនមានសេចក្ដីដឹងដទៃ ប្រសើរជាង ។

១ - ធម៌ គឺ ខន្ធ អាយតនៈ ធាតុ នឹងសំដៅដល់ទិដ្ឋិ ( អដ្ឋកថា ) ។

៨៣

បឋមបណ្ណាសកេ មហាវគ្គោ

ឯតទានុត្តរិយំ អានន្ទ ញាណានំ យទិទំ តត្ថ តត្ថ យថាភូតញ្ញាណំ ។ ឯតស្មា ចាហំ អានន្ទ ញាណា អញ្ញំ ញាណំ ឧត្តរិតរំ វា បណីតតរំ វា នត្ថីតិ វទាមិ ។ ទសយិមានិ អានន្ទ តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថា-គតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ ទស ។ ឥធានន្ទ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ។ យម្បានន្ទ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ។ ឥទម្បានន្ទ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

ម្នាលអានន្ទ មួយទៀត តថាគតសម្តែងថា ញាណដទៃលើសលុប ឬ ថ្លៃថ្លាជាងញាណនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ តថាគតពល របស់ព្រះតថាគតនេះ មាន ១០ ប្រការ ព្រោះព្រះតថាគត ប្រកបដោយពលៈទាំងឡាយ ហើយទើបប្តេជ្ញានូវហេតុ ដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ចុះ តថាគតពល ១០ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ ព្រះតថាគត ក្នុងលោកនេះ ជ្រាបច្បាស់នូវហេតុ តាមហេតុផង ជ្រាបច្បាស់នូវអំពើ មិនមែនជាហេតុ តាមអំពើ មិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់នូវហេតុ តាមហេតុផង ជ្រាបច្បាស់នូវអំពើ ដែលមិនមែនជាហេតុ តាមអំពើដែលមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ នេះជាតថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគត អាស្រ័យនឹងពលៈ ហើយប្តេជ្ញានូវហេតុ ដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

បុន ចបរំ អានន្ទ តថាគតោ អតីតានាគតប្បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ អនេកធាតុំ នានាធាតុំ លោកំ យថាភូតំ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ សត្តានំ នានាធិមុត្តិកតំ យថាភូតំ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។

ម្នាលអានន្ទ មួយទៀត ព្រះតថាគតជ្រាបច្បាស់នូវវិបាកនៃកុសល-កម្មនិងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត អនាគត និងបច្ចុប្បន្ន តាមឋាក់ តាមហេតុ ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវផ្លូវ ដែលទៅកាន់ទីទាំងពួង ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវលោក ដែលមានធាតុច្រើនយ៉ាង មានធាតុផ្សេង ៗ គ្នា ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវអធ្យាស្រ័យផ្សេង ៗ គ្នា របស់សត្វទាំងឡាយ ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវឥន្ទ្រិយក្លៀវក្លានិងទន់ របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។

បុន ចបរំ អានន្ទ តថាគតោ ឈានវិមោក្ខសមា-ធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ យម្បានន្ទ ។ បេ ។ ឥទម្បានន្ទ ។ បេ ។ បុន ចបរំ អានន្ទ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

ម្នាលអានន្ទ មួយទៀត ព្រះតថាគត ជ្រាបច្បាស់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ ដោយសេចក្តីជាក់លាក់ ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគត រលឹកឃើញនូវជាតិ ដែលបាននៅអាស្រ័យក្នុងកាលមុន ជាអនេកជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវជាតិ ដែលធ្លាប់នៅអាស្រ័យហើយ ក្នុងកាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយទៀត ព្រះតថាគត មានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្សធម្មតា ។ បេ ។ ជ្រាបច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ។ ម្នាលអានន្ទ ត្រង់ដែល ។ បេ ។ ម្នាលអានន្ទ នេះជា ។ បេ ។ ម្នាលអានន្ទ មួយវិញទៀត ព្រះតថាគត បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។

យម្បានន្ទ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បានន្ទ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ ឥមានិ ខោ អានន្ទ ទស តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតីតិ ។

[២៣] អត្ថិ ភិក្ខវេ ធម្មា កាយេន បហាតព្វា នោ វាចាយ អត្ថិ ភិក្ខវេ ធម្មា វាចាយ បហាតព្វា នោ កាយេន អត្ថិ ភិក្ខវេ ធម្មា នេវ កាយេន បហាតព្វា នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វា ។

ម្នាលអានន្ទ ត្រង់ដែលព្រះតថាគតធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោ-វិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំង-ឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលអានន្ទ នេះជា តថាគតពល របស់ព្រះតថាគត ព្រោះព្រះតថាគតអាស្រ័យនឹងពលៈហើយប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលអានន្ទ នេះជា តថាគតពលរបស់ព្រះតថាគតទាំង ១០ ប្រការ ព្រោះ ព្រះតថាគតប្រកបដោយពលៈទាំងឡាយ ហើយប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

[២៣] ម្នាលភិក្ខុទាំងឡាយ ពួកធម៌ ដែលបុគ្គលគប្បីលះដោយកាយ មិនបាច់វាចាក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកធម៌ ដែលបុគ្គលគប្បីលះ ដោយវាចា មិនបាច់កាយ ក៏មាន ម្នាលភិក្ខុទាំងឡាយ ពួកធម៌ ដែលបុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះដោយវាចា គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាក៏មាន ។

## ៨៧



កតមេ ច ភិក្ខវេ ធម្មា កាយេន បហាតព្វា នោ វាចាយ ។ ឥធ ភិក្ខវេ ភិក្ខុ អកុសលំ អាបន្នោ ហោតិ កញ្ចិទេវ ទេសំ កាយេន ។ តមេនំ អនុវិច្ច វិញ្ញូ សព្រហ្មចារី ឯវមាហំសុ អាយស្មា ខោ អកុសលំ អាបន្នោ កញ្ចិទេវ ទេសំ កាយេន សាធុ វតាយស្មា កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតូតិ ។ សោ អនុវិច្ច វិញ្ញូហិ សព្រហ្មចារីហិ វុច្ចមានោ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា កាយេន បហាតព្វា នោ វាចាយ ។ កតមេ ច ភិក្ខវេ ធម្មា វាចាយ បហាតព្វា នោ កាយេន ។ ឥធ ភិក្ខវេ ភិក្ខុ អកុសលំ អាបន្នោ ហោតិ កញ្ចិទេវ ទេសំ វាចាយ ។

ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ ដែលបុគ្គលគប្បីលះ ដោយកាយ មិនបាច់វាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសល ដោយកាយ ។ ពួកវិញ្ញូជន ជាសព្រហ្មចារី ដៀងមើលរឿយ ៗ នូវភិក្ខុនោះហើយ និយាយ យ៉ាងនេះថា លោកដ៏មានអាយុ បានត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសល ដោយកាយហើយ លោកដ៏មានអាយុ ចូរលះកាយទុច្ចរិត ហើយចម្រើនកាយសុចរិត ឲ្យត្រឹមត្រូវឡើង ។ កាលពួកវិញ្ញូជន ជាសព្រហ្មចារី ដៀងមើលរឿយ ៗ ហើយស្តីថា ភិក្ខុនោះក៏លះកាយទុច្ចរិត ហើយចម្រើនកាយសុចរិតទៅ ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា ធម៌ដែលបុគ្គលគប្បីលះ ដោយកាយ មិនបាច់វាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ ដែលបុគ្គលគប្បីលះ ដោយវាចា មិនបាច់កាយ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសល ដោយវាចា ។

តមេនំ អនុវិច្ច វិញ្ញូ សព្រហ្មចារី ឯវមាហំសុ អាយស្មា ខោ អកុសលំ អាបន្នោ កញ្ចិទេវ ទេសំ វាចាយ សាធុ វតាយស្មា វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតូតិ ។ សោ អនុវិច្ច វិញ្ញូហិ សព្រហ្មចារីហិ វុច្ចមានោ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា វាចាយ បហាតព្វា នោ កាយេន ។ កតមេ ច ភិក្ខវេ ធម្មា នេវ កាយេន បហាតព្វា នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វា ។ លោភោ ភិក្ខវេ នេវ កាយេន បហាតព្វោ នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វោ ។ ទោសោ ភិក្ខវេ... មោហោ ភិក្ខវេ... កោធោ ភិក្ខវេ... ឧបនាហោ ភិក្ខវេ... មក្ខោ ភិក្ខវេ... បឡាសោ ភិក្ខវេ... មច្ឆរិយំ ភិក្ខវេ នេវ កាយេន បហាតព្វំ នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វំ ។

ពួកវិញ្ញូជន ជាសព្រហ្មចារី ដៀងមើលរឿយ ៗ នូវភិក្ខុនោះ ហើយនិយាយ យ៉ាងនេះថា លោកដ៏មានអាយុ បានត្រូវនូវចំណែកនៃអាបត្តិណាមួយ ជាអកុសល ដោយវាចាហើយ លោកដ៏មានអាយុ ចូរលះវចីទុច្ចរិត ហើយចម្រើនវចីសុចរិតឲ្យត្រឹមត្រូវឡើង ។ កាល ពួកវិញ្ញូជន ជាសព្រហ្មចារី ដៀងមើលរឿយ ៗ ហើយស្តីថា ភិក្ខុនោះក៏លះវចីទុច្ចរិត ហើយចម្រើនវចីសុចរិតទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលបុគ្គលគប្បីលះ ដោយវាចា មិនបាច់កាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ ដែលបុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះ ដោយវាចា គប្បីលះចេញព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈ បុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះដោយវាចាទេ គប្បីលះចេញព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ទោសៈ... ម្នាលភិក្ខុទាំងឡាយ មោហៈ... ម្នាលភិក្ខុទាំងឡាយ កោធៈ... ម្នាលភិក្ខុទាំងឡាយ ឧបនាហៈ... ម្នាលភិក្ខុទាំងឡាយមក្ខៈ... ម្នាលភិក្ខុទាំងឡាយ បលាសៈ... ម្នាលភិក្ខុទាំងឡាយ មច្ឆរិយៈ បុគ្គលមិនគប្បីលះដោយកាយ មិនគប្បីលះដោយវាចា គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។

៨៩



ចាបិកា ភិក្ខវេ ឥស្សា នេវ កាយេន បហាតព្វា នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វា ។ កាតមា ច ភិក្ខវេ ចាបិកា ឥស្សា ។ ឥធ ភិក្ខវេ ឥជ្ឈតិ គហបតិស្ស វា គហបតិបុត្តស្ស វា ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា ។ តត្រញ្ញតរស្ស ទាសស្ស វា ឧបវាសស្ស វា ឯវំ ហោតិ អហោ វតិមស្ស គហបតិស្ស វា គហបតិបុត្តស្ស វា ន ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វាតិ ។ សមណោ វា បន ព្រាហ្មណោ វា លាភី ហោតិ ចីវរបិណ្ឌចាតសេនាសនគិលានប្បច្ចយកេសជ្ជបរិក្ខារានំ ។ តត្រញ្ញតរស្ស សមណស្ស វា ព្រាហ្មណស្ស វា ឯវំ ហោតិ អហោ វត អយមាយស្មា ន លាភី អស្ស ចីវរបិណ្ឌចាតសេនាសនគិលានប្បច្ចយកេសជ្ជ-បរិក្ខារានន្តិ ។ អយំ វុច្ចតិ ភិក្ខវេ ចាបិកា ឥស្សា ។

ម្នាលភិក្ខុទាំងឡាយ ឥស្សា ដ៏លាមក បុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះ ដោយវាចាទេ គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ចុះឥស្សា ដ៏លាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គហបតី ឬគហបតិបុត្ត ក្នុងលោកនេះ បរិបូណ៌ ដោយទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី ។ ខ្ញុំកំដរ ឬ អ្នកដែលនៅជុំរកកោនណាមួយ មានសេចក្តីប្រណែន នឹងគហបតី ឬគហបតិបុត្តនោះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យគហបតី ឬ គហបតិបុត្តនេះ បានបរិបូណ៌ដោយទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី ដូច្នេះឡើយ ។ ចំណែកខាង សមណៈឬព្រាហ្មណ៍វិញ ដែលជាអ្នកបាននូវចីវរបិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ សមណៈឬព្រាហ្មណ៍ណាមួយ មានសេចក្តីប្រណែននឹងសមណៈ ឬព្រាហ្មណ៍នោះ យ៉ាងនេះថា ធ្វើដូចម្តេច ហ្ន៎ កុំឲ្យលោកដ៏មានអាយុនេះ បានចីវរបិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥស្សា ដ៏លាមក ។

ចាបិកា ភិក្ខវេ ឥស្សា នេវ កាយេន បហាតព្វា នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វា ។ ចាបិកា ភិក្ខវេ ឥច្ឆា នេវ កាយេន បហាតព្វា នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វា ។ កតមា ច ភិក្ខវេ ចាបិកា ឥច្ឆា ។ ឥធ ភិក្ខវេ ឯកច្ចោ អស្សទ្ធោ សមានោ សទ្ធោតិ មំ ជានេយ្យុន្តិ ឥច្ឆតិ ទុស្សីលោ សមានោ សីលវាតិ មំ ជានេយ្យុន្តិ ឥច្ឆតិ អប្បស្សុតោ សមានោ ពហុស្សុតោតិ មំ ជានេយ្យុន្តិ ឥច្ឆតិ សង្គណិការាមោ សមានោ បវិវិត្តោតិ មំ ជានេយ្យុន្តិ ឥច្ឆតិ កុសីតោ សមានោ អារទ្ធវីរិយោតិ មំ ជានេយ្យុន្តិ ឥច្ឆតិ មុដ្ឋស្សតិ

ម្នាលភិក្ខុទាំងឡាយ ឥស្សា ដ៏លាមក បុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះ ដោយវាចាទេ គប្បីលះចេញ ព្រោះឃើញជាក់ស្តែងដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ឥច្ឆា ដ៏លាមក បុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះ ដោយវាចាទេ គប្បីលះចេញ ព្រោះឃើញជាក់ស្តែង ដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ ចុះឥច្ឆា ដ៏លាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាបុគ្គលមិនមានសទ្ធា តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជា អ្នកមានសទ្ធា ជាបុគ្គលទ្រុស្តសីល តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជាអ្នកមានសីល ជាបុគ្គលចេះដឹងតិច តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថា ជាអ្នកចេះដឹងច្រើន ជាបុគ្គលត្រេកអរ ក្នុងការច្រូកច្របល់ ដោយគ្នីគ្នា តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថា ជាអ្នកស្ងាត់កាយ ជាបុគ្គលខ្ជិល តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថា ជាអ្នកមានប្រារព្ធព្យាយាម ជាបុគ្គលភ្លេចភ្លាំងស្មារតី

សមានោ ឧបដ្ឋិតស្សតីតិ មំ ជានេយ្យុន្តិ ឥច្ឆតិ អសមាហិតោ សមានោ សមាហិតោតិ មំ ជានេយ្យុន្តិ ឥច្ឆតិ ទុប្បញ្ញោ សមានោ បញ្ញវាតិ មំ ជានេយ្យុន្តិ ឥច្ឆតិ អខីណាសវោ សមានោ ខីណាសវោតិ មំ ជានេយ្យុន្តិ ឥច្ឆតិ ។ អយំ វុច្ចតិ ភិក្ខវេ បាបិកា ឥច្ឆា ។ បាបិកា ភិក្ខវេ ឥច្ឆា[១] នេវ កាយេន បហាតព្វា នោ វាចាយ បញ្ញាយ ទិស្វា ទិស្វា បហាតព្វា ។ តញ្ចេ ភិក្ខវេ ភិក្ខុំ លោភោ អភិភុយ្យ ឥរិយតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បលាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា អភិភុយ្យ ឥរិយតិ សោ ឯវមស្ស វេទិតព្វោ ន អយមាយស្មា តថា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហីមំ អាយស្មន្តំ លោភោ អភិភុយ្យ ឥរិយតិ ។

១ ម. ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា ។

តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថា ជាអ្នកមានស្មារតីតាំងមាំ ជាបុគ្គលមិនបានសមាធិ តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជាអ្នកបានសមាធិ ជាបុគ្គលអប្បប្រាជ្ញា តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជាអ្នកមានប្រាជ្ញា ជាបុគ្គលមិនទាន់អស់អាសវៈ តែប្រាថ្នាថា អ្នកផង គប្បីស្គាល់អញថាជាអ្នក អស់អាសវៈហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥច្ឆា ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ ឥច្ឆា ដ៏លាមក បុគ្គលមិនគប្បីលះ ដោយកាយ មិនគប្បីលះ ដោយវាចាទេ គប្បីលះចេញព្រោះឃើញជាក់ស្តែង ដោយប្រាជ្ញាបាន ។ ម្នាលភិក្ខុទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈមិនកើតមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោភៈ មកគ្របសង្កត់ លោកដ៏មានអាយុនេះបាន ។

ន អយមាយស្មា តថា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា ន ហោតិ តថាហិមំ អាយស្មន្តំ បាបិកា ឥច្ឆា អភិភុយ្យ ឥរិយតិ ។ តញ្ច ភិក្ខវេ ភិក្ខុំ លោភោ នាភិភុយ្យ ឥរិយតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា នាភិភុយ្យ ឥរិយតិ សោ ឯវមស្ស វេទិតព្វោ តថា អយមាយស្មា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហិមំ អាយស្មន្តំ លោភោ នាភិភុយ្យ ឥរិយតិ ។ តថា អយមាយស្មា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ

ទោសៈមិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ ទើប ឥច្ឆា ដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះបាន ។ ម្នាលភិក្ខុទាំងឡាយ បើលោកៈមិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនគ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមាន ដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះក៏ដឹងច្បាស់ យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោភៈមិនគ្របសង្កត់លោកដ៏មានអាយុនេះបាន ។ ទោសៈ មិនមាន ដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ ដឹងច្បាស់យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ

បាបិកា ឥស្សា បាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ បាបិកា ឥច្ឆា នាភិភុយ្យ ឥរិយតីតិ ។

[២៨] ឯកំ សមយំ អាយស្មា មហាចុន្ទោ ចេតីសុ វិហរតិ សហជាតិយំ ។ តត្រ ខោ អាយស្មា មហាចុន្ទោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាចុន្ទស្ស បច្ចស្សោសុំ ។ អាយស្មា មហាចុន្ទោ ឯតទវោច ញាណវាទំ អាវុសោ ភិក្ខុ វទមានោ ជានាមីមំ ធម្មំ បស្សាមីមំ ធម្មន្តិ ។ តញ្ចេ អាវុសោ ភិក្ខុំ លោភោ អភិភុយ្យ តិដ្ឋតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ សោ ឯវមស្ស វេទិតព្វោ ន អយមាយស្មា តថា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហីមំ អាយស្មន្តំ លោភោ អភិភុយ្យ តិដ្ឋតិ ។

ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជា ឥច្ឆា ដ៏លាមក មិនគ្របសង្កត់លោក ដ៏មានអាយុនេះបាន ។

[២៤] សម័យមួយ ព្រះមហាចុន្ទៈដ៏មានអាយុ គង់ក្នុងប្រទេសឈ្មោះសហជាតិ ក្នុងដែនចេតី ។ ក្នុងទីនោះឯង ព្រះមហាចុន្ទៈដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោ ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យ របស់ព្រះមហាចុន្ទ ដ៏មានអាយុថា ម្នាលអាវុសោ ។ ព្រះមហាចុន្ទៈដ៏មានអាយុ មានថេរវាចា ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនិយាយនូវញាណវាទថា ខ្ញុំដឹងធម៌នេះ ខ្ញុំឃើញធម៌នេះ ។ ម្នាលអាវុសោទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោភៈ គ្របសង្កត់លោក ដ៏មានអាយុនេះ ។

ន អយមាយស្មា តថា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា ន ហោតិ តថាហិមំ អាយស្មន្តំ បាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ ។ ភាវនាវាទំ អាវុសោ ភិក្ខុ វទមានោ ភាវិតកាយោម្ហិ ភាវិតសីលោ ភាវិតចិត្តោ ភាវិតប្បញ្ញោតិ ។ តញ្ចេ អាវុសោ ភិក្ខុំ លោភោ អភិភុយ្យ តិដ្ឋតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ សោ ឯវមស្ស វេទិតព្វោ ន អយមាយស្មា តថា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហិមំ អាយស្មន្តំ លោភោ អភិភុយ្យ តិដ្ឋតិ ។

ទោសៈ មិនមាន ដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយភាវនា-វាទថា ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើលោកៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោកៈមិនមានដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោកៈគ្របសង្កត់ លោកដ៏មានអាយុនេះ ។

ន អយមាយស្មា តថា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ ចាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ ។ ញាណាវានញ្ច អាវុសោ ភិក្ខុ វេទមានោ ភាវេនាវានញ្ច ជានាមីមំ ធម្មំ បស្សាមីមំ ធម្មំ ភាវិតកាយោម្ហិ ភាវិតសីលោ ភាវិតចិត្តោ ភាវិតប្បញ្ញោតិ ។ តញ្ចេ អាវុសោ ភិក្ខុំ លោភោ អភិភុយ្យ តិដ្ឋតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ សោ ឃវេមស្ស វេទិតព្វោ ន អយមាយស្មា តថា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហីមំ អាយស្មន្តំ លោភោ អភិភុយ្យ តិដ្ឋតិ ។

ទោសៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុ អ្នកនិយាយនូវញាណវាទ និងភាវនាវាទ ថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើលោកៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆ-រិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោកៈ គ្របសង្កត់លោកដ៏មានអាយុនេះ ។

ន អយមាយស្មា តថា បជាជាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ ចាបិកា ឥច្ឆា អភិកុយ្យ តិដ្ឋតិ ។ សេយ្យថាបិ អាវុសោ បុរិសោ ទឡ្ហិក្ខោរ សមានោ អឌ្ឍវាធំ វទេយ្យ អធនោរ សមានោ ធនវាធំ[១] វទេយ្យ អភោគវារ សមានោ ភោគវាធំ[២] វទេយ្យ សោ កិស្មិញ្ចិទេវ ធនករណីយេ សមុប្បន្នេ ន សក្កុណេយ្យ ឧបនីហាតុំ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា តមេធំ ឃរំ ជានេយ្យុំ ទឡ្ហិក្ខោរ អយមាយស្មា សមានោ អឌ្ឍវាធំ វទេតិ អធនោរ អយមាយស្មា សមានោ ធនវាធំ វទេតិ អភោគវារ អយមាយស្មា សមានោ ភោគវាធំ វទេតិ ។

---

១ ម. ធនវា វាទំ ។ ២ ម. អភោគោរ សមានោ ភោគវា វាទំ ។

ទោសៈមិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមានហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសកម្សត់ តែអួតថា អ្នកស្តុកស្តម្ភ ជាអ្នកឥតទ្រព្យ តែអួតថា អ្នកមានទ្រព្យ ជាអ្នកឥតភោគៈ តែអួតថា ជាអ្នកមានភោគៈ កាលបើមានករណីយកិច្ចដែលត្រូវធ្វើ ដោយទ្រព្យណាមួយ កើតឡើងហើយ បុរសនោះ មិនអាចប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី បានឡើយ អ្នកផងត្រូវដឹងបុរសនោះ យ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកកម្សត់សោះ តែអួតថា អ្នកស្តុកស្តម្ភ អ្នកដ៏មានអាយុនេះ ឥតទ្រព្យសោះ តែអួតថា អ្នកមានទ្រព្យ អ្នកដ៏មានអាយុនេះ ជាអ្នកឥតភោគៈសោះ តែអួតថា អ្នកមានភោគៈ ។

តំ កិស្ស ហេតុ ។ តថា ហិ អយមាយស្មា កិស្មិញ្ចិទេវ ធនករណីយេ សមុប្បន្នេ ន សក្កោតិ ឧបនីហាតុំ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វាតិ ។ ឯវមេវ ខោ អាវុសោ ញាណវាទញ្ច ភិក្ខុ វទមានោ ភាវនាវាទញ្ច ជានាមិមំ ធម្មំ បស្សាមិមំ ធម្មំ ភាវិតកាយោម្ហិ ភាវិតសីលោ ភាវិតចិត្តោ ភាវិតបញ្ញោតិ តញ្ច អាវុសោ ភិក្ខុំ លោភោ អភិភុយ្យ តិដ្ឋតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ សោ ឯវមស្ស វេទិតព្វោ ន អយមាយស្មា តថា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហិមំ អាយស្មន្តំ លោភោ អភិភុយ្យ តិដ្ឋតិ ។ ន អយមាយស្មា តថា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ

ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កាលបើកិច្ចដែលត្រូវធ្វើ ដោយទ្រព្យណាមួយ កើតឡើងហើយ អ្នកដ៏មានអាយុនេះមិនអាច ដើម្បីប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តីបានឡើយ យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយនូវញាណវាទ និងភាវនាវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ម្នាលអាវុសោទាំងឡាយ បើលោភៈគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក គ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ ហេតុដូច្នោះ បានជាលោភៈគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈមិនមានដល់បុគ្គល ដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ មិនដឹងច្បាស់យ៉ាងនោះទេ មោហៈ កោធៈ ឧបនាហៈ មក្ខៈ

បលាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ ចាបិកា ឥច្ឆា អភិកុយ្យ តិដ្ឋតិ ។ ញាណាវាជំ អាវុសោ ភិក្ខុ វេទមានោ ជាជាមីមំ ជម្មំ បស្សាមីមំ ជម្មន្តិ ។ តញ្ចេ អាវុសោ ភិក្ខុំ លោភោ ជាភិកុយ្យ តិដ្ឋតិ ទោសោ មោហោ កោជោ ឧបជាហោ មក្ខោ បលាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ជាភិកុយ្យ តិដ្ឋតិ សោ ឯវមស្ស វេទិតព្វោ តថា អយមាយស្មា បជាជាតិ យថា បជានតោ លោភោ ន ហោតិ តថាហីមំ អាយស្មន្តំ លោភោ ជាភិកុយ្យ តិដ្ឋតិ ។ តថា អយមាយស្មា បជាជាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោជោ ឧបជាហោ មក្ខោ បលាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ ចាបិកា ឥច្ឆា ជាភិកុយ្យ តិដ្ឋតិ ។

បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក គ្របសង្កត់លោកដ៏មានអាយុនេះ យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយនូវញាណវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ។ ម្នាលអាវុសោទាំងឡាយ បើលោកៈ មិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆាដ៏លាមក មិនគ្របសង្កត់ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោកៈ មិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆាដ៏លាមក មិនគ្របសង្កត់លោកដ៏មានអាយុនេះ ។

៩៩



ភាវនាវាទំ អាវុសោ ភិក្ខុ វទមានោ ភាវិតកាយោម្ហិ ភាវិតសីលោ ភាវិតចិត្តោ ភាវិតប្បញ្ញោតិ ។ តញ្ចេ អាវុសោ ភិក្ខុំ លោភោ អភិភុយ្យ តិដ្ឋតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បលាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ សោ ឯវមស្ស វេទិតព្វោ តថា អយមាយស្មា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហិមំ អាយស្មន្តំ លោភោ អភិភុយ្យ តិដ្ឋតិ ។ តថា អយមាយស្មា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បលាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា ន ហោតិ តថាហិមំ អាយស្មន្តំ បាបិកា ឥច្ឆា អភិភុយ្យ តិដ្ឋតិ ។ ញាណវាទញ្ច អាវុសោ ភិក្ខុ វទមានោ ភាវនាវាទញ្ច ជានាមិមំ ធម្មំ បស្សាមិមំ ធម្មំ ភាវិតកាយោម្ហិ ភាវិតសីលោ ភាវិតចិត្តោ ភាវិតប្បញ្ញោតិ ។

ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយនូវការនាវាទថា ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើលោភៈមិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនគ្របសង្កត់ទេ ភិក្ខុនោះ អ្នកទាំងឡាយ គប្បីដឹងយ៉ាងនេះថា លោភៈមិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់ យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោភៈ មិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់ យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សាដ៏លាមក ឥច្ឆាដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក មិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុនិយាយនូវញាណវាទ និងការនាវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។

១០០



តញ្ច អាវុសោ ភិក្ខុំ លោភោ ជាភិភុយ្យ តិដ្ឋតិ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា ជាភិភុយ្យ តិដ្ឋតិ សោ ឯវមស្ស វេទិតព្វោ តថា អយមាយស្មា បជានាតិ យថា បជានតោ លោភោ ន ហោតិ តថាហីមំ អាយស្មន្តំ លោភោ ជាភិភុយ្យ តិដ្ឋតិ ។ តថា អយមាយស្មា បជានាតិ យថា បជានតោ ទោសោ ន ហោតិ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ មច្ឆរិយំ បាបិកា ឥស្សា បាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ បាបិកា ឥច្ឆា ជាភិភុយ្យ តិដ្ឋតិ ។ សេយ្យថាបិ អាវុសោ បុរិសោ អឌ្ឍោវ សមានោ អឌ្ឍវាទំ វទេយ្យ ធនវាវ សមានោ ធនវាទំ វទេយ្យ ភោគវាវ សមានោ ភោគវាទំ វទេយ្យ សោ កិស្មិញ្ចិទេវ ធនករណី-យេ សមុប្បន្នេ សក្កុណេយ្យ ឧបនីហាតុំ ធនំ វា

ម្នាលអាវុសោទាំងឡាយ បើលោកៈ មិនគ្របសង្កត់ភិក្ខុនោះទេ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនគ្របសង្កត់ទេ ភិក្ខុនោះ អ្នកទាំងឡាយគប្បីដឹងយ៉ាងនេះថា លោកៈ មិនមានដល់បុគ្គលដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ ហេតុដូច្នោះ បានជាលោកៈមិនគ្របសង្កត់លោកដ៏មានអាយុនេះ ។ ទោសៈ មិនមានដល់បុគ្គល ដែលដឹងច្បាស់ យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់ យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក មិនគ្របសង្កត់លោកដ៏មានអាយុនេះបានឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាបុរសស្តុកស្តម្ភមែន ហើយនិយាយថា អ្នកស្តុកស្តម្ភ អ្នកមានទ្រព្យមែន ហើយនិយាយថា អ្នកមានទ្រព្យ អ្នកមានភោគៈមែន ហើយនិយាយថា អ្នកមានភោគៈ កាលបើកិច្ចដែលត្រូវធ្វើ ដោយទ្រព្យណាមួយ កើតឡើងហើយ បុរសនោះ ក៏អាចប្រមូលមក នូវទ្រព្យក្តី

ជញ្ញំ វា វេជតំ វា ជាតរូបំ វា តមេនំ ឯវំ ជានេ-
យ្យុំ អឡ្លោវ អយមាយស្ន សមាដោ អឡ្បវាជំ
វេទេតិ ជនវាវ អយមាយស្ន សមាដោ ជនវាជំ
វេទេតិ ភោតវាវ អយមាយស្ន សមាដោ ភោតវាជំ
វេទេតិ ។ តំ កិស្ស ហេតុ ។ តថា ហិ អយមា-
យស្ន កិស្មិញ្ចិនេវ ជនការណីយេ សមុប្បន្នេ
សក្កោតិ ឧបនីហាតុំ ជនំ វា ជញ្ញំ វា វេជតំ វា
ជាតរូបំ វាតិ ។ ឯវមេវ ខោ អាវុសោ ញាណវា-
ទញ្ចូ ភិក្ខុ វេទមាដោ ភាវដាវាទញ្ចូ ជាដាមីមំ ជម្មំ
បស្សាមីមំ ជម្មំ ភាវិតកាយោម្ហិ ភាវិតសីលោ
ភាវិតចិត្តោ ភាវិតប្បញ្ញោតិ ។ តញ្ចេ អាវុសោ
ភិក្ខុំ លោភោ ដាភិភុយ្យ តិដ្ឋតិ ដោសោ
មោហោ កោដោ ឧបដាហោ មក្ខោ បលាសោ
មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ដាភិភុយ្យ
តិដ្ឋតិ សោ ឯវមស្ស វេទិតញ្ចោ តថា អយមាយស្ន
បជាដាតិ យថា បជានតោ លោភោ ន ហោតិ

ស្រូវក្តី ប្រាក់ក្តី មាសក្តី អ្នកផង ត្រូវដឹងបុរសនោះយ៉ាង នេះថា អ្នកដ៏មានអាយុនេះ ជាអ្នកស្តុកស្តម្ភមែន ហើយនិយាយថា អ្នកស្តុកស្តម្ភ អ្នកដ៏មានអាយុនេះ ជាអ្នកមានទ្រព្យមែន និយាយថា អ្នកមានទ្រព្យ អ្នកដ៏មានអាយុនេះ ជាអ្នកមានភោគៈមែន និយាយថា អ្នកមានភោគៈ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កាលបើ កិច្ចដែលខ្លួនត្រូវធ្វើ ដោយទ្រព្យណាមួយ កើតឡើងហើយ អ្នកដ៏មានអាយុនេះ ក៏អាចប្រមូលមកនូវទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តីបាន យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ កាលភិក្ខុ និយាយអួតញាណវាទនិងភាវនាវាទថា ខ្ញុំដឹងធម៌នេះ ឃើញធម៌នេះ ខ្ញុំជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនចិត្ត បានចម្រើនប្រាជ្ញាហើយ ។ ម្នាលអាវុសោទាំងឡាយ បើជាលោភៈ មិនគ្របសង្កត់ភិក្ខុនោះ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆាដ៏លាមក មិនគ្របសង្កត់ទេ ភិក្ខុនោះអ្នកទាំងឡាយគប្បីដឹងយ៉ាងនេះថា លោកៈមិនមានដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់ យ៉ាងនោះដែរ

តថាហីមំ អាយស្មន្តំ លោកោ ជាភិកុយ្យ តិដ្ឋតិ ។ តថា អយមាយស្មា បជាជាតិ យថា បជានតោ ចោសោ ន ហោតិ មោហោ កោជោ ឱបជាហោ មក្ខោ បលាសោ មច្ឆរិយំ ចាបិកា ឥស្សា ចាបិកា ឥច្ឆា ន ហោតិ តថាហីមំ អាយស្មន្តំ ចាបិកា ឥច្ឆា ជាភិកុយ្យ តិដ្ឋតីតិ ។

[២៥] ទសយិមានិ ភិក្ខវេ កសិណាយតនានិ ។ កាតមានិ ទស ។ បឋវីកសិណមេកោ សញ្ជានាតិ ឧទ្ធំ អជោ តិរិយំ អទ្វយំ អប្បមាណំ អាចោកសិណមេកោ សញ្ជានាតិ... តេជោកសិណមេកោ សញ្ជានាតិ... វាយោកសិណមេកោ សញ្ជានាតិ... ជីលកសិណមេកោ សញ្ជានាតិ... បីតកសិណមេកោ សញ្ជានាតិ... លោហិតកសិណមេកោ សញ្ជានាតិ... ឱជាតកសិណមេកោ សញ្ជានាតិ ... អាកាសកសិណមេកោ សញ្ជានាតិ . . .

ហេតុដូច្នោះ បានជាលោកៈ មិនគ្របសង្កត់លោកដ៏មានអាយុនេះបាន ។ ទោសៈ មិនមាន ដល់បុគ្គលដែលដឹងច្បាស់យ៉ាងណា លោកដ៏មានអាយុនេះ ក៏ដឹងច្បាស់យ៉ាងនោះដែរ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ មច្ឆរិយៈ ឥស្សា ដ៏លាមក ឥច្ឆា ដ៏លាមក មិនមាន ហេតុដូច្នោះ បានជាឥច្ឆា ដ៏លាមក មិនគ្របសង្កត់លោក ដ៏មានអាយុនេះ ។

[២៥] ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈនេះ មាន ១០ ប្រការ ។ កសិណាយតនៈ ១០ ប្រការ តើដូចម្តេចខ្លះ ។ បុគ្គលមួយពួក ដឹងបឋវីកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានគូ មិនមានប្រមាណ ១ បុគ្គលមួយពួក ដឹងអាបោកសិណ ... ១ បុគ្គលមួយពួក ដឹងតេជោកសិណ ... ១ បុគ្គល មួយពួក ដឹងវាយោកសិណ ... ១ បុគ្គល មួយពួក ដឹងនីលកសិណ ... ១ បុគ្គលមួយពួក ដឹងបីតកសិណ ... ១ បុគ្គលមួយពួក ដឹងលោហិតកសិណ ... ១ បុគ្គលមួយពួកដឹង ឱទាតកសិណ ... ១ បុគ្គលមួយពួក ដឹងអាកាសកសិណ ... ១

វិញ្ញាណកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ អទ្វយំ អប្បមាណំ ។ ឥមានិ ខោ ភិក្ខវេ ទស កសិណាយតនានីតិ ។

[២៦] ឯកំ សមយំ អាយស្មា មហាកច្ចានោ អវន្តីសុ វិហរតិ កុររឃរេ(១) បវត្តេ បព្វតេ ។ អថខោ កាលី ឧបាសិកា កុររឃរិកា(២) យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ កាលី ឧបាសិកា កុររឃរិកា អាយស្មន្តំ មហាកច្ចានំ ឯតទវោច វុត្តមិទំ ភន្តេ ភគវតា កុមារីបញ្ហេសុ

អត្ថស្ស បត្តិ(៣) ហទយស្ស សន្តិ(៤)
ជេត្វាន សេនំ បិយសាតរូបំ
ឯកោហ ឈាយី(៥) សុខមានុពោធឹ
តស្មា ជនេន ន ករោមិ សក្ខឹ
សក្ខី ន សម្បជ្ជតិ កេនចិ មេតិ ។

---

១ ម. កុលឃរេ ។ ២ ម. កុលឃរិកា ។ ៣ ឱ. ម. បត្តី ។ ៤ ឱ. ម. សន្តី ។ ៥ ឱ. ឯកោហំ ឈាយី ។ ម. ឯកាហំ ឈាយំ ។

បុគ្គលមួយពួក ដឹងវិញ្ញាណកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានគូ មិនមានប្រមាណ ១ ។ ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈ មាន ១០ ប្រការនេះឯង ។

[២៦] សម័យមួយ ព្រះមហាកច្ចានៈ គង់នៅបវត្តបព៌ត ជិតក្រុងកុររឃរៈ ក្នុងដែនអវន្តី ។ គ្រានោះ នាងកាលីឧបាសិកា នៅក្នុងក្រុងឈ្មោះកុររឃរៈ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ថ្វាយបង្គំ ព្រះមហាកច្ចានៈដ៏មានអាយុ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះនាងកាលីឧបាសិកា នៅក្នុងក្រុងឈ្មោះកុររឃរៈ អង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះមហាកច្ចានៈ ដ៏មានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ក្នុងកុមារីបញ្ហា[១]ថា

ការសម្រេចប្រយោជន៍ ជាសេចក្តីស្ងប់រម្ងាប់នៃហឫទ័យតថាគត ម្នាក់ឯង បានឈ្នះនូវកិលេសសេនា ជាទីស្រឡាញ់ ជាទីត្រេកអរ បានឈាន ត្រាស់ដឹងនូវព្រះនិព្វានជាសុខ ហេតុនោះ តថាគតមិនធ្វើសាក្សីដោយសារជនទេ សាក្សី (មិត្តធម៌) ដោយជនណាមួយ មិនសម្រេច ដល់តថាគតឡើយ ។

១ ប្រស្នាដែលទ្រង់ពោលចំពោះពួកកុមារីជាធីតានៃមារ ។

ឥមស្ស នុ ខោ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ បឋវីកសិណ-សមាបត្តិបរមា ខោ ភគិនិ ឯកេ សមណ-ព្រាហ្មណា អត្ថាភិនិព្វត្តេសុំ[១] ។ យាវតា ខោ ភគិនិ បឋវីកសិណសមាបត្តិបរមតា តទភិញ្ញាសិ ភគវា តទភិញ្ញាយ ភគវា អាទិមទ្ទស[២] អាទីនវមទ្ទស និស្សរណមទ្ទស មគ្គាមគ្គញាណទស្សនមទ្ទស តស្ស អាទិទស្សនហេតុ[៣] អាទីនវទស្សនហេតុ និស្សរណទស្សនហេតុ មគ្គាមគ្គញាណទស្សនហេតុ អត្ថស្ស បត្តិ ហទយស្ស សន្តិ វិទិតា ហោតិ ។

---

១ ម. អត្ថោតិ អភិនិព្វត្តេសុំ ។ ២ ម. អស្សាទមទ្ទស ។ ៣ ម. អស្សាទទស្ស-នហេតុ ។

បពិត្រលោកដ៏ចម្រើន សេចក្ដីនៃភាសិត ដែលព្រះដ៏មានព្រះភាគ សម្ដែងដោយសង្ខេបនេះ យើងគប្បីយល់ដោយពិស្ដារ ដូចម្ដេចបាន ។ ម្នាលនាង ពួកសមណព្រាហ្មណ៍ខ្លះ ចូលកាន់បបរិកសិណ ដ៏ឧត្តម ហើយញុំាងបបរិកសិណនោះឲ្យកើត ដោយប្រកាន់ថាជាប្រយោជន៍ ។ ម្នាលនាង ព្រះដ៏មានព្រះភាគ បានត្រាស់ដឹងនូវការចូលកាន់បបរី-កសិណ ដ៏ឧត្តមនោះ ព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់បបរីកសិណ ដ៏ឧត្តមនោះ ហើយបានឃើញខាងដើម គឺសមុ-ទយសច្ច បានឃើញទោស គឺទុក្ខសច្ច បានឃើញនូវធម៌ជាគ្រឿងរលាស់ គឺនិរោធសច្ច បានឃើញមគ្គាមគ្គញ្ញាណទស្សនៈ គឺ មគ្គសច្ច ព្រះអង្គបានជ្រាប នូវការសម្រេចប្រយោជន៍ ជាការស្ងប់នៃហ្ឫទ័យ ព្រោះហេតុនៃការឃើញខាងដើម ព្រោះហេតុនៃការឃើញទោស ព្រោះហេតុនៃការឃើញ នូវធម៌ជាគ្រឿងរលាស់ ព្រោះហេតុនៃការឃើញ នូវមគ្គាមគ្គញ្ញាណ ។

អាចោកសិណសមាបត្តិបរមា ខោ ភតិនិ... តេជោ-កសិណសមាបត្តិបរមា ខោ ភតិនិ... វាយោកសិណ-សមាបត្តិបរមា ខោ ភតិនិ... នីលកសិណសមា-បត្តិបរមា ខោ ភតិនិ... បីតកសិណសមាបត្តិបរមា ខោ ភតិនិ... លោហិតកសិណសមាបត្តិបរមា ខោ ភតិនិ... ឱទាតកសិណសមាបត្តិបរមា ខោ ភតិនិ... អាកាសកសិណសមាបត្តិបរមា ខោ ភតិនិ... វិញ្ញាណកសិណសមាបត្តិបរមា ខោ ភតិនិ ឯកេ សមណព្រាហ្មណា អត្តាភិនិព្វត្តេសុំ ។ យាវតា ខោ ភតិនិ វិញ្ញាណកសិណសមាបត្តិបរមតា តទភិញ្ញាសិ ភតវា តទភិញ្ញាយ ភតវា អាទិមទ្ទស អាទីនវ-មទ្ទស និស្សរណមទ្ទស មគ្គាមគ្គញ្ញាណទស្សនមទ្ទស តស្ស អាទិទស្សនហេតុ អាទីនវទស្សនហេតុ និស្សរណទស្សនហេតុ មគ្គាមគ្គញ្ញាណទស្សនហេតុ អត្ថស្ស បត្តិ ហទយស្ស សន្តិ វិទិតា ហោតិ ។ ឥតិ ខោ ភតិនិ យន្តំ វុត្តំ ភតវតា កុមារីបញ្ហេសុ

ម្នាលនាង... ចូលកាន់អាបោកសិណ ដ៏ឧត្តម ម្នាលនាង... ចូលកាន់តេ-ជោកសិណ ដ៏ឧត្តម ម្នាលនាង... ចូលកាន់វាយោកសិណ ដ៏ឧត្តម ម្នាលនាង... ចូលកាន់នីលកសិណដ៏ឧត្តម ម្នាលនាង... ចូលកាន់បីតកសិណ ដ៏ឧត្តម ម្នាលនាង... ចូលកាន់លោហិតកសិណដ៏ឧត្តម ម្នាលនាង... ចូលកាន់ឱទាតកសិណ ដ៏ឧត្តម ម្នាលនាង... ចូលកាន់អាកាសកសិណ ដ៏ឧត្តម ម្នាលនាង ពួកសមណព្រាហ្មណ៍ខ្លះ ចូលកាន់វិញ្ញាណកសិណ ដ៏ឧត្តម ហើយញ៉ាំងវិញ្ញាណកសិណ (នោះ) ឲ្យកើត ដោយប្រកាន់ថាជាប្រយោជន៍ ។ ម្នាលនាង ព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់វិញ្ញាណកសិណ ដ៏ឧត្តមនោះ លុះព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់វិញ្ញាណកសិណ ដ៏ឧត្តមនោះហើយ បានឃើញខាងដើម បានឃើញទោស បានឃើញធម៌ជាគ្រឿងរលាស់ បានឃើញមគ្គាមគ្គញ្ញាណទស្សនៈ ព្រះអង្គជ្រាប នូវការបានសម្រេចប្រយោជន៍ ជាការស្ងប់ហឫទ័យ ព្រោះហេតុនៃការឃើញខាងដើម ព្រោះហេតុនៃការឃើញទោស ព្រោះហេតុនៃការឃើញធម៌ជាគ្រឿងរលាស់ ព្រោះហេតុនៃការឃើញមគ្គាមគ្គញ្ញាណ ។ ម្នាលនាង ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យណា ក្នុងកុមារីបញ្ហាទាំងឡាយថា

អត្ថស្ស បត្តិ ហទយស្ស សន្តិ
ជេត្វាន សេនំ បិយសាតរូបំ
ឯកោហំ ឈាយី សុខមនុពោធឹ
តស្មា ជនេន ន ករោមិ សក្ខឹ
សក្ខី ន សម្បជ្ជតិ កេនចិ មេតិ ។

ឥមស្ស ខោ ភគិនិ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

[២៧] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ បវិសឹសុ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។

ការសម្រេចប្រយោជន៍ ជាសេចក្ដីស្ងប់ នៃ
ហឫទ័យតថាគតម្នាក់ឯង បានឈ្នះនូវកិលេស-
សេនា ជាទីស្រឡាញ់ ជាទីត្រេកអរ បាន
ឈាន ត្រាស់ដឹងនូវព្រះនិព្វាន ជាសុខ ហេតុ
នោះ តថាគត មិនធ្វើសាក្សី ដោយសារជនទេ
សាក្សី ដោយសារជន (ណាមួយ) មិនសម្រេច
ដល់តថាគតឡើយ ។

ម្នាលនាង សេចក្ដីនៃភាសិត ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែង ដោយសង្ខេបនេះឯង យើងគប្បីដឹង ដោយពិស្ដារ យ៉ាងនេះ ។

[២៧] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យហើយ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ លំដាប់នោះ ភិក្ខុទាំងនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅព្រឹកពេក បើដូច្នោះគួរយើងចូលទៅឯអារាមនៃពួកបរិព្វាជក ជាអន្យតិរ្ថិយសិនចុះ ។

អថខោ តេ ភិក្ខូ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមឹសុ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សមណោ អាវុសោ គោតមោ សាវកានំ ឯវំ ធម្មំ ទេសេតិ ឯថ តុម្ហេ ភិក្ខវេ សព្វំ ធម្មំ អភិជានាថ សព្វំ ធម្មំ អភិញ្ញាយ អភិញ្ញាយ វិហរថាតិ ។ មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម ឯថ តុម្ហេ អាវុសោ សព្វំ ធម្មំ អភិជានាថ សព្វំ ធម្មំ អភិញ្ញាយ អភិញ្ញាយ វិហរថាតិ ។ ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយសោ[១] កឹ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។

១ ឱ. ម. អធិប្បាយោ សោ ។

លំដាប់នោះ ភិក្ខុទាំងនោះ ក៏ចូលទៅឯអារាម របស់បរិព្វាជក ជាអន្យ-តិរ្ថិយ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹករួចហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ពួកបរិព្វាជក អន្យតិរ្ថិយទាំងនោះ បាននិយាយថា ម្នាលអាវុសោទាំងឡាយ សមណគោតមតែងសម្តែងធម៌ដល់សាវ័កទាំងឡាយ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយ ៗ នូវធម៌ទាំងពួង ។ ម្នាលអាវុសោទាំងឡាយ ពួកយើងក៏សម្តែងធម៌ដល់ពួកសាវ័កយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរចូលមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយ ៗ នូវធម៌ទាំងពួង ។ ម្នាលអាវុសោទាំងឡាយ ដូចយ៉ាង ធម្មទេសនា ជាមួយនឹងធម្មទេសនាក្តី ពាក្យប្រៀនប្រដៅ ជាមួយនឹងពាក្យប្រៀនប្រដៅក្តី របស់សមណគោតម នឹងយើងនេះ តើមានសេចក្តីប្លែកគ្នា ដូចម្តេច មានអធិប្បាយ ដូចម្តេច មានដំណើរផ្សេង ៗ គ្នាដូចម្តេច ។

អថខោ តេ ភិក្ខូ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹសុ នប្បដិក្កោសឹសុ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមឹសុ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។ អថខោ តេ ភិក្ខូ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ មយំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ បវិសិម្ហា ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។

លំដាប់នោះ ភិក្ខុទាំងនោះ ក៏មិនត្រេកអរ មិនទទឹងទាស់នឹងភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះមិនត្រេកអរ មិនទទឹងទាស់ហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ដោយគិតថា យើងទាំងឡាយ នឹងយល់សេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ ។ គ្រានោះ ភិក្ខុទាំងនោះក៏ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាជាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួររួចហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ យើងខ្ញុំទាំងឡាយ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅព្រឹកពេកនៅឡើយ បើដូច្នោះគួរតែយើងឈៀងចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយសិនចុះ ។

១០៩



អថខោ មយំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិម្ហា ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទិម្ហា សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិម្ហា ។ ឯកមន្តំ និសិន្នេ ខោ ភន្តេ អញ្ញតិត្ថិយា បរិព្វាជកា អម្ហេ ឯតទវោចុំ សមណោ អាវុសោ គោតមោ សាវកានំ ឯវំ ធម្មំ ទេសេតិ ឯថ តុម្ហេ ភិក្ខវេ សព្វំ ធម្មំ អភិជានាថ សព្វំ ធម្មំ អភិញ្ញាយ អភិញ្ញាយ វិហរថាតិ ។ មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម ឯថ តុម្ហេ អាវុសោ សព្វំ ធម្មំ អភិជានាថ សព្វំ ធម្មំ អភិញ្ញាយ អភិញ្ញាយ វិហរថាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកយើងខ្ញុំ ក៏បានចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយ លុះចូលដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះពួកយើងខ្ញុំ អង្គុយក្នុងទីសមគួរហើយ ពួកបរិព្វាជក ជាអន្យតិរ្ថិយ បាននិយាយពាក្យដូច្នេះថា ម្នាលអាវុសោទាំងឡាយ សមណគោតម តែងសម្តែងធម៌ដល់ពួកសាវ័កយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចូលមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយ ៗ នូវធម៌ទាំងពួង ។ ម្នាលអាវុសោទាំងឡាយ ពួកយើង ក៏សម្តែងធម៌ដល់ពួកសាវ័ក យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំង-ឡាយ ចូរចូលមកនេះ អ្នកទាំងឡាយ ចូរដឹងច្បាស់នូវធម៌ទាំងពួង អ្នកទាំងឡាយ ចូរត្រាស់ដឹងរឿយ ៗ នូវធម៌ទាំងពួងដែរ ។

ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយសោ កិំ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។ អថខោ មយំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទិម្ហា នប្បដិក្កោសិម្ហា អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមិម្ហា ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។ ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ឯកោ អាវុសោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណំ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានិ តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានិ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាករណានិ បញ្ច បញ្ហា បញ្ច ឧទ្ទេសា បញ្ច វេយ្យាករណានិ ឆ បញ្ហា ឆ ឧទ្ទេសា ឆ វេយ្យាករណានិ

ម្នាលអាវុសោទាំងឡាយ ដូចយ៉ាង ធម្មទេសនាជាមួយនឹងធម្មទេសនាក្តី ពាក្យប្រដៅជាមួយនឹងពាក្យប្រដៅក្តី របស់សមណគោតម នឹងយើងនេះ តើមានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានដំណើរផ្សេង ៗ គ្នាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកយើងខ្ញុំ មិនត្រេកអរ មិនទទឹងទាស់នឹងភាសិត របស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះទេ លុះមិនត្រេកអរ មិនទទឹងទាស់ហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅដោយគិតថា ពួកយើងនឹងយល់សេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវនិយាយយ៉ាងនេះ នឹងពួកបរិព្វាជក ជាអន្យតិរ្ថិយដែលមានវាទៈ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចុះបញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦

សត្ត បញ្ហា សត្ត ឧទ្ទេសា សត្ត វេយ្យាករណានិ អដ្ឋ បញ្ហា អដ្ឋ ឧទ្ទេសា អដ្ឋ វេយ្យាករណានិ នវ បញ្ហា នវ ឧទ្ទេសា នវ វេយ្យាករណានិ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ។ ឯវំ បុដ្ឋា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា នេវ សម្បាទយិស្សន្តិ ឧត្តរឹបិ[១] វិឃាតំ អាបជ្ជិស្សន្តិ ។ តំ កិស្ស ហេតុ ។ យថាតំ ភិក្ខវេ អវិសយស្មឹ នាហន្តំ ភិក្ខវេ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ ឥមេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វា ។ ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណន្តិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

---

១ ឱ. ន ចេវ សម្បាយិស្សន្តិ ឧត្តរិញ្ច ។ ម. ន ចេវ សំបាយិស្សន្តិ ឧត្តរិ ច ។

បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ (តើដូចម្ដេច) ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ សួរយ៉ាងនេះហើយ ពួកបរិព្វាជក ជាអន្យតិរ្ថិយ ក៏ឆ្លើយមិនរួច ទាំងបានសេចក្ដីចង្អៀតចង្អល់ថែមទៀតផង ។ ដំណើរនោះព្រោះអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មិនមែនជាវិស័យរបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស តថាគត មិនដែលឃើញអ្នកណាមួយ អាចញ៉ាំងចិត្តតថាគតឲ្យត្រេកអរ ដោយការឆ្លើយនូវបញ្ហាទាំងនេះ បានឡើយ លើកលែងតែព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ឬក៏អ្នកធ្លាប់ស្ដាប់អំពីសំណាក់ព្រះតថាគតចេញ ។ ពាក្យថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យដែលតថាគត ពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។

១១២



ឯកធម្មេ ភិក្ខវេ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច[១] ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមស្មឹ ឯកធម្មេ ។ សព្វេ សត្តា អាហារដ្ឋិតិកា ។ ឥមស្មឹ ខោ ភិក្ខវេ ឯកធម្មេ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណន្តិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ទ្វីសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ ទ្វីសុ ។

---

១ ម. សម្មទត្ថំ អភិសមេច្ច ។

ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌មួយគឺអ្វី ។ គឺពួកសត្វទាំងពួង រស់នៅដោយសារអាហារ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយនេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនុ៎ះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនោះ ។ ពាក្យថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ នុ៎ះ តថាគតពោលហើយ ពាក្យដែលតថាគត ពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃក្នុងធម៌ ២ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ២ គឺអ្វី ។

នាមេ ច រូបេ ច ។ ឥមេសុ ខោ ភិក្ខវេ ទ្វីសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តីសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ តីសុ ។ តីសុ វេទនាសុ ។ ឥមេសុ ខោ ភិក្ខវេ តីសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។

គឺនាម ១ រូប ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ២ នេះឯង រមែងធ្វើនូវបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះនុ៎ះ តថាគតពោលហើយ ពាក្យដែលតថាគត ពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៣ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៣ គឺអ្វីខ្លះ ។ គឺវេទនាទាំង ៣ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៣ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ចតូសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជ-មានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្ម-ត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ ចតូសុ ។ ចតូសុ អាហារេសុ ។ ឥមេសុ ខោ ភិក្ខវេ ចតូសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាក-រណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ បញ្ច បញ្ហា បញ្ច ឧទ្ទេសា បញ្ច វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ពាក្យណា ដែលតថាគតពោលថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះនុ៎ះ តថាគតពោលហើយ ពាក្យដែលតថាគត ពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺអាហារទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យ ដែលតថាគត ពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។

បញ្ចសុ ភិក្ខវេ ជម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ជិដ្ឋេវ ជម្មេ ទុក្ខស្សន្តការោ ហោតិ ។ កតមេសុ បញ្ចសុ ។ បញ្ចសុ ឧចាជានក្ខន្ធេសុ ។ ឥមេសុ ខោ ភិក្ខវេ បញ្ចសុ ជម្មេសុ ភិក្ខុ សម្មា-និព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាប-រិយន្តទស្សាវី សម្មត្តាភិសមេច្ច ជិដ្ឋេវ ជម្មេ ទុក្ខស្សន្ត-ការោ ហោតិ ។ បញ្ច បញ្ហា បញ្ច ឧទ្ទេសា បញ្ច វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឆ បញ្ហា ឆ ឧទ្ទេសា ឆ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឆសុ ភិក្ខវេ ជម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិ-សមេច្ច ជិដ្ឋេវ ជម្មេ ទុក្ខស្សន្តការោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនៀយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹង នូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៥ រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វីខ្លះ ។ គឺឧបាទានក្ខន្ធទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៥ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យ ដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹង នូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៦ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កតមេសុ ឆសុ ។ ឆសុ អជ្ឈត្តិកេសុ អាយតនេសុ ។ ឥមេសុ ខោ ភិក្ខវេ ឆសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ឆ បញ្ហា ឆ ឧទ្ទេសា ឆ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ សត្ត បញ្ហា សត្ត ឧទ្ទេសា សត្ត វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ សត្តសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ សត្តសុ ។ សត្តសុ វិញ្ញាណដ្ឋិតីសុ ។ ឥមេសុ ខោ ភិក្ខវេ សត្តសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។

ធម៌ ៦ គឺអ្វី ។ គឺអាយតនៈខាងក្នុងទាំង ៦ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹង នូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៦ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគត ពោលថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគត ពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៧ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៧ គឺអ្វី ។ គឺវិញ្ញាណដ្ឋិតិទាំង ៧ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុតនៃទុក្ខ ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃក្នុងធម៌ទាំង ៧ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

១១៧



សត្ត បញ្ហា សត្ត ឧទ្ទេសា សត្ត វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ អដ្ឋ បញ្ហា អដ្ឋ ឧទ្ទេសា អដ្ឋ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ អដ្ឋសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ អដ្ឋសុ ។ អដ្ឋសុ លោកធម្មេសុ ។ ឥមេសុ ខោ ភិក្ខវេ អដ្ឋសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ អដ្ឋ បញ្ហា អដ្ឋ ឧទ្ទេសា អដ្ឋ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ នវ បញ្ហា នវ ឧទ្ទេសា នវ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ពាក្យណា ដែលតថាគតពោលថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុតនៃទុក្ខ ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៨ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៨ គឺអ្វី ។ គឺលោកធម៌ទាំង ៨ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុតនៃទុក្ខ ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៨ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។

ទសសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ ទសសុ ។ ទសសុ សត្តាវាសេសុ ។ ឥមេសុ ខោ ភិក្ខវេ ទសសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ទសសុ ភិក្ខវេ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៩ រមែងធ្វើនូវទីបំផុត នៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសៈទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោល ថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះនុ៎ះ តថាគតពោលហើយ ចុះពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ១០ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កតមេសុ ទសសុ ។ ទសសុ អកុសលកម្មបថេសុ ។ ឥមេសុ ខោ ភិក្ខវេ ទសសុ ធម្មេសុ ភិក្ខុ សម្មានិព្ពិជ្ជមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

[២៨] ឯកំ សមយំ ភគវា កជង្គលាយំ វិហរតិ វេឡុវនេ ។ អថខោ សម្ពហុលា កជង្គលា(១) ឧបាសកា យេន កជង្គលា(២) ភិក្ខុនី តេនុបសង្កមឹសុ ឧបសង្កមិត្វា កជង្គលំ ភិក្ខុនឹ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ កជង្គលា ឧបាសកា កជង្គលំ(៣) ភិក្ខុនឹ ឯតទវោចុំ វុត្តមិទំ អយ្យេ ភគវតា មហាបញ្ហេសុ ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ

---

១ ម. កជង្គលកា ។ ២ ម. កជង្គលិកា ។ ៣ ម. កជង្គលិកំ ។

ធម៌ទាំង ១០ គឺអ្វី ។ គឺ អកុសលកម្មបថទាំង ១០ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើ ភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ១០ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

[២៨] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទៀបក្រុងកជង្គលា ។ គ្រានោះ ពួកកជង្គលឧបាសក (ឧបាសកអ្នកនៅក្នុងក្រុងកជង្គលា) ជាច្រើនគ្នា បានចូលទៅរកកជង្គលា-ភិក្ខុនី (ភិក្ខុនីនៅក្នុងក្រុងកជង្គលា) លុះចូលទៅដល់ ថ្វាយបង្គំកជង្គលា-ភិក្ខុនីហើយ អង្គុយក្នុងទីសមគួរ ។ លុះពួកកជង្គលឧបាសក អង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងកជង្គលាភិក្ខុនីថា បពិត្រនាងម្ចាស់ ពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ ក្នុងមហាបញ្ហាថា បញ្ហា ១ ឧទ្ទេស១

ឯកំ វេយ្យាករណំ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានិ តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានិ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាករណានិ បញ្ច បញ្ហា បញ្ច ឧទ្ទេសា បញ្ច វេយ្យាករណានិ ឆ បញ្ហា ឆ ឧទ្ទេសា ឆ វេយ្យាករណានិ សត្ត បញ្ហា សត្ត ឧទ្ទេសា សត្ត វេយ្យាករណានិ អដ្ឋ បញ្ហា អដ្ឋ ឧទ្ទេសា អដ្ឋ វេយ្យាករណានិ នវ បញ្ហា នវ ឧទ្ទេសា នវ វេយ្យាករណានិ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យា-ករណានីតិ ។ ឥមស្ស នុ ខោ អយ្យេ ភគវតា សង្ខិត្តេន ភាសិតស្ស កថំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។ ន ខោ បនេតំ អាវុសោ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ នបិ មនោភាវនីយានំ ភិក្ខូនំ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ

វេយ្យាករណ៍ ១ បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ បញ្ហា ៦ ឧទ្ទេស ៦ វេយ្យា-ករណ៍ ៦ បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ។ បពិត្រនាងម្ចាស់ សេចក្តីនៃពាក្យដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែង ដោយបំប្រួញនេះ តើគួរយល់ដោយពិស្តារ ដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ អាត្មាមិនបានស្តាប់ ក្នុងទីចំពោះព្រះភក្រ្ត មិនបានត្រងត្រាប់ ក្នុងទីចំពោះព្រះភក្រ្ត នៃព្រះដ៏មានព្រះភាគទេ ទាំងមិនបានស្តាប់ ក្នុងទីចំពោះមុខ មិនបានត្រងត្រាប់ ក្នុងទីចំពោះមុខ ពួកភិក្ខុ អ្នកអប់រំចិត្តទេ

១២១



អបិច យថាមេត្ថ ខាយតិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ អយ្យោតិ ខោ កជង្គលា ឧបាសកា កជង្គលាយ ភិក្ខុនិយា បច្ចស្សោសុំ ។ កជង្គលា ភិក្ខុនី ឯតទវោច ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ ឯកធម្មេ អាវុសោ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្ត-ទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្ត-ករោ ហោតិ ។ កតមស្មឹ ឯកធម្មេ ។ សព្វេ សត្តា អាហារដ្ឋិតិកា ។ ឥមស្មឹ ខោ អាវុសោ ឯកធម្មេ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្តាភិស-មេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។

ប៉ុន្តែពាក្យនុ៎ះ អាត្មាយល់យ៉ាងណា អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្ត នូវពាក្យនុ៎ះ ឲ្យប្រពៃចុះ អាត្មានឹងសម្តែងប្រាប់ ។ ពួកកជង្គលឧបាសក ក៏បានទទួលពាក្យ នៃកជង្គលាភិក្ខុនីថា ករុណា នាងម្ចាស់ ។ កជង្គលាភិក្ខុនីបានពោលដូច្នេះថា ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ១ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ១ គឺអ្វី ។ គឺសត្វទាំងពួង រស់ដោយសារអាហារ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌មួយនេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណន្តិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ ទ្វីសុ អាវុសោ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ ទ្វីសុ ។ នាមេ ច រូបេ ច ។ ឥមេសុ ខោ អាវុសោ ទ្វីសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ទ្វេ បញ្ហា ទ្វេ ឧទ្ទេសា ទ្វេ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

ពាក្យណា ដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ២ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ២ គឺអ្វី ។ គឺនាម ១ រូប ១ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ២ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះមានព្រះភាគសម្តែងថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនុ៎ះ ព្រះមានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។

តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ តីសុ អាវុសោ ធម្មេសុ ភិក្ខុ សម្មានិព្ពិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ តីសុ ។ តីសុ វេទនាសុ ។ ឥមេសុ ខោ អាវុសោ តីសុ ធម្មេសុ ភិក្ខុ សម្មា-និព្ពិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ តយោ បញ្ហា តយោ ឧទ្ទេសា តីណិ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។

ពាក្យដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៣ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៣ គឺអ្វី ។ គឺ វេទនាទាំង ៣ ។ ម្នាលអាវុសោទាំង-ឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រ-យោជន៍ដោយប្រពៃ ក្នុងធម៌ទាំង ៣ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។

ចតូសុ អាវុសោ ធម្មេសុ ភិក្ខុ សម្មាសុភាវិតចិត្តោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ ចតូសុ ។ ចតូសុ សតិបដ្ឋានេសុ ។ ឥមេសុ ខោ អាវុសោ ចតូសុ ធម្មេសុ ភិក្ខុ សម្មាសុភាវិតចិត្តោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ចត្តារោ បញ្ហា ចត្តារោ ឧទ្ទេសា ចត្តារិ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។ បញ្ច បញ្ហា បញ្ច ឧទ្ទេសា បញ្ច វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ បញ្ចសុ អាវុសោ ធម្មេសុ ភិក្ខុ សម្មាសុភាវិតចិត្តោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ បញ្ចសុ ។ បញ្ចសុ ឥន្ទ្រិយេសុ... កតមេសុ ឆសុ ។ ឆសុ និស្សរណីយាសុ ធាតូសុ ... កតមេសុ សត្តសុ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺសតិប្បដ្ឋាន ៤ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៤ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តបានចម្រើនល្អ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៥ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វី ។ គឺឥន្ទ្រិយទាំង ៥... ធម៌ ៦ គឺអ្វី ។ គឺនិស្សរណីយធាតុទាំង ៦... ធម៌ ៧ គឺអ្វី ។

សត្តសុ ពោជ្ឈង្គេសុ... កតមេសុ អដ្ឋសុ ។ អដ្ឋសុ អរិយេសុ អដ្ឋង្គិកេសុ មគ្គេសុ ។ ឥមេសុ ខោ អាវុសោ អដ្ឋសុ ធម្មេសុ ភិក្ខុ សម្មាសុភាវិតចិត្តោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ អដ្ឋ បញ្ហា អដ្ឋ ឧទ្ទេសា អដ្ឋ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។ នវ បញ្ហា នវ ឧទ្ទេសា នវ វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ នវសុ អាវុសោ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី សម្មត្ថាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ នវសុ ។ នវសុ សត្តាវាសេសុ ។ ឥមេសុ ខោ អាវុសោ នវសុ ធម្មេសុ ភិក្ខុ សម្មានិព្វិន្ទមានោ សម្មាវិរជ្ជមានោ សម្មាវិមុច្ចមានោ សម្មាបរិយន្តទស្សាវី

គឺពោជ្ឈង្គទាំង ៧ . . . ធម៌ ៨ គឺអ្វី ។ គឺអដ្ឋង្គិកមគ្គដ៏ប្រសើរទាំង ៨ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៨ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគ សម្តែងថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះ ពាក្យនុ៎ះ ព្រះមានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះមានព្រះភាគ សម្តែងថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ៩ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសៈទាំង ៩ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ

១២៦



សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ នវ បញ្ហា នវ ឧទ្ទេសា នវ វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ ទសសុ អាវុសោ ធម្មេសុ ភិក្ខុ សម្មាសុភាវិតចិត្តោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ កតមេសុ ទសសុ ។ ទសសុ កុសលកម្មបថេសុ ។ ឥមេសុ ខោ អាវុសោ ទសសុ ធម្មេសុ សម្មាសុភាវិតចិត្តោ សម្មាបរិយន្តទស្សាវី សម្មត្តាភិសមេច្ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ។ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ៩ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ពាក្យដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះនុ៎ះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តបានចម្រើនល្អដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ ១០ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ១០ គឺអ្វី ។ គឺកុសលកម្មបថទាំង ១០ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ ដោយប្រពៃ ឃើញនូវទីបំផុត ដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ ដោយប្រពៃ ក្នុងធម៌ទាំង ១០ នេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគ សម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។

## ១២៧



ឥតិ ខោ អាវុសោ យន្តំ វុត្តំ ភគវតា[១] មហាបញ្ហេសុ ឯកោ បញ្ហោ ឯកោ ឧទ្ទេសោ ឯកំ វេយ្យាករណំ ។ បេ ។ ទស បញ្ហា ទស ឧទ្ទេសា ទស វេយ្យាករណានីតិ ឥតិ ឥមស្ស ខោ អហំ អាវុសោ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ អាកង្ខមានា ច បន តុម្ហេ អាវុសោ ភគវន្តញ្ញេវ ឧបសង្កមិត្វា ឯតមត្ថំ បរិបុច្ឆេយ្យាថ[២] យថា នោ ភគវា ព្យាករោតិ តថា នំ ធារេយ្យាថាតិ ។ ឯវំ អយ្យេតិ ខោ កជង្គលា ឧបាសកា កជង្គលាយ ភិក្ខុនិយា ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា កជង្គលំ ភិក្ខុនឹ អភិវាទេត្វា បទក្ខិណំ កត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

---

១ ម. ឯត្ថន្តរេ សង្ខិត្តេន ភាសិតាសូតិ បាឋា ទិស្សន្តិ ។ ២ ឱ. ម. បដិបុច្ឆេយ្យាថ ។ ៣ ម. យថា ខោ នំ ។

ម្នាលអាវុសោទាំងឡាយ ពាក្យណា ដែលព្រះដ៏មានព្រះភាគ សម្តែងហើយ ក្នុងមហាបញ្ហាថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ។ បេ ។ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះនោះ ម្នាលអាវុសោទាំងឡាយ ពាក្យដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយសង្ខេបនេះ អាត្មាយល់សេចក្តី ដោយពិស្តារយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ ប្រសិនណា បើអ្នកទាំងឡាយ ប្រាថ្នា (ចង់ដឹងច្បាស់) ត្រូវចូលទៅគាល់ ព្រះដ៏មានព្រះភាគ ហើយទូលសួរបញ្ហាក់សេចក្តីនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ដោះស្រាយសេចក្តីនោះយ៉ាងណា អ្នកទាំងឡាយ ចូរចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។ ពួកកជង្គលឧបាសក ក៏ត្រេកអរអនុមោទនា នូវភាសិតរបស់កជង្គលាភិក្ខុនីថា ករុណានាងម្ចាស់ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំកជង្គលាភិក្ខុនី រួចធ្វើប្រទក្សិណ ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកកជង្គលឧបាសក អង្គុយក្នុងទីសមគួរហើយ

ឯកមន្តំ និសិន្នា ខោ កាជង្គលា ឧបាសិកា យាវតកោ អហោសិ កាជង្គលាយ ភិក្ខុនិយា សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ សាធុ សាធុ គហបតយោ បណ្ឌិតា គហបតយោ កាជង្គលា ភិក្ខុនី មហាបញ្ញា គហបតយោ កាជង្គលា ភិក្ខុនី សចេបិ តុម្ហេ គហបតយោ មំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាថ អហម្បិចេតំ ឯវមេវ ព្យាករេយ្យំ យថាតំ[១] កាជង្គលាយ ភិក្ខុនិយា ព្យាកតំ ។ ឯសោ ចេវ តស្ស អត្ថោ ឯវញ្ច នំ ធារេយ្យាថាតិ ។

[២៩] យាវតា ភិក្ខវេ កាសិកោសលា យាវតា រញ្ញោ បសេនទិស្ស កោសលស្ស វិជិតំ[២] រាជា តត្ថ បសេនទិ កោសលោ អគ្គមក្ខាយតិ ។

១ ម. យថា ហិ ។ ២ ម. វិជិតេ ។

ក្រាបទូលព្រះដ៏មានព្រះភាគ តាមទំនងពាក្យ ដែលខ្លួនបានសំណេះ-សំណាល ជាមួយនឹងកជង្គលាភិក្ខុនី ដោយសព្វគ្រប់ ។ (ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា) ម្នាលគហបតីទាំងឡាយ ល្អហើយ ល្អហើយ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្សមានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគតក៏ដោះស្រាយសេចក្តីនោះ យ៉ាងនោះ ដូចជាកជង្គលាភិក្ខុនី ដែលដោះស្រាយដែរ ។ នុ៎ះជាសេចក្តីនៃបញ្ហានោះ អ្នកទាំងឡាយ ត្រូវចាំទុកនូវសេចក្តីនោះ យ៉ាងនេះចុះ ។

[២៩] ម្នាលភិក្ខុទាំងឡាយ ជនអ្នកនៅ ក្នុងកាសីជនបទ និងកោសលជនបទ កំណត់ត្រឹមណា ដែនរបស់ស្តេចបសេនទិ-កោសល កំណត់ត្រឹមណា ស្តេចបសេនទិកោសល ប្រា-កដថា ជាអ្នកប្រសើរ ក្នុងដែននោះ (កំណត់ត្រឹមណោះ) ។

វញ្ញោមិ ខោ ភិក្ខវេ បសេនទិស្ស កោសលស្ស អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ យាវតា ភិក្ខវេ ចន្ទិមសុរិយា បរិហរន្តិ ទិសា ភន្តិ វិរោចមានា តាវ សហស្សធាលោកោ តស្មឹ សហស្សធាលោកេ សហស្សំ ចន្ទានំ សហស្សំ សុរិយានំ សហស្សំ សិនេរុបព្វតរាជានំ សហស្សំ ជម្ពុទីបានំ សហស្សំ អមរគោយានានំ[១] សហស្សំ ឧត្តរកុរូនំ សហស្សំ បុព្វវិទេហានំ ចត្តារិ មហាសមុទ្ទសហស្សានិ ចត្តារិ មហារាជសហស្សានិ សហស្សំ ចាតុម្មហារាជិកានំ សហស្សំ តាវត្តឹសានំ សហស្សំ យាមានំ សហស្សំ តុសិតានំ សហស្សំ និម្មានរតីនំ សហស្សំ បរនិម្មិតវសវត្តីនំ សហស្សំ ព្រហ្មលោកានំ យាវតា ភិក្ខវេ សហស្សលោកធាតុ

---

១ ឱ. ម. អបរគោយានានំ ។

ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្តេចបសេនទិកោសល គង់មានសភាពក្ខាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញ យ៉ាងនេះហើយ រមែងនឿយណាយ ក្នុងការឋិតនៅក្នុងរាជសម្បត្តិនោះ កាលនឿយណាយ ក្នុងការឋិតនៅក្នុងរាជសម្បត្តិនោះហើយ រមែងមិនត្រេកអរ ក្នុងភាពនៃខ្លួនជាស្តេចក្នុងដែនកោសល ដ៏ប្រសើរ ដោយរាជសម្បត្តិឡើយ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ដ៏ថោកទាប ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយ គោចរទៅត្រឹមណា ទិសទាំងឡាយ ក៏ភ្លឺរុងរឿងកំណត់ត្រឹមណោះ លោកធាតុត្រឹមមួយពាន់ ក្នុងលោកមួយពាន់នោះមានព្រះចន្ទមួយពាន់ ព្រះអាទិត្យមួយពាន់ ស្តេចភ្នំសិនេរុមួយពាន់ ជម្ពូទ្វីបមួយពាន់ អមរគោយានទ្វីបមួយពាន់ ឧត្តរកុរុទ្វីបមួយពាន់ បុព្វវិទេហទ្វីបមួយពាន់ មហាសមុទ្ទ ៤ ពាន់ មហារាជ ៤ ពាន់ ចាតុម្មហារាជិកៈមួយពាន់ តាវត្តិង្សមួយពាន់ យាមៈមួយពាន់ តុសិតមួយពាន់ និម្មានរតីមួយពាន់ បរនិម្មិតវសវត្តីមួយពាន់ ព្រហ្មលោកមួយពាន់ ម្នាលភិក្ខុទាំងឡាយ លោកធាតុមួយពាន់ កំណត់ត្រឹមណា

មហាព្រហ្មា តត្ថ អគ្គមក្ខាយតិ ។ មហាព្រហ្មុនោបិ ខោ ភិក្ខវេ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្ពិន្ទតិ តស្មឹ និព្ពិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ ។ ហោតិ សោ ភិក្ខវេ សមយោ យំ អយំ លោកោ សំវដ្ដតិ សំវដ្ដមានេ ភិក្ខវេ លោកេ យេភុយ្យេន សត្តា អាភស្សរវត្តនិកា ភវន្តិ ។ តេ តត្ថ ហោន្តិ មនោមយា បីតិភក្ខា សយំបភា អន្តលិក្ខេ ចរា សុភដ្ឋាយិនោ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ ។ សំវដ្ដមានេ ភិក្ខវេ លោកេ អាភស្សរា ទេវា អគ្គមក្ខាយន្តិ ។ អាភស្សរានំបិ ខោ ភិក្ខវេ ទេវានំ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។

មហាព្រហ្ម ប្រាកដថាជាអ្នកប្រសើរ ក្នុងលោកធាតុមួយពាន់នោះ កំណត់ត្រឹមណោះ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ មហាព្រហ្ម គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងការឋិតនៅក្នុងសម្បត្តិនោះ កាលនឿយណាយ ក្នុងការឋិតនៅក្នុងសម្បត្តិនោះហើយ រមែងមិនត្រេកអរ ក្នុងភាពនៃខ្លួនជាអ្នកប្រសើរឡើយ នឹងបាច់ពោលទៅថ្វីក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ មានសម័យ ដែលលោកនេះកំពុងវិនាស ម្នាលភិក្ខុទាំងឡាយ កាលលោកកំពុងវិនាស ពួកសត្វជាច្រើន រមែងទៅកើតក្នុងព្រហ្មលោកជាន់អាភស្សរៈ ។ ពួកសត្វក្នុងជាន់អាភស្សរៈនោះ កើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺខ្លួនឯង ចរទៅក្នុងអាកាស ឋិតនៅក្នុងវិមានដ៏ល្អ ឋិតនៅអស់កាលដ៏យូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ កាលលោកកំពុងវិនាស ពួកទេវតាជាន់អាភស្សរៈ រមែងប្រសើរជាងគេ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកទេវតាជាន់អាភស្សរៈ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។

១៣១



ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មិន្តិ ។ ទសយិមានិ ភិក្ខវេ កសិណាយតនានិ ។ កតមានិ ទស ។ បឋវីកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ អទ្វយំ អប្បមាណំ ។ អាបោកសិណមេកោ សញ្ជានាតិ... តេជោកសិណមេកោ សញ្ជានាតិ... វាយោកសិណមេកោ សញ្ជានាតិ... នីលកសិណមេកោ សញ្ជានាតិ... បីតកសិណមេកោ សញ្ជានាតិ... លោហិតកសិណមេកោ សញ្ជានាតិ... ឱទាតកសិណមេកោ សញ្ជានាតិ... អាកាសកសិណមេកោ សញ្ជានាតិ... វិញ្ញាណកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ អទ្វយំ អប្បមាណំ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងការឋិតនៅក្នុងសម្បត្តិនោះ កាលនឿយណាយ ក្នុងការឋិតនៅក្នុងសម្បត្តិនោះហើយ រមែងមិនត្រេកអរក្នុងភាពនៃខ្លួនជាអ្នកប្រសើរ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈមាន ១០ យ៉ាង ។ កសិណាយតនៈ ១០ យ៉ាង តើដូចម្ដេចខ្លះ ។ គឺបុគ្គលពួកមួយ ស្គាល់ច្បាស់នូវបឋវីកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានចំណែកពីរ រកប្រមាណមិនបាន ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវអាបោកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវតេជោកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវាយោកសិណ... បុគ្គលពួកមួយស្គាល់ច្បាស់នូវនីលកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវបីតកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវលោហិតកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវឱទាតកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវអាកាសកសិណ... បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានចំណែកពីរ រកប្រមាណមិនបាន ។

ឥមានិ ខោ ភិក្ខវេ ទស កសិណាយតនានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទសន្នំ កសិណាយតនានំ យទិទំ វិញ្ញាណកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ អទ្វយំ អប្បមាណំ ។ ឯវំសញ្ញិនោបិ ខោ ភិក្ខវេ សន្តិ សត្តា ឯវំសញ្ញីនំបិ ខោ ភិក្ខវេ សត្តានំ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ ។ អដ្ឋិមានិ ភិក្ខវេ អភិភាយតនានិ ។ កតមានិ អដ្ឋ ។ អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បឋមំ អភិភាយតនំ ។

ម្នាលភិក្ខុទាំងឡាយ កសិណាយតនៈ មាន ១០ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកសិណាយតនៈទាំង ១០ នេះ កសិណាយតនៈដ៏ប្រសើរទុំះ បានដល់បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ទាំងខាងលើ ខាងក្រោម ទទឹង មិនមានចំណែកពីរ រកប្រមាណមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ តែងមានសេចក្តីសម្គាល់យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានសញ្ញាយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក អ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងវិញ្ញាណកសិណនោះ កាលនឿយណាយក្នុងវិញ្ញាណកសិណនោះហើយ រមែងមិនត្រេកអរ ក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈ (ហេតុជាគ្រឿងគ្របសង្កត់នូវបច្ចនីកធម៌) នេះមាន ៨ យ៉ាង ។ អភិភាយតនៈ ៨ យ៉ាងតើដូចម្តេចខ្លះ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់រូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។

អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ តតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ ។ សេយ្យថាបិ នាម ឧម្មារបុប្ផំ[១] នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ

១ ឱ. ម. ឧម្មាបុប្ផំ ។

បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះហើយមានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់ នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលបង្ហាញថា នេះមានសម្បុរខៀវ មានពន្លឺខៀវ ។ ប្រៀបដូចជាផ្កាត្រកៀតខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា នេះមានពណ៌ខៀវ មានពន្លឺខៀវ

សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ ឯវមេវំ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បញ្ចមំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ ។ សេយ្យថាបិ នាម កណ្ណិការបុប្ផំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ

ពុំនោះសោត រូបនោះ ប្រៀបដូចជាសំពត់ កើតក្នុងក្រុងពារាណសី មានសាច់មដ្ឋ ទាំងពីរខាង ហៅថា សំពត់ខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា នេះមានពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលបង្ហាញថា នេះមានសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបលឿង មានសម្បុរលឿង ជាទីចង្អុលបង្ហាញថា នេះមានសម្បុរលឿង មានពន្លឺលឿង ។ ប្រៀបដូចជាផ្កាកណ្ណិការលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា នេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ កើតក្នុងក្រុងពារាណសី មានសាច់មដ្ឋទាំងពីរខាងហៅថា សំពត់លឿង ជាទីចង្អុលបង្ហាញថា នេះមានពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ

ឯវមេវំ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិ-ភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិ-តកនិភាសានិ ។ សេយ្យថាបិ នាម ពន្ធជីវកបុប្ផំ[១] លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតកនិភាសំ សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតក-និភាសំ ឯវមេវំ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ

---

១ ឱ. ម. ពន្ធុជីវកបុប្ផំ ។

បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបលឿង មានសម្បុរលឿង ជាទីចង្អុលបង្ហាញថា នេះមានសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលបង្ហាញថា នេះមានសម្បុរក្រហម មានពន្លឺក្រហម ។ ប្រៀបដូចជាផ្កាចប្បារក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់ កើតក្នុងក្រុងពារាណសី មានសាច់មដ្ឋ ទាំងពីរខាង ដែលជាសំពត់ក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា នេះមានពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលបង្ហាញថា នេះមានសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់ នូវរូបទាំងនោះហើយ មានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៧ ។

សត្តមំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ ។ សេយ្យថាបិ នាម ឱសធិតារកា ឱទាតា ឱទាតវណ្ណា ឱទាតនិទស្សនា ឱទាតនិភាសា សេយ្យថា វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ ឱទាតំ ឱទាតវណ្ណំ ឱទាតនិទស្សនំ ឱទាតនិភាសំ ឯវមេវំ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយតនំ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ អភិភាយតនានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ អដ្ឋន្នំ អភិភាយតនានំ យទិទំ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ

បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូប ស មានសម្បុរ ស ជាទីចង្អុលបង្ហាញថា នេះមានសម្បុរ ស មានពន្លឺ ស ។ ប្រៀបដូចជាផ្កាយព្រឹក ស មានពណ៌ ស ជាទីចង្អុលបង្ហាញថា នេះមានពណ៌ ស មានពន្លឺ ស ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ កើតក្នុងក្រុងពារាណសី មានសាច់មដ្ឋទាំងពីរខាង ដែលជាសំពត់ ស មានពណ៌ ស ជាទីចង្អុលបង្ហាញថា នេះមានពណ៌ ស មានពន្លឺ ស យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់ នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូប ស មានសម្បុរ ស ជាទីចង្អុលបង្ហាញថា នេះមានសម្បុរ ស មានពន្លឺ ស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជាអភិភាយតនៈទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈមាន ៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាអភិភាយតនៈទាំង ៨ នេះ អភិភាយតនៈដ៏ប្រសើរនុ៎ះ បានដល់បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូប ស មានសម្បុរ ស

១៣៧



ឱជាតនិចស្សជានិ ឱជាតនិកាសានិ តានិ អភិកុយ្យ
ជាជាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ ឯវំសញ្ញិ-
ដោបិ ខោ ភិក្ខវេ សន្តិ សត្តា ឯវំសញ្ញីនំបិ
ខោ ភិក្ខវេ សត្តានំ អត្ថេវ អញ្ញថត្តំ អត្ថិ
វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយ-
ស្សាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ
វិរជ្ជតិ បគេវ ហីនស្មឹ ។ ចតស្សោ ឥមា ភិក្ខវេ
បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា
ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា
បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។
ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទា ។

ជាទីចង្អុលបង្ហាញថា នេះមានសម្បុរ ស មានពន្លឺ ស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសេចក្ដីសម្គាល់យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ពួកសត្វដែលមានសញ្ញាយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំង-ឡាយ អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងអត្តភាព នៃពួកសត្វនោះ កាលនឿយណាយ ក្នុងអត្តភាព នៃពួកសត្វនោះ រមែងមិនត្រេកអរ ក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិនេះ មាន ៤ យ៉ាង ។ សេចក្ដីប្រតិបត្តិ ៤ យ៉ាង តើ ដូចម្ដេចខ្លះ ។ គឺសេចក្ដីប្រតិបត្តិលំបាក ទាំងត្រាស់ដឹងបាន ដោយយឺតយូរ ១ សេចក្ដីប្រតិបត្តិលំបាក តែត្រាស់ដឹងបាន ដោយឆាប់រហ័ស ១ សេចក្ដីប្រតិបត្តិស្រួល តែត្រាស់ដឹងបាន ដោយយឺតយូរ ១ សេចក្ដីប្រតិបត្តិស្រួល ទាំងត្រាស់ដឹងបាន ដោយឆាប់រហ័ស ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិ មាន ៤ យ៉ាងនេះឯង ។

ឯតទគ្គំ ភិក្ខវេ ឥមាសំ ចតុន្នំ បដិបទានំ យទិទំ សុខា បដិបទា ខិប្បាភិញ្ញា ។ ឯវំ បដិបន្នាបិ ខោ ភិក្ខវេ សន្តិ សត្តា ឯវំ បដិបន្នានំបិ ខោ ភិក្ខវេ សត្តានំ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ ។ ចតស្សោ ឥមា ភិក្ខវេ សញ្ញា ។ កតមា ចតស្សោ ។ បរិត្តមេកោ សញ្ជានាតិ មហគ្គតមេកោ សញ្ជា-នាតិ អប្បមាណមេកោ សញ្ជានាតិ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនមេកោ សញ្ជានាតិ ។ ឥមា ខោ ភិក្ខវេ ចតស្សោ សញ្ញា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ចតុន្នំ សញ្ញានំ យទិទំ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនមេកោ សញ្ជានាតិ ។

ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីប្រតិបត្តិទាំង ៤ យ៉ាងនេះ សេចក្តីប្រតិបត្តិ ដ៏ប្រសើរនុ៎ះ បានដល់សេចក្តីប្រតិបត្តិស្រួល ទាំងត្រាស់ដឹងបាន ដោយឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ តែងមានសេចក្តីប្រតិបត្តិយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានសេចក្តីប្រតិបត្តិយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងអត្តភាពនៃពួកសត្វនោះ កាលនឿយណាយ ក្នុងអត្តភាពនៃពួកសត្វនោះហើយ រមែងមិនត្រេកអរក្នុងរបស់ ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ៤ យ៉ាង ។ សញ្ញា ៤ យ៉ាង តើដូចម្តេចខ្លះ ។ បុគ្គលពួកមួយ ស្គាល់នូវបរិត្តារម្មណ៍គឺកាមាវចរ បុគ្គលពួកមួយ ស្គាល់នូវមហគ្គតារម្មណ៍គឺរូបាវចរ បុគ្គលពួកមួយ ស្គាល់នូវអប្បមាណារម្មណ៍ គឺ លោកុត្តរ បុគ្គលពួកមួយស្គាល់នូវអាកិញ្ចញ្ញាយតនៈថា វត្ថុតិចតួចមិនមាន ។ ម្នាលភិក្ខុទាំង-ឡាយ សញ្ញាមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសញ្ញាទាំង ៤ យ៉ាងនេះ សញ្ញា ដ៏ប្រសើរនុ៎ះ បានដល់បុគ្គលពួកមួយ ស្គាល់នូវអាកិញ្ចញ្ញាយតនៈថា វត្ថុតិចតួច មិនមាន ដូច្នេះ ។

១៣៩



ឯវំសញ្ញិនោបិ ខោ ភិក្ខវេ សន្តិ សត្តា ឯវំសញ្ញីនំបិ ខោ ភិក្ខវេ សត្តានំ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ ។ ឯតទគ្គំ ភិក្ខវេ ពាហិរកានំ ទិដ្ឋិគតានំ យទិទំ នោ ចស្សំ នោ ច មេ សិយា ន ភវិស្សាមិ ន មេ ភវិស្សតីតិ ។ ឯវំទិដ្ឋិនោ ភិក្ខវេ ឯតំ ចាដិកង្ខំ យា ចាយំ តស្ស[១] ភវេ អប្បដិកុល្យ-តា សា ចស្ស ន ភវិស្សតិ យា ចាយំ តស្ស ភវនិរោធេ បដិកុល្យតា សា ចស្ស ន ភវិស្សតីតិ ។

១ ឱ. ម. តស្សាតិ បាឋោ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វតែងមានសញ្ញាយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ពួកសត្វដែលមានសញ្ញាយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងអត្តភាព នៃពួកសត្វនោះ កាលនឿយណាយ ក្នុងអត្តភាពនៃពួកសត្វនោះហើយ រមែងមិនត្រេកអរ ក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទិដ្ឋិ (សេចក្តីយល់) ទាំងឡាយ ដែលប្រព្រឹត្តទៅខាងក្រៅសាសនា សេចក្តីយល់ដ៏លើសទុំះ បានដល់សេចក្តីយល់ថា បើអាត្មាអញ មិនមានក្នុងអតីតទេ អត្តភាពរបស់អាត្មាអញនេះ ក៏មិនមានក្នុងបច្ចុប្បន្នដែរ បើអាត្មាអញនឹងមិនមានក្នុងអនាគតទេ គ្រឿងកង្វល់បន្តិចបន្តួច ក៏មិនមានដល់អាត្មាអញដែរ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ តែងកើតប្រាកដ ដល់បុគ្គលអ្នកមានទិដ្ឋិយ៉ាងនេះថា ការមិនខ្ពើមរអើមក្នុងភពណា របស់បុគ្គលនោះ ការមិនខ្ពើមរអើមនោះ នឹងមិនមានដល់បុគ្គលនោះផង ការខ្ពើមរអើម ក្នុងធម៌ជាគ្រឿងរលត់ភពណា របស់បុគ្គលនោះ ការខ្ពើមរអើមនោះនឹងមិនមាន ដល់បុគ្គលនោះផង ។

ឯវំទិដ្ឋិនោបិ ខោ ភិក្ខវេ សន្តិ សត្តា ឯវំទិដ្ឋីនំបិ ខោ ភិក្ខវេ សត្តានំ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា បរមយក្ខវិសុទ្ធឹ[១] បញ្ញបេន្តិ ។ ឯតទគ្គំ ភិក្ខវេ បរមយក្ខវិសុទ្ធឹ បញ្ញបេន្តានំ យទិទំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ តេ តទភិញ្ញាយ តស្ស សច្ឆិកិរិយាយ ធម្មំ ទេសេន្តិ ។ ឯវំវាទិនោបិ ខោ ភិក្ខវេ សន្តិ សត្តា ឯវំវាទីនំបិ ខោ ភិក្ខវេ សត្តានំ អត្ថេវ អញ្ញថត្តំ អត្ថិ វិបរិណាមោ ។

១ បរមត្ថសុទ្ធឹ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វ តែងមានទិដ្ឋិយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ពួកសត្វដែលមានទិដ្ឋិយ៉ាងនេះ ក៏គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក អ្នកចេះដឹង កាលឃើញយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងពួកសត្វនោះ កាលនឿយណាយ ក្នុងពួកសត្វនោះហើយ រមែងមិនត្រេកអរ ក្នុងរបស់ដ៏ប្រសើរ នឹងបាច់ពោលទៅថ្វី ក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ រមែងបញ្ញត្តនូវសេចក្តីបរិសុទ្ធ ក្នុងសត្វដ៏ឧត្តម[១] ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ កាលបញ្ញត្តនូវសេចក្តីបរិសុទ្ធ ក្នុងពួកសត្វដ៏ឧត្តម ការបញ្ញត្តដ៏ប្រសើរនុ៎ះ បានដល់បុគ្គល ដែលកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយតនៈ ។ ពួកសមណព្រាហ្មណ៍ ទាំងនោះ ដឹងនូវនេវសញ្ញានាសញ្ញាយតនៈនោះហើយ ក៏សម្តែងធម៌ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនេវសញ្ញានាសញ្ញាយតនៈនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វទុកជាមានវាទៈយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកសត្វដែលមានវាទៈយ៉ាងនេះ គង់មានសភាពក្លាយទៅ ប្រែប្រួលទៅ ។

១ ជាឈ្មោះ នេវសញ្ញានាសញ្ញាយតនលាភិបុគ្គល ។

១៤១



ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ តស្មឹបិ និព្វិន្ទតិ តស្មឹ និព្វិន្ទន្តោ អគ្គេ វិរជ្ជតិ បគេវ ហីនស្មឹ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ ឯតទគ្គំ ភិក្ខវេ បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តានំ យទិទំ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមោក្ខោ ឯវំវាទី ខោ មំ ភិក្ខវេ ឯវមក្ខាយឹ ឯកេ សមណព្រាហ្មណា អសតា តុច្ឆា មុសា អភូតេន[១] អព្ភាចិក្ខន្តិ ន សមណោ គោតមោ កាមានំ បរិញ្ញំ បញ្ញបេតិ ន រូបានំ បរិញ្ញំ បញ្ញបេតិ ន វេទនានំ បរិញ្ញំ បញ្ញបេតីតិ កាមានញ្ចាហំ ភិក្ខវេ បរិញ្ញំ បញ្ញបេមិ

១ ម. អភូតា ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះ រមែងនឿយណាយ ក្នុងពួកសត្វនោះ កាលនឿយណាយ ក្នុងពួកសត្វនោះហើយ រមែងមិនត្រេកអរ ក្នុងរបស់ដ៏ប្រសើរ នឹងចាំបាច់ពោលទៅថ្វី ក្នុងរបស់ដ៏ថោកទាប ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ តែងបញ្ញត្តនូវព្រះនិព្វានដ៏ឧត្តម ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ កាលបញ្ញត្តនូវនិព្វានដ៏ឧត្តម ក្នុងបច្ចុប្បន្ន ការបញ្ញត្តដ៏ប្រសើរនុ៎ះ បានដល់ការរួចស្រឡះដោយមិនប្រកាន់ ព្រោះដឹងតាមពិតនូវការកើតឡើងផង នូវការរលត់ទៅផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផងនៃផស្សាយតនៈទាំង ៦ មានសមណព្រាហ្មណ៍ពួកមួយ តែងនិយាយបង្កាច់តថាគតដែលពោលយ៉ាងនេះប្រាប់យ៉ាងនេះ ដោយពាក្យមិនទៀងទាត់ មិនពិតជាពាក្យកុហកថា សមណគោតម មិនបញ្ញត្តនូវការកំណត់ដឹងពួកកាមផង មិនបញ្ញត្តនូវការកំណត់ដឹងនូវពួករូបផង មិនបញ្ញត្តនូវការកំណត់ដឹងពួកវេទនាផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវការកំណត់ដឹង[១]

១ អដ្ឋកថាថា កន្លងនូវកាមទាំងឡាយបាន ដោយបឋមជ្ឈាន ។

រូបានញ្ច បរិញ្ញំ បញ្ញបេមិ វេទនានញ្ច បរិញ្ញំ បញ្ញបេមិ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ អនុបាទា បរិនិព្វានំ បញ្ញបេមីតិ ។

[៣០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ ឧយ្យោធិកាយ និវត្តោ ហោតិ ជិតសង្គាមោ[១] លទ្ធាធិប្បាយោ ។ អថខោ រាជា បសេនទិ កោសលោ យេនារាមោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោ វ អារាមំ បាវិសិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អព្ភោកាសេ ចង្កមន្តិ ។ អថខោ រាជា បសេនទិ កោសលោ យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ម. វិជិតសង្គាមោ ។

នូវកាមទាំងឡាយផង បញ្ញត្តនូវការកំណត់ដឹង[១] នូវរូបទាំងឡាយផង បញ្ញត្តនូវការកំណត់ដឹង[២] នូវវេទនាទាំងឡាយផង តថាគតមិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានត្រជាក់កើតហើយ រមែងបញ្ញត្តនូវបរិនិព្វាន ដោយមិនមានសេចក្តីប្រកាន់ ក្នុងបច្ចុប្បន្ន ដូច្នេះ ។

[៣០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រឡប់មកពីច្បាំង ទ្រង់បានឈ្នះសង្គ្រាមហើយ ទ្រង់បានតាមព្រះរាជបំណងហើយ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ស្តេចទៅកាន់អារាម ទ្រង់ស្តេចទៅដោយព្រះរាជយាន កំណត់ត្រឹមទី ដែលបរយានទៅបាន រួចស្តេចទ្រង់ចុះអំពីព្រះរាជយាន ទ្រង់ស្តេចទៅ ដោយព្រះបាទទទេ ចូលទៅកាន់អារាម ។ សម័យនោះ ភិក្ខុទាំងឡាយ ជាច្រើនរូប កំពុងចង្រ្កម ក្នុងទីវាល ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ក៏ចូលទៅរក ភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ

---

១ កន្លងនូវរូបទាំងឡាយបាន ដោយអរូបាវចរជ្ឈានទាំងឡាយ ។ ២ កន្លងនូវវេទនា ដោយអនុបាទានិព្វាន ។

តេ ភិក្ខូ ឯតទវោច កហំ នុ ខោ ភន្តេ ភគវា ឯតរហិ វិហរតិ អរហំ សម្មាសម្ពុទ្ធោ ទស្សនកាមា ហិ មយំ ភន្តេ[១] ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯសោ មហារាជ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាឡិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេហិ វិវរិស្សតិ តេ ភគវា ទ្វារន្តិ ។ អថខោ រាជា បសេនទិ កោសលោ យេន សោ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាឡិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេសិ ។ វិវរិ ភគវា ទ្វារំ ។ អថខោ រាជា បសេនទិ កោសលោ វិហារំ បវិសិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវតោ បាទានិ[១] មុខេន ច បរិចុម្ពតិ បាណីហិ ច បរិសម្ពាហតិ នាមញ្ច សាវេតិ

១ ឱ. ឯត្ថន្តរេ តន្តិ បាឋោ ទិស្សតិ ។ ២ បាទេតិ បាឋោ មញ្ញេ ភវេយ្យ ។

បានសួរកិក្ខុទាំងនោះដូច្នេះថា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន ឥឡូវនេះ ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ស្តេចគង់នៅក្នុងទីណា បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន ដ្បិតយើងខ្ញុំមានប្រាថ្នា ចង់គាល់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ បពិត្រមហារាជ វិហារនុ៎ះមានទ្វារបិទហើយ សូមព្រះអង្គមានព្រះសូរសៀងតិច ស្តេចចូលទៅតាមទ្វារនោះកុំរួសរាន់ពេក ចូលទៅកាន់របៀងសឹមគ្រហែមហើយគោះសន្ទះទ្វារ ព្រះដ៏មានព្រះភាគនឹងទ្រង់បើកទ្វារថ្វាយព្រះអង្គ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះសូរសៀងតិចហើយ ចូលទៅកាន់វិហារដែលមានទ្វារបិទហើយ មិនបានរួសរាន់ ហើយទ្រង់ចូលទៅកាន់របៀង ហើយគ្រហែម គោះសន្ទះទ្វារ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់បើកទ្វារ ។ គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅកាន់វិហារ ក្រាបចុះទៀបព្រះបាទទាំងគូនៃព្រះដ៏មានព្រះភាគដោយព្រះសិរ្ស ហើយជប់នូវព្រះបាទទាំងគូ នៃព្រះដ៏មានព្រះភាគ ដោយព្រះឱស្ឋផង ទ្រង់ប្របាច់ ដោយព្រះហស្តផង ទ្រង់ក្រាបទូលឲ្យជ្រាបព្រះនាមផងថា

រាជាហំ ភន្តេ បសេនទិ កោសលោ រាជាហំ ភន្តេ បសេនទិ កោសលោតិ ។ កម្បន ត្វំ មហារាជ អត្ថវសំ សម្បស្សមានោ ឥមស្មឹ សរីរេ ឯវរូបំ បរមនិបច្ចការំ ករោសិ មេត្តូបហារំ ឧបទំសេសីតិ ។ កតញ្ញុតំ ខោ អហំ ភន្តេ កតវេទិតំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ ភគវា ហិ ភន្តេ ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ ពហុជនហិតាយ អរិយញ្ញាយេ[១] បតិដ្ឋាបិតា យទិទំ កល្យាណ-ធម្មតាយ កុសលធម្មតាយ ។ យម្បិ ភន្តេ ភគវា ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ ពហុជនហិតាយ អរិយញ្ញាយេ បតិដ្ឋាបិតា យទិទំ កល្យាណធម្មតាយ កុសលធម្មតាយ

១ ឱ. ម. ពហុនោ ជនស្ស អរិយេ ញាយេ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាស្តេចឈ្មោះបសេនទិកោសល បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាស្តេច ឈ្មោះបសេនទិកោសល ។ បពិត្រមហារាជ ព្រះអង្គពិចារណាឃើញ នូវអំណាចប្រយោជន៍ ដូចម្តេច ទើបធ្វើសេចក្តីគោរពដ៏ក្រៃលែង ទ្រង់សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះសរីរៈនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវកតញ្ញូកតវេទិតា ទើបធ្វើសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតព្រះដ៏មានព្រះភាគ ប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ព្រះអង្គទ្រង់តាំងទុក នូវអរិយញ្ញាណទាំងឡាយ[១] គឺកល្យាណធម៌ និងកុសលធម៌ ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់ប្រតិបត្តិ ដើម្បីប្រយោជន៍ ដល់ជនច្រើន ព្រះអង្គទ្រង់តាំងទុក នូវអរិយញ្ញាណទាំងឡាយ គឺកល្យាណធម៌ និងកុសលធម៌ ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដោយអំណាចនៃប្រយោជន៍ណា

១ អដ្ឋកថាថា មគ្គប្រកបដោយវិបស្សនា ។

ឥធម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា សីលវា ពុទ្ធសីលោ អរិយសីលោ កុសលសីលោ កុសលសីលេន សមន្នាគតោ ។ យម្បិ ភន្តេ ភគវា សីលវា ពុទ្ធសីលោ អរិយសីលោ កុសលសីលោ កុសលសីលេន សមន្នាគតោ ឥធម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា ទីឃរត្តំ អារញ្ញកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចនៃប្រយោជន៍ នេះឯង ទើបធ្វើសេចក្តីគោរព ដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គមានសីល មានសីលចម្រើនហើយ មានសីលដ៏ប្រសើរ មានកុសលសីល (សីលល្អ) ប្រកបដោយកុសលសីល[១] ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ មានសីល មានសីលចម្រើនហើយ មានសីលដ៏ប្រសើរ មានកុសលសីល ប្រកបដោយកុសលសីល ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញ នូវអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គគង់នៅក្នុងព្រៃ ទ្រង់គប់រកសេនា-សនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ អស់កាលយូរ ។

---

១ អដ្ឋកថាថា សីលមិនមានទោស ។

យម្បិ ភន្តេ ភគវា ជីឃវត្តំ អារញ្ញកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ ឥធម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរម-និបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរចីវរបិណ្ឌបាត-សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ។ យម្បិ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរចីវរបិណ្ឌបាត-សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ឥធម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ

បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គគង់នៅ ក្នុងព្រៃ ទ្រង់គប់រកសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅ ក្នុងព្រៃជិតនិងព្រៃឆ្ងាយ អស់កាលយូរ ដោយអំណាច នៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តាមានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ទ្រង់សន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់សន្តោស ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ដោយអំណាច នៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវទាន ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន

អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ យម្បិ ភន្តេ ភគវា អាហុនេយ្យោ ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ឥទម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា យាយំ កថា អភិ-សល្លេខិកា ចេតោវិចរណសប្បាយា[១] សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ឯវរូបាយ[២] កថាយ និកាមលាភី អកិច្ឆលាភី អកសិរលាភី ។ យម្បិ ភន្តេ ភគវា យាយំ កថា អភិសល្លេខិកា ចេតោវិចរណសប្បាយា សេយ្យថីទំ អប្បិច្ឆកថា ។ បេ ។

១ ឱ. ម. វិវរណសប្បាយា ។ ២ ឱ. ឯវរូបិយា ។

គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គគួរទទួលនូវបច្ចុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវទាន ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ដោយអំណាច នៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងកិរិយារាប់អាន ប្រកបដោយមេត្តាមានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផ្លូវផង់ដ៏ក្រៃ-លែង ជាទីសប្បាយនៃការត្រាច់ទៅនៃចិត្ត គឺ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផ្លូវផង់ដ៏ក្រៃលែង ជាទីសប្បាយនៃការត្រាច់ទៅនៃចិត្ត គឺអប្បិច្ឆកថា ។បេ។

វិមុត្តិញ្ញាណទស្សនកថា ឯវរូបាយ កថាយ និកាមលាភី អកិច្ឆលាភី អកសិរលាភី ឥទម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី ។ យម្បិ ភន្តេ ភគវា ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្ម-សុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិ-រលាភី ឥទម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ

វិមុត្តិញ្ញាណទស្សនកថា ដោយអំណាច នៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរព ដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ព្រះអង្គបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅ ក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ដោយអំណាច នៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាព យ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គរលឹកឃើញនូវជាតិ ដែលព្រះអង្គ ធ្លាប់អាស្រ័យនៅ ក្នុងកាលមុន ជាច្រើនជាតិ

សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធុប្បន្នោតិ[1] ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

---

១ ឱ. ម. ឥធុបបន្នោតិ ។

គឺរលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១ សែនជាតិខ្លះ រលឹកឃើញបាន ច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តវិវដ្តកប្បខ្លះ ដូច្នេះថា អាត្មាអញនៅ ក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើត ក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ ព្រះមានព្រះភាគ ព្រះអង្គរលឹកឃើញជាតិ ដែលព្រះអង្គធ្លាប់អាស្រ័យនៅ ក្នុងកាលមុនបានច្រើនជាតិ ព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ។

យម្បិ ភន្តេ ភគវា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទម្បិ ខោ អហំ ភន្តេ អត្តវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ បុន ចបរំ ភន្តេ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នា-គតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា

បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់រលឹកឃើញនូវជាតិ ដែលព្រះអង្គធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ គឺរលឹកឃើញ បាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវជាតិ ដែលព្រះអង្គធ្លាប់អាស្រ័យនៅ ក្នុងកាលមុន បានច្រើនជាតិ ព្រមទាំង អាការ ទាំងឧទ្ទេសដូច្នេះ ដោយអំណាច នៃប្រយោជន៍ណា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍ នេះឯង ទើបធ្វើនូវសេចក្តីគោរព ដ៏ក្រៃលែង សម្តែងកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ មានចក្ខុទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញសត្វទាំងឡាយ ដែលច្យុត ដែលចាប់បដិសន្ធិ ជាសត្វថោកទាបនិងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ដឹងច្បាស់នូវពួកសត្វដែល អន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ តិះដៀលពួក អរិយបុគ្គល ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែក ធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក

១៤១



ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុច-រិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មា-ទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ យម្បិ ភន្តេ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ឥទម្បិ ខោ អហំ ភន្តេ អត្ថវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។

អើហ្ន៎ ចំណែកឯសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិមិនតិះដៀលពួកអរិយ-បុគ្គល ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ទេវលោក ។ ព្រះដ៏មានព្រះភាគ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលចាប់បដិសន្ធិ ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ដោយអំណាច នៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាច នៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរព ដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាព យ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។

បុន ចបរំ ភន្តេ ភគវា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ យម្បិ ភន្តេ ភគវា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥធម្បិ ខោ អហំ ភន្តេ អត្ថវសំ សម្បស្សមានោ ភគវតិ ឯវរូបំ បរមនិបច្ចការំ ករោមិ មេត្តូបហារំ ឧបទំសេមិ ។ ហន្ទ ទានិ មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ មហារាជ កាលំ មញ្ញសីតិ ។ អថខោ រាជា បសេនទិ កោសលោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមីតិ ។

មហាវគ្គោ តតិយោ ។

បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគ ធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ដោយប្រាជ្ញា ដ៏ឧត្តម ដោយព្រះអង្គឯង ក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ។ បេ ។ ដោយអំណាចនៃប្រយោជន៍ណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញអំណាចនៃប្រយោជន៍នេះឯង ទើបធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង សម្តែងនូវកិរិយារាប់អាន ប្រកបដោយមេត្តា មានសភាពយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន ណ្ហើយប៉ុណ្ណឹងចុះ យើងខ្ញុំព្រះអង្គនឹងទៅឥឡូវនេះ (ព្រោះថា) យើងខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ បពិត្រមហារាជ សូមព្រះអង្គ សម្គាល់នូវកាលគួរនឹងស្តេចយាងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។

ចប់ មហាវគ្គទី ៣ ។

១៨៣

បឋមបណ្ណាសកេ មហាវគ្គោ

# តស្សុទ្ទានំ

សីហាជិមុត្តិកាយេ
ចុន្ទោ[១] កសិណោ ច
កាលី ច ទ្វេ មហាបញ្ញា
កោសលេហិ អបរេ ទ្វេតិ[១] ។

---

១ ឱ. ម. ចុន្ទេន ។ ២ ឱ. ម. បរេ ទុវេតិ ។

បឋមបណ្ណាសក មហាវគ្គ

# ឧទ្ទាននៃមហាវគ្គនោះ គឺ

*និយាយអំពីសត្វសីហៈ ១ អធិមុត្តបទ ១ អំពីធម៌ដែលត្រូវលះដោយកាយ ១ ព្រះចុន្ទត្ថេរ ១ កសិណាយតនៈ ១ ឧបាសិកាឈ្មោះកាលី ១ មហាបញ្ហាពីរលើក ព្រះបាទបសេនទិកោសលពីរលើក ដទៃទៀត ។*

---

# ឧបាលិវគ្គោ ចតុត្ថោ

[៣១] អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ បាតិមោក្ខំ ឧទ្ទិដ្ឋន្តិ ។ ទស ខោ ឧបាលិ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ បាតិមោក្ខំ ឧទ្ទិដ្ឋំ ។ កតមេ ទស ។ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បស-ន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ

# ឧបាលិវគ្គទី ៤

[៣១] គ្រានោះ ព្រះឧបាលិដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលចំពោះព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ សម្តែងឡើងនូវបាតិមោក្ខ ដល់សាវ័កទាំងឡាយ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ តថាគត បញ្ញត្តសិក្ខាបទ សម្តែងឡើងនូវបាតិមោក្ខ ដល់សាវ័កទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង ។ ប្រយោជន៍ ១០ យ៉ាង តើដូចម្តេចខ្លះ ។ គឺដើម្បីសេចក្តីល្អនៃសង្ឃ ១ ដើម្បីនៅសប្បាយនៃសង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលទ្រុស្តសីល ១ ដើម្បីនៅជាសុខស្រួលនៃភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១

សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឥមេ ខោ ឧបាលិ ទស អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ បាតិមោក្ខំ ឧទ្ទិដ្ឋំ ។ កតិ នុ ខោ ភន្តេ បាតិមោក្ខដ្ឋបនាតិ ។ ទស ខោ ឧបាលិ បាតិមោក្ខដ្ឋបនា ។ កតមេ ទស ។ បារាជិកោ តស្សំ បរិសាយំ និសិន្នោ ហោតិ បារាជិកកថា វិប្បកតា ហោតិ អនុប-សម្បន្នោ តស្សំ បរិសាយំ និសិន្នោ ហោតិ អនុបសម្បន្នកថា វិប្បកតា ហោតិ សិក្ខំ បច្ចក្ខាតកោ តស្សំ បរិសាយំ និសិន្នោ ហោតិ សិក្ខំ បច្ចក្ខាតកកថា វិប្បកតា ហោតិ បណ្ឌកោ តស្សំ បរិសាយំ និសិន្នោ ហោតិ បណ្ឌកកថា វិប្បកតា ហោតិ ភិក្ខុនីទូសកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ភិក្ខុនីទូសក-កថា វិប្បកតា ហោតិ ។ ឥមេ ខោ ឧបាលិ ទស បាតិមោក្ខដ្ឋបនាតិ ។

ដើម្បីតាំងនៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ១ ។ ម្នាលឧបាលិ តថាគត បញ្ញត្តសិក្ខាបទ សម្តែងឡើងនូវបាតិមោក្ខ ដល់សាវ័កទាំងឡាយ ព្រោះអាស្រ័យនូវអំណាចប្រយោជន៍ ១០ យ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ការបញ្ឈប់បាតិមោក្ខ តើមានប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ ការបញ្ឈប់បាតិមោក្ខមាន ១០ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខ ១០ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុត្រូវបារាជិកអង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីភិក្ខុត្រូវបារាជិក ដែលសង្ឃធ្វើមិនទាន់ស្រេច ១ អនុបសម្បន្ន អង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីអនុបសម្បន្ន ដែលសង្ឃធ្វើ មិនទាន់ស្រេច ១ ភិក្ខុពោលលាសិក្ខា អង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នា អំពីភិក្ខុអ្នកពោលលាសិក្ខា ដែលសង្ឃធ្វើមិនទាន់ស្រេច ១ បណ្ឌកៈ អង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីបណ្ឌកៈ ដែលសង្ឃធ្វើ មិនទាន់ស្រេច ១ ភិក្ខុអ្នកប្រទូស្តភិក្ខុនី អង្គុយក្នុងបរិស័ទនោះ ១ ពាក្យពណ៌នាអំពីភិក្ខុអ្នកប្រទូស្តភិក្ខុនី ដែលសង្ឃធ្វើមិនទាន់ស្រេច ១ ។ ម្នាលឧបាលិ ការបញ្ឈប់បាតិមោក្ខ មាន ១០ យ៉ាងនេះឯង ។

[៣២] កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោតិ ។ ទសហិ ខោ ឧបាលិ ធម្មេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោ ។ កតមេហិ ទសហិ ។ ឥធុបាលិ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុត-ធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តានិ[១]

---

១ ឱ. ម. សុប្បវត្តីនិ ។

[៣២] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ ប៉ុន្មានយ៉ាង ទើបគួរសន្មតដោយឧព្វាហិកាកម្ម[១]វាចាបាន ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាង ទើបគួរសន្មតដោយឧព្វាហិកាកម្មវាចាបាន ។ ប្រកបដោយធម៌ ១០ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមហើយ ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចា:និងគោចរ: ឃើញភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ពហុស្សូតទ្រទ្រង់នូវពុទ្ធវចន: ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចន: ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជន: ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ ក៏បានស្តាប់ច្រើន បានចាំទុក បានសន្សំទុក ដោយវាចា (ស្ទាត់ជំនាញ) ជាក់ច្បាស់ក្នុងចិត្ត ចេះដឹងល្អដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះទេ ទើបឯបាតិមោក្ខ ទាំងពីរយ៉ាង ក៏ភិក្ខុនោះ ចាំបានដោយពិស្តារ ចេះចែករំលែកបាន ដោយស្រួល ចេះស្ទាត់ រត់មាត់

---

១ បានពោលទុកក្នុងសមថក្ខន្ធក:រួចហើយ ។

សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ វិនយេ ខោ បន ឋិតោ ហោតិ អសំហិរោ បដិពលោ ហោតិ ឧភោ អត្ថប្បច្ចត្ថិកេ សញ្ញាបេតុំ[១] និជ្ឈាបេតុំ បេក្ខាតុំ[២] បសាទេតុំ អធិករណសមុប្បាទ-វូបសមកុសលោ ហោតិ អធិករណំ ជានាតិ អធិករណសមុទយំ ជានាតិ អធិករណនិរោធំ ជានាតិ អធិករណនិរោធគាមិនីបដិបទំ ជានាតិ ។ ឥមេហិ ខោ ឧបាលិ ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយ សម្មន្និតព្វោតិ ។

[៣៣] កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នា-គតេន ភិក្ខុនា ឧបសម្បាទេតព្វន្តិ ។ ទសហិ ខោ ឧបាលិ ធម្មេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វំ ។ កតមេហិ ទសហិ ។ ឥធុបាលិ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី

១ ម. ឯត្ថន្តរេ បញ្ញាបេតុន្តិ ទិស្សតិ ។ ២ ឱ. ម. បេក្ខេតុំ ។

វិនិច្ឆ័យបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកខ្ជាប់ខ្ជួនឥត ទើសទាល់ក្នុងផ្លូវវិន័យ ១ ជាអ្នកអង់អាច ដើម្បីធ្វើបុគ្គលទាំងពីរដែល ជាសត្រូវនឹងគ្នាឲ្យដឹងច្បាស់ ឲ្យពិនិត្យ ឲ្យពិចារណា ឲ្យឃើញ ឲ្យជ្រះថ្លា បាន ១ អ្នកឈ្លាស ក្នុងការរម្ងាប់អធិករណ៍ ដែលកើតឡើងហើយ ១ អ្នក ស្គាល់អធិករណ៍ ១ ស្គាល់ហេតុដែលកើតអធិករណ៍ ១ ស្គាល់ធម៌សម្រាប់ រម្ងាប់អធិករណ៍ ១ ស្គាល់បដិបទា ជាដំណើរទៅកាន់ធម៌ សម្រាប់រំលត់ អធិករណ៍ ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរសន្មត ដោយឧព្វាហិកាកម្មវាចាបាន ។

[៣៣] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបគួរញ៉ាំងកុលបុត្រឲ្យឧបសម្បទាបាន ។ ម្នាលឧបាលិ ភិក្ខុប្រកប ដោយធម៌ ១០ យ៉ាង គួរញ៉ាំងកុលបុត្រឲ្យឧបសម្បទាបាន ។ ប្រកបដោយ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ ជាអ្នក មានសីលសង្រួមហើយ ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយ អាចារៈនិងគោចរៈ ឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច

សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ចាតិមោក្ខំ ខោ បនស្ស វិត្ថារេន ស្វាគតំ ហោតិ សុវិភត្តំ សុប្បវត្តំ សុវិនិច្ឆិតំ សុត្តសោ អនុព្យញ្ជនសោ បដិពលោ ហោតិ គិលានំ ឧបដ្ឋាតុំ វា ឧបដ្ឋាបេតុំ វា បដិពលោ ហោតិ អនភិរតឹ វូបកាសេតុំ វា វូបកាសាបេតុំ វា បដិពលោ ហោតិ ឧប្បន្នំ កុក្កុច្ចំ ធម្មតោ វិនោទេតុំ បដិពលោ ហោតិ ឧប្បន្នំ ទិដ្ឋិគតំ ធម្មតោ វិវេចេតុំ បដិពលោ ហោតិ អធិសីលេ សមាទបេតុំ បដិពលោ ហោតិ អធិចិត្តេ សមាទបេតុំ

សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ពហុស្សូត ទ្រទ្រង់នូវពុទ្ធ-វចនៈដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏បានស្តាប់ច្រើន បានចាំទុក បានសន្សំទុកដោយវាចា (ស្ទាត់ជំនាញ) ជាក់ច្បាស់ក្នុងចិត្ត ចេះដឹងល្អ ដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះទេ បាតិ-មោក្ខ ក៏ភិក្ខុនោះចាំបាន ដោយពិស្តារ ចេះចែករំលែកបានស្រួល ចេះស្ទាត់រត់មាត់ វិនិច្ឆ័យបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ អ្នកអង់អាច ដើម្បីបម្រើ ឬ ឲ្យគេបម្រើនូវអ្នកជំងឺ ១ អ្នកអង់អាច ដើម្បីរម្ងាប់ឬឲ្យគេរម្ងាប់សេចក្តីអផ្សុក ១ អ្នកអង់អាច ដើម្បីបន្ទោបង់សេចក្តីសង្ស័យ ដែលកើតហើយដោយធម៌ ១ អ្នកអង់អាច ដើម្បីកម្ចាត់បង់ទិដ្ឋិដែលកើតហើយដោយធម៌ ១ អ្នកអង់អាចដើម្បីញុំាងបុគ្គលឲ្យសមាទានក្នុងអធិសីល ១ អ្នកអង់អាចដើម្បីញុំាងបុគ្គលឲ្យសមាទានក្នុងអធិចិត្ត ១

បដិពលោ ហោតិ អធិប្បញ្ញាយ សមាទបេតុំ ។ ឥមេហិ ខោ ឧបាលិ ទសហិ ធម្មេហិ សមន្នាគតេន ភិក្ខុនា ឧបសម្បាទេតព្វន្តិ ។

[៣៤] កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតេន ភិក្ខុនា និស្សយោ ទាតព្វោតិ ។ បេ ។ សាមណេរោ ឧបដ្ឋាបេតព្វោតិ ។ ទសហិ ខោ ឧបាលិ ធម្មេហិ សមន្នាគតេន ភិក្ខុនា សាមណេរោ ឧបដ្ឋាបេតព្វោ ។ កតមេហិ ទសហិ ។ ឥធុបាលិ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ បដិពលោ ហោតិ គិលានំ ឧបដ្ឋាតុំ វា ឧបដ្ឋាបេតុំ វា បដិពលោ ហោតិ អនភិរតឹ វូបកាសេតុំ វា វូបកាសាបេតុំ វា

អ្នកអង់អាច ដើម្បីញ៉ាំងបុគ្គលឲ្យសមាទាន ក្នុងអធិប្បញ្ញា ១ ។ ម្នាល ឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរញ៉ាំងកុលបុត្រឲ្យ ឧបសម្បទាបាន ។

[៣៤] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបគួរឲ្យនិស្ស័យបាន ។ បេ ។ គួរឲ្យសាមណេរបម្រើបាន ។ ម្នាល ឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាង គួរឲ្យសាមណេរបម្រើបាន ។ ប្រកបដោយធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនា នេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ពហុស្សូត ។ បេ ។ចេះដឹងល្អដោយទិដ្ឋិ ១ មិនតែប៉ុណ្ណោះឡើយ បាតិមោក្ខ ក៏ភិក្ខុនោះចាំបាន ដោយពិស្តារ ចេះចែករំលែកបានដោយ ស្រួល ចាំស្ទាត់រត់មាត់ វិនិច្ឆ័យបានដោយស្រួល តាមសូត្រ តាម អនុព្យញ្ជនៈ ១ អ្នកអង់អាច ដើម្បីបម្រើ ឬឲ្យគេបម្រើនូវអ្នកជំងឺ ១ អ្នកអង់អាច ដើម្បីរម្ងាប់ ឬប្រើគេឲ្យរម្ងាប់ នូវសេចក្តីអផ្សុក ១

បដិពលោ ហោតិ ឧប្បន្នំ កុក្កុច្ចំ ធម្មតោ វិនោទេតុំ បដិពលោ ហោតិ ឧប្បន្នំ ទិដ្ឋិកតំ ធម្មតោ វិវេចេតុំ បដិពលោ ហោតិ អធិសីលេ សមាទបេតុំ បដិពលោ ហោតិ អធិចិត្តេ សមាទបេតុំ បដិ-ពលោ ហោតិ អធិប្បញ្ញាយ សមាទបេតុំ ។ ឥមេហិ ខោ ឧបាលិ ទសហិ ធម្មេហិ សមន្នា-គតេន ភិក្ខុនា សាមណេរោ ឧបដ្ឋាបេតព្វោតិ ។

[៣៤] សង្ឃភេទោ សង្ឃភេទោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃោ ភិន្នោ ហោតីតិ ។ ឥធុបាលិ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ ធម្មំ អធម្មោតិ ទីបេន្តិ អវិនយំ វិនយោតិ ទីបេន្តិ វិនយំ អវិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ

អ្នកអង់អាច ដើម្បីបន្ទោបង់សេចក្តីសង្ស័យ ដែលកើតឡើងហើយដោយធម៌ ១ អ្នកអង់អាច ដើម្បីកម្ចាត់បង់នូវទិដ្ឋិដែលកើតឡើងហើយដោយធម៌ ១ អ្នកអង់អាច ដើម្បីញុាំងកុលបុត្រឲ្យសមាទានក្នុងអធិសីល ១ អ្នកអង់អាច ដើម្បីញុាំងកុលបុត្រឲ្យសមាទានក្នុងអធិចិត្ត ១ អ្នកអង់អាចដើម្បីញុាំងកុលបុត្រឲ្យសមាទានក្នុងអធិប្បញ្ញា ១ ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយធម៌ ១០ យ៉ាងនេះឯង ទើបគួរឲ្យសាមណេរបម្រើបាន ។

[៣៥] បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ការបែកសង្ឃ ៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃបែកគ្នាតើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងសភាពមិនមែនធម៌ថាជាធម៌ ១ សម្តែងធម៌ថា មិនមែនធម៌ ១ សម្តែងសភាព មិនមែនជាវិន័យថាជាវិន័យ ១ សម្តែងវិន័យថា មិនមែនជាវិន័យ ១ សម្តែងធម្មវិន័យ ដែលតថាគត មិនបានសម្តែង មិនបានពោលហើយថាជាធម្មវិន័យ ដែលតថាគត បានសម្តែង បានពោលហើយ ១ សម្តែងធម្មវិន័យ ដែលតថាគត បានសម្តែង បានពោលហើយថា ធម្មវិន័យដែលតថាគត មិនបានសម្តែង មិនបានពោលហើយ ១

អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។ តេ ឥមេហិ ទសហិ វត្ថូហិ អវកស្សន្តិ បវកស្សន្តិ[១] អាវេនិកកម្មានិ[២] ករោន្តិ អាវេនិកបាតិមោក្ខំ[៣] ឧទ្ទិសន្តិ ។ ឯត្តាវតា ខោ ឧបាលិ សង្ឃោ ភិន្នោ ហោតីតិ ។

[៣៦] សង្ឃសាមគ្គី សង្ឃសាមគ្គីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃោ សមគ្គោ ហោតី-តិ ។ ឥធុបាលិ ភិក្ខូ អធម្មំ អធម្មោតិ ទីបេន្តិ ធម្មំ ធម្មោតិ ទីបេន្តិ អវិនយំ អវិនយោតិ ទីបេន្តិ វិនយំ វិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថា-គតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ

---

១ ឱ. វវកស្សន្តិ ។ ម. អបកស្សន្តិ ។ ២ ឱ. ម. អាវេនិកម្មានិ ។ ៣ ឱ. ម. អាវេនិ-បាតិមោក្ខំ ។

សម្តែងនូវវត្ថុ ដែលតថាគត មិនបានសន្សំហើយ ថាជាវត្ថុដែលតថាគត បានសន្សំហើយ ១ សម្តែងនូវវត្ថុ ដែលតថាគត បានសន្សំហើយ ថាជាវត្ថុដែលតថាគត មិនបានសន្សំវិញ ១ សម្តែងនូវសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយថាជាសិក្ខាបទ ដែលតថាគតបានបញ្ញត្ត ១ សម្តែងនូវសិក្ខាបទដែលតថាគត បានបញ្ញត្តហើយថាជាសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយ ១ ។ ភិក្ខុទាំងនោះ ដឹកនាំបង្ខំធ្វើនូវសង្ឃកម្ម ផ្សេងគ្នា សម្តែងនូវបាតិមោក្ខ ផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលឧបាលិ សង្ឃបែកគ្នា ដោយហេតុប៉ុណ្ណោះឯង ។

[៣៦] បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សេចក្តីព្រមព្រៀង នៃសង្ឃ ៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃព្រមព្រៀងគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ថា មិនមែនធម៌ ១ សម្តែងនូវធម៌ថាជាធម៌ ១ សម្តែងនូវសភាពមិនមែនជាវិន័យថា មិនមែនជាវិន័យ ១ សម្តែងនូវវិន័យថាជាវិន័យ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យដែលតថាគតមិនបានសម្តែងមិនបានពោលហើយ ១

ភាសិតំ លបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ អនាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។ តេ ឥមេហិ ទសហិ វត្ថូហិ ន អវកាស្សន្តិ ន បវកាស្សន្តិ ន អាវេនិកកម្មានិ ករោន្តិ ន អាវេនិកបាតិមោក្ខំ ឧទ្ទិសន្តិ ។ ឯត្តាវតា ខោ ឧបាលិ សង្ឃោ សមគ្គោ ហោតីតិ ។

[៣៧] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សង្ឃភេទោ សង្ឃភេទោតិ ភន្តេ វុច្ចតិ

សម្តែងនូវធម្មវិន័យ ដែលតថាគត បានសម្តែង បានពោលហើយ ថាជាធម្មវិន័យ ដែលតថាគតបានសម្តែង បានពោលហើយ ១ សម្តែងនូវវត្តដែលតថាគត មិនបានសន្សំហើយ ថាជាវត្តដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវវត្តដែលតថាគត បានសន្សំហើយ ថាជាវត្ត ដែលតថាគត បានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគត បានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគត បានបញ្ញត្ត ១ ។ ភិក្ខុទាំងនោះ មិនដឹកនាំ មិនបង្ខំ មិនធ្វើនូវសង្ឃកម្មផ្សេងគ្នា មិនសម្តែងនូវបាតិមោក្ខផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលឧបាលិ សង្ឃព្រមព្រៀងគ្នា ដោយហេតុប៉ុណ្ណោះឯង ។

[៣៧] គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយ ក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ការបែកសង្ឃ ៗ

១៦៣



កិត្តាវតា នុ ខោ ភន្តេ សង្ឃោ ភិន្នោ ហោតីតិ ។ ឥធានន្ទ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ ធម្មំ អធម្មោតិ ទីបេន្តិ អវិនយំ វិនយោតិ ទីបេន្តិ វិនយំ អវិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេ-នាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។ តេ ឥមេហិ ទសហិ វត្ថូហិ អវកស្សន្តិ បវកស្សន្តិ អាវេនិកកម្មានិ ករោន្តិ អាវេនិកបាតិមោក្ខំ ឧទ្ទិសន្តិ ។ ឯត្តាវតា ខោ អានន្ទ សង្ឃោ ភិន្នោ ហោតីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន សង្ឃបែកគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលអានន្ទ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ថាជាធម៌ ១ សម្តែងនូវធម៌ថា មិនមែនជាធម៌ ១ សម្តែងនូវសភាពមិនមែនវិន័យថាជាវិន័យ ១ សម្តែងនូវវិន័យថាមិនមែនជាវិន័យ ១ សម្តែងនូវធម្មវិន័យដែលតថាគត មិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យដែលតថាគត បានសម្តែង បានពោលហើយ ១ សម្តែងនូវធម្មវិន័យដែលតថាគត បានសម្តែងបានពោលហើយថាជាធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលវិញ ១ សម្តែងនូវវត្តដែលតថាគតមិនបានសន្សំហើយថាជាវត្ត ដែលតថាគតបានសន្សំហើយ ១ សម្តែងនូវវត្តដែលតថាគតបានសន្សំហើយថាជាវត្ត ដែលតថាគត មិនបានសន្សំវិញ ១ សម្តែងនូវសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយ ថាជាសិក្ខាបទដែលតថាគតបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តវិញ ១ ។ ភិក្ខុទាំងនោះ ដឹកនាំបង្វែ ធ្វើនូវសង្ឃកម្មផ្សេងគ្នា សម្តែងនូវបាតិមោក្ខផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលអានន្ទ សង្ឃបែកគ្នា ដោយហេតុប៉ុណ្ណោះឯង ។

[៣៨] សមគ្គំ បន ភន្តេ សង្ឃំ ភេត្វា កឹ សោ បសវតីតិ ។ កប្បដ្ឋិយំ(១) អានន្ទ កិព្វិសំ បសវតីតិ ។ កឹ បន ភន្តេ កប្បដ្ឋិយំ កិព្វិសន្តិ ។ កប្បំ អានន្ទ និរយម្ហិ បច្ចតីតិ ។

អាចាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ
វគ្គរតោ អធម្មដ្ឋោ យោគក្ខេមតោ ធំសតិ(២)
សង្ឃំ សមគ្គំ ភេត្វាន កប្បំ និរយម្ហិ បច្ចតីតិ ។

[៣៩] សង្ឃសាមគ្គី សង្ឃសាមគ្គីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃោ សមគ្គោ ហោតីតិ ។ ឥធានន្ទ ភិក្ខូ អធម្មំ អធម្មោតិ ទីបេន្តិ ធម្មំ ធម្មោតិ ទីបេន្តិ អវិនយំ អវិនយោតិ ទីបេន្តិ វិនយំ វិនយោតិ ទីបេន្តិ

១ ម. កប្បដ្ឋិកំ ។ ២ ម. យោគក្ខេមា បធំសតិ ។

[៣៨] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបំបែកសង្ឃ ដែលព្រមព្រៀងគ្នានោះ តើទទួលនូវផលដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុនោះ រមែងទទួលផលដ៏ខ្ជាប់ខ្ជួន តាំងនៅអស់មួយកប្ប[១] ។ បពិត្រព្រះអង្គដ៏ចម្រើន ផលដ៏ខ្ជាប់ខ្ជួន តាំងនៅអស់មួយកប្ប តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុនោះ ឆេះនៅក្នុងនរក អស់មួយកប្ប ។

ភិក្ខុអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនតាំងខ្លួននៅក្នុងធម៌
ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅ អស់មួយកប្ប
រមែងឃ្លាតចាកធម៌ ជាគ្រឿងក្សេមចាកយោគៈ ភិក្ខុបំបែកសង្ឃ
ដែលព្រមព្រៀងគ្នា រមែងឆេះនៅក្នុងនរក អស់មួយកប្ប ។

[៣៩] បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថាសេចក្តីព្រមព្រៀងគ្នានៃសង្ឃ ៗ បពិត្រព្រះអង្គដ៏ចម្រើន សង្ឃព្រមព្រៀងគ្នា តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលអានន្ទ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ថា មិនមែនធម៌ ១ សម្តែងនូវធម៌ថាជាធម៌ ១ សម្តែងនូវសភាពមិនមែនជាវិន័យថា មិនមែនជាវិន័យ ១ សម្តែងនូវវិន័យថាជាវិន័យ ១

១ អស់ ១ អាយុកប្បក្នុងនរក (អដ្ឋកថា) ។

អភាសិតំ អលបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ ភាសិតំ លបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ អនាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។ តេ ឥមេហិ ទសហិ វត្ថូហិ ន អវ-កស្សន្តិ ន បវកស្សន្តិ ន អាវេនិកកម្មានិ ករោន្តិ ន អាវេនិកបាតិមោក្ខំ ឧទ្ទិសន្តិ ។ ឯត្តាវតា ខោ អានន្ទ សង្ឃោ សមគ្គោ ហោតីតិ ។

[៤០] កិន្នុ បន ភន្តេ សង្ឃំ សមគ្គំ កត្វា កឹ សោ បសវតីតិ ។ ព្រហ្មំ អានន្ទ បុញ្ញំ បសវតីតិ ។

សម្តែងនូវធម្មវិន័យដែលតថាគត មិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យ ដែលតថាគត មិនបានសម្តែង មិនបានពោលហើយ ១ សម្តែងនូវធម្មវិន័យ ដែលតថាគត បានសម្តែង បានពោលហើយថាជាធម្មវិន័យដែលតថាគត បានសម្តែង បានពោលហើយ ១ សម្តែងនូវវត្ត ដែលតថាគត មិនបានសន្សំហើយថាជាវត្តដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវវត្ត ដែលតថាគត បានសន្សំហើយថាជាវត្តដែលតថាគតបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយថាជាសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលព្រះតថាគត បានបញ្ញត្តហើយ ថាជាសិក្ខាបទដែលតថាគតបានបញ្ញត្ត ១ ។ ភិក្ខុទាំងនោះ មិនដឹកនាំ មិនបង្ខំ មិនធ្វើសង្ឃកម្មផ្សេងគ្នា មិនសម្តែងបាតិមោក្ខផ្សេងគ្នា ដោយវត្ថុ ១០ យ៉ាងនេះឯង ។ ម្នាលអានន្ទ សង្ឃព្រមព្រៀងគ្នា ដោយហេតុប៉ុណ្ណោះឯង ។

[៤០] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នកសង្រួបសង្រួមសង្ឃ ដែលបែកគ្នាហើយ ឲ្យបានព្រមព្រៀងគ្នាទៅវិញនោះ តើទទួលផលដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុនោះ រមែងទទួលនូវបុណ្យដ៏ប្រសើរ ។

១៦៦



កឹ បន ភន្តេ ព្រហ្មំ បុញ្ញន្តិ ។ កប្បំ អានន្ទ សគ្គម្ហិ មោទតីតិ ។

សុខា សង្ឃស្ស សាមគ្គី សមគ្គានញ្ចនុគ្គហោ
សមគ្គរតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតិ
សង្ឃំ សមគ្គំ កត្វាន កប្បំ សគ្គម្ហិ មោទតីតិ ។

ឧបាលិវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

ឧបាលិ បន(១) ឧព្វាហោ ឧបសម្បទនិស្សយេន(២) ច
សាមណេរោ ច ទ្វេ ភេទា អានន្ទេហិ អបរេ ទ្វេតិ(៣) ។

១ ឱ. ឧបាលិដ្ឋបនំ ។ ម. ឋបនា ។ ២ ម. ឧបសម្បទនិស្សយោ ។ ៣ ម. បរេ ទុវេតិ ។

បពិត្រព្រះអង្គដ៏ចម្រើន បុណ្យដ៏ប្រសើរ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុនោះរមែងបានរីករាយ ក្នុងឋានសួគ៌ អស់មួយកប្ប ។

សេចក្តីព្រមព្រៀងគ្នានៃសង្ឃ រមែងនាំមក នូវសេចក្តីសុខ
ភិក្ខុអ្នកអនុគ្រោះពួកភិក្ខុ ដែលព្រមព្រៀងគ្នាផង អ្នកត្រេកអរ
ក្នុងការព្រមព្រៀងគ្នាផង តាំងខ្លួនក្នុងធម៌ផង រមែងមិនឃ្លាត
ចាកធម៌ជាគ្រឿងក្សេមចាកយោគៈ ភិក្ខុអ្នកសង្រួបសង្រួមសង្ឃ
ឲ្យព្រមព្រៀងគ្នា រមែងរីករាយ ក្នុងឋានសួគ៌ អស់មួយកប្ប ។

ចប់ ឧបាលិវគ្គ ទី ៥ ។

# ឧទ្ទាននៃឧបាលិវគ្គនោះគឺ

និយាយអំពីព្រះឧបាលិ ១ ឧព្វាហិកាកម្មវាចា ១ ភិក្ខុគួរឲ្យ ឧបសម្បទាដល់កុលបុត្រ ១ ភិក្ខុគួរឲ្យនិស្ស័យ ១ ភិក្ខុគួរ ឲ្យសាមណេរបម្រើ ១ សង្ឃភេទ ២ លើក សង្ឃភេទ ២ លើក ដទៃទៀត ដែលព្រះឧបាលិនិងព្រះអានន្ទ ទូលសួរ ។

# អក្កោសវគ្គោ បញ្ចមោ

[៤១] អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន សង្ឃេ ភណ្ឌនកលហវិគ្គហវិវាទា ឧប្បជ្ជន្តិ ភិក្ខូ[១] ន ផាសុ វិហរន្តីតិ ។ ឥធុបាលិ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ ធម្មំ អធម្មោតិ ទីបេន្តិ អវិនយំ វិនយោតិ ទីបេន្តិ វិនយំ អវិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ អនា-ចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ

១ ឱ. ម. ឯត្ថន្តរេ ចសទ្ទោ អត្ថិ ។

# អក្កោសវគ្គទី ៥

[៤១] គ្រានោះ ព្រះឧបាលិដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសេចក្តីបង្កហេតុ ជម្លោះ សេចក្តីប្រកួតប្រកាន់ វិវាទគ្នា កើតឡើងក្នុងសង្ឃ ពួកភិក្ខុក៏នៅមិនសប្បាយ ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ ថាជាធម៌ ១ សម្តែងនូវធម៌ថាមិនមែនជាធម៌ ១ សម្តែងនូវសភាព មិនមែនជាវិន័យ ថាជាវិន័យ ១ សម្តែងនូវវិន័យថា មិនមែនជាវិន័យ ១ សម្តែងនូវធម្មវិន័យដែលតថាគត មិនបានសម្តែង មិនបានពោលហើយ ថាជាធម្មវិន័យដែលតថាគត បានសម្តែង បានពោលហើយ ១ សម្តែងនូវធម្មវិន័យដែលតថាគតបានសម្តែង បានពោលហើយ ថាជាធម្មវិន័យដែលតថាគតមិនបានសម្តែង មិនបានពោលវិញ ១ សម្តែងនូវវត្ត ដែលតថាគតមិនបានសន្សំហើយ ថាជាវត្ត ដែលតថាគត បានសន្សំហើយ ១

អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។ អយំ ខោ ឧបាលិ ហេតុ អយំ បច្ចយោ យេន សង្ឃេ កណ្ឌានកាលហារិត្តុហារិភាធា ឧប្បជ្ជន្តិ ភិក្ខូ ន ផាសុ វិហរន្តីតិ ។

[៤២] កតិ នុ ខោ ភន្តេ វិវាទមូលានីតិ ។ ទស ខោ ឧបាលិ វិវាទមូលានិ ។ កតមានិ ទស ។ ឥធុបាលិ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ ធម្មំ អធម្មោតិ ទីបេន្តិ អវិនយំ វិនយោតិ ទីបេន្តិ វិនយំ អវិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ

សម្តែងនូវវត្ត ដែលតថាគតបានសន្សំហើយ ថាជាវត្តដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគត បានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគត បានបញ្ញត្តហើយថាជាសិក្ខាបទ ដែលតថាគត មិនបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមានសេចក្តីបង្កហេតុ ជម្លោះ សេចក្តីប្រកួតប្រកាន់ វិវាទគ្នា កើតឡើង ក្នុងសង្ឃ ពួកភិក្ខុក៏នៅមិនសប្បាយ ។

[៤២] បពិត្រព្រះអង្គដ៏ចម្រើន មូលហេតុនៃវិវាទមានប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ មូលហេតុនៃវិវាទមាន ១០ យ៉ាង ។ មូលហេតុនៃវិវាទ ១០ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាពមិនមែនធម៌ ថាជាធម៌ ១ សម្តែងនូវធម៌ថា មិនមែនជាធម៌ ១ សម្តែងនូវសភាពមិនមែនវិន័យថាជាវិន័យ ១ សម្តែងនូវវិន័យថាមិនមែនជាវិន័យ ១ សម្តែងនូវធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោលហើយថាជាធម្មវិន័យ ដែលតថាគត បានសម្តែង បានពោលហើយ ១

ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។ ឥមានិ ខោ ឧបាលិ ទស វិវាទមូលានីតិ ។

[៤៣] កតិ នុ ខោ ភន្តេ វិវាទមូលានីតិ ។ ទស ខោ ឧបាលិ វិវាទមូលានិ ។ កតមានិ ទស ។ ឥធុបាលិ ភិក្ខូ អនាបត្តឹ អាបត្តីតិ ទីបេន្តិ អាបត្តឹ អនាបត្តីតិ ទីបេន្តិ លហុកំ អាបត្តឹ គរុកាបត្តីតិ ទីបេន្តិ គរុកំ អាបត្តឹ លហុកាបត្តីតិ ទីបេន្តិ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លាបត្តីតិ ទីបេន្តិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លាបត្តីតិ ទីបេន្តិ

សម្តែងនូវធម្មវិន័យ ដែលតថាគត បានសម្តែង បានពោលហើយថាជាធម្មវិន័យ ដែលតថាគត មិនបានសម្តែង មិនបានពោលវិញ ១ សម្តែងនូវវត្ត ដែលតថាគត មិនបានសន្សំហើយថាជាវត្ត ដែលតថាគតបានសន្សំហើយ ១ សម្តែងនូវវត្ត ដែលតថាគត បានសន្សំហើយថាជាវត្ត ដែលតថាគត មិនបានសន្សំហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ ថាជាសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ១ សម្តែងនូវសិក្ខាបទ ដែលតថាគត បានបញ្ញត្តហើយ ថាជាសិក្ខាបទដែលតថាគត មិនបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ មូលហេតុនៃវិវាទ មាន ១០ យ៉ាងនេះឯង ។

[៤៣] បពិត្រព្រះអង្គដ៏ចម្រើន មូលហេតុនៃវិវាទ តើមានប៉ុន្មានយ៉ាង ។ ម្នាលឧបាលិ មូលហេតុនៃវិវាទមាន ១០ យ៉ាង ។ មូលហេតុនៃវិវាទ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលឧបាលិ ពួកភិក្ខុក្នុងសាសនានេះ សម្តែងនូវអនាបត្តិ ថាជាអាបត្តិ ១ សម្តែងនូវអាបត្តិ ថាជា អនាបត្តិ ១ សម្តែងនូវលហុកាបត្តិ ថាជា គរុកាបត្តិ ១ សម្តែងនូវគរុកាបត្តិ ថាជា លហុកាបត្តិ ១ សម្តែងនូវទុដ្ឋុល្លាបត្តិ ថាជា អទុដ្ឋុល្លាបត្តិ ១ សម្តែងអទុដ្ឋុល្លាបត្តិ ថាជា ទុដ្ឋុល្លាបត្តិ ១

សាវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ[១] ទីបេន្តិ អនវសេសំ អាបត្តឹ សាវសេសាបត្តីតិ ទីបេន្តិ សប្បដិកម្មំ អាបត្តឹ អប្បដិកម្មាបត្តីតិ ទីបេន្តិ អប្បដិកម្មំ អាបត្តឹ សប្បដិកម្មាបត្តីតិ ទីបេន្តិ ។ ឥមានិ ខោ ឧបាលិ ទស វិវាទមូលានីតិ ។

[៤៤] ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ពលិហរណេ វនសណ្ឌេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចោទកេន ភិក្ខវេ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោ ។

១ ឱ. ម. អនវសេសាបត្តីតិ ។

សម្តែងនូវសាវសេសាបត្តិ[១] ថាជា អនវសេសាបត្តិ[២] ១ សម្តែងនូវអនវសេសាបត្តិ ថាជា សាវសេសាបត្តិ ១ សម្តែងសប្បដិកម្មាបត្តិ[៣] គឺអាបត្តិដែលកែបាន ថាជា អប្បដិកម្មាបត្តិ[៤] គឺអាបត្តិកែមិនបាន ១ សម្តែងនូវអប្បដិកម្មាបត្តិ ថាជា សប្បដិកម្មាបត្តិ ១ ។ ម្នាលឧបាលិ មូលហេតុនៃវិវាទ មាន ១០ យ៉ាងនេះឯង ។

[៤៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃជាទីនាំទៅនូវពលិកម្ម (ដើម្បីប្រយោជន៍ដល់ទេវតា) ទៀបក្រុងកុសិនារា ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយដូច្នេះ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ ប្រការ ចំពោះខ្លួនឯងសិន ត្រូវតាំងធម៌ ៥ ប្រការទុកក្នុងខ្លួន រួចសឹមចោទភិក្ខុដទៃ ។

---

១-៣ សំដៅយកអាបត្តិ ៦ កង គឺសង្ឃាទិសេស ១ ថុល្លច្ច័យ ១ បាចិត្តិយ ១ បាដិទេសនីយ ១ ទុក្កដ ១ ទុព្ភាសិត ១ ។ ២-៤ សំដៅយកបារាជិកាបត្តិ ១ ។

១៧១



កតមេ បញ្ច ធម្មា អជ្ឈត្តំ បច្ចវេក្ខិតព្វា ។ ចោទកេន ភិក្ខវេ ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ បរិសុទ្ធកាយសមាចារោ នុ ខោម្ហិ បរិសុទ្ធេនម្ហិ កាយសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ភិក្ខវេ ភិក្ខុ បរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធេន កាយសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា កាយិកំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ភិក្ខវេ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ បរិសុទ្ធវចីសមាចារោ នុ ខោម្ហិ បរិសុទ្ធេនម្ហិ វចីសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។

ធម៌ ៥ ប្រការ តើដូចម្តេច ដែលភិក្ខុអ្នកចោទ ត្រូវពិចារណាចំពោះខ្លួនឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានកាយសមាចារ បរិសុទ្ធ ឬហ្ន៎ អាត្មាអញជាអ្នកប្រកបដោយកាយសមាចារ ដ៏បរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនង់ គួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញឬ មិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនមានកាយសមាចារ បរិសុទ្ធ មិនប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនង់គួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះឯងគង់មានអ្នកផងស្តីដាស់តឿនថា នៃលោកដ៏មានអាយុ លោកសិក្សានូវសមាចារផ្លូវកាយជាមុនសិន ភិក្ខុនោះគង់មានអ្នកផងស្តីដាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានវចីសមាចារ បរិសុទ្ធ ឬហ្ន៎ អាត្មាអញប្រកបដោយវចីសមាចារដ៏បរិសុទ្ធ មិនធ្លុះធ្លាយមិនមានទំនង់ គួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។

ឆោ ចេ ភិក្ខវេ ភិក្ខុ បរិសុទ្ធវចីសមាចារោ ហោតិ បរិសុទ្ធេន វចីសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា វាចសិកំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ភិក្ខវេ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ មេត្តំ នុ ខោ[១] ចិត្តំ បច្ចុបដ្ឋិតំ សព្រហ្មចារីសុ អឃាតំ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ ឆោ ចេ ភិក្ខវេ ភិក្ខុនោ មេត្តចិត្តំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អឃាតំ តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា សព្រហ្មចារីសុ មេត្តចិត្តំ ឧបដ្ឋបេហីតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ភិក្ខវេ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិ-តព្វំ ពហុស្សុតោ នុ ខោម្ហិ សុតធរោ សុតសន្និចយោ

---

១ ឱ. ម. ឯត្ថន្តរេ មេតិ អត្ថិ ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនមានវចីសមាចារ បរិសុទ្ធទេ មិនប្រកបដោយវចីសមាចារ បរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនង់គួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះគង់មានអ្នកផង់ស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកសិក្សា នូវសមាចារផ្លូវវាចាជាមុនសិន ភិក្ខុនោះ គង់មានអ្នកផង់ស្តីដាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទមានបំណង់នឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាង់នេះថា ចិត្តរបស់អាត្មាអញមានមេត្តាតាំងមាំមិនមានអាឃាតក្នុងសព្រហ្មចារីបុគ្គលទេឬហ្ន៎ធម៌នុ៎ះ មានគ្រប់គ្រាន់ដល់អាត្មាអញឬមិនមានទេ ។ ម្នាលភិក្ខុទាំង-ឡាយ បើភិក្ខុមិនតាំង់មេត្តាចិត្ត ដែលមិនមានអាឃាត ក្នុងសព្រហ្មចារី-បុគ្គលទេ ភិក្ខុនោះ គង់មានអ្នកផង់ស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកតាំង់មេត្តាចិត្ត (ឲ្យមាំ) ក្នុងសព្រហ្មចារីបុគ្គលចុះ ភិក្ខុនោះ គង់មានអ្នកផង់ស្តីដាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទ មានបំណង់នឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាង់នេះថា អាត្មាអញជាពហុស្សូត ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈដែលខ្លួនបានស្តាប់មកហើយ សន្សំនូវពុទ្ធវចនៈដែលខ្លួន បានស្តាប់ហើយឬហ្ន៎

១៧៣



យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស មេ ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ សោ ចេ ភិក្ខវេ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ន ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា អាគមំ បរិយាបុណស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ បុន ចបរំ ភិក្ខវេ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន

ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្ដាល លម្អបទខាងចុង ប្រកាសនូវព្រហ្មចរិយៈព្រមទាំងអត្ថទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ដែលអាត្មាអញនោះបានស្ដាប់ច្រើន បានទ្រទ្រង់ បានសន្សំដោយពាក្យ បានពិចារណាមុតមាំក្នុងចិត្ត បានយល់ត្រឹមត្រូវដោយទិដ្ឋិ ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនមែនជាពហុស្សូតជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្ដាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែលខ្លួនបានស្ដាប់ហើយសោះទេ បើធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្ដាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយៈព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះជាអ្នកមិនបានស្ដាប់ច្រើន ទ្រទ្រង់សន្សំដោយពាក្យ ពិចារណាមុតមាំក្នុងចិត្ត យល់ត្រឹមត្រូវដោយទិដ្ឋិទេ ភិក្ខុនោះឯងគង់មានអ្នកផងស្ដីដាស់តឿនថា នៃលោកដ៏មានអាយុ ចូរលោករៀននិកាយសិនទៅ ភិក្ខុនោះ គង់មានអ្នកផង ស្ដីដាស់តឿន ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ

១៧៤



ឯវំ បច្ចវេក្ខិតព្វំ ឧភយានិ នុ ខោ មេ បាតិ-
មោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ
សុប្បវត្តានិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ
សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។
នោ ចេ ភិក្ខវេ ភិក្ខុនោ ឧភយានិ បាតិមោក្ខានិ
វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តានិ
សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ឥទម្បនា-
យស្មា កត្ថ វុត្តំ ភគវតាតិ ឥតិ បុដ្ឋោ ន
សម្បាយតិ តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ
អាយស្មា វិនយំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ
វត្តារោ ។ ឥមេ បញ្ច ធម្មា អជ្ឈត្តំ ឧបដ្ឋាបេតព្វា ។
កតមេ បញ្ច ធម្មា អជ្ឈត្តំ ឧបដ្ឋាបេតព្វា ។
កាលេន វក្ខាមិ នោ អកាលេន ភូតេន វក្ខាមិ
នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន

ត្រូវពិចារណាថា បាតិមោក្ខទាំងពីរ អាត្មាអញចេះចាំ ដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ តាមសូត្រគឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈដែរឬ ធម៌នុ៎ះ មានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើបាតិមោក្ខទាំងពីរ ភិក្ខុមិនបានចេះចាំដោយពិស្តារ ចែកចេញដោយប្រពៃ ចាំស្ទាត់ រត់មាត់ កាត់សេចក្តីដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈទេ ភិក្ខុនោះឯង បើមានគេសួរថា ម្នាលលោកដ៏មានអាយុ ចុះសិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងក្នុងទីណា មុខជានឹងឆ្លើយប្រាប់ទៅវិញមិនរួច ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោករៀននូវវិន័យសិនទៅ ភិក្ខុនោះ គង់មានអ្នកផងស្តីដាស់តឿន ១ ។ ធម៌ ៥ ប្រការនេះ ភិក្ខុត្រូវពិចារណាចំពោះខ្លួន ។ ធម៌ ៥ ប្រការ តើដូចម្តេច ដែលភិក្ខុអ្នកចោទត្រូវតាំងទុកក្នុងខ្លួន ។ អាត្មាអញនិយាយត្រូវតាមកាល មិននិយាយខុសកាល ១ អាត្មាអញនិយាយពាក្យពិត មិននិយាយពាក្យមិនពិត ១ អាត្មាអញនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យអាក្រក់ ១

អត្ថសញ្ញិតេន វក្ខាមិ នោ អនត្ថសញ្ញិតេន មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោតិ ។ ឥមេ បញ្ច ធម្មា អជ្ឈត្តំ ឧបដ្ឋាបេតព្វា ។ ចោទកេន ភិក្ខវេ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោតិ ។

[៥៩] ទសយិមេ ភិក្ខវេ អាទីនវា រាជន្តេ-បុរប្បវេសនេ ។ កតមេ ទស ។ ឥធ ភិក្ខវេ រាជា មហេសិយា សទ្ធឹ និសិន្នោ ហោតិ តត្រ ភិក្ខុ បវិសតិ មហេសី តំ ភិក្ខុំ[១] ទិស្វា សិតំ បាតុករោតិ ភិក្ខុ វា មហេសឹ ទិស្វា សិតំ បាតុករោតិ តត្ថ រញ្ញោ ឯវំ ហោតិ អទ្ធា ឥមេសំ កតំ វា ករិស្សន្តិ វាតិ ។ អយំ ភិក្ខវេ បឋមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។

១ ឱ. ម. មហេសី វា ភិក្ខុំ ។

អាត្មាអញនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យដែលឥតប្រយោជន៍ ១ អាត្មាអញតាំងមេត្តាចិត្ត ហើយសឹមនិយាយ មិននិយាយទាំងទោសចិត្ត ១ ។ ធម៌ ៥ ប្រការនេះឯង ដែលភិក្ខុអ្នកចោទ ត្រូវតាំងទុកក្នុងខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ មានបំណងដើម្បីចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ ប្រការនេះចំពោះខ្លួន ហើយត្រូវតាំងធម៌ ៥ ប្រការនេះ ទុកក្នុងខ្លួន រួចសឹមចោទភិក្ខុដទៃ ។

[៤៥] ម្នាលភិក្ខុទាំងឡាយ ទោស ១០ យ៉ាងនេះ រមែងមានក្នុងការចូលទៅខាងក្នុងរាជបុរី ។ ទោស ១០ យ៉ាងតើ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាក្នុងលោកនេះ កំពុងគង់នៅជាមួយនឹងមហេសី បើភិក្ខុចូលទៅក្នុងទីនោះ មហេសីបានឃើញភិក្ខុនោះ រមែងធ្វើនូវញញឹមឲ្យប្រាកដខ្លះ ភិក្ខុឃើញមហេសីហើយធ្វើនូវញញឹមឲ្យប្រាកដខ្លះ ព្រះរាជារមែងរង្កៀសក្នុងរឿងនោះយ៉ាងនេះថា ការកន្ទងនូវមេថុននៃអ្នកទាំងពីរនេះបានធ្វើហើយ ឬថានឹងធ្វើនូវការកន្ទងនូវមេថុនមិនខាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១ ក្នុងការចូលទៅក្នុងរាជបុរី ។

បុន ចបរំ ភិក្ខវេ រាជា ពហុភិច្ចោ ពហុករណីយោ អញ្ញតរំ ឥត្ថឹ គន្ត្វា ន សរតិ សា តេន គព្ភំ គណ្ហាតិ តត្ថ រញ្ញោ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ ទុតិយោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរេ អញ្ញតរំ រតនំ នស្សតិ តត្ថ រញ្ញោ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ តតិយោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរេ អព្ភន្តរា គុយ្ហមន្តា ពហិទ្ធា សម្ភេទំ គច្ឆន្តិ តត្ថ រញ្ញោ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ ចតុត្ថោ អាទីនវោ រាជន្តេបុរប្បវេសនេ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជា ជាបុគ្គលមានកិច្ចច្រើន មានការងារច្រើន ទ្រង់ស្តេចទៅប្រោសប្រាណស្ត្រីណាមួយ ហើយក៏ភ្លេចទៅ ឯស្ត្រីនោះ ក៏មានគភ៌ ដោយព្រះរាជានោះ ព្រះរាជារមែងរង្កៀសក្នុងរឿងនោះ យ៉ាងនេះថា បុគ្គលនីមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ២ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រតនៈណាមួយ ក្នុងរាជ-បុរីបាត់ទៅ ព្រះរាជារមែងរង្កៀសក្នុងរឿងនោះ យ៉ាងនេះថា បុគ្គលនីមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៣ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រឿងរ៉ាវទាំងឡាយ ដែលព្រះរាជា ត្រូវបិទបាំងទុកខាងក្នុង មាននៅខាងក្នុងបុរីរបស់ព្រះរាជាត្រឡប់បែកខ្ចរខ្ចាយ ទៅខាងក្រៅ ព្រះរាជាទ្រង់រង្កៀសក្នុងរឿងនោះយ៉ាងនេះថា បុគ្គលនីមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៤ ក្នុងការចូលទៅខាងក្នុងរាជបុរី ។

១៧៧

បឋមបណ្ណាសកេ អក្កោសវគ្គោ

បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរេ បិតា វា បុត្តំ បត្ថេតិ បុត្តោ វា បិតរំ បត្ថេតិ តេសំ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ខោ ភិក្ខវេ បឋមោ អាទីនវោ រាជន្តេបុរប្ប-វេសនេ ។ បុន ចបរំ ភិក្ខវេ រាជា នីចឋានិយំ ឧច្ចេ ឋានេ ឋបេតិ យេសន្តំ អមនាបំ តេសំ ឯវំ ហោតិ រាជា ខោ បព្វជិតេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ ឆដ្ឋោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រាជា ឧច្ចឋានិយំ នីចេ ឋានេ ឋបេតិ យេ-សន្តំ អមនាបំ តេសំ ឯវំ ហោតិ រាជា ខោ បព្វជិតេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជបិតា រមែងប្រាថ្នា (ដើម្បីសម្លាប់) ព្រះរាជបុត្រ ខាងក្នុងរាជបុរី ឬថា ព្រះរាជបុត្រ ប្រាថ្នា (ដើម្បីសម្លាប់) ព្រះរាជបិតា ព្រះរាជបិតានិងព្រះរាជបុត្រ ទ្រង់រង្កៀសយ៉ាងនេះថា បុគ្គលនីមួយដទៃ មិនដែលចូលទៅក្នុងទីនេះទេ លើកលែងតែបព្វជិតចេញ ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៥ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចទ្រង់តាំងមន្ត្រីដែលតាំងនៅក្នុងតំណែងទាប ឲ្យឡើងកាន់តំណែងខ្ពស់ ការតាំងនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ស្តេចតែងនៅច្រឡូកច្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៦ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជាទ្រង់បន្ថយមន្ត្រី ដែលតាំងនៅក្នុងតំណែងខ្ពស់ ឲ្យថយចុះក្នុងតំណែងទាបវិញ ការតាំងនោះមិនជាទីគាប់ចិត្ត របស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ព្រះរាជាតែងនៅច្រឡូកច្រឡំ ដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។

អយំ ខោ ភិក្ខវេ សត្តមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រាជា អកាលេ សេនំ ឧយ្យោជេតិ យេសន្តំ អមជាបំ តេសំ ឯវំ ហោតិ រាជា ខោ បព្វជិតេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ អដ្ឋមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រាជា កាលេ សេនំ ឧយ្យោ-ជេត្វា អន្តរាមគ្គតោ និវត្តាបេសិ[១] យេសន្តំ អមជាបំ តេសំ ឯវំ ហោតិ រាជា ខោ បព្វជិតេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ នវមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរំ ហត្ថិសម្ពាធំ អស្សសម្ពាធំ រថសម្ពាធំ[២] រជនីយានិ រូបសទ្ទគន្ធ-រសផោដ្ឋព្វានិ យានិ ន បព្វជិតសារុប្បានិ[៣] ។

១ ឱ. និវត្តាបេតិ ។ ២ ឱ. ម. ហត្ថិសម្មទំ អស្សសម្មទំ រថសម្មទំ ។ ៣ ម. បព្វជិតស្ស សារុប្បានិ ។

ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៧ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជា ទ្រង់បញ្ជូនកងទ័ពទៅក្នុងកាលមិនគួរ ការបញ្ជូនកងទ័ពទៅនោះ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយណា ជនទាំងឡាយនោះ រមែងរង្កៀសយ៉ាងនេះថា ព្រះរាជានៅប្រឡូកប្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៨ ក្នុងការចូលទៅ ខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជាបញ្ជូនកងទ័ពទៅក្នុងកាលគួរ ហើយឲ្យត្រឡប់មកវិញ ពាក់កណ្តាលផ្លូវ ការឲ្យត្រឡប់មកវិញនោះ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ព្រះរាជានៅប្រឡូកប្រឡំ ដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៩ ក្នុងការចូលទៅក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ខាងក្នុងរាជបុរី តែងចង្អៀត ដោយដំរី ចង្អៀត ដោយសេះ ចង្អៀត ដោយរថ ទាំងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាហេតុនៃសេចក្តីត្រេកអរ សុទ្ធតែជារបស់មិនសមគួរ ដល់បព្វជិតទេ ។

អយំ ភិក្ខវេ ទសមោ អានីសំសោ រាជន្តេបុរប្បវេសនេ ។ ឥមេ ខោ ភិក្ខវេ ទស អានីសំសា រាជន្តេបុរប្បវេសនេតិ ។

[៤៦] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ សម្ពហុលា សក្កា ឧបាសកា តទហុបោសថេ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ សក្កេ ឧបាសកេ ភគវា ឯតទវោច អបិ នុ តុម្ហេ សក្កា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសថាតិ ។ អប្បេកទា មយំ ភន្តេ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសាម អប្បេកទា ន ឧបវសាមាតិ ។ តេសំ វោ សក្កា អលាភា តេសំ ទុល្លទ្ធំ យេ តុម្ហេ ឯវំ សោកសភយេ[១] ជីវិតេ មរណសភយេ ជីវិតេ អប្បេកទា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសថ អប្បេកទា ន ឧបវសថ ។

---

១ សោកភយេតិ វា បាឋោ ។

ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១០ ក្នុងការចូលទៅខាងក្នុងរាជបុរី ។ ម្នាលភិក្ខុទាំងឡាយ ទោស ១០ យ៉ាងនេះឯង រមែងមានក្នុងការចូលទៅខាងក្នុងរាជបុរី ។

[៤៦] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ពួកសក្យឧបាសកជាច្រើន បានចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងថ្ងៃឧបោសថនោះ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកសក្យឧបាសក អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ជួនកាល យើងទាំងឡាយ បានរក្សាឧបោសថប្រកបដោយអង្គ ៨ ជួនកាល យើងទាំងឡាយ មិនបានរក្សា ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយនោះពេញជាឥតលាភហើយ ការបាននូវអត្តភាពជាមនុស្ស អ្នកទាំងឡាយនោះបានដោយកម្រ ដ្បិតថាអ្នកទាំងឡាយ ជួនកាលក៏បានរក្សាឧបោសថប្រកបដោយអង្គ ៨ ជួនកាលក៏មិនបានរក្សា ក្នុងជីវិតប្រកបដោយសោកនិងភ័យ ក្នុងជីវិតប្រកបដោយមរណៈនិងភ័យយ៉ាងនេះ ។

តំ កឹ មញ្ញថ សក្កា ។ ឥធ បុរិសោ យេន[២] កម្មដ្ឋានេន អញបជ្ជ អកុសលំ ជិវសំ អឌ្ឍកហាបណំ និព្វិសេយ្យ ទក្ខោ បុរិសោ ឧដ្ឋានសម្បន្នោតិ អលំ វចនាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សក្កា ។ ឥធ បុរិសោ យេន កម្មដ្ឋានេន អញបជ្ជ អកុសលំ ជិវសំ កហាបណំ និព្វិសេយ្យ ទក្ខោ បុរិសោ ឧដ្ឋានសម្បន្នោតិ អលំ វចនាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សក្កា ។ ឥធ បុរិសោ យេន កម្មដ្ឋានេន អញបជ្ជ អកុសលំ ជិវសំ ទ្វេ កហាបណេ និព្វិសេយ្យ តយោ កហាបណេ និព្វិសេយ្យ ចត្តារោ កហាបណេ និព្វិសេយ្យ បញ្ច កហាបណេ និព្វិសេយ្យ ឆ កហាបណេ និព្វិសេយ្យ សត្ត កហាបណេ និព្វិសេយ្យ អដ្ឋ កហាបណេ និព្វិសេយ្យ

---

២ ឱ. ម. យេន កេនចីតិ អត្ថិ ។

ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះ ដូចម្តេច ។ បុរសក្នុងលោកនេះ ក្នុង ១ ថ្ងៃ រកបានកន្លះកហាបណៈដោយហេតុនៃការងារណាមួយ ដែលមិនប៉ះពាល់អកុសលកម្ម តើគួរហៅថា បុរសអ្នកឈ្លាស បរិបូណ៌ដោយសេចក្តីព្យាយាមដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ។ បុរសក្នុងលោកនេះ ក្នុង ១ ថ្ងៃ រកបាន ១ កហា-បណៈ ដោយហេតុនៃការងារណាមួយ ដែលមិនប៉ះពាល់អកុសលកម្ម តើគួរហៅថា បុរសអ្នកឈ្លាស បរិបូណ៌ដោយសេចក្តីព្យាយាមដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុដូចម្តេច ។ បុរសក្នុងលោកនេះ ក្នុង ១ ថ្ងៃរកបាន ២ កហាបណៈ ដោយហេតុនៃការងារណាមួយ ដែលមិនប៉ះពាល់អកុសលកម្ម រកបាន ៣ កហាបណៈ រកបាន ៤ កហាបណៈ រកបាន ៥ កហាបណៈ រកបាន ៦ កហាបណៈ រកបាន ៧ កហាបណៈ រកបាន ៨ កហាបណៈ

នវ កហាបណេ និព្វិសេយ្យ ទស កហាបណេ និព្វិសេយ្យ វីសំ កហាបណេ និព្វិសេយ្យ តឹសំ កហាបណេ និព្វិសេយ្យ ចត្តាឡីសំ កហាបណេ និព្វិសេយ្យ បញ្ញាសំ កហាបណេ និព្វិសេយ្យ កហាបណសតំ និព្វិសេយ្យ ទក្ខោ បុរិសោ ឧដ្ឋានសម្បន្នោតិ អលំ វចនាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សក្កា ។ អបិ នុ ខោ សោ បុរិសោ ទិវសេ[១] កហាបណសតំ កហាបណសហស្សំ និព្វិសមានោ លទ្ធំ លទ្ធំ និក្ខិបន្តោ[២] វស្សសតជីវី មហន្តំ ភោគក្ខន្ធំ អធិគច្ឆេយ្យាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សក្កា ។ អបិ នុ ខោ សោ បុរិសោ ភោគហេតុកំ ភោគនិទានំ ភោគាធិករណំ ឯកំ វា រត្តឹ ឯកំ វា ទិវសំ ឧបឌ្ឍំ វា រត្តឹ ឧបឌ្ឍំ វា ទិវសំ ឯកន្តសុខប្បដិសំវេទី វិហរេយ្យាតិ ។

---

១ ឱ. ម. អបិ នុ សោ បុរិសោ ទិវសេ ទិវសេតិ អត្ថិ ។ ២ ឱ. ម. ឯត្ថន្តរេ វស្សសតាយុកោតិ បាឋោ ទិស្សតិ ។

រកបាន ៩ កហាបណៈ រកបាន ១០ កហាបណៈ រកបាន ២០ កហាបណៈ រកបាន ៣០ កហាបណៈ រកបាន ៤០ កហាបណៈ រកបាន ៥០ កហាបណៈ រកបាន ១០០ កហាបណៈ តើគួរហៅថា បុរសអ្នកឈ្លាស បរិបូណ៌ដោយសេចក្តីព្យាយាមដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះ ដូចម្តេច ។ បុរសនោះ កាលរកបាន ១០០ កហាបណៈ ១.០០០ កហាបណៈ ក្នុងមួយថ្ងៃ ទុកដាក់នូវកហាបណៈ ដែលខ្លួនរកបានហើយ ៗ រស់នៅបាន ១០០ ឆ្នាំ គប្បីបាននូវគំនរនៃភោគៈដ៏ច្រើនដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះ ដូចម្តេច ។ បុរសនោះ គប្បីបានទទួលនូវសុខយ៉ាងឯក អស់រាត្រីមួយ ឬមួយថ្ងៃ អស់កន្លះរាត្រី ឬ កន្លះថ្ងៃ ដែលមានភោគៈជាហេតុ មានភោគៈជាគ្រឿងប្រគល់ឲ្យ មានភោគៈជាអធិករណ៍ មែនដែរឬ ។

ណោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ កាមា ហិ ភន្តេ អនិច្ចា តុច្ឆា មុសា មោសធម្មាតិ ។ ឥធ បន វា សក្កា មម សាវកោ ទស វស្សានិ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ យថា មយានុសិដ្ឋំ តថា បដិបជ្ជមានោ សតំបិ វស្សានិ សតំបិ វស្សសតានិ សតំបិ វស្សសហស្សានិ ឯកន្តសុខប្បដិសំវេទី វិហរេយ្យ ។ សោ ច ខ្វស្ស សកទាគាមី វា អនាគាមី វា អបណ្ណកំ វា សោ-តាបន្នោ ។ តិដ្ឋន្តុ សក្កា ទស វស្សានិ ឥធ មម សាវកោ នវ វស្សានិ អដ្ឋ វស្សានិ សត្ត វស្សានិ ឆ វស្សានិ បញ្ច វស្សានិ ចត្តារិ វស្សានិ តីណិ វស្សានិ ទ្វេ វស្សានិ ឯកំ វស្សំ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ យថា មយានុសិដ្ឋំ យថា បដិបជ្ជ-មានោ សតំបិ វស្សានិ សតំបិ វស្សសតានិ សតំបិ វស្សសហស្សានិ ឯកន្តសុខប្បដិសំវេទី វិហរេយ្យ ។

ហេតុនុ៎ះ មិនមែនទេ ព្រះអង្គ ។ រឿងនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា កាមទាំងឡាយមិនទៀង ទទេ មិនពិត វិនាសទៅជាធម្មតា ។ ម្នាលសក្យៈទាំងឡាយ ចំណែកខាងសាវ័ករបស់តថាគត ក្នុងសាសនានេះជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគត ប្រៀនប្រដៅហើយ អស់ ១០ ឆ្នាំ គប្បីទទួលសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំ ក៏មាន ១០.០០០ (១ម៉ឺន) ឆ្នាំ ក៏មាន ១០០.០០០ (១សែន) ឆ្នាំ ក៏មាន ។ សាវ័ករបស់តថាគត នោះបានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំង-ឡាយ ១០ ឆ្នាំលើកទុកចុះ សាវ័ករបស់តថាគតក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគត ប្រៀនប្រដៅហើយ អស់ ៩ ឆ្នាំ ៨ ឆ្នាំ ៧ ឆ្នាំ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ គប្បីទទួលនូវសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំ ក៏មាន ១០.០០០ (១ម៉ឺន) ឆ្នាំក៏មាន ១០០.០០០ (១សែន) ឆ្នាំ ក៏មាន ។

១៨៣



សោ ច ខ្វស្ស សកទាគាមី វា អនាគាមី វា អបណ្ណកំ វា សោតាបន្នោ ។ តិដ្ឋតុ សក្កា ឯកំ វស្សំ ឥធ មម សាវកោ ទស មាសេ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ យថា មយានុសិដ្ឋំ តថា បដិបជ្ជមានោ សតំបិ វស្សានិ សតំបិ វស្សសតានិ សតំបិ វស្សសហស្សានិ ឯកន្តសុខប្បដិសំវេទី វិហរេយ្យ ។ សោ ច ខ្វស្ស សកទាគាមី វា អនាគាមី វា អបណ្ណកំ វា សោតាបន្នោ ។ តិដ្ឋន្តុ សក្កា ទស មាសា ឥធ មម សាវកោ នវ មាសេ អដ្ឋ មាសេ សត្ត មាសេ ឆ មាសេ បញ្ច មាសេ ចត្តារោ មាសេ តយោ មាសេ ទ្វេ មាសេ ឯកមាសំ អឌ្ឍមាសំ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ យថា មយានុសិដ្ឋំ តថា បដិបជ្ជមានោ សតំបិ វស្សានិ សតំបិ វស្សសតានិ សតំបិ វស្ស-សហស្សានិ ឯកន្តសុខប្បដិសំវេទី វិហរេយ្យ ។

សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ៗ ម្នាលសក្យៈទាំងឡាយ ១ ឆ្នាំលើកទុកចុះ សាវ័ករបស់តថាគត ក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគត ប្រៀនប្រដៅហើយ អស់ត្រឹមតែ ១០ ខែ ក៏គប្បីទទួលនូវសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំ ក៏មាន ១០.០០០ (១ម៉ឺន) ឆ្នាំ ក៏មាន ១០០.០០០ (១សែន) ឆ្នាំ ក៏មាន ៗ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ៗ ម្នាលសក្យៈទាំងឡាយ ១០ ខែលើកទុកចុះ សាវ័ករបស់តថាគត ក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគត ប្រៀនប្រដៅហើយ អស់ ៩ ខែ ៨ ខែ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែ ក៏គប្បីបានទទួលនូវសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំ ក៏មាន ១០.០០០ ( ១ម៉ឺន ) ឆ្នាំ ក៏មាន ១០០.០០០ ( ១សែន ) ឆ្នាំ ក៏មាន ៗ

សោ ច ខ្វស្ស សកទាគាមី វា អនាគាមី វា អបណ្ណកំ វា សោតាបន្នោ ។ តិដ្ឋតុ សត្តា អឌ្ឍមាសោ ឥធ មម សាវកោ ទស រត្តិន្ទិវេ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ យថា មយានុសិដ្ឋំ តថា បដិបជ្ជមានោ សតំបិ វស្សានិ សតំបិ វស្សសតានិ សតំបិ វស្សសហស្សានិ ឯកន្តសុខប្បដិសំវេទី វិហរេយ្យ ។ សោ ច ខ្វស្ស សកទាគាមី វា អនាគាមី វា អបណ្ណកំ វា សោតាបន្នោ ។ តិដ្ឋន្តុ សត្តា ទស រត្តិន្ទិវា ឥធ មម សាវកោ នវ រត្តិន្ទិវេ អដ្ឋ រត្តិន្ទិវេ សត្ត រត្តិន្ទិវេ ឆ រត្តិន្ទិវេ បញ្ច រត្តិន្ទិវេ ចត្តារោ រត្តិន្ទិវេ តយោ រត្តិន្ទិវេ ទ្វេ រត្តិន្ទិវេ ឯករត្តិន្ទិវំ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ យថា មយានុសិដ្ឋំ តថា បដិបជ្ជមានោ សតំបិ វស្សានិ សតំបិ វស្សសតានិ សតំបិ វស្សសហស្សានិ ឯកន្តសុខប្បដិសំវេទី វិហរេយ្យ ។

សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ កន្លះខែលើកទុកចុះ សាវ័ករបស់តថាគត ក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគត ប្រៀនប្រដៅហើយ អស់យប់និងថ្ងៃ ១០ ក៏គប្បីបានទទួលនូវសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំក៏មាន ១០.០០០ (១ម៉ឺន) ឆ្នាំ ក៏មាន ១០០.០០០ (១សែន) ឆ្នាំ ក៏មាន ។ សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ យប់និងថ្ងៃ ១០ លើកទុកចុះ សាវ័ករបស់តថាគតក្នុងសាសនានេះជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រតិបត្តិតាមពាក្យដែលតថាគត ប្រៀនប្រដៅហើយ អស់យប់និងថ្ងៃ ៩ យប់និងថ្ងៃ ៨ យប់និងថ្ងៃ ៧ យប់និងថ្ងៃ ៦ យប់និងថ្ងៃ ៥ យប់និងថ្ងៃ ៤ យប់និងថ្ងៃ ៣ យប់និងថ្ងៃ ២ យប់និងថ្ងៃ ១ ក៏គប្បីបានទទួលនូវសេចក្តីសុខយ៉ាងឯក អស់ ១០០ ឆ្នាំ ក៏មាន ១០.០០០ (១ម៉ឺន) ឆ្នាំ ក៏មាន ១០០.០០០ (១សែន) ឆ្នាំក៏មាន ។

សោ ច ខ្វស្ស សកទាគាមី វា អនាគាមី វា អបណ្ណកំ វា សោតាបន្នោ ។ តេសំ វោ សត្តា អលាភា តេសំ ទុល្លទ្ធំ យេ តុម្ហេ ឯវំ សោកសភយេ ជីវិតេ មរណសភយេ ជីវិតេ អប្បេកទា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសថ អប្បេកទា ន ឧបវសថាតិ ។ ឯតេ មយំ ភន្តេ អជ្ជតគ្គេ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិស្សាមាតិ ។

[៤៧] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ មហាលិ លិច្ឆវី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហាលិ លិច្ឆវី ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយាតិ ។

សាវ័ករបស់តថាគតនោះ បានជាសកទាគាមីខ្លះ អនាគាមីខ្លះ បានដល់សោតៈពិតប្រាកដខ្លះ ។ ម្នាលសក្យៈទាំងឡាយ អ្នកទាំងឡាយចំជាឥតលាភហើយ ការបាននូវអត្តភាពជាមនុស្ស អ្នកទាំងឡាយនោះបានដោយកម្រ ដ្បិតថា អ្នកទាំងឡាយ ជួនកាល បានរក្សាឧបោសថប្រកបដោយអង្គ ៨ ជួនកាល មិនបានរក្សា ក្នុងជីវិតប្រកបដោយសោកនិងភ័យ ក្នុងជីវិតប្រកបដោយមរណៈនិងភ័យយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងទាំងឡាយនេះ នឹងរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ចាប់ដើមតាំងពីថ្ងៃនេះ តរៀងទៅ ។

[៤៧] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ លិច្ឆវី ឈ្មោះមហាលិ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះលិច្ឆវី ឈ្មោះមហាលិ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យនៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏លាមក ។

លោភោ ខោ មហាលិ ហេតុ លោភោ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា ទោសោ ខោ មហាលិ ហេតុ ទោសោ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា មោហោ ខោ មហាលិ ហេតុ មោហោ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា អយោនិសោ មនសិការោ ខោ មហាលិ ហេតុ អយោនិសោ មនសិការោ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា មិច្ឆាបណិហិតំ ខោ មហាលិ ចិត្តំ ហេតុ មិច្ឆាបណិហិតំ ចិត្តំ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា ។ អយំ ខោ មហាលិ ហេតុ អយំ បច្ចយោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយាតិ ។

ម្នាលមហាលិ លោភៈជាហេតុ លោភៈជាបច្ច័យនៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏លាមក ម្នាលមហាលិ ទោសៈជាហេតុ ទោសៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏លាមក ម្នាលមហាលិ មោហៈជាហេតុ មោហៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏លាមក ម្នាលមហាលិ អយោនិសោមនសិការៈ (ការមិនបានធ្វើទុកក្នុងចិត្ត ដោយឧបាយ) ជាហេតុ អយោនិសោមនសិការៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏លាមក ម្នាលមហាលិ ចិត្តដែលបុគ្គលតម្កល់ខុស ជាហេតុ ចិត្តដែលបុគ្គលតម្កល់ខុស ជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តតទៅ នៃកម្មដ៏លាមក ។ ម្នាលមហាលិ នេះជាហេតុ នេះជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏លាមក នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏លាមក ។

កោ បន ភន្តេ ហេតុ កោ បច្ចយោ កល្យាណស្ស កម្មស្ស កិរិយាយ កល្យា-ណស្ស កម្មស្ស បវត្តិយាតិ ។ អលោភោ ខោ មហាលិ ហេតុ អលោភោ បច្ចយោ កល្យាណស្ស កម្មស្ស កិរិយាយ កល្យាណស្ស កម្មស្ស បវត្តិយា អទោសោ ខោ មហាលិ ហេតុ អទោសោ បច្ចយោ កល្យាណស្ស កម្មស្ស កិរិយាយ កល្យាណស្ស កម្មស្ស បវត្តិយា អមោហោ ខោ មហាលិ ហេតុ អមោហោ បច្ចយោ កល្យាណស្ស កម្មស្ស កិរិយាយ កល្យាណស្ស កម្មស្ស បវត្តិយា យោនិសោ មនសិការោ ខោ មហាលិ ហេតុ យោនិសោ មនសិ-ការោ បច្ចយោ កល្យាណស្ស កម្មស្ស កិរិយាយ កល្យាណស្ស កម្មស្ស បវត្តិយា សម្មាបណិហិតំ ខោ មហាលិ ចិត្តំ ហេតុ សម្មាបណិហិតំ ចិត្តំ បច្ចយោ

បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏ល្អ ។ ម្នាលមហាលិ អលោភៈ (ការមិនលោភ) ជាហេតុ អលោភៈជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅនៃកម្មដ៏ល្អ ម្នាលមហាលិ អទោសៈ (ការមិនប្រទូស្ត) ជាហេតុ អទោសៈ ជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏ល្អ ម្នាលមហាលិ អមោហៈ (ការមិនវង្វេង) ជាហេតុ អមោហៈ ជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏ល្អ ម្នាលមហាលិ យោនិសោមនសិការៈ (ការធ្វើទុកក្នុងចិត្ត ដោយឧបាយ) ជាហេតុ យោនិសោមនសិការៈ ជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏ល្អ ចិត្តដែលបុគ្គលតម្កល់ត្រូវ ជាហេតុ ចិត្តដែលបុគ្គលតម្កល់ត្រូវ ជាបច្ច័យ

កល្យាណស្ស កម្មស្ស កិរិយាយ កល្យាណស្ស កម្មស្ស បវត្តិយា ។ អយំ ខោ មហាលិ ហេតុ អយំ បច្ចយោ កល្យាណស្ស កម្មស្ស កិរិយាយ កល្យាណស្ស កម្មស្ស បវត្តិយាតិ ។ ឥមេ ខោ មហាលិ ទស ធម្មា លោកេ ន សំវិជ្ជេយ្យុំ នយិទ បញ្ញាយេថ អធម្មចរិយវិសមចរិយាតិ វា ធម្មចរិយសមចរិយាតិ វា ។ យស្មា ច ខោ មហាលិ ឥមេ ទស ធម្មា លោកេ សំវិជ្ជន្តិ តស្មា បញ្ញាយតិ អធម្មចរិយវិសមចរិយាតិ វា ធម្មចរិយសមចរិយាតិ វាតិ ។

[៤៨] ទសយិមេ ភិក្ខវេ ធម្មា បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វា ។ កតមេ ទស ។ វេវណ្ណិយម្ហិ អជ្ឈុបគតោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ បរប្បដិពទ្ធា មេ ជីវិកាតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ អញ្ញោ មេ អាកប្បោ ករណីយោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ

នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏ល្អ ។ ម្នាលមហាលិ នេះជាហេតុ នេះជាបច្ច័យ នៃកិរិយាធ្វើនូវកម្មដ៏ល្អ នៃកិរិយាប្រព្រឹត្តទៅ នៃកម្មដ៏ល្អ ។ ម្នាលមហាលិ បើធម៌ ១០ យ៉ាងនេះ មិនគប្បីមានក្នុងលោកទេ ពាក្យថា អធម្មចរិយវិសមចរិយាក្តី[១] ពាក្យថា ធម្មចរិយសមចរិយាក្តី[២] ក៏មិនគប្បីប្រាកដ ក្នុងលោកនេះដែរ ។ ម្នាលមហាលិ ព្រោះតែធម៌ ១០ យ៉ាងនេះ មានប្រាកដក្នុងលោក ហេតុនោះបានជាពាក្យថា អធម្មចរិយវិសមចរិយាក្តី ធម្មចរិយសមចរិយាក្តី ទើបមានប្រាកដ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ បព្វជិតគប្បីពិចារណារឿយ ៗ ។ ធម៌ ១០ យ៉ាងគឺអ្វីខ្លះ ។ គឺបព្វជិត គប្បីពិចារណារឿយ ៗ ថា អាត្មាអញកាន់យកនូវភេទដ៏ប្លែក អំពីភេទរបស់គ្រហស្ថ ១ បព្វជិតគប្បីពិចារណារឿយ ៗ ថា ការប្រព្រឹត្តចិញ្ចឹមជីវិត របស់អាត្មាអញប្រព្រឹត្តជាប់ ដោយបុគ្គលដទៃ ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា អាកប្បកិរិយាផ្សេងអំពីគ្រហស្ថ អាត្មាអញគួរធ្វើ ១

---

១ កិរិយាប្រព្រឹត្តមិនស្មើ បានដល់ការមិនប្រព្រឹត្តធម៌ដោយអំណាចអកុសលកម្មបថ ។
២ កិរិយាប្រព្រឹត្តស្មើ បានដល់ការប្រព្រឹត្តធម៌ដោយអំណាចកុសលកម្មបថ ។ អដ្ឋកថា ។

១៨៩



កច្ចិ នុ ខោ មេ អត្តា សីលតោ ន ឧបវទតីតិ
បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ កច្ចិ នុ ខោ មំ
អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តីតិ
បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ សព្វេហិ មេ
បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ
បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ កម្មស្សកោម្ហិ
កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិ-
សរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា
បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ បព្វជិតេន
អភិណ្ហំ បច្ចវេក្ខិតព្វំ កថម្ភូតស្ស មេ រត្តិន្ទិវា
វីតិបតន្តីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ កច្ចិ
នុ ខោហំ សុញ្ញាគារេ អភិរមាមីតិ បព្វជិតេន
អភិណ្ហំ បច្ចវេក្ខិតព្វំ អត្ថិ នុ ខោ មេ
ឧត្តរិមនុស្សធម្មា អលមរិយញាណទស្សនវិសេសោ

បព្វជិត គប្បីពិចារណារឿយ ៗ ថា អាត្មាអញមិនតិះដៀលខ្លួនឯង ដោយសីលធម៌បានទេឬ ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា ពួកសព្រហ្មចារីជាវិញ្ញូជន គយគន់មើលហើយ មិនតិះដៀលអាត្មាអញ ដោយសីលធម៌បានទេឬ ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា ការព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារទាំងអស់ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៃអាត្មាអញតែងមានជាធម្មតា ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្សមានកម្មជាគ្រឿងរលឹកឃើញ អាត្មាអញនឹងធ្វើនូវកម្មណា ល្អ ឬអាក្រក់អាត្មាអញគង់នឹងបានជាអ្នកទទួលយកនូវផល នៃកម្មនោះពុំខានឡើយ ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា យប់និងថ្ងៃទាំងឡាយ ចេះតែកន្លងទៅ ៗ តើអាត្មាអញ បានធ្វើដូចម្តេចខ្លះហើយ ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា សព្វថ្ងៃនេះ អាត្មាអញមានសេចក្តីអភិរម្យ ត្រេកអរក្នុងផ្ទះដ៏ស្ងាត់ខ្លះដែរ ឬទេ ១ បព្វជិត គប្បីពិចារណារឿយ ៗ ថា ឧត្តរិមនុស្សធម៌ គឺ ធម៌ជារបស់មនុស្ស ដ៏ប្រសើរក្រៃលែង មានដល់អាត្មាអញដែរឬ ធម៌ដ៏វិសេស ដែលគួរនឹងឃើញ ដោយប្រាជ្ញាដ៏ប្រសើរ

អជិតោ សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ ន មង្កុ ភវិស្សាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វាតិ ។

[៤៩] ទសយិមេ ភិក្ខវេ ធម្មា បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វា សរីរដ្ឋា ។ កតមេ ទស ។ សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ កាយសំវរោ វចីសំវរោ អាជីវសំវរោ ពោនោព្ភវិកោ ភវសង្ខារោ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា សរីរដ្ឋាតិ ។

[៥០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា ឧបដ្ឋានសាលាយំ សន្និសិន្នា សន្និបតិតា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តិ[១] ។

១ ឱ. ម. វិតុទន្តា វិហរន្តិ ។

អាត្មាអញបានត្រាស់ដឹងហើយឬ អាត្មាអញនោះសព្រហ្មចារីទាំងឡាយ សួរក្នុងកាលជាទីបំផុត (មរណសម័យ) នឹងមិនអិមអៀមទេឬ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯង បព្វជិតគប្បីពិចារណារឿយ ៗ ។

[៤៩] ម្នាលភិក្ខុទាំងឡាយ ធម៌ដែលឋិតនៅក្នុងសរីរៈ ១០ យ៉ាងនេះ បព្វជិតគប្បីពិចារណារឿយ ៗ ។ ធម៌ ១០ យ៉ាងតើអ្វីខ្លះ ។ គឺត្រជាក់ ១ ក្ដៅ ១ សេចក្ដីឃ្លាន ១ ស្រេក ១ ឧច្ចារៈ ១ បស្សាវៈ ១ សង្រួមកាយ ១ សង្រួមវាចា ១ សង្រួមក្នុងការចិញ្ចឹមជីវិត ១ ភវសង្ខារ ដែលនាំសត្វឲ្យកើត ក្នុងភពទៀត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯង ដែលឋិតនៅក្នុងសរីរៈ ។

[៥០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ អង្គុយប្រជុំគ្នា ក្នុងឧបដ្ឋានសាលា កើតមានសេចក្ដីប្រកួតប្រកាន់ឈ្លោះប្រកែក និយាយចាក់ដោតគ្នា ដោយលំពែងគឺមាត់ ។

អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយនុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា[១] កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ មយំ ភន្តេ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា ឧបដ្ឋានសាលាយំ សន្និសិន្នា សន្និបតិតា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរាមាតិ ។ ន ខោ បនេតំ ភិក្ខវេ តុម្ហាកំ បតិរូបំ កុលបុត្តានំ សទ្ធា អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរេយ្យាថ ។ ទសយិមេ ភិក្ខវេ ធម្មា សារណីយា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តិ ។

---

១ ម. ឯត្ថន្តរេ សន្និបតិតាតិ បាឋោ អត្ថិ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីពួនសម្ងំ ក្នុងសាយណ្ហ-សម័យ ក៏ចូលទៅរកឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នាដោយកថាដូចម្តេច ចុះអន្តរាកថាដូចម្តេច ដែលអ្នកទាំងឡាយធ្វើមិនទាន់ដាច់ស្រេច ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ យើងខ្ញុំទាំងឡាយ ត្រឡប់មកអំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងឧបដ្ឋានសាលា ក៏កើតមានសេចក្តីប្រកួតប្រកាន់ ឈ្លោះប្រកែក និយាយចាក់ដោតគ្នាដោយលំពែងគឺមាត់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មានសេចក្តីប្រកួតប្រកាន់ ឈ្លោះប្រកែក និយាយចាក់ដោតគ្នា ដោយលំ-ពែងគឺមាត់ ព្រោះហេតុណា ហេតុនុ៎ះ មិនសមគួរដល់អ្នកទាំងឡាយជាកុលបុត្ត អ្នកមានសទ្ធាចេញចាកផ្ទះ ចូលមកកាន់ផ្នួសសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ ជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីមូលមិត្រគ្នា ។

កតមេ ទស ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរ-សម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ យម្បិ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ អយម្បិ ធម្មោ សារាណីយោ បិយករ-ណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្ប-ដិវិទ្ធា ។ យម្បិ ភិក្ខវេ ភិក្ខុ ពហុស្សុតោ ហោតិ ។ បេ ។

ធម៌ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ដោយហេតុណា នេះជាធម៌ គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយមួយទៀត ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុងប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះឯង ក៏បានស្តាប់ច្រើន បានចាំទុក ចាំស្ទាត់រត់មាត់ ជាក់ច្បាស់ ក្នុងចិត្តត្រាស់ដឹងល្អដោយទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាពហុស្សូត ។ បេ ។

ទិដ្ឋិយា សុប្បដិវិទ្ធា អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ យម្បិ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនឹ ។ យម្បិ ភិក្ខវេ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនឹ អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា

ចេះដឹងល្អ ដោយទិដ្ឋិ ដោយហេតុណា នេះជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានមិត្រល្អ មានសំឡាញ់ល្អ សមគប់រកមិត្រល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានមិត្រល្អ មានសំឡាញ់ល្អ សមគប់រកមិត្រល្អ ដោយហេតុណា នេះ ជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈ ជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ ដោយហេតុណា នេះ ជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា

ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។ យម្បិ ភិក្ខវេ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ ។ យម្បិ ភិក្ខវេ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ អយម្បិ ធម្មោ សារាណីយោ

ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កិច្ចការណានីមួយ ធំ ឬ តូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងនោះ ប្រកបដោយឧបាយជាគ្រឿងពិចារណា ក្នុងកិច្ចការទាំងនោះថា គួរធ្វើ គួរចាត់ចែង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចការណានីមួយ ធំ ឬ តូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងនោះ ប្រកបដោយឧបាយជាគ្រឿងពិចារណា ក្នុងកិច្ចការទាំងនោះថា គួរធ្វើ គួរចាត់ចែង ដោយហេតុណា នេះជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាក្នុងធម៌ មានការហៅរកដោយពាក្យជាទីស្រឡាញ់ អ្នកមានសេចក្តីរីករាយ ដ៏លើសលុបក្នុងអភិធម្ម ក្នុងអភិវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នានូវធម៌ មានការហៅរកដោយពាក្យជាទីស្រឡាញ់ អ្នកមានសេចក្តីរីករាយ ដ៏លើសលុប ក្នុងអភិធម្ម ក្នុងអភិវិន័យ ដោយហេតុណា នេះ ជាធម៌គួររលឹករកគ្នា

បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្ប-ទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុស-លេសុ ធម្មេសុ ។ យម្បិ ភិក្ខវេ ភិក្ខុ អារទ្ធ-វីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសន-គិលានប្បច្ចយភេសជ្ជបរិក្ខារេន ។ យម្បិ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរ-បិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន

ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីធ្វើនូវពួកកុសលធម៌ឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងពួកកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីធ្វើពួកកុសលធម៌ ឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងពួកកុសលធម៌ ដោយហេតុណា នេះជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រម-ព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោស ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកសន្តោស ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន

អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។ យម្បិ ភិក្ខវេ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។

ដោយហេតុណា នេះ ជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងភាវៈជាអ្នកមានប្រាជ្ញាចាស់ក្លា ដ៏ប្រសើរ រលឹកឃើញរឿយ ៗ នូវកិច្ច ដែលខ្លួនធ្វើយូរហើយផង នូវសម្តី ដែលខ្លួននិយាយយូរហើយផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងភាវៈជាអ្នកមានប្រាជ្ញាចាស់ក្លា ដ៏ប្រសើរ រលឹកឃើញរឿយ ៗ នូវកិច្ច ដែលខ្លួនធ្វើយូរហើយផង នូវសម្តី ដែលខ្លួននិយាយយូរហើយផង ដោយហេតុណា នេះ ជាធម៌គួររលឹកគ្នា ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើនូវសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។

១៩៧



បុន ចបរំ ភិក្ខវេ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ យម្បិ ភិក្ខវេ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា សារាណីយា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តីតិ ។

អក្កោសវគ្គោ បញ្ចមោ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់នូវការកើតឡើង និងសេចក្ដីវិនាសទៅ (នៃខន្ធបញ្ចកៈ) ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លាយបង់នូវកិលេស ជាធម្មជាតិ ដល់នូវការអស់ទៅនៃទុក្ខ ដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់នូវការកើតឡើង និងវិនាសទៅ ជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទម្លាយបង់នូវកិលេស ជាធម្មជាតិ ដល់នូវកិរិយាអស់ទៅនៃទុក្ខ ដោយប្រពៃ ដោយហេតុណា នេះជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ១ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ ១០ យ៉ាងនេះឯង ជាធម៌គួររលឹករកគ្នា ធ្វើនូវសេចក្ដីស្រឡាញ់ ធ្វើនូវសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ។

ចប់ អក្កោសវគ្គ ទី ៥ ។

# តស្សុទ្ទានំ

វិរាគា ទ្វេ ច មូលានិ
កុសិនារា បវេសនេ
សក្កា មហាលិ ជម្ពា[១] ច
សរីរដ្ឋា ច ភណ្ឌជាតិ ។

១ ឱ. ម. សក្កោ មហាលិ ធម្មោ ច ។

# ឧទ្ទាននៃអក្កោសវគ្គនោះ គឺ

និយាយអំពីវិវាទ ១ វិវាទមូលពីរលើក ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងនគរកុសិនារា ១ ទោសក្នុងការចូលទៅខាងក្នុងរាជបុរី ១ សក្យឧបាសក ១ លិច្ឆវី ឈ្មោះមហាលិ ១ ធម៌ដែលបព្វជិតគួរពិចារណារឿយ ៗ ១ ធម៌ដែលឋិតនៅក្នុងសរីរៈ ១ ពួកភិក្ខុអ្នកមានសេចក្តីប្រកួតប្រកាន់គ្នា ១ ។

---

# សចិត្តវគ្គោ បឋមោ

[៥១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច នោ ចេ ភិក្ខវេ ភិក្ខុ បរចិត្តបរិយាយកុសលោ ហោតិ អថ សចិត្តបរិយាយកុសលា ភវិស្សាមាតិ[១] ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ កថញ្ច ភិក្ខវេ ភិក្ខុ សចិត្តបរិយាយកុសលោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ

១ ឱ. ម. សចិត្តបរិយាយកុសលោ ភវិស្សាមីតិ ។

# សចិត្តវគ្គទី ១

[៥១] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនឈ្លាសក្នុងវារៈនៃចិត្តអ្នកដទៃទេ ត្រូវគិតថា យើងទាំងឡាយ គួរជាអ្នកឈ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកឈ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រីឬបុរស កំលោះជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលពិចារណាមើលនូវស្រមោលមុខរបស់ខ្លួនក្នុងកញ្ចក់ដែលបរិសុទ្ធផូរផង់ ឬក្នុងភាជន៍ទឹកថ្លាបើឃើញធូលី ឬ កន្ទួលក្នុងកញ្ចក់នោះ រមែងព្យាយាម ដើម្បីលះបង់នូវធូលី ឬ កន្ទួលនោះចេញ

នោ ចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តេនេវត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ លាភា វត មេ បរិសុទ្ធំ វត មេតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ បច្ចវេក្ខណា ពហុការា[១] ហោតិ កុសលេសុ ធម្មេសុ អភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ អនភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ ព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ អព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ ថីនមិទ្ធបរិយុដ្ឋិតោ នុ ខោ ពហុលំ វិហរាមិ វិគតថីនមិទ្ធោ នុ ខោ ពហុលំ វិហរាមិ ឧទ្ធតោ នុ ខោ ពហុលំ វិហរាមិ អនុទ្ធតោ នុ ខោ ពហុលំ វិហរាមិ វិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ តិណ្ណវិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ កោធនោ នុ ខោ ពហុលំ វិហរាមិ អក្កោធនោ នុ ខោ ពហុលំ វិហរាមិ

---

១ ម. ភិក្ខុ បច្ចវេក្ខមានោ ពហុការោ ។

បើមិនឃើញធូលីឬកន្ទួលក្នុងកញ្ចក់នោះទេ ក៏មានចិត្តត្រេកអរ មានសេចក្តីត្រិះរិះគ្រប់គ្រាន់ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ មុខរបស់អាត្មាអញបរិសុទ្ធ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជាការពិចារណា ក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើនដល់ភិក្ខុថា អាត្មាអញជាអ្នកមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានចិត្តព្យាបាទច្រើនឬហ្ន៎ អាត្មាអញជាអ្នកត្រូវថីនមិទ្ធៈរួបរឹតច្រើនឬហ្ន៎ អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានចិត្តអណ្តែតអណ្តូងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមិនមានចិត្តអណ្តែតអណ្តូងច្រើនឬហ្ន៎ អាត្មាអញជាអ្នកមានវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើនឬហ្ន៎ អាត្មាអញមានសេចក្តីក្រោធច្រើន ឬហ្ន៎

២០១



សំកិលិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ អសំកិ-លិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ សារទ្ធកាយោ នុ ខោ ពហុលំ វិហរាមិ អសារទ្ធកាយោ នុ ខោ ពហុលំ វិហរាមិ កុសីតោ នុ ខោ ពហុលំ វិហរាមិ អារទ្ធវីរិយោ នុ ខោ ពហុលំ វិហរាមិ អសមាហិតោ នុ ខោ ពហុលំ វិហរាមិ សមា-ហិតោ នុ ខោ ពហុលំ វិហរាមីតិ ។ សចេ ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភិជ្ឈាលុ ពហុលំ វិហរាមិ ព្យាបន្នចិត្តោ ពហុលំ វិហរាមិ ថីនមិទ្ធបរិយុដ្ឋិតោ ពហុលំ វិហរាមិ ឧទ្ធតោ ពហុលំ វិហរាមិ វិចិកិច្ឆោ ពហុលំ វិហរាមិ កោធនោ ពហុលំ វិហរាមិ សំកិលិដ្ឋចិត្តោ ពហុលំ វិហរាមិ សារទ្ធកាយោ ពហុលំ វិហរាមិ កុសីតោ ពហុលំ វិហរាមិ អសមាហិតោ ពហុលំ វិហរាមីតិ ។

អាត្មាអញ ជាអ្នកមានចិត្តសៅហ្មងច្រើនឬហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តមិនសៅហ្មងច្រើនឬហ្ន៎ អាត្មាអញ ជាអ្នកមានកាយក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញ មានកាយមិនបានក្រវល់ក្រវាយច្រើនឬហ្ន៎ អាត្មាអញមានសេចក្ដីខ្ជិលច្រអូសច្រើនឬហ្ន៎ អាត្មាអញ មានព្យាយាមប្រារព្ធហើយច្រើនឬហ្ន៎ អាត្មាអញ មានចិត្តមិនខ្ជាប់ខ្ជួនច្រើនឬហ្ន៎ អាត្មាអញ មានចិត្តខ្ជាប់ខ្ជួនច្រើន ឬហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុកាលពិចារណាដឹងយ៉ាងនេះថា អាត្មាអញ មានអភិជ្ឈាច្រើន អាត្មាអញ មានចិត្តព្យាបាទច្រើន អាត្មាអញ ត្រូវថីនមិទ្ធៈរួបរឹតច្រើន អាត្មាអញ មានចិត្តអណ្ដែតអណ្ដូងច្រើន អាត្មាអញ មានវិចិកិច្ឆាច្រើន អាត្មាអញ មានសេចក្ដីក្រោធច្រើន អាត្មាអញ មានចិត្តសៅហ្មងច្រើន អាត្មាអញ មានកាយក្រវល់ក្រវាយច្រើន អាត្មាអញជាអ្នកខ្ជិលច្រអូសច្រើន អាត្មាអញ មានចិត្តមិនខ្ជាប់ខ្ជួនច្រើន ។

តេន ភិក្ខវេ ភិក្ខុនា តេសំយេវ ចាបកានំ អកុ-
សលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច
វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហិ ច អប្បដិវានី
ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យ-
ថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា
តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ
អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោ-
ឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច
ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសំ
យេវ ចាបកានំ អកុសលានំ ធម្មានំ បហានាយ
អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច
ឧស្សោឡ្ហិ ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច
ករណីយំ ។ សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ
ឯវំ ជានាតិ អនភិជ្ឈាលុ ពហុលំ វិហរាមិ អព្យាបន្នចិត្តោ
ពហុលំ វិហរាមិ វិគតថីនមិទ្ធោ ពហុលំ វិហរាមិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង ខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលភ្លើងឆេះ ឬ ក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង ខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬ ក្បាលនោះឯង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ ដ៏លាមកទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុកាលពិចារណា ដឹងយ៉ាងនេះថា អាត្មាអញ ជាអ្នកមិនមានអភិជ្ឈាច្រើន អាត្មាអញ ជាអ្នកមានចិត្តមិនព្យាបាទច្រើន អាត្មាអញ ជាអ្នកប្រាសចាកថីនមិទ្ធៈច្រើន

អនុទ្ធតោ ពហុលំ វិហរាមិ តិណ្ណវិចិកិច្ឆោ ពហុលំ វិហរាមិ អក្កោធនោ ពហុលំ វិហរាមិ អសំ-កិលិដ្ឋចិត្តោ ពហុលំ វិហរាមិ អសារទ្ធកាយោ ពហុលំ វិហរាមិ អារទ្ធវិរិយោ ពហុលំ វិហរាមិ សមា-ហិតោ ពហុលំ វិហរាមីតិ ។ តេន ភិក្ខវេ ភិក្ខុនា តេសុយេវ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរឹ អាសវានំ ខយាយ យោគោ ករណីយោតិ ។

[៤២] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច ជោ ចេ អាវុសោ ភិក្ខុ បរចិត្តបរិយាយកុសលោ ហោតិ អថ សចិត្តបរិយាយកុសលា ភវិស្សាមាតិ ។ ឯវញ្ហិ វោ អាវុសោ សិក្ខិតព្វំ ។ កថញ្ចាវុសោ ភិក្ខុ សចិត្តបរិយាយកុសលោ ហោតិ ។

អាត្មាអញ ជាអ្នកមានចិត្ត មិនអណ្តែតអណ្តូងច្រើន អាត្មាអញ ជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើន អាត្មាអញ ជាអ្នកមិនមានសេចក្តីក្រោធច្រើន អាត្មាអញ ជាអ្នកមានចិត្តមិនសៅហ្មងច្រើន អាត្មាអញ ជាអ្នកមានកាយមិនក្រវល់ក្រវាយច្រើន អាត្មាអញ ជាអ្នកប្រារព្ធសេចក្តីព្យាយាមច្រើន អាត្មាអញ ជាអ្នកមានចិត្តខ្ជាប់ខ្ជួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីតាំងនៅក្នុងកុសលធម៌ទាំងនោះ ធ្វើព្យាយាម ដើម្បីឲ្យអស់ទៅនៃអាសវៈទាំងឡាយតទៅ ។

[៩២] ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ថេរវាចា របស់ព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្ត ដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បើភិក្ខុមិនឆ្លាស ក្នុងវារៈនៃចិត្តបុគ្គលដទៃទេ ត្រូវគិតថា យើងទាំងឡាយ គួរជាអ្នកឆ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកឆ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។

សេយ្យថាបិ អាវុសោ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ នោ ចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តេនេវត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ លាភា វត មេ បរិសុទ្ធំ វត មេតិ ឯវមេវ ខោ អាវុសោ ភិក្ខុនោ បច្ចវេក្ខណា ពហុការា ហោតិ កុសលេសុ ធម្មេសុ អភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ អនភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ ព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ អព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ ថីនមិទ្ធបរិយុដ្ឋិតោ នុ ខោ ពហុលំ វិហរាមិ វិគតថីនមិទ្ធោ នុ ខោ ពហុលំ វិហរាមិ ឧទ្ធតោ នុ ខោ ពហុលំ វិហរាមិ

ម្នាលអាវុសោទាំងឡាយ ដូចជាស្ត្រី ឬ បុរស កំលោះ ជំទង់ ប្រកបដោយជាតិ ជាអ្នកស្អិតស្អាង កាលពិចារណាមើលស្រមោលរបស់ខ្លួន ក្នុងកញ្ចក់ ដែលបរិសុទ្ធផូរផង់ ឬ ក្នុងភាជន៍ទឹកថ្លា បើឃើញធូលី ឬ កន្ទួលក្នុងកញ្ចក់ ក៏រមែងព្យាយាមលះបង់នូវធូលី ឬ កន្ទួលនោះចេញ បើមិនឃើញធូលី ឬ កន្ទួលនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញ មានលាភ ឱហ្ន៎ (មុខ) របស់អាត្មាអញ បរិសុទ្ធ យ៉ាងណាមិញ ម្នាលអាវុសោទាំង-ឡាយ ឧបមេយ្យ ដូចជា ការពិចារណា ក្នុងកុសលធម៌ទាំងឡាយរមែងមានឧបការៈច្រើន ដល់ភិក្ខុថា អាត្មាអញ ជាអ្នកមានអភិជ្ឈាច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមិនមានអភិជ្ឈាច្រើន ឬ ហ្ន៎ អាត្មាអញ មានចិត្តព្យាបាទច្រើន ឬហ្ន៎ អាត្មាអញ មិនមានចិត្តព្យាបាទច្រើន ឬហ្ន៎ អាត្មាអញ ត្រូវថីនមិទ្ធៈរួបរឹតច្រើន ឬហ្ន៎ អាត្មាអញ ប្រាសចាកថីនមិទ្ធៈច្រើន ឬហ្ន៎ អាត្មាអញមានចិត្តអណ្តែតអណ្តូងច្រើន ឬហ្ន៎

២០៥



អនុទ្ធតោ នុ ខោ ពហុលំ វិហរាមិ វិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ តិណ្ណវិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ កោធនោ នុ ខោ ពហុលំ វិហរាមិ អក្កោធនោ នុ ខោ ពហុលំ វិហរាមិ សំកិលិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ អសំកិលិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ សារទ្ធកាយោ នុ ខោ ពហុលំ វិហរាមិ អសារទ្ធកាយោ នុ ខោ ពហុលំ វិហរាមិ កុសីតោ នុ ខោ ពហុលំ វិហរាមិ អារទ្ធវីរិយោ នុ ខោ ពហុលំ វិហរាមិ អសមាហិតោ នុ ខោ ពហុលំ វិហរាមិ សមាហិតោ នុ ខោ ពហុលំ វិហរាមីតិ ។ សចេ អាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភិជ្ឈាលុ ពហុលំ វិហរាមិ ។ បេ ។ អសមាហិតោ ពហុលំ វិហរាមីតិ ។

ទុតិយបណ្ណាសក សចិត្តវគ្គ

អាត្មាអញ មិនមានចិត្តអណ្តែតអណ្តូងច្រើន ឬ ហ្ន៎ អាត្មាអញ មានវិចិកិច្ឆា ច្រើន ឬ ហ្ន៎ អាត្មាអញ ឆ្លងវិចិកិច្ឆាច្រើន ឬ ហ្ន៎ អាត្មាអញ មានសេចក្តីក្រោធច្រើន ឬ ហ្ន៎ អាត្មាអញ មិនមានសេចក្តីក្រោធច្រើន ឬ ហ្ន៎ អាត្មាអញ មានចិត្តសៅហ្មងច្រើន ឬ ហ្ន៎ អាត្មាអញ មិនមានចិត្តសៅហ្មងច្រើន ឬ ហ្ន៎ អាត្មាអញ មានកាយក្រវល់ក្រវាយច្រើន ឬ ហ្ន៎ អាត្មាអញ មានកាយមិនក្រវល់ក្រវាយច្រើន ឬ ហ្ន៎ អាត្មាអញ ខ្ជិលច្រអូសច្រើន ឬ ហ្ន៎ អាត្មាអញ ប្រារព្ធព្យាយាមច្រើន ឬ ហ្ន៎ អាត្មាអញមានចិត្ត មិនខ្ជាប់ខ្ជួនច្រើន ឬ ហ្ន៎ អាត្មាអញ មានចិត្តខ្ជាប់ខ្ជួនច្រើន ឬហ្ន៎ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណា រមែងដឹងយ៉ាងនេះថា អាត្មាអញ មានអភិជ្ឈាច្រើន ។ បេ ។ អាត្មាអញ មានចិត្តមិនបានខ្ជាប់ខ្ជួនច្រើន ។

តេនាវុសោ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហិ ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យថាបិ អាវុសោ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ អាវុសោ តេន ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហិ ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អនភិជ្ឈាលុ ពហុលំ វិហរាមិ ។ បេ ។ សមាហិតោ ពហុលំ វិហរាមីតិ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង មិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះនូវពួកអកុសលធម៌ ដ៏លាមកទាំងនោះចេញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬ ក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬ ក្បាលនោះឯង យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ ដ៏លាមកទាំងនោះចេញ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណា រមែងដឹងយ៉ាងនេះថា អាត្មាអញជាអ្នកមិនមានអភិជ្ឈាច្រើន ។ បេ ។ អាត្មាអញ មានចិត្តខ្ជាប់ខ្ជួនច្រើន ។

២០៧



តេជាវុសោ ភិក្ខុនា តេសុយេវ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរឹ អាសវានំ ខយាយ យោគោ ករណីយោតិ ។

[៨៣] ឋិតិម្បហំ ភិក្ខវេ ន វណ្ណេមិ[១] កុសលេសុ ធម្មេសុ បគេវ បរិហានឹ ។ វុឌ្ឍិញ្ច ខោ អហំ ភិក្ខវេ វណ្ណេមិ កុសលេសុ ធម្មេសុ នោ ឋិតឹ នោ ហានឹ ។ កថញ្ច ភិក្ខវេ ហានិ ហោតិ កុសលេសុ ធម្មេសុ នោ ឋិតិ នោ វុឌ្ឍិ ។ ឥធ ភិក្ខវេ ភិក្ខុ យត្តកោ ហោតិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ បដិភាណេន តស្ស តេ ធម្មា នេវ តិដ្ឋន្តិ នោ វឌ្ឍន្តិ ។ ហានិមេតំ ភិក្ខវេ វទាមិ កុសលេសុ ធម្មេសុ នោ ឋិតឹ នោ វុឌ្ឍឹ ។

១ ឱ. ម. ន វណ្ណយាមិ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គួរតាំងនៅ ក្នុងកុសលធម៌ទាំងនោះ ហើយធ្វើនូវសេចក្តីព្យាយាម ដើម្បីអស់ទៅ នៃអាសវៈទាំងឡាយតទៅ ។

[៥៣] ម្នាលភិក្ខុទាំងឡាយ តថាគត មិនសរសើរការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយទេ នឹងបាច់និយាយថ្វីដល់ការសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ តថាគត សរសើរនូវសេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ តែម្យ៉ាង មិនសរសើរការតាំងនៅដដែល មិនសរសើរការសាបសូន្យទេ ។ ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាការចម្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងប៉ុន្មាន ក្នុងសាសនានេះ ប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈបញ្ញានិងបដិភាណៈ ធម៌ទាំងឡាយនោះ របស់ភិក្ខុនោះ មិនតាំងនៅដដែល មិនចម្រើន ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវហេតុនេះថា ជាសេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ មិនមែន ជាការតាំងនៅដដែល មិនមែន ជាសេចក្តីចម្រើនទេ ។

ឯវំ ខោ ភិក្ខវេ ហានិ ហោតិ កុសលេសុ ធម្មេសុ នោ ឋិតិ នោ វុឌ្ឍិ ។ កថញ្ច ភិក្ខវេ ឋិតិ ហោតិ កុសលេសុ ធម្មេសុ នោ ហានិ នោ វុឌ្ឍិ ។ ឥធ ភិក្ខវេ ភិក្ខុ យត្តកោ ហោតិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ បដិភាណេន តស្ស តេ ធម្មា នេវ ហាយន្តិ នោ វឌ្ឍន្តិ ។ ឋិតិមេតំ ភិក្ខវេ វទាមិ កុសលេសុ ធម្មេសុ នោ ហានឹ នោ វុឌ្ឍឹ ។ ឯវំ ខោ ភិក្ខវេ ឋិតិ ហោតិ កុសលេសុ ធម្មេសុ នោ ហានិ នោ វុឌ្ឍិ ។ កថញ្ច ភិក្ខវេ វុឌ្ឍិ ហោតិ កុសលេសុ ធម្មេសុ នោ ឋិតិ នោ ហានិ ។ ឥធ ភិក្ខវេ ភិក្ខុ យត្តកោ ហោតិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ បដិភាណេន តស្ស តេ ធម្មា នេវ តិដ្ឋន្តិ នោ ហាយន្តិ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនសេចក្តីចម្រើន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាសេចក្តីសាបសូន្យ មិនមែនជាសេចក្តីចម្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងប៉ុន្មាន ក្នុងសាសនានេះ ប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញានិងបដិភាណៈ ពួកធម៌នោះ របស់ភិក្ខុនោះ មិនសាបសូន្យ មិនចម្រើន ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវហេតុនេះ ថាជាការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការសាបសូន្យ មិនមែនជាសេចក្តីចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ការតាំងនៅដដែល ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការសាបសូន្យ មិនមែនជាសេចក្តីចម្រើន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាការសាបសូន្យ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងប៉ុន្មាន ក្នុងសាសនានេះប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញានិងបដិភាណៈ ពួកធម៌នោះ របស់ភិក្ខុនោះ មិនតាំងនៅដដែល មិនសាបសូន្យទេ ។

វុឌ្ឍិមេតំ ភិក្ខវេ វទាមិ កុសលេសុ ធម្មេសុ នោ ឋិតឹ នោ ហានឹ ។ ឯវំ ខោ ភិក្ខវេ វុឌ្ឍិ ហោតិ កុសលេសុ ធម្មេសុ នោ ឋិតិ នោ ហានិ ។ នោ ចេ ភិក្ខវេ ភិក្ខុ បរចិត្តបរិយាយកុសលោ ហោតិ អថ សចិត្តបរិយាយកុសលា ភវិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ កថញ្ច ភិក្ខវេ សចិត្តបរិយាយកុសលោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ នោ ចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តេនេវត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ លាភា វត មេ បរិសុទ្ធំ វត មេតិ

ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវហេតុនេះថា ជាសេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាសេចក្តីសាបសូន្យទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ មិនមែនជាការតាំងនៅដដែល មិនមែនជាសេចក្តីសាបសូន្យយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនឆ្លាស ក្នុងវារៈនៃចិត្តបុគ្គលដទៃទេ គួរគិតថា យើងទាំងឡាយជាអ្នកឆ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុឆ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រី ឬ បុរស កំលោះ ឬ ជំទង់ ប្រកបដោយជាតិ ជាអ្នកស្អិតស្អាង កាលពិចារណាមើលស្រមោលមុខរបស់ខ្លួន ក្នុងកញ្ចក់ ដ៏បរិសុទ្ធផូរផង់ ឬ ក្នុងភាជន៍ទឹកថ្លា បើឃើញនូវធូលី ឬ កន្ទួល ក្នុងកញ្ចក់ ឬ ទឹកនោះ តែងព្យាយាម ដើម្បីលះបង់នូវធូលី ឬ កន្ទួល នោះចេញ បើមិនឃើញធូលី ឬកន្ទួល ក្នុងកញ្ចក់ ឬ ទឹកនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញ មានលាភ ឱហ្ន៎ មុខរបស់អាត្មាអញ បរិសុទ្ធ ឧបមាយ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ បច្ចវេក្ខណា ពហុការា ហោតិ កុសលេសុ ធម្មេសុ អភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ អនភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ ព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ អព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ ថីនមិទ្ធបរិយុដ្ឋិតោ នុ ខោ ពហុលំ វិហរាមិ វិគតថីនមិទ្ធោ នុ ខោ ពហុលំ វិហរាមិ ឧទ្ធតោ នុ ខោ ពហុលំ វិហរាមិ អនុទ្ធតោ នុ ខោ ពហុលំ វិហរាមិ វិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ តិណ្ណវិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ កោធនោ នុ ខោ ពហុលំ វិហរាមិ អក្កោធនោ នុ ខោ ពហុលំ វិហរាមិ សំកិលិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ អសំកិលិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ សារទ្ធកាយោ នុ ខោ ពហុលំ វិហរាមិ អសារទ្ធកាយោ នុ ខោ ពហុលំ វិហរាមិ កុសីតោ នុ ខោ ពហុលំ វិហរាមិ អារទ្ធវីរិយោ នុ ខោ ពហុលំ វិហរាមិ

ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យ ដូចជា ការពិចារណា ក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើន ដល់ភិក្ខុនោះថា អាត្មាអញ ជាអ្នកមានអភិជ្ឈាច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមិនមានអភិជ្ឈាច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តព្យាបាទច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តមិនមានព្យាបាទច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកត្រូវថីនមិទ្ធៈគ្របសង្កត់ច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកប្រាសចាកថីនមិទ្ធៈច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តអណ្តែតអណ្តូងច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តមិនអណ្តែតអណ្តូងច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានវិចិកិច្ឆាច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានសេចក្តីក្រោធច្រើន ឬ ហ្ន៎ អាត្មាអញ មិនមានសេចក្តីក្រោធច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តសៅហ្មងច្រើន ឬ ហ្ន៎ អាត្មាអញជាអ្នកមានចិត្តមិនសៅហ្មងច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានកាយ ក្រវល់ក្រវាយច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានកាយ មិនក្រវល់ក្រវាយច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកខ្ជិលច្រអូសច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានព្យាយាម ប្រារព្ធច្រើន ឬ ហ្ន៎

អសមាហិតោ នុ ខោ ពហុលំ វិហរាមិ សមាហិតោ នុ ខោ ពហុលំ វិហរាមីតិ ។ សចេ ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភិជ្ឈាលុ ពហុលំ វិហរាមិ ព្យាបន្នចិត្តោ ពហុលំ វិហរាមិ ថីនមិទ្ធបរិយុដ្ឋិតោ ពហុលំ វិហរាមិ ឧទ្ធតោ ពហុលំ វិហរាមិ វិចិកិច្ឆោ ពហុលំ វិហរាមិ កោធនោ ពហុលំ វិហរាមិ សំកិលិដ្ឋចិត្តោ ពហុលំ វិហរាមិ សារទ្ធកាយោ ពហុលំ វិហរាមិ កុសីតោ ពហុលំ វិហរាមិ អសមាហិតោ ពហុលំ វិហរាមីតិ ។ តេន ភិក្ខវេ ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច

អាត្មាអញ ជាអ្នកមានចិត្ត មិនខ្ជាប់ខ្ជួនច្រើន ឬ ហ្ន៎ អាត្មាអញ ជាអ្នកមានចិត្តខ្ជាប់ខ្ជួនច្រើន ឬ ហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា អាត្មាអញ ជាអ្នកមានអភិជ្ឈាច្រើន អាត្មាអញ ជាអ្នកមានចិត្តព្យាបាទច្រើន អាត្មាអញ ជាអ្នកត្រូវថីនមិទ្ធៈគ្របសង្កត់ច្រើន អាត្មាអញ ជាអ្នកមានចិត្តអណ្តែតអណ្តូងច្រើន អាត្មាអញ ជាអ្នកមានវិចិកិច្ឆាច្រើន អាត្មាអញ ជាអ្នកមានសេចក្តីក្រោធច្រើន អាត្មាអញ ជាអ្នកមានចិត្តសៅហ្មងច្រើន អាត្មាអញ ជាអ្នកមានកាយក្រវល់ក្រវាយច្រើន អាត្មាអញ ជាអ្នកខ្ជិលច្រអូសច្រើន អាត្មាអញ ជាអ្នកមានចិត្ត មិនខ្ជាប់ខ្ជួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គួរធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់ នូវពួកអកុសលធម៌ ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ត្រូវភ្លើងឆេះ ឬ ក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ ធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង

សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អនភិជ្ឈាលុ ពហុលំ វិហរាមិ អព្យាបន្នចិត្តោ ពហុលំ វិហរាមិ វិគតថី-នមិទ្ធោ ពហុលំ វិហរាមិ អនុទ្ធតោ ពហុលំ វិហរាមិ តិណ្ណវិចិកិច្ឆោ ពហុលំ វិហរាមិ អក្កោ-ធនោ ពហុលំ វិហរាមិ អសំកិលិដ្ឋចិត្តោ ពហុលំ វិហរាមិ អសារទ្ធកាយោ ពហុលំ វិហរាមិ អារទ្ធ-វីរិយោ ពហុលំ វិហរាមិ សមាហិតោ ពហុលំ វិហរាមីតិ ។ តេន ភិក្ខវេ ភិក្ខុនា តេសុយេវ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរី អាសវានំ ខយាយ យោគោ ករណីយោតិ ។

សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬ ក្បាល នោះឯង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរប្រញាប់ធ្វើ សេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមក ទាំងនោះចេញ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា អាត្មាអញ ជាអ្នកមិនមានអភិជ្ឈាច្រើន អាត្មាអញ ជាអ្នកមានចិត្ត មិនព្យាបាទច្រើន អាត្មាអញជាអ្នកប្រាសចាកថីនមិទ្ធៈច្រើន អាត្មាអញ ជាអ្នកមានចិត្តមិនអណ្តែតអណ្តូងច្រើន អាត្មាអញ ជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើន អាត្មាអញ ជាអ្នកមិនមានសេចក្តីក្រោធច្រើន អាត្មាអញ ជាអ្នកមានចិត្ត មិនសៅហ្មងច្រើន អាត្មាអញ ជាអ្នកមានកាយ មិនក្រវល់ក្រវាយច្រើន អាត្មាអញជាអ្នកមានព្យាយាមប្រារព្ធច្រើន អាត្មាអញ ជាអ្នកមានចិត្តខ្ជាប់ខ្ជួនច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីតាំងនៅ ក្នុងកុសលធម៌ទាំងនោះ ហើយគួរធ្វើព្យាយាម ដើម្បីឲ្យអស់ទៅនៃអាសវៈទាំងឡាយ តទៅ ។

ទុតិយបណ្ណាសកេ សចិត្តវគ្គោ

[៥៤] នោ ចេ ភិក្ខវេ ភិក្ខុ បរចិត្តបរិយាយ-កុសលោ ហោតិ អថ សចិត្តបរិយាយកុសលា ភវិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ កថញ្ច ភិក្ខវេ ភិក្ខុ សចិត្តបរិយាយកុសលោ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ នោ ចេ តស្ស បស្សតិ រជំ វា អង្គណំ វា តេនេវត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ លាភា វត មេ បរិសុទ្ធំ វត មេតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ បច្ចវេក្ខណា ពហុការា ហោតិ កុសលេសុ ធម្មេសុ លាភី នុ ខោម្ហិ អជ្ឈត្តំ ចេតោ-សមថស្ស ន នុ ខោម្ហិ លាភី អជ្ឈត្តំ ចេតោសមថស្ស

ទុតិយបណ្ណាសក សចិត្តវគ្គ

[៥៤] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនឆ្លាស ក្នុងវារៈនៃចិត្តអ្នកដទៃទេ គួរគិតថា យើងទាំងឡាយ ជាអ្នកឆ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុឆ្លាសក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្ត្រី ឬ បុរស កំលោះ ឬ ជំទង់ ប្រកបដោយជាតិ ជាអ្នកស្អិតស្អាង ពិចារណាមើលស្រមោលមុខរបស់ខ្លួន ក្នុងកញ្ចក់ដ៏បរិសុទ្ធផូរផង់ ឬ ក្នុងភាជន៍ទឹកថ្លា បើឃើញនូវធូលី ឬ កន្ទួលក្នុងកញ្ចក់ ឬ ទឹកនោះ ក៏ព្យាយាម ដើម្បីលះបង់នូវធូលី ឬ កន្ទួលនោះចេញ បើមិនឃើញធូលី ឬ កន្ទួលនៃមុខនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ មុខរបស់អាត្មាអញ បរិសុទ្ធ ឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា ការពិចារណាក្នុងកុសលធម៌ទាំងឡាយ រមែងមានឧបការៈច្រើន ដល់ភិក្ខុថា អាត្មាអញ ជាអ្នកបាននូវចេតោសមថៈ ខាងក្នុងសន្តាន ឬហ្ន៎

លាភី នុ ខោម្ហិ អធិប្បញ្ញាធម្មវិបស្សនាយ ន នុ ខោម្ហិ លាភី អធិប្បញ្ញាធម្មវិបស្សនាយាតិ ។ សចេ ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ លាភិម្ហិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយាតិ ។ តេន ភិក្ខវេ ភិក្ខុនា អជ្ឈត្តំ ចេតោសមថេ បតិដ្ឋាយ អធិប្បញ្ញាធម្មវិបស្សនាយ យោគោ ករណីយោ ។ សោ អបរេន សមយេន លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ ។ សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ លាភិម្ហិ អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្សាតិ ។ តេន ភិក្ខវេ ភិក្ខុនា អធិប្បញ្ញាធម្មវិបស្សនាយ បតិដ្ឋាយ អជ្ឈត្តំ ចេតោសមថេ យោគោ ករណីយោ ។ សោ អបរេន សមយេន លាភី ចេវ ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ លាភី ច អជ្ឈត្តំ ចេតោសមថស្ស ។

អាត្មាអញ ជាអ្នកមិនបាននូវចេតោសមថៈ ខាងក្នុងសន្តាន ឬ ហ្ន៎ អាត្មាអញ ជាអ្នកបានអធិប្បញ្ញាធម្មវិបស្សនា ឬ ហ្ន៎ អាត្មាអញ ជាអ្នកមិនបានអធិប្បញ្ញាធម្មវិបស្សនា ឬ ហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញ បានចេតោសមថៈខាងក្នុងសន្តាន តែមិនបានអធិប្បញ្ញាធម្មវិបស្សនាទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរឋិតនៅ ក្នុងចេតោសមថៈ ខាងក្នុងសន្តាន ហើយធ្វើព្យាយាម ក្នុងអធិប្បញ្ញាធម្មវិបស្សនា ។ លុះសម័យខាងក្រោយមក ភិក្ខុនោះ ក៏បាននូវចេតោសមថៈខាងក្នុងសន្តានផង បាននូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណា រមែងដឹង យ៉ាងនេះថា អាត្មាអញ បាននូវអធិប្បញ្ញាធម្មវិបស្សនា តែមិនបានចេតោសមថៈខាងក្នុងសន្តានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរឋិតនៅ ក្នុងអធិប្បញ្ញា-ធម្មវិបស្សនាហើយ ធ្វើសេចក្តីព្យាយាម ក្នុងចេតោសមថៈខាងក្នុងសន្តាន ។ លុះសម័យខាងក្រោយមក ភិក្ខុនោះបាន នូវអធិប្បញ្ញា-ធម្មវិបស្សនាផង បាននូវចេតោសមថៈ ខាងក្នុងសន្តានផង ។

សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ន លាភី អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយាតិ ។ តេន ភិក្ខវេ ភិក្ខុនា តេសំយេវ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសំយេវ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណា រមែងដឹងយ៉ាងនេះថាអាត្មាអញមិនបានចេតោសមថៈខាងក្នុងសន្តាន ទាំងមិនបានអធិប្បញ្ញាធម្មវិបស្សនា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវពួកធម៌ ជាកុសលទាំងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬ ក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់នូវសំពត់ ឬ ក្បាលនោះឯងយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវពួកកុសលធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។

សោ អបរេន សមយេន លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញា-ធម្មវិបស្សនាយ ។ សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ លាភិម្ហិ អជ្ឈត្តំ ចេតោសមថស្ស លាភី អធិប្បញ្ញាធម្មវិបស្សនាយាតិ ។ តេន ភិក្ខវេ ភិក្ខុនា តេសុយេវ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរឹ អាសវានំ ខយាយ យោគោ ករណីយោ ។ ចីវរម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ បិណ្ឌបាតម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ សេនាសនម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ គាមនិគមម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ ជនបទប្បទេសម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិ-តព្វំបិ អសេវិតព្វំបិ បុគ្គលម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ ។

លុះសម័យខាងក្រោយមក ភិក្ខុនោះ បានទូវចេតោសមថៈ ខាងក្នុងសន្តានផង បានទូវអធិប្បញ្ញាធម្មវិបស្សនាផង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុពិចារណា រមែងដឹងយ៉ាងនេះថា អាត្មាអញបានចេតោសមថៈខាងក្នុងសន្តាន បានអធិប្បញ្ញាធម្មវិបស្សនា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គួរតាំងនៅ ក្នុងកុសលធម៌ទាំងនោះ ហើយធ្វើព្យាយាម ដើម្បីឲ្យអស់ទៅ នៃអាសវៈទាំងឡាយ តទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចីវរ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបិណ្ឌបាត ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសេនាសនៈ ដោយចំណែកពីរប្រការ គឺ គួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវស្រុក ឬនិគម ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវជនបទ ឬ ប្រទេសដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គល ដោយចំណែកពីរ គឺគួរសេព ១ មិនគួរសេព ១ ។

## ២១៧



ចីវរម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា ចីវរំ ឥមំ ខោ មេ ចីវរំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ ចីវរំ ន សេវិតព្វំ ។ តត្ថ យំ ជញ្ញា ចីវរំ ឥមំ ខោ មេ ចីវរំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបំ ចីវរំ សេវិតព្វំ ។ ចីវរម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ បិណ្ឌបាតម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចីវរ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនេះ តថាគតពោលហើយ ដោយប្រការដូច្នេះឯង ពាក្យដែលតថាគត ពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាចីវរទាំងពីរប្រការនោះ ភិក្ខុគប្បីដឹង នូវចីវរណាថា កាលបើអាត្មាអញ សេពចីវរនេះឯង អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ចីវរបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាចីវរទាំងពីរប្រការនោះ ភិក្ខុគប្បីដឹងចីវរណាមួយ កាលបើអាត្មាអញ សេពចីវរណា អកុសលធម៌ទាំងឡាយ សាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ចីវរបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចីវរ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនេះតថាគតពោលហើយ ព្រោះសំដៅហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបិណ្ឌបាត ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយ ដោយប្រការដូច្នេះនេះ ពាក្យដែលតថាគត ពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។

តត្ថ យំ ជញ្ញា បិណ្ឌបាតំ ឥទំ[១] ខោ មេ បិណ្ឌបាតំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ បិណ្ឌបាតោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា បិណ្ឌបាតំ ឥទំ[២] ខោ មេ បិណ្ឌបាតំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ បិណ្ឌបាតោ សេវិតព្វោ ។ បិណ្ឌបាតម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ សេនាសនម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា សេនាសនំ ឥទំ ខោ មេ សេនាសនំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ

១-២ ឱ. ម. ឥមំ ។

បណ្ដាបិណ្ឌបាតទាំងនោះ ភិក្ខុគប្បីដឹងនូវបិណ្ឌបាតណាថា កាលបើអាត្មាអញ សេពបិណ្ឌបាតនេះឯង អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ បិណ្ឌបាតបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដាបិណ្ឌបាតទាំងនោះ ភិក្ខុគប្បីដឹងនូវបិណ្ឌបាតណាថា កាលបើអាត្មាអញ សេពបិណ្ឌបាតនេះឯង អកុសលធម៌ទាំង-ឡាយសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង បិណ្ឌបាតបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបិណ្ឌបាត ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនេះ តថា-គតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវសេនាសនៈ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្ដេច ។ បណ្ដាសេនាសនៈទាំងនោះ ភិក្ខុគប្បីដឹង នូវសេនាសនៈណាថា កាលបើអាត្មាអញ សេពសេនាសនៈនេះឯង អកុសលធម៌ទាំងឡាយ ចម្រើនឡើង

២១៩

ទុតិយបណ្ណាសកេ សចិត្តវគ្គោ

កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ សេនាសនំ ន សេវិតព្វំ ។ តត្ថ យំ ជញ្ញា សេនាសនំ ឥទំ ខោ មេ សេនាសនំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបំ សេនាសនំ សេវិតព្វំ ។ សេនាសនម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ គាមនិគមម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា គាមនិគមំ ឥទំ ខោ មេ គាមនិគមំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ គាមនិគមោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា គាមនិគមំ ឥទំ ខោ មេ គាមនិគមំ សេវតោ

កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ សេនាសនៈបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាសេនាសនៈទាំងនោះ ភិក្ខុដឹងនូវសេនាសនៈណាថា កាលបើអាត្មាអញ សេពសេនាសនៈនេះឯង អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង សេនាសនៈបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសេនាសនៈ ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវស្រុក ឬ និគម ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយ អាស្រ័យហេតុដូចម្តេច ។ បណ្តាស្រុក ឬ និគមនោះ ភិក្ខុគប្បីដឹងនូវស្រុក ឬ និគមណាថា កាលបើអាត្មាអញ សេពស្រុក ឬ និគមនោះឯង អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ស្រុក ឬ និគមបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្តាស្រុក ឬ និគមទាំងនោះ ភិក្ខុគប្បីដឹងស្រុក ឬ និគមណាថា កាលបើអាត្មាអញ សេពស្រុក ឬ និគមនេះឯង

អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ គាមនិគមោ សេវិតព្វោ ។ គាមនិគមម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ជនបទប្បទេសម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា ជនបទប្បទេសំ ឥមំ ខោ មេ ជនបទប្បទេសំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ ជនបទប្បទេសោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា ជនបទប្បទេសំ ឥមំ ខោ មេ ជនបទប្បទេសំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ ជនបទប្បទេសោ សេវិតព្វោ ។

អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ តែង ចម្រើនឡើង ស្រុក ឬ និគមបែបនេះភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវស្រុក ឬ និគម ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ តថាគតពោលនូវជនបទ ឬ ប្រទេស ដោយចំណែក ពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យ ហេតុដូចម្ដេច ។ បណ្ដាជនបទ ឬ ប្រទេសទាំងនោះ ភិក្ខុគប្បីដឹងជនបទ ឬ ប្រទេសណាថា កាលបើអាត្មាអញសេពជនបទ ឬ ប្រទេសនេះឯង អកុស-លធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ ជនបទ ឬប្រទេសបែបនេះ ភិក្ខុមិនគួរសេពឡើយ ។ បណ្ដាជនបទឬប្រទេសទាំង នោះ ភិក្ខុគប្បីដឹងនូវជនបទ ឬ ប្រទេសណាថា កាលបើអាត្មាអញ សេព ជនបទ ឬ ប្រទេសនេះឯង អកុសលធម៌ទាំងឡាយសាបសូន្យទៅ កុសល-ធម៌ទាំងឡាយ តែងចម្រើនឡើង ជនបទឬប្រទេសបែបនេះ ភិក្ខុគួរសេព ។

ជនបទប្បទេសម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ បុគ្គលម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា បុគ្គលំ ឥមំ ខោ មេ បុគ្គលំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ បុគ្គលោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា បុគ្គលំ ឥមំ ខោ មេ បុគ្គលំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ បុគ្គលោ សេវិតព្វោ ។ បុគ្គលម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

[៥៥] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវជនបទឬប្រទេស ដោយចំណែកពីរប្រការ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណាដែលតថាគតពោលហើយដោយប្រការដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គល ដោយចំណែកពីរ គឺគួរសេព ១ មិនគួរសេព ១ ពាក្យនុ៎ះ តថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យហេតុដូចម្តេច ។ បណ្តាបុគ្គលទាំងនោះភិក្ខុគប្បីដឹងនូវបុគ្គលណាថា កាលបើអាត្មាអញសេពបុគ្គលនេះឯង អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ បុគ្គលបែបនេះ ភិក្ខុមិនគួរសេព ។ បណ្តាបុគ្គលទាំងនោះ ភិក្ខុគប្បីដឹងនូវបុគ្គលណាថា កាលបើអាត្មាអញ សេពបុគ្គលនេះឯង អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង បុគ្គលបែបនេះ ភិក្ខុគួរសេព ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គល ដោយចំណែកពីរ គឺគួរសេព ១ មិនគួរសេព ១ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។

[៥៥] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយ ថាម្នាលអាវុសោ ភិក្ខុទាំងឡាយ ។

អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច បរិហាន-ធម្មោ បុគ្គលោ បរិហានធម្មោ បុគ្គលោតិ អាវុសោ វុច្ចតិ អបរិហានធម្មោ បុគ្គលោ អបរិហានធម្មោ បុគ្គលោតិ អាវុសោ វុច្ចតិ ។ កិត្តាវតា នុ ខោ អាវុសោ បរិហានធម្មោ បុគ្គលោ វុត្តោ ភគវតា កិត្តាវតា ច បន អបរិហានធម្មោ បុគ្គលោ វុត្តោ ភគវតាតិ ។ ទូរតោបិ ខោ មយំ អាវុសោ អាគច្ឆេយ្យាម អាយ-ស្មតោ សារីបុត្តស្ស សន្តិកេ ឯតស្ស ភាសិតស្ស អត្ថមញ្ញាតុំ សាធុ វតាយស្មន្តំយេវ សារីបុត្តំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ អាយស្មតោ សារីបុត្តស្ស សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេន-ហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

ពួកភិក្ខុទាំងនោះ ទទួលថេរវាចា របស់ព្រះសារីបុត្ត ដ៏មានអាយុថា អាវុសោ ។ ព្រះសារីបុត្ត ដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ អ្នកផងតែងនិយាយថា បុគ្គលមានធម៌សាបសូន្យ បុគ្គលមានធម៌សាបសូន្យដូច្នេះ ម្នាលអាវុសោទាំងឡាយ អ្នកផង តែងនិយាយថា បុគ្គលមានធម៌មិនសាបសូន្យ បុគ្គលមានធម៌មិនសាបសូន្យដូច្នេះ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលមានធម៌សាបសូន្យ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្តេច ចំណែកខាងបុគ្គលមានធម៌មិនសាបសូន្យ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្តេច ។ ពួកភិក្ខុតបថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយមកអំពីចម្ងាយ ដើម្បីដឹងនូវសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះសារីបុត្ត ដ៏មានអាយុ សូមព្រះសារីបុត្ត ដ៏មានអាយុ សម្តែងនូវសេចក្តីនៃភាសិតនោះឲ្យទាន ពួកភិក្ខុបានស្តាប់ ព្រះសារីបុត្ត ដ៏មានអាយុហើយ នឹងចងចាំបាន ។ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ ខ្ញុំនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលថេរវាចា របស់ព្រះសារីបុត្ត ដ៏មានអាយុថា ករុណាអាវុសោ យ៉ាងនេះ ។

២២៣



អាយស្មា សារីបុត្តោ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ បរិហានធម្មោ បុគ្គលោ វុត្តោ ភគវតា ។ ឥធាវុសោ ភិក្ខុ អសុតញ្ចេវ ធម្មំ ន សុណាតិ សុតា ចស្ស ធម្មា សម្មោហំ[១] គច្ឆន្តិ យេ ចស្ស ធម្មា បុព្វេ ចេតសោ សម្ផុដ្ឋបុព្វា[២] តេ ចស្ស[៣] ន សមុទាចរន្តិ អវិញ្ញាតញ្ច ន វិជានាតិ ។ ឯត្តាវតា ខោ អាវុសោ បរិហានធម្មោ បុគ្គលោ វុត្តោ ភគវតា ។ កិត្តាវតា ច បនាវុសោ អបរិ-ហានធម្មោ បុគ្គលោ វុត្តោ ភគវតា ។ ឥធាវុសោ ភិក្ខុ អសុតញ្ចេវ ធម្មំ សុណាតិ សុតា ចស្ស ធម្មា ន សម្មោហំ គច្ឆន្តិ យេ ចស្ស ធម្មា បុព្វេ ចេតសោ សម្ផុដ្ឋបុព្វា តេ ចស្ស សមុទាចរន្តិ

១ ឱ. ម. សម្មោសំ ។ ២ ម. អសម្មុដ្ឋបុព្វា ។ ៣ ឱ. តេ ច ។

ព្រះសារីបុត្ត ដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលដែលមានធម៌សាបសូន្យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានស្តាប់ធម៌ ដែលខ្លួនមិនធ្លាប់បានស្តាប់ផង ធម៌ទាំងឡាយ ដែលភិក្ខុនោះ ធ្លាប់បានស្តាប់ហើយ ក៏ដល់នូវការភ្លេចភ្លាំងទៅផង មួយទៀត ធម៌ទាំងឡាយណា ដែលភិក្ខុនោះធ្លាប់ពាល់ត្រូវដោយចិត្ត ក្នុងកាលមុន ធម៌ទាំងនោះ ក៏មិនផុសឡើងដល់ភិក្ខុនោះផង ភិក្ខុនោះមិនដឹងនូវធម៌ដែលខ្លួនមិនទាន់ដឹងផង ។ ម្នាលអាវុសោទាំងឡាយ បុគ្គលមានធម៌សាបសូន្យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយបរិយាយប៉ុណ្ណេះឯង ។ ម្នាលអាវុសោទាំង-ឡាយ បុគ្គលមានធម៌មិនសាបសូន្យ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបរិយាយដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្តាប់នូវធម៌ដែលខ្លួនមិនធ្លាប់បានស្តាប់ផង ពួកធម៌ដែលភិក្ខុនោះ ធ្លាប់ស្តាប់ហើយ ក៏មិនដល់នូវការភ្លេចភ្លាំងទៅផង មួយទៀត ពួកធម៌ណា ដែលភិក្ខុនោះ ធ្លាប់ពាល់ត្រូវ ដោយចិត្តក្នុងកាលមុន ពួកធម៌នោះ ក៏ផុសឡើង ដល់ភិក្ខុនោះឯង

អវិញ្ញាតញ្ច វិជានាតិ ។ ឯត្តាវតា ខោ អាវុសោ អបរិហានធម្មោ បុគ្គលោ វុត្តោ ភគវតា ។ នោ ចេ អាវុសោ ភិក្ខុ បរចិត្តបរិយាយកុសលោ ហោតិ អថ សចិត្តបរិយាយកុសលា ភវិស្សាមាតិ ។ ឯវញ្ហិ វោ អាវុសោ សិក្ខិតព្វំ ។ កថញ្ចាវុសោ ភិក្ខុ សចិត្តបរិយាយកុសលោ ហោតិ ។ សេយ្យថាបិ អាវុសោ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តស្សេវ រជស្ស វា អង្គណស្ស វា បហានាយ វាយមតិ នោ ចេ តត្ថ បស្សតិ រជំ វា អង្គណំ វា តេនេវត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ លាភា វត មេ បរិសុទ្ធំ វត មេតិ ឯវមេវ ខោ អាវុសោ ភិក្ខុនោ បច្ចវេក្ខណា ពហុការា ហោតិ កុសលេសុ ធម្មេសុ

ភិក្ខុនោះ ក៏ដឹងច្បាស់នូវធម៌ ដែលខ្លួនមិនធ្លាប់ដឹងផង ។ ម្នាលអាវុសោទាំងឡាយ បុគ្គលមានធម៌មិនសាបសូន្យ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបរិយាយប៉ុណ្ណេះឯង ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុមិនឈ្លាស ក្នុងវារៈនៃចិត្តអ្នកដទៃ គួរគិតថា យើងទាំងឡាយជាអ្នកឈ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំង-ឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកឈ្លាស ក្នុងវារៈនៃចិត្តរបស់ខ្លួន តើដោយប្រការដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្ត្រី ឬ បុរស កំលោះ ឬ ជំទង់ ប្រកបដោយជាតិជាអ្នកស្អិតស្អាង កាលពិចារណាមើល ស្រមោលមុខរបស់ខ្លួន ក្នុងកញ្ចក់ដ៏បរិសុទ្ធផូរផង់ ឬ ក្នុងភាជន៍ទឹកថ្លា បើឃើញធូលី ឬ កន្ទួលក្នុងកញ្ចក់ ឬ ទឹកនោះតែងព្យាយាម ដើម្បីលះបង់ធូលី ឬ កន្ទួលនោះចេញ បើមិនឃើញធូលី ឬ កន្ទួលក្នុងកញ្ចក់ ឬ ទឹកនោះទេ ក៏មានចិត្តត្រេកអរ មានតម្រិះគ្រប់គ្រាន់ដោយហេតុនោះថា ឱហ្ន៎ អាត្មាអញមានលាភ ឱហ្ន៎ (មុខ) របស់អាត្មាអញបរិសុទ្ធ មានឧបមាយ៉ាងណា ម្នាលអាវុសោទាំងឡាយ ឧបមេយ្យដូចជាការពិចារណា ក្នុងកុសលធម៌ទាំងឡាយ ជាធម៌មានឧបការៈច្រើនដល់ភិក្ខុជា

អនភិជ្ឈាលុ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ[១] អព្យាបន្នចិត្តោ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ វិគតថីនមិទ្ធោ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ អនុទ្ធតោ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ តិណ្ណវិចិកិច្ឆោ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ អក្កោធនោ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ អសំកិលិដ្ឋចិត្តោ នុ ខោ ពហុលំ វិហរាមិ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ លាភី នុ ខោម្ហិ អជ្ឈត្តំ ធម្មប្បាមុជ្ជស្ស សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ

---

១ ឱ. ម. សព្វវារេសុ តិសទ្ទោ នត្ថិ ។

ទុតិយបណ្ណាសក សចិត្តវគ្គ

អាត្មាអញ ជាអ្នកមិនមានអភិជ្ឈាច្រើន ឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថាមិនមានទេ អាត្មាអញ ជាអ្នកមិនមានចិត្តព្យាបាទ ច្រើនឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថា មិនមានទេ អាត្មាអញ ជាអ្នកប្រាសចាកថីនមិទ្ធៈច្រើន ឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថាមិនមានទេ អាត្មាអញ ជាអ្នកមានចិត្តមិនអណ្តែតអណ្តូងច្រើន ឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញ ឬហ្ន៎ ឬថាមិនមានទេ អាត្មាអញ ជាអ្នកឆ្លងចាកវិចិកិច្ឆាច្រើនឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថាមិនមានទេ អាត្មាអញ ជាអ្នកមិនមានសេចក្តីក្រោធច្រើន ឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថាមិនមានទេ អាត្មាអញ ជាអ្នកមានចិត្ត មិនសៅហ្មងច្រើន ឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថា មិនមានទេ អាត្មាអញ ជាអ្នកបាននូវធម្មប្បាមុជ្ជៈខាងក្នុងសន្តាន ឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថា មិនមានទេ

លាភី នុ ខោម្ហិ អជ្ឈត្តំ ចេតោសមថស្ស សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ លាភី នុ ខោម្ហិ អធិប្បញ្ញាធម្មវិបស្សនាយ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ សព្វេបិមេ កុសលេ ធម្មេ អត្តនិ ន សមនុបស្សតិ តេនាវុសោ ភិក្ខុនា សព្វេសំយេវ ឥមេសំ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យថាបិ អាវុសោ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ

អាត្មាអញ ជាអ្នកបានចេតោសមថៈ ខាងក្នុងសន្តាន ឬហ្ន៎ ធម៌នុ៎ះមានដល់អាត្មាអញ ឬហ្ន៎ ឬថា មិនមានទេ អាត្មាអញ ជាអ្នកបាននូវអធិប្បញ្ញាធម្មវិបស្សនា ឬហ្ន៎ ធម៌នុ៎ះ មានដល់អាត្មាអញ ឬហ្ន៎ ឬថា មិនមានទេ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណា មិនឃើញពួកកុសលធម៌ទាំងអស់នេះ ក្នុងខ្លួនទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវពួកកុសលធម៌ទាំងអស់នេះ ។ ម្នាលអាវុសោទាំងឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគួរប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់នូវសំពត់ ឬ ក្បាលនោះឯង យ៉ាងណាមិញ

២២៧



ឯវមេវ ខោ អាវុសោ តេន ភិក្ខុនា សព្វេសំយេវ ឥមេសំ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហិ ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ ឯកច្ចេ កុសលេ ធម្មេ អត្តនិ សមនុបស្សតិ ឯកច្ចេ កុសលេ ធម្មេ អត្តនិ ន សមនុបស្សតិ តេនាវុសោ ភិក្ខុនា យេ កុសលេ ធម្មេ អត្តនិ សមនុបស្សតិ តេសុ កុសលេសុ ធម្មេសុ បតិដ្ឋាយ យេ កុសលេ ធម្មេ អត្តនិ ន សមនុបស្សតិ តេសំ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហិ ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ គប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបានចំពោះនូវពួកកុសលធម៌ទាំងនេះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុពិចារណាឃើញនូវកុសលធម៌ទាំងឡាយពួកខ្លះ ក្នុងខ្លួន មិនឃើញនូវកុសលធម៌ទាំងឡាយពួកខ្លះ ក្នុងខ្លួនទេ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុនោះពិចារណាឃើញនូវកុសលធម៌ទាំងឡាយណា ក្នុងខ្លួន ឋិតនៅក្នុងកុសលធម៌ទាំងឡាយនោះ (បើ) មិនទាន់ឃើញនូវកុសលធម៌ទាំងឡាយណាក្នុងខ្លួនទេ ត្រូវធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្ប-ជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវកុសលធម៌ទាំងឡាយនោះ ។

សេយ្យថាបិ អាវុសោ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ អាវុសោ តេន ភិក្ខុនា យេ កុសលេ ធម្មេ អត្តនិ សមនុ-បស្សតិ តេសុ កុសលេសុ ធម្មេសុ បតិដ្ឋាយ យេ កុសលេ ធម្មេ អត្តនិ ន សមនុបស្សតិ តេសំ កុសលានំ ធម្មានំ បដិលាភាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សចេ បនាវុសោ ភិក្ខុ បច្ចវេក្ខមានោ សព្វេបិមេ កុសលេ ធម្មេ អត្តនិ សមនុបស្សតិ តេនាវុសោ ភិក្ខុនា សព្វេស្វេវ ឥមេសុ កុសលេសុ ធម្មេសុ បតិដ្ឋាយ ឧត្តរឹ អាសវានំ ខយាយ យោគោ ករណីយោតិ ។

ម្នាលអាវុសោទាំងឡាយ ដូចជាសំពត់ដែលត្រូវភ្លើងឆេះ ឬក្បាលដែលត្រូវភ្លើងឆេះ បុគ្គលគប្បីប្រញាប់ធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីលត់សំពត់ ឬក្បាលនោះឯង យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះ ពិចារណាឃើញនូវកុសលធម៌ទាំងឡាយណា ក្នុងខ្លួន ឋិតនៅ ក្នុងកុសលធម៌ទាំងឡាយនោះ (បើ) មិនទាន់ឃើញនូវកុសលធម៌ទាំងឡាយណា ក្នុងខ្លួនទេ ត្រូវធ្វើនូវសេចក្តីប៉ុនប៉ងផង ព្យាយាមផង សេចក្តីខ្មីឃ្មាតផង ប្រឹងប្រែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យលើសលុប ដើម្បីបាននូវកុសលធម៌ទាំងឡាយនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុពិចារណាឃើញកុសលធម៌ទាំងអស់នេះ ក្នុងខ្លួន ម្នាលអាវុសោទាំងឡាយ ភិក្ខុនោះគួរឋិតនៅ ក្នុងកុសលធម៌ទាំងអស់នេះ ហើយធ្វើនូវសេចក្តីព្យាយាម ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ តទៅ ។

[៤៦] ទសយិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា ទស ។ អសុភសញ្ញា មរណសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ ឥមា ខោ ភិក្ខវេ ទស សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

[៤៧] ទសយិមា ភិក្ខវេ សញ្ញា ភាវិតា ពហុលីកតា

[៥៦] ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ១០ ប្រការដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។ សញ្ញា ១០ តើដូចម្ដេចខ្លះ ។ គឺអសុភសញ្ញា (សម្គាល់ថាមិនស្អាត) ១ មរណសញ្ញា (សម្គាល់ក្នុងសេចក្ដីស្លាប់) ១ អាហារេបដិកូលសញ្ញា (សម្គាល់ថាគួរខ្ពើមរអើមក្នុងអាហារ) ១ សព្វលោកេអនភិរតសញ្ញា (សេចក្ដីសម្គាល់ថាមិនគួរត្រេកអរក្នុងលោកទាំងអស់) ១ អនិច្ចសញ្ញា (សម្គាល់ថាមិនទៀង) ១ អនិច្ចេទុក្ខសញ្ញា (សម្គាល់ថាជាទុក្ខក្នុងរបស់មិនទៀង) ១ ទុក្ខេអនត្តសញ្ញា (សម្គាល់ថា មិនមែនខ្លួនក្នុងរបស់ដែលជាទុក្ខ) ១ បហានសញ្ញា (សម្គាល់ថាគួរលះបង់) ១ វិរាគសញ្ញា (សម្គាល់ការប្រាសចាកតម្រេក) ១ និរោធសញ្ញា (សម្គាល់ការរលត់) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំង ១០ នេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈ ជាបរិយោសាន ។

[៥៧] ម្នាលភិក្ខុទាំងឡាយ សញ្ញានេះ មាន ១០ ប្រការ ដែលបុគ្គល បានចម្រើនហើយ បានធ្វើឲ្យច្រើន ហើយ

មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កតមា ទស ។ អនិច្ចសញ្ញា អនត្តសញ្ញា មរណសញ្ញា អាហារេ បដិក្កូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អដ្ឋិកសញ្ញា បុឡុវកសញ្ញា វិនីលកសញ្ញា វិច្ឆិទ្ទកសញ្ញា ឧទ្ធុមាតកសញ្ញា ។ ឥមា ខោ ភិក្ខវេ ទស សញ្ញា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

[៥៨] សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កឹមូលកា អាវុសោ សព្វេ ធម្មា កឹសម្ភវា សព្វេ ធម្មា កឹសមុទយា សព្វេ ធម្មា កឹសមោសរណា សព្វេ ធម្មា កឹបមុខា សព្វេ ធម្មា កឹអធិបតេយ្យា សព្វេ ធម្មា កឹឧត្តរា

មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។ សញ្ញា ១០ តើដូចម្តេចខ្លះ ។ គឺ អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ អដ្ឋិកសញ្ញា (សម្គាល់អសុភដែលមានតែរាងឆ្អឹង) ១ បុឡុវកសញ្ញា (សម្គាល់អសុភដែលមានដង្កូវចុះ) ១ វិនីលកសញ្ញា (សម្គាល់អសុភដែលមានពណ៌ខៀវ) ១ វិច្ឆិទ្ទកសញ្ញា (សម្គាល់អសុភដែលដាច់ជាកំណាត់) ១ ឧទ្ធុមាតកសញ្ញា (សម្គាល់អសុភដែលហើមប៉ោង) ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ១០ យ៉ាងនេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅកាន់អមតៈ មានអមតៈជាបរិយោសាន ។

[៥៨] ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះថា ម្នាលអាវុសោ ពួកធម៌ទាំងអស់ មានអ្វីជាឫសគល់ ពួកធម៌ទាំងអស់ មានអ្វីជាដែនកើត ពួកធម៌ទាំងអស់ មានអ្វីជាទីប្រជុំកើត ពួកធម៌ទាំងអស់ មានអ្វីជាទីប្រជុំចុះ ពួកធម៌ទាំងអស់ មានអ្វីជាប្រធាន ពួកធម៌ទាំងអស់ មានអ្វីជាធំ ពួកធម៌ទាំងអស់ មានអ្វីជាគ្រឿងវិសេស

២៣១



សព្វេ ធម្មា កឹសារា សព្វេ ធម្មា កឹឱគធា សព្វេ ធម្មា កឹបរិយោសានា សព្វេ ធម្មាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ កិន្តិ ព្យាករេយ្យាថាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា បុច្ឆេយ្យុំ កឹមូលកា អាវុសោ សព្វេ ធម្មា កឹសម្ភវា សព្វេ ធម្មា កឹសមុទយា សព្វេ ធម្មា កឹសមោសរណា

ពួកធម៌ទាំងអស់មានអ្វីជាខ្លឹម ពួកធម៌ទាំងអស់មានអ្វីជាគ្រឿងឈមទៅរក ពួកធម៌ទាំងអស់ មានអ្វីជាបរិយោសាន ម្នាលភិក្ខុទាំងឡាយ កាលបើត្រូវពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ សួរយ៉ាងនេះ តើអ្នកទាំងឡាយគប្បីដោះស្រាយដូចម្តេច ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះដ៏មានព្រះភាគជាឫសគល់ មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគ ជាទីពឹងនៃយើងទាំងឡាយស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្តែងនូវសេចក្តីនៃភាសិតនេះ ភិក្ខុទាំងឡាយ បានស្តាប់ព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគហើយ នឹងចងចាំបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកអន្យតិរ្ថិយបរិព្វាជក សួរយ៉ាងនេះថា ម្នាលអាវុសោ ពួកធម៌ទាំងអស់ មានអ្វីជាឫសគល់ ពួកធម៌ទាំងអស់ មានអ្វីជាដែនកើត ពួកធម៌ទាំងអស់ មានអ្វីជាទីប្រជុំកើត ពួកធម៌ទាំងអស់ មានអ្វីជាទីប្រជុំចុះ

សព្វេ ធម្មា កឹបមុខា សព្វេ ធម្មា កឹអធិបតេយ្យា សព្វេ ធម្មា កឹឧត្តរា សព្វេ ធម្មា កឹសារា សព្វេ ធម្មា កឹឱគធា សព្វេ ធម្មា កឹបរិយោ-សានា សព្វេ ធម្មាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ឆន្ទមូលកា អាវុសោ សព្វេ ធម្មា មនសិការសម្ភវា សព្វេ ធម្មា ផស្សសមុទយា សព្វេ ធម្មា វេទនាសមោសរណា សព្វេ ធម្មា សមាធិប្បមុខា សព្វេ ធម្មា សតាធិបតេយ្យា សព្វេ ធម្មា បញ្ញុត្តរា សព្វេ ធម្មា វិមុត្តិសារា សព្វេ ធម្មា អមតោគធា សព្វេ ធម្មា និព្វានបរិយោសានា សព្វេ ធម្មាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថាតិ ។

[៥៩] តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យថា បព្វជ្ជាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ

ពួកធម៌ទាំងអស់ មានអ្វីជាប្រធាន ពួកធម៌ទាំងអស់ មានអ្វីជាធំ ពួកធម៌ទាំងអស់ មានអ្វីជាគ្រឿងវិសេស ពួកធម៌ទាំងអស់ មានអ្វីជាខ្លឹម ពួកធម៌ទាំងអស់ មានអ្វីជាគ្រឿងឈមទៅរក ពួកធម៌ទាំងអស់ មានអ្វីជាបរិយោសាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលបើត្រូវពួកអន្យតិរ្ថិយ បរិព្វាជកទាំងនោះសួរយ៉ាងនេះ គប្បីដោះស្រាយ យ៉ាងនេះថា ម្នាលអាវុសោ ពួកធម៌ទាំងអស់ មានឆន្ទៈជាឫសគល់ ពួកធម៌ទាំងអស់ មានមនសិការៈជាដែនកើត ពួកធម៌ទាំងអស់ មានផស្សៈជាទីប្រជុំកើត ពួកធម៌ទាំងអស់ មានវេទនាជាទីប្រជុំចុះ ពួកធម៌ទាំងអស់ មានសមាធិជាប្រធាន ពួកធម៌ទាំងអស់ មានសតិជាធំ ពួកធម៌ទាំងអស់ មានបញ្ញាជាគ្រឿងវិសេស ពួកធម៌ទាំងអស់ មានវិមុត្តិជាខ្លឹម ពួកធម៌ទាំងអស់ មានអមតៈជាគ្រឿងឈមទៅរក ពួកធម៌ទាំងអស់ មាននិព្វានជាបរិយោសាន ម្នាលភិក្ខុទាំងឡាយ កាលបើត្រូវពួកអន្យតិរ្ថិយ បរិព្វាជកទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[៥៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ ភិក្ខុគប្បីសិក្សាយ៉ាងនេះថា ចិត្តយើងនឹងសន្សំដោយសមគួរដល់បព្វជ្ជាផង

២៣៣



ន ច ឧប្បន្នា បាបកា អកុសលា ធម្មា ចិត្តំ បរិយាទាយ ឋស្សន្តិ អនិច្ចសញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ អនត្តសញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ អសុភសញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ អាទីនវសញ្ញា-បរិចិតញ្ច នោ ចិត្តំ ភវិស្សតិ លោកស្ស សមញ្ច វិសមញ្ច ញត្វា តំ សញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ លោកស្ស សម្ភវញ្ច[១] វិភវញ្ច ញត្វា តំ សញ្ញាបរិ-ចិតញ្ច នោ ចិត្តំ ភវិស្សតិ លោកស្ស សមុ-ទយញ្ច អដ្ឋង្គមញ្ច ញត្វា តំ សញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ បហានសញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ វិរាគសញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតិ និរោធ-សញ្ញាបរិចិតញ្ច នោ ចិត្តំ ភវិស្សតីតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ យថាបព្វជ្ជាបរិចិតញ្ច ចិត្តំ ហោតិ ន ច ឧប្បន្នា បាបកា អកុសលា ធម្មា ចិត្តំ បរិយាទាយ តិដ្ឋន្តិ

១ ម. ភវញ្ច ។

អកុសលធម៌ ដ៏លាមក ដែលកើតឡើងហើយ ក៏នឹងមិនគ្រប សង្កត់ចិត្តផង ចិត្តយើងសន្សំ ក្នុងអនិច្ចសញ្ញាផង ចិត្តយើង នឹងសន្សំ ក្នុងអនត្តសញ្ញាផង ចិត្តយើងនឹងសន្សំ ក្នុងអសុភសញ្ញា ផង ចិត្តយើងនឹងសន្សំ ក្នុងអាទីនវសញ្ញាផង ចិត្តយើងនឹងសន្សំ ក្នុងសញ្ញានោះ ព្រោះដឹងនូវសុចរិតនិងទុច្ចរិត នៃសត្វលោកផង ចិត្តយើងនឹងសន្សំ ក្នុងសញ្ញានោះ ព្រោះដឹងនូវសេចក្តីចម្រើននិងសេចក្តី វិនាសនៃសត្វលោកផង ចិត្តយើងនឹងសន្សំ ក្នុងសញ្ញានោះ ព្រោះដឹង ការប្រជុំកើតនិងសាបសូន្យទៅ នៃសត្វលោកផង ចិត្តយើងនឹងសន្សំ ក្នុងបហានសញ្ញាផង ចិត្តយើងនឹងសន្សំ ក្នុងវិរាគសញ្ញាផង ចិត្តយើង នឹងសន្សំ ក្នុងនិរោធសញ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាល ណាបើ ចិត្តដែលភិក្ខុសន្សំហើយ ដោយសមគួរដល់បញ្ញាផង ពួក អកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ក៏មិនគ្រួបសង្កត់ចិត្តផង

អនិច្ចសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ អនត្តសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ អសុភសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ អាទីនវសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ លោកស្ស សមញ្ច វិសមញ្ច ញត្វា តំ សញ្ញាបរិចិតញ្ច ចិត្តំ ហោតិ លោកស្ស សម្ភវញ្ច វិភវញ្ច ញត្វា តំ សញ្ញាបរិចិតញ្ច ចិត្តំ ហោតិ លោកស្ស សមុទយញ្ច អដ្ឋង្គមញ្ច ញត្វា តំ សញ្ញាបរិចិតញ្ច ចិត្តំ ហោតិ បហានសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ វិរាគសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ និរោធសញ្ញាបរិចិតញ្ច ចិត្តំ ហោតិ ។ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

[៦០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា គិរិមានន្ទោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។

ចិត្តដែលភិក្ខុសន្សំហើយ ក្នុងអនិច្ចសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងអនត្តសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងអសុភសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងអាទីនវសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងសញ្ញានោះ ព្រោះដឹងនូវសុចរិតនិងទុច្ចរិតរបស់សត្វលោកផង ចិត្តដែលភិក្ខុសន្សំហើយក្នុងសញ្ញានោះ ព្រោះដឹងនូវសេចក្តីចម្រើននិងវិនាសរបស់សត្វលោកផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងសញ្ញានោះ ព្រោះដឹងនូវការប្រជុំកើតនិងសាបសូន្យរបស់សត្វលោកផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងបហានសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងវិរាគសញ្ញាផង ចិត្តដែលភិក្ខុសន្សំហើយ ក្នុងនិរោធសញ្ញាផង ។ បណ្តាផលទាំងពីរ ផលណាមួយរមែងប្រាកដដល់ភិក្ខុនោះ គឺនឹងបានអរហត្តផល ក្នុងបច្ចុប្បន្ន ឬកាលបើឧបាទិ នៅសេសសល់ នឹងបានអនាគាមិផល ។

[៦០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះគិរិមានន្ទដ៏មានអាយុ លោកមានអាពាធ ប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់ ។

អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អាយស្មា ភន្តេ គិរិមានន្ទោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ សាធុ ភន្តេ ភគវា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ទស សញ្ញា ភាសេយ្យាសិ ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យ ។ កតមា ទស ។ អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា សព្វលោកេ អនភិរតសញ្ញា សព្វសង្ខារេសុ អនិច្ចសញ្ញា អានាបានស្សតិ ។

គ្រានោះឯង ព្រះអានន្ទត្ថេរដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទត្ថេរដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលនូវពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន គិរិមានន្ទដ៏មានអាយុមានអាពាធ ប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់អនុគ្រោះ (បំពោះគិរិមានន្ទ) សូមស្តេចចូលទៅ ត្រង់កន្លែងដែលគិរិមានន្ទអាស្រ័យនៅ ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលអានន្ទ ប្រសិនបើអ្នកចូលទៅកាន់សំណាក់នៃគិរិមានន្ទភិក្ខុ សម្តែងប្រាប់ សញ្ញាទាំង ១០ ប្រការ ដំណើរនេះជាហេតុនឹងនាំឲ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះ បានរម្ងាប់សះស្បើយទៅមួយរំពេច ព្រោះគិរិមានន្ទភិក្ខុ បានស្តាប់នូវសញ្ញាទាំង ១០ ប្រការ ។ សញ្ញាទាំង ១០ ប្រការនោះ ដូចម្តេចខ្លះ ។ គឺ អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ សព្វសង្ខារេសុអនិច្ចសញ្ញា ១ អានាបានស្សតិ ១ ។

កតមា ចានន្ទ អនិច្ចសញ្ញា ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ រូបំ អនិច្ចំ វេទនា អនិច្ចា សញ្ញា អនិច្ចា សង្ខារា អនិច្ចា វិញ្ញាណំ អនិច្ចន្តិ ។ ឥតិ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ អនិច្ចានុបស្សី វិហរតិ ។ អយំ វុច្ចតានន្ទ អនិច្ចសញ្ញា ។

កតមា ចានន្ទ អនត្តសញ្ញា ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ចក្ខុំ អនត្តា រូបា អនត្តា សោតំ អនត្តា សទ្ទា អនត្តា ឃានំ អនត្តា គន្ធា អនត្តា ជិវ្ហា អនត្តា រសា អនត្តា កាយោ អនត្តា ផោដ្ឋព្វា អនត្តា មនោ អនត្តា ធម្មា អនត្តាតិ ។ ឥតិ ឥមេសុ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនត្តានុបស្សី វិហរតិ ។ អយំ វុច្ចតានន្ទ អនត្តសញ្ញា ។

ម្នាលអានន្ទ អនិច្ចសញ្ញា តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី ពិចារណាឃើញដូច្នេះថា រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ។ ភិក្ខុពិចារណាឃើញរឿយ ៗ ថាមិនទៀង ក្នុងឧបាទានក្ខន្ធទាំង ៥ នេះដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អនិច្ចសញ្ញា ។

ម្នាលអានន្ទ អនត្តសញ្ញា តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះនៅក្នុងព្រៃក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី ពិចារណាឃើញដូច្នេះថា ភ្នែកមិនមែនជារបស់ខ្លួនទេ រូបមិនមែនជារបស់ខ្លួនទេ ត្រចៀកមិនមែនជារបស់ខ្លួនទេ សំឡេងទាំងឡាយ មិនមែនជារបស់ខ្លួនទេ ច្រមុះមិនមែនជារបស់ខ្លួនទេ ក្លិនទាំងឡាយ មិនមែនជារបស់ខ្លួនទេ អណ្ដាតមិនមែនជារបស់ខ្លួនទេ រសទាំងឡាយមិនមែនជារបស់ខ្លួនទេ កាយមិនមែនជារបស់ខ្លួនទេ ផោដ្ឋព្វៈទាំងឡាយមិនមែនជារបស់ខ្លួនទេ ចិត្តមិនមែនជារបស់ខ្លួនទេ ធម៌ទាំងឡាយ មិនមែនជារបស់ខ្លួនទេ ។ ភិក្ខុពិចារណាឃើញរឿយ ៗ ដូច្នេះថា មិនមែនជារបស់ខ្លួនក្នុងអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នេះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អនត្តសញ្ញា ។

កតមា ចានន្ទ អសុភសញ្ញា ។ ឥធានន្ទ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោកេស-មត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ។ ឥតិ ឥមស្មឹ កាយេ អសុភានុបស្សី វិហរតិ ។ អយំ វុច្ចតានន្ទ អសុភសញ្ញា ។

កតមា ចានន្ទ អាទីនវសញ្ញា ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ ។

ម្នាលអានន្ទ អសុភសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះពិចារណាឃើញនូវកាយនេះឯង ខាងលើអំពីផ្ទៃនៃបាតជើងឡើងទៅ ខាងក្រោមអំពីចុងសក់ចុះមក ព័ទ្ធជុំវិញដោយស្បែក ពេញដោយគ្រឿងមិនស្អាត មានប្រការផ្សេង ៗ ដូច្នេះថា ក្នុងរូបកាយនេះ សក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ ឬលំពែងអរឹស សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ ភិក្ខុពិចារណាឃើញរឿយ ៗ ថា មិនល្អក្នុងរូបកាយនេះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អសុភសញ្ញា ។

ម្នាលអានន្ទ អាទីនវសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា រូបកាយនេះ មានទុក្ខច្រើន មានទោសច្រើនដោយពិត ។

ឥតិ ឥមស្មឹ កាយេ វិវិធា អាពាធា ឧប្បជ្ជន្តិ សេយ្យថីទំ ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោតិ ។

អាពាធទាំងឡាយផ្សេង ៗ តែងកើតឡើង ក្នុងកាយនេះដូច្នេះ អាពាធនោះដូចម្តេចខ្លះ គឺរោគក្នុងភ្នែក រោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្តាត រោគក្នុងកាយ រោគក្នុងក្បាល រោគស្លឹកត្រចៀក រោគក្នុងមាត់ រោគត្រង់គល់ធ្មេញ រោគក្អក រោគហឺត រោគខាងក្រៅច្រមុះ រោគក្តៅក្រហាយ រោគស្គាំងស្គម រោគក្នុងផ្ទៃ រោគខ្យល់ចាប់ វិលមុខ រោគធ្លាក់ឈាម រោគចុកសៀត រោគចុះរាក រោគឃ្លង់ រោគបូស រោគស្រែង រោគរីងរៃ រោគឆ្កួតជ្រូក រោគដំណួចពិស រោគរមាស់ រោគកមត្រិន រោគកើតក្នុងទីដែលខ្វារដោយក្រចក រោគឃ្លង់ដែក រោគឈាម រោគប្រមាត់ រោគទឹកនោមផ្អែម រោគឫសដូងដុះ រោគរលកកៃ រោគឫសដូងបាត[១] អាពាធបណ្តាលអំពីប្រមាត់ អាពាធបណ្តាលអំពីស្លេស្ម អាពាធបណ្តាលអំពីខ្យល់ អាពាធបណ្តាលអំពីសន្និបាត គឺការកម្រើកប្រមាត់ ស្លេស្ម និងខ្យល់ប្រជុំគ្នា អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីសេចក្តីព្យាយាមរបស់អ្នកឯទៀត (មានចាប់ចងវាយជាដើម) អាពាធកើតអំពីវិបាករបស់កម្ម ការត្រជាក់ ការក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក ឧច្ចារៈ (អាចម៍) បស្សាវៈ (មូត្រ) ។

១ ឫសដូងបាតដែលដុះខាងក្នុង ត្រង់ចន្លោះទ្វារធំ និងទ្វារតូច ។ អដ្ឋកថា ។

ឥតិ ឥមស្មឹ កាយេ អាទីនវានុបស្សី វិហរតិ ។ អយំ វុច្ចតានន្ទ អាទីនវសញ្ញា ។

កតមា ចានន្ទ បហានសញ្ញា ។ ឥធានន្ទ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ វិហឹសាវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នុប្បន្នេ ចាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ អយំ វុច្ចតានន្ទ បហានសញ្ញា ។

កតមា ចានន្ទ វិរាគសញ្ញា ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និព្វានន្តិ ។

ភិក្ខុពិចារណាឃើញរឿយ ៗ ថាជាទោស ក្នុងរូបកាយនេះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ នេះហៅថា អាទីនវសញ្ញា ។

ម្នាលអានន្ទ បហានសញ្ញា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀតនូវកាមវិតក្កៈ ដែលកើតឡើងហើយ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀតនូវព្យាបាទវិតក្កៈ ដែលកើតឡើងហើយ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀត នូវវិហឹសាវិតក្កៈ ដែលកើតឡើងហើយ មិនទទួលទុក លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀត នូវធម៌ដែលជាបាបអកុសលដែលកើតឡើងហើយរឿយ ៗ ។ ម្នាលអានន្ទនេះ ហៅថា បហានសញ្ញា ។

ម្នាលអានន្ទ វិរាគសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ពិចារណាឃើញរឿយ ៗ ដូច្នេះថា ធម៌ជាគ្រឿងរម្ងាប់ សង្ខារទាំងពួង លះបង់នូវឧបធិទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាករាគៈ រំលត់ទុក្ខ នេះជាធម៌ស្ងប់ធម៌ឧត្តម ។

អយំ វុច្ចតានន្ទ វិរាគសញ្ញា ។

កតមា ចានន្ទ និរោធសញ្ញា ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ និរោធោ និព្វានន្តិ ។ អយំ វុច្ចតានន្ទ និរោធសញ្ញា ។

កតមា ចានន្ទ សព្វលោកេ អនភិរតសញ្ញា ។ ឥធានន្ទ ភិក្ខុ យេ លោកេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហន្តោ វិរមតិ ន ឧបាទិយន្តោ ។ អយំ វុច្ចតានន្ទ សព្វលោកេ អនភិរតសញ្ញា ។

កតមា ចានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា ។ ឥធានន្ទ ភិក្ខុ សព្វសង្ខារេហិ អដ្ដិយតិ ហរាយតិ ជិគុច្ឆតិ ។

ម្នាលអានន្ទ នេះហៅថា វិរាគសញ្ញា ។

ម្នាលអានន្ទ និរោធសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា ធម៌ជាគ្រឿងរម្ងាប់សង្ខារទាំងពួង លះបង់នូវឧបធិទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាករាគៈ រលត់ទុក្ខ នេះ ជាធម៌ស្ងប់ជាធម៌ឧត្តម ។ ម្នាលអានន្ទ នេះហៅថា និរោធសញ្ញា ។

ម្នាលអានន្ទ សព្វលោកេអនភិរតសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ឧបាយគឺតណ្ហានិងទិដ្ឋិណា ឧបាទានគឺ សេចក្តីប្រកាន់មាំណា អភិនិវេសៈ គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ជាទីអាស្រ័យនៅនៃចិត្តណា អនុស័យ គឺកិលេសដែលដេកនៅរឿយ ៗ ក្នុងសត្តសន្តានណា ក្នុងលោក ភិក្ខុក្នុងសាសនានេះ កាលបើលះបង់នូវបាបធម៌ទាំងនោះ មិនបានប្រកាន់មាំដោយចិត្ត ក៏រមែងវៀរ (ចាកបាបធម៌ទាំងនោះ) បាន ។ ម្នាលអានន្ទ នេះហៅថា សព្វលោកេអនភិរតសញ្ញា ។

ម្នាលអានន្ទ សព្វសង្ខារេសុអនិច្ចសញ្ញា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះនឿយណាយ ធុញទ្រាន់ស្អប់ខ្ពើម ចាកសង្ខារទាំងពួង ។

២៤១



អយំ វុច្ចតានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា ។

កតមា ចានន្ទ អានាបានស្សតិ ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ

ម្នាលអានន្ទ នេះហៅថា សព្វសង្ខារេសុ អនិច្ចសញ្ញា ។

ម្នាលអានន្ទ អានាបានស្សតិ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី អង្គុយផ្គត់ភ្នែន តាំងកាយឲ្យត្រង់ផ្ចង់ស្មារតីឲ្យឆ្ពោះត្រង់ (ទៅរកកម្មដ្ឋាន) ។ ភិក្ខុនោះមានស្មារតីដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល កាលដកដង្ហើមចេញវែង ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី ភិក្ខុសិក្សា[១] ថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវកាយ[២] គឺដង្ហើមចេញទាំងអស់ឲ្យប្រាកដ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវកាយ[៣] គឺដង្ហើមចូលទាំងអស់ឲ្យប្រាកដ ទើបដកដង្ហើមចូល

---

១ អដ្ឋកថា ថា ព្យាយាម ។ ២ ធ្វើខាងដើម ខាងកណ្តាល និងទីបំផុតនៃកាយ គឺដង្ហើមចេញទាំងអស់ឲ្យប្រាកដ ។ ៣ ធ្វើខាងដើមខាងកណ្តាល និងទីបំផុតនៃកាយគឺដង្ហើមចូលទាំងអស់ឲ្យប្រាកដ ។

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ សុខប្ប-ដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នករម្ងាប់ នូវកាយសង្ខារ(១) គឺដង្ហើមចេញ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នករម្ងាប់នូវកាយសង្ខារ(២) គឺដង្ហើមចូល ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ(៣) ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចេញ

---

១-២ កាយសង្ខារដ៏គ្រោតគ្រាត ។ ៣ បានដល់ វេទនាខន្ធ និងសញ្ញាខន្ធ ។

២៤៣



ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ... សមាទហំ ចិត្តំ... វិមោចយំ ចិត្តំ... អនិច្ចានុបស្សី... វិរាគានុបស្សី... និរោធានុបស្សី... បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ អយំ វុច្ចតានន្ទ អានាបានស្សតិ ។

ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចូល ភិក្ខុសិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ... តម្កល់ចិត្តឲ្យស្មើក្នុងអារម្មណ៍... ដោះចិត្តឲ្យរួចចាកនីវរណធម៌ ជាដើម[១]... ឃើញរឿយ ៗ នូវបញ្ចក្ខន្ធថា មិនទៀង... ឃើញរឿយ ៗ នូវធម៌ដែលប្រាសចាករាគៈ... ឃើញរឿយ ៗ នូវធម៌ ដែលរលត់បង់នូវកងទុក្ខ... ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកឃើញរឿយ ៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេស ទើបដកដង្ហើមចេញ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកឃើញរឿយ ៗ នូវធម៌ ជាគ្រឿងលះបោលនូវកិលេស ទើបដកដង្ហើមចូល ។ ម្នាលអានន្ទ នេះហៅថា អានាបានស្សតិ ។

---

១ អដ្ឋកថាពន្យល់ថា ភិក្ខុដោះចិត្តឲ្យរួចចាកនីវរណធម៌ ដោយបឋមជ្ឈាន ឲ្យរួចចាកវិតក្កៈនិងវិចារៈ ដោយទុតិយជ្ឈាន ឲ្យរួចចាកបីតិដោយតតិយជ្ឈាន ឲ្យរួចចាកសុខនិងទុក្ខ ដោយចតុត្ថជ្ឈាន ឲ្យរួចចាកនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ឲ្យរួចចាកសុខសញ្ញា ដោយទុក្ខានុបស្សនា ឲ្យរួចចាកអត្តសញ្ញា ដោយអនត្តានុបស្សនា ឲ្យរួចចាកនន្ទិ ដោយនិព្វិទានុបស្សនា ឲ្យរួចចាករាគៈ ដោយវិរាគានុបស្សនា ឲ្យរួចចាកសមុទយៈដោយនិរោធានុបស្សនា ឲ្យរួចចាកអាទានៈ ដោយបដិនិស្សគ្គានុបស្សនា ។

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ឥមា ទស សញ្ញា ភាសេយ្យាសិ ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យាតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ ឥមា ទស សញ្ញា ឧគ្គហេត្វា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា អភាសិ ។ អថខោ អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភិ វុដ្ឋហិ ចាយស្មា គិរិមានន្ទោ តម្ហា អាពាធា តថា បហីនោ ច បនាយស្មតោ គិរិមានន្ទស្ស សោ អាពាធោ អហោសីតិ ។

សចិត្តវគ្គោ បឋមោ ។

ម្នាលអានន្ទ បើអ្នកចូលទៅ (កាន់សំណាក់) នៃគិរិមានន្ទភិក្ខុហើយ គប្បីសម្តែងនូវសញ្ញាទាំងឡាយ ១០ ប្រការនេះ ដំណើរនេះ ជាហេតុនឹងឲ្យអាពាធ របស់គិរិមានន្ទភិក្ខុនោះ រម្ងាប់សះស្បើយទៅ ១ រំពេច ព្រោះគិរិមានន្ទភិក្ខុ បានស្តាប់សញ្ញាទាំងឡាយ ១០ ប្រការនេះ ។ លំដាប់នោះ ព្រះអានន្ទត្ថេរដ៏មានអាយុ ក៏រៀនសញ្ញាទាំងឡាយ ១០ ប្រការនេះ ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ហើយចូលទៅត្រង់កន្លែងដែលគិរិមានន្ទលោកគង់នៅ លុះចូលទៅដល់ហើយ បានសម្តែងសញ្ញាទាំងឡាយ ១០ ប្រការនេះ ដល់គិរិមានន្ទដ៏មានអាយុ ។ លំដាប់នោះឯង អាពាធរបស់គិរិមានន្ទដ៏មានអាយុនោះ ក៏រម្ងាប់សះស្បើយទៅ ១ រំពេច ព្រោះបានស្តាប់សញ្ញាទាំងឡាយ ១០ ប្រការនេះ ឯគិរិមានន្ទ ដ៏មានអាយុ ក៏បានជាសះស្បើយចាកអាពាធនោះ ក៏អាពាធនោះ គិរិមានន្ទដ៏មានអាយុ លះបង់បានហើយ ដោយកិរិយាបានស្តាប់សញ្ញាទាំង ១០ ប្រការ ដែលព្រះអានន្ទត្ថេរ សម្តែងហើយដូច្នោះ ដោយប្រការដូច្នេះឯង ។

ចប់ សចិត្តវគ្គ ទី ១ ។

២៤៥



# តស្សុទ្ទានំ

សចិត្តសារីបុត្តា[១] ច ឋិតិ[២] ច សមថេន ច
បរិហានា[៣] ច ទ្វេ សញ្ញា មូលា បព្វជិតាពលោ[៤] ។

១ ម. សចិត្តញ្ច សារីបុត្ត ។ ២ ម. ធិតិ ។ ៣ ម. បរិហានោ ច ។ ៤ ឱ. បព្វជិតាគិរីតិ ។ ម. បព្វជិតគិរីតិ ។

# ឧទ្ទាននៃសចិត្តវគ្គនោះគឺ

*និយាយអំពីការឈ្លាសក្នុងវារៈចិត្តរបស់ខ្លួន ១ អំពីព្រះសារីបុត្ត ១ អំពីការតាំងនៅដដែល ១ អំពីសមថៈ ១ អំពីបរិហានៈ ១ អំពីសញ្ញាពីរលើក អំពីធម៌ជាមូល ១ ចិត្តសន្សំដោយបព្វជ្ជា ១ អាពាធ ១ ។*

---

# យមកវគ្គោ ទុតិយោ

[៦១] បុរិមា ភិក្ខវេ កោដិ ន បញ្ញាយតិ អវិជ្ជាយ ឥតោ បុព្វេ អវិជ្ជា នាហោសិ អថ បច្ឆា សម្ភវីតិ(១) ឯវញ្ចេតំ ភិក្ខវេ វុច្ចតិ អថ ច បន បញ្ញាយតិ ឥទប្បច្ចយា អវិជ្ជាតិ ។ អវិជ្ជម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អវិជ្ជាយ ។ បញ្ច នីវរណាតិស្ស វចនីយំ ។ បញ្ចបហំ(២) ភិក្ខវេ នីវរណេ សាហារេ វទាមិ នោ អនាហារេ ។ កោ ចាហារោ បញ្ចន្នំ នីវរណានំ ។ តីណិ ទុច្ចរិតានីតិស្ស វចនីយំ ។ តីណិបហំ ភិក្ខវេ ទុច្ចរិតានិ សាហារានិ វទាមិ នោ អនាហារានិ ។ កោ ចាហារោ តិណ្ណំ ទុច្ចរិតានំ ។ ឥន្ទ្រិយាសំវរោ-តិស្ស វចនីយំ ។ ឥន្ទ្រិយាសំវរម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ ឥន្ទ្រិយាសំវរស្ស ។ អសតាសម្បជញ្ញន្តិស្ស វចនីយំ ។

---

១ ម. សមភវីតិ ។ ២ ម. បញ្ចបាហំ ។

# យមកវគ្គ ទី ២

[៦១] ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើម របស់អវិជ្ជាមិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុនអំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អវិជ្ជានេះ តថាគតពោលយ៉ាងនេះ តែថា អវិជ្ជា រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អវិជ្ជាប្រកបដោយអាហារ មិនបានពោលថា អវិជ្ជាឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អវិជ្ជា ។ គប្បីឆ្លើយថា នីវរណៈ ៥ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា នីវរណៈ ៥ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់នីវរណៈ ៥ ។ គប្បីឆ្លើយថា ទុច្ចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទុច្ចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ទុច្ចរិត ៣ ។ គប្បីឆ្លើយថា ការមិនសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនសង្រួមឥន្ទ្រិយ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ការមិនសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា ការមិនមានសតិ មិនមានសម្បជញ្ញៈ ។

អសតាសម្បជញ្ញម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អសតាសម្បជញ្ញស្ស ។ អយោនិសោ មនសិការោតិស្ស វចនីយំ ។ អយោ-និសោ មនសិការម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អយោនិសោ មនសិ-ការស្ស ។ អស្សទ្ធិយន្តិស្ស វចនីយំ ។ អស្សទ្ធិ-យម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អស្សទ្ធិយស្ស ។ អស្សទ្ធម្មស្សវនន្តិស្ស វចនីយំ ។ អស្សទ្ធម្មស្សវនម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អស្ស-ទ្ធម្មស្សវនស្ស ។ អសប្បុរិសសំសេវោតិស្ស វចនីយំ ។ ឥតិ ខោ ភិក្ខវេ អសប្បុរិសសំសេវោ បរិបូរោ អស្សទ្ធម្មស្សវនំ បរិបូរេតិ អស្សទ្ធម្មស្សវនំ បរិបូរំ

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនមានសតិ មិនមាន សម្បជញ្ញៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ គប្បីឆ្លើយថា អយោនិសោមនសិការៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អយោនិសោមនសិការៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់អយោនិសោមនសិការៈ ។ គប្បីឆ្លើយថា អស្សទ្ធិយៈ (សេចក្តីមិនជឿ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធិយៈ ប្រកបដោយអាហារ មិនបានពោលថា ឥត អាហារទេ ។ ចុះអ្វីជាអាហារ របស់អស្សទ្ធិយៈ ។ គប្បីឆ្លើយថា អស្សទ្ធម្មស្សវនៈ (ការមិនស្តាប់ព្រះសទ្ធម្ម) ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធម្មស្សវនៈ ប្រកបដោយអាហារ មិនបាន ពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់អស្សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា អសប្បុរិសសំសេវៈ (ការសេពគប់អសប្បុរស) ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសសំសេវៈ ពេញបរិបូណ៌ រមែង ញុំាងអស្សទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ អស្សទ្ធម្មស្សវនៈ ពេញបរិបូណ៌

អស្សទ្ធិយំ បរិបូរេតិ អស្សទ្ធិយំ បរិបូរំ អយោនិសោមនសិការំ បរិបូរេតិ អយោនិសោមនសិការោ បរិបូរោ អសតាសម្បជញ្ញំ បរិបូរេតិ អសតាសម្បជញ្ញំ បរិបូរំ ឥន្ទ្រិយាសំវរំ បរិបូរេតិ ឥន្ទ្រិយាសំវរោ បរិបូរោ តីណិ ទុច្ចរិតានិ បរិបូរេតិ តីណិ ទុច្ចរិតានិ បរិបូរានិ បញ្ច នីវរណេ បរិបូរេន្តិ បញ្ច នីវរណា បរិបូរា អវិជ្ជំ បរិបូរេន្តិ ។ ឯវមេតិស្សា អវិជ្ជាយ អាហារោ ហោតិ ឯវញ្ច ចារិបូរិ ។ សេយ្យថាបិ ភិក្ខវេ ឧបរិបព្វតេ ថុល្លផុសិតកេ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ តំ ឧទកំ យថានិន្នំ បវត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតកន្ទរបទរសាខា បរិបូរា កុសុព្ភេ[១] បរិបូរេន្តិ កុសុព្ភា បរិបូរា មហាសោព្ភេ បរិបូរេន្តិ មហាសោព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា មហាសមុទ្ទំ សាគរំ បរិបូរេន្តិ

---

១ ម. កុសុម្ភេ ។

រមែងញុំាងអសទ្ធិយៈ ឲ្យពេញបរិបូណ៌ អសទ្ធិយៈពេញបរិបូណ៌ រមែងញុំាងអយោនិសោមនសិការៈ ឲ្យពេញបរិបូណ៌ អយោនិសោ មនសិការៈ ពេញបរិបូណ៌ រមែងញុំាងការមិនមានសតិ និងមិនមានសម្បជញ្ញៈ ឲ្យពេញបរិបូណ៌ ការមិនមានសតិ មិនមានសម្បជញ្ញៈពេញបរិបូណ៌ រមែងញុំាងការមិនសង្រួមឥន្ទ្រិយ ឲ្យពេញបរិបូណ៌ ការមិនសង្រួមឥន្ទ្រិយ ពេញបរិបូណ៌ រមែងញុំាងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ ទុច្ចរិតទាំង ៣ ពេញបរិបូណ៌ រមែងញុំាងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ នីវរណៈ ៥ ពេញបរិបូណ៌ រមែងញុំាងអវិជ្ជាឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហាររបស់អវិជ្ជានេះ រមែងមានយ៉ាងនេះ អាហាររបស់អវិជ្ជានេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀង មានតំណក់ថ្លោស កាលបង្អុរ កាលរំលា ហូរធ្លាក់លើកំពូលភ្នំ ទឹកនោះក៏ហូរទៅតាមទីទាប រមែងញុំាងជ្រោះភ្នំ ល្អាងនិងអូរតូច ឲ្យពេញ ជ្រោះភ្នំល្អាងនិងអូរតូច ពេញហើយ រមែងញុំាងត្រពាំងតូច ឲ្យពេញ ត្រពាំងតូចពេញហើយ រមែងញុំាងត្រពាំងធំ ឲ្យពេញ ត្រពាំងធំពេញហើយ រមែងញុំាងស្ទឹងតូច ឲ្យពេញ ស្ទឹងតូចពេញហើយ រមែងញុំាងស្ទឹងធំឲ្យពេញ ស្ទឹងធំ ពេញហើយ រមែងញុំាងមហាសមុទ្រសាគរ ឲ្យពេញ

២៤៩



ឯវមេតស្ស មហាសមុទ្ទស្ស សាគរស្ស អាហារោ ហោតិ ឯវញ្ច ចារិបូរិ ។ ឯវមេវ ខោ ភិក្ខវេ អសប្បុរិសសំសេវោ បរិបូរោ អស្សទ្ធម្មស្សវនំ បរិបូរេតិ អស្សទ្ធម្មស្សវនំ បរិបូរំ អស្សទ្ធិយំ បរិបូរេតិ អស្សទ្ធិយំ បរិបូរំ អយោនិសោ មនសិការំ បរិបូរេតិ អយោនិសោ មនសិការោ បរិបូរោ អសតាសម្បជញ្ញំ បរិបូរេតិ អសតាសម្បជញ្ញំ បរិបូរំ ឥន្ទ្រិយាសំវរំ បរិបូរេតិ ឥន្ទ្រិយាសំវរោ បរិបូរោ តីណិ ទុច្ចរិតានិ បរិបូរេតិ តីណិ ទុច្ចរិតានិ បរិបូរានិ បញ្ច នីវរណេ បរិបូរេន្តិ បញ្ច នីវរណា បរិបូរា អវិជ្ជំ បរិបូរេន្តិ ។ ឯវមេតិស្សា អវិជ្ជាយ អាហារោ ហោតិ ឯវញ្ច ចារិបូរិ ។ វិជ្ជាវិមុត្តិម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។

អាហារនៃមហាសមុទ្រសាគរនេះ រមែងមានយ៉ាងនេះ មហាសមុទ្រសា-គរពេញបរិបូណ៌យ៉ាងនេះ ឧបមាយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា អសប្បុរិសសំសេវៈ ពេញបរិបូណ៌ រមែងញ៉ាំង អស្សទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ អស្សទ្ធម្មស្សវនៈ ពេញបរិបូណ៌ ហើយ រមែងញ៉ាំងអស្សទ្ធិយៈ ឲ្យពេញបរិបូណ៌ អស្សទ្ធិយៈ ពេញ បរិបូណ៌ហើយ រមែងញ៉ាំងអយោនិសោមនសិការៈ ឲ្យពេញបរិបូណ៌ អយោនិសោមនសិការៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងការមិនមាន សតិ មិនមានសម្បជញ្ញៈ ឲ្យពេញបរិបូណ៌ ការមិនមានសតិ មិនមាន សម្បជញ្ញៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងការមិនសង្រួមឥន្ទ្រិយ ឲ្យពេញបរិបូណ៌ ការមិនសង្រួមឥន្ទ្រិយ ពេញបរិបូណ៌ហើយ រមែង ញ៉ាំងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ ទុច្ចរិត ៣ ពេញបរិបូណ៌ហើយ រមែង ញ៉ាំងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ នីវរណៈ ៥ ពេញបរិបូណ៌ហើយ រមែងញ៉ាំងអវិជ្ជា ឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះ ។ អាហារ របស់អវិជ្ជានេះ រមែងមានយ៉ាងនេះ អាហាររបស់អវិជ្ជានេះ ពេញ បរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិជ្ជា និងវិមុត្តិ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។

កោ ចាហារោ វិជ្ជាវិមុត្តិយា ។ សត្ត ពោជ្ឈង្គាតិស្ស វចនីយំ ។ សត្តបហំ ភិក្ខវេ ពោជ្ឈង្គេ សាហារេ វទាមិ នោ អនាហារេ ។ កោ ចាហារោ សត្តន្នំ ពោជ្ឈង្គានំ ។ ចត្តារោ សតិប្បដ្ឋានាតិស្ស វចនីយំ ។ ចត្តារោបហំ ភិក្ខវេ សតិប្បដ្ឋានេ សាហារេ វទាមិ នោ អនាហារេ ។ កោ ចាហារោ ចតុន្នំ សតិប្ប-ដ្ឋានានំ ។ តីណិ សុចរិតានីតិស្ស វចនីយំ ។ តីណិ-បហំ ភិក្ខវេ សុចរិតានិ សាហារានិ វទាមិ នោ អនាហារានិ ។ កោ ចាហារោ តិណ្ណំ សុចរិតានំ ។ ឥន្ទ្រិយសំវរោតិស្ស វចនីយំ ។ ឥន្ទ្រិយសំវរម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ ឥន្ទ្រិយសំវរស្ស ។ សតិសម្បជញ្ញន្តិស្ស វចនីយំ ។ សតិសម្បជញ្ញម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ សតិសម្បជញ្ញស្ស ។

ចុះអ្វីជាអាហាររបស់វិជ្ជានិងវិមុត្តិ ។ គប្បីឆ្លើយថា ពោជ្ឈង្គ ៧ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពោជ្ឈង្គ ៧ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ពោជ្ឈង្គ ៧ ។ គប្បីឆ្លើយថា សតិប្បដ្ឋាន ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិប្បដ្ឋាន ៤ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សតិប្បដ្ឋាន ៤ ។ គប្បីឆ្លើយថា សុចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សុចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សុចរិត ៣ ។ គប្បីឆ្លើយថា ការសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសង្រួមឥន្ទ្រិយប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា សតិនិងសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិនិងសម្បជញ្ញៈប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សតិនិងសម្បជញ្ញៈ ។

២៤១



យោនិសោ មនសិការោតិស្ស វចនីយំ ។ យោនិសោ មនសិការម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ យោនិសោ មនសិការស្ស ។ សទ្ធាតិស្ស វចនីយំ ។ សទ្ធម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ សទ្ធាយ ។ សទ្ធម្មស្សវនន្តិស្ស វចនីយំ ។ សទ្ធម្មស្សវនម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ សទ្ធម្មស្សវនស្ស ។ សប្បុរិសសំសេវោតិស្ស វចនីយំ ។ ឥតិ ខោ ភិក្ខវេ សប្បុរិសសំសេវោ បរិបូរោ សទ្ធម្មស្សវនំ បរិបូរេតិ សទ្ធម្មស្សវនំ បរិបូរំ សទ្ធំ បរិបូរេតិ សទ្ធា បរិបូរា យោនិសោ មនសិការំ បរិបូរេតិ យោនិសោ មនសិ-ការោ បរិបូរោ សតិសម្បជញ្ញំ បរិបូរេតិ សតិសម្ប-ជញ្ញំ បរិបូរំ ឥន្ទ្រិយសំវរំ បរិបូរេតិ ឥន្ទ្រិយសំវរោ បរិបូរោ តីណិ សុចរិតានិ បរិបូរេតិ តីណិ សុចរិ-តានិ បរិបូរានិ ចត្តារោ សតិបដ្ឋានេ បរិបូរេន្តិ

គប្បីឆ្លើយថា យោនិសោមនសិការៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា យោនិសោមនសិការៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់យោនិសោមនសិការៈ ។ គប្បី ឆ្លើយថា សទ្ធា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធាប្រ-កបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអា-ហាររបស់សទ្ធា ។ គប្បីឆ្លើយថា សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធម្មស្សវនៈ ប្រកបដោយអាហារ មិនបាន ពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា សប្បុរិសសំសេវៈ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិ-សសំសេវៈ ពេញបរិបូណ៌ រមែងញុំាងសទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ សទ្ធម្មស្សវនៈ ពេញបរិបូណ៌ហើយ រមែងញុំាងសទ្ធា ឲ្យពេញបរិបូណ៌ សទ្ធា ពេញបរិបូណ៌ហើយ រមែងញុំាងយោនិសោមនសិការៈ ឲ្យ ពេញបរិបូណ៌ យោនិសោមនសិការៈ ពេញបរិបូណ៌ហើយ រមែងញុំាង សតិនិងសម្បជញ្ញៈ ឲ្យពេញបរិបូណ៌ សតិនិងសម្បជញ្ញៈ ពេញបរិបូណ៌ ហើយ រមែងញុំាងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ ការសង្រួមឥន្ទ្រិយ ពេញបរិបូណ៌ហើយ រមែងញុំាងសុចរិត ៣ ឲ្យពេញបរិបូណ៌ សុចរិត ៣ ពេញបរិបូណ៌ហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌

ចត្តារោ សតិប្បដ្ឋានា បរិបូរា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា បរិបូរា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។ ឯវមេតិស្សា វិជ្ជាវិមុត្តិយា អាហារោ ហោតិ ឯវញ្ច ចារិបូរិ ។ សេយ្យថាបិ ភិក្ខវេ ឧបរិបព្វតេ ថុល្លផុសិតកេ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ តំ ឧទកំ យថានិន្នំ បវត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតកន្ទរបទរសាខា បរិបូរា កុសុព្ភេ បរិបូរេន្តិ កុសុព្ភា បរិបូរា មហាសោព្ភេ បរិបូរេន្តិ មហាសោព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា មហាសមុទ្ទំ សាគរំ បរិបូរេន្តិ ឯវមេតស្ស មហាសមុទ្ទស្ស សាគរស្ស អាហារោ ហោតិ ឯវញ្ច ចារិបូរិ ឯវមេវ ខោ ភិក្ខវេ សប្បុរិសសំសេវោ បរិបូរោ សទ្ធម្មស្សវនំ បរិបូរេតិ សទ្ធម្មស្សវនំ បរិបូរំ សទ្ធំ បរិបូរេតិ

សតិប្បដ្ឋាន ៤ ពេញបរិបូណ៌ហើយ រមែងញុំាងពោជ្ឈង្គ ៧ ឲ្យពេញបរិបូណ៌ ពោជ្ឈង្គ ៧ ពេញបរិបូណ៌ហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញបរិបូណ៌ ដោយប្រការ ដូច្នេះឯង ។ អាហាររបស់វិជ្ជានិងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀងមានតំណក់ថ្លោស កាលបង្អុរ កាលរំលាហូរធ្លាក់លើកំពូលភ្នំ ទឹកនោះក៏ហូរទៅតាមទីទាប រមែងញុំាងជ្រោះភ្នំល្អាង និងអូរតូច ឲ្យពេញ ជ្រោះភ្នំ ល្អាង និងអូរតូច ពេញហើយ រមែងញុំាងត្រពាំងតូច ឲ្យពេញ ត្រពាំងតូច ពេញហើយ រមែងញុំាងត្រពាំងធំ ឲ្យពេញ ត្រពាំងធំ ពេញហើយ រមែងញុំាងស្ទឹងតូចឲ្យពេញ ស្ទឹងតូចពេញហើយ រមែងញុំាងស្ទឹងធំ ឲ្យពេញ ស្ទឹងធំពេញហើយ រមែងញុំាងមហាសមុទ្រសាគរ ឲ្យពេញ អាហារនៃមហាសមុទ្រសាគរនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា សប្បុរិស-សំសេវៈ ពេញបរិបូណ៌ រមែងញុំាងសទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ សទ្ធម្មស្សវនៈ ពេញបរិបូណ៌ហើយ រមែងញុំាងសទ្ធាឲ្យពេញបរិបូណ៌

សទ្ធា បរិបូរា យោនិសោ មនសិការំ បរិបូរេតិ យោនិសោ មនសិការោ បរិបូរោ សតិសម្បជញ្ញំ បរិបូរេតិ សតិសម្បជញ្ញំ បរិបូរំ ឥន្ទ្រិយសំវរំ បរិបូរេតិ ឥន្ទ្រិយ-សំវរោ បរិបូរោ តីណិ សុចរិតានិ បរិបូរេតិ តីណិ សុចរិតានិ បរិបូរានិ ចត្តារោ សតិប្បដ្ឋានេ បរិបូរេន្តិ ចត្តារោ សតិប្បដ្ឋានា បរិបូរា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា បរិបូរា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។ ឯវមេតិស្សា វិជ្ជាវិមុត្តិយា អាហារោ ហោតិ ឯវញ្ច បារិបូរីតិ ។

[៦២] បុរិមា ភិក្ខវេ កោដិ ន បញ្ញាយតិ ភវតណ្ហាយ ឥតោ បុព្វេ ភវតណ្ហា នាហោសិ អថ បច្ឆា សម្ភវីតិ ឯវញ្ចេតំ ភិក្ខវេ វុច្ចតិ អថ ច បន បញ្ញាយតិ ឥទប្បច្ចយា ភវតណ្ហាតិ ។

សទ្ធាពេញបរិបូណ៌ហើយ រមែងញ៉ាំងយោនិសោមនសិការៈ ឲ្យពេញបរិបូណ៌ យោនិសោមនសិការៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងសតិនិងសម្បជញ្ញៈ ឲ្យពេញបរិបូណ៌ សតិនិងសម្បជញ្ញៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងការសង្រួមឥន្ទ្រិយ ឲ្យពេញបរិបូណ៌ ការសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញ៉ាំងសុចរិត ៣ ឲ្យពេញបរិបូណ៌ សុចរិត ៣ ពេញបរិបូណ៌ហើយ រមែងញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌ សតិប្បដ្ឋាន ៤ ពេញបរិបូណ៌ហើយ រមែងញ៉ាំងពោជ្ឈង្គ៧ ឲ្យពេញបរិបូណ៌ ពោជ្ឈង្គ ៧ ពេញបរិបូណ៌ហើយ រមែងញ៉ាំងវិជ្ជានិងវិមុត្តិឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះ ។ អាហាររបស់វិជ្ជានិងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។

[៦២] ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើម របស់ភវតណ្ហាមិនប្រាកដទេ ភវតណ្ហា (សេចក្តីប្រាថ្នាក្នុងភព) មិនមានក្នុងកាលមុន អំពីកាលនេះ ឬថា កើតឡើង ក្នុងខាងក្រោយឡើយ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ ក៏ ពាក្យថា ភវតណ្ហានេះ តថាគតពោលយ៉ាងនេះ តែថា ភវតណ្ហា រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ។

ភវតណ្ហម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ ភវតណ្ហាយ ។ អវិជ្ជាតិស្ស វចនីយំ ។ អវិជ្ជម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អវិជ្ជាយ ។ បញ្ច នីវរណាតិស្ស វចនីយំ ។ បញ្ច នីវរណេបហំ(១) ភិក្ខវេ សាហារេ វទាមិ នោ អនាហារេ ។ កោ ចាហារោ បញ្ចន្នំ នីវរណានំ ។ តីណិ ទុច្ចរិតានីតិស្ស វចនីយំ ។ តីណិបហំ ភិក្ខវេ ទុច្ចរិតានិ សាហារានិ វទាមិ នោ អនាហារានិ ។ កោ ចាហារោ តិណ្ណំ ទុច្ចរិ-តានំ ។ ឥន្ទ្រិយាសំវរោតិស្ស វចនីយំ ។ ឥន្ទ្រិ-យាសំវរម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ ឥន្ទ្រិយាសំវរស្ស ។ អសតាសម្បជញ្ញន្តិស្ស វចនីយំ ។ អសតាសម្បជ-ញ្ញម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។

១ ឱ. បញ្ចបហំ ភិក្ខវេ នីវរណេ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភវតណ្ហា ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ភវតណ្ហា ។ គប្បីឆ្លើយថាអវិជ្ជា ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អវិជ្ជាប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់អវិជ្ជា ។ គប្បីឆ្លើយថា នីវរណៈ ៥ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា នីវរណៈ ៥ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់នីវរណៈ ៥ ។ គប្បីឆ្លើយថា ទុច្ចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ទុច្ចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ទុច្ចរិត ៣ ។ គប្បីឆ្លើយថា ការមិនសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនសង្រួមឥន្ទ្រិយ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ការមិនសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការមិនមានសតិ មិនមានសម្បជញ្ញៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។

កោ ចាហារោ អសតាសម្បជញ្ញស្ស ។ អយោនិសោ មនសិការោតិស្ស វចនីយំ ។ អយោ-និសោ មនសិការម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អយោនិសោ មនសិការស្ស ។ អស្សទ្ធិយន្តិស្ស វចនីយំ ។ អស្សទ្ធិយម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនា-ហារំ ។ កោ ចាហារោ អស្សទ្ធិយស្ស ។ អស្សទ្ធម្មស្សវនន្តិស្ស វចនីយំ ។ អស្សទ្ធម្មស្ស-វនម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ អស្សទ្ធម្មស្សវនស្ស ។ អសប្បុរិស-សំសេវោតិស្ស វចនីយំ ។ ឥតិ ខោ ភិក្ខវេ អសប្បុរិសសំសេវោ បរិបូរោ អស្សទ្ធម្មស្សវនំ បរិបូ-រេតិ អស្សទ្ធម្មស្សវនំ បរិបូរំ អស្សទ្ធិយំ បរិបូរេតិ អស្សទ្ធិយំ បរិបូរំ អយោនិសោ មនសិការំ បរិបូរេតិ អយោនិសោ មនសិការោ បរិបូរោ

ចុះអ្វីជាអាហាររបស់ការមិនមានសតិ មិនមានសម្បជញ្ញៈ ។ គប្បីឆ្លើយថា អយោនិសោមនសិការៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អយោនិសោមនសិការៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអា-ហារទេ ។ ចុះអ្វីជាអាហាររបស់អយោនិសោមនសិការៈ ។ គប្បីឆ្លើយថា អស្សទ្ធិយៈ (សេចក្តីមិនជឿ) ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធិយៈប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់អស្សទ្ធិយៈ ។ គប្បីឆ្លើយថា អស្សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អស្សទ្ធម្មស្សវនៈ ប្រកបដោយ អាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់អស្សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា អសប្បុរិសសំសេវៈ ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសសំសេវៈ ពេញបរិបូណ៌ហើយ រមែងញុំាងអស្សទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ លុះអស្សទ្ធម្មស្សវនៈ ពេញបរិបូណ៌ហើយ រមែងញុំាងអស្សទ្ធិយៈ ឲ្យពេញបរិបូណ៌ លុះ អស្សទ្ធិយៈ ពេញបរិបូណ៌ហើយ រមែងញុំាងអយោនិសោមនសិការៈ ឲ្យពេញបរិបូណ៌ លុះអយោនិសោមនសិការៈ ពេញបរិបូណ៌ហើយ

អសតាសម្បជញ្ញំ បរិបូរេតិ អសតាសម្បជញ្ញំ បរិបូរំ ឥន្ទ្រិយាសំវរំ បរិបូរេតិ ឥន្ទ្រិយាសំវរោ បរិបូរោ តីណិ ទុច្ចរិតានិ បរិបូរេតិ តីណិ ទុច្ចរិតានិ បរិបូរានិ បញ្ច នីវរណេ បរិបូរេន្តិ បញ្ច នីវរណា បរិបូរា អវិជ្ជំ បរិបូរេន្តិ អវិជ្ជា បរិបូរា ភវតណ្ហំ បរិបូរេតិ ។ ឯវមេតិស្សា ភវតណ្ហាយ អាហារោ ហោតិ ឯវញ្ច ចារិបូរិ ។ សេយ្យថាបិ ភិក្ខវេ ឧបរិបព្វតេ ថុល្លផុ-សិតកេ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ តំ ឧទកំ យថានិន្នំ បវត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតកន្ទរបទរសាខា បរិបូរា កុសុព្ភេ បរិបូរេន្តិ កុសុព្ភា បរិបូរា មហាកុសុព្ភេ[១] បរិបូរេន្តិ មហាកុសុព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា មហាសមុទ្ទំ សាគរំ បរិបូរេន្តិ

១ ឱ. មហាសោព្ភេ ។ ម. មហាសុព្ភេ ។

រមែងញ៉ាំងការមិនមានសតិ មិនមានសម្បជញ្ញៈ ឲ្យពេញបរិបូណ៌ លុះការមិនមានសតិ មិនមានសម្បជញ្ញៈពេញបរិបូណ៌ហើយ រមែងញ៉ាំងការមិនសង្រួមឥន្ទ្រិយ ឲ្យពេញបរិបូណ៌ លុះការមិនសង្រួមឥន្ទ្រិយពេញបរិបូណ៌ហើយ រមែងញ៉ាំងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ លុះទុច្ចរិត ៣ ពេញបរិបូណ៌ហើយ រមែងញ៉ាំងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ លុះនីវរណៈ ៥ ពេញបរិបូណ៌ហើយ រមែងញ៉ាំងអវិជ្ជាឲ្យពេញបរិបូណ៌ លុះអវិជ្ជាពេញបរិបូណ៌ហើយ រមែងញ៉ាំងភវតណ្ហា ឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហាររបស់ភវតណ្ហានេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀង មានតំណក់ដ៏ថ្លោសកាលបង្អុរ កាលរំលា ហូរធ្លាក់លើកំពូលភ្នំ ទឹកនោះក៏ហូរទៅកាន់ទីទាប រមែងញ៉ាំងជ្រោះភ្នំ ល្អាងនិងអូរតូច ឲ្យពេញ លុះជ្រោះភ្នំ ល្អាងនិងអូរតូចពេញហើយ រមែងញ៉ាំងត្រពាំងតូច ឲ្យពេញ លុះត្រពាំងតូចពេញហើយ រមែងញ៉ាំងត្រពាំងធំ ឲ្យពេញ លុះត្រពាំងធំពេញហើយ រមែងញ៉ាំងស្ទឹងតូចឲ្យពេញ លុះស្ទឹងតូចពេញហើយ រមែងញ៉ាំងស្ទឹងធំឲ្យពេញ លុះស្ទឹងធំ ពេញហើយ រមែងញ៉ាំងមហាសមុទ្រសាគរឲ្យពេញ

២៤៧

ទុតិយបណ្ណាសកេ យមកវគ្គោ

ឯវមេតស្ស មហាសមុទ្ទស្ស សាគរស្ស អាហារោ ហោតិ ឯវញ្ច ចារិប្ចុរិ ឯវមេវ ខោ ភិក្ខវេ អសប្បុរិសសំសេវោ បរិប្ចុរោ អស្សទ្ធម្មស្សវនំ បរិប្ចុរេតិ អស្សទ្ធម្មស្សវនំ បរិប្ចុរំ អស្សទ្ធិយំ បរិប្ចុរេតិ អស្សទ្ធិយំ បរិប្ចុរំ អយោនិសោ មនសិការំ បរិប្ចុរេតិ អយោនិសោ មនសិការោ បរិប្ចុរោ អសតាសម្បជញ្ញំ បរិប្ចុរេតិ អសតាសម្បជញ្ញំ បរិប្ចុរំ ឥន្ទ្រិយាសំវរំ បរិប្ចុរេតិ ឥន្ទ្រិយាសំវរោ បរិប្ចុរោ តីណិ ទុច្ចរិតានិ បរិប្ចុរេតិ តីណិ ទុច្ចរិតានិ បរិប្ចុរានិ បញ្ច នីវរណេ បរិប្ចុរេន្តិ បញ្ច នីវរណា បរិប្ចុរា អវិជ្ជំ បរិប្ចុរេន្តិ អវិជ្ជា បរិប្ចុរា ភវតណ្ហំ បរិប្ចុរេតិ ។ ឯវមេតិស្សា ភវតណ្ហាយ អាហារោ ហោតិ ឯវញ្ច ចារិប្ចុរិ ។

អាហារនៃមហាសមុទ្រសាគរនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌ ហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា អសប្បុរិសសំសេវៈ ពេញបរិបូណ៌ហើយ រមែងញុាំងអស្សទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ លុះអស្សទ្ធម្មស្សវនៈ ពេញបរិបូណ៌ហើយ រមែងញុាំងអស្សទ្ធិយៈ ឲ្យពេញបរិបូណ៌ លុះអស្សទ្ធិយៈ ពេញបរិបូណ៌ហើយ រមែងញុាំងអយោនិសោមនសិការៈ ឲ្យពេញបរិបូណ៌ លុះអយោនិសោមនសិការៈពេញបរិបូណ៌ហើយ រមែងញុាំងការមិនមានសតិ មិនមានសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះការមិនមានសតិ មិនមានសម្បជញ្ញៈ ពេញបរិបូណ៌ហើយ រមែងញុាំងការមិនសង្រួមឥន្ទ្រិយ ឲ្យពេញបរិបូណ៌ លុះការមិនសង្រួមឥន្ទ្រិយ ពេញបរិបូណ៌ហើយ រមែងញុាំងទុច្ចរិត ៣ ឲ្យពេញបរិបូណ៌ លុះទុច្ចរិត ៣ ពេញបរិបូណ៌ហើយ រមែងញុាំងនីវរណៈ ៥ ឲ្យពេញបរិបូណ៌ លុះនីវរណៈ ៥ ពេញបរិបូណ៌ហើយ រមែងញុាំងអវិជ្ជាឲ្យពេញបរិបូណ៌ លុះអវិជ្ជាពេញបរិបូណ៌ហើយ រមែងញុាំងភវតណ្ហា ឲ្យពេញបរិបូណ៌ ។ អាហារ របស់ភវតណ្ហានេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌ យ៉ាងនេះ ។

វិជ្ជាវិមុត្តិម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ វិជ្ជាវិមុត្តិយា ។ សត្ត ពោជ្ឈង្គាតិស្ស វចនីយំ ។ សត្តបហំ ភិក្ខវេ ពោជ្ឈង្គេ សាហារេ វទាមិ នោ អនាហារេ ។ កោ ចាហារោ សត្តន្នំ ពោជ្ឈង្គានំ ។ ចត្តារោ សតិប្បដ្ឋានាតិស្ស វចនីយំ ។ ចត្តារោបហំ ភិក្ខវេ សតិប្បដ្ឋានេ សាហារេ វទាមិ នោ អនាហារេ ។ កោ ចាហារោ ចតុន្នំ សតិប្បដ្ឋានានំ ។ តីណិ សុចរិតានីតិស្ស វចនីយំ ។ តីណិបហំ ភិក្ខវេ សុចរិតានិ សាហារានិ វទាមិ នោ អនាហារានិ ។ កោ ចាហារោ តិណ្ណំ សុចរិតានំ ។ ឥន្ទ្រិយសំវរោតិស្ស វចនីយំ ។ ឥន្ទ្រិយសំវរម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ ឥន្ទ្រិយសំវរស្ស ។ សតិសម្បជញ្ញន្តិស្ស វចនីយំ ។ សតិសម្បជញ្ញម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិជ្ជានិងវិមុត្តិ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់វិជ្ជានិងវិមុត្តិ ។ គប្បីឆ្លើយថា ពោជ្ឈង្គ ៧ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពោជ្ឈង្គ ៧ ប្រការ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ពោជ្ឈង្គ ៧ ប្រការ ។ គប្បីឆ្លើយថា សតិប្បដ្ឋាន ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិប្បដ្ឋាន ៤ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់សតិប្បដ្ឋាន ៤ ។ គប្បីឆ្លើយថា សុចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សុចរិត ៣ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់សុចរិត ៣ ។ គប្បីឆ្លើយថា ការសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសង្រួមឥន្ទ្រិយ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ របស់ការសង្រួមឥន្ទ្រិយ ។ គប្បីឆ្លើយថា សតិនិងសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិនិងសម្បជញ្ញៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។

កោ ចាហារោ សតិសម្បជញ្ញស្ស ។ យោនិសោ មនសិការោតិស្ស វចនីយំ ។ យោនិសោ មនសិការម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ យោនិសោ មនសិការស្ស ។ សទ្ធាតិស្ស វចនីយំ ។ សទ្ធម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ សទ្ធាយ ។ សទ្ធម្មស្សវនន្តិស្ស វចនីយំ ។ សទ្ធម្មស្សវនម្បហំ ភិក្ខវេ សាហារំ វទាមិ នោ អនាហារំ ។ កោ ចាហារោ សទ្ធម្មស្សវនស្ស ។ សប្បុរិសសំសេវោតិស្ស វចនីយំ ។ ឥតិ ខោ ភិក្ខវេ សប្បុរិសសំសេវោ បរិបូរោ សទ្ធម្មស្សវនំ បរិបូរេតិ សទ្ធម្មស្សវនំ បរិបូរំ សទ្ធំ បរិបូរេតិ សទ្ធា បរិបូរា យោនិសោ មនសិការំ បរិបូរេតិ យោនិសោ មនសិការោ បរិបូរោ សតិសម្បជញ្ញំ បរិបូរេតិ សតិសម្បជញ្ញំ បរិបូរំ ឥន្ទ្រិយសំវរំ បរិបូរេតិ

ចុះអ្វីជាអាហា របស់សតិនិងសម្បជញ្ញៈ ។ គប្បីឆ្លើយថា យោនិសោ-
មនសិការៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា យោនិសោ-
មនសិការៈ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។
ចុះអ្វីជាអាហារ របស់យោនិសោមនសិការៈ ។ គប្បីឆ្លើយថា សទ្ធា ។
ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធាប្រកបដោយអាហារ មិន
បានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធា ។ គប្បីឆ្លើយថា
សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធម្មស្សវនៈ
ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហារ
របស់សទ្ធម្មស្សវនៈ ។ គប្បីឆ្លើយថា សប្បុរិសសំសេវៈ ។ ម្នាលភិក្ខុទាំង-
ឡាយ សប្បុរិសសំសេវៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងសទ្ធម្មស្សវនៈ
ឲ្យពេញបរិបូណ៌ លុះសទ្ធម្មស្សវនៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំង
សទ្ធា ឲ្យពេញបរិបូណ៌ លុះសទ្ធាពេញបរិបូណ៌ហើយ រមែងញ៉ាំងយោនិ-
សោមនសិការៈ ឲ្យពេញបរិបូណ៌ លុះយោនិសោមនសិការៈពេញបរិបូណ៌
ហើយ រមែងញ៉ាំងសតិនិងសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះសតិនិងសម្ប-
ជញ្ញៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌

ឥន្ទ្រិយសំវរោ បរិបូរោ តីណិ សុចរិតានិ បរិបូរេតិ តីណិ សុចរិតានិ បរិបូរានិ ចត្តារោ សតិប្បដ្ឋានេ បរិបូរេន្តិ ចត្តារោ សតិប្បដ្ឋានា បរិបូរា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា បរិបូរា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។ ឯវមេតិស្សា វិជ្ជាវិមុត្តិយា អាហារោ ហោតិ ឯវញ្ច ចារិបូរិ ។ សេយ្យថាបិ ភិក្ខវេ ឧបរិបព្វតេ ថុល្លផុសិតកេ ទេវេ វស្សន្តេ ទេវេ គឡគឡាយន្តេ តំ ឧទកំ យថានិន្នំ បវត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតក-ន្ទរបទរសាខា បរិបូរា កុសុព្ភេ បរិបូរេន្តិ កុសុព្ភា បរិបូរា មហាកុសុព្ភេ បរិបូរេន្តិ មហាកុសុព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា មហាសមុទ្ទំ សាគរំ បរិបូរេន្តិ ឯវមេតស្ស មហា-សមុទ្ទស្ស សាគរស្ស អាហារោ ហោតិ ឯវញ្ច ចារិបូរិ

លុះការសង្រួមឥន្ទ្រិយ ពេញបរិបូណ៌ហើយ រមែងញុំាងសុចរិត ៣ ឲ្យពេញបរិបូណ៌ លុះសុចរិត ៣ ពេញបរិបូណ៌ហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌ លុះសតិប្បដ្ឋាន ៤ ពេញបរិបូណ៌ហើយ រមែងញុំាងពោជ្ឈង្គ ៧ ប្រការ ឲ្យពេញបរិបូណ៌ លុះពោជ្ឈង្គ ៧ ប្រការ ពេញបរិបូណ៌ហើយ រមែងញុំាងវិជ្ជានិងវិមុត្តិ ឲ្យពេញបរិបូណ៌ ដោយប្រការដូច្នេះឯង ។ អាហារ របស់វិជ្ជានិងវិមុត្តិនេះ រមែងមាន យ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកភ្លៀងមានតំណក់ដ៏ថ្លោស កាលបង្អុរ កាលរំលោ ហូរធ្លាក់លើកំពូលភ្នំ ទឹកនោះក៏ហូរទៅកាន់ទីទាប រមែងញុំាងជ្រោះភ្នំ ល្អាងនិងអូរតូចឲ្យពេញ លុះជ្រោះភ្នំ ល្អាងនិងអូរតូចពេញ រមែងញុំាងត្រពាំងតូច ឲ្យពេញ លុះត្រពាំងតូចពេញ រមែងញុំាងត្រពាំងធំ ឲ្យពេញ លុះត្រពាំងធំពេញ រមែងញុំាងស្ទឹងតូចឲ្យពេញ លុះស្ទឹងតូចពេញ រមែងញុំាងស្ទឹងធំ ឲ្យពេញ លុះស្ទឹងធំពេញហើយ រមែងញុំាងមហាសមុទ្រសាគរ ឲ្យពេញ អាហារ របស់មហាសមុទ្រសាគរនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះ

ឯវមេវ ខោ ភិក្ខវេ សប្បុរិសសំសេវោ បរិបូរោ សទ្ធម្មស្សវនំ បរិបូរេតិ សទ្ធម្មស្សវនំ បរិបូរំ សទ្ធំ បរិបូរេតិ សទ្ធា បរិបូរា យោនិសោ មនសិ-ការំ បរិបូរេតិ យោនិសោ មនសិការោ បរិបូរោ សតិសម្បជញ្ញំ បរិបូរេតិ សតិសម្បជញ្ញំ បរិបូរំ ឥន្ទ្រិយសំវរំ បរិបូរេតិ ឥន្ទ្រិយសំវរោ បរិបូរោ តីណិ សុចរិតានិ បរិបូរេតិ តីណិ សុចរិតានិ បរិបូរានិ ចត្តារោ សតិប្បដ្ឋានេ បរិបូរេន្តិ ចត្តារោ សតិប្បដ្ឋានា បរិបូរា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា បរិបូរា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។ ឯវមេតិស្សា វិជ្ជាវិមុត្តិយា អាហារោ ហោតិ ឯវញ្ច បារិបូរីតិ ។

[៦៣] យេ កេចិ ភិក្ខវេ មយិ និដ្ឋង្គតា សព្វេ តេ ទិដ្ឋិសម្បន្នា ។

ម្នាលភិក្ខុទាំងឡាយ ឧបមេយ្យដូចជា សប្បុរិសសំសេវៈ ពេញបរិបូណ៌ហើយ រមែងញ៉ាំងសទ្ធម្មស្សវនៈ ឲ្យពេញបរិបូណ៌ លុះសទ្ធម្មស្សវនៈពេញបរិបូណ៌ រមែងញ៉ាំងសទ្ធាឲ្យពេញបរិបូណ៌ លុះសទ្ធាពេញបរិបូណ៌ រមែងញ៉ាំងយោនិសោមនសិការៈឲ្យពេញបរិបូណ៌ លុះយោ-និសោមនសិការៈពេញបរិបូណ៌ហើយ រមែងញ៉ាំងសតិសម្បជញ្ញៈឲ្យពេញបរិបូណ៌ លុះសតិនិងសម្បជញ្ញៈពេញបរិបូណ៌ រមែងញ៉ាំងការសង្រួមឥន្ទ្រិយឲ្យពេញបរិបូណ៌ លុះការសង្រួមឥន្ទ្រិយពេញបរិបូណ៌ រមែងញ៉ាំងសុចរិត ៣ ឲ្យពេញបរិបូណ៌ លុះសុចរិត ៣ ពេញបរិបូណ៌ រមែងញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌ លុះសតិប្បដ្ឋាន ៤ ពេញបរិបូណ៌ រមែងញ៉ាំងពោជ្ឈង្គ ៧ ប្រការ ឲ្យពេញបរិបូណ៌ លុះពោជ្ឈង្គ ៧ ប្រការពេញបរិបូណ៌ រមែងញ៉ាំងវិជ្ជានិងវិមុត្តិ ឲ្យពេញបរិបូណ៌ ។ អាហាររបស់វិជ្ជានិងវិមុត្តិនេះ រមែងមានយ៉ាងនេះ ពេញបរិបូណ៌យ៉ាងនេះឯង ។

[៦៣] ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណានីមួយ ដល់នូវការចូលចិត្តចំពោះតថាគត បុគ្គលទាំងអស់នោះជាអ្នកបរិបូណ៌ដោយទិដ្ឋិ ។

តេសំ និជ្ជិសម្បន្នានំ បញ្ចន្នំ ឥធ និដ្ឋា បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ កាតមេសំ បញ្ចន្នំ ឥធ និដ្ឋា ។ សត្តក្ខត្តុំបរមស្ស[១] កោលំកោលស្ស ឯកពីជិស្ស សកទាគាមិស្ស យោ ច ទិដ្ឋេវ ធម្មេ អរហា ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ។ កាតមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ អន្តរាបរិនិព្វាយិស្ស ឧបហច្ចបរិនិព្វាយិស្ស អសង្ខារ-បរិនិព្វាយិស្ស សសង្ខារបរិនិព្វាយិស្ស ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ យេ កេចិ ភិក្ខវេ មយិ និដ្ឋង្គតា សព្វេ តេ ទិដ្ឋិសម្បន្នា ។

---

១ ឱ. សត្តក្ខត្តុបរមស្ស ។

បណ្តាអ្នកបរិបូណ៌ដោយទិដ្ឋិនោះ បុគ្គល ៥ ពួកសម្រេច (បរិនិព្វាន) ក្នុងលោកនេះ បុគ្គល ៥ ពួកលះលោកនេះហើយ ទើបសម្រេច ។ បុគ្គល ៥ ពួកដែលសម្រេចក្នុងលោកនេះ តើដូចម្តេច ។ គឺសត្តក្ខត្តុំបរមបុគ្គល ១ កោលំកោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ ព្រះអរហន្តក្នុងបច្ចុប្បន្ន ១ បុគ្គល ៥ ពួកនេះ មានការសម្រេចក្នុងលោកនេះ ។ បុគ្គល ៥ ពួកដែលលះលោកនេះ ហើយសម្រេច តើដូចម្តេច ។ គឺ [១]អន្តរាបរិនិព្វាយិបុគ្គល ១ [២]ឧបហច្ចបរិនិព្វាយិបុគ្គល ១ [៣]អសង្ខារបរិនិព្វាយិបុគ្គល ១ [៤]សសង្ខារបរិនិព្វាយិបុគ្គល ១ [៥]ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណានីមួយ ដល់នូវការចូលចិត្តចំពោះតថាគត ពួកបុគ្គលទាំងអស់នោះ ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ។

---

១ គឺលោកបរិនិព្វាន ក្នុងរវាងអាយុមិនទាន់ដល់ពាក់កណ្តាល ។

២ លោកបរិនិព្វាន ក្នុងកាលអាយុផុតពាក់កណ្តាលហើយ ទើបដល់ទីបំផុត ។

៣ លោកបរិនិព្វាន ដោយមិនមានសេចក្តីព្យាយាមយ៉ាងខ្លាំង ។

៤ លោកបរិនិព្វាន ដោយសេចក្តីព្យាយាមខ្លាំង ។

៥ លោកមានខ្សែក្នុងខាងលើទៅកាន់អកនិដ្ឋភព ។

តេសំ និដ្ឋិសម្បន្នានំ ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋាតិ ។

[៦៤] យេ កេចិ ភិក្ខវេ មយិ អវេច្ចប្បសន្នា សព្វេ តេ សោតាបន្នា ។ តេសំ សោតាបន្នានំ បញ្ចន្នំ ឥធ និដ្ឋា បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ កតមេសំ បញ្ចន្នំ ឥធ និដ្ឋា ។ សត្តក្ខត្តុំបរមស្ស កោលំកោលស្ស ឯកពីជិស្ស សកទាគាមិស្ស យោ ច ទិដ្ឋេវ ធម្មេ អរហា ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ។ កតមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ អន្តរាបរិនិព្វាយិស្ស ឧបហច្ចបរិនិព្វាយិស្ស អសង្ខារបរិនិព្វាយិស្ស សសង្ខារបរិនិព្វាយិស្ស ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ យេ កេចិ ភិក្ខវេ មយិ អវេច្ចប្បសន្នា សព្វេ តេ សោតាបន្នា ។

បណ្ដាអ្នកបរិបូណ៌ដោយទិដ្ឋិនោះ បុគ្គល ៥ ពួកនេះ សម្រេចក្នុងលោកនេះ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។

[៦៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណានីមួយ ជ្រះថ្លាមិនញាប់ញ័រ ចំពោះតថាគត ពួកបុគ្គលទាំងអស់នោះ ជាសោតាបន្ន ជាអ្នកដល់នូវដើមខ្សែនៃអរិយមគ្គ ។ បណ្ដាសោតាបន្នបុគ្គលទាំងនោះ បុគ្គល ៥ ពួកសម្រេចក្នុងលោកនេះ បុគ្គល ៥ ពួកលះលោកនេះទើបសម្រេច ។ បុគ្គល ៥ ពួកដែលសម្រេច ក្នុងលោកនេះ តើដូចម្ដេច ។ គឺសត្តក្ខត្តុំបរមបុគ្គល ១ កោលំកោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ ព្រះអរហន្តក្នុងបច្ចុប្បន្ន ១ បុគ្គល ៥ ពួកនេះមានការសម្រេចក្នុងលោកនេះ ។ បុគ្គល ៥ ពួកដែលលះលោកនេះហើយ ទើបសម្រេចតើដូចម្ដេច ។ គឺអន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយណានីមួយ ជ្រះថ្លាមិនញាប់ញ័រ ចំពោះតថាគត ពួកបុគ្គលទាំងអស់នោះ ជាសោតាបន្ន ( អ្នកដល់នូវដើមខ្សែនៃអរិយមគ្គ ) ។

តេសំ សោតាបន្នានំ ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋាតិ ។

[៦៥] ឯកំ សមយំ អាយស្មា សារីបុត្តោ មគធេសុ វិហរតិ នាលកគាមកេ ។ អថខោ សាមណ្ឌកានិ បរិព្វាជកោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សាមណ្ឌកានិ បរិព្វាជកោ អាយស្មន្តំ សារី-បុត្តំ ឯតទវោច កិន្នុ ខោ អាវុសោ សារីបុត្ត សុខំ កឹ ទុក្ខន្តិ ។ អភិនិព្វត្តិ ខោ អាវុសោ ទុក្ខា អនភិនិព្វត្តិ សុខា ។ អភិនិព្វត្តិយា អាវុសោ សតិ ឥទំ ទុក្ខំ បាដិកង្ខំ សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ អគ្គិសម្ផស្សោ ទណ្ឌសម្ផស្សោ សត្ថសម្ផស្សោ ញាតីបិ នំ មិត្តាបិ សំគម្ម សមាគម្ម រោសេន្តិ ។

បណ្ដាសោតាបន្នបុគ្គលទាំងនោះ បុគ្គល ៥ ពួកនេះ សម្រេចក្នុងលោកនេះ បុគ្គល ៥ ពួកនេះ លះលោកនេះហើយ ទើបសម្រេច ។

[៦៥] សម័យមួយ ព្រះសារីបុត្ត ដ៏មានអាយុ គង់នៅនាលកគ្រាម ក្នុងដែនមគធៈ ។ គ្រានោះ បរិព្វាជកឈ្មោះសាមណ្ឌកានិ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានពោលពាក្យរាក់ទាក់ជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបរិព្វាជកឈ្មោះសាមណ្ឌកានិ អង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ ឈ្មោះថា សុខ អ្វីឈ្មោះថា ទុក្ខ ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ការកើតឡើងហ្នឹងឯងឈ្មោះថា ទុក្ខ ការមិនកើតឡើង ឈ្មោះថា សុខ ។ ម្នាលអាវុសោ កាលបើមានការកើតឡើង សេចក្ដីទុក្ខនេះ រមែងប្រាកដ គឺការត្រជាក់ ក្ដៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ ប៉ះត្រូវនឹងភ្លើង ប៉ះត្រូវនឹងដំបង ប៉ះត្រូវនឹងគ្រឿងសស្ត្រាវុធ ញាតិទាំងឡាយក្ដី មិត្រទាំងឡាយក្ដី រមែងចួបជុំប្រសព្វគ្នា បៀតបៀនបុគ្គលនោះ ។

អភិនិព្វត្តិយា អាវុសោ សតិ ឥទំ ទុក្ខំ ចាជិកាង្ខំ ។ អនភិនិព្វត្តិយា អាវុសោ សតិ ឥទំ សុខំ ចាជិកាង្ខំ ន សីតំ ន ឧណ្ហំ ន ជិឃច្ឆា ន បិចាសា ន ឧច្ចារោ ន បស្សាវោ ន អគ្គិសម្ផស្សោ ន ទណ្ឌសម្ផស្សោ ន សត្ថសម្ផស្សោ ញាតីបិ នំ មិត្តាបិ សំគម្ម សមាគម្ម ន រោសេន្តិ ។ អនភិនិព្វត្តិយា អាវុសោ សតិ ឥទំ សុខំ ចាជិកាង្ខន្តិ ។

[៦៦] ឯកំ សមយំ អាយស្មា សារីបុត្តោ មគធេសុ វិហរតិ នាលកគ្គាមកេ ។ អថខោ សាមណ្ឌកានិ បរិព្វាជកោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សាមណ្ឌកានិ បរិព្វាជកោ អាយស្មន្តំ សារី-បុត្តំ ឯតទវោច កិន្នុ ខោ អាវុសោ សារីបុត្ត ឥមស្មឹ ធម្មវិនយេ សុខំ កឹ ទុក្ខន្តិ ។

ម្នាលអាវុសោ កាលបើមានការកើតឡើង សេចក្តីទុក្ខនេះ រមែងប្រាកដ ។ ម្នាលអាវុសោ កាលបើមិនមានការកើតឡើង សេចក្តីសុខនេះ រមែងប្រាកដ គឺការមិនមានត្រជាក់ មិនមានក្តៅ មិនមានឃ្លាន មិនមានស្រេក មិនមានឧច្ចារៈ មិនមានបស្សាវៈ មិនមានប៉ះត្រូវនឹងភ្លើង មិនមានប៉ះត្រូវនឹងដំបង មិនមានប៉ះត្រូវនឹងគ្រឿងសស្ត្រាវុធ ឬញាតិទាំងឡាយក្តី មិត្រទាំងឡាយក្តី មិនជួបជុំប្រសព្វគ្នា បៀតបៀនបុគ្គលនោះ ។ ម្នាលអាវុសោ កាលបើ មិនមានការកើតឡើង សេចក្តីសុខនេះ រមែងប្រាកដ ។

[៦៦] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ នៅក្នុងនាលកគ្រាម ក្នុងដែនមគធៈ ។ គ្រានោះ បរិព្វាជកឈ្មោះសាមណ្ឌកានិ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបរិព្វាជក ឈ្មោះសាមណ្ឌកានិ អង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្ត ដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត អ្វីហ្ន៎ ឈ្មោះថា សុខ អ្វីឈ្មោះថា ទុក្ខ ក្នុងធម្មវិន័យនេះ ។

អនភិរតិ ខោ អាវុសោ ឥមស្មឹ ធម្មវិនយេ ទុក្ខា អភិរតិ សុខា ។ អនភិរតិយា អាវុសោ សតិ ឥទំ ទុក្ខំ បាដិកង្ខំ គច្ឆន្តោបិ សុខំ សាតំ នាធិគច្ឆតិ ឋិតោបិ... និសិន្នោបិ... សយានោបិ... គាមគតោបិ... អរញ្ញគតោបិ... រុក្ខមូលគតោបិ... សុញ្ញាគារគតោបិ... អព្ភោកាសគតោបិ... ភិក្ខុមជ្ឈគតោបិ សុខំ សាតំ នាធិគច្ឆតិ ។ អនភិរតិយា អាវុសោ សតិ ឥទំ ទុក្ខំ បាដិកង្ខំ ។ អភិរតិយា អាវុសោ សតិ ឥទំ សុខំ បាដិកង្ខំ គច្ឆន្តោបិ សុខំ សាតំ អធិគច្ឆតិ ឋិតោបិ... និសិន្នោបិ... សយានោបិ... គាមគតោបិ... អរញ្ញគតោបិ... រុក្ខមូលគតោបិ... សុញ្ញាគារគតោបិ... អព្ភោកាសគតោបិ... ភិក្ខុមជ្ឈគតោបិ សុខំ សាតំ អធិគច្ឆតិ ។ អភិរតិយា អាវុសោ សតិ ឥទំ សុខំ បាដិកង្ខន្តិ ។

ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ សេចក្តីមិនត្រេកអរនេះឯង ឈ្មោះថា ទុក្ខ សេចក្តីត្រេកអរ ឈ្មោះថា សុខ ក្នុងធម្មវិន័យនេះ ។ ម្នាលអាវុសោ កាលបើមិនមានសេចក្តីត្រេកអរ សេចក្តីទុក្ខនេះ រមែងប្រាកដ គឺបុគ្គលកាលដើរទៅក្តី រមែងមិនបានសេចក្តីសុខជាទីត្រេកអរ ឈរនៅក្តី... អង្គុយនៅក្តី... ដេកនៅក្តី... នៅក្នុងស្រុកក្តី... នៅក្នុងព្រៃក្តី... នៅជិតគល់ឈើក្តី... នៅក្នុងផ្ទះស្ងាត់ក្តី... នៅក្នុងទីវាលក្តី... នៅក្នុងកណ្តាលភិក្ខុក្តី ក៏រមែងមិនបានសេចក្តីសុខ ជាទីត្រេកអរឡើយ ។ ម្នាលអាវុសោ កាលបើមិនមានសេចក្តីត្រេកអរ សេចក្តីទុក្ខនេះ រមែងប្រាកដ ។ ម្នាលអាវុសោ កាលបើមានសេចក្តីត្រេកអរ សេចក្តីសុខនេះ រមែងប្រាកដ គឺបុគ្គលកាលដើរទៅ ក៏បានប្រសព្វសេចក្តីសុខ ជាទីត្រេកអរ ឈរក្តី... អង្គុយក្តី... ដេកក្តី... នៅក្នុងស្រុកក្តី... នៅក្នុងព្រៃក្តី... នៅជិតគល់ឈើក្តី... នៅក្នុងផ្ទះស្ងាត់ក្តី... នៅទីវាលក្តី... នៅកណ្តាលភិក្ខុក្តី... រមែងបានប្រសព្វសេចក្តីសុខ ជាទីត្រេកអរ ។ ម្នាលអាវុសោ កាលបើមានសេចក្តីត្រេកអរ សេចក្តីសុខនេះ រមែងប្រាកដ ។

[៦៧] ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន នឡកបានំ នាម កោសលានំ និគមោ តទ-វសរិ ។ តត្រ សុទំ ភគវា នឡកបានេ វិហរតិ បលាសវនេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ ភិក្ខុសង្ឃបរិវុតោ និសិន្នោ ហោតិ ។ អថខោ ភគវា ពហុទេវ រត្តឹ ភិក្ខូ(១) ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ វិគតថីនមិទ្ធោ ខោ សារីបុត្ត ភិក្ខុសង្ឃោ បដិ-ភាតុ តំ សារីបុត្ត ភិក្ខូនំ ធម្មីកថា បិដ្ឋិ មេ អាគិលាយតិ តមហំ អាយមិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សារីបុត្តោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ

---
១ ម. ភិក្ខូនំ ។

[៦៧] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងកោសលជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ស្តេចឆ្ពោះទៅកាន់និគមឈ្មោះនឡកបានៈ របស់អ្នកដែលកោសល ។ ក្នុងទីនោះ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងព្រៃចារ ទៀបស្រុកឈ្មោះនឡកបានៈ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ មានភិក្ខុ-សង្ឃចោមរោមហើយ ទ្រង់គង់ក្នុងឧបោសថថ្ងៃនោះ ។ គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហ៊ានឲ្យរីករាយ ដោយធម្មីកថា អស់វេលាយប់ជ្រៅ ទ្រង់រមិលមើលភិក្ខុសង្ឃ ដែលអង្គុយនៅស្ងប់ស្ងៀម ហើយក៏ត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកថីនមិទ្ធៈហើយម្នាលសារីបុត្ត លោកចូរបំភ្លឺធម្មីកថា ដល់ភិក្ខុទាំងឡាយចុះ តថាគតរួយខ្នង តថាគតនឹងសម្រាកខ្នងបន្តិច ។ ព្រះសារីបុត្តដ៏មានអាយុទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។លុះដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យក្រាលសង្ឃាដីមានជាន់ ៤ ហើយ សម្រេចនូវសីហសេយ្យាស ផ្ទៀងទៅខាងស្តាំ

ចាគេ ចាគំ អច្ចាជាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច យស្ស កស្សចិ អាវុសោ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វិរិយំ នត្ថិ... បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ចារិហានិយេវ[១] ចាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ អាវុសោ កាឡបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហាយ-តេវ វណ្ណេន ហាយតិ មណ្ឌលេន ហាយតិ អាភាយ ហាយតិ អារោហបរិណាហេន ឯវមេវ ខោ អាវុសោ យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វិរិយំ នត្ថិ...

១ ឱ. ម. ហានិយេវ ។

តម្រួតព្រះបាទលើព្រះបាទ មានព្រះសតិនិងសម្បជញ្ញៈ ធ្វើមនសិការៈនូវឧដ្ឋានសញ្ញា ។ ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងអម្បាលនោះ ទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ សម្តែងដូច្នេះថា ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិ មិនមាន... ឱត្តប្បៈ មិនមាន... វីរិយៈ មិនមាន... បញ្ញាក្នុងកុសលធម៌ទាំងឡាយមិនមាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីចម្រើន មិនប្រាកដឡើយ ។ ម្នាលអាវុសោ ដូចជាយប់និងថ្ងៃ របស់ព្រះចន្ទ ក្នុងកាឡបក្ខ មកដល់ ព្រះចន្ទនោះ រមែងបាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាកពន្លឺ បាត់ចាកកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ហិរិ មិនមាន ... ឱត្តប្បៈ មិនមាន ... វីរិយៈមិនមាន ...

២៦៩

ទុតិយបណ្ណាសកេ យមកវគ្គោ

បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ បារិហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ អស្សទ្ធោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ អហិរិកោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ អនោត្តប្បី បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ កុសីតោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ ទុប្បញ្ញោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ កោធនោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ ឧបនាហី បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ បាបិច្ឆោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ បាបមិត្តោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ

បញ្ញាក្នុងកុសលធម៌ទាំងឡាយ មិនមាន យប់និងថ្ងៃ របស់បុគ្គលនោះ មកដល់ សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីចម្រើន មិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ ទាំងឡាយ ពាក្យថា បុរសបុគ្គលមិនមានសទ្ធា នេះ ជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលមិនមានហិរិ នេះ ជាសេចក្តី សាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលមិនមាន ឱត្តប្បៈ នេះ ជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកខ្ជិលច្រអូស នេះ ជាសេចក្តីសាបសូន្យ ម្នាល អាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល អប្បឥតបញ្ញា នេះ ជា សេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកក្រោធ នេះ ជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកចងសេចក្តីក្រោធទុក នេះ ជាសេចក្តី សាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គលជា អ្នកប្រាថ្នាអាក្រក់ នេះ ជាសេចក្តីសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានមិត្តអាក្រក់ នេះ ជាសេចក្តីសាបសូន្យ

មិច្ឆាទិដ្ឋិកោ បុរិសបុគ្គលោតិ អាវុសោ បរិហានមេតំ ។ យស្ស កស្សចិ អាវុសោ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ អាវុសោ ជុណ្ហាបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ អារោហបរិណាហេន ឯវមេវ ខោ អាវុសោ យស្ស កស្សចិ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សទ្ធោ បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានសេចក្តីឃើញខុស នេះ ជាសេចក្តីសាបសូន្យ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណាទីមួយ មាន ហិរិ មាន . . . ឱត្តប្បៈ មាន . . . វីរិយៈ មាន . . . បញ្ញាក្នុងកុសលធម៌ទាំងឡាយមាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីសាបសូន្យរមែងមិនប្រាកដឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាយប់និងថ្ងៃរបស់ព្រះចន្ទ ក្នុងជុណ្ហបក្ខ មកដល់ ព្រះចន្ទនោះ រមែងចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំង-ឡាយ របស់បុគ្គលណាទីមួយ មាន ហិរិ មាន . . . ឱត្តប្បៈ មាន . . . វីរិយៈ មាន . . . បញ្ញាក្នុងកុសលធម៌ទាំងឡាយ មាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីសាបសូន្យ មិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំង-ឡាយ ពាក្យថា បុរសបុគ្គលអ្នកមានសទ្ធា នេះ ជាសេចក្តីមិនសាបសូន្យ

២៧១

ទុតិយបណ្ណាសកេ យមកវគ្គោ

ហិរិមា បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

ឱត្តប្បី បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

អារទ្ធវីរិយោ បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

បញ្ញវា បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

អក្កោធនោ បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

អនុបនាហី បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

អប្បិច្ឆោ បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

កល្យាណមិត្តោ បុរិសបុគ្គលោតិ អាវុសោ អបរិហានមេតំ

សម្មាទិដ្ឋិកោ បុរិសបុគ្គលោតិ អាវុសោ អបរិហាន-

មេតន្តិ ។ អថខោ ភគវា បច្ចុដ្ឋាយ អាយស្មន្តំ

សារីបុត្តំ អាមន្តេសិ សាធុ សាធុ សារីបុត្ត

ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានហិរិ នេះ ជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានឱត្តប្បៈ នេះ ជាសេចក្តីមិនសាបសូន្យ ម្នាល អាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានវីរិយៈប្រារព្ធហើយ នេះ ជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានបញ្ញា នេះ ជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោ ទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមិនមានសេចក្តីក្រោធ នេះ ជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរស-បុគ្គល ជាអ្នកមិនចងសេចក្តីក្រោធទុក នេះ ជាសេចក្តីមិនសាបសូន្យ ម្នាល អាវុសោទាំងឡាយ ពាក្យថា បុរសបុគ្គល ជាអ្នកមានសេចក្តីប្រាថ្នាតិច នេះ ជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោទាំងឡាយ ពាក្យថា បុរស-បុគ្គលជាអ្នកមានកល្យាណមិត្ត នេះ ជាសេចក្តីមិនសាបសូន្យ ម្នាលអាវុសោ ទាំងឡាយ ពាក្យថា បុរសបុគ្គលអ្នកមានការយល់ឃើញត្រូវ នេះ ជា សេចក្តីមិនសាបសូន្យ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់តើន ឡើង ត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ប្រពៃហើយ ៗ សារីបុត្ត

យស្ស កស្សចិ សារីបុត្ត សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ… ឱត្តប្បំ នត្ថិ… វីរិយំ នត្ថិ… បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ សារីបុត្ត កាឡបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហាយតេវ វណ្ណេន ហាយតិ មណ្ឌ-លេន ហាយតិ អាភាយ ហាយតិ អារោហបរិ-ណាហេន ឯវមេវ ខោ សារីបុត្ត យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ។ បេ ។ បញ្ញា នត្ថិ កុសលេសុ ធម្មេសុ ។ បេ ។ អស្សទ្ធោ បុរិសបុគ្គលោតិ សារីបុត្ត បរិហានមេតំ អហិរិកោ… អនោត្តប្បី… កុសីតោ… ទុប្បញ្ញោ… កោធនោ… ឧបនាហី… បាបិច្ឆោ… បាបមិត្តោ… មិច្ឆាទិដ្ឋិកោ បុរិសបុគ្គលោតិ សារីបុត្ត បរិហានមេតំ ។

ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយ មិនមាន ហិរិមិនមាន ... ឱត្តប្បៈ មិនមាន ... វិរិយៈ មិនមាន ... បញ្ញាក្នុងកុសលធម៌ទាំងឡាយ មិនមាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីចម្រើនមិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជាយប់និងថ្ងៃ របស់ព្រះចន្ទ ក្នុងកាឡបក្ខ មកដល់ ព្រះចន្ទនោះក៏បាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាកពន្លឺ បាត់ចាកកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមិនមាន ។ បេ ។ បញ្ញាក្នុងកុសលធម៌ទាំងឡាយមិនមាន ។ បេ ។ ក៏យ៉ាងនោះដែរ ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលមិនមានសទ្ធា នេះ ជាសេចក្តីសាបសូន្យ ជាអ្នកមិនមានហិរិ ... ជាអ្នកមិនមានឱត្តប្បៈ ... ជាអ្នកខ្ជិលច្រអូស ... ជាអ្នកអប្បឥតប្រាជ្ញា ... ជាអ្នកក្រោធ ... ជាអ្នកចងសេចក្តីក្រោធទុក ... ជាអ្នកមានសេចក្តីប្រាថ្នាអាក្រក់ ... ជាអ្នកមានមិត្តអាក្រក់ ... ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គល អ្នកមានការយល់ឃើញខុស នេះ ជាសេចក្តីសាបសូន្យ ។

២៧៣



យស្ស កស្សចិ សារីបុត្ត សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ សារីបុត្ត ជុណ្ហបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ អារោហបរិណាហេន ឯវមេវ ខោ សារីបុត្ត យស្ស កស្សចិ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សទ្ធោ បុរិសបុគ្គលោតិ សារីបុត្ត អបរិហានមេតំ ហិរិមា... ឱត្តប្បី... អារទ្ធវីរិយោ... បញ្ញវា ... អក្កោធនោ ... អនុបនាហី ... អប្បិច្ឆោ ...

ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណាមាន ហិរិ មាន . . . ឱត្តប្បៈ មាន . . . វីរិយៈ មាន . . . បញ្ញាក្នុងកុសលធម៌ទាំងឡាយ មាន យប់និងថ្ងៃរបស់បុគ្គលនោះមកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យ មិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជាយប់និងថ្ងៃណា របស់ព្រះចន្ទ ក្នុងជុណ្ហបក្ខ មកដល់ ព្រះចន្ទនោះ ចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមាន ហិរិ មាន... ឱត្តប្បៈ មាន . . . វីរិយៈ មាន . . . បញ្ញា ក្នុងកុសលធម៌ទាំងឡាយ មាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ តែងប្រាកដ សេចក្តីសាបសូន្យ មិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលជាអ្នកមានសទ្ធា នេះ ជាសេចក្តីមិនសាបសូន្យ ជាអ្នកមានហិរិ . . . ជាអ្នកមានឱត្តប្បៈ . . . ជាអ្នកមានវីរិយៈ ប្រារព្ធហើយ . . . ជាអ្នកមានបញ្ញា . . . ជាអ្នកមិនមានសេចក្តីក្រោធ . . . ជាអ្នកមិនចងសេចក្តីក្រោធទុក . . . ជាអ្នកប្រាថ្នាតិច . . .

កល្យាណមិត្តោ... សម្មាទិដ្ឋិកោ បុរិសបុគ្គលោតិ សារីបុត្ត អបរិហានមេតន្តិ ។

[៦៨] ឯកំ សមយំ ភគវា ឥច្ឆានង្គលេ វិហរតិ បលាសវនេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ ភិក្ខុសង្ឃបរិវុតោ និសិន្នោ ហោតិ ។ អថខោ ភគវា ពហុទេវ រត្តឹ ភិក្ខូ[១] ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ វិគតថីនមិទ្ធោ ខោ សារីបុត្ត ភិក្ខុសង្ឃោ បដិភាតុ តំ សារីបុត្ត ភិក្ខូនំ ធម្មីកថា បិដ្ឋិ មេ អាគិ-លាយតិ តមហំ អាយមិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សារីបុត្តោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិការិត្វា ។

១ ម. ភិក្ខូនំ ។

ជាអ្នកមានមិត្តល្អ . . . ម្នាលសារីបុត្ត ពាក្យថា បុរសបុគ្គលជាអ្នកមានសេចក្តីយល់ឃើញត្រូវ នេះ ជាសេចក្តីមិនសាបសូន្យទេ ។

[៦៨] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងព្រៃចារទៀបនិគមឈ្មោះនឡកបានៈ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគមានភិក្ខុសង្ឃចោមរោម គង់នៅក្នុងឧបោសថថ្ងៃនោះ ។ គ្រានោះព្រះដ៏មានព្រះភាគ ពន្យល់ពួកភិក្ខុឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីក-រាយ ដោយធម្មីកថា អស់វេលាយប់ជ្រៅ ទ្រង់រមិលមើលភិក្ខុសង្ឃដែលអង្គុយនៅស្ងប់ស្ងៀម ហើយត្រាស់នឹងព្រះសារីបុត្ត ដ៏មានអាយុថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកថីនមិទ្ធៈហើយ ម្នាលសារីបុត្តលោកចូរបំភ្លឺធម្មីកថា ដល់ភិក្ខុទាំងឡាយចុះ តថាគតរួយខ្នង តថាគតនឹងសម្រាកខ្នងបន្តិច ។ ព្រះសារីបុត្តដ៏មានអាយុ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យក្រាលសង្ឃាដីមានជាន់ ៤ ហើយ ទ្រង់សម្រេចនូវសីហសេយ្យាស ផ្អៀងទៅខាងស្តាំ តម្រួតព្រះបាទ លើព្រះបាទ មានព្រះសតិនិងសម្បជញ្ញៈ ធ្វើមនសិការៈនូវឧដ្ឋានសញ្ញា ។

២៧៤



តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច យស្ស កស្សចិ អាវុសោ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វិរិយំ នត្ថិ... បញ្ញា នត្ថិ... សោតាវធានំ នត្ថិ... ធម្មធារណា នត្ថិ... អត្ថុបបរិក្ខា នត្ថិ... ធម្មានុធម្មប្បដិបត្តិ នត្ថិ... អប្បមាទោ នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ អាវុសោ កាឡបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហាយតេវ វណ្ណេន ហាយតិ មណ្ឌលេន ហាយតិ អាភាយ ហាយតិ អារោហបរិណាហេន ឯវមេវ ខោ អាវុសោ យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ ...

ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលស្តាប់ពាក្យព្រះសារី-បុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយរបស់បុគ្គលណានីមួយ មិនមាន ហិរិ មិនមាន . . . ឱត្តប្បៈ មិនមាន . . . វីរិយៈ មិនមាន . . . បញ្ញា មិនមាន . . . ការផ្ចង់ដើម្បីស្តាប់ មិនមាន . . . ការទ្រទ្រង់ធម៌ មិនមាន . . . ការពិចារណាអត្ថ មិនមាន . . . ការប្រតិបត្តិធម៌សមគួរតាមធម៌ មិនមាន . . . សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ មិនមាន យប់និងថ្ងៃ របស់បុគ្គលនោះមកដល់ សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដសេចក្តីចម្រើនមិនប្រាកដឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាយប់និងថ្ងៃ របស់ព្រះចន្ទក្នុងកាឡបក្ខ មកដល់ ព្រះចន្ទនោះ រមែងបាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាករស្មី បាត់ចាកកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយ មិនមាន ហិរិ មិនមាន . . .

ឱត្តប្បំ នត្ថិ... វីរិយំ នត្ថិ... បញ្ញា នត្ថិ... សោតាវធានំ នត្ថិ... ធម្មធារណា នត្ថិ... អត្ថុបបរិក្ខា នត្ថិ... ធម្មានុធម្មប្បដិបត្តិ នត្ថិ... អប្បមាទោ នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ យស្ស កស្សចិ អាវុសោ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ... សោតាវធានំ អត្ថិ... ធម្មធារណា អត្ថិ... អត្ថុបបរិក្ខា អត្ថិ... ធម្មានុធម្មប្បដិបត្តិ អត្ថិ... អប្បមាទោ អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ អាវុសោ ជុណ្ហបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ

ឱត្តប្បៈ មិនមាន ... វីរិយៈ មិនមាន ... បញ្ញា មិនមាន ... ការផ្ទង់ដើម្បីស្តាប់ មិនមាន ... ការទ្រទ្រង់ធម៌ មិនមាន ... ការពិចារណាអត្ថ មិនមាន ... ការប្រតិបត្តិធម៌សមគួរតាមធម៌ មិនមាន ... សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មិនមាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ ប្រាកដសេចក្តីចម្រើន រមែងមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយ មាន ហិរិ មាន ... ឱត្តប្បៈ មាន ... វីរិយៈ មាន ... បញ្ញា មាន ... ការផ្ទង់ដើម្បីស្តាប់ មាន ... ការទ្រទ្រង់ធម៌ មាន ... ការពិចារណាអត្ថ មាន ... ការប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ មាន ... សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដសេចក្តីសាបសូន្យ រមែងមិនប្រាកដឡើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាយប់និងថ្ងៃ របស់ព្រះចន្ទ ក្នុងជុណ្ហបក្ខ មកដល់ ព្រះចន្ទនោះ ចម្រើនដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ

២៧៧



អាពោហាបរិណាហេន ឯវមេវ ខោ អាវុសោ យស្ស កស្សចិ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វិរិយំ អត្ថិ... បញ្ញា អត្ថិ... សោតាវធានំ អត្ថិ... ធម្មធារណា អត្ថិ... អត្ថុបបរិក្ខា អត្ថិ... ធម្មានុធម្មប្បដិបត្តិ អត្ថិ... អប្បមាទោ អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។ អថខោ ភគវា បច្ចុដ្ឋាយ អាយស្មន្តំ សារីបុត្តំ អាមន្តេសិ សាធុ សាធុ សារីបុត្ត យស្ស កស្សចិ សារីបុត្ត សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វិរិយំ នត្ថិ... បញ្ញា នត្ថិ... សោតាវធានំ នត្ថិ... ធម្មធារណា នត្ថិ... អត្ថុបបរិក្ខា នត្ថិ... ធម្មានុធម្មប្បដិបត្តិ នត្ថិ ... អប្បមាទោ នត្ថិ

ចម្រើនដោយកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយ មាន ហិរិ មាន ... ឱត្តប្បៈ មាន ... វិរិយៈ មាន ... បញ្ញា មាន ... ការផ្ទង់ដើម្បីស្តាប់ មាន ... ការទ្រទ្រង់ធម៌ មាន ... ការពិចារណាអត្ថ មាន ... ការប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ មាន ... សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យ រមែងមិនប្រាកដឡើយ ។ លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់តើនចាកអាសនៈហើយ បានត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ប្រពៃណាស់ហើយសារីបុត្ត ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយ មិនមាន ហិរិ មិនមាន ... ឱត្តប្បៈ មិនមាន ... វិរិយៈ មិនមាន ... បញ្ញា មិនមាន ... ការផ្ទង់ដើម្បីស្តាប់ មិនមាន ... ការទ្រទ្រង់ធម៌ មិនមាន ... ការពិចារណាអត្ថ មិនមាន ... ការប្រតិបត្តិធម៌ តាមសមគួរដល់ធម៌មិនមាន ... សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មិនមាន

កុសលេសុ ធម្មេសុ តស្ស យា វុត្តិ វា ឋិតិ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ សារីបុត្ត កាឡបក្ខេ ចន្ទស្ស យា វុត្តិ វា ឋិតិ វា អាគច្ឆតិ ហាយតេវ វណ្ណេន ហាយតិ មណ្ឌលេន ហាយតិ អាភាយ ហាយតិ អារោហបរិណាហេន ឯវមេវ ខោ សារីបុត្ត យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ។ បេ ។ អប្បមាទោ នត្ថិ កុសលេសុ ធម្មេសុ តស្ស យា វុត្តិ វា ឋិតិ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ យស្ស កស្សចិ សារីបុត្ត សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ... សោតាវធានំ អត្ថិ... ធម្មធារណា អត្ថិ... អត្ថុបបរិក្ខា អត្ថិ... ធម្មានុធម្មប្បដិបត្តិ អត្ថិ... អប្បមាទោ អត្ថិ កុសលេសុ ធម្មេសុ តស្ស យា វុត្តិ វា ឋិតិ វា អាគច្ឆតិ

យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីចម្រើន រមែងមិនប្រាកដឡើយ ។ ម្នាលសារីបុត្ត ដូចជាយប់និងថ្ងៃ របស់ព្រះចន្ទក្នុងកាឡបក្ខ មកដល់ព្រះចន្ទនោះ រមែងបាត់ចាកពណ៌ បាត់ចាកមណ្ឌល បាត់ចាកពន្លឺ បាត់ចាកកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយ មិនមាន ។ បេ ។ សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មិនមាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ ប្រាកដ សេចក្តីចម្រើន រមែងមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមាន ហិរិ មាន ... ឱត្តប្បៈ មាន ... វិរិយៈ មាន ... បញ្ញា មាន ... ការផ្ចង់ដើម្បីស្តាប់ មាន ... ការទ្រទ្រង់ធម៌ មាន ... ការពិចារណាអត្ថ មាន ... សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មាន យប់និងថ្ងៃរបស់បុគ្គលនោះមកដល់

វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ សារីបុត្ត ជុណ្ហបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ អារោ-ហបរិណាហេន ឯវមេវ ខោ សារីបុត្ត យស្ស កស្សចិ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ។ បេ ។ អប្បមាទោ អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។

[៦៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ បច្ឆាភត្តំ បិណ្ឌ-បាតប្បដិក្កន្តា ឧបដ្ឋានសាលាយំ សន្និសិន្នា សន្និបតិតា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរន្តិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ

សេចក្តីចម្រើន រមែងប្រាកដ សេចក្តីសាបសូន្យ រមែងមិនប្រាកដ ឡើយ ។ ម្នាលសារីបុត្ត ដូចជាយប់និងថ្ងៃ របស់ព្រះចន្ទ ក្នុងជុណ្ហបក្ខ មកដល់ ព្រះចន្ទនោះ រមែងចម្រើន ដោយពណ៌ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកម្ពស់និងទំហំ យ៉ាងណាមិញ ម្នាលសារីបុត្ត សទ្ធាក្នុងកុសលធម៌ទាំងឡាយ របស់បុគ្គលណានីមួយមាន ។ បេ ។ សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយមាន យប់និងថ្ងៃរបស់បុគ្គលនោះ មកដល់ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ រមែងប្រាកដ សេចក្តីសាបសូន្យ រមែងមិនប្រាកដឡើយ ក៏យ៉ាងនោះដែរ ។

[៦៩] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្តហើយ ក៏អង្គុយជួបជុំគ្នា ក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថា ច្រើនយ៉ាង គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ និយាយអំពីសេនាទាហាន និយាយអំពីភ័យ

យុទ្ធកថំ អន្នកថំ ចានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ[១] សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិ ភវាភវកថំ ឥតិ វាតិ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា[២] កា ច បន វោ អន្តរាកថា វិប្បកតាតិ ។

១ ម. ឯត្ថន្តរេ បុរិសកថន្តិ អត្ថិ ។ ២ ម. ឯត្ថន្តរេ សន្និបតិតាតិ អត្ថិ ។

និយាយអំពីចម្បាំង និយាយអំពីម្ហូបចំណី និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីយោធាដែលក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីញាតិ ដែលចែកឋានទៅកាន់បរលោក និយាយអំពីពាក្យដែលឥតប្រយោជន៍ មានសភាពផ្សេង ៗ និយាយអំពីលោក និយាយអំពីរឿងជីកសមុទ្រ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យហើយ ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ ហើយទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ស្រេចហើយទើបត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយក្នុងកាលអម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំគ្នាដោយកថា ដូចម្តេចហ្ន៎ម្យ៉ាងទៀត អន្តរាកថា ដូចម្តេចហ្ន៎ ដែលអ្នកទាំងឡាយ បញ្ឈប់ទៅ ។

ឥធ មយំ ភន្តេ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា ឧបដ្ឋានសាលាយំ សន្និសិន្នា សន្និបតិតា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរាម សេយ្យថីទំ រាជកថំ ចោរកថំ ។ បេ ។ ឥតិ ភវាភវកថំ ឥតិ វាតិ ។ ន ខោ បនេតំ ភិក្ខវេ តុម្ហាកំ បដិរូបំ កុលបុត្តានំ សទ្ធា[១] អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរេយ្យាថ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ

១ ម. សទ្ធាយ ។

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ពួកខ្ញុំព្រះអង្គត្រឡប់អំពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយ អង្គុយជួបជុំគ្នាក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថាជាច្រើនយ៉ាង គឺនិយាយអំពីស្តេច និយាយអំពីចោរ ។ បេ ។ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រកបតិរច្ឆានកថាជាច្រើនយ៉ាង ដោយហេតុណា ហេតុនោះ មិនសមគួរដល់អ្នកទាំងឡាយដែលជាកុលបុត្តអ្នកចេញចាកផ្ទះ ដោយសទ្ធាហើយចូលកាន់ផ្នួសឡើយ តិរច្ឆានកថានោះគឺ និយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ និយាយអំពីសេនាទាហាន និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីម្ហូបចំណី និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីកម្រងផ្កា និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីយោធាក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីញាតិដែលចែកឋានទៅកាន់បរលោក និយាយពាក្យដែលឥតប្រយោជន៍ មានសភាពផ្សេង ៗ

លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិ ភវាភវកថំ ឥតិ វា ។ ទសយិមានិ ភិក្ខវេ កថាវត្ថូនិ ។ កតមានិ ទស ។ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ឥមានិ ខោ ភិក្ខវេ ទស កថាវត្ថូនិ ។ ឥមេសំ ចេ តុម្ហេ ភិក្ខវេ ទសន្នំ កថាវត្ថូនំ ឧបាទាយុបាទាយ កថំ កថេយ្យាថ ឥមេសម្បិ ចន្ទិមសុរិយានំ ឯវំមហិទ្ធិកានំ ឯវំមហានុភាវានំ តេជសា តេជំ បរិយាទិយេយ្យាថ កោ បន វាទោ អញ្ញតិត្ថិយានំ បរិព្វាជកានន្តិ ។

[៧០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

និយាយអំពីលោក និយាយអំពីរឿងសមុទ្រ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ កថាវត្ថុ ( ហេតុគួរនិយាយ ) អម្បាលនេះមាន ១០ ប្រការ ។ កថាវត្ថុ ១០ ប្រការ តើដូចម្តេចខ្លះ ។ គឺនិយាយអំពីសេចក្តីប្រាថ្នាតិច ១ និយាយអំពីសេចក្តីសន្តោស ១ និយាយអំពីសេចក្តីស្ងាត់ ១ និយាយអំពីសេចក្តីមិនច្រឡូកច្រឡំ ដោយពួកគណៈ ១ និយាយអំពីប្រារព្ធសេចក្តីព្យាយាម ១ និយាយអំពីសីល ១ និយាយអំពីសមាធិ ១ និយាយអំពីបញ្ញា ១ និយាយអំពីវិមុត្តិ ១ និយាយអំពីវិមុត្តិញ្ញាណទស្សនៈ ១ ម្នាលភិក្ខុទាំងឡាយ កថាវត្ថុមាន ១០ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ និយាយនូវកថា ដែលអាស្រ័យកថាវត្ថុ ១០ ប្រការនេះឯង អ្នកទាំងឡាយ នឹងគ្របសង្កត់នូវតេជះនៃព្រះចន្ទនិងព្រះអាទិត្យនេះឯង ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ដោយតេជះរបស់ខ្លួន នឹងបាច់ពោលទៅថ្វី ដល់ពួកបរិព្វាជកជាអន្យតិរ្ថិយឡើយ ។

[៧០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

២៨៣

តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា ឧបដ្ឋានសាលាយំ សន្និសិន្នា សន្និបតិតា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរន្តិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ ។ បេ ។ ឥតិ ភវាភវកថំ ឥតិ វា ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ មយំ ភន្តេ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា ឧបដ្ឋានសាលាយំ សន្និសិន្នា សន្និបតិតា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរាម សេយ្យថីទំ រាជកថំ ចោរកថំ ។ បេ ។ ឥតិ ភវាភវកថំ ឥតិ វា ។

សម័យនោះឯង ភិក្ខុច្រើនរូប ត្រឡប់អំពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយ អង្គុយជួបជុំគ្នា ក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថា ច្រើនប្រការ គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ ។ បេ ។ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ គង់ស្រេចហើយ ទើបត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលអម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយជួបជុំគ្នា ដោយកថាដូចម្តេចហ្ន៎ ចុះអន្តរាកថាដូចម្តេច ដែលពួកអ្នកបញ្ឈប់ទៅ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ពួកខ្ញុំព្រះអង្គត្រឡប់អំពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយ អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា ប្រកបតិរច្ឆានកថាជាច្រើន គឺនិយាយអំពីស្តេច និយាយអំពីចោរ ។ បេ ។ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។

ឯ ខោ បនេតំ ភិក្ខវេ តុម្ហាកំ បដិរូបំ កុលបុត្តានំ សទ្ធា អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ អនេកាវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរេយ្យាថ សេយ្យថីទំ រាជកថំ ។ បេ ។ ឥតិ ភវាភវកថំ ឥតិ វា ។ ទសយិមានិ ភិក្ខវេ ចាសំសានិ ឋានានិ ។ កាតមានិ ទស ។ ឥធ ភិក្ខវេ ភិក្ខុ អត្តនា ច អប្បិច្ឆោ ហោតិ អប្បិច្ឆកថញ្ច ភិក្ខូនំ កត្តា ហោតិ អប្បិច្ឆោ ច ភិក្ខុ អប្បិច្ឆកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ឋានំ ។ អត្តនា ច សន្តុដ្ឋោ ហោតិ សន្តុដ្ឋិកថញ្ច ភិក្ខូនំ កត្តា ហោតិ សន្តុដ្ឋោ ច ភិក្ខុ សន្តុដ្ឋិកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ឋានំ ។ អត្តនា ច បវិវិត្តោ ហោតិ បវិវេកកថញ្ច ភិក្ខូនំ កត្តា ហោតិ បវិវិត្តោ ច ភិក្ខុ បវិវេកកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ឋានំ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រកបតិរច្ឆានកថាជាច្រើន ដោយហេតុណា ហេតុនេះ មិនសមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ដោយសទ្ធា ចូលមកកាន់ផ្នួសទេ តិរច្ឆានកថានោះគឺនិយាយអំពីស្តេច ។ បេ ។ និយាយអំពីសេចក្តីចម្រើននិងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ឋានៈ ដែលគួរសរសើរនេះមាន ១០ យ៉ាង ។ ឋានៈ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាតិច ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រាថ្នាតិច ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈគួរសរសើរថា ភិក្ខុជាអ្នកប្រាថ្នាតិច ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រាថ្នាតិចដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកសន្តោស ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីសន្តោសដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកសន្តោសផង សម្តែងអំពីសេចក្តីសន្តោសដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកស្ងប់ស្ងាត់ ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីស្ងប់ស្ងាត់ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកស្ងប់ស្ងាត់ផង សម្តែងអំពីសេចក្តីស្ងប់ស្ងាត់ដល់ភិក្ខុទាំងឡាយផង ១ ។

អត្តនា ច អសំសដ្ឋោ ហោតិ អសំសដ្ឋកថញ្ច[១] ភិក្ខូនំ កត្តា ហោតិ អសំសដ្ឋោ ច ភិក្ខុ អសំសដ្ឋកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ហានំ ។ អត្តនា ច អារទ្ធវីរិយោ ហោតិ វីរិយារម្ភកថញ្ច ភិក្ខូនំ កត្តា ហោតិ អារទ្ធវីរិយោ ច ភិក្ខុ វីរិយារម្ភកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ហានំ ។ អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាកថញ្ច ភិក្ខូនំ កត្តា ហោតិ សីលសម្បន្នោ ច ភិក្ខុ សីលសម្បទាកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ហានំ ។ អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាកថញ្ច ភិក្ខូនំ កត្តា ហោតិ សមាធិសម្បន្នោ ច ភិក្ខុ សមាធិសម្បទាកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ហានំ ។

១ ឱ. អសំសគ្គកថញ្ច ។

ភិក្ខុជាអ្នកមិនច្រឡូកច្រឡំដោយពួកគណៈ ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីមិនច្រឡូកច្រឡំ ដោយពួកគណៈ ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកមិនច្រឡូកច្រឡំ ដោយពួកគណៈផង សម្តែងអំពីសេចក្តីមិនច្រឡូកច្រឡំដោយពួកគណៈ ដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកមានព្យាយាមប្រារព្ធហើយ ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីប្រារព្ធព្យាយាម ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកមានព្យាយាមប្រារព្ធហើយផង សម្តែងអំពីសេចក្តីប្រារព្ធព្យាយាម ដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯងផង សម្តែងអំពីសេចក្តីបរិបូណ៌ដោយសីលដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ដោយសីលផង សម្តែងអំពីការបរិបូណ៌ដោយសីល ដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ដោយសមាធិ ដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ ដោយសមាធិ ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈ ដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ ដោយសមាធិផង សម្តែងអំពីការបរិបូណ៌ ដោយសមាធិ ដល់ភិក្ខុទាំងឡាយផង ១ ។

អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញាសម្បទាកថញ្ច ភិក្ខូនំ កត្តា ហោតិ បញ្ញាសម្បន្នោ ច ភិក្ខុ បញ្ញាសម្បទាកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ឋានំ ។ អត្តនា ច វិមុត្តិសម្បន្នោ ហោតិ វិមុត្តិសម្បទាកថញ្ច ភិក្ខូនំ កត្តា ហោតិ វិមុត្តិសម្បន្នោ ច ភិក្ខុ វិមុត្តិសម្បទាកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ឋានំ ។ អត្តនា ច វិមុត្តិញ្ញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញ្ញាណទស្សនសម្បទាកថញ្ច ភិក្ខូនំ កត្តា ហោតិ វិមុត្តិញ្ញាណទស្សនសម្បន្នោ ច ភិក្ខុ វិមុត្តិញ្ញាណទស្សនសម្បទាកថញ្ច ភិក្ខូនំ កត្តាតិ ចាសំសមេតំ ឋានំ ។ ឥមានិ ខោ ភិក្ខវេ ទស ចាសំសានិដ្ឋានានីតិ ។

យមកវគ្គោ ទុតិយោ ។

ភិក្ខុជាអ្នកបរិបូណ៌ដោយបញ្ញា ដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ ដោយបញ្ញា ដល់ភិក្ខុទាំងឡាយ នេះ ជាឋានៈ ដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ ដោយបញ្ញាផង សម្តែងអំពីការបរិបូណ៌ ដោយបញ្ញា ដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ ដោយវិមុត្តិ ដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ ដោយវិមុត្តិ ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ ដោយវិមុត្តិផង ស-ម្តែងអំពីការបរិបូណ៌ ដោយវិមុត្តិ ដល់ភិក្ខុទាំងឡាយផង ១ ។ ភិក្ខុជាអ្នកបរិបូណ៌ ដោយវិមុត្តិញ្ញាណទស្សនៈ ដោយខ្លួនឯងផង សម្តែងអំពីការបរិបូណ៌ ដោយវិមុត្តិញ្ញាណទស្សនៈ ដល់ភិក្ខុទាំងឡាយផង នេះ ជាឋានៈដែលគួរសរសើរថា ភិក្ខុជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈផង សំ-ដែងអំពីការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈដល់ភិក្ខុទាំងឡាយផង ១ ។ ម្នាលភិក្ខុទាំងឡាយ ឋានៈដែលគួរសរសើរមាន ១០ យ៉ាងនេះឯង ។

ចប់ យមកវគ្គ ទី ២ ។

# តស្សុទ្ទានំ

អវិជ្ជា តណ្ហាជិជ្ឈា ច អវេច្ច ទ្វេ សុខានិ ច

ជឡ្បកចានេជ ទ្វេ ច(១) វត្ថុកថា អបរេ ទ្វេ(២) ។

---

១ ឱ. ម. នឡ្បកបានេ ទ្វេ វុត្តា ។ ២ ឱ. កថាវត្ថុ អបរេ ទ្វេតិ ។ ម. កថាវត្ថុ បរេ ទុវេតិ ។

ទុតិយបណ្ណាសក យមកវគ្គ

# ឧទ្ទាននៃយមកវគ្គនោះគឺ

និយាយអំពីអវិជ្ជា ១ តណ្ហា ១ (ការសម្រេចព្រះនិព្វាន) ១ សេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះតថាគត ១ សេចក្ដីសុខពីរលើក ពីព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់និគមឈ្មោះនឡកបានៈ ពីរលើក និងវត្ថុកថា ដទៃទៀត ពីរលើក ។

# អាកង្ខវគ្គោ តតិយោ

[៧១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នបាតិមោក្ខា បាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយទស្សាវី[១] សមាទាយ សិក្ខថ សិក្ខាបទេសុ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ សព្រហ្មចារីនំ បិយោ ចស្សំ មនាបោ ច គរុ ច ភាវនីយោ ចាតិ សីលេស្វេវស្ស បរិបូរិការី[២] អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ

---

១ ឱ. ម. ភយទស្សាវិនោ ។ ២ ឱ. ម. បរិបូរការី ។

# អាកង្ខវគ្គ ទី ៣

[៧១] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះបានទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះអង្គដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរបរិបូណ៌ ដោយសីល បរិបូណ៌ ដោយបាតិមោក្ខ ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញនូវភ័យ ក្នុងទោសមានប្រមាណតិច ជាអ្នកសមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ប្រកបរឿយ ៗ នូវការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារៈ (ផ្ទះស្ងាត់) ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា

## ២៨៩



លាភី អស្សំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារានន្តិ សីលេស្វេវស្ស បរិបូរិការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេសាហំ បរិភុញ្ជាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារានំ តេសន្តេ ការា មហប្ផលា អស្សុ មហានិសំសាតិ សីលេស្វេវស្ស... ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេ[១] បេតា ញាតិសាលោហិតា កាលកតា បសន្នចិត្តា អនុស្សរន្តិ តេសន្តំ មហប្ផលំ អស្ស មហានិសំសន្តិ សីលេស្វេវស្ស ... ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ អស្សំ ឥតរីតរចីវរ-បិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេនាតិ សីលេស្វេវស្ស... ព្រូហេតា សុញ្ញាគារានំ ។

១ ឱ. ម. យេមេ ។

អាត្មាអញ គួរជាបុគ្គលបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីលប្រកបរឿយ ៗ នូវការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញប្រើប្រាស់ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ របស់ទាយកណា ការឲ្យនូវបច្ច័យទាំងនោះរបស់ទាយកទាំងនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើន ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា ពួកប្រេតជាញាតិសាលោហិតណា (របស់អាត្មាអញ) ដែលធ្វើមរណកាលស្លាប់ទៅហើយ មានចិត្តជ្រះថ្លារលឹករឿយ ៗ ការរលឹកនោះ របស់ប្រេតទាំងនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើន ភិក្ខុនោះគួរជាអ្នកបំពេញ ក្នុងសីល ... ជាអ្នកចម្រើន នូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញ គប្បីជាអ្នកសន្ដោស ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ភិក្ខុនោះគួរជាអ្នកបំពេញ ក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារៈ ។

អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ខមោ អស្សំ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិប្បានំ[១] ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកោ អស្សន្តិ សីលេស្វេវស្ស... ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អរតិរតិសហោ អស្សំ ន ច មំ អរតិរតិ សហេយ្យ ឧប្បន្នំ អរតិរតឹ អភិភុយ្យ[២] វិហរេយ្យន្តិ សីលេស្វេវស្ស... ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ភយភេរវសហោ អស្សំ ន ច មំ ភយភេរវោ សហេយ្យ

១ ម. តិព្វានំ ។ ២ ឱ. ម. អភិភុយ្យ អភិភុយ្យ ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាអ្នកអត់ធន់នូវត្រជាក់ ក្តៅ ការឃ្លាន ការស្រេក សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃនិងពស់តូចពស់ធំ ជាអ្នកអត់សង្កត់ នូវគន្លងនៃពាក្យដែលគេនិយាយអាក្រក់ មកកាន់សោតទ្វារដែលញុំាងទុក្ខឲ្យកើតឡើង នាំឲ្យវេទនា ប្រព្រឹត្តទៅ ក្នុងសរីរៈ ជាទុក្ខក្លាខ្លាំង ខ្លោចផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ជាទីនាំទៅនូវជីវិត ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីអត់ធន់នូវសេចក្តីអផ្សុក (ក្នុងនេក្ខម្មៈ) និងសេចក្តីត្រេកអរក្នុងកាមគុណ (ឯសេចក្តីត្រេកអរនិងសេចក្តីអផ្សុក) ក្នុងនេក្ខម្មៈ និងសេចក្តីត្រេកអរ (ក្នុងកាមគុណ) កុំគប្បីគ្របសង្កត់នូវអាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់នូវសេចក្តីអផ្សុក (ក្នុងនេក្ខម្មៈ) និងសេចក្តីត្រេកអរ (ក្នុងកាមគុណ) ដែលកើតឡើងហើយ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីជាអ្នកគ្របសង្កត់នូវអារម្មណ៍ ដែលគួរខ្លាច ឯអារម្មណ៍ដែលគួរខ្លាច កុំគប្បីគ្របសង្កត់នូវអាត្មាអញឡើយ

ឧប្បន្នំ ភយភេរវំ អភិភុយ្យ វិហរេយ្យន្តិ សីលេស្វេវស្ស... ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភីតិ សីលេស្វេវស្ស... ព្រូហេតា សុញ្ញាគារានំ ។ អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ សីលេស្វេវស្ស បរិបូរការី អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ។ សម្បន្នសីលា ភិក្ខវេ វិហរថ សម្បន្នចាតិមោក្ខា ចាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខថ សិក្ខាបទេសូតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

អាត្មាអញ គប្បីគ្របសង្កត់នូវអារម្មណ៍ ដែលគួរខ្លាច ដែលកើតឡើង ហើយ ភិក្ខុនោះ គួរជាអ្នកបំពេញ ក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីបាន ដោយមិនបាច់ប្រាថ្នា បានដោយងាយ បានដោយមិនលំបាកនូវចតុត្ថជ្ឈានទាំងកិរិយានៅជាសុខ ក្នុងបច្ចុប្បន្ន ដែលអាស្រ័យនូវចិត្ត ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ... ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីប្រាថ្នាថា អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន បានដល់នូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈហើយ សម្រេចសម្រាន្តនៅ ភិក្ខុនោះគួរជាអ្នកបំពេញក្នុងសីល ប្រកបនូវការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារៈ ។ ពាក្យណាដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបរិបូណ៌ ដោយសីល ដោយបាតិមោក្ខ ចូរសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យ ក្នុងទោសមានប្រមាណតិច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។

[៧២] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ សម្ពហុលេហិ អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ អាយស្មតា ច ចាលេន[(១)] អាយស្មតា ច ឧបចាលេន[(២)] អាយស្មតា ច កក្កដេន[(៣)] អាយស្មតា ច កឡិម្ភេន[(៤)] អាយស្មតា ច និកដេន អាយស្មតា ច កដិស្សហេន អញ្ញេហិ ច អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី ភទ្រេហិ ភទ្រេហិ យានេហិ បរម្បរាយ[(៥)] ឧច្ចាសទ្ទា មហាសទ្ទា មហាវនំ អជ្ឈោគាហន្តិ ភគវន្តំ ទស្សនាយ ។ អថខោ តេសំ អាយស្មន្តានំ ឯតទហោសិ

---

១ ឱ. ម. ចាលេន ។ ២ ឱ. ម. ឧបចាលេន ។ ៣ ម. កុក្កុដេន ។ ៤ ឱ. កឡិម្ពេន ។ ៥ ឱ. ចរបុរាយ ។ ម. បរបុរាយ ។ អដ្ឋកថាយំ បន បរម្បុរាយាតិ ទិស្សតិ ។

[៧២] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងកូដាគារ-សាលា នាមហាវ័ន ជិតក្រុងវេសាលីជាមួយនឹងសាវ័កជាថេរៈច្រើនរូប ដែលមានឈ្មោះល្បីល្បាញគឺព្រះបាលៈ ដ៏មានអាយុ ១ ព្រះឧបបាលៈដ៏មានអាយុ ១ ព្រះកក្កដៈដ៏មានអាយុ ១ ព្រះកឡិម្ភៈដ៏មានអាយុ ១ ព្រះនិកដៈដ៏មានអាយុ ១ ព្រះកដិស្សហៈដ៏មានអាយុ ១ ព្រមទាំងសាវ័កជាថេរៈដែលមានឈ្មោះល្បីល្បាញឯទៀតផង ។ សម័យនោះឯង ពួកស្តេចលិច្ឆវីច្រើនអង្គ ដែលមានឈ្មោះល្បីល្បាញ ត្រាច់ទៅ ដោយយានដ៏ប្រសើរក្រៃលែងត ៗ គ្នា មានសំឡេងអឺងកងរំពង បរទៅកាន់ព្រៃមហាវ័ន ដើម្បីជួបព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះថេរៈ ដ៏មានអាយុទាំងនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា

២៩៣



ឥមេ ខោ សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី ភទ្រេហិ ភទ្រេហិ យានេហិ បរម្បរាយ ឧច្ចាសទ្ទា មហាសទ្ទា មហាវនំ អជ្ឈោគាហន្តិ ភគវន្តំ ទស្សនាយ សទ្ទកណ្ដកា ខោ បន ឈានា វុត្តា ភគវតា យន្នូន មយំ យេន គោសិង្គសាលវនទាយោ តេនុបសង្កមេយ្យាម តត្ថ មយំ អប្បសទ្ទា អប្បកិណ្ណា ផាសុ វិហរេយ្យាមាតិ អថខោ តេ អាយស្មន្តោ យេន គោសិង្គសាល-វនទាយោ តេនុបសង្កមឹសុ តត្ថ តេ អាយស្មន្តោ អប្បសទ្ទា អប្បកិណ្ណា ផាសុ វិហរន្តិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ កហំ នុ ខោ ភិក្ខវេ ចាលោ កហំ ឧបចាលោ កហំ កក្កដោ កហំ កឡិម្ភោ កហំ និកដោ កហំ កដិស្សហោ កហំ នុ ខោ តេ ភិក្ខវេ ថេរា សាវកា គតាតិ ។ ឥធ ភន្តេ តេសំ អាយស្មន្តានំ ឯតទហោសិ

ពួកស្តេចលិច្ឆវីមានប្រមាណច្រើនទាំងនេះ ដែលមានឈ្មោះល្បីល្បាញ ត្រាច់ទៅដោយយានដ៏ប្រសើរក្រៃលែងតៗ គ្នា មានសំឡេងអឺងកងរំពង ចូលទៅកាន់ព្រៃមហាវ័ន ដើម្បីជួបព្រះដ៏មានព្រះភាគ ឯព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ឈានមានសំឡេងជាបន្លា បើដូច្នោះគួរតែយើងទាំងឡាយ ចូលទៅរកព្រៃគោសិង្គសាលវ៍ន ហើយយើងទាំងឡាយគប្បីមានសំឡេងតិច មានការនៅច្រឡូកច្រឡំគ្នាតិច ទើបនៅជាសុខក្នុងទីនោះ បានជាព្រះថេរៈដ៏មានអាយុទាំងនោះ ក៏ចូលទៅឯព្រៃគោសិង្គសា-លវ័ន ព្រះថេរៈដ៏មានអាយុទាំងនោះ មានសំឡេងតិច មានការច្រឡូកច្រឡំគ្នាតិច ហើយនៅជាសុខក្នុងទីនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅ ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាលៈនៅក្នុងទីណា ភិក្ខុឧបបាលៈនៅក្នុងទីណា ភិក្ខុកក្កដៈ នៅក្នុងទីណា ភិក្ខុកឡិម្ភៈនៅក្នុងទីណា ភិក្ខុនិកដៈ នៅក្នុងទីណា ភិក្ខុកដិស្សហៈនៅក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ឯសាវ័កជាថេរៈទាំងនោះនៅចំទីណាដែរ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះព្រះថេរៈ ដ៏មានអាយុទាំងនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា

ឥមេ ខោ សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី ភទ្រេហិ ភទ្រេហិ យានេហិ បរម្បរាយ ឧច្ចាសទ្ទា មហាសទ្ទា មហាវនំ អជ្ឈោ-គាហន្តិ ភគវន្តំ ទស្សនាយ សទ្ទកណ្ដកា ខោ ឈានា វុត្តា ភគវតា យន្នូន មយំ យេន គោ-សិង្គសាលវនទាយោ តេនុបសង្កមេយ្យាម តត្ថ មយំ អប្បសទ្ទា អប្បកិណ្ណា ផាសុ វិហរេយ្យាមាតិ អថខោ តេ ភន្តេ អាយស្មន្តោ យេន គោសិង្គ-សាលវនទាយោ តេនុបសង្កមឹសុ តត្ថ តេ អាយស្មន្តោ អប្បសទ្ទា អប្បកិណ្ណា ផាសុ វិហរន្តីតិ ។ សាធុ សាធុ ភិក្ខវេ យថា តេ មហាសាវកា សម្មាព្យាករមានា ព្យាករេយ្យុំ សទ្ទកណ្ដកា ហិ ភិក្ខវេ ឈានា វុត្តា មយា ។ ទសយិមេ ភិក្ខវេ កណ្ដកា ។ កតមេ ទស ។ បវិវេការាមស្ស សង្គណិការាមតា កណ្ដកោ

ពួកស្តេចលិច្ឆវី មានប្រមាណច្រើននេះ ដែលមានឈ្មោះល្បីល្បាញ ត្រាច់ទៅដោយយានដ៏ប្រសើរក្រៃលែងត ៗ គ្នា មានសំឡេងអឺងកងរំពង ចូលទៅកាន់ព្រៃមហាវ័ន ដើម្បីជួបព្រះដ៏មានព្រះភាគ ព្រះអង្គក៏ទ្រង់សម្តែងថា ឈានមានសំឡេងជាបន្លា បើដូច្នោះគួរតែយើងទាំងឡាយ ចូលទៅឯព្រៃគោសិង្គសាលវ័ន យើងទាំងឡាយ គប្បីមានសំឡេងតិច មានការនៅច្រឡូកច្រឡំគ្នាតិច ទើបនៅជាសុខក្នុងទីនោះ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះ លោកដ៏មានអាយុទាំងនោះ ចូលទៅឯព្រៃគោសិង្គ-សាលវន លោកដ៏មានអាយុទាំងនោះ ក៏មានសំឡេងតិច មានការនៅច្រឡូកច្រឡំគ្នាតិច ហើយនៅជាសុខក្នុងទីនោះ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រពៃហើយ ប្រពៃហើយ កាលមហាសាវ័កទាំងនោះព្យាករដោយប្រពៃ គប្បីព្យាករ តាមពិត ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគត ពោលហើយថា ឈានមានសំឡេងជាបន្លា ។ ម្នាលភិក្ខុទាំងឡាយ បន្លាទាំងឡាយនេះ មាន ១០ យ៉ាង ។ បន្លាទាំង ១០ យ៉ាង តើដូចម្តេចខ្លះ ។ គឺសភាពជាអ្នកត្រេកអរ ក្នុងពួកគណៈ ជាបន្លា របស់បុគ្គល ដែលមានសេចក្តីស្ងប់ស្ងាត់ជាទីត្រេកអរ ១

អសុភនិមិត្តានុយោគំ អនុយុត្តស្ស សុភនិមិត្តានុយោគោ កណ្ដកោ ឥន្ទ្រិយេសុ គុត្តទ្វារស្ស វិសូកទស្សនំ កណ្ដកោ ព្រហ្មចរិយស្ស មាតុគ្គាមុបចារោ[១] កណ្ដកោ បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ ទុតិយស្ស ឈានស្ស វិតក្កវិចារា កណ្ដកា តតិយស្ស ឈានស្ស បីតិ កណ្ដកោ ចតុត្ថស្ស ឈានស្ស អស្សាសបស្សាសា កណ្ដកា សញ្ញាវេទយិតនិរោធសមាបត្តិយា សញ្ញា ច វេទនា ច កណ្ដកា រាគោ កណ្ដកោ ទោសោ កណ្ដកោ មោហោ កណ្ដកោ ។ អកណ្ដកា ភិក្ខវេ វិហរថ អកណ្ដកា និកណ្ដកា ភិក្ខវេ វិហរថ[២] អកណ្ដកា ភិក្ខវេ អរហន្តោ អកណ្ដកា និកណ្ដកា ភិក្ខវេ អរហន្តោតិ[៣] ។

១ ឱ. មាតុគាមោបវិចារោ ។ ម. មាតុគាមូបវិចរោ ។ ២ ឱ. ម. និកណ្ដកា ភិក្ខវេ វិហរថ អកណ្ដកនិកណ្ដកា ភិក្ខវេ វិហរថ ។ ៣ ឱ. ម. និកណ្ដកា ភិក្ខវេ អរហន្តោ អកណ្ដកនិកណ្ដកា ភិក្ខវេ អរហន្តោតិ ។

ការប្រកបរឿយ ៗ នូវសុភនិមិត្ត ជាបន្ទារបស់បុគ្គលដែលប្រកបរឿយ ៗ នូវអសុភនិមិត្ត ១ ការឃើញនូវសត្រូវគឺល្បែងផ្សេង ៗ ជាបន្ទារបស់បុគ្គលមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ ១ ការត្រាច់ទៅជិតមាតុគ្រាម ជាបន្ទារបស់ព្រហ្មចរិយៈ ១ សំឡេង ជាបន្ទារបស់បឋមជ្ឈាន ១ វិតក្កៈនិងវិចារៈជាបន្ទារបស់ទុតិយជ្ឈាន ១ បីតិ ជាបន្ទារបស់តតិយជ្ឈាន ១ អស្សាសប្បស្សាសៈ ជាបន្ទារបស់ចតុត្ថជ្ឈាន ១ សញ្ញានិងវេទនា ជាបន្ទារបស់សញ្ញាវេទយិតនិរោធសមាបត្តិ ១ រាគៈ ជាបន្ទា ទោសៈ ជាបន្ទា មោហៈ ជាបន្ទា ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកុំមានធម៌ជាបន្ទាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកុំមានធម៌ជាបន្ទាឡើយ ចូរនាំធម៌ជាបន្ទាចេញ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តទាំងឡាយមិនមានធម៌ ជាបន្ទាទេ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តទាំងឡាយ មិនមានធម៌ជាបន្ទាទេ បាននាំធម៌ ជាបន្ទាចេញហើយ ។

[៧៣] ទសយិមេ ភិក្ខវេ ធម្មា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ កតមេ ទស ។ ភោគា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ វណ្ណោ ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ អារោគ្យំ ឥដ្ឋំ កន្តំ មនាបំ ទុល្លភំ លោកស្មឹ សីលានិ[១] ឥដ្ឋានិ កន្តានិ មនាបានិ ទុល្លភានិ លោកស្មឹ ព្រហ្មចរិយំ ឥដ្ឋំ កន្តំ មនាបំ ទុល្លភំ លោកស្មឹ មិត្តា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ពាហុសច្ចំ ឥដ្ឋំ កន្តំ មនាបំ ទុល្លភំ លោកស្មឹ បញ្ញា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ធម្មោ[២] ឥដ្ឋោ កន្តោ មនាបោ ទុល្លភោ លោកស្មឹ សគ្គា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។

---

១ ម. សីលំ ...។ ២ ឱ. ម. ធម្មា ...។

[៧៣] ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលបានដោយកម្រ ក្នុងលោក ។ ធម៌ទាំង ១០ យ៉ាង តើដូចម្តេច ។ គឺភោគៈជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលបានដោយកម្រ ក្នុងលោក ១ ពណ៌សម្បុរ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ សភាពមិនមានរោគ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ សីល ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ ព្រហ្មចរិយៈ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ មិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ សភាពជាអ្នកចេះដឹងច្រើន ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ បញ្ញាជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រក្នុងលោក ១ ធម៌ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ១ ឋានសួគ៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបាន ដោយកម្រ ក្នុងលោក ១ ។

២៩៧



ឥមេ ខោ ភិក្ខវេ ទស ធម្មា ឥដ្ឋា កន្តា មនាបា ទុល្លភា លោកស្មឹ ។ ឥមេសំ ខោ ភិក្ខវេ ទសន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ទស ធម្មា បរិបន្ថា[១] ។ អាលស្យំ[២] អនុដ្ឋានំ ភោគានំ បរិបន្ថោ អមណ្ឌនា អវិភូសនា វណ្ណស្ស បរិបន្ថោ អសប្បាយកិរិយា អារោគ្យស្ស បរិបន្ថោ បាបមិត្តតា សីលានំ បរិបន្ថោ ឥន្ទ្រិយាសំវរោ ព្រហ្មចរិយស្ស បរិបន្ថោ វិសំវាទនា មិត្តានំ បរិបន្ថោ អសជ្ឈាយកិរិយា ពាហុសច្ចស្ស បរិបន្ថោ អស្សុស្សូសា អបរិបុច្ឆា បញ្ញាយ បរិបន្ថោ អននុយោគោ អប្បច្ចវេក្ខណា ធម្មានំ បរិបន្ថោ មិច្ឆាបដិបត្តិ សគ្គានំ បរិបន្ថោ ។ ឥមេសំ ខោ ភិក្ខវេ ទសន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ឥមេ ទស ធម្មា បរិបន្ថា ។

---

១ ម. គ បរិពន្ធា ។ ២ ម. អាលស្យំ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះឯង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាង នាំឲ្យអន្តរាយដល់ធម៌ ១០ យ៉ាងនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ។ គឺការខ្ជិលនិងការមិនប្រឹងប្រែង នាំឲ្យអន្តរាយដល់ភោគៈ ១ ការមិនប្រដាប់មិនតាក់តែង នាំឲ្យអន្តរាយដល់ពណ៌សម្បុរ ១ ការធ្វើនូវសេចក្តីមិនសប្បាយ នាំឲ្យអន្តរាយដល់ភាពមិនមានរោគ ១ មិត្តលាមក នាំឲ្យអន្តរាយដល់សីល ១ ការមិនសង្រួមនូវឥន្ទ្រិយ នាំឲ្យអន្តរាយដល់ព្រហ្មចរិយៈ ១ ការពោលពាក្យខុស នាំឲ្យអន្តរាយ ដល់ពួកមិត្ត ១ ការធ្វើនូវសេចក្តីមិនស្វាធ្យាយ នាំឲ្យអន្តរាយ ដល់ភាពចេះដឹងច្រើន ១ ការមិនប្រុងស្តាប់ មិនសាកសួរ នាំឲ្យអន្តរាយដល់បញ្ញា ១ ការមិនប្រកបរឿយ ៗ ការមិនពិចារណា នាំឲ្យអន្តរាយដល់ធម៌ទាំងឡាយ ១ សេចក្តីប្រតិបត្តិខុស នាំឲ្យអន្តរាយ ដល់ឋានសួគ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះ នាំឲ្យអន្តរាយដល់ធម៌ ១០ យ៉ាងនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលបានដោយកម្រ ក្នុងលោក ។

ឥមេសំ ខោ ភិក្ខវេ ទសន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ទស ធម្មា អាហារា ។ អនាលស្សំ ឧដ្ឋានំ ភោគានំ អាហារោ មណ្ឌនា វិភូសនា វណ្ណស្ស អាហារោ សប្បាយកិរិយា អារោគ្យស្ស អាហារោ កល្យាណមិត្តតា សីលានំ អាហារោ ឥន្ទ្រិយសំវរោ ព្រហ្មចរិយស្ស អាហារោ អវិសំវាទនា មិត្តានំ អាហារោ សជ្ឈាយកិរិយា ពាហុសច្ចស្ស អាហារោ សុស្សូសា បរិបុច្ឆា បញ្ញាយ អាហារោ អនុយោគោ បច្ចវេក្ខណា ធម្មានំ អាហារោ សម្មាបដិបត្តិ សគ្គានំ អាហារោ ។ ឥមេសំ ខោ ភិក្ខវេ ទសន្នំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ ទុល្លភានំ លោកស្មឹ ឥមេ ទស ធម្មា អាហារាតិ ។

[៧៤] ទសហិ ភិក្ខវេ វឌ្ឍីហិ វឌ្ឍមានោ អរិយសាវកោ អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយី ច ហោតិ វរាទាយី កាយស្ស ។

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ យ៉ាង ជាអាហារនៃធម៌ទាំង ១០ នេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ។ គឺសេចក្តីមិនខ្ជិល សេចក្តីព្យាយាម ជាអាហាររបស់ភោគៈ ១ ការប្រដាប់ ការតាក់តែង ជាអាហារ របស់ពណ៌សម្បុរ ១ ការធ្វើនូវសេចក្តីសប្បាយ ជាអាហារ របស់ភាពមិនមានរោគ ១ សភាពមិត្តល្អ ជាអាហារ របស់សីល ១ ការសង្រួមឥន្ទ្រិយ ជាអាហារ របស់ព្រហ្មចរិយៈ ១ ការមិនពោលពាក្យខុស ជាអាហារ របស់មិត្តទាំងឡាយ ១ ការធ្វើនូវកិរិយាស្វាធ្យាយ ជាអាហារ របស់ភាពអ្នកចេះដឹងច្រើន ១ ការស្តាប់ ការសាកសួរ ជាអាហារ របស់បញ្ញា ១ ការប្រកបរឿយ ៗ ការពិចារណា ជាអាហាររបស់ធម៌ទាំងឡាយ ១ សេចក្តីប្រតិបត្តិល្អ ជាអាហាររបស់ឋានសួគ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ១០ នេះឯង ជាអាហារ នៃធម៌ ១០ យ៉ាងនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត បុគ្គលបានដោយកម្រ ក្នុងលោក ។

[៧៤] ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក កាលចម្រើនដោយសេចក្តីចម្រើន ១០ យ៉ាង រមែងចម្រើន ដោយសេចក្តីចម្រើនដ៏ប្រសើរ ឈ្មោះថាអ្នកកាន់យកនូវខ្លឹមរបស់កាយផង ជាអ្នកកាន់យកនូវវត្ថុ ដ៏ប្រសើររបស់កាយផង ។

កតមេហិ ទសហិ ។ ខេត្តវត្ថូហិ វឌ្ឍតិ ធនធញ្ញេន វឌ្ឍតិ បុត្តទារេហិ វឌ្ឍតិ ទាសកម្មករបោរិសេហិ វឌ្ឍតិ ចតុប្បទេហិ វឌ្ឍតិ សទ្ធាយ វឌ្ឍតិ សីលេន វឌ្ឍតិ សុតេន វឌ្ឍតិ ចាគេន វឌ្ឍតិ បញ្ញាយ វឌ្ឍតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ វឌ្ឍីហិ វឌ្ឍមានោ អរិយសាវកោ អរិយាយ វឌ្ឍិយា វឌ្ឍតិ សារាទាយី ច ហោតិ វរាទាយី កាយស្សាតិ ។

ធនេន ធញ្ញេន ច យោធ វឌ្ឍតិ
បុត្តេហិ ទារេហិ ចតុប្បទេហិ ច
ស ភោគវា ហោតិ យសស្សិ បូជិតោ
ញាតីហិ មិត្តេហិ អថោបិ រាជុភិ ។
សទ្ធាយ សីលេន ច យោធ វឌ្ឍតិ
បញ្ញាយ ចាគេន សុតេន ចូភយំ

ការចម្រើនដោយសេចក្តីទាំង ១០ យ៉ាង តើដូចម្តេច ។ គឺចម្រើន ដោយស្រែចម្ការ ១ ចម្រើន ដោយទ្រព្យនិងស្រូវ ១ ចម្រើន ដោយកូននិងប្រពន្ធ ១ ចម្រើន ដោយបុរសជាទាសៈនិងកម្មករ ១ ចម្រើន ដោយសត្វមានជើង ៤ ទាំងឡាយ ១ ចម្រើន ដោយសទ្ធា ១ ចម្រើន ដោយសីល ១ ចម្រើន ដោយសុតៈ ១ ចម្រើន ដោយចាគៈ ១ ចម្រើន ដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក កាលចម្រើន ដោយសេចក្តីចម្រើន ១០ យ៉ាងនេះឯង រមែងចម្រើន ដោយសេចក្តីចម្រើនដ៏ប្រសើរ ឈ្មោះថាអ្នកកាន់យកនូវខ្លឹមរបស់កាយផង ជាអ្នកកាន់យកនូវវត្ថុដ៏ប្រសើរ របស់កាយផង ។

បុគ្គលណាក្នុងលោកនេះ ចម្រើន ដោយទ្រព្យផង ដោយស្រូវផង ដោយកូនផង ដោយប្រពន្ធផង ដោយសត្វជើង ៤ ផង បុគ្គលនោះឈ្មោះថា មានភោគៈ មានយសដែលពួកញាតិនិងមិត្ត ព្រមទាំងស្តេចបូជាហើយ ។ បុគ្គលណាក្នុងលោកនេះ ចម្រើនដោយសទ្ធាផង ដោយសីលផង ដោយបញ្ញាផង ដោយចាគៈផង ដោយសុតៈទាំងពីរផង

សោ តាទិសោ សប្បុរិសោ វិចក្ខណោ
ឥធេវ ធម្មេ ឧភយេន វឌ្ឍតីតិ ។

[៧៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មិគសាលាយ ឧបាសិកាយ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ មិគសាលា ឧបាសិកា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ មិគសាលា ឧបាសិកា អាយស្មន្តំ អានន្ទំ ឯតទវោច កថំកថា នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយំ ។

បុគ្គលបែបនោះហៅថា សប្បុរស ជាអ្នកពិចារណាឃើញច្បាស់ រមែងចម្រើនដោយហេតុទាំងពីរ ក្នុងបច្ចុប្បន្ននេះឯង ។

[៧៥] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅឯលំនៅ នៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ មិគសាលាឧបាសិកា ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះមិគសាលាឧបាសិកា អង្គុយក្នុងទីសមគួរហើយ ក៏បានទូលសួរព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើៗ គ្នាក្នុងបរលោក ។

៣០១



បិតា មេ ភន្តេ បុរាណោ ព្រហ្មចារី អហោសិ អារាចារី[១] វិរតោ មេថុនា គាមធម្មា សោ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ[២] តុសិតំ កាយំ ឧបបន្នោតិ ។ បិតុ បិយោ[៣] មេ ភន្តេ ឥសិទត្តោ អព្រហ្មចារី អហោសិ សទារសន្តុដ្ឋោ សោបិ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ ។ កថំកថា នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយន្តិ ។ ឯវមេវ ខោ បនេតំ ភគិនិ ភគវតា ព្យាកតន្តិ ។ អថខោ អាយស្មា អានន្ទោ មិគសាលាយ ឧបាសិកាយ និវេសនេ បិណ្ឌបាតំ គហេត្វា ឧដ្ឋាយាសនា បក្កាមិ ។

---

១ ម. ហោតិ អនាចារី ។ ២ ម. សកទាគាមិបត្តោ ។ ៣ ឱ. បេត្តា បិយោ ម. បិតាមហោ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន បិតារបស់ខ្ញុំឈ្មោះបុរាណៈជាព្រហ្មចារី ជាអ្នកប្រព្រឹត្តឆ្ងាយវៀរចាកមេថុនជាធម៌របស់អ្នកស្រុក លុះគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថាជាសកទាគាមិសត្វ បានទៅកើតក្នុងពពួកទេវតាក្នុងជាន់តុសិត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ឥសិទត្តជាទីស្រឡាញ់របស់បិតានៃខ្ញុំ មិនមែនជាព្រហ្មចារី នៅត្រេកអរដោយប្រពន្ធរបស់ខ្លួន លុះធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថាជាសកទាគាមិសត្វ បានទៅកើតក្នុងពពួកទេវតា ជាន់តុសិតដែរ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួកគឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើ ៗ គ្នា ក្នុងបរលោក ។ ម្នាលនាង ដំណើរនេះព្រះមានព្រះភាគទ្រង់ព្យាករហើយ យ៉ាងនេះឯង ។ លំដាប់នោះ ព្រះអានន្ទ ដ៏មានអាយុ ទទួលចង្ហាន់បិណ្ឌបាត ក្នុងលំនៅនៃមិគសាលាឧបាសិការួចហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។

អថខោ អាយស្មា អានន្ទោ បច្ឆាភត្តំ បិណ្ឌ-
ចាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ
ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ យេន មិគសាលាយ ឧបាសិកាយ
និវេសនំ តេនុបសង្កមឹ ឧបសង្កមិត្វា បញ្ញត្តេ
អាសនេ និសីទឹ ។ អថខោ ភន្តេ មិគសាលា
ឧបាសិកា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា
មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នា ខោ ភន្តេ មិគសាលា ឧបាសិកា មំ
ឯតទវោច កថំកថា នាមាយំ ភន្តេ អានន្ទ
ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ
នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ
សមសមគតិកា ភវិស្សន្តិ អភិសម្បរាយំ ។

ក៏កាលដែលព្រះអានន្ទដ៏មានអាយុ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទ ដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅឯលំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ មិគសាលាឧបាសិកា ចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយថ្វាយបង្គំខ្ញុំព្រះអង្គ ហើយអង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះមិគសាលាឧបាសិកា អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងខ្ញុំព្រះអង្គថា បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើ ៗ គ្នា ក្នុងបរលោក ។

៣០៣

បិតា មេ ភន្តេ បុរាណោ ព្រហ្មចារី អហោសិ អារាចារី វិរតោ មេថុនា គាមធម្មា សោ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ ។ បិតុ បិយោ មេ ភន្តេ ឥសិទត្តោ អព្រហ្មចារី អហោសិ សទារសន្តុដ្ឋោ សោបិ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ ។ កថំកថា នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយន្តិ ។ ឯវំ វុត្តេ អហំ ភន្តេ មិគសាលំ ឧបាសិកំ ឯតទវោចំ ឯវមេវ ខោ[១] បនេតំ ភគិនិ ភគវតា ព្យាកតន្តិ ។ កា ចានន្ទ មិគសាលា ឧបាសិកា ពាលា អព្យត្តា អន្ធកា អន្ធកបញ្ញា[២]

---

១ ឱ. ម. ឯវំ ខោ ។ ២ ឱ. អម្ពកា អម្ពកបញ្ញា ។ ម. អម្មកា អម្មកបញ្ញា ។ អដ្ឋកថាយំ អម្ពកា អម្ពកសញ្ញាតិ ទិស្សតិ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន បិតាខ្ញុំឈ្មោះបុរាណៈជាព្រហ្មចារី ជាអ្នកប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក លុះគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករ ថាជាសកទាគាមិសត្វ បានទៅកើត ក្នុងពួកទេវតាជាន់តុសិត ។ បពិត្រលោកម្ចាស់ ដ៏ចម្រើន ឥសិទត្ត ជាទីស្រឡាញ់នៃបិតារបស់ខ្ញុំ មិនមែនជាព្រហ្មចារីនៅត្រេកអរដោយប្រពន្ធរបស់ខ្លួន លុះគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថាជាសកទាគាមិសត្វ បានទៅកើតក្នុងពពួកទេវតាជាន់តុសិតដែរ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយនេះ តើគប្បីយល់ដូចម្តេច ព្រោះដូចជាបុគ្គលពីរពួកគឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ សឹងមានគតិស្មើ ៗ គ្នា ក្នុងបរលោក ។ បពិត្រព្រះអង្គដ៏ចម្រើន កាលមិគសាលាឧបាសិកា និយាយយ៉ាងនេះរួចហើយ ខ្ញុំព្រះអង្គក៏បាននិយាយនឹងមិគសាលាឧបាសិកាដូច្នេះថា ម្នាលនាង ដំណើរនេះព្រះដ៏មានព្រះភាគទ្រង់ព្យាករយ៉ាងហ្នឹងឯង ។ ម្នាលអានន្ទ មិគសាលា-ឧបាសិកាជាអ្វី ជាស្ត្រីពាល មិនឈ្លាសវៃ ជាស្ត្រី ផងឹត មានបញ្ញា ផងឹត

កោ ច បុរិសបុគ្គលា បរោបរិយញ្ញាណោ[១] ។ ទសយិមេ អានន្ទ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ទស ។ ឥធានន្ទ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តំ ទុស្សីល្យំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ[២] វិមុត្តឹ ន លភតិ សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ តញ្ច ចេតោ-វិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តំ ទុស្សីល្យំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ

---

១ ឱ. ម. បុរិសបុគ្គលបរោបរិយេ ញាណោ ។ ២ ឱ. ម. សាមាយិកំបិ ។

មួយទៀត បុរសបុគ្គលណា (មានវិស័យមិនទើសទាល់) ក្នុងបរោបរិយ-
ញ្ញាណ (បញ្ញាជាគ្រឿងដឹងនូវឥន្ទ្រិយក្លានិងទន់របស់បុគ្គលដទៃ) ។
ម្នាលអានន្ទ បុគ្គល ១០ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល
ទាំង ១០ ពួក តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោក
នេះ ជាអ្នកទ្រុស្តសីល ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញា-
វិមុត្តិនោះ ដែលជាហេតុនាំឲ្យភាពទ្រុស្តសីលនោះ រលត់ទៅដោយ
មិនមានសេសសល់ បុគ្គលនោះមិនបានធ្វើដោយការស្តាប់ផង មិនបាន
ធ្វើដោយភាវៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវ
វិមុត្តិដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយ
ស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ
ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្ត ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង
មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុង
លោកនេះ ជាអ្នកទ្រុស្តសីលតែដឹងច្បាស់ តាមពិតនូវចេតោវិមុត្តិនិងបញ្ញា-
វិមុត្តិនោះ ដែលជាហេតុនាំឲ្យភាពទ្រុស្តសីលនោះ រលត់ទៅដោយមិន
មានសេសសល់បុគ្គលនោះ ធ្វើដោយការស្តាប់ផង ភាវៈចេះដឹងច្រើនផង

ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។ តត្រានន្ទ បមាណិកា បមិនន្តិ ឥមស្សាបិ តេ វ ធម្មា អបរស្សាបិ តេ វ ធម្មា កស្មា នេសំ ឯកោ ហីនោ ឯកោ បណីតោតិ ។ តញ្ហិ តេសំ អានន្ទ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ តត្រានន្ទ យ្វាយំ បុគ្គលោ ទុស្សីលោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តំ ទុស្សីល្យំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ ។ អយំ អានន្ទ បុគ្គលោ អមុនា បុរិមេន បុគ្គលេន អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។

ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេសមិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកនូវប្រមាណក្នុងបុគ្គលនោះ អាចត្រិះរិះថា នោះជាធម៌ របស់បុគ្គលនេះ នោះជាធម៌ របស់បុគ្គលដទៃ បណ្តាបុគ្គលទាំងនោះ ហេតុអ្វីបានជាបុគ្គលម្នាក់ថោកទាប បុគ្គលម្នាក់ខ្ពង់ខ្ពស់ ។ ម្នាលអានន្ទ ព្រោះកិរិយាធ្វើនូវប្រមាណនោះ របស់បុគ្គល ទាំងនោះ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ។ ម្នាលអានន្ទ ក្នុងដំណើរនោះ បុគ្គលណាទ្រុស្តសីល តែដឹងច្បាស់ តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ជាហេតុនាំឲ្យភាពទ្រុស្តសីលនោះ រលត់ទៅ ដោយមិនសេសសល់ បុគ្គលនោះ ធ្វើការដោយការស្តាប់ផង ធ្វើដោយភាវៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិប្រព្រឹត្តទៅ តាមកាលផង ។ ម្នាលអានន្ទ បុគ្គលនេះប្រសើរផង ឧត្តមផង ជាងបុគ្គលមុនឯណោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

ឥមញ្ហិ អានន្ទ បុគ្គលំ ធម្មសោតោ និព្ពហតិ តទន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតេន ។ តស្មាតិហានន្ទ មា បុគ្គលេសុ បមាណិកា អហុវត្ថ មា បុគ្គលេសុ បមាណំ គណ្ហិត្ថ ។ ខញ្ញតិ ហានន្ទ បុគ្គលោ បុគ្គលេសុ បមាណំ គណ្ហន្តោ អហញ្ចានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ សីលវា ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តំ សីលំ អបរិ-សេសំ និរុជ្ឈតិ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ ន លភតិ សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។

ម្នាលអានន្ទ ព្រោះក្រសែធម៌គឺវិបស្សនាញាណ រមែងដឹកនាំបុគ្គលនេះ (ឲ្យដល់នូវអរិយភូមិ) អ្នកណាក្រៅពីតថាគតនឹងគប្បីដឹង ហេតុនោះបាន ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងលោកនេះ អ្នកទាំង-ឡាយ ជាអ្នកកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ កុំមានឡើយ កុំកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយឡើយ ។ ម្នាលអានន្ទ បុគ្គលក្នុងលោកនេះ កាលកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ ឈ្មោះថាជីករំលើងនូវគុណ ម្នាលអានន្ទ តថាគតក្តី បុគ្គលណាដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសីល តែមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសីលនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះមិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយភាវៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះ ដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលប្រព្រឹត្តតាមកាលផង លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យមិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសឡើយ ។

ឥធានន្ទ ឯកច្ចោ បុគ្គលោ សីលវា ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តំ សីលំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។ តត្រានន្ទ ។ បេ ។ អហញ្ចានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ តិព្វរាគោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស សោ រាគោ អបរិសេសោ និរុជ្ឈតិ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ ន លភតិ

ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសីល ទាំងដឹងច្បាស់តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុ នាំឲ្យសីលនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ ធ្វើដោយការស្តាប់ផង ធ្វើដោយការៈចេះដឹងច្រើនផង ចាក់ធ្លុះ ដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ ក្នុងដំណើរនោះ ។ បេ ។ ម្នាលអានន្ទ តថាគតក្តី បុគ្គលដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានរាគៈក្លៀវក្លា ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យរាគៈនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះមិនបានធ្វើ ដោយការស្តាប់ផង មិនបានធ្វើ ដោយការៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបានវិមុត្តិ ដែលប្រព្រឹត្តទៅ តាមកាលផង

សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ តិព្វរាគោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស សោ រាគោ អបរិសេសោ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។ តត្រានន្ទ ។ បេ ។ អហញ្ចានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ កោធនោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស សោ កោធោ អបរិសេសោ និរុជ្ឈតិ

លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានរាគៈក្លៀវក្លា តែដឹងច្បាស់ តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យរាគៈនោះ រលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះធ្វើដោយការស្តាប់ផង ធ្វើដោយភាវៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ដែលប្រព្រឹត្តទៅ តាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ ក្នុងដំណើរនោះ ។ បេ ។ ម្នាលអានន្ទ តថាគតក្តី បុគ្គលណា ដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធទាំងមិនដឹងច្បាស់ តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសេចក្តីក្រោធនោះ រលត់ទៅ ដោយមិនមានសេសសល់

តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ ន លភតិ សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ កោធនោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស សោ កោធោ អបរិសេសោ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។ តត្រានន្ទ ។ បេ ។ អហញ្ចានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។

បុគ្គលនោះមិនបានធ្វើ ដោយការស្តាប់ផង មិនបានធ្វើ ដោយភាវៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះ ដោយទិដ្ឋិផង មិនបាននូវវិមុត្តិដែលប្រព្រឹត្តទៅ តាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធ តែដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសេចក្តីក្រោធនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះធ្វើ ដោយការស្តាប់ផង ធ្វើដោយភាវៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅ តាមកាលផង លុះបុគ្គលនោះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។ ម្នាលអានន្ទ ក្នុងដំណើរនោះ ។ បេ ។ ម្នាលអានន្ទ តថាគតក្តី បុគ្គលណា ដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។

ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ ឧទ្ធតោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តំ ឧទ្ធច្ចំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ ន លភតិ សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ ឧទ្ធតោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តំ ឧទ្ធច្ចំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។

ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានចិត្តរវើរវាយ ទាំងមិនដឹងច្បាស់ តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យសេចក្តីរវើរវាយនោះរលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ មិនបានធ្វើ ដោយការស្តាប់ផង មិនបានធ្វើ ដោយភាវៈចេះដឹងច្រើនផង មិនបានចាក់ធ្លុះ ដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលប្រព្រឹត្តទៅតាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេសទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង មិនប្រព្រឹត្តទៅដើម្បីគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះជាអ្នកមានចិត្តរវើរវាយ តែដឹងច្បាស់ តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យចិត្តរវើរវាយនោះ រលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះ ធ្វើដោយការស្តាប់ផង ធ្វើដោយភាវៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ដែលប្រព្រឹត្តទៅ តាមកាលផង លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យទេ ជាបុគ្គលប្រព្រឹត្តទៅ ដើម្បីគុណវិសេសតែម្យ៉ាង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យឡើយ ។

៣១១



តត្រានន្ទ បមាណិកា បមិនន្តិ ឥមស្សាបិ តេ វ ធម្មា អបរស្សាបិ តេ វ ធម្មា កស្មា នេសំ ឯកោ ហីនោ ឯកោ បណីតោតិ ។ តញ្ហិ តេសំ អានន្ទ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ តត្រានន្ទ យ្វាយំ បុគ្គលោ ឧទ្ធតោ ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តំ ឧទ្ធច្ចំ អបរិសេសំ និរុជ្ឈតិ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិ-យាបិ សុប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ លភតិ ។ អយំ អានន្ទ បុគ្គលោ អមុនា បុរិមេន បុគ្គលេន អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ ឥមញ្ហិ អានន្ទ បុគ្គលំ ធម្មសោតោ និព្ពហតិ តទនន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតេន ។ តស្មាតិហានន្ទ មា បុគ្គលេសុ បមា-ណិកា អហុវត្ថ មា បុគ្គលេសុ បមាណំ គណ្ហិត្ថ ។

ម្នាលអានន្ទ បុគ្គលអ្នកកាន់យកនូវប្រមាណ ក្នុងបុគ្គលនោះ រមែងត្រិះរិះថា នោះជាធម៌របស់បុគ្គលនេះ នោះជាធម៌របស់បុគ្គលដទៃ បណ្តាបុគ្គលទាំងនោះ ហេតុអ្វីបានជាបុគ្គលម្នាក់ថោកទាប បុគ្គលម្នាក់ខ្ពង់ខ្ពស់ ។ ម្នាលអានន្ទ ព្រោះកិរិយាធ្វើនូវប្រមាណនោះ របស់បុគ្គលទាំងនោះ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ។ ម្នាលអានន្ទ ក្នុងដំណើរនោះ បុគ្គលណាជាអ្នកមានចិត្តរវើរវាយ តែដឹងច្បាស់ តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាហេតុនាំឲ្យចិត្តរវើរវាយនោះ រលត់ទៅ ដោយមិនមានសេសសល់ បុគ្គលនោះធ្វើដោយការស្តាប់ផង ធ្វើដោយការៈចេះដឹងច្រើនផង ចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលប្រព្រឹត្តទៅ តាមកាលផង ។ ម្នាលអានន្ទ បុគ្គលនេះ ប្រសើរផង ឧត្តមផង ជាងបុគ្គលមុនឯណោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាក្រសែធម៌ រមែងដឹកនាំបុគ្គលនោះ (ឲ្យដល់នូវអរិយភូមិ) អ្នកណាក្រៅពីព្រះតថាគត នឹងគប្បីដឹងហេតុនោះបាន ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងលោកនេះ អ្នកទាំងឡាយជាអ្នកកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ កុំមានឡើយ កុំកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយឡើយ ។

ខញ្ញតិ ហានន្ទ បុគ្គលោ បុគ្គលេសុ បមាណំ គណ្ហន្តោ អហញ្ចានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។ កា ចានន្ទ មិគសាលា ឧបាសិកា ពាលា អព្យត្តា អន្ធកា អន្ធកបញ្ញា កេ ច បុរិសបុគ្គលា បរោ-បរិយញ្ញាណោ ។ ឥមេ ខោ អានន្ទ ទស បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ យថារូបេន អានន្ទ សីលេន បុរាណោ សមន្នាគតោ អហោសិ តថារូបេន សីលេន ឥសិទត្តោ សមន្នាគតោ អភវិស្ស ។ នយិទ បុរាណោ ឥសិទត្តស្ស គតិបិ[1] អញ្ញស្ស យថារូបាយ អានន្ទ បញ្ញាយ ឥសិទត្តោ សមន្នាគតោ អហោសិ តថារូបាយ បញ្ញាយ បុរាណោ សមន្នាគតោ អភវិស្ស ។ នយិទ ឥសិទត្តោ បុរាណស្ស គតិបិ អញ្ញស្ស ។ ឥតិ ខោ អានន្ទ ឥមេ បុគ្គលា ឧភោ ឯកង្គហីនាតិ ។

១ ឱ. គតិម្បិ ។

ម្នាលអានន្ទ បុគ្គលក្នុងលោកនេះ កាលកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយ ឈ្មោះថាជីករំលើងនូវគុណ ម្នាលអានន្ទ តថាគតក្តី បុគ្គលណាដែលប្រហែលនឹងតថាគតក្តី ទើបគួរកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ។ ម្នាលអានន្ទ មិគសាលាឧបាសិកា ជាអ្វី ជាស្ត្រីពាល មិនឈ្លាសវៃ ជាស្ត្រី ធំធឹត មានបញ្ញា ធំធឹត មួយទៀតបុរសបុគ្គលណា (មានវិស័យមិនទើសទាល់) ក្នុងបរោបរិយញ្ញាណ (បញ្ញាជាគ្រឿងដឹងនូវឥន្ទ្រិយក្លានិងទន់របស់បុគ្គលដទៃ) ។ ម្នាលអានន្ទ បុគ្គល ១០ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។ ម្នាលអានន្ទ ឧបាសកឈ្មោះបុរាណៈ ប្រកបដោយសីលមានសភាពយ៉ាងណា ឥសិ-ទត្ត ក៏ប្រកបដោយសីលមានសភាពយ៉ាងនោះដែរ ។ បុរាណ-ឧបាសក ក្នុងលោកនេះមានគតិ មិនប្លែកអំពីឥសិទត្តទេ ម្នាលអានន្ទ ឥសិទត្ត ប្រកបដោយបញ្ញាមានសភាពយ៉ាងណា បុរាណឧបាសកប្រកបដោយបញ្ញាមានសភាពយ៉ាងនោះដែរ ។ ឥសិទត្តឧបាសកក្នុងលោកនេះ មានគតិ មិនប្លែកអំពីបុរាណឧបាសកទេ ។ ម្នាលអានន្ទ បុគ្គលទាំងពីរនេះ ថោកទាបដោយគុណធម៌មួយ ៗ ម្នាក់ ៗ

[៧៦] តយោមេ ភិក្ខវេ ធម្មា លោកេ ន សំវិជ្ជេយ្យុំ ន តថាគតោ លោកេ ឧប្បជ្ជេយ្យ អរហំ សម្មាសម្ពុទ្ធោ ន តថាគតប្បវេទិតោ ធម្មវិនយោ លោកេ ទីបេយ្យ ។ កតមេ តយោ ។ ជាតិ ច ជរា ច មរណញ្ច ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា លោកេ ន សំវិជ្ជេយ្យុំ ន តថាគតោ លោកេ ឧប្បជ្ជេយ្យ អរហំ សម្មាសម្ពុទ្ធោ ន តថាគតប្បវេទិតោ ធម្មវិនយោ លោកេ ទីបេយ្យ ។ យស្មា ច ខោ ភិក្ខវេ ឥមេ តយោ ធម្មា លោកេ សំវិជ្ជន្តិ តស្មា តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ តស្មា តថាគតប្បវេទិតោ ធម្មវិនយោ លោកេ ទិប្បតិ ។ តយោ[១] ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ជាតឹ បហាតុំ ជរំ បហាតុំ មរណំ បហាតុំ ។ កតមេ តយោ ។ រាគំ អប្បហាយ ទោសំ អប្បហាយ មោហំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ

១ ឱ. តយោមេ ។

[៧៦] ម្នាលភិក្ខុទាំងឡាយ (ប្រសិនបើ) ធម៌ទាំងនោះ មិនមានក្នុងលោកទេ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក៏មិនគប្បីកើតឡើងក្នុងលោកឡើយ ទាំងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ ក៏មិនភ្លឺច្បាស់ក្នុងលោកដែរ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺជាតិ ១ ជរា ១ មរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ (ប្រសិនបើ) ធម៌ទាំង ៣ នេះ មិនមានក្នុងលោកទេ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធក៏មិនគប្បីកើតឡើងក្នុងលោក ទាំងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ ក៏មិនភ្លឺច្បាស់ក្នុងលោកនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ នេះ រមែងមានក្នុងលោក ព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោក ព្រោះហេតុនោះ ទើបធម្ម-វិន័យ ដែលព្រះតថាគតសម្តែងហើយ ភ្លឺច្បាស់ក្នុងលោកដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់រាគៈ ១ មិនលះបង់ទោសៈ ១ មិនលះបង់មោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ នេះចេញហើយ

អភព្វោ ជាតឹ បហាតុំ ជរំ បហាតុំ មរណំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ អប្ប-ហាយ អភព្វោ រាគំ បហាតុំ ទោសំ បហាតុំ មោហំ បហាតុំ ។ កតមេ តយោ ។ សក្កាយទិដ្ឋឹ អប្បហាយ វិចិកិច្ឆំ អប្បហាយ សីលព្វតបរាមាសំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ អភព្វោ រាគំ បហាតុំ ទោសំ បហាតុំ មោហំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ សក្កាយទិដ្ឋឹ បហាតុំ វិចិកិច្ឆំ បហាតុំ សីលព្វតបរាមាសំ បហាតុំ ។ កតមេ តយោ ។ អយោនិសោ មនសិការំ អប្បហាយ កុម្មគ្គសេវនំ អប្បហាយ ចេតសោ លីនត្តំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ អភព្វោ សក្កាយទិដ្ឋឹ បហាតុំ វិចិកិច្ឆំ បហាតុំ សីលព្វតបរាមាសំ បហាតុំ ។

មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានទេ ។ ម្នាល ភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរ លះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់សក្កាយទិដ្ឋិ ១ មិនលះបង់វិចិកិច្ឆា ១ មិន លះបង់សីលព្វតបរាមាសៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិន លះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនលះបង់ធម៌ ទាំង ៣ ហើយ មិនគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់ សីលព្វតបរាមាសៈបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់ នូវការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ១ មិនលះបង់នូវកិរិយាសេពគប់ នូវផ្លូវខុស ១ មិនលះបង់នូវភាពរួញរានៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះចេញហើយ មិនគួរលះបង់ សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសៈបានទេ ។

តយោ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អយោ-
និសោ មនសិការំ បហាតុំ កុម្មគ្គសេវនំ បហាតុំ
ចេតសោ លីនត្តំ បហាតុំ ។ កតមេ តយោ ។
មុដ្ឋស្សច្ចំ អប្បហាយ អសម្បជញ្ញំ អប្បហាយ
ចេតសោ វិក្ខេបំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ
តយោ ធម្មេ អប្បហាយ អភព្វោ អយោនិសោ
មនសិការំ បហាតុំ កុម្មគ្គសេវនំ បហាតុំ ចេតសោ
លីនត្តំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ អប្ប-
ហាយ អភព្វោ មុដ្ឋស្សច្ចំ បហាតុំ អសម្បជញ្ញំ
បហាតុំ ចេតសោ វិក្ខេបំ បហាតុំ ។ កតមេ
តយោ ។ អរិយានំ អទស្សនកម្យតំ អប្បហាយ
អរិយធម្មំ អសោតុកម្យតំ អប្បហាយ ឧបារម្ភចិត្តតំ
អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ
អប្បហាយ អភព្វោ មុដ្ឋស្សច្ចំ បហាតុំ អសម្បជញ្ញំ
បហាតុំ ចេតសោ វិក្ខេបំ បហាតុំ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវភាពរួញរាទៃចិត្តបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់ការភ្លេចស្មារតី ១ មិនលះបង់សេចក្តីមិនដឹងខ្លួន ១ មិនលះបង់សេចក្តីរវើរវាយនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវភាពរួញរាទៃចិត្តបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ ១ មិនលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ ១ មិនលះបង់នូវភាពនៃចិត្តប្រកាន់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយ នៃចិត្តបានទេ ។

តយោ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អរិយានំ អធស្សនកាម្យតំ បហាតុំ អរិយធម្មំ អសោតុកាម្យតំ បហាតុំ ឧបារម្ភចិត្តតំ បហាតុំ ។ កតមេ តយោ ។ ឧទ្ធច្ចំ អប្បហាយ អសំវរំ អប្បហាយ ទុស្សីល្យំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ អភព្វោ អរិយានំ អធស្សនកាម្យតំ បហាតុំ អរិយធម្មំ អសោតុកាម្យតំ បហាតុំ ឧបារ-ម្ភចិត្តតំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ អប្ប-ហាយ អភព្វោ ឧទ្ធច្ចំ បហាតុំ អសំវរំ បហាតុំ ទុស្សីល្យំ បហាតុំ ។ កតមេ តយោ ។ អស្សទ្ធិយំ អប្បហាយ អវទញ្ញុតំ អប្បហាយ កោសជ្ជំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ អភព្វោ ឧទ្ធច្ចំ បហាតុំ អសំវរំ បហាតុំ ទុស្សីល្យំ បហាតុំ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ចេញហើយ មិនគួរលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំង-ឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវសេចក្តីរវើរវាយ ១ មិនលះបង់នូវសេចក្តីមិនសង្រួម ១ មិនលះបង់នូវភាពទ្រុស្តសីល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ទាំងឡាយ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវចិត្តរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវភាពមិនមានសទ្ធា ១ មិនលះបង់នូវភាពមិនដឹងនូវពាក្យពោល ១ មិនលះបង់នូវសេចក្តីខ្ជិល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ ៣ នេះហើយ មិនគួរលះបង់នូវសេចក្តីរវើ-រវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ ។

៣១៧

ទុតិយបណ្ណាសកេ អាកង្ខវគ្គោ

តយោ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អស្សទ្ធិយំ បហាតុំ អវទញ្ញុតំ បហាតុំ កោសជ្ជំ បហាតុំ ។ កតមេ តយោ ។ អនាទរិយំ អប្បហាយ ទោវចស្សតំ អប្បហាយ បាបមិត្តតំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ អភព្វោ អស្សទ្ធិយំ បហាតុំ អវទញ្ញុតំ បហាតុំ កោសជ្ជំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អនាទរិយំ បហាតុំ ទោវចស្សតំ បហាតុំ បាបមិត្តតំ បហាតុំ ។ កតមេ តយោ ។ អហិរិកំ អប្បហាយ អនោត្តប្បំ អប្បហាយ បមាទំ អប្បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ អប្បហាយ អភព្វោ អនាទរិយំ បហាតុំ ទោវចស្សតំ បហាតុំ បាបមិត្តតំ បហាតុំ ។ អហិរិកោយំ ភិក្ខវេ អនោត្តប្បី បមត្តោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ចេញហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្តីខ្ជិលបានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវសេចក្តីមិនអើពើ ១ មិនលះបង់នូវភាពជាអ្នកប្រដៅក្រ ១ មិនលះបង់នូវភាពនៃបាបមិត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្តីខ្ជិលបានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនបានលះបង់ធម៌ទាំង ៣ ហើយ មិនគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់ភាពនៃបាបមិត្របានទេ ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺមិនលះបង់នូវសេចក្តីមិនអៀនខ្មាសនឹងអំពើទុច្ចរិត ១ មិនលះបង់នូវសេចក្តីក្តៅក្រហាយនឹងអំពើទុច្ចរិត ១ មិនលះបង់នូវសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះបង់ធម៌ទាំង ៣ នេះហើយ មិនគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្របានទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះជាអ្នកមិនមានសេចក្តីអៀនខ្មាស មិនមានសេចក្តីក្តៅក្រហាយនឹងអំពើទុច្ចរិត ជាអ្នកប្រមាទ ។

សោ បមត្តោ សមានោ អភព្វោ អជានិយំ បហាតុំ ទោវចស្សតំ បហាតុំ ចាបមិត្តតំ បហាតុំ ។ សោ ចាបមិត្តោ សមានោ អភព្វោ អស្សទ្ធិយំ បហាតុំ អវទញ្ញុតំ បហាតុំ កោសជ្ជំ បហាតុំ ។ សោ កុសីតោ សមានោ អភព្វោ ឧទ្ធច្ចំ បហាតុំ អសំវរំ បហាតុំ ទុស្សីល្យំ បហាតុំ ។ សោ ទុស្សីលោ សមានោ អភព្វោ អរិយានំ អទស្សនកម្យតំ បហាតុំ អរិយធម្មំ អសោតុកម្យតំ បហាតុំ ឧបារម្ភចិត្តតំ បហាតុំ ។ សោ ឧបារម្ភចិត្តោ សមានោ អភព្វោ មុដ្ឋស្សច្ចំ បហាតុំ អសម្បជញ្ញំ បហាតុំ ចេតសោ វិក្ខិត្តចិត្តតំ[១] បហាតុំ ។ សោ វិក្ខិត្តចិត្តោ សមានោ អភព្វោ អយោនិសោ មនសិការំ បហាតុំ កុម្មគ្គសេវនំ បហាតុំ ចេតសោ លីនត្តំ បហាតុំ ។ សោ លីនចិត្តោ សមានោ អភព្វោ សក្កាយទិដ្ឋឹ បហាតុំ វិចិកិច្ឆំ បហាតុំ

---

១ ឱ. វិក្ខេបំ ។

កាលបើបុគ្គលនោះ ជាអ្នកប្រមាទហើយ មិនគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្របានទេ ។ កាលបើបុគ្គលនោះមានបាបមិត្រហើយ មិនគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹងពាក្យពោល លះបង់នូវសេចក្តីខ្ជិលបានទេ ។ កាលបើបុគ្គលនោះមានសេចក្តីខ្ជិលហើយ មិនគួរលះបង់នូវសេចក្តីរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបានទេ ។ កាលបើបុគ្គលនោះមានភាពជាអ្នកទ្រុស្តសីលហើយ មិនគួរលះបង់ភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនឃើញព្រះអរិយៈទាំងឡាយ លះបង់នូវភាពនៃសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយ-ធម៌ លះបង់នូវភាពនៃចិត្តប្រកួតប្រកាន់បានទេ ។ កាលបើបុគ្គលនោះមានភាពនៃចិត្តប្រកួតប្រកាន់ហើយ មិនគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវចិត្តរវើរវាយបានទេ ។ កាលបើបុគ្គលនោះ មានចិត្តរវើរវាយហើយ មិនគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវកិរិយាសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបានទេ ។ កាលបើបុគ្គលនោះ មានចិត្តរួញរា មិនគួរលះបង់នូវសក្កាយទិដ្ឋិ លះបង់នូវវិចិកិច្ឆា

៣១៩



សីលព្វតបរាមាសំ បហាតុំ ។ សោ វិចិកិច្ឆោ សមានោ អភព្វោ រាគំ បហាតុំ ទោសំ បហាតុំ មោហំ បហាតុំ ។ រាគំ អប្បហាយ ទោសំ អប្បហាយ មោហំ អប្បហាយ អភព្វោ ជាតឹ បហាតុំ ជរំ បហាតុំ មរណំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ ជាតឹ បហាតុំ ជរំ បហាតុំ មរណំ បហាតុំ ។ កតមេ តយោ ។ រាគំ បហាយ ទោសំ បហាយ មោហំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ ជាតឹ បហាតុំ ជរំ បហាតុំ មរណំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ រាគំ បហាតុំ ទោសំ បហាតុំ មោហំ បហាតុំ ។ កតមេ តយោ ។ សក្កាយទិដ្ឋឹ បហាយ វិចិកិច្ឆំ បហាយ សីលព្វតបរាមាសំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ រាគំ បហាតុំ ទោសំ បហាតុំ មោហំ បហាតុំ ។

លះបង់នូវសីលព្វតបរាមាសៈបានទេ ។ កាលបើបុគ្គលនោះមានវិចិកិច្ឆា មិនគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបានទេ ។ កាលបើមិនបានលះបង់រាគៈ មិនបានលះបង់ទោសៈ មិនបានលះបង់មោហៈ មិនគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន ។ ធម៌ទាំង ៣ តើដូចម្តេចខ្លះ ។ គឺលះបង់រាគៈ ១ លះបង់ទោសៈ ១ លះបង់មោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ទាំង ៣ នេះចេញបានហើយ ទើបគួរលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់សក្កាយទិដ្ឋិ ១ លះបង់វិចិកិច្ឆា ១ លះបង់សីលព្វតបរាមាសៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន ។

តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ សក្កាយទិដ្ឋឹ បហាតុំ វិចិកិច្ឆំ បហាតុំ សីលព្វតបរាមាសំ បហាតុំ ។ កតមេ តយោ ។ អយោនិសោ មនសិការំ បហាយ កុម្មគ្គសេវនំ បហាយ ចេតសោ លីនត្តំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ សក្កាយទិដ្ឋឹ បហាតុំ វិចិកិច្ឆំ បហាតុំ សីលព្វតបរាមាសំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ អយោនិសោ មនសិការំ បហាតុំ កុម្មគ្គសេវនំ បហាតុំ ចេតសោ លីនត្តំ បហាតុំ ។ កតមេ តយោ ។ មុដ្ឋស្សច្ចំ បហាយ អសម្បជញ្ញំ បហាយ ចេតសោ វិក្ខេបំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ អយោនិសោ មនសិការំ បហាតុំ កុម្មគ្គសេវនំ បហាតុំ ចេតសោ លីនត្តំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ មុដ្ឋស្សច្ចំ បហាតុំ អសម្បជញ្ញំ បហាតុំ ចេតសោ វិក្ខេបំ បហាតុំ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសៈបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់ការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ១ លះបង់ការសេពគប់ផ្លូវខុស ១ លះបង់សេចក្តីរួញរានៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់សក្កាយទិដ្ឋិ លះបង់វិចិកិច្ឆា លះបង់សីលព្វតបរាមាសៈបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់ការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវការសេព-គប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវការភ្លេចស្មារតី ១ លះបង់នូវសេចក្តីមិនដឹងខ្លួន ១ លះបង់នូវសេចក្តីរវើរវាយនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរវើរវាយនៃចិត្តបាន ។

៣២១



កតមេ តយោ ។ អរិយានំ អទស្សនកាមតំ បហាយ អរិយធម្មំ អសោតុកាមតំ បហាយ ឧបារម្ភចិត្តតំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ មុដ្ឋស្សច្ចំ បហាតុំ អសម្បជញ្ញំ បហាតុំ ចេតសោ វិក្ខេបំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ អរិយានំ អទស្សនកាមតំ បហាតុំ អរិយធម្មំ អសោតុកាមតំ បហាតុំ ឧបារម្ភចិត្តតំ បហាតុំ ។ កតមេ តយោ ។ ឧទ្ធច្ចំ បហាយ អសំវរំ បហាយ ទុស្សីល្យំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ អរិយានំ អទស្សនកាមតំ បហាតុំ អរិយធម្មំ អសោតុកាមតំ បហាតុំ ឧបារម្ភចិត្តតំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ ឧទ្ធច្ចំ បហាតុំ អសំវរំ បហាតុំ ទុស្សីល្យំ បហាតុំ ។

ធម៌ទាំង ៣ តើដូចម្ដេច ។ គឺលះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ ១ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ ១ លះបង់នូវចិត្តប្រកួតប្រកាន់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្ដីមិនដឹងខ្លួន លះបង់នូវសេចក្ដីរវើរវាយនៃចិត្តបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់សេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន ។ ធម៌ទាំង ៣ តើដូចម្ដេច ។ គឺលះបង់នូវសេចក្ដីរវើរវាយ ១ លះបង់នូវសេចក្ដីមិនសង្រួម ១ លះបង់នូវភាពទ្រុស្តសីល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្ដីប្រាថ្នា ដើម្បីមិនស្ដាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្ដីរវើរវាយ លះបង់នូវសេចក្ដីមិនសង្រួម លះបង់នូវភាពទ្រុស្តសីល ។

កតមេ តយោ ។ អស្សទ្ធិយំ បហាយ អវទញ្ញុតំ បហាយ កោសជ្ជំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ ឧទ្ធច្ចំ បហាតុំ អសំវរំ បហាតុំ ទុស្សីល្យំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ អស្សទ្ធិយំ បហាតុំ អវទញ្ញុតំ បហាតុំ កោសជ្ជំ បហាតុំ ។ កតមេ តយោ ។ អនាទរិយំ បហាយ ទោវចស្សតំ បហាយ បាបមិត្តតំ បហាយ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ អស្សទ្ធិយំ បហាតុំ អវទញ្ញុតំ បហាតុំ កោសជ្ជំ បហាតុំ ។ តយោ ភិក្ខវេ ធម្មេ បហាយ ភព្វោ អនាទរិយំ បហាតុំ ទោវចស្សតំ បហាតុំ បាបមិត្តតំ បហាតុំ ។ កតមេ តយោ ។ អហិរិកំ បហាយ អនោត្តប្បំ បហាយ បមាទំ បហាយ ។

ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវភាពមិនមានសទ្ធា ១ លះបង់នូវសេចក្តីមិនដឹងនូវពាក្យពោល ១ លះបង់នូវសេចក្តីខ្ជិល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ នេះបានហើយ ទើបគួរលះបង់នូវសេចក្តីរវើរវាយ លះបង់នូវសេចក្តីមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវសេចក្តីមិនដឹងនូវពាក្យពោល លះបង់នូវសេចក្តីខ្ជិលបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវសេចក្តីមិនអើពើ ១ លះបង់នូវភាពជាអ្នកប្រដៅក្រ ១ លះបង់នូវភាពនៃបាបមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវភាពមិនមានសទ្ធា លះបង់នូវភាពមិនដឹង នូវពាក្យពោល លះបង់នូវសេចក្តីខ្ជិលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន ។ ធម៌ទាំង ៣ តើដូចម្តេច ។ គឺលះបង់នូវសេចក្តីមិនអៀនខ្មាសនឹងអំពើទុច្ចរិត ១ លះបង់នូវសេចក្តីមិនក្តៅនឹងអំពើទុច្ចរិត ១ លះបង់នូវសេចក្តីធ្វេសប្រហែស ១ ។

៣២៣



ឥមេ ខោ ភិក្ខវេ តយោ ធម្មេ បហាយ ភព្វោ អនាទរិយំ បហាតុំ ទោវចស្សតំ បហាតុំ បាបមិត្តតំ បហាតុំ ។ ហិរិមាយំ ភិក្ខវេ ឱត្តប្បី អប្បមត្តោ ហោតិ ។ សោ អប្បមត្តោ សមានោ ភព្វោ អនាទរិយំ បហាតុំ ទោវចស្សតំ បហាតុំ បាបមិត្តតំ បហាតុំ ។ សោ កល្យាណមិត្តោ សមានោ ភព្វោ អស្សទ្ធិយំ បហាតុំ អវទញ្ញុតំ បហាតុំ កោសជ្ជំ បហាតុំ ។ សោ អារទ្ធវីរិយោ សមានោ ភព្វោ ឧទ្ធច្ចំ បហាតុំ អសំ-វរំ បហាតុំ ទុស្សីល្យំ បហាតុំ ។ សោ សីលវា សមានោ ភព្វោ អរិយានំ អទស្សនកម្យតំ បហាតុំ អរិយធម្មំ អសោតុកម្យតំ បហាតុំ ឧបារម្ភចិត្តតំ បហាតុំ ។ សោ អនុបារម្ភចិត្តោ សមានោ ភព្វោ មុដ្ឋស្សច្ចំ បហាតុំ អសម្បជញ្ញំ បហាតុំ ចេតសោ វិក្ខេបំ បហាតុំ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលលះបង់ធម៌ទាំង ៣ បានហើយ ទើបគួរលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាបមិត្តបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ជាអ្នកមានសេចក្តីអៀនខ្មាសនឹងអំពើទុច្ចរិត ក្តៅនឹងអំពើទុច្ចរិត មិនប្រមាទ ។ កាលបើបុគ្គលនោះ មិនប្រមាទហើយ ទើបគួរដើម្បីលះបង់នូវសេចក្តីមិនអើពើ លះបង់នូវភាពជាអ្នកប្រដៅក្រ លះបង់នូវភាពនៃបាប-មិត្តបាន ។ កាលបើបុគ្គលនោះ មានកល្យាណមិត្តហើយ ទើបគួរដើម្បីលះបង់នូវភាពមិនមានសទ្ធា លះបង់នូវសេចក្តីមិនដឹងនូវពាក្យពោល លះបង់នូវសេចក្តីខ្ជិលបាន ។ កាលបើបុគ្គលនោះ មានសេចក្តីព្យាយាមប្រារព្ធហើយ ទើបគួរ ដើម្បីលះបង់នូវសេចក្តីរវើរវាយ លះបង់នូវការមិនសង្រួម លះបង់នូវភាពទ្រុស្តសីលបាន ។ កាលបើបុគ្គលនោះមានសីល ទើបគួរ ដើម្បីលះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនឃើញនូវព្រះអរិយៈទាំងឡាយ លះបង់នូវសេចក្តីប្រាថ្នា ដើម្បីមិនស្តាប់នូវអរិយធម៌ លះបង់នូវចិត្តប្រកួតប្រកាន់បាន ។ កាលបើបុគ្គលនោះមិនមានចិត្តប្រកួតប្រកាន់ហើយ ទើបគួរ ដើម្បីលះបង់នូវការភ្លេចស្មារតី លះបង់នូវសេចក្តីមិនដឹងខ្លួន លះបង់នូវសេចក្តីរសាប់រសល់នៃចិត្តបាន ។

សោ អវិក្ខិត្តចិត្តោ សមានោ ភព្វោ អយោនិសោ មនសិការំ បហាតុំ កុម្មគ្គសេវនំ បហាតុំ ចេតសោ លីនត្តំ បហាតុំ ។ សោ អលីនចិត្តោ សមានោ ភព្វោ សក្កាយទិដ្ឋឹ បហាតុំ វិចិកិច្ឆំ បហាតុំ សីលព្វតបរាមាសំ បហាតុំ ។ សោ អវិ-ចិកិច្ឆោ សមានោ ភព្វោ រាគំ បហាតុំ ទោសំ បហាតុំ មោហំ បហាតុំ ។ [១]រាគំ បហាយ ទោសំ បហាយ មោហំ បហាយ ភព្វោ ជាតឹ បហាតុំ ជរំ បហាតុំ មរណំ បហាតុន្តិ ។

[៧៧] ទសហិ ភិក្ខវេ អសទ្ធម្មេហិ សមន្នា-គតោ កាកោ ។ កតមេហិ ទសហិ ។ ធំសី ច បគព្ភោ ច តិន្តិណោ[២] ច មហគ្ឃសោ ច លុទ្ទោ ច អការុណិកោ ច ទុព្វលោ ច ឱរវី[៣] ច មុដ្ឋ-ស្សតិ ច នេចយិកោ ច ។ ឥមេហិ ខោ ភិក្ខវេ ទសហិ អសទ្ធម្មេហិ សមន្នាគតោ កាកោ ។

១ ឱ. ម. ឯត្ថ សោតិ បាឋោ អត្ថិ ។ ២ ម. និល្លជោ ។ ៣ ឱ. ន. ឱរវិតា ។

កាលបើបុគ្គលនោះ មិនមានចិត្តរសាប់រសល់ហើយ ទើបគួរ ដើម្បីលះបង់នូវកិរិយាធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយ លះបង់នូវការសេពគប់នូវផ្លូវខុស លះបង់នូវសេចក្តីរួញរានៃចិត្តបាន ។ កាលបើបុគ្គលនោះមិនមានចិត្តរួញរាហើយ ទើបគួរ ដើម្បីលះបង់នូវសក្កាយទិដ្ឋិ លះបង់នូវវិចិកិច្ឆា លះបង់នូវសីលព្វតបរាមាសៈបាន ។ កាលបើបុគ្គលនោះមិនមានវិចិកិច្ឆាហើយ ទើបគួរ ដើម្បីលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈបាន ។ កាលបើបុគ្គលនោះ លះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈហើយ ទើបគួរ ដើម្បីលះបង់ជាតិ លះបង់ជរា លះបង់មរណៈបាន ។

[៧៧] ម្នាលភិក្ខុទាំងឡាយ ក្អែកប្រកបដោយអសទ្ធម្ម ១០ យ៉ាង ។ ប្រកបដោយអសទ្ធម្មទាំង ១០ យ៉ាង តើដូចម្តេច ។ គឺជាសត្វកម្ចាត់បង់ (នូវគុណ) ១ ក្រអឺតក្រឱង ១ មានសេចក្តីវេះវាម ១ ស៊ីច្រើន ១ អាក្រក់ ១ មិនមានសេចក្តីករុណា ១ មានកម្លាំងថយ ១ មានសំឡេងគ្រាវ ១ មានស្មារតីវង្វេង ១ ធ្វើនូវសេចក្តីសន្សំ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្អែកប្រកបដោយអសទ្ធម្ម ១០ យ៉ាងនេះឯង ។

ឯវមេវ ខោ ភិក្ខវេ ទសហិ អសទ្ធម្មេហិ សមន្នា-
គតោ ចាបភិក្ខុ ។ កតមេហិ ទសហិ ។ ជំសី
ច បតញ្ចោ ច តិន្តិណោ ច មហាត្ឋសោ ច លុទ្ធោ
ច អកាទុណិកោ ច ទុព្វលោ ច ឱរវី ច មុដ្ឋ-
ស្សតិ ច នេចយិកោ ច ។ ឥមេហិ ខោ ភិក្ខវេ
ទសហិ អសទ្ធម្មេហិ សមន្នាគតោ ចាបភិក្ខូតិ ។

[៧៨] ទសហិ ភិក្ខវេ អសទ្ធម្មេហិ សមន្នា-
គតា និគ្គន្ថា ។ កតមេហិ ទសហិ ។ អស្សទ្ធា ភិក្ខវេ
និគ្គន្ថា ទុស្សីលា ភិក្ខវេ និគ្គន្ថា អហិរិកា ភិក្ខវេ និគ្គន្ថា
អនោត្តប្បិនោ ភិក្ខវេ និគ្គន្ថា អសប្បុរិសភត្តិនោ[១]
ភិក្ខវេ និគ្គន្ថា អត្តុក្កំសកាបរវម្ភកា[២] ភិក្ខវេ និគ្គន្ថា
សន្ទិដ្ឋិបរាមាសី[៣] អាធានគ្គាហី ទុប្បដិនិស្សគ្គិនោ

១ ឱ. ម. អសប្បុរិសសម្ភត្តិនោ ។ ២ ម. អត្តុក្កំសនបរវម្ភកា ។ ៣ ឱ. ម. សន្ទិដ្ឋិបរាមាសា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបប្រកបដោយអសទ្ធម្ម ១០ យ៉ាង ក៏យ៉ាងនោះដែរ ។ ប្រកបដោយអសទ្ធម្ម ១០ យ៉ាង តើដូចម្តេច ។ គឺជាអ្នកកម្ចាត់បង់ (នូវគុណ) ១ ជាអ្នកក្រអឺតក្រឱង ១ ជាអ្នកមិនមានសេចក្តីវេះវាង ១ ជាអ្នកស៊ីច្រើន ១ ជាមនុស្សអាក្រក់ ១ ជាអ្នកមិនមានសេចក្តីករុណា ១ ជាអ្នកមានកម្លាំងថយ ១ ជាអ្នកមានសំឡេងអាក្រក់ ១ ជាអ្នកមានស្មារតីវង្វេង ១ ជាអ្នកធ្វើនូវសេចក្តីសន្សំ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាប ប្រកបដោយអសទ្ធម្ម ១០ យ៉ាង យ៉ាងនេះឯង ។

[៧៨] ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថ ប្រកបដោយអសទ្ធម្ម ១០ យ៉ាង ។ ប្រកបដោយអសទ្ធម្ម ១០ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថមិនមានសទ្ធា ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកទ្រុស្តសីល ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថមិនមានហិរិ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថមិនមានឱត្តប្បៈ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកមានអសប្បុរសជាមិត្រ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថ ជាអ្នកតម្កើងខ្លួនឯង ហើយបង្អាប់បុគ្គលដទៃ ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថ ជាអ្នកស្ទាបអង្អែល ក្នុងទិដ្ឋិរបស់ខ្លួន ជាអ្នកប្រកាន់មាំ ជាអ្នកលះបង់នូវអំពើ ដែលខ្លួនប្រកាន់ បានដោយកម្រ ១

ភិក្ខវេ និក្កដ្ឋា កុហកា ភិក្ខវេ និក្កដ្ឋា ចាបិច្ឆា ភិក្ខវេ និក្កដ្ឋា មិច្ឆាទិដ្ឋិកា ភិក្ខវេ និក្កដ្ឋា[១] ។ ឥមេហិ ខោ ភិក្ខវេ ទសហិ អសទ្ធម្មេហិ សមន្នាគតា និក្កដ្ឋាតិ ។

[៧៩] ទសយិមានិ ភិក្ខវេ អាឃាតវត្ថូនិ ។ កាតមានិ ទស ។ អនត្ថំ មេ អចរីតិ អាឃាតំ ពន្ធតិ អនត្ថំ មេ ចរតីតិ អាឃាតំ ពន្ធតិ អនត្ថំ មេ ចរិស្សតីតិ អាឃាតំ ពន្ធតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ... អនត្ថំ ចរតិ... អនត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ... អត្ថំ ចរតិ...

១ ម. បាបមិត្តា ភិក្ខវេ និគ្គន្ថាតិ បាឋោ ទិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកកុហក ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកមានសេចក្តីប្រាថ្នាដ៏លាមក ១ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថជាអ្នកមានទិដ្ឋិខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិគ្រន្ថប្រកបដោយអសទ្ធម្ម ១០ យ៉ាងនេះឯង ។

[៧៩] ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ (ហេតុនៃគំនុំ) នេះមាន ១០ យ៉ាង ។ អាឃាតវត្ថុទាំង ១០ យ៉ាង តើដូចម្តេច ។ បុគ្គលចងគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញហើយ ១ ចងគំនុំដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ ដល់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ ... ១ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ១ ចងគំនុំដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ... ១

អត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ អដ្ឋានេ ច កុប្បតិ ។ ឥមានិ ខោ ភិក្ខវេ ទស អាឃាតវត្ថូនីតិ ។

[៨០] ទសយិមេ ភិក្ខវេ អាឃាតប្បដិវិនយា ។ កតមេ ទស ។ អនត្ថំ មេ អចរិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អនត្ថំ មេ ចរតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អនត្ថំ មេ ចរិស្សតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ ... អនត្ថំ ចរតិ ...

នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ១ ក្រោធក្នុងទីដែលមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុមាន ១០ យ៉ាងនេះឯង ។

[៨០] ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យ (ការកម្ចាត់បង់នូវគំនុំ) នេះមាន ១០ យ៉ាង ។ អាឃាតប្បដិវិន័យទាំង ១០ យ៉ាង តើដូចម្តេច ។ គឺបុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញហើយ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តអំពើ មិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញហើយ ... ១ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍...១

អនត្ថំ ចរិស្សតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ... អត្ថំ ចរតិ... អត្ថំ ចរិស្សតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ អដ្ឋានេ ច ន កុប្បតិ ។ ឥមេ ខោ ភិក្ខវេ ទស អាឃាតប្បដិវិនយាតិ ។

អាកង្ខវគ្គោ តតិយោ ។

## តស្សុទ្ទានំ

អាកង្ខោ កណ្ដកោ ឥដ្ឋា វឌ្ឍី ច មិគសាលយ[១]
អភព្វោ ចេវ[២] កាកោ ច និគណ្ឋា ទស[៣] វត្ថូនីតិ ។

១ ម. មិគសាលាយ ។ ២ ម. វិសមញ្ញា ខោ ។ ៣ ឱ. ម. ទ្វេ ច ។

នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ កម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ ១ ... កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ... ១ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ អាត្មាអញគប្បីបាននូវអំពើជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះ អំពីណា ១ មិនក្រោធក្នុងទីមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតប្បដិវិន័យមាន ១០ យ៉ាងនេះឯង ។

ចប់ អាកង្ខវគ្គ ទី ៣ ។

## ឧទ្ទាននៃអាកង្ខវគ្គនោះគឺ

និយាយអំពីសេចក្តីប្រាថ្នា ១ អំពីធម៌ជាបន្ទា ១ អំពីធម៌ជាទីប្រាថ្នា ១ អំពីសេចក្តីចម្រើន ១ អំពីមិគសាលាឧបាសិកា ១ អំពីបុគ្គលមិនគួរលះបង់ ១ អំពីក្អែក ១ អំពីពួកនិគ្រន្ថ ១ អំពីវត្ថុ ១០ យ៉ាងមាន (ពីរលើក) ១ ។

# ថេរវគ្គោ ចតុត្ថោ

[៨១] ឯកំ សមយំ ភគវា ចម្បាយំ វិហរតិ គគ្គរាយ ពោក្ខរណិយា តីរេ ។ អថខោ អាយស្មា វាហុនោ[១] យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា វាហុនោ ភគវន្តំ ឯតទ-វោច កតីហិ នុ ខោ ភន្តេ ធម្មេហិ តថាគតោ និស្សដោ វិសំយុត្តោ វិប្បមុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ។ ទសហិ ខោ វាហុន ធម្មេហិ តថាគតោ និស្សដោ វិសំយុត្តោ វិប្បមុត្តោ វិមរិយា-ទិកតេន ចេតសា វិហរតិ ។ កតមេហិ ទសហិ ។ រូបេន ខោ វាហុន តថាគតោ និស្សដោ វិសំយុត្តោ វិប្បមុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ វេទនាយ ខោ វាហុន... សញ្ញាយ ខោ វាហុន... សង្ខារេហិ ខោ វាហុន... វិញ្ញាណេន ខោ វាហុន... ជាតិយា ខោ វាហុន... ជរាយ ខោ វាហុន... មរណេន ខោ វាហុន...

---
១ ឱ. ពាហុនោ ។ ម. វាហនោ ។

# ថេរវគ្គ ទី ៩

[៨១] សម័យមួយ ព្រះដ៏មានព្រះភាគ គង់ក្បែរឆ្នេរស្រះឈ្មោះគគ្គរា ជិតក្រុងចម្បា ។ គ្រានោះ ព្រះវាហុនៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះវាហុនៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលសួរ ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគត មានព្រះហឫទ័យទម្លាយនូវទំនប់គឺកិលេស តើរលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាកធម៌ប៉ុន្មានយ៉ាង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាកធម៌ ១០ យ៉ាង ។ ធម៌ ១០ យ៉ាង តើអ្វីខ្លះ ។ ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាករូប ១ ម្នាលវាហុនៈ ចាកវេទនា ... ១ ម្នាលវាហុនៈ ចាកសញ្ញា ... ១ ម្នាលវាហុនៈ ចាកសង្ខារទាំងឡាយ ... ១ ម្នាលវាហុនៈ ចាកវិញ្ញាណ ... ១ ម្នាលវាហុនៈ ចាកជាតិ ... ១ ម្នាលវាហុនៈ ចាកជរា ... ១ ម្នាលវាហុនៈ ចាកមរណៈ ... ១

ទុក្ខេហិ ខោ វាហុន ... កិលេសេហិ ខោ វាហុន តថាគតោ និស្សដោ វិសំយុត្តោ វិប្បមុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សេយ្យថាបិ វាហុន ឧប្បលំ វា បទុមំ វា បុណ្ឌរីកំ វា ឧទកេ ជាតំ ឧទកេ សំវឌ្ឍំ ឧទកា អច្ចុគ្គម្ម តិដ្ឋតិ[១] អនុបលិត្តំ ឧទកេន ឯវមេវ ខោ វាហុន ឥមេហិ ទសហិ ធម្មេហិ តថាគតោ និស្សដោ វិសំយុត្តោ វិប្បមុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ។

[៨២] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច សោ វតានន្ទ ភិក្ខុ អស្សទ្ធោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

១ ម. បច្ចុគ្គម្ម ឋិតំ ។

ម្នាលវាហុនៈ ចាកទុក្ខទាំងឡាយ ... ១ ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ រួចស្រឡះចាកកិលេស ១ ។ ម្នាលវាហុនៈ ដូចឧប្បលក្តី ឈូកក្រហមក្តី ឈូកសក្តី ដែលដុះក្នុងទឹក លូតលាស់ក្នុងទឹក លូតផុតអំពីទឹក មិនជាប់ដោយទឹក យ៉ាងណាមិញ ម្នាលវាហុនៈ ព្រះតថាគតមានចិត្តទម្លាយនូវទំនប់ គឺកិលេស រលាស់ចេញ ឃ្លាតចេញ ផុតស្រឡះហើយ ចាកធម៌ទាំង ១០ ប្រការនេះ ក៏យ៉ាងនោះដែរ ។

[៨២] គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទពាក្យថា ភិក្ខុនោះឯង មិនមានសទ្ធា នឹងដល់នូវសេចក្តីចម្រើន លូត-លាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។

សោ វតានន្ទ ភិក្ខុ ទុស្សីលោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ អប្បស្សុតោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ ទុព្វចោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ បាបមិត្តោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ កុសីតោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ មុដ្ឋស្សតិ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ អសន្តុដ្ឋោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ

ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកទ្រុស្តសីល នឹងដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកបេះដឹងតិច នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រដៅក្រ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានមិត្តអាក្រក់ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកខ្ជិលច្រអូស នឹងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានស្មារតីភ្លេចភ្លាំង នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមិនមានសន្តោស នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ

នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ បាបិច្ឆោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ មិច្ឆាទិដ្ឋិកោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ ឥមេហិ ខោ ទសហិ ធម្មេហិ សមន្នាគតោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ សទ្ធោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ សីលវា សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ ពហុស្សុតោ សុតធរោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតិ ។

មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រាថ្នាលាមក នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាមិច្ឆាទិដ្ឋិ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ប្រកបដោយធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានសទ្ធា នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានសីល នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកចេះដឹង អ្នកទ្រទ្រង់ព្រះសូត្រ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

## ៣៣៣



សោ វតានន្ទ សុវចោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ កល្យាណមិត្តោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ អារទ្ធវីរិយោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ ឧបដ្ឋិតស្សតិ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ សទ្ធោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហាន-មេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ អប្បិច្ឆោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ សម្មាទិដ្ឋិកោ សមានោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ហានមេតំ វិជ្ជតិ ។

ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រដៅងាយ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានកល្យាណ-មិត្តនឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានព្យា-យាមប្រារព្ធហើយ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានស្មារតីតាំងមាំ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកមានចិត្តសន្តោស នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាអ្នកប្រាថ្នាតិច នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។ ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ជាសម្មាទិដ្ឋិ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

សោ វតានន្ទ ភិក្ខុ ឥមេហិ ខោ ទសហិ ធម្មេហិ សមន្នាគតោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

[៨៣] អថខោ អាយស្មា បុណ្ណិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា បុណ្ណិយោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន អប្បេ-កទា តថាគតំ ធម្មទេសនា បដិភាតិ អប្បេកទា ន បដិភាតីតិ ។ សទ្ធោ ច បុណ្ណិយ ភិក្ខុ ហោតិ នោ ច ឧបសង្កមិតា នេវ តាវ តថាគតំ ធម្មទេសនា បដិភាតិ ។ យតោ ច ខោ បុណ្ណិយ ភិក្ខុ សទ្ធោ ច ហោតិ ឧបសង្កមិតា ច ឯវំ តថាគតំ ធម្មទេសនា បដិភាតិ សទ្ធោ ច បុណ្ណិយ ភិក្ខុ ហោតិ ឧបសង្កមិតា ច នោ ច បយិរុបាសិតា . . . បយិរុបាសិតា ច

ម្នាលអានន្ទ ពាក្យថា ភិក្ខុនោះឯង ប្រកបដោយធម៌ទាំង ១០ យ៉ាងនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះ នុ៎ះ ទើបជាឋានៈ ។

[៨៣] គ្រានោះ ព្រះបុណ្ណិយៈដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល សួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ក្នុងកាលខ្លះធម្មទេសនា ប្រាកដដល់ព្រះតថាគត ក្នុងកាលខ្លះមិនប្រាកដ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបុណ្ណិយៈ ភិក្ខុជាអ្នកមានសទ្ធា តែមិនចូលទៅរក ដរាបណា ធម្មទេសនាមិនប្រាកដ ដល់ព្រះតថាគត ដរាបនោះ ។ ម្នាលបុណ្ណិយៈ កាលបើភិក្ខុមានសទ្ធាផង ចូលទៅរកផង យ៉ាងនេះ ទើបធម្មទេសនាប្រាកដ ដល់ព្រះតថាគត ម្នាលបុណ្ណិយៈ ភិក្ខុអ្នកមានសទ្ធាផង ចូលទៅរកផង តែមិនចូលទៅអង្គុយជិត ... ចូលទៅអង្គុយជិតហើយ

ធោ ច បរិបុច្ឆិតា... បរិបុច្ឆិតា ច ធោ ច ឱហិតសោតោ ធម្មំ សុណាតិ... ឱហិតសោតោ ច ធម្មំ សុណាតិ ធោ ច សុត្វា ធម្មំ ធារេតិ... សុត្វា ច ធម្មំ ធារេតិ ធោ ច ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខតិ... ធតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ ធោ ច អត្ថ-មញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ... អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ ធោ ច កល្យាណវាចោ ហោតិ កល្យាណ-វាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា កល្យាណ-វាចោ ច ហោតិ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា ធោ ច សន្ទស្សកោ ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្ម-ចារីនំ ធេវ តាវ តថាគតំ ធម្មទេសធា បដិភាតិ ។

តែមិនសាកសួរ ... សាកសួរហើយ តែមិនផ្ទង់ត្រចៀកស្តាប់ធម៌ ... ផ្ទង់ត្រចៀកស្តាប់ធម៌ហើយ តែស្តាប់មិនចាំធម៌ ... ស្តាប់ចាំធម៌ទុកហើយ តែមិនពិចារណានូវអត្ថនៃធម៌ ដែលខ្លួនចាំទុកហើយ ... ពិចារណានូវធម៌ ដែលខ្លួនចាំទុកហើយ តែមិនដឹងអត្ថមិនដឹងធម៌ ប្រតិបត្តិសមគួរតាមធម៌ ... ដឹងអត្ថដឹងធម៌ ប្រតិបត្តិសមគួរតាមធម៌ហើយ តែមិនមានវាចាល្អ ពោលពាក្យដ៏ពីរោះ ប្រកបដោយសម្តីអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ញុំាងជនដទៃឲ្យដឹងនូវអត្ថបាន មានវាចាល្អ ពោលពាក្យពីរោះ ប្រកបដោយសម្តីអ្នកក្រុង ជាវាចាឥតទោស ញុំាងជនដទៃឲ្យដឹងនូវអត្ថហើយ តែមិនពន្យល់ មិនណែនាំ មិនឲ្យក្លៀវក្លា មិនឲ្យរីករាយ ដល់ពួកសព្រហ្មចារីបុគ្គល ធម្មទេសនា រមែងមិនប្រាកដ ដល់ព្រះតថាគត ដរាបនោះទេ ។

យតោ ច ខោ បុណ្ណិយ ភិក្ខុ សទ្ធោ ច ហោតិ ឧបសង្កមិតា ច បយិរុបាសិតា ច បរិបុច្ឆិតា ច ឱហិតសោតោ ច ធម្មំ សុណាតិ សុត្វា ច ធម្មំ ធារេតិ ធតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ កល្យាណវាចោ ច ហោតិ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនីយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ឯវំ តថាគតំ ធម្មទេសនា បដិភាតិ ។ ឥមេហិ ខោ បុណ្ណិយ ទសហិ ធម្មេហិ សមន្នាគតា ឯកន្តំ តថាគតំ ធម្មទេសនា បដិភាតីតិ[១] ។

[៨៤] តត្រ ខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ[២] ។

១ ឱ. ម. ហោតីតិ ។ ២ ម. ភិក្ខវេតិ ។

ម្នាលបុណ្ណិយៈ លុះតែភិក្ខុមានសទ្ធា ១ បានចូលមកជិត ១ ចូលទៅអង្គុយជិត ១ សាកសួរ ១ ផ្ទង់ត្រចៀកស្តាប់ធម៌ ១ ស្តាប់ហើយចាំធម៌ទុក ១ ពិចារណានូវអត្ថនៃធម៌ ដែលខ្លួនចាំហើយ ១ ដឹងអត្ថដឹងធម៌ហើយប្រតិបត្តិសមគួរតាមធម៌ ១ មានវាចាល្អ ពោលពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ជាវាចាល្អច្បាស់លាស់ ជាវាចាឥតទោស អាចញ៉ាំងជនដទៃ ឲ្យដឹងសេចក្តី ១ ពន្យល់ ណែនាំ ឲ្យក្លាហាន ឲ្យរីករាយដល់ពួកសព្រហ្មចារីបុគ្គល ១ យ៉ាងនេះ ទើបធម្មទេសនាប្រាកដ ដល់ព្រះតថាគត ។ ម្នាលបុណ្ណិយៈ ធម្មទេសនា ដែលប្រកបដោយធម៌ទាំង ១០ យ៉ាងនេះឯង ទើបប្រាកដដល់ព្រះតថាគត ដោយពិត ។

[៨៤] ក្នុងទីនោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។

៣៣៧

អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។ អាយស្មា មហាមោគ្គល្លានោ ឯតទវោច ឥធាវុសោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ ។ សោ តថាគតេន វា តថាគតសាវកេន វា ឈាយិនា សមាបត្តិកុសលេន បរចិត្តកុសលេន បរចិត្តបរិយាយកុសលេន សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ ឥរិណំ អាបជ្ជតិ វិចិនំ អាបជ្ជតិ អនយំ អាបជ្ជតិ ព្យសនំ អាបជ្ជតិ អនយព្យសនំ អាបជ្ជតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី

ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យរបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ថា ព្រះករុណាអាវុសោ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ពោលពាក្យដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ អួតនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តចប់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងនូវចិត្ត នៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ តែងសួរឈ្ងេចឈ្ងី ដេញដោល ពិនិត្យបញ្ជាក់មើលនូវភិក្ខុនោះ ។ ភិក្ខុនោះ កាលបើព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងនូវចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ សួរឈ្ងេចឈ្ងី ដេញដោល ពិនិត្យបញ្ជាក់មើល ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើននិងសេចក្តីវិនាស ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន

សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្ត-បរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច មនសិករោតិ កឹ នុ ខោ អយមាយស្មា អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយ-កុសលោ ឯវំ ចេតសា ចេតោ បរិច្ច បជានាតិ កោធនោ ខោ បន អយមាយស្មា កោធបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ កោធបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ឧបនាហី ខោ បន អយមាយស្មា[១] ឧបនាហបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ ឧបនាហបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។

---

១ ឱ. សព្វាវរ ខោ បនាយមាយស្មាតិ បាឋោ ទិស្សតិ ។

ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តរបស់បុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្ត របស់បុគ្គលដទៃ ធ្វើទុកក្នុងចិត្ត ព្រោះបានកំណត់ដឹងនូវចិត្តដោយចិត្តយ៉ាងនេះថា ហេតុអ្វីអ្នកដ៏មានអាយុនេះ អួតនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គ-ភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្ត នៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ ក៏ដឹងច្បាស់នូវបុគ្គលនោះ ព្រោះបានកំណត់ដឹងនូវចិត្តដោយចិត្ត យ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកមានសេចក្តីក្រោធ មានចិត្តត្រូវសេចក្តីក្រោធ រួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយសេចក្តីក្រោធនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានឧបនាហៈ មានចិត្តត្រូវឧបនាហៈ រួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយឧបនាហៈនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។

៣៣៩



មក្ខី ខោ បន អយមាយស្មា មក្ខបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ មក្ខបរិយុដ្ឋានំ ខោ បន តថាគតប្ប-
វេទិតេ ធម្មវិនយេ បរិហានមេតំ ។ បឡាសី ខោ បន អយមាយស្មា បឡាសបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ បឡាសបរិយុដ្ឋានំ ខោ បន តថាគតប្ប-
វេទិតេ ធម្មវិនយេ បរិហានមេតំ ។ ឥស្សុកី ខោ បន អយមាយស្មា ឥស្សាបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ ឥស្សាបរិយុដ្ឋានំ ខោ បន តថា-
គតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ មច្ឆរី ខោ បន អយមាយស្មា មច្ឆេរបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ មច្ឆេរបរិយុដ្ឋានំ ខោ បន តថាគត-
តប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ សឋោ ខោ បន អយមាយស្មា សាឋេយ្យបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ សាឋេយ្យបរិយុដ្ឋានំ ខោ បន

អ្នកដ៏មានអាយុនេះ ជាអ្នកមានមក្ខៈ មានចិត្តត្រូវមក្ខៈរួបរឹត នៅដោយច្រើន ចំណែកខាងការរួបរឹត ដោយមក្ខៈនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានបឡាសៈ មានចិត្តត្រូវបឡាសៈរួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយបឡាសៈនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានឫស្យា មានចិត្តត្រូវឫស្យា រួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយឫស្យានេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានមច្ឆរិយៈ មានចិត្តត្រូវមច្ឆរិយៈរួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយមច្ឆរិយៈនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានការអួត មានចិត្តត្រូវសាថេយ្យៈរួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយសាថេយ្យៈនេះ

តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ មាយាវី ខោ បន អយមាយស្មា មាយាបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ មាយាបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ចាបិច្ឆោ ខោ បន អយមាយស្មា ឥច្ឆាបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ ឥច្ឆាបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ មុដ្ឋស្សតិ ខោ បន អយមាយស្មា ឧត្តរិករណីយេ ឱរមត្តកេន វិសេសាធិគមេន អន្តរាវោសានំ អាបន្នោ អន្តរាវោសានគមនំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ សោ វតាវុសោ ភិក្ខុ ឥមេ ទស ធម្មេ អប្បហាយ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតាវុសោ ភិក្ខុ ឥមេ ទស ធម្មេ បហាយ

ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានមាយា មានចិត្តត្រូវមាយា រួបរឹតនៅដោយច្រើន ចំណែកខាងការរួបរឹត ដោយមាយានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក មានចិត្តត្រូវសេចក្តីប្រាថ្នាលាមក រួបរឹត នៅដោយច្រើន ចំណែកខាងការរួបរឹតដោយសេចក្តីប្រាថ្នាលាមកនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ដល់នូវការផ្អាកទុកនូវសេចក្តីព្យាយាម ក្នុងចន្លោះដោយការបាននូវគុណវិសេសដ៏ថយថោក ក្នុងកិច្ចដែលខ្លួនត្រូវធ្វើតទៅទៀត ចំណែកខាងដំណើរដែលផ្អាកនូវសេចក្តីព្យាយាម ក្នុងចន្លោះនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯងមិនបានលះបង់នូវធម៌ទាំង ១០ នេះ នឹងដល់នូវការចម្រើន លូតលាស់ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង លះបង់នូវធម៌ទាំង ១០ នេះ

ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

[៨៤] ឯកំ សមយំ អាយស្មា មហាចុន្ទោ ចេតីសុ វិហរតិ សហជាតិយំ ។ តត្រ ខោ អាយស្មា មហាចុន្ទោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាចុន្ទស្ស បច្ចស្សោសុំ ។ អាយស្មា មហាចុន្ទោ ឯតទវោច ឥធាវុសោ ភិក្ខុ កត្ថី ហោតិ វិកត្ថី អធិគមេសុ អហំ បឋមំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ ទុតិយំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ តតិយំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ ចតុត្ថំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ អាកាសានញ្ចាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ វិញ្ញាណញ្ចាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ អាកិញ្ចញ្ញាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជាមិបិ

នឹងដល់នូវការចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

[៨៥] សម័យមួយ ព្រះមហាចុន្ទៈ ដ៏មានអាយុ គង់ក្នុងសហជាតិប្រទេស ក្នុងដែនចេតី ។ ក្នុងទីនោះឯង ព្រះមហាចុន្ទៈដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យព្រះមហាចុន្ទៈ ដ៏មានអាយុថា អាវុសោ ។ ព្រះមហាចុន្ទៈ ដ៏មានអាយុ បានសម្តែងដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ តែងពោលអួតក្នុងអធិគមៈ (ធម៌ដែលគួរត្រាស់ដឹង) ថា ខ្ញុំចូលកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ទុតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់តតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ចតុត្ថជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកាសានញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ក៏បាន ចេញក៏បាន ខ្ញុំចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ក៏បាន

វុដ្ឋហាមិបិ អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមិបិ វុដ្ឋហាមិបីតិ ។ តមេនំ តថាគតោ វា តថាគតស្សាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ ។ សោ តថាគតេន វា តថាគតស្សាវកេន វា ឈាយិនា សមាបត្តិកុសលេន បរចិត្តកុសលេន បរចិត្តបរិយាយកុសលេន សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ ឥរិណំ អាបជ្ជតិ វិចិនំ អាបជ្ជតិ អនយំ អាបជ្ជតិ ព្យសនំ អាបជ្ជតិ អនយព្យសនំ អាបជ្ជតិ ។ តមេនំ តថាគតោ វា តថាគតស្សាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច មនសិករោតិ កឹ នុ ខោ អយមាយស្មា កត្ថី ហោតិ វិកត្ថី អធិគមេសុ អហំ បឋមំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ ។ បេ ។

ចេញក៏បាន ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្ត នៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ សួរឈ្ងេចឈ្ងី ដេញដោល ពិនិត្យបញ្ជាក់មើល ចំពោះភិក្ខុនោះ ។ ភិក្ខុនោះ កាលព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ដែលជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃ កាលសួរឈ្ងេចឈ្ងី ដេញដោល ពិនិត្យបញ្ជាក់មើលទៅ ក៏ដល់នូវភាវៈ ទទេ ដល់នូវភាវៈ ឥតគុណ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើននិងសេចក្តីវិនាស ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តបុគ្គលដទៃ រមែងកំណត់ទុកក្នុងចិត្ត ចំពោះភិក្ខុនោះ ព្រោះបានកំណត់ដឹងនូវចិត្តដោយចិត្តយ៉ាងនេះថា ហេតុអ្វីអ្នកដ៏មានអាយុនេះ តែងពោលអួត ចំពោះអធិគមធម៌ថា ខ្ញុំចូលទៅកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ។ បេ ។

អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមិបិ វុដ្ឋហាមិបីតិ ។ តមេនំ តថាគតោ វា តថាគតស្សាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច បជានាតិ ឪយវត្តំ ខោ អយមាយស្មា ខណ្ឌការី ឆិទ្ទការី សពលការី កម្មាសការី ន សតតការី ន សតតវុត្តី[១] សីលេសុ ។ ទុស្សីលោ[២] អយមាយស្មា ទុស្សីល្យំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ អស្សទ្ធោ ខោ បន អយមាយស្មា អជាចារោ អស្សទ្ធិយំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ អប្បស្សុតោ ខោ បន អយមាយស្មា អជាចារោ អប្បសច្ចំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។

---

១ ឱ. ន សន្តតការី ន សន្តតវុត្តី ។ ម. ន សន្តតការី ន សន្តវុត្តី ។
២ ម. ឯត្ថន្តរេ ខោសទ្ទោ អត្ថិ ។

ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគតឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តបុគ្គលដទៃ រមែងកំណត់ដឹងចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកធ្វើឲ្យដាច់ ធ្វើឲ្យធ្លុះធ្លាយ ធ្វើឲ្យពពាល ធ្វើឲ្យពព្រុស ធ្វើមិនឲ្យទៀងទាត់ ប្រព្រឹត្តមិនទៀងត្រង់ ក្នុងសីលទាំងឡាយ អស់កាលវែង ។ អ្នកដ៏មានអាយុនេះ ជាអ្នកទ្រុស្តសីល ចំណែកខាងភាព នៃបុគ្គលទ្រុស្តសីលនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមិនមានសទ្ធា មិនមានអាចារៈ ចំណែកខាងការមិនមានសទ្ធានេះ ជាសេចក្តីសាបសូន្យក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកចេះដឹងតិច មិនមានអាចារៈ ចំណែកខាងការចេះដឹងតិចនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។

ទុព្វចោ ខោ បន អយមាយស្មា អធាចារោ[១] នោវចស្សតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ បាបមិត្តោ ខោ បន អយមាយស្មា បាបមិត្តតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ កុសីតោ ខោ បន អយមាយស្មា កោសជ្ជំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ មុដ្ឋស្សតិ ខោ បន អយមាយស្មា មុដ្ឋសច្ចំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ កុហកោ ខោ បន អយមាយស្មា កុហនា[២] ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ទុព្ភរោ ខោ បន អយមាយស្មា ទុព្ភរតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ទុប្បញ្ញោ ខោ បន អយមាយស្មា ទុប្បញ្ញតា ខោ បន

១ ឱ. ម. អនាចារោតិ បាឋោ ន ទិស្សតិ ។ ២ ម. កោហញ្ញំ ។

អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេប្រដៅក្រ មិនមានអាចារៈ ចំណែកខាងភាព នៃបុគ្គលប្រដៅក្រនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្ម-វិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ មានមិត្តអាក្រក់ ចំណែកខាងភាព នៃបុគ្គលមានមិត្តអាក្រក់នេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលខ្ជិលច្រអូស ចំណែកខាងសេចក្តីខ្ជិលច្រអូសនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ចំណែកខាងការភ្លេចស្មារតីនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលកុហក ចំណែកខាងការកុហកនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេចិញ្ចឹមក្រ ចំណែកខាងភាពនៃបុគ្គល ដែលគេចិញ្ចឹមក្រនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកឥតបញ្ញា ចំណែកខាងភាពនៃបុគ្គលឥតបញ្ញានេះ

តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ សេយ្យថាបិ អាវុសោ សហាយកោ សហាយកំ ឯវំ វទេយ្យ យទា តេ សម្ម ធនេន(១) ធនករណីយំ អស្ស បវេទេយ្យាសិ(២) មំ ធនំ ទស្សាមិ តេ ធនន្តិ ។ សោ កិស្មិញ្ចិទេវ(៣) ធនករណីយេ សមុប្បន្នេ សហាយកោ សហាយកំ ឯវំ វទេយ្យ អត្ថោ មេ សម្ម ធនេន ទេហិ មេ ធនន្តិ ។ សោ ឯវំ វទេយ្យ តេនហិ សម្ម ឥធ ខណាហីតិ ។ សោ តត្រ ខណន្តោ នាធិគច្ឆេយ្យ ។ សោ ឯវំ វទេយ្យ អលិកំ មំ សម្ម អវច តុច្ឆកំ មំ សម្ម អវច ឥធ ខណាហីតិ ។ សោ ឯវំ វទេយ្យ នាហន្តំ សម្ម អលិកំ អវចំ តុច្ឆកំ អវចំ តេនហិ សម្ម ឥធ ខណាហីតិ ។ សោ តត្របិ ខណន្តោ នាធិគច្ឆេយ្យ ។

---

១ ម. ពន្ធោ ។ ២ ឱ. យាចិស្សសិ ។ ម. បរាជេយ្យាបិ ។ ៣ ម. កិញ្ចិទេវ ។

ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ ម្នាលអាវុសោទាំងឡាយ ដូចជាសំឡាញ់ម្នាក់និយាយទៅនឹងសំឡាញ់យ៉ាងនេះថា ម្នាលសំឡាញ់ បើអ្នកត្រូវការចំពោះធនកិច្ចដោយទ្រព្យ ក្នុងកាលណា អ្នកគប្បីប្រាប់ធនកិច្ច (នោះ) ដល់ខ្ញុំ ៗ នឹងឲ្យទ្រព្យដល់អ្នក ។ សំឡាញ់នោះ កាលបើធនកិច្ចណាមួយ កើតឡើង ក៏និយាយទៅនឹងសំឡាញ់ យ៉ាងនេះថា ម្នាលសំឡាញ់ ខ្ញុំត្រូវការដោយទ្រព្យ ចូរអ្នកឯងឲ្យទ្រព្យ (នោះ) មកខ្ញុំ ។ សំឡាញ់នោះក៏និយាយយ៉ាងនេះថា ម្នាលសំឡាញ់ បើដូច្នោះអ្នកចូរជីក ក្នុងទីនេះចុះ ។ សំឡាញ់នោះ កាលជីកក្នុងទីនោះទៅ ក៏មិនបាន ។ សំឡាញ់នោះនិយាយយ៉ាងនេះថា ម្នាលសំឡាញ់ អ្នកឯងនិយាយឡេះឡោះនឹងខ្ញុំ ម្នាលសំឡាញ់ អ្នកឯងនិយាយពាក្យទទេនឹងខ្ញុំថា អ្នកឯងចូរជីក ក្នុងទីនេះចុះ ។ សំឡាញ់នោះ និយាយយ៉ាងនេះថា ម្នាលសំឡាញ់ ខ្ញុំមិននិយាយឡេះឡោះនឹងអ្នកទេ ខ្ញុំមិននិយាយពាក្យទទេ នៃសំ-ឡាញ់ បើដូច្នោះ អ្នកឯងចូរជីក ក្នុងទីនេះដូច្នេះ ។ សំឡាញ់នោះ កាលបើជីក ក្នុងទីនោះម្តងទៀត ក៏នៅតែមិនបាន ។

សោ ឯវំ វទេយ្យ អលិកំ មំ សម្ម អវច តុច្ឆកំ មំ សម្ម អវច ឥធ ខណាហីតិ ។ សោ ឯវំ វទេយ្យ ណាហន្តំ សម្ម អលិកំ អវចំ តុច្ឆកំ អវចំ តេនហិ សម្ម ឥធ ខណាហីតិ ។ សោ តត្របិ ខណន្តោ ណាធិគច្ឆេយ្យ ។ សោ ឯវំ វទេយ្យ អលិកំ មំ សម្ម អវច តុច្ឆកំ មំ សម្ម អវច ឥធ ខណាហីតិ ។ សោ ឯវំ វទេយ្យ ណាហន្តំ សម្ម អលិកំ អវចំ តុច្ឆកំ អវចំ អបិច អហមេវ ឧម្មាទំ បាបុណឹ ចេតសោ វិបរិយាយន្តិ ។ ឯវមេវ ខោ អាវុសោ ភិក្ខុ កត្ថី ហោតិ វិកត្ថី អធិគមេសុ អហំ បឋមំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ ទុតិយំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ តតិយំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ ចតុត្ថំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ អាកាសានញ្ចាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ

សំឡាញ់នោះ និយាយយ៉ាងនេះថា ម្នាលសំឡាញ់ អ្នកឯងនិយាយឡេះឡោះនឹងខ្ញុំ ម្នាលសំឡាញ់ អ្នកឯងនិយាយពាក្យទទេនឹងខ្ញុំថា អ្នកឯងចូរជីក ក្នុងទីនេះចុះ ។ សំឡាញ់នោះនិយាយ យ៉ាងនេះថា ម្នាលសំឡាញ់ ខ្ញុំមិននិយាយឡេះឡោះនឹងអ្នកទេ ខ្ញុំមិននិយាយទទេទេ ម្នាលសំឡាញ់ បើដូច្នោះ អ្នកឯងចូរជីក ក្នុងទីនេះចុះ ។ សំឡាញ់នោះ កាលជីក ក្នុងទីនោះម្តងទៀត ក៏នៅតែមិនបាន ។ សំឡាញ់នោះនិយាយយ៉ាងនេះថា ម្នាលសំឡាញ់ អ្នកឯងនិយាយឡេះឡោះនឹងខ្ញុំ ម្នាលសំឡាញ់ អ្នកឯងនិយាយពាក្យទទេនឹងខ្ញុំថា អ្នកឯងចូរជីក ក្នុងទីនេះចុះ ។ សំឡាញ់នោះនិយាយយ៉ាងនេះថា ម្នាលសំឡាញ់ ខ្ញុំមិននិយាយឡេះឡោះនឹងអ្នកទេ ខ្ញុំមិននិយាយពាក្យទទេនឹងអ្នកទេ ប៉ុន្តែខ្ញុំដល់នូវភាពជាអ្នកឆ្កួត ប្រែប្រួលចិត្ត សេចក្តីនេះយ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពោលអួត ក្នុងអធិគមធម៌ថា ខ្ញុំចូលកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ទុតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់តតិយជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់ចតុត្ថជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកាសានញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន

៣៤៧



អហំ វិញ្ញាណញ្ចាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ អាកិញ្ចញ្ញាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមិបិ វុដ្ឋហាមិបីតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ ។ សោ តថាគតេន វា តថាគតសាវកេន វា ឈាយិនា សមាបត្តិកុសលេន បរចិត្តកុសលេន បរចិត្តបរិយាយកុសលេន សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ ឥរិណំ អាបជ្ជតិ វិចិនំ អាបជ្ជតិ អនយំ អាបជ្ជតិ ព្យសនំ អាបជ្ជតិ អនយព្យសនំ អាបជ្ជតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ

ខ្ញុំចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក៏បាន ចេញក៏បាន ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ តែងសួរឈ្ងេចឈ្ងី ដេញដោល ពិនិត្យមើលនូវភិក្ខុនោះ ។ ភិក្ខុនោះ កាលបើព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្ត នៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ សួរឈ្ងេចឈ្ងី ដេញដោល ពិនិត្យបញ្ជាក់មើលទៅ ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើននិងសេចក្តីវិនាស ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ

ឯវំ ចេតសា ចេតោ បរិច្ច មនសិករោតិ កឹ នុ ខោ អយមាយស្មា កត្ថី ហោតិ វិកត្ថី អជិតមេសុ អហំ បឋមំ ឈានំ សមាបជ្ជាមិបិ វុដ្ឋហាមិបិ ។ បេ ។ អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមិបិ វុដ្ឋហាមិបីតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច បជានាតិ ចិររត្តំ ខោ អយមាយស្មា ខណ្ឌការី ឆិទ្ទការី សពលការី កម្មាសការី ន សតតការី ន សតតវុត្តី សីលេសុ ។ ទុស្សីលោ អយមាយស្មា ទុស្សីល្យំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ អស្សទ្ធោ ខោ បន អយមាយស្មា អស្សទ្ធិយំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ អប្បស្សុតោ ខោ បន អយមាយស្មា អនាចារោ

ធ្វើទុកក្នុងចិត្តចំពោះភិក្ខុនោះ ព្រោះបានកំណត់ដឹងនូវចិត្តដោយចិត្ត យ៉ាងនេះថា ហេតុអ្វីអ្នកដ៏មានអាយុនេះ តែងពោលអួត ក្នុងអធិគមធម៌ថា ខ្ញុំចូលកាន់បឋមជ្ឈានក៏បាន ចេញក៏បាន ។ បេ ។ ខ្ញុំចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ។ ព្រះតថាគត ឬ សាវ័ក របស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកធ្វើឲ្យដាច់ ធ្វើឲ្យធ្លុះធ្លាយ ធ្វើឲ្យពពាល ធ្វើឲ្យពព្រុស ធ្វើមិនទៀងទាត់ ប្រព្រឹត្តមិនទៀងត្រង់ ក្នុងសីលទាំងឡាយ អស់កាលវែង ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលទ្រុស្តសីល ចំណែកខាងភាពនៃបុគ្គលទ្រុស្តសីលនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមិនមានសទ្ធា ចំណែកខាងការមិនមានសទ្ធានេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលមានការចេះដឹងតិច មិនមានអាចារៈ

៣៤៩



អប្បសច្ចំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ទុព្ពចោ ខោ បន អយមាយស្មា ទោវចស្សតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ចាបមិត្តោ ខោ បន អយមាយស្មា ចាបមិត្តតា ខោ បន តថាគត-តប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ កុសីតោ ខោ បន អយមាយស្មា កោសជ្ជំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ មុដ្ឋស្សតិ ខោ បន អយមាយស្មា មុដ្ឋសច្ចំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ កុហកោ ខោ បន អយមាយស្មា កុហនា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ទុព្ភរោ ខោ បន អយមាយស្មា ទុព្ភរតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។

ចំណែកខាងការចេះដឹងតិចនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេប្រដៅក្រ ចំណែកខាងភាវៈ នៃបុគ្គលគេប្រដៅក្រនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលមានមិត្តអាក្រក់ ចំណែកខាងភាព នៃបុគ្គលមានមិត្តអាក្រក់នេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលខ្ជិលច្រអូស ចំណែកខាងការខ្ជិលច្រអូសនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ចំណែកខាងការភ្លេចស្មារតីនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលកុហក ចំណែកខាងការកុហកនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថា-គត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាបុគ្គលដែលគេចិញ្ចឹមក្រ ចំណែកខាងភាព នៃបុគ្គលដែលគេចិញ្ចឹមក្រនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។

ទុប្បញ្ញោ ខោ បន អយមាយស្មា ទុប្បញ្ញតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ សោ វតាវុសោ ភិក្ខុ ឥមេ ទស ធម្មេ អប្បហាយ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតាវុសោ ភិក្ខុ ឥមេ ទស ធម្មេ បហាយ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

[៨៦] ឯកំ សមយំ អាយស្មា មហាកស្សបោ រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ អាយស្មា មហាកស្សបោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាកស្សបស្ស បច្ចស្សោសុំ ។ អាយស្មា មហាកស្សបោ ឯតទវោច ឥធាវុសោ ភិក្ខុ អញ្ញំ ព្យាករោតិ

អ្នកដ៏មានអាយុនេះ ជាបុគ្គលអប្បបញ្ញា ចំណែកខាងភាពនៃបុគ្គលអប្បបញ្ញានេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយក៏យ៉ាងនោះឯង ។ ម្នាលអាវុសោទាំងឡាយ ពាក្យថាភិក្ខុនោះឯង មិនលះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ក្នុងធម្មវិន័យ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា បើភិក្ខុនោះឯង លះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

[៨៦] សម័យមួយ ព្រះមហាកស្សបដ៏មានអាយុ គង់ក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមហាកស្សបដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យព្រះមហាកស្សប ដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះមហាកស្សបដ៏មានអាយុ បានពោលពាក្យ ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោលអួតអរហត្តផលថា

វីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ ។ សោ តថាគតេន វា តថាគតសាវកេន វា ឈាយិនា សមាបត្តិកុសលេន បរចិត្តកុសលេន បរចិត្តបរិយាយកុសលេន សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ ឥរិណំ អាបជ្ជតិ វិចិនំ អាបជ្ជតិ អនយំ អាបជ្ជតិ ព្យសនំ អាបជ្ជតិ អនយព្យសនំ អាបជ្ជតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច មនសិករោតិ

ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្ត ស្រេចហើយ សោឡសកិច្ចអាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះ តថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុង សមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្ត បុគ្គលដទៃ តែងសួរឈ្លេចឈ្លី ដេញដោល ពិនិត្យបញ្ជាក់មើលនូវ ភិក្ខុនោះ ។ ភិក្ខុនោះ កាលបើព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ សួរឈ្លេចឈ្លី ដេញដោល ពិនិត្យ បញ្ជាក់មើល ក៏ដល់នូវភាវៈទទេ ដល់នូវភាវៈឥតគុណ ដល់នូវសេចក្តីមិន ចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីមិនចម្រើននិងសេចក្តីវិនាស ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុង សមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់ បុគ្គលដទៃ រមែងកំណត់ធ្វើទុកក្នុងចិត្តនូវភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា

កឹ នុ ខោ អយមាយស្មា អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថាគតោ វា តថាគតស្សាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច បជានាតិ អភិមានិកោ ខោ បន អយមាយស្មា អភិមានសច្ចោ អប្បត្តេ បត្តសញ្ញី អកតេ កតសញ្ញី អនធិគតេ អធិគតសញ្ញី អភិមានេន អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថាគតោ វា តថាគតស្សាវកោ វា ឈាយី សមាបត្តិកុសលោ

ដូចម្តេចក៏អ្នកដ៏មានអាយុនេះ ពោលអួតអរហត្តផលថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តស្រេចហើយ សោឡសកិច្ចអាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះ មិនមានឡើយ ។ ព្រះតថាគត ឬ សាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកស្មានហួសហេតុ ពោលថា ខ្លួនបានគុណវិសេសដោយទៀងទាត់ សម្គាល់ថា ដល់ហើយក្នុងធម៌ដែលខ្លួនមិនទាន់បានដល់ សម្គាល់ថា ធ្វើហើយក្នុងធម៌ ដែលខ្លួនមិនទាន់ធ្វើ សម្គាល់ថា ត្រាស់ដឹងហើយ ក្នុងធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ពោលអួតអរហត្តផលដោយការស្មានហួសហេតុថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គ-ព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោ-ឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ

៣៩៣



បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច មនសិករោតិ ក៏ំ នុ ខោ អយមា- យស្មា និស្សាយ អធិមានិកោ អធិមានសច្ចោ អប្បត្តេ បត្តសញ្ញី អកតេ កតសញ្ញី អនធិគតេ អធិគតសញ្ញី អធិមានេន អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថា- គតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិ- កុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច បជានាតិ ពហុស្សុតោ ខោ បន អយមាយស្មា សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវល- បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ

ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈនៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ធ្វើទុកក្នុងចិត្តនូវភិក្ខុនោះ កំណត់ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ អាស្រ័យហេតុដូចម្តេចហ្ន៎ បានជាអ្នកស្ងានហួសហេតុ ពោលថា ខ្លួនបានគុណវិសេស ដោយទៀងទាត់ ហើយសម្គាល់ថា ដល់ក្នុងធម៌ដែលខ្លួនមិនទាន់ដល់ សម្គាល់ថា ធ្វើហើយក្នុងធម៌ ដែលខ្លួនមិនទាន់ធ្វើ សម្គាល់ថា ត្រាស់ដឹងហើយក្នុងធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ហើយពោលអួតអរហត្តផល ដោយការស្មានហួសហេតុថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញប្រព្រឹត្តស្រេចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគតឬសាវ័ករបស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ ជាអ្នកចេះដឹងច្រើន ជាអ្នកចេះចាំនូវសូត្រ សន្សំនូវសូត្រ ធម៌ទាំងឡាយណា មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសមគ្គព្រហ្មចរិយៈព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌គ្រប់ទាំងអស់

តថារូបស្ស ធម្មា ពហុស្សុតា[១] ធតា[២] វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា តស្មា អយមាយស្មា អធិមានិកោ អធិមានសច្ចោ អប្បត្តេ បត្តសញ្ញី អកតេ កតសញ្ញី អនធិគតេ អធិគតសញ្ញី អធិមានេន អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ តមេនំ តថាគតោ វា តថាគតសាវកោ វា ឈាយី សមាបត្តិកុសលោ បរចិត្តកុសលោ បរចិត្តបរិយាយកុសលោ ឯវំ ចេតសា ចេតោ បរិច្ច បជានាតិ អភិជ្ឈាលុ ខោ បន អយមាយស្មា អភិជ្ឈាបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ អភិជ្ឈាបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។

១ ម. ឯត្ថន្តរេ ហោន្តីតិ បាឋោ ទិស្សតិ ។ ២ ម. ធាតា ។

ធម៌មានសភាពដូច្នោះ បុគ្គលនោះ ជាអ្នកចេះដឹងច្រើន ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ដោយចិត្ត ចាក់ធ្លុះចំពោះ ដោយយល់ឃើញ ព្រោះហេតុនោះ អ្នកដ៏មានអាយុនេះ ជាអ្នកស្មានហួសហេតុ ពោលថាខ្លួនបានគុណវិសេសដោយទៀងទាត់ សម្គាល់ថា ដល់ហើយក្នុងធម៌ដែលខ្លួន មិនទាន់ដល់ សម្គាល់ថា ធ្វើហើយក្នុងធម៌ដែលខ្លួន មិនបានធ្វើ សម្គាល់ថា ត្រាស់ដឹងហើយ ក្នុងធម៌ដែលខ្លួន មិនបានត្រាស់ដឹង ទើបពោលអួតអរហត្តផល ដោយការស្មាន ហួសហេតុថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តស្រេចហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះតថាគតឬសាវ័ក របស់ព្រះតថាគត ជាអ្នកមានឈាន ឈ្លាសក្នុងសមាបត្តិ ឈ្លាសក្នុងការដឹងចិត្តនៃបុគ្គលដទៃ ឈ្លាសក្នុងវារៈ នៃចិត្តរបស់បុគ្គលដទៃ រមែងកំណត់ដឹងនូវចិត្តភិក្ខុនោះ ដោយចិត្តយ៉ាងនេះថា អ្នកដ៏មានអាយុនេះ មានអភិជ្ឈា មានចិត្តត្រូវអភិជ្ឈារួបរឹតច្រើន ចំណែកខាងការរួបរឹត ដោយអភិជ្ឈានេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។

ព្យាបន្នោ[1] ខោ បន អយមាយស្មា ព្យាបាទបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ ព្យាបាទបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ថីនមិទ្ធី[2] ខោ បន អយមាយស្មា ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ ថីនមិទ្ធបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ ឧទ្ធតោ ខោ បន អយមាយស្មា ឧទ្ធច្ចបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ ឧទ្ធច្ចបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ វិចិកិច្ឆោ ខោ បន អយមាយស្មា វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា ពហុលំ វិហរតិ វិចិកិច្ឆាបរិយុដ្ឋានំ ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ កម្មារាមោ ខោ បន អយមាយស្មា កម្មរតោ កម្មារាមតំ អនុយុត្តោ កម្មារាមតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។

១ ឱ. ព្យាបាទោ ។ ២ ឱ. ម. ថីនមិទ្ធោ ។

អ្នកដ៏មានអាយុនេះ ជាអ្នកមានព្យាបាទ មានចិត្តត្រូវព្យាបាទរួបរឹតច្រើន ចំណែកខាងការរួបរឹត ដោយព្យាបាទនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ មានថីនមិទ្ធៈ មានចិត្តត្រូវថីនមិទ្ធៈរួបរឹតច្រើន ចំណែកខាងការរួបរឹត ដោយថីនមិទ្ធៈ នេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានឧទ្ធច្ចៈ មានចិត្តត្រូវឧទ្ធច្ចៈរួបរឹតច្រើន ចំណែកខាងការរួបរឹត ដោយឧទ្ធច្ចៈនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានវិចិកិច្ឆា មានចិត្តត្រូវវិចិកិច្ឆារួបរឹតច្រើន ចំណែកខាងការរួបរឹតដោយវិចិកិច្ឆានេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានការងារ ជាទីត្រេកអរ ត្រេកអរហើយក្នុងការងារ ប្រកបរឿយ ៗ នូវសេចក្តីត្រេកអរ ក្នុងការងារ ចំណែកខាងភាពនៃបុគ្គល ដែលមានការងារ ជាទីត្រេកអរនេះ ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។

កស្សាភមោ ខោ បន អយមាយស្មា កស្សបតោ កស្សាភមតំ អនុយុត្តោ កស្សាភមតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ និទ្ទា-ភមោ ខោ បន អយមាយស្មា និទ្ទារតោ និទ្ទាភមតំ អនុយុត្តោ និទ្ទាភមតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ សង្គណិកាភមោ ខោ បន អយមាយស្មា សង្គណិការតោ[១] សង្គណិ-កាភមតំ អនុយុត្តោ សង្គណិកាភមតា ខោ បន តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ មុដ្ឋស្សតិ ខោ បន អយមាយស្មា ឧត្តរិករណីយេ ឱរមត្តកេន វិសេសាធិគមេន អន្តរា-វោសានំ អាបន្នោ អន្តរាវោសានគមនំ ខោ បន

១ ម. សង្គណិករតោ ។

អ្នកដ៏មានអាយុនេះ ជាអ្នកមានតិរច្ឆានកថាជាទីត្រេកអរ ត្រេកអរហើយក្នុងតិរច្ឆានកថា ប្រកបរឿយៗ នូវសេចក្ដីត្រេកអរក្នុងតិរច្ឆានកថា ចំណែកខាងភាពនៃបុគ្គលមានតិរច្ឆានកថា ជាទីត្រេកអរនេះ ជាសេចក្ដីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានការដេកលក់ជាទីត្រេកអរ ត្រេកអរហើយក្នុងការដេកលក់ ប្រ-កបរឿយៗ នូវសេចក្ដីត្រេកអរក្នុងការដេកលក់ ចំណែកខាងភាពនៃបុគ្គលមានការដេកលក់ជាទីត្រេកអរនេះ ជាសេចក្ដីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកមានសេចក្ដីត្រេកអរក្នុងការប្រឡូកប្រឡំដោយពួក ត្រេកអរហើយក្នុងការប្រឡូកប្រ-ឡំដោយពួក ប្រកបរឿយៗ នូវសេចក្ដីត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួក ចំណែកខាងភាពនៃសេចក្ដីត្រេកអរ ក្នុងការប្រឡូកប្រឡំ ដោយពួក នេះជាសេចក្ដីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ អ្នកដ៏មានអាយុនេះ ជាអ្នកភ្លេចស្មារតី ដល់នូវការផ្អាកព្យា-យាមទុកក្នុងចន្លោះ ដោយការបានគុណវិសេសដ៏ថោកថយ ក្នុងកិច្ចដែលខ្លួនត្រូវធ្វើតទៅទៀត ចំណែកខាងការផ្អាកសេចក្ដីព្យាយាមក្នុងចន្លោះនេះ

តថាគតប្បវេទិតេ ធម្មវិនយេ បរិហានមេតំ ។ សោ វតាវុសោ ភិក្ខុ ឥមេ ទស ធម្មេ អប្បហាយ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតាវុសោ ភិក្ខុ ឥមេ ទស ធម្មេ បហាយ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

[៨៧] តត្រ ខោ ភគវា កាឡកភិក្ខុំ[១] អារព្ភ ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឥធ ភិក្ខវេ ភិក្ខុ អធិករណិកោ ហោតិ អធិករណសមថស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ អធិករណិកោ ហោតិ អធិករណសមថស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។

---

១ ឱ. កាសកំ ភិក្ខុំ ។ ម. តាលង្កតំ ភិក្ខុំ ។

ជាសេចក្តីសាបសូន្យ ក្នុងធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថា ភិក្ខុនោះឯង មិនលះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។ ម្នាលអាវុសោទាំងឡាយ ពាក្យថាភិក្ខុនោះឯង លះបង់នូវធម៌ទាំង ១០ ប្រការនេះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ដូច្នេះនុ៎ះ ទើបជាឋានៈ ។

[៨៧] ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធនូវកាឡកភិក្ខុ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើអធិករណ៍ មិនពោលសរសើរការរម្ងាប់អធិករណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើអធិករណ៍ មិនពោលសរសើរការរម្ងាប់អធិករណ៍ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។

បុន ចបរំ ភិក្ខវេ ភិក្ខុ ន សិក្ខាកាមោ ហោតិ សិក្ខាសមាទានស្ស[១] ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ ន សិក្ខាកាមោ ហោតិ សិក្ខាសមា-ទានស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ទាបិច្ឆោ ហោតិ ឥច្ឆាវិនយស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ ទាបិច្ឆោ ហោតិ ឥច្ឆាវិនយស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ កោធវិនយស្ស ន វណ្ណវាទី ។

១ ម. សិក្ខាកាមស្ស ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនប្រាថ្នានូវសិក្ខា មិនពោលសរសើរការសមាទាននូវសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានសេចក្តីប្រាថ្នា ក្នុងសិក្ខា មិនពោលសរសើរការសមាទាននូវសិក្ខា ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសេចក្តីប្រាថ្នាលាមក មិនពោលសរសើរការកម្ចាត់បង់នូវសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសេចក្តីប្រាថ្នាលាមក មិនពោលសរសើរ ការកម្ចាត់បង់នូវសេចក្តីប្រាថ្នា ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសេចក្តីក្រោធ មិនពោលសរសើរការកម្ចាត់បង់សេចក្តីក្រោធ ។

៣៤៩



យម្បិ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ កោធវិនយស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ មក្ខី ហោតិ មក្ខវិនយស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ មក្ខី ហោតិ មក្ខវិនយស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សឋោ ហោតិ សាឋេយ្យវិនយស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ សឋោ ហោតិ សាឋេយ្យវិនយស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសេចក្តីក្រោធ មិនពោលសរសើរការកម្ចាត់បង់សេចក្តីក្រោធ ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណគេ មិនពោលសរសើរការកម្ចាត់បង់នូវសេចក្តីលុបគុណគេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកលុបគុណគេ មិនពោលសរសើរការកម្ចាត់បង់នូវសេចក្តីលុបគុណគេ ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកអួតអាង មិនពោលសរសើរការកម្ចាត់បង់នូវការអួតអាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកអួតអាង មិនពោលសរសើរការកម្ចាត់បង់នូវការអួតអាង ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព

ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ មាយាវី ហោតិ មាយាវិនយស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ មាយាវី ហោតិ មាយាវិនយស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាម-ញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មានំ ន និសាមកជាតិកោ[១] ហោតិ ធម្មនិសន្តិយា ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ ធម្មានំ ន និសាមកជាតិកោ ហោតិ ធម្មនិសន្តិយា ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ន បដិសល្លានោ ហោតិ

១ ឱ. និសាមកជាតិយោ ។

មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានមាយា មិនពោលសរសើរការកម្ចាត់បង់នូវមាយា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានមាយា មិនពោលសរសើរនូវការកម្ចាត់បង់នូវមាយា ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រកបដោយជាតិ ជាអ្នកមិនពិចារ-ណានូវធម៌ មិនពោលសរសើរការពិចារណានូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រកបដោយជាតិ ជាអ្នកមិនពិចារណានូវធម៌ មិនពោលសរសើរការពិចារណានូវធម៌ ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នក មិនមានការពួនសម្ងំ

បដិសល្លានស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ ន បដិសល្លានោ ហោតិ បដិសល្លានស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្រហ្មចារីនំ ន បដិសន្ថារកោ[១] ហោតិ បដិសន្ថារកស្ស ន វណ្ណវាទី ។ យម្បិ ភិក្ខុ សព្រហ្មចារីនំ ន បដិសន្ថារកោ ហោតិ បដិសន្ថារកស្ស ន វណ្ណវាទី អយម្បិ ធម្មោ ន បិយតាយ ន គរុតាយ ន ភាវនាយ ន សាមញ្ញាយ ន ឯកីភាវាយ សំវត្តតិ ។ ឯវរូបស្ស ភិក្ខវេ ភិក្ខុនោ កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មំ សព្រហ្មចារី សក្ករេយ្យុំ គរុករេយ្យុំ[២] មានេយ្យុំ បូជេយ្យុន្តិ ។ អថខោ នំ សព្រហ្មចារី នេវ[៣] សក្ករោន្តិ ន គរុករោន្តិ ន មានេន្តិ ន បូជេន្តិ ។

---

១ ម. បដិសន្ធារកោ ។ ២ ម. គរុំករេយ្យុំ ។ ៣ ឱ. ម. ន ចេវ ។

មិនពោលសរសើរការពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនពួនសម្ងំ មិនពោលសរសើរការពួនសម្ងំ ដោយហេតុណា នេះឯងជាធម៌មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនធ្វើបដិសន្ថារៈ ដល់សព្រហ្មចារីបុគ្គល ទាំងឡាយ មិនពោលសរសើរបុគ្គលអ្នកធ្វើបដិសន្ថារៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនធ្វើបដិសន្ថារៈ ដល់ពួកសព្រហ្មចារីបុគ្គល មិនពោលសរសើរបុគ្គលអ្នកធ្វើបដិសន្ថារៈ ដោយហេតុណា នេះឯងជាធម៌ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្រឡាញ់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីគោរព មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីចម្រើន មិនប្រព្រឹត្តទៅ ដើម្បីភាពជាសមណៈ មិនប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសភាពយ៉ាងនេះ ពិតជាមានសេចក្ដីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើម្ដេចហ្ន៎ ពួកសព្រហ្មចារីបុគ្គល គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះអាត្មាអញ អេះ ។ ប៉ុន្តែ ពួកសព្រហ្មចារីបុគ្គល មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា ចំពោះភិក្ខុនោះឡើយ ។

តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ វិញ្ញូ សព្រហ្មចារី តេ ចាបកេ អកុសលេ ធម្មេ អប្បហីនេ សមនុបស្សន្តិ ។ សេយ្យថាបិ ភិក្ខវេ អស្សមូឡ្ហកស្ស[១] កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មំ មនុស្សា អាជានីយដ្ឋានេ ច ឋបេយ្យុំ អាជានីយភោជនញ្ច ភោជេយ្យុំ អាជានីយ-បរិមជ្ជនញ្ច បរិមជ្ជេយ្យុន្តិ ។ អថខោ តំ មនុស្សា ន ចេវ អាជានីយដ្ឋានេ ឋបេន្តិ ន ច អាជានីយភោជនំ ភោជេន្តិ ន ច អាជានីយបរិមជ្ជនំ បរិមជ្ជន្តិ ។ តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ វិញ្ញូ មនុស្សា តានិ សាឋេយ្យានិ កូដេយ្យានិ ជិម្ហេយ្យានិ វង្កេយ្យានិ អប្បហីនានិ សមនុបស្សន្តិ ឯវមេវ ខោ ភិក្ខវេ ឯវរូបស្ស ភិក្ខុនោ កិញ្ចាបិ ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មំ សព្រហ្មចារី សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុន្តិ

១ ឱ. អស្សខលុង្កស្ស ។ ម. អស្សខឡុង្កស្ស ។

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារី ជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងនោះ ដែលភិក្ខុទាំងនោះ មិនទាន់លះបង់ ។ ម្នាលភិក្ខុទាំងឡាយ ដូចសេះល្ងង់ខ្លៅ ពិតជាមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ពួកមនុស្សគប្បីតម្កើងអញ ក្នុងទីជាសេះអាជា-នេយ្យផង ឲ្យអញបរិភោគនូវភោជនរបស់សេះអាជានេយ្យផង ដុសខាត់អញ ដូចជាដុសខាត់សេះអាជានេយ្យផង ។ តែថា ពួកមនុស្សមិនតម្កល់នូវសេះនោះ ក្នុងទីនៃសេះអាជានេយ្យ មិនឲ្យបរិភោគនូវភោជនរបស់សេះអាជានេយ្យ មិនដុសខាត់ ដូចជាការដុសខាត់សេះអាជានេយ្យទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកមនុស្សជាអ្នកដឹង រមែងពិចារណាឃើញច្បាស់ នូវអំពើរឹងត្អឹង កៀចក្រាញ កកិចកកុច វៀចវេរ ទាំងនោះ ដែលសេះនោះមិនទាន់លះបង់ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច ភិក្ខុមានសភាពយ៉ាងនេះ ពិតជាមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកសព្រហ្មចារីបុគ្គល គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជា ចំពោះអាត្មាអញ អេះ

៣៦៣



អថខោ នំ សព្រហ្មចារី នេវ សក្ករោន្តិ ន គរុករោន្តិ ន មានេន្តិ ន បូជេន្តិ ។ តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ វិញ្ញូ សព្រហ្មចារី តេ ចាបកេ អកុសលេ ធម្មេ អប្បហីនេ សមនុបស្សន្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ន អធិករណិកោ ហោតិ អធិករណសមថស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ ន អធិករណិកោ ហោតិ អធិករណសមថស្ស វណ្ណវាទី អយម្បិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សិក្ខាកាមោ ហោតិ សិក្ខា-សមាទានស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ សិក្ខា-កាមោ ហោតិ សិក្ខាសមាទានស្ស វណ្ណវាទី អយម្បិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អប្បិច្ឆោ ហោតិ ឥច្ឆាវិនយស្ស វណ្ណវាទី ។

តែបើទុកជាដូច្នោះ ពួកសព្រហ្មចារីបុគ្គល ក៏មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា ចំពោះភិក្ខុនោះឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារីជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់នូវអកុសលធម៌លាមកទាំងនោះ ដែលភិក្ខុនោះមិនទាន់លះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនធ្វើអធិករណ៍ ពោលសរសើរការរម្ងាប់អធិករណ៍ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនធ្វើអធិករណ៍ ពោលសរសើរការរម្ងាប់អធិករណ៍ ដោយហេតុណា នេះឯងជាធម៌ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ ដើម្បីសេចក្តីគោរព ដើម្បីសេចក្តីចម្រើន ដើម្បីភាពជាសមណៈ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាក្នុងសិក្ខា ពោលសរសើរការសមាទានសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នាក្នុងសិក្ខា ពោលសរសើរការសមាទានសិក្ខា ដោយហេតុណា នេះឯង ជាធម៌ ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្រឡាញ់ ដើម្បីសេចក្តីគោរព ដើម្បីសេចក្តីចម្រើន ដើម្បីភាពជាសមណៈ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកប្រាថ្នាតិច ពោលសរសើរការកម្ចាត់បង់សេចក្តីប្រាថ្នា ។

យម្បិ ភិក្ខវេ ភិក្ខុ អប្បិច្ឆោ ហោតិ ឥច្ឆាវិនយស្ស វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អក្កោធនោ ហោតិ កោធវិនយស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ អក្កោធនោ ហោតិ កោធ-វិនយស្ស វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អមក្ខី ហោតិ មក្ខវិនយស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ អមក្ខី ហោតិ មក្ខវិនយស្ស វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អសឋោ ហោតិ សាឋេយ្យវិនយស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ អសឋោ ហោតិ សាឋេយ្យវិនយស្ស វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រាថ្នាតិច ពោលសរសើរការកម្ចាត់បង់នូវសេចក្ដីប្រាថ្នា ដោយហេតុណា នេះឯងជាធម៌ ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ ពោលសរសើរការកម្ចាត់បង់សេចក្ដីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនក្រោធ ពោលសរសើរការកម្ចាត់បង់សេចក្ដីក្រោធ ដោយហេតុណា នេះឯងជាធម៌ ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនលុបគុណគេ ពោលសរសើរការកម្ចាត់បង់ការលុបគុណគេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនលុបគុណគេ ពោលសរសើរការកម្ចាត់បង់ នូវការលុបគុណគេ ដោយហេតុណា នេះឯងជាធម៌ ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនអួតអាង ពោលសរសើរការកម្ចាត់បង់សេចក្ដីអួតអាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនអួតអាង ពោលសរសើរនូវការកម្ចាត់បង់សេចក្ដីអួតអាង ដោយហេតុណា នេះឯងជាធម៌ ។ បេ ។

ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ អមាយាវី ហោតិ មាយាវិនយស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ អមាយាវី ហោតិ មាយាវិនយស្ស វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មានំ និសាមកជាតិកោ ហោតិ ធម្មនិសន្តិយា វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ ធម្មានំ និសាមកជាតិកោ ហោតិ ធម្មនិសន្តិយា វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ បដិសល្លានោ ហោតិ បដិសល្លានស្ស វណ្ណវាទី ។ យម្បិ ភិក្ខវេ ភិក្ខុ បដិសល្លានោ ហោតិ បដិសល្លានស្ស វណ្ណវាទី អយម្បិ ធម្មោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ សព្រហ្មចារីនំ បដិសន្ថារកោ ហោតិ បដិសន្ថារកស្ស វណ្ណវាទី ។

ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមិនមានមាយា ពោលសរសើរការកម្ចាត់បង់មាយា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមិនមានមាយា ពោលសរសើរការកម្ចាត់បង់មាយា ដោយហេតុណា នេះឯងជាធម៌ ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុប្រកបដោយជាតិ ជាអ្នកពិចារណានូវធម៌ ពោលសរសើរការពិចារណានូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយជាតិជាអ្នកពិចារណានូវធម៌ ពោលសរសើរនូវការពិចារណាធម៌ ដោយហេតុណា នេះឯងជាធម៌ ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកពួនសម្ងំ ពោលសរសើរការពួនសម្ងំ ។ ភិក្ខុជាអ្នកពួនសម្ងំ ពោលសរសើរការពួនសម្ងំ ដោយហេតុណា នេះឯងជាធម៌ ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើនូវបដិសន្ថារៈ ដល់ពួកសព្រហ្មចារីបុគ្គល ពោលសរសើរបុគ្គលអ្នកធ្វើបដិសន្ថារៈ ។

៣៦៦



យម្បិ ភិក្ខវេ ភិក្ខុ សព្រហ្មចារីនំ បដិសន្ថារកោ ហោតិ បដិសន្ថារកស្ស វណ្ណភាសី អយម្បិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ ឯវរូបស្ស ភិក្ខវេ ភិក្ខុនោ កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មំ សព្រហ្មចារី សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុន្តិ អថខោ នំ សព្រហ្មចារី សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ ។ តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ វិញ្ញូ សព្រហ្មចារី តេ បាបកេ អកុសលេ ធម្មេ បហីនេ សមនុបស្សន្តិ ។ សេយ្យថាបិ ភិក្ខវេ ភទ្ទស្ស អស្សាជានីយស្ស កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មំ មនុស្សា អាជានីយដ្ឋានេ ច ឋបេយ្យុំ អាជានីយភោជនញ្ច ភោជេយ្យុំ អាជានីយបរិមជ្ជនញ្ច បរិមជ្ជេយ្យុន្តិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើបដិសន្ថារៈ ដល់ពួកសព្រហ្មចារីបុគ្គល ពោលសរសើរបុគ្គលអ្នកធ្វើនូវបដិសន្ថារៈ ដោយហេតុណា នេះឯងជាធម៌ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្រឡាញ់ ដើម្បីសេចក្ដីគោរព ដើម្បីសេចក្ដី ចម្រើន ដើម្បីភាពជាសមណៈ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុមានសភាពយ៉ាងនេះ បើទុកជា មិនគប្បីបង្កើតសេចក្ដី ប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ពួកសព្រហ្មចារីបុគ្គល គប្បីធ្វើ សក្ការៈ គោរព រាប់អាន បូជា ចំពោះអាត្មាអញ ក៏គង់តែពួកសព្រហ្មចារី-បុគ្គលធ្វើសក្ការៈ គោរព រាប់អាន បូជា ចំពោះភិក្ខុនោះដែរ ។ ដំណើរ នោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារី ជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់ នូវអកុសលធម៌ដ៏លាមក ទាំង នោះដែលភិក្ខុនោះលះបង់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសេះ អាជានេយ្យដ៏ចម្រើន បើទុកជា មិនគប្បីបង្កើតសេចក្ដីប្រាថ្នា យ៉ាង នេះថា ធ្វើដូចម្ដេចហ្ន៎ ពួកមនុស្សគប្បីតម្កើងអញ ក្នុងទីជាសេះ អាជានេយ្យផង គប្បីឲ្យអញបរិភោគនូវភោជនរបស់សេះអាជានេយ្យផង គប្បីជុសខាត់អញ ដោយការជុសខាត់ ដូចជាសេះអាជានេយ្យផង

អថខោ នំ មនុស្សា អាជានីយដ្ឋានេ ច ឋបេន្តិ អាជានីយភោជនញ្ច ភោជេន្តិ អាជានីយ-បរិមជ្ជនញ្ច បរិមជ្ជន្តិ ។ តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ វិញ្ញូ មនុស្សា តានិ សាឋេយ្យានិ កូដេយ្យានិ ជិម្ហេយ្យានិ វង្កេយ្យានិ បហីនានិ សមនុបស្សន្តិ ឯវមេវ ខោ ភិក្ខវេ ឯវរូបស្ស ភិក្ខុនោ កិញ្ចាបិ ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វត មំ សព្រហ្មចារី សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុន្តិ អថខោ នំ សព្រហ្មចារី សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ ។ តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ វិញ្ញូ សព្រហ្មចារី តេ បាបកេ អកុសលេ ធម្មេ បហីនេ សមនុបស្សន្តីតិ ។

[៨៨] យោ សោ ភិក្ខវេ ភិក្ខុ អក្កោសក-បរិភាសកោ អរិយុបវាទី សព្រហ្មចារីនំ អដ្ឋានមេតំ

ពួកមនុស្សក៏គង់តែតម្កើងសេះអាជានេយ្យនោះ ក្នុងទីជាសេះអាជានេយ្យផង ឲ្យបរិភោគនូវភោជនរបស់សេះអាជានេយ្យផង ជុសខាត់ដូចជាជុសខាត់សេះអាជានេយ្យផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះថា ពួកមនុស្សជាអ្នកដឹង រមែងពិចារណាឃើញច្បាស់នូវអំពើរឹងត្អឹងកៀចក្រាញ កកិចកកុច វៀចវេរទាំងនោះ ដែលសេះអាជា-នេយ្យនោះលះបង់ហើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យ ដូចជាភិក្ខុមានសភាពយ៉ាងនេះ បើទុកជាមិនគប្បីបង្កើតសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកសព្រហ្មចារីបុគ្គល គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជា ចំពោះអាត្មាអញ ក៏គង់តែពួកសព្រហ្មចារីបុគ្គល ធ្វើសក្ការៈ គោរព រាប់អាន បូជា ចំពោះភិក្ខុនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកសព្រហ្មចារី ជាវិញ្ញូជន រមែងពិចារណាឃើញច្បាស់នូវអកុសលធម៌ដ៏លាមកទាំងនោះ ដែលភិក្ខុនោះលះបង់ហើយ ។

[៨៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកជេរប្រទេចផ្តាសាពួកសព្រហ្មចារីបុគ្គល ជាអ្នកតិះដៀលព្រះអរិយៈ ដំណើរនោះ មិនមែន

អនវកាសោ[១] យំ សោ ទសន្នំ ព្យសនានំ អញ្ញតរញ្ញតរំ[២] ព្យសនំ ន[៣] និគច្ឆេយ្យ ។ កតមេសំ ទសន្នំ ។ អនធិគតំ នាធិគច្ឆតិ អធិគតា[៤] បរិហាយតិ សទ្ធម្មស្ស ន វោទាយន្តិ[៥] សទ្ធម្មេសុ វា អភិមានិកោ ហោតិ អនភិរតោ វា ព្រហ្មចរិយំ ចរតិ អញ្ញតរំ វា សង្កិលិដ្ឋំ អាបត្តឹ អាបជ្ជតិ គាឡ្ហំ រោគាតង្កំ[៦] ផុសតិ ឧម្មាទំ វា បាបុណាតិ ចិត្តក្ខេបំ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យោ សោ ភិក្ខវេ ភិក្ខុ អក្កោសកបរិភាសកោ អរិយុបវាទី សព្រហ្មចារីនំ អដ្ឋានមេតំ អនវកាសោ យំ សោ ឥមេសំ ទសន្នំ ព្យសនានំ អញ្ញតរញ្ញតរំ ព្យសនំ ន និគច្ឆេយ្យាតិ ។

១ ម. ឋានមេតំ អវកាសោ ។ ២ ឱ. អញ្ញតរំ ។ ៣ ម. នសទ្ធោ នត្ថិ ។ ៤ ម. អធិគតំ ។ ៥ ឱ. វោទាយតិ ។ ៦ ឱ. ម. គាឡ្ហំ វា រោគាតង្កំ ។

ជាហេតុ មិនមែនជាបច្ច័យ ដែលមិននាំឲ្យភិក្ខុនោះ គប្បីដល់នូវសេចក្តីវិនាសទាំង ១០ ប្រការ សេចក្តីវិនាសណាមួយទេ ។ សេចក្តីវិនាសទាំង ១០ ប្រការ តើដូចម្តេចខ្លះ ។ បុគ្គលនោះមិនបាននូវគុណធម៌ ដែលខ្លួនមិនទាន់បាន ១ សាបសូន្យចាកគុណធម៌ ដែលខ្លួនបានហើយ ១ ព្រះសទ្ធម្មរបស់បុគ្គលនោះមិនផូរផង់ ១ ជាអ្នកស្មានហួសហេតុ ក្នុងព្រះសទ្ធម្ម ១ ប្រព្រឹត្តព្រហ្មចារ្យទាំងមិនមានសេចក្តីត្រេកអរ ១ ត្រូវអាបត្តិណាមួយដែលសៅហ្មង ១ ប្រទះសេចក្តីទុក្ខ ព្រោះរោគដ៏ធ្ងន់ ១ ដល់នូវការឆ្កួតវាយមាយចិត្ត ១ ធ្វើមរណៈទាំងវង្វេង ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជេរប្រទេច ផ្តាសា ពួកសព្រហ្មចារីបុគ្គលជាអ្នកតិះដៀលព្រះអរិយៈ ដំណើរនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ដែលមិនមែន នាំឲ្យភិក្ខុនោះ គប្បីដល់នូវសេចក្តីវិនាសទាំង ១០ ប្រការនេះ សេចក្តីវិនាសណាមួយទេ ។

[៨៩] អថខោ កោកាលិកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច បាបិច្ឆា ភន្តេ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំគតាតិ ។ មា ហេវំ កោកាលិក មា ហេវំ កោកាលិក បសាទេហិ កោកាលិក សារីបុត្ត-មោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ ទុតិយម្បិ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯត-ទវោច កិញ្ចាបិ មេ ភន្តេ ភគវា សទ្ធាយិកោ បច្ចយិកោ អថខោ បាបិច្ឆា វ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំគតាតិ ។ មា ហេវំ កោកាលិក មា ហេវំ កោកាលិក បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។

[៨៩] គ្រានោះ កោកាលិកភិក្ខុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះកោកាលិកភិក្ខុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សារីបុត្តនិងមោគ្គល្លាន ជាអ្នកប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ព្រះអង្គត្រាស់ថា ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះ ម្នាលកោកាលិកៈ អ្នកកុំនិយាយ យ៉ាងនេះឡើយ ម្នាលកោកាលិកៈ ចូរអ្នកញុំាងចិត្តឲ្យជ្រះថ្លា ចំពោះសារីបុត្តនិងមោគ្គល្លានចុះ ព្រោះថា សារីបុត្តនិងមោគ្គល្លាន ជាអ្នកមានសីល ជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ទូលព្រះដ៏មានព្រះភាគ ជាគម្រប់ ២ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ គួរខ្ញុំព្រះអង្គជឿយកតម្រាប់ ក៏មែនពិតហើយ តែថា សារីបុត្តនិងមោគ្គល្លាន ជាអ្នកប្រាថ្នាលាមកប្រាកដ លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ម្នាលកោកាលិកៈ អ្នកកុំនិយាយយ៉ាងនេះ ម្នាលកោកាលិកៈ អ្នកកុំនិយាយ យ៉ាងនេះឡើយ ម្នាលកោកាលិកៈ អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លា ចំពោះសារីបុត្តនិងមោគ្គល្លានចុះ ព្រោះថា សារីបុត្តនិងមោគ្គល្លាន មានសីល ជាទីស្រឡាញ់ ។

តតិយម្បិ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច កិញ្ចាបិ ខោ មេ ភន្តេ ភគវា សទ្ធាយិកោ បច្ចយិកោ អថខោ បាបិច្ឆា វ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំគតាតិ ។ មា ហេវំ កោកាលិក មា ហេវំ កោកាលិក បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ អថខោ កោកាលិកោ ភិក្ខុ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អចិរប្បក្កន្តស្ស ច កោកាលិកស្ស ភិក្ខុនោ សាសបមត្តីហិ បិឡកាហិ សព្វោ កាយោ ផុដ្ឋោ[១] អហោសិ សាសបមត្តិយោ ហុត្វា មុគ្គមត្តិយោ អហេសុំ មុគ្គមត្តិយោ ហុត្វា កាឡាយមត្តិយោ[២] អហេសុំ កាឡាយមត្តិយោ ហុត្វា

---

១ ឱ. ម. ផុដោ ។ ២ ឱ. កលាយមត្តិយោ ។

កោកាលិកភិក្ខុ ក៏ទូលព្រះដ៏មានព្រះភាគ ជាគម្រប់ ៣ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ គួរខ្ញុំព្រះអង្គជឿយកតម្រាប់តាមក៏ពិតមែនហើយ តែថា សារីបុត្តនិងមោគ្គល្លាន សុទ្ធតែជាអ្នកប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ម្នាលកោកា-លិកៈ អ្នកកុំនិយាយ យ៉ាងនេះ ម្នាលកោកាលិកៈ អ្នកកុំនិយាយ យ៉ាងនេះឡើយ ម្នាលកោកាលិកៈ អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លា ចំពោះសារីបុត្តនិងមោគ្គល្លានចុះ ព្រោះថា សារីបុត្តនិងមោគ្គល្លាន ជាអ្នកមានសីលជាទីស្រឡាញ់ ។ គ្រានោះ កោកាលិកភិក្ខុ ក្រោកចាកអាសនៈហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចក៏ធ្វើប្រទក្សិណ ចៀសចេញទៅ ។ ក៏កាលដែលកោកាលិកភិក្ខុ ចៀសចេញទៅមិនយូរប៉ុន្មាន ក៏កើតអុតប៉ុនៗ គ្រាប់ស្ពៃរួបរឹតកាយទាំងមូល លុះអុតកើតប៉ុនៗ គ្រាប់ស្ពៃហើយ ក៏ដោរឡើង ប៉ុនគ្រាប់សណ្តែកបាយ លុះប៉ុនគ្រាប់សណ្តែកបាយហើយ ក៏ដោរឡើង ប៉ុនគ្រាប់សណ្តែកកង់ លុះប៉ុនគ្រាប់សណ្តែកកង់ហើយ

កោលដ្ឋិមត្តិយោ អហោសុំ កោលដ្ឋិមត្តិយោ ហុត្វា កោលមត្តិយោ អហោសុំ កោលមត្តិយោ ហុត្វា អាមលកមត្តិយោ អហោសុំ អាមលកមត្តិយោ ហុត្វា[១] វេលុវសលាដុកមត្តិយោ អហោសុំ វេលុវសលាដុកមត្តិយោ ហុត្វា វិល្វមត្តិយោ[២] អហោសុំ វិល្វមត្តិយោ ហុត្វា បភិជ្ជឹសុ បុព្វញ្ច លោហិតញ្ច បគ្ឃរឹសុ ។ ស្វាស្សុជំ[៣] កទលិបត្តេសុ សេតិ មច្ឆោវ វិសកលិកតោ[៤] ។ អថខោ តុជិបច្ចេកព្រហ្មា[៥] យេន កោកាលិកោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា វេហាសេ ឋត្វា កោកាលិកំ ភិក្ខុំ ឯតទវោច បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ កោសិ ត្វំ អាវុសោតិ ។

---

១ ម. ឯត្ថន្តរេ តិណ្ឌុកមត្តិយោ អហោសុំ តិណ្ឌុកមត្តិយោ ហុត្វាតិ បាឋោ ទិស្សន្តិ ។ ២ ឱ. ពិល្លមត្តិយោ ។ ម. ពិលមត្តិយោ ។ ៣ ម. សោស្សុទំ ។ ៤ ឱ. ម. វិសគិលិតោ ។ ៥ ឱ. តុទុប្បច្ចេកព្រហ្មា ។ ម. តុទិបច្ចេកព្រហ្មា ។

ក៏ដោរឡើង ប៉ុនគ្រាប់ពទ្រា លុះប៉ុនគ្រាប់ពទ្រាហើយ ក៏ដោរឡើង ប៉ុនផ្លែពទ្រា លុះប៉ុនផ្លែពទ្រាហើយ ក៏ដោរឡើង ប៉ុនផ្លែកន្ទួតព្រៃ លុះប៉ុនផ្លែកន្ទួតព្រៃហើយ ក៏ដោរឡើងប៉ុនក្តឹបល្ពៅ លុះប៉ុនក្តឹបល្ពៅហើយ ក៏ដោរឡើង ប៉ុនផ្លែល្ពៅធំ លុះប៉ុនផ្លែល្ពៅធំហើយ ខ្ទុះនិងឈាមក៏ហូរចេញរហាម ។ បានឮថា កោកាលិកភិក្ខុនោះ ដេកលើស្លឹកចេក ដូចជាត្រីដែលគេ ប្រាស់ស្រកាហើយ ។ លំដាប់នោះ តុទិ-បច្ចេកព្រហ្ម[១] បានចូលទៅរក កោកាលិកភិក្ខុ លុះចូលទៅដល់ហើយ ក៏ឋិតនៅឰដ៏អាកាស ហើយពោលទៅនឹងកោកាលិកភិក្ខុ ដូច្នេះថា ម្នាលកោកាលិកៈ ចូរលោកញុំាងចិត្តឲ្យជ្រះថ្លា ចំពោះព្រះសារី-បុត្តនិងព្រះមោគ្គល្លានចុះ ព្រោះថា ព្រះសារីបុត្តនិងព្រះមោគ្គល្លានមានសីល ជាទីស្រឡាញ់ ។ ម្នាលអាវុសោ អ្នកជាអ្វី ។

១ ព្រហ្មនោះ កាលពីដើម ជាព្រះថេរៈឈ្មោះតុទិត្ថេរ ត្រូវជាឧបជ្ឈាយ៍របស់កោកាលិកភិក្ខុ បានដល់អនាគាមិផលទៅកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ។ អដ្ឋកថា។

អហំ តុទិបច្ចេកព្រហ្មាតិ ។ ឥធ តុំ អាវុសោ ភគវតា អនាគាមី ព្យាកតោ អថ កិញ្ចរហិ ឥធាគតោ បស្ស យាវញ្ច[១] តេ ឥទំ អបរទ្ធន្តិ ។ អថខោ តុទិបច្ចេកព្រហ្មា កោកាលិកំ ភិក្ខុំ គាថាយ[២] អជ្ឈភាសិ

បុរិសស្ស ហិ ជាតស្ស កុធារី[៣] ជាយតេ មុខេ
យាយ ឆិន្ទតិ អត្តានំ ពាលោ ទុព្ភាសិតំ ភណំ ។
យោ និន្ទិយំ បសំសតិ តំ វា និន្ទតិ យោ បសំសិយោ
វិចិនាតិ មុខេន សោ កលឹ កលិនា តេន សុខំ ន វិន្ទតិ ។

---

១ ឱ. យាវ ។ ២ ម. គាថាហិ ។ ៣ ឱ. កុថារិ ។

យើង ជាតុទិបច្ចេកព្រហ្ម ។ ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា អ្នកឯងជាអនាគាមិបុគ្គលហើយតើ ចុះអ្នកឯងមកក្នុងទីនេះ ដើម្បីអ្វីទៀត អ្នកឯងចូរមើលតែនូវកំហុសរបស់អ្នកនោះចុះ ។ លំដាប់នោះ តុទិបច្ចេកព្រហ្ម ក៏បានពោលនឹងកោកាលិកភិក្ខុ ដោយគាថាដូច្នេះថា

បុគ្គលពាល កាលពោលនូវទុព្ភាសិត ឈ្មោះថាកាប់ខ្លួនឯង
ដោយប៉ូវថៅ គឺផរុសវាចាណា ប៉ូវថៅគឺផរុសវាចានោះ
កើតតែក្នុងមាត់ របស់បុរសជាតិ ដោយពិត ។

បុគ្គលណា សរសើរនូវបុគ្គលដែលគួរនិន្ទាក្តី តិះដៀលបុគ្គលដែលគួរសរសើរនោះក្តី បុគ្គលនោះឈ្មោះថា សន្សំនូវទោស ដោយមាត់ រមែងមិនបានសេចក្តីសុខ ព្រោះទោសនោះទេ ។

អប្បមត្តោ[១] អយំ កលិ
យោ អក្ខេសុ ធនបរាជយោ
(សព្វស្សាបិ សហាបិ អត្តនា)
អយមេវ មហត្តរោ កលិ
យោ សុគតេសុ មនំ បទោសយេ[២] ។
សតំ សហស្សានំ និរព្វុទានំ
ឆត្តឹស ច បញ្ច ច[៣] អព្វុទានិ
យមរិយគរហី និរយំ ឧបេតិ
វាចំ មនញ្ច បណិធាយ បាបកន្តិ ។

អថខោ កោកាលិកោ ភិក្ខុ តេនេវ- ពាធេន កាលមកាសិ ។ កាលកតោ ច កោកាលិកោ ភិក្ខុ បទុមនិរយំ ឧបបជ្ជតិ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វា ។

១ ម. អប្បមត្តកោ ។ ២ ម. បទូសយេ ។ ៣ ឱ. ម. ឆត្តឹសតិ បញ្ច ច ។

ការចាញ់ ដោយទ្រព្យណា ព្រោះល្បែងភ្នាល់ទាំងឡាយ (ព្រមទាំងខ្លួនទាំងអស់) ជាកំហុសមានប្រមាណតិចទេ បុគ្គលណា ញុំាងចិត្ត ឲ្យប្រទូស្ត ចំពោះពួកបុគ្គលអ្នកប្រព្រឹត្តល្អនេះឯង ជាកំហុសធំក្រៃលែង ។ បុគ្គលតម្កល់នូវវាចានិងចិត្តដ៏លាមក ហើយតិះដៀលព្រះអរិយៈ រមែងទៅកាន់នរកណា នរកនោះ មាន ១ សែននិរព្វុទៈផង និង ៣៦ អព្វុទៈ[១] (ដោយឡែកទៀត) ផង ៥ អព្វុទៈផង ។

គ្រានោះ កោកាលិកភិក្ខុ ក៏ធ្វើមរណកាល ដោយជំងឺនោះឯង ។ លុះកោកាលិកភិក្ខុ ធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះថ្នាំងថ្នាក់ចិត្តចំពោះព្រះសារីបុត្តនិងព្រះមោគ្គល្លាន ។

១ អដ្ឋកថាជា និរព្វុទៈវិញ ។

អថខោ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ[1] កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ[2] ខោ ព្រហ្មា សហម្បតិ ភគវន្តំ ឯតទវោច កោកាលិកោ ភន្តេ ភិក្ខុ កាលកតោ កាលកតោ ច ភន្តេ កោកាលិកោ ភិក្ខុ បទុមនិរយំ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។ ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុប-សង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

១ ម. អភិក្កន្តវណ្ណា ។ ២ ម. ឋិតា ។

គ្រានោះ កាលបើរាត្រីបឋមយាមកន្លងទៅហើយ សហម្បតិព្រហ្ម មានរស្មីរុងរឿងធ្វើវត្តជេតពនទាំងមូល ឲ្យភ្លឺច្បាស់ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសហម្បតិព្រហ្មឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលទៅហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណ-កាល ទៅកើតក្នុងបទុមនរក ព្រោះថ្នាំងថ្នាក់ចិត្តចំពោះព្រះសារីបុត្តនិងព្រះមោគ្គល្លាន ។ សហម្បតិព្រហ្មបានពោលពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយបាត់ចាកទីនោះទៅមួយរំពេច ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលបើរាត្រីនោះ កន្លងទៅហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងយប់មិញនេះ កាលរាត្រីបឋមយាម កន្លងទៅហើយ សហម្បតិព្រហ្ម មានរស្មីរុងរឿង ធ្វើវត្តជេតពនទាំងមូល ឲ្យភ្លឺច្បាស់ ហើយចូលមករកតថាគត លុះចូលមកដល់ថ្វាយបង្គំតថាគត ហើយឋិតនៅ ក្នុងទីសមគួរ ។

ឯកមន្តំ ឋិតោ ខោ ភិក្ខវេ ព្រហ្មា សហម្បតិ មំ ឯតទវោច កោកាលិកោ ភន្តេ ភិក្ខុ កាលកតោ កាលកតោ ច ភន្តេ កោកាលិកោ ភិក្ខុ បទុមនិរយំ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។ ឥទមវោច ភិក្ខវេ ព្រហ្មា សហម្បតិ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កីវទីឃំ[1] នុ ខោ ភន្តេ បទុមនិរយេ អាយុប្បមាណន្តិ ។ ទីឃំ ខោ ភិក្ខុ បទុមនិរយេ អាយុប្បមាណំ តំ ន សុករំ សង្ខាតុំ ឯត្តកានិ វស្សានីតិ វា ឯត្តកានិ វស្សសតានីតិ វា ឯត្តកានិ វស្សសហស្សានីតិ វា ឯត្តកានិ វស្សសតសហស្សានីតិ វាតិ ។ សក្កា បន ភន្តេ ឧបមា[2] កាតុន្តិ ។ សក្កា ភិក្ខូតិ ភគវា អវោច សេយ្យថាបិ ភិក្ខវេ

១ ម. កឹវទីឃំ ។ ២ ម. ឧបមំ ។

ម្នាលភិក្ខុទាំងឡាយ លុះសហម្បតិព្រហ្ម ឋិតនៅ ក្នុងទីសមគួរហើយ បានពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលទៅហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណ-កាលទៅ ទៅកើតក្នុងបទុមនរក ព្រោះផ្ចាំងផ្ចាក់ចិត្តចំពោះសារីបុត្តនឹងមោគ្គល្លាន ។ ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណបាត់ចាកទីនោះទៅមួយរំពេច ។ និមិត្តតែព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក្រាបថ្វាយបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រមាណនៃអាយុ ក្នុងបទុមនរកវែងប៉ុន្មាន ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រមាណនៃអាយុក្នុងបទុមនរក វែងណាស់ ប្រមាណនៃអាយុ ក្នុងបទុមនរកនោះបុគ្គលមិនងាយនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ឬប៉ុណ្ណេះពាន់ឆ្នាំ ឬក៏ប៉ុណ្ណេះសែនឆ្នាំបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើសេចក្តីឧបមាបានដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាចធ្វើបាន ដូច្នេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រៀបដូច

វីសតិខារិកោ កោសលកោ តិលវាហោ តតោ បុរិសោ វស្សសតសហស្សស្ស[១] អច្ចយេន ឯកមេកំ តិលំ ឧទ្ធរេយ្យ ។ ខិប្បតរំ ខោ សោ ភិក្ខុ វីសតិខារិកោ កោសលកោ តិលវាហោ ឥមិនា ឧបក្កមេន បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ន ត្វេវ ឯកោ អព្វុទោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អព្វុទា និរយា ឯវមេកោ និរព្វុទោ និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ និរព្វុទា និរយា ឯវមេកោ អពព្វោ និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ អពព្វា និរយា ឯវមេកោ អហហោ និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ អហហា និរយា ឯវមេកោ អដដោ និរយោ ។

១ ឱ. ម. វស្សសតស្ស វស្សសតស្ស ។

រទេះផ្ទុកល្ង របស់អ្នកដែនកោសលចំណុះ ២០ ខារិកៈ[១] (អម្រែក) កន្លងទៅបាន ១ សែនឆ្នាំ មានបុរសម្នាក់ រើសយកល្ង ១ គ្រាប់ ៗ អំពីរទេះនោះចេញ ។ ម្នាលភិក្ខុ រទេះផ្ទុកល្ង របស់អ្នកដែនកោសលចំណុះ ២០ ខារិកៈនោះដល់នូវការអស់រលីងទៅ ដោយសេចក្តីព្យាយាមនេះឈ្មោះថា ឆាប់រហ័សនៅឡើយ ឯអព្វុទនរក ១ មិនឆាប់ដូច្នេះទេ ម្នាលភិក្ខុ ដូចជា អព្វុទៈ[២]នរក ២០ ត្រូវជា និរព្វុទនរក ១ ។ ម្នាលភិក្ខុ ដូចជា និរព្វុទនរក ២០ ត្រូវជា អពពូនរក ១ ។ ម្នាលភិក្ខុ ដូចជា អពពូនរក ២០ ត្រូវជា អហហនរក ១ ។ ម្នាលភិក្ខុ ដូចជា អហហនរក ២០ ត្រូវជា អដដនរក ១ ។

---

១. ៤ បត្ថៈ របស់អ្នកមគធៈ ត្រូវជាមួយបត្ថៈ ក្នុងដែនកោសល ៤ បត្ថៈ របស់អ្នកដែនកោសលនោះ ត្រូវជាមួយអាឡ្ហកៈ ៤ អាឡ្ហកៈត្រូវជាមួយទោនៈ ៤ ទោនៈ ត្រូវជាមួយមានិកា ៤ មានិកា ត្រូវជាមួយខារី ។ អដ្ឋកថា ។

២ ពាក្យ អព្វុទៈនេះជាឈ្មោះនៃការរាប់ឆ្នាំរបស់សត្វ ដែលឆេះនៅ ក្នុងនរកអវីចិនោះឯង ដូចសម្តែងតទៅ គឺសំខ្យាមួយរយសែនឈ្មោះថា ១ កោដិ ១ រយសែនកោដិឈ្មោះថា ១ បកោដិ ១ រយសែនបកោដិឈ្មោះថា ១ កោដិប្បកោដិ ១ រយសែនកោដិប្បកោដិឈ្មោះថា ១ នហុត ១ រយសែននហុតឈ្មោះថា និន្នហុត ១ រយសែននិន្នហុតឈ្មោះថា ១ អព្វុទៈ ម្តែគុណអំពីអព្វុទៈឈ្មោះថា និរព្វុទៈ ។ ន័យនេះគប្បីដឹងគ្រប់បទទាំងអស់ ។ អដ្ឋកថា ។

សេយ្យថាបិ ភិក្ខុ វីសតិ អហហា និរយា ឯវមេកោ កុមុទោ និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ កុមុទា និរយា ឯវមេកោ សោគន្ធិកោ និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ សោគន្ធិកា និរយា ឯវមេកោ ឧប្បលោ[១] និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ ឧប្បលា និរយា ឯវមេកោ បុណ្ឌរីកោ និរយោ ។ សេយ្យថាបិ ភិក្ខុ វីសតិ បុណ្ឌរីកា និរយា ឯវមេកោ បទុមោ និរយោ ។ បទុមេ ខោ បន ភិក្ខុ និរយេ កោកាលិកោ ភិក្ខុ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

បុរិសស្ស ហិ ជាតស្ស កុឋារី ជាយតេ មុខេ
យាយ ឆិន្ទតិ អត្តានំ ពាលោ ទុព្ភាសិតំ ភណំ ។

---

១ ឱ. ម. ឧប្បលកោ ។

ម្នាលភិក្ខុ ដូចជា អដដនរក ២០ ត្រូវជា កុមុទនរក ១ ។ ម្នាលភិក្ខុ ដូចជា កុមុទនរក ២០ ត្រូវជា សោគន្ធិកនរក ១ ។ ម្នាលភិក្ខុ ដូចជា សោគន្ធិកនរក ២០ ត្រូវជា ឧប្បលនរក ១ ។ ម្នាលភិក្ខុ ដូចជា ឧប្បលនរក ២០ ត្រូវជា បុណ្ឌរីកនរក ១ ។ ម្នាលភិក្ខុ ដូចជា បុណ្ឌរីក-នរក ២០ ត្រូវជា បទុមនរក ១ ។ ម្នាលភិក្ខុ ដូចជាកោកាលិកភិក្ខុ ទៅកើតក្នុងបទុមនរក ព្រោះផ្តាំងផ្តាក់ចិត្តចំពោះសារីបុត្តនិងមោគ្គល្លាន ។ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌នេះហើយ ព្រះសុគតជាព្រះសាស្តា លុះសម្តែងធម៌នេះហើយ ទើបសម្តែងគាថានេះតទៅទៀតថា

បុគ្គលពាល កាលពោលនូវពាក្យទុព្ភាសិត ឈ្មោះថា កាប់នូវខ្លួន ដោយប៉ូវថៅគឺផរុសវាចាណា ប៉ូវថៅគឺផរុសវាចានោះ តែងកើតក្នុងមាត់ របស់បុរសជាតិ ដោយពិត ។

យោ និន្ទិយំ បសំសតិ តំ វា និន្ទតិ យោ បសំសិយោ វិចិនាតិ មុខេន សោ កលឹ កលិនា តេន សុខំ ន វិន្ទតិ ។ អប្បមត្តោ អយំ កលិ យោ អក្ខេសុ ធនបរាជយោ

( សព្វស្សាបិ សហាបិ អត្តនា )

អយមេវ មហត្តរោ កលិ

យោ សុគតេសុ មនំ បទោសយេ ។

សតំ សហស្សានំ និរព្ពុទានំ

ឆត្តឹស ច បញ្ច ច[១] អព្ពុទានិ

យមរិយគរហី និរយំ ឧបេតិ

វាចំ មនញ្ច បណិធាយ បាបកន្តិ ។

[៩០] អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច

១ ឱ. ម. ឆត្តឹសតិ បញ្ច ច ។

បុគ្គលណា សរសើរនូវបុគ្គលដែលគួរនិន្ទា ឬតិះដៀលបុគ្គលដែលគួរសរសើរ បុគ្គលនោះឈ្មោះថាសន្សំនូវទោសដោយមាត់ រមែងមិនបានសេចក្ដីសុខ ព្រោះទោសនោះទេ ។

ការចាញ់ ដោយទ្រព្យណា ព្រោះល្បែងភ្នាល់ទាំងឡាយ (ព្រមទាំងខ្លួនទាំងអស់) ការចាញ់ នេះឈ្មោះថា កំហុសមានប្រមាណតិចទេ បុគ្គលណា ញុំាងចិត្តឲ្យប្រទូស្ត ចំពោះពួកបុគ្គលដែលប្រព្រឹត្តល្អ បុគ្គលនេះឯង ទើបឈ្មោះថា មានកំហុសធំក្រៃលែង ។ បុគ្គលតម្កល់វាចានិងចិត្តដ៏លាមក តិះដៀលព្រះអរិយៈ រមែងទៅកើត ក្នុងនរកណា នរកនោះ មានមួយសែននិរព្វុទៈ និង ៣៦ និរព្វុទៈ (ដោយឡែកទៀត) ផង ៥ អព្វុទៈផង ។

[៩០] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយ ក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ក៏ត្រាស់សួរដូច្នេះថា

៣៧៩



កតិ នុ ខោ សារីបុត្ត ខីណាសវស្ស ភិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ ទស ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ កតមានិ ទស ។ ឥធ ភន្តេ ខីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទម្បិ[១] ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។

---

១ អយំ បិសទ្ទោ អយុត្តោ ។ សោ ហិ នាម បិសទ្ទោ សព្វដ្ឋានេសុ ឧត្តរឹ ទុតិយបទេ បយុត្តោយេវ ។

ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រព ប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈថា អាសវៈរបស់អាត្មាអញ អស់ហើយ កម្លាំងរបស់ភិក្ខុ ជាខីណាស្រពនោះ តើមានប៉ុន្មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅ នៃអាសវៈថា អាសវៈរបស់អាត្មាអញ អស់ហើយ កម្លាំងរបស់ភិក្ខុ ជាខីណាស្រពនោះ មាន ១០ យ៉ាង ។ កម្លាំង ១០ យ៉ាងតើដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន គឺភិក្ខុជាខីណាស្រព ក្នុងសាសនានេះ ពិចារណាឃើញច្បាស់នូវសង្ខារទាំងពួង ដោយសេចក្តីថា មិនទៀង ដោយបញ្ញាដ៏ប្រពៃតាមពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ពិចារណាឃើញច្បាស់នូវសង្ខារទាំងពួង ដោយសេចក្តីថា មិនទៀង ដោយបញ្ញាដ៏ប្រពៃតាមពិត ដោយហេតុណា បពិត្រព្រះអង្គចម្រើន នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រព អាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈរបស់អាត្មាអញ អស់ហើយ ១ ។

បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ អង្គារកាសុបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ អង្គារកាសុបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ[១] ព្យន្តីភូតំ សព្វសោ អាសវដ្ឋានិយេហិ ធម្មេហិ ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានិយេហិ ធម្មេហិ ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ

---

១ ម. សកដ្ឋានេ និក្ខម្មាភិរតំ ។

បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ពិចារណាឃើញច្បាស់នូវកាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃតាមពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ពិចារណាឃើញច្បាស់ នូវកាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃតាមពិត ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រព អាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញ អស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព មានចិត្តឱនទៅកាន់វិវេក ឈមទៅរកវិវេក ទោរទន់ទៅរកវិវេក ឋិតនៅក្នុងវិវេក ត្រេកអរក្នុងការចេញចាកកាម ជាចិត្តវិនាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព មានចិត្តឱនទៅរកវិវេក ឈមទៅរកវិវេក ទោរទន់ទៅរកវិវេក ឋិតនៅក្នុងវិវេក ត្រេកអរក្នុងការចេញចាកកាម ជាចិត្តវិនាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព

៣៨១

ទុតិយបណ្ណាសកេ ថេរវគ្គោ

យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សម្មប្បធានា ភាវិតា ហោន្តិ សុភាវិតា... ចត្តារោ ឥទ្ធិប្បាទា ភាវិតា ហោន្តិ សុភាវិតា... បញ្ចិន្ទ្រិយានិ បញ្ច ពលានិ ភាវិតានិ ហោន្តិ សុភាវិតានិ... សត្ត ពោជ្ឈង្គា ភាវិតា ហោន្តិ សុភាវិតា... អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ។

ដែលនាំឲ្យភិក្ខុជាខីណាស្រព អាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រពចម្រើន អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពបានចម្រើន អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំង របស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រព អាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈរបស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណា-ស្រពបានចម្រើន អប់រំល្អហើយ នូវសម្មប្បធាន ៤ ... ១ ចម្រើន អប់រំល្អហើយ នូវឥទ្ធិបាទ ៤ ... ១ ចម្រើន អប់រំល្អហើយ នូវឥន្ទ្រិយ ៥ ពលៈ ៥ ... ១ ចម្រើន អប់រំល្អហើយ នូវពោជ្ឈង្គ ៧ ... ១ ចម្រើន អប់រំល្អហើយ នូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ។

យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ ឥមានិ ខោ ភន្តេ ទស ខីណាសវស្ស ភិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។

ថេរវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

វាហុនោ ចានន្ទោ ច បុណ្ណិយោ ច ព្យាករណំ

កត្ថី អញ្ញាជិករណំ កោកាលិកោ ច ពលានិ ច[១] ។

---

១ ម. វាហនានន្ទោ បុណ្ណិយោ ព្យាករំ កត្ថិ មានិកោ នបិយកោ សកោកាលិ ខីណាសវពលេន ចាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ចម្រើន អប់រំល្អ ហើយនូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ចាត់ជាកម្លាំង របស់ភិក្ខុជាខីណាស្រព ដែលនាំឲ្យភិក្ខុជាខីណាស្រព អាស្រ័យនូវកម្លាំងហើយ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ប្រកបដោយកម្លាំងទាំងឡាយណា ប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញ អស់ហើយ កម្លាំងរបស់ភិក្ខុ ជាខីណាស្រពនោះមាន ១០ យ៉ាងនេះឯង ។

ចប់ ថេរវគ្គទី ៤ ។

# ឧទ្ទាននៃថេរវគ្គនោះគឺ

និយាយអំពីព្រះវាហុនត្ថេរ ១ ព្រះអានន្ទត្ថេរ ១ ព្រះបុណ្ណិយ-ត្ថេរ ១ ការពោលអួតអរហត្តផល ១ ភិក្ខុពោលអួត ១ ការស្មានហួសហេតុ ១ អធិករណ៍ ១ កោកាលិកភិក្ខុ ១ កម្លាំង ១ ។

# ឧបាសកវគ្គោ បញ្ចមោ

[៩១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ទសយិមេ គហបតិ កាមភោគិ-នោ[១] សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ទស ។ ឥធ គហបតិ ឯកច្ចោ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សាហសេន ន អត្តានំ សុខេតិ បិណេតិ[២] ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សាហសេន អត្តានំ សុខេតិ

១ ឱ. ម. កាមភោគី ។ ២ ម. ន បិនេតិ ។

# ឧបាសកវគ្គទី ៥

[៩១] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថ-បិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាប ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះ អនាថបិណ្ឌិកគហបតី បានអង្គុយ ក្នុងទីសមគួរហើយ ទើបព្រះដ៏មាន ព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី អ្នកបរិភោគកាមនេះ មាន ១០ ពួក ក្នុងលោក ។ ១០ ពួក តើដូចម្តេចខ្លះ ។ ម្នាលគហបតី ក្នុង លោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកនូវភោគៈទាំង-ឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែង រកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេបាន មកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករំលែក មិនធ្វើបុណ្យ ទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគ កាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែង សង្កត់សង្កិនគេ លុះស្វះស្វែងរកនូវភោគៈទាំងឡាយ មិនត្រូវតាម គន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ

បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សាហសេន អត្តានំ សុខេតិ បីណេតិ សំវិភជតិ បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហសេនបិ អសាហសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហសេនបិ អសាហសេនបិ ន អត្តានំ សុខេតិ បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហសេនបិ អសាហសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហសេនបិ អសាហសេនបិ អត្តានំ សុខេតិ បីណេតិ

ឲ្យឆ្អែត តែមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិន លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិន គេបានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ទាំងចែករលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វែងរកភោគៈទាំងឡាយត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនក៏មាន មិនកំហែងសង្កត់សង្កិនក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនក៏មាន មិនកំហែងសង្កត់សង្កិនក៏មាន បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត

ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហសេនបិ អសាហសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហសេនបិ អសាហសេនបិ អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន ន អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ ។

តែទាស់មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្វះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្វះ មិនត្រូវតាមគន្លងធម៌ខ្វះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្វះ មិនត្រូវតាមគន្លងធម៌ខ្វះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្វះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្វះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់ មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ១ ។

ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ គធិតោ មុច្ឆិតោ អជ្ឈោបន្នោ អនាទីនវទស្សាវី អនិស្សរណបញ្ញោ បរិភុញ្ជតិ ។ ឥធ បន គហបតិ ឯកច្ចោ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវ-ទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ ។ តត្រ គហបតិ យ្វាយំ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហសេន អធម្មេន ភោគេ បរិយេសិត្វា សាហសេន ន អត្តានំ សុខេតិ

ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ តែនៅជក់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ១ ។ ម្នាលគហបតី ក្នុងលោកនេះ មានអ្នកបរិភោគកាមខ្លះ ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្លក់ចិត្តនឹងភោគៈទាំងនោះទេ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ១ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេបានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ

បិនេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី តីហិ ឋានេហិ គារយ្ហោ អធម្មេន ភោគេ បរិយេសតិ សាហាសេ-ជាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ន អត្តានំ សុខេតិ បិនេតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន គារយ្ហោ ។ អយំ គហបតិ កាមភោគី ឥមេហិ តីហិ ឋានេហិ គារយ្ហោ ។ តត្រ គហបតិ យ្វាយំ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហាសេន អធម្មេន ភោគេ បរិយេសិត្វា សាហាសេន អត្តានំ សុខេតិ បិនេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី ទ្វីហិ ឋានេហិ គារយ្ហោ ឯកេន ឋានេន បាសំសោ អធម្មេន ភោគេ បរិយេសតិ សាហាសេជាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ

ឲ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ៣ ប្រការគឺគេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ នេះថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គួរគេតិះដៀល ដោយហេតុទី ៣ នេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុទាំង ៣ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខឲ្យឆ្អែត តែទាស់មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ២ ប្រការគេសរសើរ ដោយហេតុ ១ ប្រការគឺគេតិះដៀល ដោយហេតុទី ១ នេះថា ស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ

អត្តានំ សុខេតិ បីណេតីតិ ឥមិនា ឯកេន ឋានេន បាសំសោ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ អយំ គហបតិ កាមភោគី ឥមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ឥមិនា ឯកេន ឋានេន បាសំសោ ។ តត្រ គហបតិ យ្វាយំ កាមភោគី អធម្មេន ភោគេ បរិយេសតិ សាហាសេន អធម្មេន ភោគេ បរិយេសិត្វា សាហាសេន អត្តានំ សុខេតិ បីណេតិ សំវិភជតិ បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី ឯកេន ឋានេន គារយ្ហោ ទ្វីហិ ឋានេហិ បាសំសោ អធម្មេន ភោគេ បរិយេសតិ សាហាសេនាតិ ឥមិនា ឯកេន ឋានេន គារយ្ហោ អត្តានំ សុខេតិ បីណេតីតិ ឥមិនា បឋមេន ឋានេន បាសំសោ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ ។

គេសរសើរ ដោយហេតុ ១ ប្រការនេះថា បេះធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល ដោយហេតុទី ២ នេះថា មិនចែករំលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះ-ដៀល ដោយហេតុទាំង ២ ប្រការនេះ គេសរសើរដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំ-ហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀល ដោយហេតុ ១ ប្រការ គេសរសើរដោយហេតុ ២ ប្រការ គឺគេតិះដៀល ដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ១ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុទី ២ នេះថា បេះចែករំលែក ធ្វើបុណ្យទាំងឡាយ ។

## ៣៨៩

### ទុតិយបណ្ណាសកេ ឧបាសកវគ្គោ

អយំ គហបតិ កាមភោគី ឥមិនា ឯកេន ឋានេន គារយ្ហោ ឥមេហិ ទ្វីហិ ឋានេហិ បាសំសោ ។ តត្រ គហបតិ យ្វាយំ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហសេនបិ អសាហសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហសេនបិ អសាហសេនបិ ន អត្តានំ សុខេតិ បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី ឯកេន ឋានេន បាសំសោ តីហិ ឋានេហិ គារយ្ហោ ធម្មេន ភោគេ បរិយេ-សតិ អសាហសេនាតិ ឥមិនា ឯកេន ឋានេន បាសំសោ អធម្មេន ភោគេ បរិយេសតិ សាហ-សេនាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ន អត្តានំ សុខេតិ បីណេតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន គារយ្ហោ ។

ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេតិះដៀលដោយហេតុ ១ ប្រការនេះ គេសរសើរដោយហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំង-ឡាយត្រូវតាមគន្លងធម៌ខ្លះមិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចេះចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ១ ប្រការ គេតិះដៀល ដោយហេតុ ៣ ប្រការ គឺគេសរសើរដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ២ នេះថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ៣ នេះថា មិនចេះចែករលែក មិនធ្វើបុណ្យទាំងឡាយ ។

អយំ គហបតិ កាមភោគី ឥមិនា បឋមេន[១] ឋានេន បាសំសោ ឥមេហិ តីហិ ឋានេហិ គារយ្ហោ ។ តត្រ គហបតិ យ្វាយំ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហសេនបិ អសាហសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហសេនបិ អសាហសេនបិ អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី ទ្វីហិ ឋានេហិ បាសំសោ ទ្វីហិ ឋានេហិ គារយ្ហោ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ អធម្មេន ភោគេ បរិយេសតិ សាហសេនាតិ ឥមិនា បឋមេន ឋានេន គារយ្ហោ អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។

១ ឱ. ម. ឯកេន ។

ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ១ ប្រការនេះ គេតិះដៀល ដោយហេតុទាំង ៣ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែទាស់មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរ ដោយហេតុ ២ ប្រការ គេតិះដៀល ដោយហេតុ ២ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀល ដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំង-ឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គួរគេតិះដៀលដោយហេតុទី ២ នេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។

៣៩១



អយំ គហបតិ កាមភោគី ឥមេហិ ទ្វីហិ ឋានេហិ បាសំសោ ឥមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។ តត្រ គហបតិ យ្វាយំ កាមភោគី ធម្មាធម្មេន ភោគេ បរិយេសតិ សាហសេនបិ អសាហសេនបិ ធម្មាធម្មេន ភោគេ បរិយេសិត្វា សាហសេនបិ អសាហសេនបិ អត្តានំ សុខេតិ បីណេតិ សំវិភជតិ បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី តីហិ ឋានេហិ បាសំសោ ឯកេន ឋានេន គារយ្ហោ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ អធម្មេន ភោគេ បរិយេសតិ សាហសេនាតិ ឥមិនា ឯកេន ឋានេន គារយ្ហោ អត្តានំ សុខេតិ បីណេតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន បាសំសោ ។ អយំ គហបតិ កាមភោគី ឥមេហិ តីហិ ឋានេហិ បាសំសោ ឥមិនា ឯកេន ឋានេន គារយ្ហោ ។

ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ២ ប្រការនេះ គេតិះដៀលដោយហេតុទាំង ២ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន លុះស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ខ្លះ មិនត្រូវតាមគន្លងធម៌ខ្លះ គឺកំហែងសង្កត់សង្កិនគេក៏មាន មិនកំហែងសង្កត់សង្កិនគេក៏មាន បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀលដោយហេតុ ១ ប្រការគឺគេសរសើរ ដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ មិនត្រូវតាមគន្លងធម៌ គឺកំហែងសង្កត់សង្កិនគេ គេសរសើរដោយហេតុទី ២ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរដោយហេតុ ទី ៣ នេះថា ចេះចែករលែកធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ៣ ប្រការនេះ គេតិះដៀលដោយហេតុ ១ ប្រការនេះ ។

តត្រ គហបតិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន ន អត្តានំ សុខេតិ បីណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី ឯកេន ឋានេន ចាសំសោ ទ្វីហិ ឋានេហិ គារយ្ហោ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា ឯកេន ឋានេន ចាសំសោ ន អត្តានំ សុខេតិ បីណេតីតិ ឥមិនា បឋមេន ឋានេន គារយ្ហោ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ទុតិយេន ឋានេន គារយ្ហោ ។ អយំ គហបតិ កាមភោគី ឥមិនា ឯកេន ឋានេន ចាសំសោ ឥមេហិ ទ្វីហិ ឋានេហិ គារយ្ហោ ។ តត្រ គហបតិ យ្វាយំ កាម-ភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន

ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំ-ហែងសង្កត់សង្កិនគេ បានមកហើយ មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ១ ប្រការ គេតិះដៀល ដោយហេតុ ២ ប្រការ គឺគេសរសើរ ដោយហេតុ ១ ប្រការនេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេតិះដៀលដោយហេតុទី ១ នេះថា មិនធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀលដោយហេតុទី ២ នេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ១ ប្រការនេះ គេតិះដៀលដោយហេតុ ២ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំង-ឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ

៣៩៣



អត្តានំ សុខេតិ បិណេតិ ន សំវិភជតិ ន បុញ្ញានិ ករោតិ អយំ គហបតិ កាមភោគី ទ្វីហិ ឋានេហិ ចាសំសោ ឯកេន ឋានេន ការយ្ហោ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា បឋមេន ឋានេន ចាសំសោ អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន ចាសំសោ ន សំវិភជតិ ន បុញ្ញានិ ករោតីតិ ឥមិនា ឯកេន ឋានេន ការយ្ហោ ។ អយំ គហបតិ កាមភោគី ឥមេហិ ទ្វីហិ ឋានេហិ ចាសំសោ ឥមិនា ឯកេន ឋានេន ការយ្ហោ ។ តត្រ គហបតិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ អនាទីនវទស្សាវី

ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត តែមិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ២ ប្រការ គេតិះដៀល ដោយហេតុ ១ ប្រការ គឺគេសរសើរដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ នេះថា ចេះធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេតិះដៀល ដោយហេតុ ១ ប្រការនេះថា មិនចែករលែក មិនធ្វើបុណ្យទាំងឡាយ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ២ ប្រការនេះ គេតិះដៀល ដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ តែនៅជក់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស

អនិស្សរណប្បញ្ញោ បរិភុញ្ជតិ អយំ គហបតិ កាមភោគី តីហិ ឋានេហិ ចាសំសោ ឯកេន ឋានេន គារយ្ហោ ធម្មេន ភោគេ បរិយេសតិ អសាហ-សេនាតិ ឥមិនា បឋមេន ឋានេន ចាសំសោ អត្តានំ សុខេតិ បិនេតីតិ ឥមិនា ទុតិយេន ឋានេន ចាសំសោ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន ចាសំសោ តេ ច ភោគេ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ អនាទីនវ-ទស្សាវី អនិស្សរណប្បញ្ញោ បរិភុញ្ជតីតិ ឥមិនា ឯកេន ឋានេន គារយ្ហោ ។ អយំ គហបតិ កាមភោគី ឥមេហិ តីហិ ឋានេហិ ចាសំសោ ឥមិនា ឯកេន ឋានេន គារយ្ហោ ។ តត្រ គហបតិ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិនេតិ សំវិភជតិ បុញ្ញានិ ករោតិ

មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរដោយហេតុ ៣ ប្រការ គេតិះដៀល ដោយហេតុ ១ ប្រការគឺគេសរសើរ ដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ នេះថា ចេះធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត គេសរសើរ ដោយហេតុទី ៣ នេះថា ចេះចែករំលែក ធ្វើបុណ្យទាំងឡាយ គេតិះដៀល ដោយហេតុ ១ ប្រការនេះថា ជក់ ជ្រប់ ឈ្លក់ចិត្តនឹងភោគៈទាំងនោះ មិនឃើញទោស មិនមានបញ្ញាជាគ្រឿងរើខ្លួន ហើយចេះតែបរិភោគ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ៣ ប្រការនេះ គេតិះដៀល ដោយហេតុ ១ ប្រការនេះ ។ ម្នាលគហបតី បណ្ដាអ្នកបរិភោគកាមទាំងនោះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែង សង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួន ឲ្យបានសុខ ឲ្យឆ្អែត ចែករំលែក ធ្វើបុណ្យទាំងឡាយ

តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ អយំ គហបតិ កាមភោគី ចតូហិ ឋានេហិ បាសំសោ ធម្មេន ភោគេ បរិយេសតិ អសាហសេនាតិ ឥមិនា បឋមេន ឋានេន បាសំសោ អត្តានំ សុខេតិ បិណេតីតិ ឥមិនា ទុតិយេន ឋានេន បាសំសោ សំវិភជតិ បុញ្ញានិ ករោតីតិ ឥមិនា តតិយេន ឋានេន បាសំសោ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតីតិ ឥមិនា ចតុត្ថេន ឋានេន បាសំសោ ។ អយំ គហបតិ កាមភោគី ឥមេហិ ចតូហិ ឋានេហិ បាសំសោ ។ ឥមេ ខោ គហបតិ ទស កាមភោគិនោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ ខោ គហបតិ ទសន្នំ កាមភោគីនំ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បិណេតិ សំវិភជតិ

ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្ពក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ម្នាលគហបតី អ្នកបរិភោគកាមនេះ គួរគេសរសើរ ដោយហេតុ ៤ ប្រការ គឺគេសរសើរ ដោយហេតុទី ១ នេះថា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ គេសរសើរ ដោយហេតុទី ២ នេះថា ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត គេសរសើរ ដោយហេតុទី ៣ នេះថា ចែករលែក ធ្វើបុណ្យទាំងឡាយ គេសរសើរ ដោយហេតុទី ៤ នេះថា មិនជក់ មិនជ្រប់ មិនឈ្ពក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ ។ ម្នាលគហបតី អ្នកបរិភោគកាមនេះ គេសរសើរដោយហេតុទាំង ៤ ប្រការនេះ ។ ម្នាលគហបតី អ្នកបរិភោគកាមទាំង ១០ ពួកនេះ មានក្នុងលោក ។ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌ គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យសុខឲ្យឆ្អែត ចែករលែក

បុញ្ញានិ ករោតិ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ អយំ ឥមេសំ ទសន្នំ កាមភោគីនំ អគ្គោ ច សេដ្ឋោ ច បាមោក្ខោ ច ឧត្តមោ ច បវរោ ច ។ សេយ្យថាបិ គហបតិ គវា ខីរំ ខីរម្ហា ទធិ ទធិម្ហា នវនីតំ នវនីតម្ហា សប្បិ សប្បិម្ហា សប្បិមណ្ឌោ តត្ថ អគ្គមក្ខាយតិ ឯវមេវ ខោ គហបតិ ឥមេសំ ទសន្នំ កាមភោគីនំ យ្វាយំ កាមភោគី ធម្មេន ភោគេ បរិយេសតិ អសាហសេន ធម្មេន ភោគេ បរិយេសិត្វា អសាហសេន អត្តានំ សុខេតិ បីណេតិ សំវិភជតិ បុញ្ញានិ ករោតិ តេ ច ភោគេ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ អយំ ឥមេសំ ទសន្នំ កាមភោគីនំ អគ្គោ ច សេដ្ឋោ ច បាមោក្ខោ ច ឧត្តមោ ច បវរោ ចាតិ ។

ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្ងក់ចិត្តនឹងភោគៈទាំងឡាយ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថាជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ។ ម្នាលគហបតី ដូចជាទឹកដោះស្រស់ កើតពីមេគោ ទឹកដោះជូរក្លាយពីទឹកដោះស្រស់ ទឹកដោះខាប់ក្លាយពីទឹកដោះជូរ ទឹកដោះរាវក្លាយពីទឹកដោះខាប់ ទឹកដោះថ្លា ក្លាយពីទឹកដោះរាវ ទឹកដោះថ្លា ប្រាកដជាប្រសើរជាងទឹកដោះទាំងនោះ យ៉ាងណាមិញ ម្នាលគហបតី បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមណា ស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌គឺមិនកំហែងសង្កត់សង្កិនគេ លុះស្វះស្វែងរកភោគៈទាំងឡាយ ត្រូវតាមគន្លងធម៌គឺមិនកំហែងសង្កត់សង្កិនគេ បានមកហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យឆ្អែត ចែករលែក ធ្វើបុណ្យទាំងឡាយ ថែមទាំងមិនជក់ មិនជ្រប់ មិនឈ្ងក់ចិត្តនឹងភោគៈទាំងនោះ ឃើញទោស មានបញ្ញាជាគ្រឿងរើខ្លួន ហើយបរិភោគ បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមនេះ ឈ្មោះថាជាកំពូលផង ប្រសើរផង ចម្បងផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង យ៉ាងនោះដែរ ។

[៩២] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច យតោ ខោ គហបតិ អរិយសាវកស្ស បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ អរិយោ ចស្ស ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ ខីណបិត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ កតមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ យំ គហបតិ បាណាតិបាតី បាណាតិបាតប្បច្ចយា ទិដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ

[៩២] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើអរិយសាវ័ក រម្ងាប់ភ័យនិងពៀរទាំង ៥ បានហើយ (អរិយសាវ័កនោះ) ជាអ្នកបរិបូណ៌ ដោយសោតាបត្តិយង្គៈ ទាំង ៤ ទាំងញាយធម៌ (មគ្គព្រមទាំងវិបស្សនា) ដ៏ប្រសើរ អរិយសាវ័កនោះ ឃើញហើយដោយប្រពៃ ចាក់ធ្លុះហើយដោយប្រពៃ ដោយប្រាជ្ញា កាលបើអរិយ-សាវ័កនោះ ចង់ (ព្យាករ) ក៏គប្បីព្យាករខ្លួន ដោយខ្លួនឯងថា អាត្មាអញ អស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយ ទុគ្គតិ វិនិបាតហើយ អាត្មាអញ ជាសោតាបន្នបុគ្គល លែងទៅកើតក្នុងអបាយហើយ ជាបុគ្គលទៀងទាត់ ប្រាកដជានឹងបានត្រាស់ដឹង តទៅខាងមុខ ។ ចុះអរិយសាវ័ក បានរម្ងាប់ភ័យនិងពៀរទាំង ៥ តើដូចម្តេច ។ ម្នាលគហបតី អ្នកសម្លាប់សត្វ តែងទទួលភ័យនិងពៀរ ដែលជាបច្ចុប្បន្នផង ទទួលភ័យនិងពៀរ ក្នុងបរលោកផង

ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ចាណាតិបាតា បដិវិរតោ ខោ និដ្ឋធម្មិកំ[១] ភយំ វេរំ បសវតិ ន សម្បរាយិកំ[២] ភយំ វេរំ បសវតិ ន ចេតសិកំ[៣] ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ ចាណាតិបាតា បដិវិរតស្ស ឯវន្តំ[៤] ភយំ វេរំ វូបសន្តំ ហោតិ ។ យំ គហបតិ អទិន្នាទាយី... កាមេសុ មិច្ឆាចារី... មុសាវាទី... សុរាមេរយមជ្ជប្បមាទដ្ឋាយី សុរាមេរយមជ្ជប្បមាទដ្ឋានប្បច្ចយា និដ្ឋធម្មិកម្បិ ភយំ វេរំ បសវតិ សម្បរាយិកម្បិ ភយំ វេរំ បសវតិ ចេតសិកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ខោ និដ្ឋធម្មិកំ ភយំ វេរំ បសវតិ ន សម្បរាយិកំ ភយំ វេរំ បសវតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតស្ស ឯវន្តំ ភយំ វេរំ វូបសន្តំ ហោតិ ។

---

១ ម. ទិដ្ឋធម្មិកម្បិ ។ ២ ម. សម្បរាយិកម្បិ ។ ៣ ម. ចេតសិកម្បិ ។ ៤ ម. ឯតំ ។

រងទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះហេតុតែសម្លាប់សត្វ អ្នកវៀរចាកការសម្លាប់សត្វ តែងមិនទទួលភ័យនិងពៀរ ជាបច្ចុប្បន្នផង មិនទទួលភ័យនិងពៀរ ក្នុងបរលោកផង មិនរងទុក្ខទោមនស្សដែលប្រព្រឹត្តទៅ ក្នុងចិត្តផង ។ កាលអរិយសាវ័ក វៀរចាកការសម្លាប់សត្វ ជាអ្នករម្ងាប់ភ័យនិងពៀរនោះយ៉ាងនេះ ។ ម្នាលគហបតី អ្នកយករបស់ដែលគេមិនបានឲ្យ ... អ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ... អ្នកនិយាយពាក្យកុហក ... អ្នកប្រព្រឹត្តហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរានិងមេរ័យ តែងទទួលភ័យនិងពៀរដែលជាបច្ចុប្បន្នផង ក្នុងបរលោកផង រងទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹង គឺសុរានិងមេរ័យជាបច្ច័យ អ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹងគឺសុរានិងមេរ័យ តែងមិនទទួលភ័យនិងពៀរ ជាបច្ចុប្បន្នផង មិនទទួលភ័យនិងពៀរ ក្នុងបរលោកផង មិនរងទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្តផង ។ កាលអរិយសាវ័ក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកទឹកស្រវឹងគឺសុរានិងមេរ័យ រមែងជាអ្នករម្ងាប់ភ័យនិងពៀរនោះ យ៉ាងនេះ ។

៣៩៩



ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ។ កតមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។ ឥធ គហបតិ អរិយស្សាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

ភ័យនិងពៀរទាំង ៥ នេះ រមែងស្ងប់រម្ងាប់ទៅ ។ អរិយសាវ័ក អ្នកបរិ-បូណ៌ ដោយសោតាបត្តិយង្គៈ ៤ តើដូចម្តេច ។ ម្នាលគហបតី អរិយ-សាវ័ក ក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវ គឺកិលេស ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរដ្ឋាន ព្រះអង្គជ្រាបនូវត្រៃលោក ព្រះអង្គប្រសើរ ដោយសីលាទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងបួន ព្រះអង្គលែងត្រឡប់មកកើតក្នុងត្រៃភព ។ អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ថា ព្រះធម៌ដែល ព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ជាធម៌គឺព្រះអរិយបុគ្គល ឃើញដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលព្រះអរិយ-បុគ្គលគួរហៅអ្នកដទៃឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គលគួរ បង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងដោយខ្លួនឯង ។

សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមា-ធិសំវត្តនិកេហិ ។ ឥមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ ។

អរិយសាវ័ក ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃសាវ័ក របស់ព្រះមានព្រះភាគ ប្រតិបត្តិហើយ ដោយប្រពៃ ព្រះសង្ឃសាវ័ក របស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយ ដោយត្រង់ ព្រះសង្ឃសាវ័ក របស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិហើយ ដើម្បីត្រាស់ដឹងព្រះនិព្វាន ព្រះសង្ឃសាវ័ក របស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃសាវ័កនេះ បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវ័ក របស់ព្រះដ៏មានព្រះភាគនុ៎ះ គួរទទួលវត្ថុ ដែលបុគ្គលនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាស្រែបុណ្យ ដ៏ប្រសើរ របស់សត្វលោក ។ អរិយសាវ័ក ជាអ្នកប្រកប ដោយសីលទាំងឡាយ ជាទីត្រេកអរ របស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលពួកវិញ្ញូជន សរសើរហើយ ជាសីលមិនជ្រោកជ្រាក ជាសីលនាំឲ្យបានសមាធិ ។ អរិយសាវ័ក ប្រកបដោយសោតាបត្តិយង្គៈទាំង ៤ យ៉ាងនេះឯង ។

កតមោ ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ ។ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ

ចុះញាយធម៌ ដ៏ប្រសើរ ដែលអរិយសាវ័កនោះ ឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយបញ្ញា តើដូចម្តេច ។ ម្នាលគហបតី អរិយសាវ័ក ក្នុងសាសនានេះ ពិចារណាឃើញច្បាស់ថា កាលបើរបស់នេះមាន របស់នេះក៏មាន របស់នេះកើតឡើង ព្រោះកើតរបស់នេះ កាលបើរបស់នេះគ្មាន របស់នេះក៏គ្មាន របស់នេះរលត់ ព្រោះរលត់របស់នេះ យ៉ាងដូចសង្ខារទាំងឡាយ កកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កកើតឡើង ព្រោះសង្ខារជាបច្ច័យ នាមរូប កកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ កកើតឡើង ព្រោះនាម-រូបជាបច្ច័យ ផស្សៈ កកើតឡើង ព្រោះសឡាយតនៈជាបច្ច័យ វេទនា កកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហា កកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទាន កកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភព កកើតឡើង ព្រោះឧបាទាន ជាបច្ច័យ ជាតិ កកើតឡើង ព្រោះភពជាបច្ច័យ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ កកើតឡើង ព្រោះជាតិជាបច្ច័យ ។ ការកើតនៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះឯង ។ ការរលត់សង្ខារ ព្រោះវិនាសនិងការរលត់អវិជ្ជាមិនមានសេសសល់ ការរលត់វិញ្ញាណ ព្រោះរលត់សង្ខារ

វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្ស-និរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុ-បាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយញ្ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្ប-ដិវិទ្ធោ ។ យតោ ខោ គហបតិ អរិយសាវកស្ស ឥមានិ បញ្ច ភយានិ វេរានិ វូបសន្តានិ ហោន្តិ ឥមេហិ ចតូហិ សោតាបត្តិយង្គេហិ សមន្នាគតោ ហោតិ អយញ្ចស្ស អរិយោ ញាយោ បញ្ញាយ សុទិដ្ឋោ ហោតិ សុប្បដិវិទ្ធោ សោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆា-នយោនិ ខីណបិត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ

ការរលត់នាមរូប ព្រោះរលត់វិញ្ញាណ ការរលត់សឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់វេទនា ព្រោះរលត់ផស្សៈ ការរលត់តណ្ហា ព្រោះរលត់វេទនា ការរលត់ឧបាទាន ព្រោះរលត់តណ្ហា ការរលត់ភព ព្រោះរលត់ឧបាទាន ការរលត់ជាតិ ព្រោះរលត់ភព ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ រលត់ ព្រោះរលត់ជាតិ ។ ការរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះឯង ។ ញាយធម៌ ដ៏ប្រសើរនេះ អរិយសាវ័កនោះ បានឃើញច្បាស់ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញា ។ ម្នាលគហបតី កាលណាអរិយសាវ័ក រម្ងាប់ភ័យនិងពៀរទាំង ៥ ប្រការនេះផង ជាអ្នកបរិបូណ៌ដោយសោតាបត្តិយង្គៈទាំង ៤ ប្រការនេះផង ញាយធម៌ ដ៏ប្រសើរនេះផង អរិយសាវ័កនោះ ឃើញដោយប្រពៃ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញាផង ក្នុងកាលនោះ កាលបើអរិយសាវ័កនោះចង់ (ព្យាករ) ក៏គប្បីព្យាករខ្លួនដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយ ទុគ្គតិ វិនិបាតហើយ

សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

[៩៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អនាថបិណ្ឌិកោ គហបតិ ទិវា ទិវស្ស សាវត្ថិយា និក្ខមិ ភគវន្តំ ទស្សនាយ ។ អថខោ អនាថបិណ្ឌិ-កស្ស គហបតិស្ស ឯតទហោសិ អកាលោ ខោ តាវ ភគវន្តំ ទស្សនាយ បដិសល្លីនោ ភគវា មនោ-ភាវនីយានម្បិ ភិក្ខូនំ អកាលោ ទស្សនាយ បដិស-ល្លីនា មនោភាវនីយា ភិក្ខូ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្ក-មេយ្យន្តិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិ ។ តេន ខោ បន សមយេន អញ្ញតិត្ថិយា បរិព្វាជកា សង្គម្ម សមាគម្ម ឧន្នាទិនោ ឧច្ចាសទ្ទា មហាសទ្ទា

អាត្មាអញជាសោតាបន្នបុគ្គល លែងទៅកើតក្នុងអបាយហើយ ជាបុគ្គលទៀងទាត់ ប្រាកដជានឹងបានត្រាស់ដឹង តទៅខាងមុខ ។

[៩៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចេញអំពីក្រុងសាវត្ថីទាំងថ្ងៃត្រង់ ដើម្បីទៅគាល់ព្រះដ៏មានព្រះភាគ ។ ទើបអនាថបិណ្ឌិកគហបតី មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលនេះ ជាកាល មិនគួរដើម្បីទៅគាល់ព្រះមានព្រះភាគទេ ដ្បិតព្រះមានព្រះភាគ កំពុងសម្ងំ កាលនេះជាកាល មិនគួរដើម្បីទៅជួប នឹងពួកភិក្ខុ អ្នកចម្រើនសមាធិចិត្តទេ ដ្បិតពួកភិក្ខុ អ្នកចម្រើនសមាធិចិត្ត កំពុងសម្ងំដែរ បើដូច្នោះ គួរតែអាត្មាអញ ចូលទៅឯអារាមពួកអន្យតិរ្ថិយបរិព្វាជកសិន ។ គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅឯអារាម ពួកអន្យតិរ្ថិយបរិព្វាជក ។ សម័យនោះឯង ពួកអន្យ-តិរ្ថិយបរិព្វាជក ប្រជុំគ្នា មកជួបជុំ និយាយគ្នាកោកកាក គឹកកងរំពង

អនេកវិហិតំ តិរច្ឆានកថំ កថេន្តា និសិន្នា ហោន្តិ ។ អទ្ទសំសុ ខោ តេ អញ្ញតិត្ថិយា បរិព្វាជកា អនាថបិណ្ឌិកំ គហបតឹ ទូរតោ វ អាគច្ឆន្តំ ទិស្វាន អញ្ញមញ្ញំ សណ្ឋាបេសុំ[១] អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ អយំ អនាថបិណ្ឌិកោ គហបតិ អាគច្ឆតិ សមណស្ស គោតមស្ស សាវកោ យាវតា ខោ បន សមណស្ស គោតមស្ស សាវកា គិហី ឱទាតវសនា សាវត្ថិយំ បដិវសន្តិ អយំ តេសំ អញ្ញតរោ អនាថបិណ្ឌិកោ គហបតិ អប្បសទ្ទកាមា ខោ បន តេ អាយស្មន្តោ អប្បសទ្ទវិនីតា អប្បសទ្ទស្ស វណ្ណវាទិនោ អប្បេវ នាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ អថខោ តេ បរិព្វាជកា តុណ្ហី អហេសុំ ។

១ ឱ. សណ្ឋាបេសុំ ។

ហើយអង្គុយ ជជែកគ្នាពីតិរច្ឆានកថាផ្សេង ៗ ។ អន្យតិរ្ថិយបរិព្វាជក ទាំងនោះ បានឃើញអនាថបិណ្ឌិកគហបតី កំពុងដើរមកពីចម្ងាយ លុះឃើញហើយ ក៏ឃាត់គ្នីគ្នាថា អ្នកទាំងឡាយនិយាយតិច ៗ អ្នក ទាំងឡាយ កុំនិយាយខ្លាំង (ព្រោះ) អនាថបិណ្ឌិកគហបតីនេះ ជា សាវ័កនៃសមណគោតម គាត់មក ពួកគ្រហស្ថ អ្នកស្លៀកពាក់ស ជាសាវ័កនៃសមណគោតម ដែលនៅក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន បណ្តា គ្រហស្ថ ជាសាវ័កទាំងនោះ អនាថបិណ្ឌិកគហបតីនេះ ជាសាវ័ក ម្នាក់ដែរ អ្នកដ៏មានអាយុទាំងនោះ ត្រូវការតែសំឡេងតិច ហាត់តែ ខាងសំឡេងតិច និយាយសរសើរតែសំឡេងតិច យើងធ្វើដូចម្តេច ឲ្យ ទាល់តែអនាថបិណ្ឌិកគហបតី សម្គាល់បរិសទ្យមានសំឡេងតិចថា គួរ ចូលមកបាន ។ ទើបបរិព្វាជកទាំងនោះ នាំគ្នាសម្ងំស្ងាត់ ប្រៀប ។

អថខោ អនាថបិណ្ឌិកោ គហបតិ យេន តេ បរិព្វាជកា តេនុបសង្កមិ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ វទេហិ គហបតិ កឹទិដ្ឋិកោ សមណោ គោតមោតិ ។ ន ខោ អហំ ភន្តេ ភគវតោ សព្វំ ទិដ្ឋឹ ជានាមីតិ ។ ឥតោ[១] កិរ ត្វំ គហបតិ ន សមណស្ស គោតមស្ស សព្វំ ទិដ្ឋឹ ជានាសិ វទេហិ គហបតិ កឹទិដ្ឋិកា ភិក្ខូតិ ។ ភិក្ខូនំបិ ខោ អហំ ភន្តេ ន សព្វំ ទិដ្ឋឹ ជានាមីតិ ។ ឥតិ កិរ ត្វំ គហបតិ ន សមណស្ស គោតមស្ស សព្វំ ទិដ្ឋឹ ជានាសិ នបិ ភិក្ខូនំ សព្វំ ទិដ្ឋឹ ជានាសិ

១ ឱ. ម. ឥតិ ។

គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅរកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ និយាយរាក់ទាក់សំណេះសំណាលជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងនោះ លុះបង្ហើយពាក្យដែលគួររាក់ទាក់ សំណេះសំណាលគួរឲ្យរលឹកហើយ អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតីអង្គុយក្នុងទីសមគួរហើយ អន្យតិរ្ថិយបរិព្វាជកទាំងនោះ និយាយយ៉ាងនេះថា ម្នាលគហបតី អ្នកចូរមានប្រសាសន៍ មកមើល ព្រះសមណគោតម មានសេចក្តីយល់ដូចម្តេច ។ អនាថបិណ្ឌិកគហបតីឆ្លើយថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំមិនដឹងសេចក្តីយល់សព្វគ្រប់ របស់ព្រះដ៏មានព្រះភាគទេ ។ ពួកអន្យតិរ្ថិយបរិព្វាជក សួរថា ម្នាលគហបតី បើឥឡូវនេះលោកមិនជ្រាបសេចក្តីយល់សព្វគ្រប់ របស់ព្រះសមណគោតមទេ ម្នាលគហបតី លោកចូរមានប្រសាសន៍មកចុះ ពួកភិក្ខុមានសេចក្តីយល់ដូចម្តេច ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំក៏មិនដឹងសេចក្តីយល់សព្វគ្រប់ របស់ពួកភិក្ខុដែរ ។ ម្នាលគហបតី បើអ្នកមិនដឹងសេចក្តីយល់សព្វគ្រប់ របស់ព្រះសមណគោតម ទាំងមិនដឹងសេចក្តីយល់សព្វគ្រប់ របស់ពួកភិក្ខុ ដោយប្រការដូច្នេះទេ

វទេហិ គហបតិ កឹទិដ្ឋិកោសិ តុវន្តិ ។ ឯតំ ខោ ភន្តេ អម្ហេហិ ន ទុក្ករំ ព្យាកាតុំ យំទិដ្ឋិកា មយន្តិ[១] ឥង្ឃ តាវ អាយស្មន្តោ យថាសកានិ ទិដ្ឋិគតានិ ព្យាករោន្តុ បច្ឆាបេតំ អម្ហេហិ ន[២] ទុក្ករំ ភវិស្សតិ ព្យាកាតុំ យំទិដ្ឋិកា មយន្តិ ។ ឯវំ វុត្តេ អញ្ញតរោ បរិព្វាជកោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ អហំ គហបតីតិ ។ អញ្ញតរោបិ ខោ បរិព្វាជកោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ អហំ គហបតីតិ ។ អញ្ញតរោបិ ខោ បរិព្វាជកោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច អន្តវា លោកោ... អនន្តវា លោកោ...

---

១ ម. តិសទ្ទោ នត្ថិ ។ ២ ឱ. នោ ។

ម្នាលគហបតី លោកមានប្រសាសន៍មកមើល ចុះលោកមានសេចក្តីយល់ដូចម្តេច ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ យើងមានសេចក្តីយល់បែបណា ការដែលយើងព្យាករនូវសេចក្តីយល់បែបនុ៎ះ មិនជាការក្រទេ ប៉ុន្តែ សូមឲ្យលោកដ៏មានអាយុទាំងឡាយ ព្យាករសេចក្តីយល់ទាំងឡាយ តាមសមគួរ របស់ខ្លួនមុនចុះ យើងមានសេចក្តីយល់បែបណា ការដែលយើង នឹងព្យាករនូវសេចក្តីយល់បែបនុ៎ះ មិនជាការក្រទេ សឹមយើងព្យាករ ក្នុងកាលជាខាងក្រោយ ។ កាលដែលអនាថបិណ្ឌិកគហបតី និយាយយ៉ាងនេះហើយ មានបរិព្វាជកម្នាក់និយាយ នឹងអនាថបិណ្ឌិកគហបតី យ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្តីយល់យ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ។ មានបរិព្វាជកម្នាក់ទៀត និយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្តីយល់យ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ។ មានបរិព្វាជកម្នាក់ទៀតនិយាយនឹងអនាថបិណ្ឌិកគហបតី យ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្តីយល់យ៉ាងនេះថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ...

តំ ជីវំ តំ សរីរំ... អញ្ញំ ជីវំ អញ្ញំ សរីរំ... ហោតិ តថាគតោ បរម្មរណា... ន ហោតិ តថាគតោ បរម្មរណា... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ អហំ គហបតីតិ ។ ឯវំ វុត្តេ អនាថបិណ្ឌិកោ គហបតិ តេ បរិព្វាជកេ ឯតទវោច យ្វាយំ ភន្តេ អាយស្មា ឯវមាហ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ អហំ គហបតីតិ ឥមស្ស អយមាយស្មតោ ទិដ្ឋិ អត្តនោ វា អយោនិសោ មនសិការហេតុ ឧប្បន្នា បរឃោសប្បច្ចយា[១] វា សា ខោ បនេសា ទិដ្ឋិ ភូតា សង្ខតា ចេតយិតា បដិច្ចសមុប្បន្នា យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ ចេតយិតំ បដិច្ចសមុប្បន្នំ តទនិច្ចំ យទនិច្ចំ តំ ទុក្ខំ

១ ម. បរតោ ឃោសប្បច្ចយា ។

ជីវិតនោះគឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វស្លាប់ទៅ កើតទៀត ... សត្វស្លាប់ទៅ មិនកើតទៀត ... សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ... សត្វស្លាប់ទៅ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ។ កាលដែលពួកបរិព្វាជក និយាយយ៉ាងនេះហើយ អនាថបិណ្ឌិកគហបតី និយាយនឹងពួកបរិព្វាជកទាំងនោះ យ៉ាងនេះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ លោកដ៏មានអាយុណា និយាយយ៉ាងនេះថា ម្នាលគហបតី អាត្មាយល់យ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ សេចក្តីយល់របស់លោកដ៏មានអាយុនេះ កើតឡើង ព្រោះហេតុនៃការមិនធ្វើទុកក្នុងចិត្ត ដោយឧបាយនៃខ្លួនឬ ព្រោះហេតុតែសំឡេងរបស់បុគ្គលដទៃ សេចក្តីយល់នោះ កើតមានហើយ បច្ច័យតាក់តែងហើយ គិតហើយព្រោះអាស្រ័យគ្នា កើតហើយ របស់ណាមួយ កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នា កើតហើយ របស់នោះ មិនទៀង របស់ណា មិនទៀង របស់នោះជាទុក្ខ

យំ ទុក្ខំ តទេវ សោ អាយស្មា អស្សិជោ តទេវ សោ អាយស្មា អជ្ឈុបគតោ ។ យោចាយំ ភន្តេ អាយស្មា ឯវមាហ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ អហំ គហបតីតិ ឥមស្សាបិ អយមាយស្មតោ ទិដ្ឋិ អត្តនោ វា អយោនិសោ មនសិការហេតុ ឧប្បន្នា បរឃោសប្បច្ចយា វា សា ខោ បនេសា ទិដ្ឋិ ភូតា សង្ខតា ចេតយិតា បដិច្ចសមុប្បន្នា យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ ចេតយិតំ បដិច្ចសមុប្បន្នំ តទនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទេវ សោ អាយស្មា អស្សិជោ តទេវ សោ អាយស្មា អជ្ឈុបគតោ ។ យោចាយំ ភន្តេ អាយស្មា ឯវមាហ អន្តវា លោកោ... អនន្តវា លោកោ... តំ ជីវំ តំ សរីរំ . . . អញ្ញំ ជីវំ អញ្ញំ សរីរំ . . . ហោតិ

របស់ណាជាទុក្ខ លោកដ៏មានអាយុនោះ ឈ្មោះថា ជាប់ស្អិតនឹងរបស់នោះឯង លោកដ៏មានអាយុនោះ ឈ្មោះថា ជំពាក់ស្អិតនឹងរបស់នោះឯង ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ លោកដ៏មានអាយុណា និយាយយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្តីយល់យ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតទេ សេចក្តីយល់ របស់លោកដ៏មានអាយុនេះ កើតឡើង ព្រោះហេតុមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃខ្លួន ឬ ៗ ព្រោះហេតុតែសំឡេងរបស់បុគ្គលដទៃ សេចក្តីយល់នោះ កើតមានហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នា កើតហើយ របស់ណាមួយ កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ ព្រោះអាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ លោកដ៏មានអាយុនោះ ឈ្មោះថា ជាប់ស្អិតនឹងរបស់នោះ លោកដ៏មានអាយុនោះ ឈ្មោះថាជំពាក់ស្អិតនឹងរបស់នោះ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ លោកដ៏មានអាយុណា និយាយយ៉ាងនេះថា ម្នាលគហបតី អាត្មាមានសេចក្តីយល់យ៉ាងនេះថា លោកមានទីបំផុត ... លោកមិនមានទីបំ-ផុត ... ជីវិតនោះ គឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ...

តថាគតោ បរម្មរណា... ន ហោតិ តថាគតោ បរម្មរណា... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ អហំ គហបតីតិ ឥមស្សាបិ អយមាយស្មតោ ទិដ្ឋិ អត្តនោ វា អយោនិសោ មនសិការហេតុ ឧប្បន្នា បរឃោស-ប្បច្ចយា វា សា ខោ បនេសា ទិដ្ឋិ ភូតា សង្ខតា ចេតយិតា បដិច្ចសមុប្បន្នា យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ ចេតយិតំ បដិច្ចសមុប្បន្នំ តទនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទេវ សោ អាយស្មា អល្លីនោ តទេវ សោ អាយស្មា អជ្ឈុបគតោតិ ។ ឯវំ វុត្តេ តេ បរិព្វាជកា អនាថបិណ្ឌិកំ គហបតឹ ឯតទវោចុំ ព្យាកតានិ ខោ គហបតិ អម្ហេហិ សព្វេហេវ យថាសកានិ ទិដ្ឋិគតានិ វទេហិ គហបតិ កឹទិដ្ឋិកោសិ តុវន្តិ ។

សត្វស្លាប់ទៅកើតទៀត ... សត្វស្លាប់ទៅមិនកើតទៀត ... សត្វស្លាប់ទៅកើតទៀត ក៏មាន មិនកើតទៀត ក៏មាន ... សត្វស្លាប់កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃមិនពិតទេ សេចក្តីយល់របស់លោកដ៏មានអាយុនេះ កើតឡើងហើយ ព្រោះហេតុនៃការមិនធ្វើទុកក្នុងចិត្ត ដោយឧបាយនៃខ្លួន ឬ ព្រោះហេតុតែសំឡេង របស់បុគ្គលដទៃ សេចក្តីយល់នោះ កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នា កើតហើយ របស់ណាមួយ កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នា កើតហើយ របស់នោះ មិនទៀង របស់ណាមិនទៀង របស់នោះ ជាទុក្ខ របស់ណា ជាទុក្ខ លោកដ៏មានអាយុនោះ ឈ្មោះថាជាប់ស្អិតនឹងរបស់នោះ លោកដ៏មានអាយុនោះ ឈ្មោះថាជំពាក់ស្អិតនឹងរបស់នោះ ។ កាលដែលអនាថបិណ្ឌិកគហបតី និយាយយ៉ាងនេះហើយ បរិព្វាជកទាំងនោះ និយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា ម្នាលគហបតី ពួកយើងទាំងអស់គ្នា បានព្យាករសេចក្តីយល់ តាមសមគួររបស់ខ្លួនហើយ ម្នាលគហបតី លោកមានប្រសាសន៍ មកមើលចុះ លោកមានសេចក្តីយល់ដូចម្តេច ។

យំ ខោ បន ភន្តេ កិញ្ចិ ភូតំ សង្ខតំ ចេតយិតំ បដិច្ចសមុប្បន្នំ តទនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវំទិដ្ឋិកោ ខោ អហំ ភន្តេតិ ។ យំ ខោ គហបតិ កិញ្ចិ ភូតំ សង្ខតំ ចេតយិតំ បដិច្ច-សមុប្បន្នំ តទនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទេវ ត្វំ គហបតិ អល្លីនោ តទេវ ត្វំ គហ-បតិ អជ្ឈុបគតោតិ ។ យំ ខោ បន ភន្តេ កិញ្ចិ ភូតំ សង្ខតំ ចេតយិតំ បដិច្ចសមុប្បន្នំ តទនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ តស្ស ច ឧត្តរឹ និស្សរណំ យថាភូតំ បជានាមីតិ ។

អនាថបិណ្ឌិកគហបតី ឆ្លើយតបថា បពិត្រលោកដ៏ចម្រើនទាំងឡាយ របស់ណា កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះ មិនទៀង របស់ណា មិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំមានសេចក្តីយល់របស់នោះយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ម្នាលគហបតី របស់ណាមួយ កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ ម្នាលគហបតី អ្នកឈ្មោះថាជាប់ស្អិតនឹងរបស់នោះ ម្នាលគហបតី អ្នកឈ្មោះថាជំពាក់ស្អិតនឹងរបស់នោះ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ របស់ណាមួយ កើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះ មិនទៀង របស់ណា មិនទៀង របស់នោះជាទុក្ខ របស់ណា ជាទុក្ខ ខ្ញុំយល់របស់នោះ ដោយប្រពៃដោយប្រាជ្ញាដ៏ត្រឹមត្រូវ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ទាំងខ្ញុំដឹងច្បាស់នូវការរលាស់ចេញ នូវរបស់នោះ តទៅទៀត តាមសេចក្តីពិត ។

ឯវំ វុត្តេ តេ បរិព្វាជកា តុណ្ហីភូតា មង្កុភូតា បត្តក្ខន្ធា អធោមុខា បជ្ឈាយន្តា អប្បដិ-ភាណា និសីទឹសុ ។ អថខោ អនាថបិណ្ឌិកោ គហបតិ តេ បរិព្វាជកេ តុណ្ហីភូតេ មង្កុភូតេ បត្តក្ខន្ធេ អធោមុខេ បជ្ឈាយន្តេ អប្បដិភាណេ វិទិត្វា ឧដ្ឋាយាសនា យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អនាថបិណ្ឌិកោ គហបតិ យាវតកោ អហោសិ តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ កថា-សល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ សាធុ សាធុ គហបតិ ឯវំ ខោ តេ គហបតិ មោឃបុរិសា កាលេន កាលំ សហធម្មេន សុនិគ្គហិតំ និគ្គហេតព្វាតិ ។ អថខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ធម្មិយា កថាយ សន្ទ-ស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

កាលដែលអនាថបិណ្ឌិកគហបតី និយាយយ៉ាងនេះហើយ បរិព្វាជក ទាំងនោះ នៅស្ងៀម អៀនខ្មាស ឱនក សំយុងមុខ អង្គុយ សញ្ចប់សញ្ចឹង គ្មានបដិភាណ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតី ដឹងថា បរិព្វាជកទាំងនោះ នៅស្ងៀម អៀនខ្មាស ឱនក សំយុងមុខ សញ្ចប់សញ្ចឹង គ្មានបដិភាណ ហើយក៏ក្រោកចាកអាសនៈ ហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិក-គហបតី អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលការចរចាទាំង ប៉ុន្មាន (ដែលខ្លួននិយាយ) ជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំង នោះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាល គហបតី ល្អហើយ ៗ ម្នាលគហបតី អ្នកត្រូវផ្ចាញ់ផ្ចាល់មោឃបុរស ទាំងនោះ ឲ្យរៀបរយតាមគន្លងធម៌ សព្វ ៗ កាលយ៉ាងនេះចុះ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ ណែនាំអនាថបិណ្ឌិក-គហបតី ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។

អថខោ អនាថបិណ្ឌិកោ គហបតិ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អចិរបក្កន្តេ អនាថបិណ្ឌិកេ គហបតិម្ហិ ភិក្ខូ អាមន្តេសិ យោបិ ខោ(១) ភិក្ខវេ ភិក្ខុ ទីឃរត្តំ អវេធិធម្មោ(២) ឥមស្មឹ ធម្មវិនយេ សោបិ ឯវមេវំ អញ្ញតិត្ថិយេ បរិព្វាជកេ សហធម្មេន សុនិគ្គហិតំ និគ្គហេយ្យ(៣) យថាតំ អនាថ-បិណ្ឌិកេន គហបតិនា និគ្គហិតាតិ ។

[៩៤] ឯកំ សមយំ ភគវា ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ ។ អថខោ វជ្ជិយមាហិតោ គហបតិ ទិវា ទិវស្ស ចម្បាយ និក្ខមិ ភគវន្តំ ទស្សនាយ ។

---

១ ឱ. ម. សោ ។ ២ ឱ. ម. ភិក្ខុ វស្សសតុបសម្បន្នោតិ ទិស្សន្តិ ។ ៣ ឱ. ម. និគ្គណ្ហេយ្យ ។

លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ ណែនាំឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយហើយ ទើបអនាថបិណ្ឌិកគហបតី ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណរួចចេញទៅ ។ កាលអនាថបិណ្ឌិក-គហបតី ចេញទៅមិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាបួសត្រឹមត្រូវ ក្នុងធម្មវិន័យនេះ អស់កាលយូរ ភិក្ខុនោះ គួរផ្ចាញ់ផ្ចាល់ នូវពួកអន្យតិរ្ថិយបរិព្វាជកឲ្យរៀបរយ តាមគន្លងធម៌ ដូចជាអនាថបិណ្ឌិកគហបតី ផ្ចាញ់ផ្ចាល់យ៉ាងនេះបុះ ។

[៩៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរស្រះបោក្ខរណី ឈ្មោះ គគ្គរា ទៀបក្រុងចម្បា ។ គ្រានោះ វជ្ជិយមាហិតគហ-បតី ចេញអំពីក្រុងចម្បាទៅទាំងថ្ងៃត្រង់ ដើម្បីគាល់ព្រះដ៏មានព្រះភាគ ។

៤១៣



អថខោ វជ្ជិយមាហិតស្ស គហបតិស្ស ឯតទហោសិ អកាលោ ខោ តាវ ភគវន្តំ ទស្សនាយ បដិសល្លីនោ ភគវា មនោភាវនីយានំ[១] ភិក្ខូនំ អកាលោ ទស្សនាយ បដិសល្លីនា មនោភាវនីយា ភិក្ខូ យន្នូនាហំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យន្តិ ។ អថខោ វជ្ជិយមា-ហិតោ គហបតិ យេន អញ្ញតិត្ថិយានំ បរិព្វា-ជកានំ អារាមោ តេនុបសង្កមិ ។ តេន ខោ បន សមយេន អញ្ញតិត្ថិយា បរិព្វាជកា សង្គម្ម សមាគម្ម ឧន្នាទិនោ ឧច្ចាសទ្ទា មហាសទ្ទា អនេកវិហិតំ តិរច្ឆានកថំ កថេន្តា និសិន្នា ហោន្តិ ។ អទ្ទសំសុ ខោ តេ អញ្ញតិត្ថិយា បរិព្វាជកា វជ្ជិយមាហិតំ គហបតឹ ទូរតោ វ អាគច្ឆន្តំ ទិស្វាន អញ្ញមញ្ញំ សណ្ឋាបេសុំ អប្ប-សទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ

១ ឱ. ម. មនោភាវនីយានំបិ ។

លំដាប់នោះ វជ្ជិយមាហិតគហបតី មានសេចក្តីត្រិះរិះ យ៉ាងនេះថា កាលនេះ ជាកាលមិនគួរ ដើម្បីគាល់ព្រះដ៏មានព្រះភាគទេ ដ្បិតព្រះដ៏មានព្រះភាគ កំពុងសម្ងំ កាលនេះ ជាកាលមិនគួរ ដើម្បីឲ្យចួបភិក្ខុទាំងឡាយអ្នកចម្រើនសមាធិចិត្តទេ ដ្បិតភិក្ខុទាំងឡាយ អ្នកចម្រើនសមាធិចិត្ត កំពុងសម្ងំដែរ បើដូច្នោះគួរតែអាត្មាអញ ចូលទៅឯអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជកសិនចុះ ។ លំដាប់នោះ វជ្ជិយមាហិតគហបតីចូលទៅឯអារាម របស់ពួកអន្យតិរ្ថិយបរិព្វាជក ។ សម័យនោះ ពួកអន្យតិរ្ថិយបរិព្វាជក ប្រជុំគ្នា មកជួបជុំ និយាយគ្នាកោកកាក គឹកកង រំពង អង្គុយជជែកគ្នា ពីតិរច្ឆានកថាផ្សេង ៗ ។ អន្យតិរ្ថិយបរិព្វាជកទាំងនោះ បានឃើញវជ្ជិយមាហិតគហបតី កំពុងដើរមកពីចម្ងាយ លុះឃើញហើយ ក៏ឃាត់គ្នីគ្នាថា អ្នកទាំងឡាយ និយាយតិច ៗ អ្នកទាំងឡាយកុំនិយាយខ្លាំង (ព្រោះ)

អយំ វជ្ជិយមាហិតោ គហបតិ អាគច្ឆតិ សមណស្ស គោតមស្ស សាវកោ ។ យាវតា ខោ បន សមណស្ស គោតមស្ស សាវកា គិហី ឱទាតវសនា ចម្បាយំ បដិវសន្តិ អយំ តេសំ អញ្ញតរោ វជ្ជិយមាហិតោ គហបតិ ។ អប្បសទ្ទកាមា ខោ បន តេ អាយស្មន្តោ អប្បសទ្ទវិនីតា អប្បសទ្ទស្ស វណ្ណវាទិនោ អប្បេវ នាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ អថខោ តេ បរិព្វាជកា តុណ្ហី អហេសុំ ។ អថខោ វជ្ជិយមាហិតោ គហបតិ យេន[១] បរិព្វាជកា តេនុបសង្កមិ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វជ្ជិយមាហិតំ គហបតឹ តេ បរិព្វាជកា ឯតទវោចុំ

១ ម. ឯត្តន្តរេ តេតិ បាឋោ ទិស្សតិ ។

វជ្ជិយមាហិតគហបតីនេះ ជាសាវ័កសមណគោតម គាត់មក ។ ពួកគ្រហស្ថអ្នកស្លៀកពាស់ស ជាសាវ័កសមណគោតម ដែលនៅក្នុងក្រុងចម្បាទាំងប៉ុន្មាន បណ្តាគ្រហស្ថជាសាវ័កទាំងនោះ វជ្ជិយមាហិតគហបតីនេះ ជាសាវ័កម្នាក់ដែរ ។ អ្នកដ៏មានអាយុទាំងនោះ ត្រូវការតែសំឡេងតិចហាត់តែសំឡេងតិច និយាយសរសើរតែសំឡេងតិច យើងធ្វើដូចម្តេចឲ្យទាល់តែវជ្ជិយមាហិតគហបតី សម្គាល់បរិសទ្យ មានសំឡេងតិចថាគួរចូលមករក ។ ទើបបរិព្វាជកទាំងនោះ នាំគ្នាស្ងៀម ។ លំដាប់នោះវជ្ជិយមាហិតគហបតី ចូលទៅរកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់ សំណេះសំណាល ជាមួយនឹងអន្យតិរ្ថិយ-បរិព្វាជកទាំងនោះ លុះបង្ហើយពាក្យដែលគួររាក់ទាក់ សំណេះសំណាលគួរឲ្យរលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវជ្ជិយមាហិតគហបតីអង្គុយក្នុងទីសមគួរហើយ បរិព្វាជកទាំងនោះ ក៏និយាយយ៉ាងនេះថា

សច្ចំ កិរ គហបតិ សមណោ គោតមោ សព្វំ តបំ គរហតិ សព្វំ តបស្សឹ លូខាជីវឹ ឯកំសេន ឧបក្កោសតិ ឧបវទតីតិ ។ ន ខោ ភន្តេ ភគវា សព្វំ តបំ គរហតិ នបិ សព្វំ តបស្សឹ លូខាជីវំ ឯកំសេន ឧបក្កោសតិ ឧបវទតិ ។ គារយ្ហំ ខោ ភន្តេ ភគវា គរហតិ បសំសិយំ[១] បសំសតិ គារយ្ហំ ខោ បន ភន្តេ ភគវា គរហន្តោ បសំសិយំ[២] បសំសន្តោ វិភជ្ជវាទី[៣] ភគវា ន សោ ភគវា ឯត្ថ ឯកំសវាទីតិ[៤] ។ ឯវំ វុត្តេ អញ្ញតរោ បរិព្វាជកោ វជ្ជិយមាហិតំ គហបតឹ ឯតទវោច អាគមេហិ ត្វំ គហបតិ យស្ស ត្វំ សមណស្ស គោតមស្ស វណ្ណំ ភាសសិ

---

១-២ ម. បសំសិតព្វំ ។ ៣ ឱ. ម. វិភជ្ជវាទោ ។ ៤ ឱ. ម. ឯកំសវាទោតិ ។

ម្នាលគហបតី ឮថា ព្រះសមណគោតម តែងតិះដៀលតបធម៌ទាំងនោះ ត្មះតិះដៀល បន្តុះបង្អាប់បុគ្គលមានតបៈ រស់នៅដោយសេចក្ដីសៅហ្មងទាំងអស់ តែម្យ៉ាងមែនឬ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ព្រះដ៏មានព្រះភាគ មិនមែនតិះដៀលតបធម៌ទាំងអស់ ទាំងមិនត្មះតិះ-ដៀល បន្តុះបង្អាប់បុគ្គលមានតបៈ រស់នៅដោយសេចក្ដីសៅហ្មងទាំងអស់ តែម្យ៉ាងទេ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ព្រះដ៏មានព្រះភាគ តែងតិះដៀលបុគ្គល ដែលគេគួរតិះដៀល តែងសរសើរបុគ្គលដែលគេគួរសរសើរ បពិត្រលោកដ៏ចម្រើនទាំងឡាយ កាលព្រះដ៏មានព្រះភាគ តិះដៀលបុគ្គល ដែលគេគួរតិះដៀល សរសើរបុគ្គល ដែលគេគួរសរសើរ ព្រះដ៏មានព្រះភាគ ព្រះអង្គសម្ដែងចែករលែក ព្រះដ៏មានព្រះភាគនោះ ព្រះអង្គមិនមែនជាអ្នកសម្ដែងម៉ៅ ក្នុងហេតុនុ៎ះទេ ។ កាលដែលវជ្ជិយមាហិតគហបតី និយាយយ៉ាងនេះហើយ មានបរិព្វា-ជកម្នាក់ និយាយនឹងវជ្ជិយមាហិតគហបតី យ៉ាងនេះថា ម្នាលគហបតី អ្នកចូរបង្អង់សិន អ្នកនិយាយសរសើរគុណ នៃព្រះសមណគោតមណា

សោ សមណោ គោតមោ វេនយិកោ អប្ប-
ញ្ញត្តិកោតិ ។ ឯត្ថចាហំ ភន្តេ អាយស្មន្តេ
វក្ខាមិ សហធម្មេន ឥធំ កុសលន្តិ ភន្តេ ភគវតា
បញ្ញត្តំ ឥធំ អកុសលន្តិ ភន្តេ ភគវតា បញ្ញត្តំ
ឥតិ កុសលាកុសលំ ភគវា បញ្ញាបយមានោ
សប្បញ្ញត្តិកោ[១] ន សោ ភគវា វេនយិកោ
អប្បញ្ញត្តិកោតិ ។ ឯវំ វុត្តេ[២] បរិព្វាជកា
តុណ្ហីភូតា មង្កុភូតា បត្តក្ខន្ធា អធោមុខា បជ្ឈា-
យន្តា អប្បដិភាណា និសីទឹសុ ។ អថខោ
វជ្ជិយមាហិតោ គហបតិ តេ បរិព្វាជកេ
តុណ្ហីភូតេ មង្កុភូតេ បត្តក្ខន្ធេ អធោមុខេ

១ ឱ. ម. ឯត្ថន្តរេ ភគវាតិ បាឋោ ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ តេតិ បាឋោ ទិស្សតិ ។

ព្រះសមណគោតមនោះ ជាអ្នកញុំាងសត្វឲ្យវិនាស ជាអ្នកបញ្ញត្តព្រះនិព្វាន មិនច្បាស់លាស់ ទេតើ ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំសូមនិយាយនឹងពួកលោកដ៏មានអាយុ តាមគន្លងធម៌ ត្រង់រឿងនេះបន្តិច បពិត្រលោកដ៏ចម្រើនទាំងឡាយ (ព្រោះ) ពាក្យនេះ ជាកុសល ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ បពិត្រលោកដ៏ចម្រើនទាំងឡាយ ពាក្យនេះ ជាអកុសល ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ កាលព្រះដ៏មានព្រះភាគ បញ្ញត្តនូវកុសលនិងអកុសល ដោយប្រការដូច្នេះ ឈ្មោះថាជាអ្នកបញ្ញត្តព្រះនិព្វានត្រឹមត្រូវ ព្រះដ៏មានព្រះភាគនោះ មិនមែនជាអ្នកញុំាងសត្វឲ្យវិនាស មិនមែនជាអ្នកបញ្ញត្តព្រះនិព្វាន មិនច្បាស់លាស់ទេ ។ កាលដែលវជ្ជិយមាហិតគហបតី និយាយយ៉ាងនេះហើយ បរិព្វាជកទាំងឡាយ នៅស្ងៀម អៀនខ្មាស ឱនក សំយុងមុខ អង្គុយសញ្ជប់សញ្ជឹង គ្មានបដិភាណ ។ លំដាប់នោះ វជ្ជិយមាហិតគហបតីដឹងថា បរិព្វាជកទាំងនោះ នៅស្ងៀម អៀនខ្មាស ឱនក សំយុងមុខ

បជ្ឈាយន្តេ អប្បដិភាណេ វិទិត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វជ្ជិយមាហិតោ គហបតិ យាវតកោ អហោសិ តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ កថា-សល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ សាធុ សាធុ គហបតិ ឯវំ ខោ តេ គហបតិ មោឃ-បុរិសា កាលេន កាលំ សហធម្មេន សុនិគ្គហិតំ និគ្គហេតព្វា ។ នាហំ គហបតិ សព្វំ តបំ តបិ-តព្វន្តិ វទាមិ ន បនាហំ គហបតិ សព្វំ តបំ ន តបិតព្វន្តិ វទាមិ នាហំ គហបតិ សព្វំ សមាទានំ សមាទិតព្វន្តិ វទាមិ ន បនាហំ គហបតិ សព្វំ សមាទានំ ន សមាទិតព្វន្តិ វទាមិ នាហំ គហបតិ សព្វំ បធានំ បទហិតព្វន្តិ វទាមិ ន បនាហំ គហបតិ សព្វំ បធានំ ន បទហិតព្វន្តិ វទាមិ

សញ្ជប់សញ្ជឹង គ្មានបដិភាណ ហើយក៏ក្រោកចាកអាសនៈចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះវជ្ជិយមាហិតគហបតី អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលការចរចា ទាំងប៉ុន្មាន ដែលខ្លួននិយាយជាមួយនឹងអន្យតិរ្ថិយបរិព្វាជកទាំងឡាយនោះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលគហបតី ល្អហើយ ៗ ម្នាលគហបតី អ្នកត្រូវផ្ចាញ់ផ្ចាល់មោឃបុរសទាំងនោះ ឲ្យរៀបរយ តាមគន្លងធម៌ សព្វ ៗ កាល យ៉ាងនេះចុះ ។ ម្នាលគហបតី តថាគតមិនហៅតបៈ ថាជាធម៌ ដែលគេត្រូវដុតកម្ដៅទាំងអស់ទេ ម្នាលគហបតី តថាគត ក៏មិនហៅតបៈ ថាជាធម៌ ដែលគេមិនត្រូវដុតកម្ដៅទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅការសមាទាន ថាជាកិច្ច ដែលគេត្រូវសមាទានទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅការសមាទាន ថាជាកិច្ច ដែលគេមិនត្រូវសមាទានទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅបធានៈ ថាជាកិច្ច ដែលគេត្រូវតម្កល់ទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅបធានៈ ថាជាកិច្ច ដែលគេមិនត្រូវតម្កល់ទាំងអស់ទេ

ជាហំ គហបតិ សព្វំ បដិនិស្សគ្គំ[១] បដិនិស្សជ្ជិតព្វោតិ វទាមិ ន បជាហំ គហបតិ សព្វំ បដិនិស្សគ្គំ ន បដិនិស្សជ្ជិតព្វោតិ វទាមិ ជាហំ គហបតិ សព្វំ វិមុត្តឹ[២] វិមុច្ចិតព្វាតិ[៣] វទាមិ ន បជាហំ គហបតិ សព្វំ វិមុត្តឹ ន វិមុច្ចិតព្វាតិ វទាមិ យញ្ហិ គហបតិ តបំ តបតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ តបំ ន តបិតព្វន្តិ វទាមិ ។ យញ្ច ខ្វាស្ស គហបតិ តបំ តបតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ តបំ តបិតព្វន្តិ វទាមិ ។ យញ្ហិ គហបតិ សមាទានំ សមាទយតោ[៤] អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ សមាទានំ ន សមាទិតព្វន្តិ វទាមិ ។

១ ឱ. ម. សព្វោ បដិនិស្សគ្គោ ។ ២ ឱ. ម. សព្វា វិមុត្តិ ។ ៣ ម. វិមុញ្ចិតព្វាតិ ។ ៤ ឱ. ម. សមាទិយតោ ។

ម្នាលគហបតី តថាគត មិនហៅបដិនិស្សគ្គៈ ជាជាធម៌ ដែលគេត្រូវលះបង់ទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅបដិនិស្សគ្គៈ ជាជាធម៌ដែលគេមិនត្រូវលះបង់ទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅវិមុត្តិ ជាជាធម្មជាតិ ដែលគេត្រូវរួចស្រឡះទាំងអស់ទេ ម្នាលគហបតី តថាគត មិនហៅវិមុត្តិ ជាជាធម្មជាតិ ដែលគេមិនត្រូវរួចស្រឡះទាំងអស់ទេ ម្នាលគហបតី ព្រោះថា កាលបុគ្គលដុតកម្តៅដោយតបៈណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ ទើបតថាគត ហៅតបៈ មានសភាពយ៉ាងនេះ ជាជាធម៌ ដែលគេមិនត្រូវដុតកម្តៅ ។ ម្នាលគហបតី លុះតែបុគ្គលនោះ ដុតកម្តៅ ដោយតបៈណា អកុសលធម៌ទាំង-ឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង ទើបតថាគត ហៅតបៈ មានសភាពយ៉ាងនេះ ជាជាធម៌ ដែលគេត្រូវដុតកម្តៅ ។ ម្នាលគហបតី កាលបុគ្គលកាន់យក ដោយការសមាទានណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសល-ធម៌ទាំងឡាយ សាបសូន្យទៅ តថាគតហៅ ការសមាទានមានសភាពយ៉ាងនេះ ជាជាកិច្ច ដែលគេមិនត្រូវសមាទាន ។

យញ្ច ខ្វាស្ស គហបតិ សមាចារំ សមាចរតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ សមាចារំ សមាចរិតព្វន្តិ វទាមិ ។ យញ្ហិ គហបតិ បរិយេសនំ បរិយេសតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ បរិយេសនំ ន បរិយេសិតព្វន្តិ វទាមិ ។ យញ្ច ខ្វាស្ស គហបតិ បរិយេសនំ បរិយេសតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ បរិយេសនំ បរិយេសិតព្វន្តិ វទាមិ ។ យញ្ហិ គហបតិ បដិនិស្សគ្គំ បដិនិស្សជ្ជតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ បដិនិស្សគ្គោ ន បដិនិ-ស្សជ្ជិតព្វោតិ វទាមិ ។ យញ្ច ខ្វាស្ស គហបតិ បដិនិស្សគ្គំ បដិនិស្សជ្ជតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ បដិនិស្សគ្គោ បដិនិស្សជ្ជិតព្វោតិ វទាមិ ។

ម្នាលគហបតី លុះតែបុគ្គលនោះ កាន់យក ដោយការសមាទាន ណា អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ ទាំងឡាយ ចម្រើនឡើង តថាគត ហៅការសមាទាន មានសភាពយ៉ាង នេះ ថាជាកិច្ច ដែលគេត្រូវកាន់យក ។ ម្នាលគហបតី កាលបុគ្គល តម្កល់ដោយបធានៈណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសល-ធម៌ទាំងឡាយ សាបសូន្យទៅ តថាគត ហៅបធានៈ មានសភាព យ៉ាងនេះ ថាជាកិច្ច ដែលគេមិនត្រូវតម្កល់ ។ ម្នាលគហបតី លុះ តែបុគ្គលនោះ តម្កល់ ដោយបធានៈណា អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង តថាគត ហៅបធានៈ មានសភាពយ៉ាងនេះ ថាជាកិច្ច ដែលគេត្រូវតម្កល់ ។ ម្នាលគហបតី កាលបុគ្គលលះ ដោយបដិនិស្សគ្គៈណា អកុសលធម៌ទាំងឡាយ ចម្រើន ឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ តថាគត ហៅបដិនិស្សគ្គៈ មានសភាពយ៉ាងនេះ ថាជាធម៌ ដែលគេមិនត្រូវលះ ។ ម្នាលគហ-បតី លុះតែបុគ្គលនោះលះ ដោយបដិនិស្សគ្គៈណា អកុសលធម៌ទាំង-ឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង តថាគត ហៅបដិនិស្សគ្គៈ មានសភាពយ៉ាងនេះ ថាជាធម៌ ដែលគេត្រូវលះ ។

យញ្ហិ គហបតិ វិមុត្តឹ វិមុច្ចតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបា វិមុត្តិ ន វិមុច្ចិតព្វាតិ វទាមិ ។ យញ្ច ខ្វាស្ស គហបតិ វិមុត្តឹ វិមុច្ចតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបា វិមុត្តិ វិមុច្ចិតព្វាតិ វទាមីតិ ។ អថខោ វជ្ជិយមាហិតោ គហបតិ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អចិរបក្កន្តេ វជ្ជិយមាហិតេ គហបតិម្ហិ ភិក្ខូ អាមន្តេសិ យោបិ ខោ[១] ភិក្ខុ ទីឃរត្តំ អប្បរជក្ខោ ឥមស្មឹ ធម្មវិនយេ សោបិ ឯវមេវំ អញ្ញតិត្ថិយេ បរិព្វាជកេ សហធម្មេន សុនិគ្គហិតំ និគ្គហេយ្យ យថាតំ វជ្ជិយមាហិតេន គហបតិនា និគ្គហិតាតិ ។

---

១ ម. សោ ភិក្ខវេ ។ ឱ. សោ ។

ម្នាលគហបតី កាលបុគ្គលរួចស្រឡះ ដោយវិមុត្តិណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ តថាគតហៅវិមុត្តិ មានសភាពយ៉ាងនេះ ថាជាធម្មជាតិ ដែលគេមិនត្រូវរួចស្រឡះ ។ ម្នាលគហបតី លុះតែបុគ្គលនោះ រួចស្រឡះ ដោយវិមុត្តិណា អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង តថាគត ហៅវិមុត្តិ មានសភាពយ៉ាងនេះ ថាជាធម្មជាតិ ដែលគេត្រូវរួចស្រឡះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏វជ្ជិយមាហិតគហបតី ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណ ចៀសចេញទៅ ។ កាលដែលវជ្ជិយមាហិតគហបតី ចៀសចេញទៅ មិនទាន់យូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុណា មានធូលីតិច ក្នុងភ្នែក (មិនសូវជឿងឆ្ងល់) ក្នុងធម្មវិន័យនេះអស់កាលយូរ ភិក្ខុនោះឯង គួរផ្ចាញ់ផ្ចាល់ពួកអន្យតិរ្ថិយបរិព្វាជកឲ្យរៀបរយ តាមគន្លងធម៌ ដូចជា វជ្ជិយមាហិតគហបតី ដែលផ្ចាញ់ផ្ចាល់យ៉ាងនេះបាន ។

[៩៥] អថខោ ឧត្តិយោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧត្តិយោ បរិព្វាជកោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភោ គោតម សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ អព្យាកតំ ខោ ឯតំ ឧត្តិយ មយា សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភោ គោតម អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឯតម្បិ ខោ ឧត្តិយ អព្យាកតំ មយា អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ នុ ខោ ភោ គោតម អន្តវា លោកោ ... អនន្តវា លោកោ ... តំ ជីវំ តំ សរីរំ ... អញ្ញំ ជីវំ អញ្ញំ សរីរំ ... ហោតិ តថាគតោ បរម្មរណា ...

[៩៥] លំដាប់នោះ ឧត្តិយបរិព្វាជក ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់ សំណេះសំណាលជាមួយនឹងព្រះដ៏មានព្រះភាគ លុះបង្ហើយពាក្យ ដែលគួររាក់ទាក់សំណេះសំណាល គួរឲ្យរលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧត្តិយបរិព្វាជក អង្គុយក្នុងទីសមគួរហើយ បានទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ចុះលោកទៀង ពាក្យនេះពិត ពាក្យដទៃ មិនពិតទេឬដូចម្ដេច ។ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា លោកទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតនេះ តថាគត មិនដែលព្យាករទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះលោកមិនទៀង ពាក្យនេះពិត ពាក្យដទៃ មិនពិតទេឬដូចម្ដេច ។ ម្នាលឧត្តិយៈ ពាក្យថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃមិនពិតនេះ តថាគត ក៏មិនដែលព្យាករដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះលោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះគឺសរីរៈនោះ ... ជីវិតដទៃសរីរៈដទៃ ... សត្វស្លាប់ទៅកើតទៀត ... សត្វស្លាប់ទៅមិនកើតទៀត ...

ន ហោតិ តថាគតោ បរម្មរណា... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឯតម្បិ ខោ ឧត្តិយ អព្យាកតំ មយា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ នុ ខោ ភោ គោតម សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥតិ បុដ្ឋោ សមានោ អព្យាកតំ ខោ ឯតំ ឧត្តិយ មយា សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ បន ភោ គោតម អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥតិ បុដ្ឋោ សមានោ ឯតម្បិ ខោ ឧត្តិយ អព្យាកតំ មយា អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ នុ ខោ ភោ គោតម អន្តវា លោកោ... អនន្តវា លោកោ . . . តំ ជីវំ តំ សរីរំ . . .

សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ... សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃមិនពិតទេ ឬដូចម្តេច ។ ម្នាលឧត្តិយៈ ពាក្យថា សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ មិនពិត នេះក៏តថាគត មិនព្យាករដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំសួរថា ចុះលោកនេះទៀង ពាក្យនេះពិត ពាក្យដទៃ មិនពិតទេ ឬដូចម្តេច ដូច្នេះ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា លោកទៀង ពាក្យនេះពិត ពាក្យដទៃ មិនពិតនេះ តថាគត មិនព្យាករទេ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំសួរថា ចុះលោកមិនទៀង ពាក្យនេះពិត ពាក្យដទៃ មិនពិតទេ ឬដូចម្តេច ដូច្នេះ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃ មិនពិតនេះ តថាគត ក៏មិនព្យាករដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំសួរថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះ គឺសរីរៈនោះ ...

៤២៣



អញ្ញំ ជីវំ អញ្ញំ សរីរំ... ហោតិ តថាគតោ បរម្មរណា... ន ហោតិ តថាគតោ បរម្មរណា... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥតិ បុដ្ឋោ សមានោ ឯតម្បិ ខោ ឧត្តិយ អព្យាកតំ មយា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ អថ កិញ្ចរហិ ភោតា គោតមេន ព្យាកតន្តិ ។ អភិញ្ញា[១] ខោ អហំ ឧត្តិយ សាវកានំ ធម្មំ ទេសេមិ សត្តានំ វិសុទ្ធិយា សោក-បរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយាតិ ។ យំ បនេតំ ភវំ គោតមោ អភិញ្ញា[២] សាវកានំ ធម្មំ ទេសេសិ

១-២ ឱ. ម. អភិញ្ញាយ ។

ជីវិតដទៃ សរីរៈដទៃ ... សត្វស្លាប់ទៅកើតទៀត ... សត្វស្លាប់ទៅមិនកើតទៀត ... សត្វស្លាប់ទៅកើតទៀត ក៏មាន មិនកើតទៀត ក៏មាន ... សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ មិនពិតទេ ឬដូចម្តេច ដូច្នេះ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ ពាក្យថា សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃមិនពិតនេះ តថាគត ក៏មិនព្យាករដែរ កាលបើយ៉ាងនេះ ចុះព្រះគោតមដ៏ចម្រើន ទ្រង់ព្យាករដូចម្តេចវិញ ។ ព្រះអង្គត្រាស់ថា ម្នាលឧត្តិយៈ តថាគតដឹងច្បាស់ហើយសម្តែងធម៌ដល់សាវកទាំងឡាយ ដើម្បីបរិសុទ្ធិដល់ពួកសត្វ ដើម្បីកន្លងនូវសោកនិងការខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ ដែលគួរដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ព្រះគោតមដ៏ចម្រើន ដឹងច្បាស់នូវធម៌ណា ហើយសម្តែងធម៌ ដល់ពួកសាវក

សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ សព្វោ វា តេន លោកោ និយ្យាស្សតិ[១] ឧបឌ្ឍោ វា តិភាគោ វា[២] ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ មាហេវ ខោ ឧត្តិយោ បរិព្វាជកោ បាបកំ ទិដ្ឋិគតំ បដិលភិ[៣] សព្វំ សាមុក្កំសិកំ វត មេ សមណោ គោតមោ បញ្ហំ បុដ្ឋោ សំសាទេតិ[៤] នោ វិសជ្ជេតិ នូន ន វិសហតីតិ តនស្ស ឧត្តិយស្ស បរិព្វាជកស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ អថខោ អាយស្មា អានន្ទោ ឧត្តិយំ បរិព្វាជកំ ឯតទវោច តេនហាវុសោ ឧត្តិយ ឧបមន្តេ ករិស្សាមិ ឧបមាយមិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។

---

១ ឱ. និយ្យិស្សតិ ។ ម. និយ្យតិ ។ ២ ឱ. វាតិ ។ ម. វាតិ វទេហិ ។ ៣ ឱ. បដិលភតិ ។ ៤ ម. សំសាវេតិ ។

ដើម្បីបរិសុទ្ធិដល់ពួកសត្វ ដើម្បីកន្លងនូវសោកនិងការខ្សឹកខ្សួល ដើម្បីអស់ទៅ នៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ ដែលគួរដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន បើចុះមានតែព្រះអង្គនឹងជញ្ជូនលោកទាំងមូល ឬលោកពាក់កណ្តាល ឬក៏លោកទាំង ៣ ភាគ យកទៅដោយធម៌នោះ (មិនខាន) ។ កាលដែលឧត្តិយបរិព្វាជក និយាយយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ស្ងៀម ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះ យ៉ាងនេះថា កុំឲ្យឧត្តិយ-បរិព្វាជក បាននូវសេចក្តីយល់ដ៏លាមកថា អាត្មាអញសួរប្រស្នាទាំងអស់ ដែលកើតឡើង ដោយខ្លួនឯង ព្រះសមណគោតមទាល់ មិនឆ្លើយពិតជាឆ្លើយមិនរួច ដូច្នេះឡើយ ការបាននូវសេចក្តីយល់នោះ មិនជាប្រយោជន៍ ជាទុក្ខ ដល់ឧត្តិយបរិព្វាជកនោះ អស់កាលយូរ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ មានថេរវាចាចំពោះឧត្តិយបរិព្វាជក យ៉ាងនេះថា ម្នាលអាវុសោឧត្តិយៈ បើដូច្នោះ មានតែអាត្មានឹងធ្វើសេចក្តីប្រៀបធៀប ឲ្យអ្នកស្តាប់ ដ្បិតពួកវិញ្ញូបុរសខ្លះ ក្នុងលោកនេះ យល់សេចក្តីនៃភាសិតបាន ដោយសារការប្រៀបធៀប ។

សេយ្យថាបិ អាវុសោ ឧត្តិយ រញ្ញោ បច្ចន្តិមំ នគរំ តំ ទឡ្ហទ្ទាលំ[១] ទឡ្ហបាការតោរណំ ឯកទ្វារំ ។ តត្រស្ស ទោវារិកោ បណ្ឌិតោ ព្យត្តោ មេធាវី អញ្ញាតានំ និវារេតា ញាតានំ បវេសេតា សោ តស្ស នគរស្ស សមន្តា[២] អនុបរិយាយបថំ អនុក្កមមានោ ន បស្សេយ្យ បាការសន្ធឹ វា បាការវិវរំ វា អន្តមសោ វិឡារនិស្សក្កនមត្តម្បិ[៣] នោ ច ខ្វាស្ស ឯវំ ញាណំ ហោតិ ឯត្តកា បាណា ឥមំ នគរំ បវិសន្តិ វា និក្ខមន្តិ វាតិ ។ អថ ខ្វាស្ស ឯវមេត្ថ ហោតិ យេ ខោ កេចិ ឱឡារិកា បាណា ឥមំ នគរំ បវិសន្តិ វា និក្ខមន្តិ វា សព្វេ តេ ឥមិនា ទ្វារេន បវិសន្តិ វា និក្ខមន្តិ វាតិ ។ ឯវមេវ ខោ អាវុសោ ឧត្តិយ ន តថាគតស្ស ឯវំ ឧស្សុក្កតំ[៤] ហោតិ

---

១ ឱ. ម. ទឡ្ហុទ្ទាបំ ។ ២ ម. ឯត្ថន្តរេ អនុបរិយាយបថំ អនុក្កមតិ ។ ៣ ម. ពិឡារនិក្ខមនមត្តម្បិ ។ ៤ ម. ឧស្សុក្កំ ។

ម្នាលអាវុសោឧត្តិយៈ ដូចជាបច្ចន្តិមនគររបស់ព្រះរាជា នគរនោះមានប៉មដ៏មាំ មានកំពែងនិងមេទ្វារដ៏មាំ មានទ្វារតែមួយ ។ ត្រង់ទ្វារនៃនគរនោះ មានឆ្មាំទ្វារប៉ិនប្រសប់ ឈ្លៀវឆ្លាស វាងវៃ ឃាត់ពួកជនដែលមិនស្គាល់ បើកឲ្យតែពួកជន ដែលស្គាល់ចូលបាន ឆ្មាំទ្វារនោះ ដើរយាមល្បាត តាមផ្លូវជិតកំពែង ជុំវិញនគរនោះ មិនឃើញទីតនៃកំពែង និងចន្លោះនៃកំពែង ល្មមឲ្យឆ្មាចូលរួច ក៏មិនបានឃើញ ឆ្មាំទ្វារនោះ ថែមទាំងមិនបានដឹងយ៉ាងនេះថា ពួកសត្វតូច ៗ ប៉ុណ្ណេះ ចូលទៅកាន់នគរនេះ ឬចេញពីនគរនេះទេ ។ ឆ្មាំទ្វារនោះ គ្រាន់តែចំណាំ ត្រង់ទ្វារនុ៎ះយ៉ាងនេះថា ពួកសត្វធំ ៗ ណាមួយ ចូលមកកាន់នគរនេះ ឬចេញទៅ ពួកសត្វទាំងអស់នោះ ចូលក្តី ចេញក្តី តាមទ្វារនេះ យ៉ាងណាមិញ ។ ម្នាលអាវុសោឧត្តិយៈ ព្រះតថាគតមិនមានសេចក្តីខ្វល់ខ្វាយ យ៉ាងនេះថា

សព្វោ វា តេន លោកោ និយ្យាស្សតិ ឧបឌ្ឍោ វា តិភាគោ វាតិ ។ អថខោ ឯវមេត្ត តថាគតស្ស ហោតិ យេ ខោ កេចិ លោកម្ហា និយ្យឹសុ វា និយ្យន្តិ វា និយ្យាស្សន្តិ[១] វា សព្វេ តេ បញ្ចនីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា ឯវមេតេ លោកម្ហា និយ្យឹសុ វា និយ្យន្តិ វា និយ្យាស្សន្តិ[១] វាតិ ។ យទេវ ខោ[២] ត្វំ អាវុសោ ឧត្តិយ ភគវន្តំ ឥមំ បញ្ហំ អបុច្ឆិ តទេវេតំ[៣] បញ្ហំ ភគវន្តំ អញ្ញេន បរិយាយេន អបុច្ឆិ តស្មា តេ តំ ភគវា ន ព្យាកាសីតិ ។

---

១ ឱ. ម. និយ្យិស្សន្តិ ។ ២ ម. ក្វេត្ត ។ ៣ ឱ. តទេវ តំ ។

តថាគតនឹងជញ្ជូនលោកទាំងមូល ឬលោកពាក់កណ្តាល ឬក៏លោកទាំង ៣ ភាគ ទៅដោយធម៌នោះទេ ។ ព្រះតថាគតគ្រាន់តែជ្រាបក្នុងហេតុនុ៎ះ យ៉ាងនេះថា តថាគតជញ្ជូនហើយ ឬកំពុងជញ្ជូន ឬក៏នឹងជញ្ជូនពួកសត្វ ណាមួយ ចាកលោកបាន (ទាល់តែ) សត្វទាំងអស់នោះ លះនីវរណធម៌ ទាំង ៥ ប្រការ ជាគ្រឿងសៅហ្មងចិត្ត ដែលធ្វើបញ្ញា ឲ្យមានកម្លាំងថយ តម្កល់ចិត្តស៊ប់ក្នុងសតិប្បដ្ឋាន ៤ ចម្រើនពោជ្ឈង្គ ៧ តាមសេចក្តីពិត ទើបតថាគតជញ្ជូនហើយ ឬកំពុងជញ្ជូន ឬក៏នឹងជញ្ជូនសត្វទាំងនុ៎ះ ចាកលោកយ៉ាងនេះ យ៉ាងនោះដែរ ។ ម្នាលអាវុសោឧត្តិយៈ អ្នកបានសួរប្រស្នាណានឹងព្រះដ៏មានព្រះភាគហើយ អ្នកបានសួរប្រស្នានោះ នឹងព្រះដ៏មានព្រះភាគ ដោយទំនងដទៃ ហេតុនោះ បានជាព្រះដ៏មានព្រះភាគទ្រង់មិនព្យាករប្រស្នានោះ ឲ្យអ្នកស្តាប់ ។

[៩៦] ឯកំ សមយំ អាយស្មា អានន្ទោ[១] រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ យេន តបោទា តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ ។ តបោទាយ[២] គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិ គត្តានិ បុព្វាបយមានោ ។ កោកនុទោបិ ខោ បរិព្វាជកោ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ យេន តបោទា តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ ។ អទ្ទសា[៣] ខោ កោកនុទោ បរិព្វាជកោ អាយស្មន្តំ អានន្ទំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ អានន្ទំ ឯតទវោច ក្វេត្ថ[៤] អាវុសោតិ ។ អហមាវុសោ[៥] ភិក្ខូតិ ។ កតមេ អាវុសោ ភិក្ខូតិ ។ សមណា អាវុសោ សក្យបុត្តិយាតិ[៦] ។ បុច្ឆេយ្យាម មយំ អាយស្មន្តំ កញ្ចិទេវ ទេសំ សចេ អាយស្មា ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។

---

១ ឱ. ម. ឯត្ថន្តរេ រាជគហេ វិហរតិ តបោទារាមេ ។ អថខោ អាយស្មា អានន្ទោតិ អត្ថិ ។ ២ ម. តបោទេ ។ ៣ ម. អទ្ទស ។ ៤ ឱ. ម. ក្វត្ថ ។ ៥ ឱ. អម្ហាវុសោ ។ ៦ ឱ. ម. កតមេសំ ... អាវុសោ ភិក្ខូនន្តិ ។ សមណានំ ... អាវុសោ សក្យបុត្តិយានន្តិ ។

## ៤២៧



[៩៦] សម័យមួយ ព្រះអានន្ទដ៏មានអាយុ ក្រោកឡើងក្នុងបច្ចូស-សម័យនៃរាត្រី ដើរចូលទៅរកស្ទឹងតបោទា ដើម្បីលាបស្រឡាបខ្លួន ។ លុះលាបស្រឡាបខ្លួន ក្នុងស្ទឹងតបោទាហើយ មានចីវរតែមួយឡើងមកឈរសំដិលខ្លួនឲ្យស្ងួតដូចមុន ។ កោកនុទបរិញ្វាជកក្រោកឡើងក្នុងបច្ចូស-សម័យនៃរាត្រី ហើយក៏ចូលទៅរកស្ទឹងតបោទា ដើម្បីលាបស្រឡាបខ្លួនដែរ ។ កោកនុទបរិញ្វាជក បានឃើញព្រះអានន្ទដ៏មានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏សួរព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោ លោកជាអ្វីដែរ ក្នុងពួកសមណៈទាំងនោះ ។ ម្នាលអាវុសោ យើងជាភិក្ខុ ។ ម្នាលអាវុសោ ពួកជនដូចម្តេចដែលហៅថា ភិក្ខុ ។ ម្នាលអាវុសោ ពួកសមណៈជាសក្យបុត្តិយ៍ ។ យើងសូមសួរហេតុណាមួយនឹងលោកដ៏មានអាយុ បើលោកដ៏មានអាយុ ឲ្យឱកាស ដើម្បីឆ្លើយប្រស្នា ។

បុច្ឆាវុសោ សុត្វា វេទិស្សាមាតិ ។ កឹ នុ ខោ ភោ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ[១] ភវន្តិ ។ ន ខោ អហំ អាវុសោ ឯវំទិដ្ឋិកោ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ នុ ខោ[២] ភោ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ ភវន្តិ ។ ន ខោ អហំ អាវុសោ ឯវំទិដ្ឋិកោ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ នុ ខោ ភោ អន្តវា លោកោ... អនន្តវា លោកោ... តំ ជីវំ តំ សរីរំ... អញ្ញំ ជីវំ អញ្ញំ សរីរំ... ហោតិ តថាគតោ បរម្មរណា... ន ហោតិ តថាគតោ បរម្មរណា... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ ភវន្តិ ។

---

១ ឱ. ម. ទិដ្ឋិ ។ ២ ឱ. ម. កឹ បន ។

ម្នាលអាវុសោ អ្នកចូរសួរមកចុះ យើងស្តាប់ហើយនឹងប្រាប់បាន ។ ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិ យ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ ។ ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះទេ ។ ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិ យ៉ាងនេះថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ ។ ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដូច្នេះទេ ។ ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះគឺសរីរៈនោះ ... ជីវិតដទៃ សរីរៈដទៃ ... សត្វស្លាប់ទៅរមែងកើតទៀតក៏មាន ... សត្វស្លាប់ទៅមិនកើតទៀតក៏មាន ... សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ... សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ដែរឬ ។

៤២៩



ន ខោ អហំ អាវុសោ ឯវំទិដ្ឋិកោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តេនហិ ភវំ ន ជានាតិ ន បស្សតីតិ ។ ន ខោ អហំ អាវុសោ ន ជានាមិ ន បស្សាមិ ជានាមហំ អាវុសោ បស្សាមីតិ ។ កឹ នុ ខោ ភោ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ ភវន្តិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ អាវុសោ ឯវំទិដ្ឋិកោ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ នុ ខោ ភោ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ ភវន្តិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ អាវុសោ ឯវំទិដ្ឋិកោ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ នុ ខោ ភោ អន្តវា លោកោ ... អនន្តវា លោកោ ... តំ ជីវំ តំ សរីរំ ...

ម្នាលអាវុសោ យើងមិនមានទិដ្ឋិ យ៉ាងនេះថា សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះទេ ។ បើដូច្នោះ លោកមិនដឹង មិនឃើញទេឬ ។ ម្នាលអាវុសោ យើងមិនមែនមិនដឹង មិនមែន មិនឃើញទេ ម្នាលអាវុសោ យើងដឹង យើងឃើញ ។ កាលខ្ញុំសួរថា ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិ យ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះទេ ។ កាលខ្ញុំសួរថា ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិ យ៉ាងនេះថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដែរឬ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមានទិដ្ឋិ យ៉ាងនេះថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះទេ ។ កាលខ្ញុំសួរដូច្នេះថា ម្នាលលោកដ៏ចម្រើន លោកមានទិដ្ឋិ យ៉ាងនេះថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះគឺសរីរៈនោះ ...

អញ្ញំ ជីវំ អញ្ញំ សរីរំ ... ហោតិ តថាគតោ បរម្មរណា ... ន ហោតិ តថាគតោ បរម្មរណា ... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិកោ ភវន្តិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ អាវុសោ ឯវំទិដ្ឋិកោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ តេនហិ ភវំ ន ជានាតិ ន បស្សតីតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ អាវុសោ ន ជានាមិ ន បស្សាមិ ជានាមហំ អាវុសោ បស្សាមីតិ វទេសិ ។ យថាកថំ បនាវុសោ ឥមស្ស ភាសិតស្ស អត្ថោ ទដ្ឋព្វោតិ ។ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ខោ អាវុសោ ទិដ្ឋិគតមេតំ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ខោ អាវុសោ ទិដ្ឋិគតមេតំ អន្តវា លោកោ... អនន្តវា លោកោ . . . តំ ជីវំ តំ សរីរំ . . .

ជីវិតដទៃ សរីរៈដទៃ ... សត្វស្លាប់ទៅកើតទៀត ក៏មាន ... សត្វស្លាប់ទៅមិនកើតទៀត ក៏មាន ... សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ... សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះដែរឬ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យដូច្នេះទេ ។ កាលខ្ញុំសួរដូច្នេះថា បើដូច្នេះ មានតែលោកមិនដឹង មិនឃើញទេ លោកឆ្លើយថា ម្នាលអាវុសោ យើងមិនមែនមិនដឹង មិនមែនមិនឃើញទេ ម្នាលអាវុសោ យើងដឹង យើងឃើញ ។ ម្នាលអាវុសោ សេចក្តីនៃភាសិតនេះ តើគប្បីយល់ដូចម្តេច ។ ម្នាលអាវុសោ ត្រង់ទិដ្ឋិ (សេចក្តីយល់ឃើញថា) លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ម្នាលអាវុសោ ត្រង់ទិដ្ឋិថា លោកមិនទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ម្នាលអាវុសោ ត្រង់ទិដ្ឋិថា លោកមានទីបំផុត ... លោកមិនមានទីបំផុត ... ជីវិតនោះគឺសរីរៈនោះ ...

អញ្ញំ ជីវំ អញ្ញំ សរីរំ... ហោតិ តថាគតោ បរម្មរណា... ន ហោតិ តថាគតោ បរម្មរណា... ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា... នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃ-មញ្ញន្តិ ខោ អាវុសោ ទិដ្ឋិគតមេតំ ។ យាវតា អាវុសោ ទិដ្ឋិគតា យាវតា ទិដ្ឋិដ្ឋានា អធិដ្ឋានំ បរិយុដ្ឋានំ សមុគ្ឃាតោ[១] តមហំ ជានាមិ តមហំ បស្សាមិ[២] តមហំ ជានន្តោ ជានាមីតិ[៣] តមហំ បស្សន្តោ បស្សាមីតិ[៤] ក្យាហំ វក្ខាមិ ន ជានាមិ ន បស្សាមីតិ ជានាមហំ អាវុសោ បស្សាមីតិ ។ កោ ជាម[៥] អាយស្មា កថញ្ច បជាយស្មន្តំ សព្រហ្មចារី សញ្ជានន្តីតិ[៦] ។ អានន្ទោតិ ខោ មេ អាវុសោ ជាមំ អានន្ទោតិ ច បន មំ សព្រហ្មចារី សញ្ជានន្តីតិ ។

១ ឱ. ទិដ្ឋិដ្ឋានអធិដ្ឋានបរិយុដ្ឋានសមុដ្ឋានសមុគ្ឃាតោ ។ ម. ទិដ្ឋិដ្ឋានំ ទិដ្ឋិអធិដ្ឋានំ ទិដ្ឋិបរិយុដ្ឋានំ ទិដ្ឋិសមុដ្ឋានំ ទិដ្ឋិសមុគ្ឃាតោ ។ ២ ម. បស្សាមីតិ ។ ៣ ឱ. ម. អយំ បាឋោ នត្ថិ ។ ៤ ឱ. ម. អយំ បាឋោ នត្ថិ ។ ៥ ឱ. ម. នាមោ ។ ៦ ឱ. ម. ជានន្តីតិ ។

ជីវិតដទៃ សរីរៈដទៃ ... សត្វស្លាប់ទៅកើតទៀត ក៏មាន ... សត្វស្លាប់ទៅមិនកើតទៀត ក៏មាន ... សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ ... សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យសោះសូន្យ ។ ម្នាលអាវុសោ ទិដ្ឋិទាំងប៉ុន្មាន ហេតុនៃទិដ្ឋិទាំងប៉ុន្មាន ការតាំងនៅនៃទិដ្ឋិ ការរួបរឹតដោយទិដ្ឋិ ការដកឡើងនូវទិដ្ឋិទាំងប៉ុន្មាន យើងដឹងនូវទិដ្ឋិនោះ ឃើញនូវទិដ្ឋិនោះ កាលយើងដឹងនូវទិដ្ឋិនោះ ទើបពោលថា ដឹង កាលឃើញនូវទិដ្ឋិនោះ ទើបពោលថា ឃើញ យើងនឹងពោលថា យើងមិនដឹង មិនឃើញដូចម្ដេចកើត ម្នាលអាវុសោ យើងដឹងមែន ឃើញមែន ។ លោកដ៏មានអាយុ នាមជាអ្វី ពួកសព្រហ្មចារីបុគ្គលស្គាល់លោកដ៏មានអាយុថាដូចម្ដេច ។ ម្នាលអាវុសោ នាមរបស់យើងថា អានន្ទដូច្នេះ ពួកសព្រហ្មចារី ក៏ស្គាល់យើងថាអានន្ទដូច្នេះដែរ ។

មហាចរិយេន កិរ ភោ[១] សទ្ធឹ មន្តយមានា[២] ន ជានិម្ហា[៣] អាយស្មា អានន្ទោតិ ។ សចេ ហិ មយំ សញ្ជានេយ្យាម[៤] អយមាយស្មា អានន្ទោតិ ឯត្តកម្បិ នោ នប្បដិភាសេយ្យ ខមតុ ច មេ អាយស្មា អានន្ទោតិ ។

[៩៧] ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស[៥] ។ កតមេហិ ទសហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរ-សម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមា-ទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិ-កល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា

---

១ ឱ. មហាចរិយេន វត កិរ ភោតា ។ ២ ម. មន្តិយមានា ។ ៣ ឱ. ម. ជានិម្ហ ។ ៤ ម. ជានេយ្យាម ។ ៥ ម. លោកស្សាតិ ។

លោកដ៏ចម្រើន យើងកាលប្រឹក្សាជាមួយនឹងអាចារ្យជាធំ តែមិនដែលស្គាល់ថា អានន្ទដ៏មានអាយុ ដូច្នេះសោះ ។ ពិតណាស់ បើយើងស្គាល់ថា នេះជាព្រះអានន្ទ ដ៏មានអាយុ ដូច្នេះមែន យើងក៏មិនហ៊ានពោលដេញដោលប៉ុណ្ណោះឡើយ សូមព្រះអានន្ទ ដ៏មានអាយុ អត់ទោសដល់ខ្ញុំឲ្យទាន ។

[៩៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប ដោយធម៌ ១០ ប្រការ ជាអ្នកគួរទទួលវត្ថុ ដែលគេនាំមកបូជា គួរទទួលវត្ថុ ដែលគេនាំមកទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ១០ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ ដោយអាចារៈនិងគោចរៈ ឃើញនូវភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូតទ្រទ្រង់នូវសូត្រ ចេះចាំដោយច្បាស់លាស់នូវសូត្រ ធម៌ទាំងឡាយណា ដែលមានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង

សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្ម-
ចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា
ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា
ទិដ្ឋិយា សុប្បដិវិទ្ធា កល្យាណមិត្តោ ហោតិ
កល្យាណសហាយោ កល្យាណសម្បវង្កោ សម្មាទិដ្ឋិ-
កោ ហោតិ សម្មាទស្សនេន សមន្នាគតោ អនេក-
វិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា
ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ
តិរោកុឌ្ឌំ[១] តិរោបាការំ តិរោបព្វតំ អសជ្ជមានោ
គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិ-
ម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ
អភិជ្ជមានេ[២] គច្ឆតិ សេយ្យថាបិ បឋវិយំ
អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី
សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ
ឯវំមហានុភាវេ បាណិនា បរាមសតិ បរិមជ្ជតិ
ព្រហ្មលោកាបិ កាយេន ច វសំ វត្តេតិ

១ ម. តិរោកុដ្ដំ ។ ២ ម. អភិជ្ជមានោ ។

ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ពួកធម៌ ដែលមានសភាពដូច្នោះ ភិក្ខុនោះ បាន រៀនសូត្រច្រើន បានទ្រទ្រង់ ចាំស្ទាត់ រត់មាត់ យល់ច្បាស់ក្នុងចិត្ត ចាក់ធ្លុះល្អដោយទិដ្ឋិ ១ ជាអ្នកមានកល្យាណជន ជាមិត្រ មានកល្យា-ណជន ជាសំឡាញ់ មានកល្យាណជន ជាទីមូលមិត្ត ១ ជាសម្មាទិដ្ឋិ ប្រកបដោយការឃើញត្រូវ ១ រមែងបានឥទ្ធិវិធញ្ញាណ គឺការតាក់តែង ឫទ្ធិបានច្រើនយ៉ាង គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ឬមនុស្ស ច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរទៅកាន់ទីវាលទីខាងក្រៅ ទី ខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ដូចគេ ដើរទៅលើអាកាសក៏បាន ងើបឡើងនិងមុជចុះក្នុងផែនដី ដូចគេងើបមុជ ក្នុងទឹកក៏បាន ដើរទៅក្នុងទឹក ក៏មិនបែកធ្លាយទឹក ដូចគេដើរលើផែនដី ក៏បាន ទៅក្នុងអាកាសទាំងភ្នែន ដូចសកុណជាត ដែលមានស្លាបក៏ បាន យកដៃទៅស្ទាបអង្អែល ចាប់ពាល់នូវព្រះចន្ទនិងព្រះអាទិត្យទាំង នេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ១

ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ... វីតទោសំ វា ចិត្តំ... សមោហំ វា ចិត្តំ... វីតមោហំ វា ចិត្តំ... សង្ខិត្តំ វា ចិត្តំ... វិក្ខិត្តំ វា ចិត្តំ... មហគ្គតំ វា ចិត្តំ... អមហគ្គតំ វា ចិត្តំ... សឧត្តរំ វា ចិត្តំ... អនុត្តរំ វា ចិត្តំ... សមាហិតំ វា ចិត្តំ... អសមាហិតំ វា ចិត្តំ... វិមុត្តំ វា ចិត្តំ... អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ

ឮសំឡេងពីរប្រការបាន គឺសំឡេង ជាទិព្វ និងសំឡេង ជារបស់មនុស្សធម្មតា ក្នុងទីឆ្ងាយក្តី ជិតក្តី ដោយទិព្វសោតធាតុ ដ៏បរិសុទ្ធកន្លងបង់នូវសោតធាតុ ជារបស់មនុស្សធម្មតា ១ កំណត់ដឹងនូវចិត្តនៃសត្វដទៃ បុគ្គលដទៃ ដោយចិត្ត របស់ខ្លួនបាន គឺដឹងច្បាស់ថា ចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី ... ចិត្តប្រាសចាកទោសៈក្តី ... ចិត្តប្រកបដោយមោហៈក្តី ... ចិត្តប្រាសចាកមោហៈក្តី... ចិត្តដែលរួញថយក្តី ... ចិត្តដែលរាយមាយក្តី ... ចិត្តជាមហគ្គតៈក្តី ... ចិត្តមិនមែនជាមហគ្គតៈក្តី ... ចិត្តដែលជាសឧត្តរៈគឺកាមាវចរក្តី ... ចិត្តដែលជាអនុត្តរៈគឺរូបាវចរនិងអរូបាវចរក្តី ... ចិត្តដែលខ្ជាប់ខ្ជួនក្តី ... ចិត្តដែលមិនខ្ជាប់ខ្ជួនក្តី ... ចិត្តដែលរួចស្រឡះក្តី ... ចិត្តដែលមិនទាន់រួចផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ១ រមែងរលឹកនូវខន្ធដែលអាស្រ័យនៅ ក្នុងកាលមុនជាច្រើនប្រការ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ

បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសត-សហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំ-សុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិ-សំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធុ-បបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេ-និវាសំ អនុស្សរតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមា-នុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ

៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១ រយជាតិខ្លះ មួយពាន់ជាតិខ្លះ ១ សែនជាតិខ្លះ អស់សំវដ្តកប្បជាច្រើនខ្លះ អស់វិវដ្តកប្បជាច្រើនខ្លះ អស់សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា អាត្មាអញបានកើត ក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើត ក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ បានមកកើត ក្នុងភពនេះ រមែងរលឹកនូវខន្ធ ដែលអាស្រ័យនៅ ក្នុងកាលមុន ជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ១ មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុ របស់មនុស្សធម្មតា ឃើញនូវសត្វទាំង-ឡាយ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅ តាមកម្ម របស់ខ្លួនថា

សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ

អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ច-រិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើ ជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏តែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក មួយទៀត សត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើ ជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏តែងទៅកើត ក្នុងសុគតិ សួគ៌ទេវលោក មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុ ជារបស់មនុស្សធម្មតា ឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ១

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[៩៨] ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ យស្សំ យស្សំ ទិសាយំ វិហរតិ ផាសុយេវ វិហរតិ ។ កតមេហិ ទសហិ ។ ថេរោ ហោតិ រត្តញ្ញូ ចិរប្បព្វជិតោ សីលវា ហោតិ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា

រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ១០ នេះឯង ទើបជាអ្នកគួរទទួលវត្ថុ ដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេនាំមកទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្ត ដ៏ប្រសើរ របស់សត្វលោក ។

[៩៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ១០ យ៉ាង នៅក្នុងទិសណា ៗ រមែងនៅ ជាសុខសប្បាយ ។ ប្រកបដោយធម៌ទាំង ១០ យ៉ាង តើដូចម្តេចខ្លះ ។ ភិក្ខុជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ ១ ជាអ្នកមានសីល សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ទ្រទ្រង់នូវសូត្រ ចាំស្ទាត់នូវសូត្រ ធម៌ទាំងឡាយណា មានលម្អ បទខាងដើម មានលម្អ បទកណ្តាល មានលម្អ បទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ពួកធម៌ ដែលមានសភាពដូច្នោះ

ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តានិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ អធិករណសមុប្បាទវូបសមកុសលោ ហោតិ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន បាសាទិកោ ហោតិ អភិក្កន្តប្បដិក្កន្តេ[១] សុសំវុតោ អន្តរឃរេ និសជ្ជាយ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

១ ម. អភិក្កន្តបដិក្កន្តោ ។

ភិក្ខុនោះ បានរៀនសូត្រច្រើន បានទ្រទ្រង់ ចាំស្ទាត់រត់មាត់ យល់ច្បាស់ក្នុងចិត្ត ចាក់ធ្លុះល្អដោយទិដ្ឋិ ១ ទាំងបាតិមោក្ខពីរប្រការ ក៏ភិក្ខុនោះចាំស្ទាត់ល្អដោយពិស្តារ ចែករំលែកដោយល្អ ឲ្យប្រព្រឹត្តទៅដោយល្អ វិនិច្ឆ័យដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកឈ្លាសក្នុងការរម្ងាប់អធិករណ៍ដែលកើតឡើង ១ ជាអ្នកប្រាថ្នាធម៌ មានសណ្ដាប់ធ្នាប់គួរជាទីស្រឡាញ់ មានសេចក្ដីត្រេកអរ ដ៏លើសលុប ក្នុងអភិធម្មនិងអភិវិន័យ ១ ជាអ្នកសន្ដោស ដោយចីវរ បិណ្ឌបាត សេនាសនៈគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ១ ជាបុគ្គលគួរជ្រះថ្លាក្នុងការឈានទៅមុខ និងការត្រឡប់ថយក្រោយ ជាអ្នកសង្រួមដោយល្អក្នុងការអង្គុយ សូម្បីក្នុងចន្លោះផ្ទះ ១ ជាអ្នកបានតាមសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ប្រសើរ នៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។

ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ ថេរោ ភិក្ខុ យស្សំ យស្សំ ទិសាយំ វិហរតិ ផាសុយេវ វិហរតីតិ ។

[៩៩] អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ អរញ្ញវនបត្ថានិ[១] បន្តានិ សេនាសនានិ បដិសេវិតុន្តិ ។ ទុរភិសម្ភវានិ ហិ ខោ ឧបាលិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ ទុក្ករំ បវិវេកំ ទុរភិរមំ ឯកត្តេ ហរន្តិ មញ្ញេ មនោ វនានិ សមាធឹ អលភមានស្ស ភិក្ខុនោ ។ យោ ខោ ឧបាលិ ឯវំ វទេយ្យ អហំ សមាធឹ អលភមានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិស្សាមីតិ តស្សេតំ បាដិកង្ខំ សំសីទិស្សតិ វា ឧប្បិលវិស្សតិ[២] វា ។

១ ឱ. អរញ្ញេ វនបត្ថានិ ។ ២ ម. ឧប្លវិស្សតិ វា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ទាំង ១០ យ៉ាង នេះឯង នៅក្នុងទិសណា ៗ រមែងនៅជាសុខសប្បាយ ដោយពិត ។

[៩៩] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ហើយអង្គុយនៅ ក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយនៅ ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានប្រាថ្នា ដើម្បីចូលទៅគប់រកសេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាតនិងព្រៃស្រោង ។ ម្នាលឧបាលិ ពិតណាស់ សេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាតនិងព្រៃស្រោង សុទ្ធតែជាទីកម្រទ្រាំនៅបាន សេចក្តីស្ងប់ស្ងាត់តែម្នាក់ឯងកម្រនឹងធ្វើបាន កម្រនឹងត្រេកអរម្នាក់ឯងបាន ព្រៃទាំងឡាយហាក់ដូចនឹងនាំចិត្តរបស់ភិក្ខុ អ្នកមិនបាននូវសមាធិយកទៅ ។ ម្នាលឧបាលិ បុគ្គលណា ពោលយ៉ាងនេះថា អាត្មាអញ កាលបើមិនបានសមាធិ នឹងចូលទៅអាស្រ័យ គប់រកសេនាសនៈ ដ៏ស្ងាត់ ដែលជាព្រៃស្បាត និងព្រៃស្រោង សេចក្តីប៉ុនប៉ងនុ៎ះ របស់ភិក្ខុនោះនឹងលឹបបាត់ទៅវិញ ឬនឹងរសាត់អណ្តែត បាត់ទៅវិញមិនខាន ។

សេយ្យថាបិ ឧចាលិ មហាឧទករហទោ អថ អាគច្ឆេយ្យ ហត្ថិនាគោ សត្តរតនោ វា អឌ្ឍដ្ឋរតនោ វា តស្ស ឯវមស្ស យន្នូនាហំ ឥមំ ឧទករហទំ ឱគាហេត្វា កណ្ណសន្ធោវិកំបិ ខិឌ្ឌំ(១) កីឡេយ្យំ បិដ្ឋិសន្ធោវិកំបិ ខិឌ្ឌំ កីឡេយ្យំ កណ្ណសន្ធោវិកំបិ ខិឌ្ឌំ កីឡិត្វា(២) បិដ្ឋិសន្ធោវិកំបិ ខិឌ្ឌំ កីឡិត្វា ន្ហាត្វា ច បិវិត្វា ច បច្ចុត្តរិត្វា យេន កាមំ បក្កមេយ្យន្តិ ។ សោ តំ ឧទករហទំ ឱគាហេត្វា កណ្ណសន្ធោវិកំបិ ខិឌ្ឌំ កីឡេយ្យ បិដ្ឋិសន្ធោ-វិកំបិ ខិឌ្ឌំ កីឡេយ្យ កណ្ណសន្ធោវិកំបិ ខិឌ្ឌំ កីឡិត្វា បិដ្ឋិសន្ធោវិកំបិ ខិឌ្ឌំ កីឡិត្វា ន្ហាត្វា ច បិវិត្វា ច បច្ចុត្តរិត្វា យេន កាមំ បក្កមេយ្យ ។ តំ កិស្ស ហេតុ ។ មហា ឧចាលិ(៣) អត្តភាវោ គម្ភីរេ គាធំ វិន្ទតិ អថ អាគច្ឆេយ្យ សសោ វា ពិឡារោ វា

---

១ ឱ. ខិដ្ដំ ។ ២ ម. កីឡេត្វា ។ ៣ ឱ. មហា ហុបាលិ ។

ម្នាលឧបាលិ ដូចជាអន្លង់ទឹកធំ ក្នុងកាលនោះ ដំរីដ៏ប្រសើរមាន កម្ពស់ ៧ ហត្ថ ឬ ៧ ហត្ថកន្លះ គប្បីដើរមក ដំរីនោះមាន គំនិតយ៉ាងនេះថា បើដូច្នោះ មានតែអាត្មាអញ ចុះកាន់អន្លង់ទឹកនេះ លាងស្លឹកត្រចៀកលេងផង លាងខ្នងលេងផង លុះលាងស្លឹក ត្រចៀកលេង លាងខ្នងលេងរួចហើយ ក៏ងូតផង ផឹកផង រួចសិន សឹមឡើងដើរចេញទៅ តាមប្រាថ្នា ។ ដំរីនោះ ក៏ចុះទៅកាន់ អន្លង់ទឹក ហើយលាងស្លឹកត្រចៀកលេងផង លាងខ្នងលេងផង លុះ លាងស្លឹកត្រចៀកលេង លាងខ្នងលេងរួចហើយ ក៏ងូតផង ផឹកផង ហើយឡើងដើរចេញ ទៅ តាមប្រាថ្នា ។ ដំណើរនោះ ព្រោះហេតុ អ្វី ។ ម្នាលឧបាលិ ព្រោះថា អត្តភាព (នៃដំរីនោះ) ធំ តែង បានទូវទីពឹងក្នុងអន្លង់ដ៏ជ្រៅ កាលបើសត្វទន្សាយ ឬសំពោច ដើរមក

តស្ស ឯវមស្ស កោ ចាហំ កោ ច ហត្ថិនាគោ យន្នូនាហំ ឥមំ ឧទករហទំ ឱគាហេត្វា កណ្ណសន្ធោវិកំបិ ខិឌ្ឌំ កីឡេយ្យំ បិដ្ឋិសន្ធោវិកំបិ ខិឌ្ឌំ កីឡេយ្យំ កណ្ណសន្ធោវិកំបិ ខិឌ្ឌំ កីឡិត្វា បិដ្ឋិសន្ធោវិកំបិ ខិឌ្ឌំ កីឡិត្វា ន្ហាត្វា ច បិវិត្វា ច បច្ចុត្តរិត្វា យេន កាមំ បក្កមេយ្យន្តិ ។ សោ តំ ឧទករហទំ សហសា អប្បដិសង្ខាយ[១] តស្សេតំ បាដិកង្ខំ សំសីទិស្សតិ វា ឧប្បិលវិស្សតិ វា ។ តំ កិស្ស ហេតុ ។ បរិត្តោ ឧបាលិ[២] អត្តភាវោ គម្ភីរេ គាធំ ន វិន្ទតិ ។ ឯវមេវ ខោ ឧបាលិ យោ ឯវំ វទេយ្យ អហំ សមាធឹ អលភមានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិស្សាមីតិ តស្សេតំ បាដិកង្ខំ សំសីទិស្សតិ វា ឧប្បិលវិស្សតិ វា ។

---

១ ឱ. អប្បដិសង្ខាយ បក្ខន្ទេយ្យ ។ ម. អប្បដិសង្ខា បក្ខន្ទេយ្យ ។ ២ ឱ. ហុបាលិ ។

ទន្សាយ ឬ សំពោចនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ចុះអញជាអ្វីទៅ ដំរីជាអ្វីទៅ បើដូច្នោះ មានតែអញ ចុះទៅកាន់អន្លង់ទឹកនោះ លាងស្លឹកត្រចៀកលេងផង លាងខ្នងលេងផង លុះលាងស្លឹកត្រចៀកលេង លាងខ្នងលេងរួចហើយ ក៏ងូតផង ផឹកផង រួចសិនសឹមឡើងដើរចេញទៅ តាមប្រាថ្នា ។ សត្វនោះមិនបានពិចារណាអន្លង់ទឹកនោះ ដោយរហ័ស សេចក្តីប៉ុនប៉ងនុ៎ះរបស់សត្វនោះ នឹងលឹបបាត់ទៅវិញ ឬនឹងរសាត់អណ្តែត បាត់ទៅវិញមិនខាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលឧបាលិ ព្រោះថា អត្តភាព វាតូច មិនត្រូវបានទីពឹងក្នុងអន្លង់ដ៏ជ្រៅទេ សេចក្តីនេះ ឧបមាយ៉ាងណា ។ ម្នាលឧបាលិ ឧបមេយ្យដូចជា បុគ្គលណា ពោលយ៉ាងនេះថា អាត្មាអញកាលបើមិនបានសមាធិ នឹងចូលទៅអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ ដែលជាព្រៃស្បាតនិងព្រៃស្រោង សេចក្តីប៉ុនប៉ងនុ៎ះ របស់ភិក្ខុនោះនឹងលឹបបាត់ទៅវិញ ឬ នឹងរសាត់អណ្តែត បាត់ទៅវិញ មិនខាន ។

សេយ្យថាបិ ឧបាលិ ទហរោ កុមារោ មន្ទោ ឧត្តានសេយ្យកោ សកេន មុត្តករីសេន កីឡតិ ។ តំ កឹ មញ្ញសិ ឧបាលិ នន្វាយំ កេវលា បរិបូរា ពាលខិឌ្ឌាតិ[១] ។ ឯវំ ភន្តេ ។ សខោ សោ ឧបាលិ កុមារោ អបរេន សមយេន វុឌ្ឍិមន្វាយ ឥន្ទ្រិយានំ បរិបាកមន្វាយ យានិ តានិ[២] កុមារកានំ កីឡាបនកានិ ភវន្តិ សេយ្យថីទំ វង្កកំ[៣] ឃដិកំ មោក្ខចិកំ បិង្គុលិកំ[៤] បត្តាឡ្ហកំ រថកំ ធនុកំ តេហិ កីឡតិ ។ តំ កឹ មញ្ញសិ ឧបាលិ នន្វាយំ ខិឌ្ឌា[៥] បុរិមាយ ខិឌ្ឌាយ[៦] អភិក្កន្តតរា ច បណីតតរា ចាតិ ។ ឯវំ ភន្តេ ។ សខោ សោ ឧបាលិ កុមារោ អបរេន សមយេន វុឌ្ឍិមន្វាយ

---

១ ម. ពាលកីឡាតិ ។ ២ ម. កានិចិ ។ ៣ ឱ. វង្កំ ។ ៤ ឱ. ចិង្គុលកំ ។ ម. ចិង្គុលកំ ។ ៥ ម. ខិឌ្ឌា ។ ៦ ម. អយំ ន ហោតិ ។

ម្នាលឧបាលិ ឬដូចកុមារក្មេងតូចខ្ចីនៅដេកផ្ងារ តែងលេងមូត្រនិងករីសៈរបស់ខ្លួន ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច ល្បែងនៃក្មេងតូចនេះ ពេញបរិបូណ៌ទាំងអស់ហើយឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ កុមារនោះឯង លុះដល់សម័យខាងក្រោយមក អាស្រ័យនូវសេចក្តីចម្រើន អាស្រ័យនូវសេចក្តីចាស់ក្លា នៃឥន្ទ្រិយទាំងឡាយ ល្បែងណារបស់ពួកកុមារ ល្បែងនោះ គឺលេងនង្គ័លតូច លេងហ៊ឹង លេងដាំដូង លេងកង្ហារ លេងពូនដីខ្សាច់ លេងរទេះតូច លេងធ្នូតូច កុមារនោះ តែងលេងដោយល្បែងទាំងនោះ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច តើល្បែងនេះល្អ ប្រសើរជាងល្បែងពីមុន ហើយឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ កុមារនោះឯង លុះសម័យខាងក្រោយមក អាស្រ័យនូវសេចក្តីចម្រើន

ឥន្ទ្រិយានំ បរិចារកមត្ថាយ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ សោតវិញ្ញេយ្យេហិ សទ្ទេហិ ... ឃានវិញ្ញេយ្យេហិ គន្ធេហិ ... ជិវ្ហាវិញ្ញេយ្យេហិ រសេហិ ... កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូ-បេហិ កាមូបសញ្ហិតេហិ រជនីយេហិ ។ តំ កឹ មញ្ញសិ ឧទាយិ ននាយំ វិជ្ជា បុរិមាហិ វិជ្ជាហិ អភិក្កន្តតរា ច បណីតតរា ចាតិ ។ ឯវំ ភន្តេ ។ ឥធ ខោ បន[១] ឧទាយិ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា[២] ។

១ ឱ. ម. បន រោ ។ ២ ម. ភគវាតិ ។

អាស្រ័យនូវសេចក្តីចាស់ក្លា នៃឥន្ទ្រិយទាំងឡាយ ក៏ឆ្អែតស្កប់ស្កល់ មូលមិត្តមានគេបម្រើ ដោយកាមគុណទាំង ៥ គឺរូប ដែលគប្បីដឹង ដោយចក្ខុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ ១ សំឡេងដែលគប្បីដឹង ដោយត្រចៀក ... ១ ក្លិនដែលគប្បីដឹង ដោយច្រមុះ ... ១ រសដែលគប្បីដឹង ដោយអណ្តាត ... ១ សម្ផស្សដែលគប្បីដឹង ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ១ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច តើល្បែងនេះល្អប្រសើរជាងល្បែងពីមុន ឬមិនមែនទេ ។ មែនហើយព្រះអង្គ ។ ម្នាលឧបាលិ ព្រះតថាគត កើតឡើង ក្នុងលោកនេះ ព្រះតថាគត ឆ្ងាយចាកកិលេស ត្រាស់ដឹងដោយប្រពៃ ដោយខ្លួនឯង បរិបូណ៌ ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ដឹងច្បាស់នូវលោក ជាសារថី អ្នកទូន្មាននូវបុរស មិនមានបុគ្គលណាស្មើ ជាសាស្តា នៃពួកទេវតា និងមនុស្ស ត្រាស់ដឹងនូវសច្ចធម៌ ជាអ្នកចែករលែកនូវព្រះសទ្ធម្ម ។

សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ ។ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ ។ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ ។ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។

ព្រះតថាគតនោះ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្សដ៏សេស ហើយប្រកាសនូវព្រហ្មចរិយធម៌ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ។ ព្រះតថាគតនោះ សម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ។ គហបតី ឬគហបតិបុត្ត ឬក៏ជនដែលកើតក្នុងត្រកូលណាមួយ តែងស្តាប់ធម៌នោះ ។ បុគ្គលនោះ លុះស្តាប់ហើយ រមែងបាននូវសទ្ធាចំពោះព្រះតថាគត ។ បុគ្គលនោះ ប្រកបដោយការបាននូវសទ្ធានេះហើយ រមែងពិចារណាឃើញច្បាស់ថា ឃរាវាស ចង្អៀតចង្អល់ ជាផ្លូវនៃធូលីគឺកិលេស បព្វជ្ជាទើបមានឱកាសល្អ បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ បរិសុទ្ធដោយចំណែកមួយ ឲ្យដូចជាស័ង្ខដែលគេខាត់ហើយទេ បើដូច្នោះ គួរតែអាត្មាអញកោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។

សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្តំ បហាយ មហន្តំ វា ញាតិបរិវដ្តំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។ សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខា-សាជីវសមាបន្នោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វប្បាណភូត-ហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្ន-ប្បាដិកង្ខី អត្ថេនេន សុចិភូតេន អត្តនា វិហរតិ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី[១] វិរតោ មេថុនា គាមធម្មា មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ

១ ម. អនាចារី ។

បុគ្គលនោះ លុះសម័យខាងក្រោយមក ក៏លះបង់គំនរទ្រព្យតិច ឬលះបង់គំនរទ្រព្យច្រើន លះបង់វង្សញាតិតិច ឬលះបង់វង្សញាតិច្រើន ហើយកោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ បុគ្គលនោះកាលបួសយ៉ាងនេះហើយ ក៏បំពេញនូវសិក្ខាសាជីវៈ សម្រាប់ពួកភិក្ខុ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីអៀនខ្មាស ដល់នូវសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សព្វសត្វ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច លះបង់អព្រហ្មចរិយធម៌ ប្រព្រឹត្តតែព្រហ្មចរិយធម៌ ចៀសវាង វៀរចាកមេថុនធម្ម ជាធម៌របស់អ្នកស្រុក លះបង់មុសាវាទ វៀរចាកមុសាវាទ ពោលតែពាក្យពិត ដោយពាក្យពិត

ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ន ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា[១] កណ្ណសុខា បេមនិយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។

១ ឱ. ម. វាចា នេសា ។

ជាអ្នកខ្ជាប់ខ្ជួនដែលគួរអ្នកផងជឿបាន មិនពោលពាក្យបំភ្លាត់សត្វលោក លះបង់បិសុណាវាចា វៀរចាកបិសុណាវាចា មិនស្តាប់ពីនេះទៅប្រាប់ក្នុងទីឯណោះ ដើម្បីបំបែកពួកជនទាំងនេះ ឬឮពាក្យ ក្នុងទីឯណោះ មិនទៅប្រាប់ដល់ពួកជនឯនេះ ដើម្បីបំបែកពួកជនឯណោះ ដូច្នេះ ជាអ្នកផ្សះផ្សាពួកជន ដែលបែកគ្នាហើយ ឲ្យកម្លាំងដល់ពួកជន ដែលព្រមព្រៀងគ្នាហើយ មានសេចក្តីព្រមព្រៀង ជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងការព្រមព្រៀង ពោលវាចាដែលជាគ្រឿងនាំឲ្យព្រមព្រៀងគ្នា លះបង់ផរុសវាចា វៀរចាកផរុសវាចា វាចាណាដែលមិនមានទោស ជាវាចាស្រួលដល់ត្រចៀក ជាពាក្យគួរជាទីស្រឡាញ់ គួរតម្កល់ទុកក្នុងហឫទ័យ ជាសម្តីរបស់អ្នកក្រុង ជាទីត្រេកអរ ដល់ជនច្រើន ជាទីពេញចិត្ត ដល់ជនច្រើន ពោលតែវាចាបែបនោះឯង លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ពោលពាក្យ តាមកាលគួរ ពោលពាក្យពិត ពោលពាក្យប្រកបដោយប្រយោជន៍ ពោលពាក្យប្រកបដោយធម៌ ពោលពាក្យប្រកបដោយវិន័យ ពោលពាក្យដែលគួរតម្កល់ទុក ក្នុងហឫទ័យ ប្រកបដោយគ្រឿងអាងតាមកាលគួរ ជាពាក្យមានកំណត់ ជាពាក្យប្រកបដោយប្រយោជន៍ ។

សោ ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ឯកភត្តិកោ ហោតិ រត្តូបរតោ វិរតោ វិកាលភោជនា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ ហោតិ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ហោតិ ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ ហោតិ អាមកធញ្ញប្បដិគ្គហណា បដិវិរតោ ហោតិ អាមកមំសប្បដិគ្គហណា បដិវិរតោ ហោតិ ឥត្ថីកុមារីបដិគ្គហណា[១] បដិវិរតោ ហោតិ ទាសីទាសប្បដិគ្គហណា បដិវិរតោ ហោតិ អជេឡកប្បដិគ្គហណា បដិវិរតោ ហោតិ កុក្កុដសូករប្បដិគ្គហណា បដិវិរតោ ហោតិ ហត្ថិគវស្សវឡវាបដិគ្គហណា បដិវិរតោ ហោតិ ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ ហោតិ ទូតេយ្យប្បហីនគមនានុយោគា បដិវិរតោ ហោតិ កយវិក្កយា បដិវិរតោ ហោតិ

១ ឱ. ម. ឥត្ថិកុមារិកបដិគ្គហណា ។

ភិក្ខុនោះ វៀរចាកការផ្តាច់ផ្តិលនូវពីជគាម ភូតគាម ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរស្រឡះចាកសេចក្តីត្រេកអរ ក្នុងការបរិភោគ ក្នុងរាត្រី វៀរចាកការបរិភោគ ក្នុងវេលាខុស វៀរចាកការច្រៀងរាំប្រគំនិងមើលនូវល្បែងដែលជាសត្រូវ ដល់កុសលធម៌ វៀរចាកការទ្រទ្រង់និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាបផ្សេង ៗ វៀរចាកទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរចាកការទទួលមាសប្រាក់ វៀរចាកការទទួលធញ្ញជាតិ ស្រូវស្រស់ វៀរចាកការទទួលកាន់យកនូវសាច់ឆៅ វៀរចាកការទទួលស្ត្រី និងកុមារី វៀរចាកការទទួលខ្ញុំស្ត្រីនិងខ្ញុំប្រុស វៀរចាកការទទួលពពែនិងចៀម វៀរចាកការទទួលមាន់និងជ្រូក វៀរចាកការទទួលដំរី គោសេះឈ្មោលនិងសេះញី វៀរចាកការទទួលស្រែនិងចម្ការ វៀរចាកការទទួលប្រកបទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្តាំដល់គ្រហស្ថនិងទៅ ដោយគេបញ្ជូន អំពីផ្ទះ ១ ទៅផ្ទះ ១ វៀរចាកការលក់និងទិញ

តុលាកូដកំសកូដមានកូដា បដិវិរតោ ហោតិ ឧក្កោដនវញ្ចនតិកតិសាវិយោគា[១] បដិវិរតោ ហោតិ ឆេទនវធពន្ធវិបរាមោសអាលោបសាហាសា[២] បដិវិរតោ ហោតិ ។ សោ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ នាម បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោវ ឌេតិ ឯវមេវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។

---

១ ឱ. ឧក្កោដនវញ្ចននិកតិសាចិយោគា ។ ២ ឱ. ឆេទនវធពន្ធនវិបរាមោស អាបសាសេហាសាការា ។ ម. ... សាហាសាការា ។

វៀរចាកការកោងដោយជញ្ជីង ការបន្ទំដោយភាជន៍មាស និងការកោងដោយវង្វាស់វង្វាល់ វៀរចាកអំពើកោងកាច ដោយមួលបង្កាច់បំភាន់ ដោយឧបាយ និងការបន្ទំ ដោយរបស់ប្ញម វៀរចាកការកាត់នូវអវយវៈ មានដៃនិងជើងជាដើម សម្លាប់ ចាប់ ចង ធ្វើឲ្យវង្វេងផ្លូវ ប្លន់អ្នកស្រុក និងកំហែងរឹបយកទ្រព្យគេ ។ ភិក្ខុនោះ ជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ចៀសចេញទៅ ក្នុងទិសណា ៗ តែងកាន់យក (គ្រឿងបរិក្ខារ) តែប៉ុណ្ណោះ ហើយចៀសចេញទៅ ក្នុងទិសនោះ ៗ ។ ដូចសត្វស្លាបហើរទៅ ក្នុងទិសណា ៗ ក៏មានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅ ដូចម្តេចមិញ ភិក្ខុជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ចៀសចេញទៅ ក្នុងទីណា ៗ តែងកាន់យក (គ្រឿងបរិក្ខារ) តែប៉ុណ្ណោះ ចៀសចេញទៅ ដូច្នេះដែរ ។ ភិក្ខុនោះ ប្រកបព្រម ដោយសីលក្ខន្ធដ៏ប្រសើរនេះហើយ រមែងទទួលសេចក្តីសុខ មិនមានទោសខាងក្នុងសន្តាន ។

សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ... ឃានេន គន្ធំ ឃាយិត្វា ... ជិវ្ហាយ រសំ សាយិត្វា ... កាយេន ផោដ្ឋព្វំ ផុសិត្វា ... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។

ភិក្ខុនោះ ឃើញរូបដោយចក្ខុ រមែងមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ ដ៏លាមកទាំងឡាយ គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាម នូវបុគ្គល ដែលជាអ្នកមិនសង្រួមនូវឥន្ទ្រិយ គឺចក្ខុណា ភិក្ខុនោះ ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយ គឺចក្ខុនោះ រក្សាឥន្ទ្រិយ គឺចក្ខុ ដល់នូវការសង្រួម ក្នុងឥន្ទ្រិយ គឺចក្ខុ ។ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... លិទ្ធរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសល-ធម៌ ដ៏លាមកទាំងឡាយគឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវបុគ្គល ដែលជាអ្នកមិនសង្រួមនូវឥន្ទ្រិយ គឺចិត្តណា ភិក្ខុនោះ ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនោះ រក្សាឥន្ទ្រិយ គឺចិត្ត ដល់នូវការសង្រួម ក្នុងឥន្ទ្រិយ គឺចិត្ត ។ ភិក្ខុនោះ ប្រកបដោយសេចក្តីសង្រួមនូវឥន្ទ្រិយ ដ៏ប្រសើរនេះហើយ ទើបទទួលនូវសេចក្តីសុខ ដែលមិនច្រឡំ ដោយកិលេស ក្នុងសន្តាន ។

សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ វិវិត្តំ[១] សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ

១ ម. បវិវិត្តំ ។

ភិក្ខុនោះ កាលឈានទៅមុខ និងត្រឡប់មកខាងក្រោយ ក៏មានសេចក្តីដឹងខ្លួន កាលក្រឡេកមើលទៅមុខ នឹងក្រឡេកមើលទៅទិសផ្សេង ៗ ក៏មានសេចក្តីដឹងខ្លួន កាលបត់ដៃជើង និងលាដៃជើង ក៏មានសេចក្តីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ ក៏មានសេចក្តីដឹងខ្លួន កាលបរិភោគ ផឹក ទំពាស៊ី ជញ្ជាប់ជញ្ជក់ ក៏មានសេចក្តីដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ក៏មានសេចក្តីដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយស្តី ស្ងៀមនៅ ក៏មានសេចក្តីដឹងខ្លួន ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធ ដ៏ប្រសើរនេះផង ប្រកបដោយការសង្រួមឥន្ទ្រិយដ៏ប្រសើរនេះផង ប្រកបដោយសតិនិងសម្បជញ្ញៈ ដ៏ប្រសើរនេះផង រមែងគប់រកសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាល គំនរចំបើង ។ ភិក្ខុនោះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី

ក និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ច-កុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ

អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ ហើយតម្រង់ស្មារតី (ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន) ។ ភិក្ខុនោះ ក៏លះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះបង់ព្យាបាទនិងសេចក្តីប្រទូស្ត មានចិត្តមិនមានព្យាបាទ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ជម្រះចាកព្យាបាទនិងសេចក្តីប្រទូស្ត លះបង់ថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ មានសតិសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មិនមានសេចក្តីរាយមាយ មានចិត្តស្ងប់ខាងក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ឆ្លងចាកវិចិកិច្ឆា មិនមានសេចក្តីសង្ស័យ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តចាកវិចិកិច្ឆា ។ ភិក្ខុនោះ លះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើបញ្ញាឲ្យថយកម្លាំង ហើយស្ងាត់ ចាកកាមទាំងឡាយ ស្ងាត់ ចាកអកុសលធម៌ទាំងឡាយ

សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តំ កឹ មញ្ញសិ ឧបាលិ ឥទ្ធាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ ឧបាលិ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។ បុន ចបរំ ឧបាលិ ភិក្ខុ វិតក្កវិចារានំ វូបសមា... ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តំ កឹ មញ្ញសិ ឧបាលិ ឥទ្ធាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ ឧបាលិ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។ បុន ចបរំ ឧបាលិ ភិក្ខុ បីតិយា ច វិរាគា ...

ក៏បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ ដែលកើត អំពីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេសជាង វិហារធម៌ពីមុន ឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ ទើបអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាតនិងព្រៃស្រោង ដរាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុ ព្រោះរម្ងាប់វិតក្កៈ វិចារៈ ... បានដល់ទុតិយជ្ឈាន ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រ-សើរវិសេស ជាងវិហារធម៌ ក្នុងកាលមុន ឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ក របស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាតនិងព្រៃស្រោង ដរាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុ ព្រោះប្រាសចាកបីតិផង...

## ៤៩៣



តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តំ កឹ មញ្ញសិ ឧបាលិ ជន្វាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ ឧបាលិ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។ បុន ចបរំ ឧបាលិ ភិក្ខុ សុខស្ស ច បហានា ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តំ កឹ មញ្ញសិ ឧបាលិ ជន្វាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។ បុន ចបរំ ឧបាលិ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា

ហើយបានដល់នូវតតិយជ្ឈាន ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេស ជាងពួកវិហារធម៌ក្នុងកាលមុន ឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ ក៏រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាតនិងព្រៃស្រោងជាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ជាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុព្រោះលះបង់នូវសុខផង ... ហើយបានដល់នូវចតុត្ថជ្ឈាន ។ ម្នាលឧបាលិ អ្នកសម្គាល់នូវដំណើរនោះ ដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេស ជាងពួកវិហារធម៌ ក្នុងកាលមុន ឬ ។ ព្រះករុណាព្រះអង្គ ។ ឯពួកសាវ័ក របស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាតនិងព្រៃស្រោងជាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ជាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវរូបសញ្ញា ដោយសព្វគ្រប់ ព្រោះវិនាសទៅនៃបដិឃសញ្ញា

នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ តំ កឹ មញ្ញសិ ឧបាលិ នន្វាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ ឧបាលិ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។ បុន ចបរំ ឧបាលិ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ... សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ... សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម សន្តមេតំ បណីតមេតន្តិ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។

ព្រោះមិនបានធ្វើទុក ក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់នូវអាកាសានញ្ចា-យតនជ្ឈានដោយបរិកម្មថា អាកាសមិនមានទីបំផុត ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេសជាងពួកវិហារធម៌ ក្នុងកាលមុន ឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់គឺព្រៃស្បាតនិងព្រៃស្រោង ដរាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ហើយ បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ... ភិក្ខុ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយសព្វគ្រប់បានដល់អាកិ-ញ្ចញ្ញាយតនជ្ឈានដោយបរិកម្មថា វត្ថុតិចតួចមិនមាន ... ភិក្ខុកន្លងនូវអាកិ-ញ្ចញ្ញាយតនជ្ឈានដោយសព្វគ្រប់ បានដល់នូវនេវសញ្ញានាសញ្ញាយតន-ជ្ឈានដោយបរិកម្មថា គុណជាតនោះស្ងប់ គុណជាតនោះ ប្រសើរ ។

តំ កឹ មញ្ញសិ ឧបាលិ ឆន្ទាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ ឧបាលិ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។ បុន ចបរំ ឧបាលិ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ ។ តំ កឹ មញ្ញសិ ឧបាលិ ឆន្ទាយំ វិហារោ បុរិមេហិ វិហារេហិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឯវំ ភន្តេ ។ ឥមម្បិ ខោ ឧបាលិ មម សាវកា អត្តនិ ធម្មំ សម្បស្សមានា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នោ ច ខោ តាវ អនុប្បត្តសទត្ថា វិហរន្តិ ។

ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច ឯវិហារធម៌នេះ ល្អវិសេស ប្រសើរវិសេស ជាងពួកវិហារធម៌ ក្នុងកាលមុន ឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ ពួកសាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាតនិងព្រៃស្រោង ដរាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍ របស់ខ្លួន ដល់ដោយលំដាប់ ដរាបនោះទេ ។ ម្នាលឧបាលិ មួយទៀត ភិក្ខុកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ បានដល់សញ្ញាវេទ-យិតនិរោធ អាសវៈទាំងឡាយរបស់ភិក្ខុនោះ ក៏អស់ទៅ ព្រោះឃើញច្បាស់ដោយប្រាជ្ញា ។ ម្នាលឧបាលិ អ្នកសម្គាល់ដំណើរនោះ ដូចម្តេច វិហារធម៌នេះ ល្អវិសេស ប្រសើរវិសេស ជាងពួកវិហារធម៌ ក្នុងកាលមុន ឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលឧបាលិ សាវ័ករបស់តថាគត កាលពិចារណាឃើញធម៌នេះ ក្នុងខ្លួនហើយ រមែងអាស្រ័យ គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃស្បាតនិងព្រៃស្រោង ដរាបណា តែថាពួកសាវ័ក មិនមែនសុទ្ធតែមានប្រយោជន៍របស់ខ្លួន ដល់ដោយលំដាប់ ដរាបនោះទេ ។

ឥង្ឃ ត្វំ ឧបាលិ សង្ឃេ វិហរាហិ សង្ឃេ តេ វិហរតោ ផាសុ ភវិស្សតីតិ ។

[១០០] ទសយិមេ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ទស ។ រាគំ ទោសំ មោហំ កោធំ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មានំ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។ ទសយិមេ ភិក្ខវេ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ទស ។ រាគំ ទោសំ មោហំ កោធំ ឧបនាហំ មក្ខំ បឡាសំ ឥស្សំ មច្ឆរិយំ មានំ ។ ឥមេ ខោ ភិក្ខវេ ទស ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។

ឧបាសកវគ្គោ បញ្ចមោ ។

ម្នាលឧបាលិ ណ្ហើយ អ្នកចូរនៅ ក្នុងសង្ឃចុះ កាលបើអ្នកនៅ ក្នុងសង្ឃ សេចក្ដីសុខសប្បាយ នឹងមានប្រាកដ ។

[១០០] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ទាំង ១០ យ៉ាង នេះចេញ មិនគួរ ដើម្បីធ្វើឲ្យច្បាស់ នូវអរហត្តបានទេ ។ ធម៌ ទាំង ១០ យ៉ាងនោះ តើដូចម្ដេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បឡាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ មានៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះបង់នូវធម៌ទាំង ១០ ប្រការនេះឯង មិនគួរធ្វើឲ្យច្បាស់ នូវអរហត្តបានឡើយ ។ ម្នាលភិក្ខុ ទាំងឡាយ បុគ្គលលះបង់នូវធម៌ទាំង ១០ ប្រការនេះ ទើបគួរដើម្បីធ្វើ ឲ្យជាក់ច្បាស់នូវអរហត្ត ។ ធម៌ទាំង ១០ នោះ តើដូចម្ដេចខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ មក្ខៈ ១ បឡាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ មានៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ទាំង ១០ ប្រការនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។

ចប់ ឧបាសកវគ្គ ទី ៥ ។

---

៤៩៧

ទុតិយបណ្ណាសកេ ឧបាសកវគ្គោ

## តស្សុទ្ទានំ

**កាមភោគី វេរំ ទិដ្ឋិ[១] វជ្ជិយឧត្តិយា ឧភោ[១] កោកនុទោ អាហុណិយោ ថេរោ ឧបាលិ អាភព្វោ[៣] ។**

ទុតិយបណ្ណាសកោ ទុតិយោ ។

---

១ ម. ភោគី ភយំ កឹទិដ្ឋិកោ ។ ២ ម. សព្វំ គរហី ឧត្តិយោ ។ ៣ ឱ. ម. អភព្វោតិ ។

ទុតិយបណ្ណាសក ឧបាសកវគ្គ

# ឧទ្ទាននៃឧបាសកវគ្គនោះគឺ

*និយាយអំពីបុគ្គលអ្នកបរិភោគកាម ១ អំពីភ័យ និងពៀរ ៥ យ៉ាង ១ អំពីទិដ្ឋិ ១ អំពីវជ្ជិយមាហិតគហបតី និងឧត្តិយបរិព្វាជកទាំងពីរ អំពីកោកនុទបរិព្វាជក ១ អំពីភិក្ខុអ្នកគួរទទួលគ្រឿងបូជា ១ អំពីភិក្ខុជាថេរៈ ១ អំពីឧបាលិ ដ៏មានអាយុ ១ អំពីបុគ្គល ដែលមិនគួរធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ១ ។*

ចប់ ទុតិយបណ្ណាសក ទី ២ ។

---

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ទសកនិបាតោ

# ឯកាទសមោ ភាគោ

# បឋមបណ្ណាសកោ

## មាតិកា អង្កេ


| | | | |
|---|---|---|---|
| *បឋមបណ្ណាសកេ* | *អានិសំសវគ្គោ* | *បឋមោ* | *១* |
| | *នាថករណវគ្គោ* | *ទុតិយោ* | *៣២* |
| | *មហាវគ្គោ* | *តតិយោ* | *៧៣* |
| | *ឧបាលិវគ្គោ* | *ចតុត្ថោ* | *១៥២* |
| | *អក្កោសវគ្គោ* | *បញ្ចមោ* | *១៦៧* |
| *ទុតិយបណ្ណាសកេ* | *សចិត្តវគ្គោ* | *បឋមោ* | *១៩៩* |
| | *យមកវគ្គោ* | *ទុតិយោ* | *២៤៦* |
| | *អាកង្ខវគ្គោ* | *តតិយោ* | *២៨៨* |
| | *ថេរវគ្គោ* | *ចតុត្ថោ* | *៣២៩* |
| | *ឧបាសកវគ្គោ* | *បញ្ចមោ* | *៣៨៣* |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ទសកនិបាត

# ឯកាទសមភាគ

# បឋមបណ្ណាសក

## មាតិកា លេខទំព័រ


| | | | | |
|---|---|---|---|---|
| *បឋមបណ្ណាសក* | *អានិសំសវគ្គ* | *ទី* | *១* .............................. | *១* |
| | *នាថករណវគ្គ* | *ទី* | *២*.............................. | *៣២* |
| | *មហាវគ្គ* | *ទី* | *៣* ............................ | *៧៣* |
| | *ឧបាលិវគ្គ* | *ទី* | *៤* ............................. | *១៥៤* |
| | *អក្កោសវគ្គ* | *ទី* | *៥* ............................ | *១៦៧* |
| *ទុតិយបណ្ណាសក* | *សចិត្តវគ្គ* | *ទី* | *១* ............................. | *១៩៩* |
| | *យមកវគ្គ* | *ទី* | *២* ............................ | *២៤៦* |
| | *អាកង្ខវគ្គ* | *ទី* | *៣* ........................... | *២៨៨* |
| | *ថេរវគ្គ* | *ទី* | *៤* ............................ | *៣២៩* |
| | *ឧបាសកវគ្គ* | *ទី* | *៥* ............................. | *៣៨៣* |

